# គាថាធម្មបទព្រៃ

♣ ♣ ♣

ប្រែនិងរៀបរៀងដោយ

ភិក្ខុវិនយធរោ មហាយិន-ឡឿន

ផ្សាយជាធម្មទានបេញពី

**វត្តខ្មែរសាន់តាអាណា**

នៅសហរដ្ឋអាមេរិច

លើក ទី៣

*ចំនួន ៥,០០០ ក្បាល*

**រក្សាសិទ្ធិ**

ព. ស. ២៥៥៦

## **សេចក្តីថ្លែងអំណរគុណ**

សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅ បំពោះ **ព្រះភិក្ខុនីសង្ឃវត្តបញ្ញា** ស្ថិតនៅក្នុងសង្កាត់ក្រាំងធ្នង់ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញនិង ពុទ្ធបរិស័ទជនជាតិតៃវ៉ាន់ ដែលបានជួយទទួលបោះពុម្ពសៀវភៅ **គាថាធម្មបទប្រែ** នេះ ដើម្បីចែកផ្សាយជាធម្មទាន ដល់សិក្ខាកាមទាំងឡាយ ។

សូមធម្មទាននេះ បានសម្រេចផល ដល់លោកអ្នកដែលបានចែកឋានទៅហើយ មួយចំណែកផង ។

មួយចំណែកទៀត សូមព្រះភិក្ខុនីសង្ឃ ជនជាតិចិន ដែលមានទីស្នាក់ការ នៅប្រទេសកម្ពុជា និង ពួកពុទ្ធបរិស័ទ ដែលបានជួយឧបត្ថម្ភ ក្នុងធម្មទាននេះ បានសម្រេចប្រយោជន៍ តាមសេចក្តីប្រាថ្នា កុំបីខានឡើយ ។

**ភិក្ខុវិនយធរោ មហាយិន-សឿន**

វត្តខ្មែរសាន់តាអាណា

2630 N. Grand Ave.
Santa Ana, CA 92705
U. S. A

*ថ្ងៃអាទិត្យ ៨ កើត ខែបុស្ស ឆ្នាំថោះ ត្រីស័ក ព.ស. ២៥៥៦*

*ត្រូវនឹងថ្ងៃទី ១៩ ខែមករា គ.ស. ២០១២*

# គាថាធម្មបទប្រែ

សម្រាប់តម្កល់ទុកជាសម្បត្តិសង្ឃ
ក្នុងបណ្ណាល័យ

វត្ត ..............................................................................................
ភូមិ ..............................................................................................
ឃុំ ...............................................................................................
ស្រុក ..........................................................................................
ខេត្ត ............................................................................................
នៅថ្ងៃ ....................................កើត ....... រោច ខែ.....................
ឆ្នាំ ..................................... ព. ស. ២៥៥ ............

អ្នកចែក **ភិក្ខុវិនយធរោ មហាយិន-នឿន**

អ្នកទទួល .................................................



ភិក្ខុវិនយធរោ មហាយិន-ណឿន

*កើតថ្ងៃទី ១០ ខែកក្កដា ១៩៥២*

*នៅភូមិទួលព្រាំ ស្រុកមោងឫស្សី ខេត្តបាត់ដំបង*

♣ ♣

**រូបំ ជីរតិ មច្ចានំ នាមគោត្តំ ន ជីរតិ ។**

រូបកាយ របស់សត្វទាំងឡាយ តែងចាស់គ្រាំគ្រា

បំណែកនាម និង គោត្រ មិនចាស់គ្រាំគ្រាឡើយ ។

# មាតិការឿង

## ភាគ ទី ១

### យមកវគ្គ ទី ១


លេខរៀង ទំព័រ

១- រឿង ព្រះចក្ខុបាលត្ថេរ ..... ១
២- រឿង មដ្ឋកុណ្ឌលី ..... ៤
៣- រឿង ព្រះតិស្សត្ថេរ ..... ៦
៤- រឿង នាងកាលីយក្ខិនី ..... ៨
៥- រឿង ភិក្ខុកោសម្ពី ..... ១០
៦- រឿង ព្រះចុល្លកាល-មហាកាល ..... ១២
៧- រឿង ព្រះទេវទត្ត ..... ១៤
៨- រឿង សញ្ជ័យបរិព្វាជក ..... ១៥
៩- រឿង ព្រះនន្ទត្ថេរ ..... ១៧
១០- រឿង នាយចុន្ទសូករិក ..... ២០
១១- រឿង ធម្មិកឧបាសក ..... ២១
១២- រឿង ភិក្ខុទេវទត្ត ..... ២៣
១៣- រឿង នាងសុមនាទេវី ..... ២៥
១៤- រឿង ទ្វេសហាយកភិក្ខុ ..... ២៧


## ភាគ ទី២

### អប្បមាទវគ្គ ទី ២


១៥- រឿង ព្រះនាងសាមាវតី ..... ៣០
១៦- រឿង កុម្ភឃោសកសេដ្ឋី ..... ៣២

លេខរៀង ទំព័រ

១៧- រឿង ព្រះចូឡបន្ថកត្ថេរ ........ ៣៣
១៨- រឿង ពាលទក្សត្រ ........ ៣៥
១៩- រឿង ព្រះមហាកស្សបត្ថេរ ........ ៣៦
២០- រឿង សហាយកភិក្ខុ ........ ៣៧
២១- រឿង សក្កទេវរាជ ........ ៣៨
២២- រឿង អញ្ញតរភិក្ខុ ........ ៤០
២៣- រឿង ព្រះនិគមតិស្សត្ថេរ ........ ៤១

ចិត្តវគ្គ ទី ៣

២៤- រឿង ព្រះមេឃិយត្ថេរ ........ ៤២
២៥- រឿង អញ្ញតរភិក្ខុ ........ ៤៤
២៦- រឿង ឧកណ្ឋិតភិក្ខុ ........ ៤៥
២៧- រឿង ព្រះភាគិនេយ្យសង្ឃរក្ខិតត្ថេរ ........ ៤៧
២៨- រឿង ព្រះចិត្តហត្ថត្ថេរ ........ ៤៩
២៩- រឿង អារទ្ធវិបស្សកភិក្ខុ ........ ៥១
៣០- រឿង ព្រះបូតិគត្តតិស្សត្ថេរ ........ ៥៣
៣១- រឿង នាយនន្ទគោបាល ........ ៥៥
៣២- រឿង ព្រះសោរេយ្យត្ថេរ ........ ៥៦

**ភាគ ទី៣**

បុប្ផវគ្គ ទី ៤

៣៣- រឿង បឋវីបសុតបញ្ចសតភិក្ខុ ........ ៦០
៣៤- រឿង មរីចិកម្មដ្ឋានិកត្ថេរ ........ ៦១
៣៥- រឿង ព្រះបាទវិឌូឌភៈ ........ ៦២

លេខរៀង ទំព័រ
៣៦- រឿង នាងបដិបូជិកា ..................... ៦៥
៣៧- រឿង មច្ឆរិយកោសិយសេដ្ឋី ..................... ៦៧
៣៨- រឿង បាដិកាជីវក ..................... ៦៨
៣៩- រឿង ចត្តបាណិឧបាសក ..................... ៦៩
៤០- រឿង នាងវិសាខា ..................... ៧១
៤១- រឿង អានន្ទត្ថេរប្បញ្ហា ..................... ៧៣
៤២- រឿង មហាកស្សបបិណ្ឌបាតទាន ..................... ៧៤
៤៣- រឿង គោធិកត្ថេរបរិនិព្វាន ..................... ៧៥
៤៤- រឿង នាយគរហទិន្ន ..................... ៧៦
ពាលវគ្គ ទី ៥
៤៥- រឿង អញ្ញត្របុរស ..................... ៧៩
៤៦- រឿង មហាកស្សបសទ្ធិវិហារិក ..................... ៨១
៤៧- រឿង អានន្ទសេដ្ឋី ..................... ៨៣
៤៨- រឿង គណ្ឋិភេទកចោរ ..................... ៨៥
៤៩- រឿង ព្រះឧទាយិត្ថេរ ..................... ៨៦
៥០- រឿង បាឋេយ្យកភិក្ខុ ..................... ៨៧
៥១- រឿង សុប្បពុទ្ធកុដ្ឋិ ..................... ៨៧
៥២- រឿង នាយកសកៈ ..................... ៨៩
៥៣- រឿង នាយសុមនមាលាការ ..................... ៩០
៥៤- រឿង នាងឧប្បលវណ្ណាថេរី ..................... ៩១
៥៥- រឿង ជម្ពុកាជីវក ..................... ៩២
៥៦- រឿង អហិប្រេត ..................... ៩៤

លេខរៀង ទំព័រ
៥៧- រឿង សង្ខីកូដប្រេត ............................................. ៩៦
៥៨- រឿង ព្រះសុជម្មត្ថេរ ............................................. ៩៨
៥៩- រឿង ព្រះវនវាសីតិស្សត្ថេរ ............................................. ៩៩

## ភាគ ទី៤

### បណ្ឌិតវគ្គ ទី៦

៦០- រឿង ព្រះរាធត្ថេរ ............................................. ១០២
៦១- រឿង អស្សជិបុនព្វសុកភិក្ខុ ............................................. ១០៣
៦២- រឿង ព្រះឆន្នត្ថេរ ............................................. ១០៤
៦៣- រឿង ព្រះមហាកប្បិនត្ថេរ ............................................. ១០៥
៦៤- រឿង បណ្ឌិតសាមណេរ ............................................. ១០៧
៦៥- រឿង ព្រះលកុណ្ឌកភទ្ទិយៈ ............................................. ១១០
៦៦- រឿង មាតានាងកាណា ............................................. ១១១
៦៧- រឿង បញ្ចសតភិក្ខុ ............................................. ១១៣
៦៨- រឿង ព្រះធម្មិកត្ថេរ ............................................. ១១៤
៦៩- រឿង ធម្មស្សវនៈ ............................................. ១១៥
៧០- រឿង អាគន្តុកភិក្ខុៈ ............................................. ១១៦

### អរហន្តវគ្គ ទី៧

៧១- រឿង ហ្មជីវក ............................................. ១១៨
៧២- រឿង ព្រះមហាកស្សបត្ថេរ ............................................. ១១៩
៧៣- រឿង ព្រះពេលដ្ឋសីសត្ថេរ ............................................. ១២០
៧៤- រឿង ព្រះអនុរុទ្ធត្ថេរ ............................................. ១២១
៧៥- រឿង ព្រះមហាកច្ចាយនត្ថេរ ............................................. ១២២

លេខរឿង ទំព័រ
៧៦- រឿង ព្រះសារីបុត្តត្ថេរ ....................................................១២៣
៧៧- រឿង ព្រះកោសម្ពីវាសីតិស្សត្ថេរ .................................. ១២៥
៧៨- រឿង ព្រះសារីបុត្តត្ថេរ .................................................... ១២៦
៧៩- រឿង ព្រះខទិរវនិយរេវតត្ថេរ ......................................... ១២៧
៨០- រឿង អញ្ញត្រិត្ថី ...........................................................១២៩

## សហស្សវគ្គ ទី ៨

៨១- រឿង តម្ពទាឋិកចោរឃាតក: ........................................ ១៣០
៨២- រឿង ព្រះទារុចីរិយត្ថេរ ................................................. ១៣២
៨៣- រឿង នាងកុណ្ឌលកេសីថេរី .......................................... ១៣៣
៨៤- រឿង អនត្ថបុច្ឆកព្រាហ្មណ៍ ............................................ ១៣៨
៨៥- រឿង សារីបុត្តមាតុលព្រាហ្មណ៍ ....................................... ១៣៩
៨៦- រឿង សារីបុត្តភាគិនេយ្យព្រាហ្មណ៍ ................................. ១៤០
៨៧- រឿង សារីបុត្តសហាយព្រាហ្មណ៍ ..................................... ១៤១
៨៨- រឿង អាយុវឌ្ឍនកុមារ ...................................................១៤២
៨៩- រឿង សង្កិច្ចសាមណេរ ................................................... ១៤៣
៩០- រឿង ព្រះខានុកោណ្ឌញ្ញត្ថេរ ......................................... ១៤៦
៩១- រឿង ព្រះសប្បទាសត្ថេរ ............................................... ១៤៧
៩២- រឿង នាងបដាចារាថេរី .................................................១៤៩
៩៣- រឿង នាងកិសាគោតមី ..................................................១៥០
៩៤- រឿង នាងពហុបុត្តិកាថេរី ...............................................១៥២

លេខរឿង ទំព័រ

## ភាគ ទី៥

### បាបវគ្គ ទី៩

៩៥- រឿង ចូឡេកសាដកព្រាហ្មណ៍ ....... ១៥៤
៩៦- រឿង សេយ្យសកភិក្ខុ ....... ១៥៦
៩៧- រឿង នាងលាជទេវធីតា ....... ១៥៧
៩៨- រឿង អនាថបិណ្ឌិកសេដ្ឋី ....... ១៥៨
៩៩- រឿង អសញ្ញតបរិក្ខារភិក្ខុ ....... ១៥៩
១០០- រឿង ពិឡាលបទកសេដ្ឋី ....... ១៦០
១០១- រឿង មហាធនពាណិជ ....... ១៦២
១០២- រឿង នាយព្រានកុក្កុដមិត្រ ....... ១៦៣
១០៣- រឿង នាយកោកសុនខលុទ្ទកៈ ....... ១៦៦
១០៤- រឿង មណីការកុលុបកតិស្សត្ថេរ ....... ១៦៨
១០៥- រឿង ជន ៣ នាក់ ....... ១៧០
១០៦- រឿង សុប្បពុទ្ធសក្កៈ ....... ១៧៣

### ទណ្ឌវគ្គ ទី ១០

១០៧- រឿង ឆព្វគ្គិយភិក្ខុ ....... ១៧៦
១០៨- រឿង ភិក្ខុឆព្វគ្គីយ៍ ....... ១៧៧
១០៩- រឿង សម្ពហុលកុមារ ....... ១៧៧
១១០- រឿង ព្រះកោណ្ឌធានត្ថេរ ....... ១៧៨
១១១- រឿង ឧបោសថកម្ម ....... ១៨០
១១២- រឿង អជគរប្រេត ....... ១៨១

លេខរឿង ទំព័រ

## ភាគ ទី៥

### បាបវគ្គ ទី៩

៩៥- រឿង ចូឡេកសាដកព្រាហ្មណ៍ ..................................... ១៥៤
៩៦- រឿង សេយ្យសកភិក្ខុ ..................................... ១៥៦
៩៧- រឿង នាងលាជទេវធីតា ..................................... ១៥៧
៩៨- រឿង អនាថបិណ្ឌិកសេដ្ឋី ..................................... ១៥៨
៩៩- រឿង អសញ្ញតបរិក្ខារភិក្ខុ ..................................... ១៥៩
១០០- រឿង ពិឡាលបទកសេដ្ឋី ..................................... ១៦០
១០១- រឿង មហាធនពាណិជ ..................................... ១៦២
១០២- រឿង នាយព្រានកុក្កុដមិត្រ ..................................... ១៦៣
១០៣- រឿង នាយកោកសុនខលុទ្ទកៈ ..................................... ១៦៦
១០៤- រឿង មណីការកុលុប្បកតិស្សត្ថេរ ..................................... ១៦៨
១០៥- រឿង ជន ៣ នាក់ ..................................... ១៧០
១០៦- រឿង សុប្បពុទ្ធសក្កៈ ..................................... ១៧៣

### ទណ្ឌវគ្គ ទី ១០

១០៧- រឿង ឆព្វគ្គិយភិក្ខុ ..................................... ១៧៦
១០៨- រឿង ភិក្ខុឆព្វគ្គីយ៍ ..................................... ១៧៧
១០៩- រឿង សម្ពហុលកុមារ ..................................... ១៧៧
១១០- រឿង ព្រះកោណ្ឌធានត្ថេរ ..................................... ១៧៨
១១១- រឿង ឧបោសថកម្ម ..................................... ១៨០
១១២- រឿង អជគរប្រេត ..................................... ១៨១

លេខរៀង ទំព័រ

១៣២- រឿង ភិក្ខុទេវទត្ត ..........២១៤

១៣៣- រឿង ការព្យាយាមបំបែកសង្ឃ ..........២១៥

១៣៤- រឿង ព្រះកាលត្ថេរ ..........២១៦

១៣៥- រឿង ចុឡ្លកាលឧបាសក ..........២១៧

១៣៦- រឿង ព្រះអត្តទត្ថត្ថេរ ..........២១៨

លោកវគ្គ ទី១៣

១៣៧- រឿង ទហរភិក្ខុ ..........២២០

១៣៨- រឿង ព្រះបាទសុទ្ធោទនៈ ..........២២១

១៣៩- រឿង វិបស្សកភិក្ខុ ..........២២៣

១៤០- រឿង អភ័យរាជកុមារ ..........២២៤

១៤១- រឿង ព្រះសម្មជ្ជនត្ថេរ ..........២២៥

១៤២- រឿង ព្រះអង្គុលិមាលត្ថេរ ..........២២៧

១៤៣- រឿង ធីតាជាងតម្បាញ ..........២២៩

១៤៤- រឿង ភិក្ខុ ៣០ រូប ..........២៣១

១៤៥- រឿង នាងចិញ្ចមាណវិកា ..........២៣៣

១៤៦- រឿង អសទិសទាន ..........២៣៤

១៤៧- រឿង នាយកាល ..........២៣៦

ពុទ្ធវគ្គ ទី១៤

១៤៨- រឿង មារធីតា ..........២៣៨

១៤៩- រឿង យមកបាដិហារ្យ ..........២៤១

១៥០- រឿង ឯរកបត្តនាគរាជ ..........២៤៣

១៥១- រឿង អានន្ទត្ថេរប្បញ្ហា ..........២៤៤

លេខរឿង ទំព័រ
១៥២- រឿង អនភិរតភិក្ខុ ..................... ២៤៦
១៥៣- រឿង អគ្គិទត្តបុរោហិត ..................... ២៤៧
១៥៤- រឿង អានន្ទត្ថេរប្បញ្ហា ..................... ២៥០
១៥៥- រឿង សម្ពហុលភិក្ខុ ..................... ២៥១
១៥៦- រឿង កស្សបទសពលសុវណ្ណចេតិយ ..................... ២៥១

សុខវគ្គ ទី ១៥

១៥៧- រឿង ការហាមព្រះញាតិ ..................... ២៥៤
១៥៨- រឿង មារ ..................... ២៥៦
១៥៩- រឿង កោសលរាជបរាជ័យ ..................... ២៥៦
១៦០- រឿង អញ្ញត្រកុលទារិកា ..................... ២៥៧
១៦១- រឿង អញ្ញត្រឧបាសក ..................... ២៥៨
១៦២- រឿង ព្រះបាទបសេនទិកោសល ..................... ២៦០
១៦៣- រឿង ព្រះតិស្សត្ថេរ ..................... ២៦១
១៦៤- រឿង សក្កទេវរាជ ..................... ២៦២

បិយវគ្គ ទី ១៦

១៦៥- រឿង តយោបព្វជិត ..................... ២៦៤
១៦៦- រឿង អញ្ញត្រកុដុម្ពី ..................... ២៦៦
១៦៧- រឿង នាងវិសាខា ..................... ២៦៧
១៦៨- រឿង ក្សត្រលិច្ឆវី ..................... ២៦៨
១៦៩- រឿង អនិត្ថិគន្ធកុមារ ..................... ២៦៨
១៧០- រឿង អញ្ញត្រព្រាហ្មណ៍ ..................... ២៧០
១៧១- រឿង បញ្ចសតទារក ..................... ២៧២

លេខរឿង ទំព័រ
១៧២- រឿង ព្រះអនាគាមិត្ថេរ ..................... ២៧២
១៧៣- រឿង នន្ទិយឧបាសក ..................... ២៧៣

កោធវគ្គ ទី ១៧

១៧៤- រឿង ព្រះនាងរោហិណី ..................... ២៧៥
១៧៥- រឿង អញ្ញតរភិក្ខុ ..................... ២៧៧
១៧៦- រឿង នាងឧត្តរាឧបាសិកា ..................... ២៧៨
១៧៧- រឿង មោគ្គល្លានត្ថេរបញ្ហា ..................... ២៧៩
១៧៨- រឿង ភិក្ខុទូលសួរបញ្ហា ..................... ២៨០
១៧៩- រឿង នាងបុណ្ណទាសី ..................... ២៨២
១៨០- រឿង អតុលឧបាសក ..................... ២៨៤
១៨១- រឿង ភិក្ខុឆព្វគ្គីយ៍ ..................... ២៨៦

**ភាគ ទី៧**

មលវគ្គ ទី ១៨

១៨២- រឿង គោឃាតកបុត្រ ..................... ២៨៨
១៨៣- រឿង អញ្ញតរព្រាហ្មណ៍ ..................... ២៩១
១៨៤- រឿង ព្រះតិស្សត្ថេរ ..................... ២៩១
១៨៥- រឿង ព្រះលោឡុទាយី ..................... ២៩៣
១៨៦- រឿង អញ្ញតរកុលបុត្រ ..................... ២៩៤
១៨៧- រឿង ចូឡសារីភិក្ខុ ..................... ២៩៥
១៨៨- រឿង បញ្ចឧបាសក ..................... ២៩៦
១៨៩- រឿង ភិក្ខុកម្លោះឈ្មោះតិស្សៈ ..................... ២៩៨
១៩០- រឿង បញ្ចឧបាសក ..................... ២៩៩

លេខរៀង ទំព័រ
១៩១- រឿង មេណ្ឌកសេដ្ឋី ....................................................៣០០
១៩២- រឿង ព្រះឧជ្ឈានសញ្ញី ............................................... ៣០១
១៩៣- រឿង សុភទ្ទបរិព្វាជក ................................................ ៣០២
ធម្មដ្ឋវគ្គ ទី ១៩
១៩៤- រឿង វិនិច្ឆយមហាអាមាត្យ ........................................ ៣០៣
១៩៥- រឿង ឆព្វគ្គីយភិក្ខុ ....................................................... ៣០៤
១៩៦- រឿង ឯកុទានត្ថេរ ........................................................៣០៥
១៩៧- រឿង ព្រះលកុណ្ឌកភទ្ទិយៈ ......................................... ៣០៦
១៩៨- រឿង សម្ពហុលភិក្ខុ .....................................................៣០៧
១៩៩- រឿង ហត្ថកភិក្ខុ .......................................................... ៣០៨
២០០- រឿង អញ្ញត្រព្រាហ្មណ៍ ..............................................៣០៩
២០១- រឿង តិរិយ ...................................................................៣១០
២០២- រឿង អរិយពាលិសិតៈ ............................................... ៣១១
២០៣- រឿង សម្ពហុលភិក្ខុ ................................................... ៣១២
មគ្គវគ្គ ទី ២០
២០៤- រឿង បញ្ចសតភិក្ខុ .....................................................៣១៣
២០៥- រឿង អបរបញ្ចសតភិក្ខុ ............................................. ៣១៥
២០៦- រឿង ព្រះបធានកម្មិកតិស្សត្ថេរ ................................. ៣១៦
២០៧- រឿង សូករប្រេត ..........................................................៣១៧
២០៨- រឿង ព្រះបោឋិលត្ថេរ ............................................... ៣១៨
២០៩- រឿង មហាលកភិក្ខុ .....................................................៣២០
២១០- រឿង សទ្ធិវិហារិកព្រះសារីបុត្រ ................................ ៣២១

លេខរៀង ទំព័រ
២១១- រឿង មហាធនពាណិជ ........................................ ៣២២
២១២- រឿង នាងកីសាគោតមី ........................................ ៣២៣
២១៣- រឿង នាងបដាចារាថេរី ........................................ ៣២៤

បកិណ្ណកវគ្គ ទី ២១

២១៤- រឿង បុព្វកម្មរបស់ព្រះអង្គ ........................................ ៣២៥
២១៥- រឿង កុក្កុដណ្ឌខាទិកា ........................................ ៣២៧
២១៦- រឿង ភទ្ទិយភិក្ខុ ........................................ ៣២៧
២១៧- រឿង លកុណ្ឌកភទ្ទិយៈ ........................................ ៣២៨
២១៨- រឿង នាយទារុសាកដិកៈ ........................................ ៣៣០
២១៩- រឿង ភិក្ខុវជ្ជីបុត្រ ........................................ ៣៣៣
២២០- រឿង ចិត្តគហបតី ........................................ ៣៣៤
២២១- រឿង នាងចូឡសុភទ្ទា ........................................ ៣៣៥
២២២- រឿង ព្រះឯកវិហារី ........................................ ៣៣៦

និរយវគ្គ ទី ២២

២២៣- រឿង នាងសុន្ទរី ........................................ ៣៣៧
២២៤- រឿង សត្វត្រូវទុក្ខបៀតបៀន ........................................ ៣៣៨
២២៥- រឿង វគ្គុមុទាតីរិយភិក្ខុ ........................................ ៣៣៩
២២៦- រឿង ខេមកសេដ្ឋីបុត្រ ........................................ ៣៤០
២២៧- រឿង ទុព្វចភិក្ខុ ........................................ ៣៤១
២២៨- រឿង ស្រីអ្នកប្រណែន ........................................ ៣៤៣
២២៩- រឿង អាគន្តុកភិក្ខុ ........................................ ៣៤៤
២៣០- រឿង ពួកនិគ្រន្ថ ........................................ ៣៤៤

លេខរៀង ទំព័រ

២៣១- រឿង តិរិយសាវក ................................................ ៣៤៥

ឆាគវគ្គ ទី ២៣

២៣២- រឿង របស់ព្រះអង្គ ................................................ ៣៤៧
២៣៣- រឿង ហត្ថាចារិយបុព្វកភិក្ខុ ....................................... ៣៤៩
២៣៤- រឿង បុត្រព្រាហ្មណ៍ ៤ នាក់ ..................................... ៣៥០
២៣៥- រឿង ព្រះបាទបសេនទិកោសល ................................ ៣៥៣
២៣៦- រឿង សានុសាមណេរ .............................................. ៣៥៤
២៣៧- រឿង ដំរីបាវេរកៈ ................................................... ៣៥៦
២៣៨- រឿង សម្ពហុលភិក្ខុ ................................................ ៣៥៧
២៣៩- រឿង មារ ............................................................. ៣៥៩

## ភាគ ទី៨

តណ្ហាវគ្គ ទី ២៤

២៤០- រឿង ត្រីឈ្មោះកបិលៈ ........................................... ៣៦២
២៤១- រឿង សុករបោតិកៈ ................................................ ៣៦៤
២៤២- រឿង វិព្ភន្តកភិក្ខុ ................................................ ៣៦៧
២៤៣- រឿង ពន្ធនាគារ .................................................... ៣៦៩
២៤៤- រឿង ព្រះនាងខេមា ................................................ ៣៧១
២៤៥- រឿង ឧគ្គសេនសេដ្ឋីបុត្រ ......................................... ៣៧២
២៤៦- រឿង ចូឡធនុគ្គហបណ្ឌិត ......................................... ៣៧៤
២៤៧- រឿង មារ ............................................................. ៣៧៦
២៤៨- រឿង ឧបកាជីវក ..................................................... ៣៧៧
២៤៩- រឿង សក្កទេវរាជ: ................................................... ៣៧៨

លេខរឿង ទំព័រ

២៥០- រឿង អបុត្តកសេដ្ឋី ........................................ ៣៧៩
២៥១- រឿង អង្កុរទេវបុត្រ ........................................ ៣៨០

ភិក្ខុវគ្គ ទី២៥

២៥២- រឿង បញ្ចភិក្ខុ ........................................ ៣៨២
២៥៣- រឿង ភិក្ខុសម្លាប់ហង្ស ........................................ ៣៨៣
២៥៤- រឿង កោកាលិកភិក្ខុ ........................................ ៣៨៤
២៥៥- រឿង ព្រះធម្មារាមត្ថេរ ........................................ ៣៨៦
២៥៦- រឿង អញ្ញតរវិបក្ខកភិក្ខុ ........................................ ៣៨៧
២៥៧- រឿង បញ្ចគ្គទាយកព្រាហ្មណ៍ ........................................ ៣៨៨
២៥៨- រឿង សម្ពហុលភិក្ខុ ........................................ ៣៩០
២៥៩- រឿង ភិក្ខុ ៥០០ រូប ........................................ ៣៩៤
២៦០- រឿង ព្រះសន្តកាយត្ថេរ ........................................ ៣៩៥
២៦១- រឿង ព្រះនង្គលកូដត្ថេរ ........................................ ៣៩៦
២៦២- រឿង ព្រះវក្កលិត្ថេរ ........................................ ៣៩៨
២៦៣- រឿង សុមនសាមណេរ ........................................ ៣៩៩

ព្រាហ្មណវគ្គ ទី២៦

២៦៤- រឿង បសាទពហុលព្រាហ្មណ៍ ........................................ ៤០១
២៦៥- រឿង សម្ពហុលភិក្ខុ ........................................ ៤០២
២៦៦- រឿង មារ ........................................ ៤០៣
២៦៧- រឿង អញ្ញតរព្រាហ្មណ៍ ........................................ ៤០៤
២៦៨- រឿង ព្រះអានន្ទ ........................................ ៤០៤
២៦៩- រឿង អញ្ញតរបព្វជិត ........................................ ៤០៥

លេខរៀង ទំព័រ
២៧០- រឿង ព្រះសារីបុត្រ ...............................................៤០៦
២៧១- រឿង ព្រះនាងបជាបតិគោតមី ...................................៤០៨
២៧២- រឿង ព្រះសារីបុត្រ ...............................................៤០៩
២៧៣- រឿង ជដិលព្រាហ្មណ៍ ..........................................៤១០
២៧៤- រឿង ព្រាហ្មណ៍កុហក .......................................... ៤១០
២៧៥- រឿង នាងកិសាគោតមី .........................................៤១២
២៧៦- រឿង អញ្ញត្រព្រាហ្មណ៍ .........................................៤១៣
២៧៧- រឿង ឧគ្គសេន ....................................................៤១៤
២៧៨- រឿង ព្រាហ្មណ៍ពីរនាក់ .........................................៤១៥
២៧៩- រឿង អក្កោសកភារទ្វាជព្រាហ្មណ៍ ...........................៤១៦
២៨០- រឿង ព្រះសារីបុត្រ ...............................................៤១៧
២៨១- រឿង នាងឧប្បលវណ្ណាថេរី ....................................៤១៩
២៨២- រឿង អញ្ញត្រព្រាហ្មណ៍ .........................................៤១៩
២៨៣- រឿង នាងខេមាភិក្ខុនី ........................................... ៤២១
២៨៤- រឿង ព្រះបព្ភារវាសីតិស្សត្ថេរ ..................................៤២១
២៨៥- រឿង អញ្ញត្រភិក្ខុ ................................................៤២៣
២៨៦- រឿង សាមណេរ ៤ រូប ........................................ ៤២៥
២៨៧- រឿង ព្រះមហាបន្ថកត្ថេរ .......................................៤២៨
២៨៨- រឿង ព្រះបិលិន្ទវច្ឆត្ថេរ ..........................................៤២៩
២៨៩- រឿង អញ្ញត្រភិក្ខុ ................................................៤៣០
២៩០- រឿង ព្រះសារីបុត្រ ...............................................៤៣១
២៩១- រឿង ព្រះមហាមោគ្គល្លានត្ថេរ ...................................៤៣២

លេខរឿង ទំព័រ

២៩២- រឿង ព្រះរេវតត្ថេរ ......................................................................៤៣២
២៩៣- រឿង ព្រះចន្ទាភត្ថេរ ......................................................................៤៣៣
២៩៤- រឿង ព្រះសីវលី ..............................................................................៤៣៦
២៩៥- រឿង ព្រះសុន្ទរសមុទ្ទ ....................................................................៤៣៧
២៩៦- រឿង ព្រះជោដិកត្ថេរ ....................................................................៤៣៩
២៩៧- រឿង ព្រះបឋមនដបុត្តកត្ថេរ ..........................................................៤៤៣
២៩៨- រឿង ព្រះទុតិយនដបុត្តកត្ថេរ ........................................................ ៤៤៤
២៩៩- រឿង ព្រះវង្គីសត្ថេរ ......................................................................៤៤៤
៣០០- រឿង នាងធម្មទិន្នាថេរី ..................................................................៤៤៨
៣០១- រឿង ព្រះអង្គុលិមាលត្ថេរ ..............................................................៤៤៩
៣០២- រឿង ទេវហិតព្រាហ្មណ៍ ..................................................................៤៥០
ឧទាន នៃគាថាធម្មបទ ...........................................................................៤៥២

# គាថាធម្មបទប្រែ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

## ភាគ ទី ១

## យមកវគ្គ ទី ១

### ១- រឿង ព្រះចក្ខុបាលត្ថេរ

*ព្រះបរមសាស្ដាទ្រង់ទេសនាប្រារព្ធព្រះថេរៈ ឈ្មោះចក្ខុបាល។ កាលពីព្រះថេរៈអង្គនេះ លោកនៅជាគ្រហស្ថ មិនទាន់បានសាងផ្នួសនោះ លោកបានទៅស្ដាប់នូវព្រះធម៌ទេសនា របស់ព្រះពុទ្ធជាម្ចាស់ហើយ កើតសេចក្ដីជ្រះថ្លា ក្នុងព្រះធម៌ទេសនានោះ យ៉ាងក្រៃលែង មានចិត្តប្រាថ្នាចង់បួសជាភិក្ខុ ក្នុងព្រះពុទ្ធសាសនា លុះត្រឡប់មកផ្ទះវិញ ក៏បានប្រគល់ទ្រព្យសម្បត្តិទាំងអស់ ឲ្យដល់ប្អូនប្រុស របស់ខ្លួនស្រេចហើយ ទើបសុំលាប្អូនទៅបួស ក្នុងសំណាក់ព្រះបរមសាស្ដា លុះបួសបាន ៥ ព្រះវស្សាហើយ លោកក៏បានចូលទៅ ក្រាបថ្វាយបង្គំសុំរៀនព្រះកម្មដ្ឋាន ជាមួយនឹងព្រះសម្មាសម្ពុទ្ធ បន្ទាប់មក ក៏បានក្រាបថ្វាយបង្គំលាព្រះអង្គទៅ បំពេញសមណធម៌ នៅក្នុងទីកន្លែងមួយដ៏ស្ងាត់ ព្រមជាមួយនឹងភិក្ខុសង្ឃ ៦០ រូប ជាបរិវារ ។ ព្រះថេរៈលោកមានសេចក្ដីព្យាយាម យ៉ាងខ្លាំងក្លាបំផុត ក្នុងការប្រតិបត្តិធម៌ លោកបានតាំងចិត្ត សច្ចាធិដ្ឋានថា "អាត្មាអញ នឹងមិនសិង របូត ៣ ខែ នៅក្នុងវជូវក្សៀងនេះ" ។*

## រឿង ព្រះចក្ខុបាលត្ថេរ

ក្នុងវស្សានោះ រោគក្នុងភ្នែក ក៏បានកើតឡើង ដល់ព្រះថេរៈ ។ គ្រូពេទ្យ បានមកជួយព្យាបាលរោគប្រគេនព្រះថេរៈ ហើយឲ្យព្រះថេរៈសិងបន្តក់ថ្នាំតាមភ្នែក ។ តែព្រះថេរៈ មិនព្រមសិងបន្តក់ថ្នាំ តាមលោកគ្រូពេទ្យប្រាប់សោះ ព្រោះលោកបានតាំងចិត្តស្រេចហើយ ថានឹងមិនសិង រហូត ៣ ខែ ។ ព្រោះហេតុនោះ រោគក្នុងភ្នែក ក៏រឹងរឹតតែរកាំធ្ងន់ខ្លាំងឡើងៗ ជារៀងរាល់ថ្ងៃ ។ មិនយូរប៉ុន្មាន ភ្នែក ទាំងទ្វេរបស់ព្រះថេរៈ ក៏បានបែកធ្លាយ ខ្វាក់ងងឹតឈឹង មើលអ្វីលែងឃើញទាំងអស់ហើយ ព្រមគ្នាជាមួយនឹងការបានសម្រេចជាព្រះអរហន្ត-សុក្ខវិបស្សកៈ ។

លុះដល់ថ្ងៃបវារណា ចេញវស្សាហើយ ព្រះចក្ខុបាលត្ថេរ បានចំរើនពរ លាពួកញាតិញោម ឧបាសក ឧបាសិកា ដើម្បីនឹងទៅគាល់ព្រះបរមសាស្ដា ដែលព្រះអង្គប្រថាប់គង់នៅ ក្នុងវត្តជេតពនមហា-វិហារ ទៀបក្រុងសាវត្ថី ។

នៅក្នុងរាត្រី នៃបច្ឆិមយាម ក្រោយពេលដែលភ្លៀងរាំងហើយ, ព្រះថេរៈ បានដើរចង្ក្រមទៅមកៗ ជាន់សត្វមេភ្លៀងស្លាប់អស់ ជាច្រើន ព្រោះលោកមើលមិនឃើញ ហើយក៏មិនមានចេតនាគិតនឹងធ្វើឲ្យសត្វមេភ្លៀងទាំងនោះស្លាប់ផងដែរ ។

ស្អែកឡើង ពេលព្រឹកព្រលឹម ក៏ស្រាប់តែមានអាគន្តុកភិក្ខុ ជាច្រើនរូប បានចូលទៅមើលកន្លែងព្រះចក្ខុបាលត្ថេរ ហើយបានឃើញសត្វមេភ្លៀង ជាច្រើនស្លាប់ ពាសពេញទីចង្ក្រមន៍ របស់ព្រះថេរៈ ក៏

បានត្អូញតិះដៀលលោក ដោយប្រការផ្សេងៗ ស្រេចហើយ ក៏នាំយករឿងនេះ ទៅក្រាបទូលថ្វាយ ដល់ព្រះបរមសាស្ដាទ្រង់ជ្រាប ។

ព្រះបរមសាស្ដាទ្រង់ត្រាស់ពន្យល់ដល់ភិក្ខុទាំងនោះថា "ម្នាលភិក្ខុទាំងឡាយ មរណចេតនា គឺ ចេតនាគិតនឹងសម្លាប់ មិនមានសោះឡើយ ដល់ព្រះថេរៈ ដែលជាព្រះអរហន្តខីណាស្រព" ។

អាគន្តុកភិក្ខុទាំងនោះ ងឿងឆ្ងល់ បានក្រាបទូលសួរព្រះពុទ្ធជាម្ចាស់ថា "បពិត្រព្រះអង្គដ៏ចំរើន ព្រះចក្ខុបាលត្ថេរ ជាព្រះអរហន្តខីណាស្រព ចុះហេតុអ្វី បានជាខ្វាក់ភ្នែក?" ។

ព្រះសាស្ដា ទ្រង់ត្រាស់សំដែងអតីតនិទាន ថា "កាលពីអតីតកាល ព្រះចក្ខុបាលត្ថេរ ធ្លាប់បានធ្វើជាគ្រូពេទ្យ ព្យាបាលជម្ងឺភ្នែក ។ សម័យថ្ងៃមួយ លោកគ្រូពេទ្យនោះ បានទៅព្យាបាលភ្នែក ដល់ស្ត្រីម្នាក់នៅជនបទ ។ ស្ត្រីនោះ បានសន្យាជាមួយគ្រូពេទ្យថា "បើលោកគ្រូពេទ្យអាចព្យាបាលជម្ងឺភ្នែកនាងខ្ញុំ ឲ្យបានជាស្បើយ ដូចដើមវិញនោះ, នាងខ្ញុំ ព្រមទាំងបុត្រ នឹងធ្វើជាទាសីអ្នកបំរើរបស់លោកគ្រូ" ។

គ្រូពេទ្យនោះ បានព្យាបាលភ្នែកនាង ឲ្យជាដូចដើមវិញហើយ, ព្រោះតែនាងមិនចង់ទៅ នៅបំរើគ្រូពេទ្យនោះឯង ទើបនាងបែរជានិយាយកុហកគ្រូពេទ្យនោះថា "លោកគ្រូ ឥឡូវនេះ ភ្នែករបស់នាងខ្ញុំ វាមិនបានជាទេ វារឹតតែឈឺលើសដើមទៅទៀត" ។

ចំណែកគ្រូពេទ្យ បានដឹងថា នាងពិតជានិយាយកុហក ដូច្នេះហើយ ក៏មានចិត្តក្រោធខឹងយ៉ាងខ្លាំង ហើយមានចេតនា ចង់ធ្វើឲ្យ

នាងវិនាស ទើបផ្សំថ្នាំពិសឲ្យនាងលាប ធ្វើឲ្យភ្នែករបស់នាង ខ្វាក់ទាំងគូ មើលអ្វីលែងឃើញទាំងអស់ ។ ព្រោះបាបកម្មដែលព្រះចក្ខុបាលត្ថេរ បានធ្វើឲ្យស្ត្រីនោះខ្វាក់ភ្នែកទាំងទ្វេ ដោយចេតនានោះឯង បានជាព្រះថេរៈ ត្រូវតែទទួលនូវបាបកម្មនោះវិញ គឺ ត្រូវតែខ្វាក់ភ្នែកនៅក្នុងជាតិនេះ" ដូច្នេះហើយ ទើបទ្រង់ត្រាស់នូវព្រះគាថានេះថា ៖

**មនោបុព្វង្គមា ធម្មា　មនោសេដ្ឋា មនោមយា**
**មនសា ចេ បទុដ្ឋេន　ភាសតិ វា ករោតិ វា**
**តតោ នំ ទុក្ខមន្វេតិ　ចក្កំវ វហតោ បទំ ។**

ធម៌ទាំងឡាយ មានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត សម្រេចមកអំពីចិត្ត, បើបុគ្គលមានចិត្ត ត្រូវទោសៈប្រទូសរ៉ាយហើយ ទោះបីនិយាយក្តី ធ្វើក្តី ក៏អាក្រក់ដែរ, ព្រោះអំពើអាក្រក់នោះឯង សេចក្តីទុក្ខ រមែងដេញជាប់ តាមក្រោយបុគ្គលនោះ ដូចជាកង់រទេះ វិលតាមជាន់ជើងគោដែលអូសទីមរទេះ យ៉ាងដូច្នោះឯង ។

## ២- រឿង មដ្ឋកុណ្ឌលី

ព្រះបរមសាស្តា ទ្រង់បានប្រារព្ធនូវមដ្ឋកុណ្ឌលី ដែលជាកូនរបស់ព្រាហ្មណ៍កំណាញ់ម្នាក់ នៅក្នុងក្រុងសាវត្ថី ។ ព្រោះព្រាហ្មណ៍ជាបិតាជាមនុស្សកំណាញ់ស្វិត ទើបគាត់ធ្វើទំហ៊ូដោយខ្លួនឯង ឲ្យកូនពាក់ ។ នៅពេលដែលមដ្ឋកុណ្ឌលីឈឺធ្ងន់, ព្រាហ្មណ៍ ជាបិតា មិនបានទៅរកគ្រូពេទ្យ មកព្យាបាលជម្ងឺឲ្យកូនគាត់ទេ ព្រោះគាត់ខ្លាច

អស់ព្រទ្យសម្បត្តិរបស់ខ្លួន ។ នៅថ្ងៃដែលមដ្ឋកុណ្ឌលីជិតនឹងមរណា នោះ ព្រាហ្មណ៍ជាបិតា បានលើកកូនមកឲ្យដេក អស់សេចក្តីសង្ឃឹម តែម្នាក់ឯង នៅរបៀងផ្ទះខាងក្រៅ ។

សម័យនោះ ព្រះសាស្តា ទ្រង់បានបញ្ចេញព្រះរស្មីទៅ ដើម្បីឲ្យមដ្ឋកុណ្ឌលីបានឃើញ ។ មដ្ឋកុណ្ឌលី ឃើញព្រះរស្មីនៃព្រះអង្គហើយ ក៏កើតសេចក្តីជ្រះថ្លា យ៉ាងខ្លាំង ក្នុងមួយរំពេចនោះ ស្រេចហើយ ក៏បានធ្វើមរណកាល នៅពេលនោះឯង ហើយបានទៅកើតនៅក្នុងឋានតាវត្តិង្សទេវលោក ក្រឡេកមើលមកឃើញឪពុក របស់ខ្លួន ដែលកំពុងតែសោកសោក យំស្រែកបោកខ្លួន យ៉ាងខ្លាំង ទើបបានចុះពីទេវលោកមក ដើម្បីជួយសង្គ្រោះ ដល់ឪពុករបស់ខ្លួន ឲ្យបានរួចផុតអំពីសេចក្តីទុក្ខសោកសៅនោះ ហើយបានធ្វើឲ្យគាត់លះបង់សេចក្តីកំណាញ់ចេញផុតពីខន្ធសន្តាន ឲ្យកើតមានចិត្តជ្រះថ្លា ក្នុងព្រះពុទ្ធសាសនា ហើយក៏ត្រឡប់ទៅកាន់ឋានទេវលោកវិញ ។

លុះព្រឹកឡើង ព្រាហ្មណ៍ជាឪពុក បានទៅអារាធនានិមន្តព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ឲ្យទទួលនូវភត្តាហារ ក្នុងផ្ទះរបស់ខ្លួនហើយ បានក្រាបទូលសួរអំពីការដែលកូនរបស់ខ្លួន គឺ មដ្ឋកុណ្ឌលីគ្រាន់តែធ្វើចិត្ត ឲ្យជ្រះថ្លា ចំពោះព្រះពុទ្ធជាម្ចាស់ តែប៉ុណ្ណោះមិនបានធ្វើកុសលអ្វីដទៃ ក្រៅអំពីនេះទេ ក៏ស្រាប់តែបានទៅកើតនៅឯឋានទេវលោក ។

ព្រះបរមសាស្តា ទ្រង់បានអធិដ្ឋានឲ្យមដ្ឋកុណ្ឌលីទេវបុត្រ ចុះ

រឿង ព្រះតិស្សត្ថេរ

មក សំដែងរឿងពិត ដល់ព្រាហ្មណ៍ជាឪពុក និង ពួកមហាជន បាន ឃើញជាក់ស្តែង ហើយព្រះអង្គត្រាស់ព្រះគាថានេះ ថា ៖

មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា
មនសា ចេ បសន្នេន ភាសតិ វា ករោតិ វា
តតោ នំ សុខមន្វេតិ ឆាយាវ អនុបាយិនី ។

ធម៌ទាំងឡាយ មានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត សម្រេចមកអំពីចិត្ត, បើបុគ្គលមានចិត្តជ្រះថ្លាហើយ ទោះបីនិយាយក្តី ធ្វើក្តី ក៏ល្អទាំងអស់ ព្រោះសេចក្តីល្អនោះឯង សេចក្តីសុខ រមែងតាមជាប់បុគ្គលនោះ ដូចជាស្រមោលដែលអន្ទោលទៅតាមប្រាណ យ៉ាងនោះឯង ។

♣ ♣ ♣

៣- រឿង ព្រះតិស្សត្ថេរ

ព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រារព្ធព្រះតិស្សត្ថេរ ។ ព្រះថេរៈជាព្រះរាជឱរសរបស់ព្រះបិតុច្ឆា របស់ព្រះអង្គ ។ លោកបានមកបួសជាភិក្ខុក្នុងព្រះពុទ្ធសាសនា នៅពេលដែលមានវ័យចាស់ជរាហើយ លោកមិនដែលធ្វើវត្តប្រតិបត្តិ គោរពចំពោះភិក្ខុអាគន្តុកៈ ដែលមានវស្សាចាស់ជាងខ្លួន តាមព្រះធម៌វិន័យឡើយ ។

ព្រះសាស្តា ទ្រង់ត្រាស់បង្គាប់ ឲ្យព្រះតិស្សៈ សុំខមាទោសចំពោះភិក្ខុអាគន្តុកៈទាំងនោះ, តែព្រះតិស្សៈ ចចេស មិនព្រមធ្វើតាមព្រះពុទ្ធដីកា របស់ព្រះអង្គឡើយ ។ គ្រានោះ ព្រះបរមសាស្តា ទ្រង់

-៧-

# គាថាធម្មបទប្រែ

*ត្រាស់សំដែង នូវអតីតនិទាន របស់ព្រះតិស្សៈ ដូចមានតទៅនេះ ៖ នៅក្នុងជាតិដែលព្រះតិស្សៈនេះ បានកើតជាតាបស ឈ្មោះ ទេវិល, តថាគត បានកើតជាតាបស ឈ្មោះ នារទៈ ។ តាបសទាំងពីររូបនោះ បានឈ្លោះទាស់ទែងគ្នា យ៉ាងខ្លាំង រហូតឮដល់ព្រះរាជាក្រុងពារាណសី... ស្តេចយាងទៅ ជួយរម្ងាប់ការវិវាទទាស់ទែងគ្នានោះ ហើយទ្រង់បានឲ្យទេវិលតាបស សុំខមាទោសនារទតាបស ព្រោះជាអ្នកខុស ។ ទោះជាព្រះរាជបញ្ជា ឲ្យធ្វើយ៉ាងនេះ ក៏ទេវិលតាបស នៅតែមិនព្រមសុំខមាទោស ចំពោះនារទតាបស ទៀត នៅតែចចេស មិនព្រមស្តាប់ មិនព្រមធ្វើតាម តាំងតែពីជាតិនោះមក រហូតមកដល់ជាតិនេះ ដូច្នេះហើយ ទើបព្រះអង្គត្រាស់នូវព្រះគាថានេះ ថា ៖*

អក្កោច្ឆិ មំ អវធិ មំ អជិនិ មំ អហាសិ មេ
យេ ច តំ ឧបនយ្ហន្តិ វេរំ តេសំ ន សម្មតិ ។
អក្កោច្ឆិ មំ អវធិ មំ អជិនិ មំ អហាសិ មេ
យេ ច តំ នូបនយ្ហន្តិ វេរំ តេសូបសម្មតិ ។

*បើជនទាំងឡាយណា ចងសេចក្តីក្រោធនោះទុក យ៉ាងនេះថា: ជនឯណោះ បានជេរអញ ជនឯណោះ បានវាយអញ ជនឯណោះ បានឈ្នះអញ ជនឯណោះ បានលួចយកទ្រព្យរបស់អញទៅហើយ (ដូច្នេះ) ពៀរវេរា របស់ជនទាំងឡាយនោះ មិនស្ងប់រម្ងាប់បានឡើយ ។*

*បើជនទាំងឡាយណា មិនចងសេចក្តីក្រោធនោះទុក យ៉ាង*

នេះថា: ជនឯណោះ បានជេរអញ ជនឯណោះ បានវាយអញ ជនឯណោះ បានឈ្នះអញ ជនឯណោះ បានលួចយកទ្រព្យរបស់អញទៅហើយ (ដូច្នេះ) ពៀរវេរា របស់ជនទាំងឡាយនោះ តែងស្ងប់រម្ងាប់ទៅបាន ។

❀ ❀ ❀

## ៤- រឿង នាងកាលីយក្ខិនី

ព្រះបរមសាស្តា ទ្រង់ប្រារព្ធស្ត្រីម្នាក់ ជាស្ត្រីអារ គ្មានកូន ។ នាង ដឹងថា: ខ្លួន ប្រាកដជាមិនមានកូន ហើយនាងខ្លាចស្វាមីមានប្រពន្ធថ្មីទៀតដែលអាចមានកូន ប្រពន្ធថ្មីនោះ នឹងមានអំណាចធំជាងខ្លួន ទើបខ្លួនឯង សម្រេចចិត្ត ដើរទៅរកស្រីម្នាក់ យកមកឲ្យស្វាមី ធ្វើជាប្រពន្ធចុង ។

មិនយូរប៉ុន្មាន ស្ត្រីដែលនាងរកមកឲ្យស្វាមី ធ្វើជាប្រពន្ធចុងនោះ ក៏ចាប់ផ្តើមមានផ្ទៃពោះ ។ ប្រពន្ធដើមនោះ ដឹងច្បាស់ថា: នាងប្រពន្ធចុងមានផ្ទៃពោះហើយ ក៏យកថ្នាំពិសមក ឲ្យប្រពន្ធចុងផឹក ។ ប្រពន្ធចុង ស្មានថា ជាថ្នាំសម្រាប់ថែរក្សាគភ៌ ក៏បានយកថ្នាំពិសនោះទៅផឹក នាងបានរលូតកូនស្លាប់ដល់ទៅពីរលើក ព្រោះថ្នាំពិសរបស់ប្រពន្ធដើម ។ ក្នុងលើក ទី៣ នាងប្រពន្ធចុង ត្រូវបានស្លាប់ទាំងខ្លួនព្រមទាំងកូននៅក្នុងផ្ទៃ ព្រោះថ្នាំពិសរបស់ប្រពន្ធដើម ដូចជាលើកមុនៗ ដែរ ។

ស្វាមីរបស់នាង បានដឹងរឿងនោះហើយ ក៏វាយធ្វើបាបនាង

-៩-

គាថាធម្មបទប្រែ

ប្រពន្ធដើម រហូតដល់ក្ស័យជីវិតតែម្តង ។ នាងប្រពន្ធដើម និង ប្រពន្ធចុង ពីរនាក់នេះ បានចងកម្មពៀរវេរា នឹងគ្នាម្នាក់ម្តងៗ យ៉ាងនេះ គឺ ៖

ប្រពន្ធចុង ស្លាប់ទៅ ក៏បានទៅកើតជាមេឆ្មា, ឯប្រពន្ធដើម ស្លាប់ទៅ បានទៅកើតជាមេមាន់ ។ មេឆ្មា បានស៊ីពងមាន់ និង មេមាន់ ។

ប្រពន្ធដើម ស្លាប់ពីមេមាន់ បានទៅកើតជាមេខ្លា, ឯប្រពន្ធចុង (មេឆ្មា) ស្លាប់ទៅ បានទៅកើតជាមេប្រើស ។ មេខ្លា បានខាំស៊ីមេប្រើស ។

ប្រពន្ធចុង (មេប្រើស) ស្លាប់ទៅកើតជានាងយក្ខិនី, ឯប្រពន្ធដើម (មេខ្លា) ស្លាប់ទៅ ក៏បានកើតជានាងកុលធីតា ។ នាងយក្ខិនី (ប្រពន្ធចុង) ក៏បានចាប់កូននាងកុលធីតា (ប្រពន្ធដើម) យកទៅខាំស៊ីអស់ រហូតដល់ទៅពីរលើក ។

ក្នុងលើកទីបី នាងកុលធីតា ក៏បាននាំយកកូនខ្ចី រត់គេចទៅផ្ទះដើមកំណើតរបស់ខ្លួន លុះដល់ពាក់កណ្តាលផ្លូវ ក៏ស្រាប់តែនាងយក្ខិនី (ស្រីប្រពន្ធចុង) ដេញជាប់ តាមក្រោយនាង មកប្រកិតៗ ។ នាងកុលធីតា ក្រឡេកឃើញនាងយក្ខិនី ដេញតាមជាប់ពីក្រោយខ្លួនយ៉ាងដូច្នេះហើយ ក៏មានសេចក្តីតក់ស្លុត ភ័យខ្លាចជាទីបំផុត ហើយបានរត់ចូលទៅ ក្នុងវត្តជេតពនមហាវិហារ យ៉ាងប្រញាប់ប្រញាល់ ។ ជួនជានៅពេលនោះ ព្រះបរមសាស្តា កំពុងតែទ្រង់សម្តែងព្រះធម៌ទេសនា អប់រំដល់ពួកពុទ្ធបរិស័ទ ។ នាងកុលធីតា បានចូលទៅជិត

ព្រះសាស្តា ហើយយកកូនទៅដាក់ នៅក្បែរព្រះបាទ របស់ព្រះអង្គ ក្រាបបង្គំទូលថា: បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះករុណា សូមប្រគេនកូនតូចនេះ ដល់ព្រះអង្គ សូមព្រះអង្គមេត្តាទទួលយកចុះ ។ បន្ទាប់គ្នានោះឯង នាងយក្ខិនី ក៏បានមកដល់វត្តជេតពននោះដែរ ។

ព្រះសាស្តា ទ្រង់បានត្រាស់ទៅកាន់នាងទាំងពីរនាក់នោះ ថា "នៃនាងទាំងពីរនាក់ ព្រោះហេតុអ្វី បានជាពួកនាង តាមចងកម្ម ចងពៀរនឹងគ្នា មិនចេះឈប់ឈរ យ៉ាងនេះ?" ដូច្នេះហើយ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

**ន ហិ វេរេន វេរានិ សម្មន្តីធ កុទាចនំ**
**អវេរេន ច សម្មន្តិ ឯស ធម្មោ សនន្តនោ ។**

មែនពិត ក្នុងពេលណាៗ ក៏ដោយ ក្នុងលោកនេះ ពួកពៀរទាំងឡាយ មិនដែលរម្ងាប់ ដោយការចងពៀរឡើយ ពៀរទាំងឡាយតែងរម្ងាប់ ដោយការមិនចងពៀរ នេះជាបវេណីធម៌ ។

♣ ♣ ♣

## ៥- រឿង ពួកភិក្ខុកោសម្ពី

ព្រះសាស្តាចារ្យ ទ្រង់បានប្រារព្ធពួកភិក្ខុកោសម្ពី ។ ពួកភិក្ខុកោសម្ពីទាំងនោះ ជាដំបូង គ្រាន់តែចោទគ្នាពីអាបត្តិតូចតាចប៉ុណ្ណោះឯង តែដល់ក្រោយៗ មក ក៏កើតមានវិវាទឈ្លោះប្រកែកគ្នា ទៅជារឿងធំដុំខ្លាំងឡើងៗ ទោះបីជាព្រះពុទ្ធជាម្ចាស់ ទ្រង់ត្រាស់ហាមប្រាមយ៉ាងណាក៏ដោយ ក៏ភិក្ខុទាំងនោះ មិនព្រមធ្វើតាមព្រះឱវាទ របស់

*ព្រះអង្គឡើយ ។*

*កាលបើយ៉ាងនេះហើយ ព្រះពុទ្ធជាម្ចាស់ ទ្រង់ជ្រាបច្បាស់ក្នុងព្រះទ័យថា: ប្រាកដជាមិនបានប្រយោជន៍អ្វីឡើយ ទើបព្រះអង្គទ្រង់ស្តេចយាង ចេញឆ្ងាយពីពួកភិក្ខុកោសម្ពីទាំងនោះ ទៅគង់ចាំព្រះវស្សា នៅក្នុងព្រៃរក្ខិតវ័ន តែមួយព្រះអង្គឯងគត់ ។*

*ចំណេរកាលក្រោយមក ពួកពុទ្ធបរិស័ទ បានថ្កោលទោសពួកភិក្ខុទាំងនោះៗ បានដឹងកំហុសរបស់ខ្លួន ក៏បានចូលទៅរកព្រះអានន្ទត្ថេរ ឲ្យលោកជួយសុំខមាទោសចំពោះព្រះពុទ្ធជាម្ចាស់ ហើយទូលសុំ ឲ្យព្រះអង្គស្តេចយាងត្រឡប់មកវិញ ។*

*ព្រះសាស្តា ទ្រង់បានទទួលពាក្យ របស់ភិក្ខុកោសម្ពីទាំងនោះហើយ ទើបស្តេចយាងវិលត្រឡប់មកវិញ ទ្រង់ប្រទានព្រះឱវាទដល់ពួកភិក្ខុទាំងនោះ ឲ្យមានសេចក្តីព្រមព្រៀងគ្នា ចេះស្រឡាញ់គ្នា កុំឲ្យមានការឈ្លោះ ទាស់ទែងនឹងគ្នាឯង តទៅទៀត ដោយព្រះធម្មិកថាទីឃាវុជាតកហើយ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

**បរេ ច ន វិជានន្តិ មយមេត្ថ យមាម សេ**
**យេ ច តត្ថ វិជានន្តិ តតោ សម្មន្តិ មេធគា ។**

*ពួកជនទាំងឡាយដទៃ (ក្រៅអំពីបណ្ឌិត) តែងមិនដឹងខ្លួនថាពួកយើងទាំងអស់គ្នា នឹងវិនាស ក្នុងកណ្តាលជំនុំនៃពួកនេះ ដូច្នេះឡើយ, ចំណែកឯជនទាំងឡាយណា ក្នុងកណ្តាលជំនុំនៃពួកនេះ ដឹងខ្លួនច្បាស់ថា ពួកយើងទាំងអស់គ្នា នឹងវិនាស ក្នុងកណ្តាលជំនុំ នៃ*

ពួកនេះ ដូច្នេះ, ការឈ្លោះប្រកែកគ្នាទាំងឡាយ រមែងរម្ងាប់អំពីជនទាំងឡាយនោះ ។

៚ ៚ ៚

## ៦- រឿង ព្រះចុល្លកាល-មហាកាល

ព្រះបរមសាស្តា ទ្រង់ប្រារព្ធព្រះចុល្លកាល និង ព្រះមហា-កាល ។ ព្រះចុល្លកាល ជាប្អូនរបស់ព្រះមហាកាល លោកបួសមិនទាន់បានមួយវស្សាផង ក៏លាចាកសិក្ខាបទ (សឹក) មកជាគ្រហស្ថ ព្រោះកិរិយារបស់លោក ចេះតែមកធ្វើឲ្យរំខានខ្លាំងពេក ។ ចំណែកព្រះមហាកាលដែលជាបង លោកបានមកបួស ក្នុងព្រះពុទ្ធសាសនា ដោយសទ្ធាជ្រះថ្លា ខិតខំចំរើនអសុភកម្មដ្ឋាន រហូតដល់បានសម្រេចអរហត្តផល ព្រមទាំងបដិសម្ភិទា ។

ឯកិរិយា របស់ព្រះមហាកាល បានឃើញកិរិយាលួងលោមរបស់កិរិយាព្រះចុល្លកាល ដែលបានធ្វើឲ្យលោកសឹកហើយ ទើបគិតនឹងធ្វើ ជាតម្រាប់តាម ហើយបានទៅអារាធនាភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន មកទទួលភត្តាហារ នៅឯផ្ទះរបស់ខ្លួន ។

ព្រះសាស្តា ព្រមទាំងភិក្ខុសង្ឃ បានទទួលភត្តាហារហើយទើបទ្រង់ស្តេចយាងត្រឡប់ទៅវត្តវិញ ទុកតែព្រះមហាកាល មួយអង្គប៉ុណ្ណោះ ឲ្យនៅចាំធ្វើភត្តានុមោទនា តាមពាក្យទូលសុំ នៃពួកកិរិយា របស់ព្រះមហាកាល ។

គ្រានោះ ពួកកិរិយា របស់ព្រះមហាកាល បាននាំគ្នាបន្ទំឲ្យ

លោក លាចាកសិក្ខាបទ, ក៏ប៉ុន្តែ ព្រះមហាកាល មិនព្រមលាចាកសិក្ខាបទទេ ព្រោះលោកជាព្រះអរហន្ត ហើយក៏បានហោះទៅ លើអាកាស ត្រឡប់ទៅវត្តវិញ ។

ពួកភិក្ខុទាំងឡាយ បានសន្ទនាគ្នាអំពីរឿងរ៉ាវព្រះមហាកាល និង ព្រះចុល្លកាល ដោយប្រការផ្សេងៗ ។

ព្រះសាស្តា ទ្រង់ជ្រាបហើយ ទ្រង់ត្រាស់ព្រះគាថានេះ ថា ៖

សុភានុបស្សឹ វិហរន្តំ ឥន្ទ្រិយេសុ អសំវុតំ
ភោជនម្ហិ អមត្តញ្ញុំ កុសីតំ ហីនវីរិយំ
តំ វេ បសហតី មារោ វាតោ រុក្ខំវ ទុព្វលំ ។
អសុភានុបស្សឹ វិហរន្តំ ឥន្ទ្រិយេសុ សុសំវុតំ
ភោជនម្ហិ ច មត្តញ្ញុំ សទ្ធំ អារទ្ធវីរិយំ
តំ វេ នប្បសហតី មារោ វាតោ សេលំវ បព្វតំ ។

មារ រមែងគ្របសង្កត់បុគ្គលដែលយល់ឃើញ នូវអារម្មណ៍ថា ល្អ មិនសង្រួម ក្នុងឥន្ទ្រីយ៍ទាំងឡាយ មិនស្គាល់ប្រមាណ ក្នុងភោជន ខ្ជិលច្រអូស មានព្យាយាមថយនោះ (បានដោយស្រួល) ដូចជាវាយោ បក់បោករំលើងនូវដើមឈើដែល (មានឫស) មិនល្អយ៉ាងនោះឯង ។

តែមារ រមែងគ្របសង្កត់បុគ្គលដែលយល់ឃើញនូវអារម្មណ៍ថា មិនល្អ សង្រួមប្រពៃ ក្នុងឥន្ទ្រីយ៍ទាំងឡាយ ស្គាល់ប្រមាណ ក្នុងភោជន មានសទ្ធា ប្រារព្ធព្យាយាមនោះមិនបាន ដូចជាវាយោ បក់

បោកក្អំថ្មតាន់ (ឲ្យបែក) មិនបាន យ៉ាងនោះឯង ។

❁ ❁ ❁

## ៧- រឿងភិក្ខុទេវទត្ត

ព្រះបរមសាស្តា ទ្រង់ប្រារព្ធសំពត់កាសាវពស្ត្រ របស់ភិក្ខុទេវទត្ត ។ សម័យថ្ងៃមួយ ភិក្ខុទេវទត្ត បានសំពត់កាសាវពស្ត្រ ពីញាតិញោមមួយក្រុម ។ សំពត់នោះជាសំពត់មានសាច់ល្អ មានតម្លៃក៏ច្រើន ។ មនុស្សខ្លះ និយាយថា: សំពត់នេះ មិនសមគួរ ដល់ភិក្ខុទេវទត្តឡើយ, តែសមគួរ ដល់ព្រះសារីបុត្រ ។

ព្រះសាស្តា ទ្រង់ជ្រាបហើយ ទើបទ្រង់សំដែងរឿងដែលភិក្ខុទេវទត្ត ធ្លាប់គ្រងសំពត់កាសាវពស្ត្រ ដែលមិនសមគួរដល់ខ្លួន តាំងតែអំពីពេលដែលទេវទត្ត កើតជាព្រានព្រៃ បានលួចយកនូវសំពត់កាសាវពស្ត្រ របស់ព្រះបច្ចេកពុទ្ធ មួយអង្គ មកស្លៀកពាក់ ដើម្បីបន្លំខ្លួន ធ្វើជាព្រះបច្ចេកពុទ្ធ លបចាំសម្លាប់ដំរី ដែលដើរនៅពីក្រោយគេបង្អស់ម្តងមួយៗ ។

ក្នុងគ្រានោះឯង ព្រះពុទ្ធជាម្ចាស់ ទ្រង់បានសោយព្រះជាតិជាស្តេចដំរី ឃើញដំរីដែលជាបរិវារ របស់ព្រះអង្គ ចេះតែបាត់អស់ទៅជាច្រើន ទើបសង្កេតមើលនូវហេតុអន្តរាយដែលកើតឡើង មិនយូរប៉ុន្មាន ក៏បានឃើញជាក់ច្បាស់ថា អន្តរាយនេះ កើតឡើង ព្រោះមានមនុស្សមកបន្លំខ្លួន ធ្វើជាព្រះបច្ចេកពុទ្ធ ។ ថ្ងៃមួយ ព្រះអង្គទ្រង់បានអែបមកនៅ ខាងក្រោយហ្វូងម្តង ដើម្បីលបចាំចាប់ព្រានព្រៃនោះ

*លុះព្រះអង្គចាប់ព្រានព្រៃបានហើយ ក៏ទ្រង់ព្រះតម្រិះ ថា: នឹងបោក សម្លាប់ចោល តែព្រះអង្គទ្រង់ត្រិះរិះទាន់ គឺ មិនបានសម្លាប់ គ្រាន់តែ អប់រំទូន្មាន ប្រៀនប្រដៅហើយ ក៏លែងព្រានព្រៃនោះទៅវិញ ... នៅ ទីបញ្ចប់នៃអតីតនិទាន ព្រះអង្គទ្រង់ត្រាស់ នូវព្រះគាថានេះ ថា ៖*

អនិក្កសាវោ កាសាវំ យោ វត្ថំ បរិទហេស្សតិ
អបេតោ ទមសច្ចេន ន សោ កាសាវមរហតិ ។
យោ ច វន្តកសាវស្ស សីលេសុ សុសមាហិតោ
ឧបេតោ ទមសច្ចេន ស វេ កាសាវមរហតិ ។

*បុគ្គលណា នៅមានទឹកអម្ចត់ គឺរាគាទិក្កិលេស (ក្នុងសន្ដាន) ជាអ្នកបោះបង់ការទូន្មាននូវឥន្ទ្រីយ និង សច្ចៈ ហើយស្លៀកដណ្ដប់ សំពត់កាសាវពស្ត្រ, បុគ្គលនោះ មិនគួរនឹងស្លៀកដណ្ដប់សំពត់ កាសាវពស្ត្រសោះឡើយ ។*

*លុះតែបុគ្គលណា មានទឹកអម្ចត់ គឺរាគាទិក្កិលេស ខ្ជាក់ ចោលអស់ហើយ ជាអ្នកមានចិត្តតម្កល់មាំ នៅក្នុងសីលទាំងឡាយ ប្រកបដោយការទូន្មានឥន្ទ្រីយ និង សច្ចៈ, បុគ្គលនោះឯង ទើបគួរ នឹងស្លៀកដណ្ដប់សំពត់កាសាវពស្ត្របាន ។*

♣ ♣ ♣

## ៨- រឿងសញ្ជ័យបរិព្វាជក

*ព្រះបរមសាស្ដា ទ្រង់បានប្រារព្ធការមិនមក របស់សញ្ជ័យ- បរិព្វាជក ។ សម័យដែលព្រះអគ្គសាវកទាំងពីរ កំពុងតែស្វែងរក*

-១៦-

## រឿងសញ្ជ័យបរិព្វាជក

មោក្ខធម៌នោះ លោកបានទៅសិក្សាជាមួយនឹងសញ្ជ័យបរិព្វាជកនេះឯង ព្រោះនៅក្នុងសម័យនោះ សញ្ជ័យបរិព្វាជក ជាគណាចារ្យដែលមានឈ្មោះសម្លេង ដ៏ល្បីល្បាញខ្លាំងណាស់ ក្នុងទីក្រុងរាជគ្រឹះ ។

ក្រោយមក ឧបតិស្សបរិព្វាជក (គឺព្រះសារីបុត្រ) បានស្តាប់នូវអរិយសច្ចកថា អំពីសំណាក់ នៃព្រះអស្សជិត្ថេរ ដោយសង្ខេបហើយ ក៏បានសម្រេចព្រះសោតាបត្តិផល ទើបត្រឡប់មកពន្យល់ឲ្យកោលិតបរិព្វាជក (ព្រះមហាមោគ្គល្លាន) ជាសំឡាញ់របស់ខ្លួន បានស្តាប់... រហូតដល់កោលិតៈ បានសម្រេចនូវព្រះសោតាបត្តិផល ដូចខ្លួនដែរ ស្រេចហើយ ទើបនាំគ្នាទៅកាន់សំណាក់គ្រូសញ្ជ័យបរិព្វា-ជក ដើម្បីសុំលាទៅ ក្រាបថ្វាយបង្គំគាល់ព្រះពុទ្ធជាម្ចាស់ ព្រមទាំងបានបបួលគ្រូសញ្ជ័យ ឲ្យទៅគាល់ជាមួយផងដែរ ។ តែគ្រូសញ្ជ័យមិនព្រមទៅជាមួយឡើយ ។ ឧបតិស្សៈ និង កោលិតៈ ព្រមទាំងបរិវារ របស់ខ្លួន បាននាំគ្នាទៅគាល់ព្រះបរមសាស្តា ហើយបានក្រាបថ្វាយបង្គំទូលសុំបព្វជ្ជា និង ឧបសម្បទ ជាភិក្ខុ ក្នុងព្រះពុទ្ធសាសនា .... លុះបានសម្រេចនូវសោឡសកិច្ចហើយ ក៏បានទទួលតំណែងជាព្រះអគ្គសាវក ឆ្វេង-ស្តាំ ។ ក្រោយមក ព្រះអគ្គសាវកទាំងពីរ បានក្រាបទូលព្រះសាស្តា អំពីរឿងដែលគ្រូសញ្ជ័យ មិនព្រមមកគាល់ព្រះអង្គ ជាមួយនឹងពួកខ្លួន តាមពាក្យបបួល ។

ព្រះសាស្តា ទ្រង់ជ្រាបហើយ ទើបត្រាស់ព្រះគាថានេះ ថា ៖

**អសារេ សារមតិនោ សារេ ចាសារទស្សិនោ**

-១៧-

គាថាធម្មបទប្រែ

តេ សារំ នាធិគច្ឆន្តិ មិច្ឆាសង្កប្បគោចរា ។
សារញ្ច សារតោ ញត្វា អសារញ្ច អសារតោ
តេ សារំ អធិគច្ឆន្តិ សម្មាសង្កប្បគោចរា ។

*ជនទាំងឡាយណា យល់ឃើញ ក្នុងធម៌ដែលមានខ្លឹមសារថា ជាធម៌មិនមានខ្លឹមសារផង ជាអ្នកយល់ឃើញ ក្នុងធម៌ដែលមិនមានខ្លឹមសារ ថា ជាធម៌មានខ្លឹមសារផង, ជនទាំងឡាយនោះ ជាអ្នកមានសេចក្តីត្រិះរិះខុស ជាអារម្មណ៍ រមែងមិនបាននូវធម៌ដែលមានខ្លឹមសារឡើយ ។*

*ឯជនទាំងឡាយណា ដែលយល់ឃើញ នូវធម៌ដែលមានខ្លឹមសារថា ជាធម៌មានខ្លឹមសារផង យល់ឃើញនូវធម៌ដែលគ្មានខ្លឹមសារថា ជាធម៌គ្មានខ្លឹមសារផង, ជនទាំងឡាយនោះ ជាអ្នកមានសេចក្តីត្រិះរិះត្រឹមត្រូវ ជាអារម្មណ៍ រមែងបាននូវធម៌ដែលមានខ្លឹមសារ ។*

៩-- រឿង ព្រះនន្ទត្ថេរ

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធព្រះនន្ទត្ថេរ ដែលត្រូវជាព្រះរាជឱរស របស់ព្រះនាងបជាបតិគោតមី ។ សម័យថ្ងៃមួយ ជាថ្ងៃរៀបមង្គលការ របស់ព្រះនន្ទកុមារ ជាមួយនឹងនាងជនបទកល្យាណី ។*

*គ្រានោះ ព្រះសាស្តា ស្តេចយាងទៅ ក្នុងពិធីរៀបមង្គលការរបស់នន្ទៈនោះដែរ ព្រះអង្គទ្រង់បានប្រទាននូវបាត្រ ទៅឲ្យនន្ទៈកាន់ ទ្រង់ត្រាស់មង្គលកថា ស្រេចហើយ ទើបស្តេចយាងត្រឡប់ទៅកាន់*

វត្តវិញ តែព្រះអង្គទ្រង់មិនបានទទួលយកបាត្រ អំពីដៃរបស់ព្រះនន្ទៈវិញឡើយ ។

ព្រះនន្ទៈ បានបីបាត្រ របស់ព្រះសាស្តា តាមក្រោយព្រះអង្គរហូតដល់វត្តតែម្តង ។ ព្រះសាស្តាទ្រង់ត្រាស់សួរព្រះនន្ទៈ ថា: នែនន្ទអ្នកបួសឬ? ។ ព្រះនន្ទៈ មិនហ៊ានប្រកែក ទើបក្រាបទូលថា: បពិត្រព្រះអង្គដ៏ចំរើន ទូលព្រះបង្គំនឹងបួស ។ លុះព្រះនន្ទៈ បួសហើយ មិនបានរៀនសូត្រធម៌អាថ៌អ្វីសោះឡើយ ព្រោះមួយថ្ងៃៗ លោកកន្លង់តែនឹកទៅដល់នាងជនបទកល្យាណី ស្រីខត្តិយកញ្ញា ដែលទើបតែនឹងរៀបមង្គលការជាមួយគ្នា ហើយថ្មីៗ នោះ ។

ព្រះសាស្តាទ្រង់ជ្រាបហើយ ទើបនាំព្រះនន្ទៈ ឲ្យទៅមើលពួកស្រីទេពអប្សរបរកញ្ញា ដែលមានរូបរាងស្អាតៗ ជាងនាងជនបទ-កល្យាណី នៅឯឋានទេវលោក ហើយទ្រង់ត្រាស់អប់រំព្រះនន្ទៈ ថា: នែនន្ទៈ ចូរអ្នកខិតខំ ព្យាយាមបំពេញសមណធម៌ ឲ្យបានត្រឹមត្រូវ, តថាគត នឹងជួយដណ្តឹងស្រីទេពអប្សរបរកញ្ញា ក្នុងឋានសួគ៌ានេះឲ្យអ្នក, តើអ្នកចង់បាននាងទេពអប្សរបរកញ្ញា ដែលមានរូបឆោមស្អាតៗ បែបណា? ។

ព្រះនន្ទៈ បានឮយ៉ាងដូច្នោះហើយ មានចិត្តត្រេកអរពន់ពេកណាស់ ខិតខំព្យាយាមបំពេញសមណធម៌ យ៉ាងខ្លាំងក្លា ជាទីបំផុតព្រោះចង់បានស្រីទេពអប្សរបរកញ្ញានោះឯង ។

ពួកភិក្ខុទាំងឡាយ ដឹងរឿងនោះហើយ ទើបនាំគ្នានិយាយ

*រិះគន់ព្រះនន្ទៈ ដោយប្រការផ្សេងៗ ថាៈ ព្រះនន្ទៈ ខំព្យាយាមបំពេញសមណធម៌ ព្រោះចង់បាននាងទេពអប្សរមកធ្វើជាភរិយា ។ ព្រះនន្ទៈ ឮពួកភិក្ខុតិះដៀល ដូច្នេះហើយ មានសេចក្តីអៀនខ្មាស ខ្លាំងណាស់ ហើយបានប្រែចិត្តគំនិតជាថ្មី ខិតខំប្រឹងបំពេញសមណធម៌ តែម្នាក់ឯង នៅក្នុងព្រៃស្ងាត់ រហូតទាល់តែបានសម្រេចព្រះអរហត្តផល ។*

*ក្រោយមក ពួកភិក្ខុបានសួរព្រះនន្ទៈ ថាៈ ម្នាលនន្ទៈ ឥឡូវនេះ តើលោកចង់សឹកដែរឬទេ? ។ ព្រះនន្ទៈ ឆ្លើយថាៈ ខ្ញុំព្រះករុណា មិនត្រូវការចង់សឹកទៀតទេ ។ ពួកភិក្ខុ ឮដូច្នោះហើយ ក៏ចោទព្រះនន្ទៈ ថាៈ ជាអ្នកពោលអួត នូវគុណធម៌ដែលមិនមានក្នុងខ្លួន ហើយបាននាំរឿងនេះ ទៅក្រាបទូលដល់ព្រះសាស្តា ។*

*ព្រះសាស្តា ទ្រង់ត្រាស់ ថាៈ ម្នាលភិក្ខុទាំងឡាយ ព្រះនន្ទៈ បានពោលត្រឹមត្រូវហើយ... បន្ទាប់ មកទ្រង់ត្រាស់ព្រះគាថានេះថា៖*

យថា អគារំ ទុច្ឆន្នំ វុដ្ឋិ សមតិវិជ្ឈតិ
ឯវំ អភាវិតំ ចិត្តំ រាគោ សមតិវិជ្ឈតិ ។
យថា អគារំ សុច្ឆន្នំ វុដ្ឋិ ន សមតិវិជ្ឈតិ
ឯវំ សុភាវិតំ ចិត្តំ រាគោ ន សមតិវិជ្ឈតិ ។

*តំណក់ទឹកភ្លៀង តែងលេចស្រោចនូវផ្ទះ ដែលគេប្រក់មិនបានជិតល្អហើយ យ៉ាងណាមិញ, រាគៈ តែងចាក់ទម្លុះនូវចិត្តដែលបុគ្គលមិនបានអប់រំល្អហើយ ក៏យ៉ាងនោះដែរ ។*

*តំណក់ទឹកភ្លៀង មិនលេចស្រោចនូវផ្ទះ ដែលគេបានប្រក់ជិត*

ល្អហើយ យ៉ាងណាមិញ, រាគៈ ក៏មិនចាក់ទម្លុះនូវចិត្ត ដែលបុគ្គលបានអប់រំល្អហើយ ក៏យ៉ាងនោះដែរ ។

❃❃❃

## ១០- រឿង នាយចុន្ទសូករិក

ព្រះបរមសាស្ដា ទ្រង់បានប្រារព្ធ នូវបុរសសម្លាប់ជ្រូកម្នាក់ឈ្មោះ ចុន្ទសូករិក ។ នាយចុន្ទសូករិកនេះ ជាមនុស្សគ្មានសីលធម៌ ប្រាសចាកមេត្តាចិត្ត គិតតែពីកាប់សម្លាប់ជ្រូក យកសាច់លក់ចិញ្ចឹមជីវិត អស់រយៈពេល ៥៥ ឆ្នាំ គាត់មិនដែលបានធ្វើបុណ្យ ឲ្យទានបន្តិចសោះ, ថ្ងៃដែលគាត់បានឃើញបាបកម្ម ដ៏កាចសាហាវ របស់គាត់នោះ គឺថ្ងៃដែលគាត់ជិតនឹងស្លាប់... គាត់មានសេចក្ដីក្ដៅក្រហល់ក្រហាយ អន្ទះអន្ទែង វារទៅ-មក បីដូចជាភ្លើង ក្នុងអវិចីនរក ដុតពេលទាំងរស់ រើបម្រះនទៀល ដូចជាសត្វជ្រូក ដែលគាត់សម្លាប់ដោយយកទឹកក្ដៅប្រេក ក្នុងមាត់ ដើម្បីសម្លាប់ យ៉ាងនោះឯង ។ គាត់ទទួលទុក្ខវេទនាបែបនេះ រហូតដល់ទៅ ៧ ថ្ងៃ ទើបបានធ្វើមរណកាល ទៅកើតសោយទុក្ខវេទនា នៅក្នុងអវិចីនរក ។

នៅពេលដែលនាយចុន្ទសូករិក កំពុងតែទទួល នូវទុក្ខវេទនារវាង ៧ ថ្ងៃនោះ, ភិក្ខុទាំងឡាយ បាននិមន្ដទៅ ដើម្បីបិណ្ឌបាត្រ នៅក្បែរផ្ទះគាត់ ហើយបានឮនូវសម្លេងស្រែកទ្រហ៊ុំ ដូចជាជ្រូកស្រែក ទើបនាំយករឿងនេះ ទៅក្រាបទូលដល់ព្រះសាស្ដា ។

ព្រះបរមសាស្ដា ទ្រង់ត្រាស់ថា "សម្លេងនោះ គឺមិនមែនជា

*សម្លេងជ្រូកស្រែកទេ គឺជាសម្លេង របស់នាយចុន្ទសូករិក" ហើយទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

**ឥធ សោចតិ បេច្ច សោចតិ**
**បាបការី ឧភយត្ថ សោចតិ**
**សោ សោចតិ សោ វិហញ្ញតិ**
**ទិស្វា កម្មកិលិដ្ឋមត្តនោ ។**

*បុគ្គលអ្នកធ្វើបាប តែងសោកស្តាយ ក្នុងលោកទាំងពីរ គឺសោកស្តាយ ក្នុងលោកនេះផង ក្នុងលោកខាងមុខផង, បុគ្គលនោះតែងសោកស្តាយក្តៅក្រហាយ ព្រោះឃើញអំពើសៅហ្មងរបស់ខ្លួនៗ*

♣ ♣ ♣

## ១១- រឿង ធម្មិកឧបាសក

*ព្រះបរមសាស្តា ទ្រង់បានប្រារព្ធធម្មិកឧបាសក ជាអ្នកមានកល្យាណធម៌ ។ នៅពេលដែលធម្មិកឧបាសកនោះ ឈឺទៀបនឹងធ្វើមរណកាលនោះ គាត់ក៏បានប្រើកូនប្រុសស្រី របស់គាត់ ដើម្បីទៅនិមន្តព្រះសង្ឃ មកសូត្រសតិបដ្ឋានសូត្រ ឲ្យគាត់ស្តាប់ ។*

*ពេលដែលព្រះសង្ឃ កំពុងតែសូត្រ នូវសតិបដ្ឋានសូត្រនោះ ធម្មិកឧបាសក បានឃើញនូវទេវរថ ជាច្រើន ដែលពួកទេវតានាំយកមក ចាំទទួលដំណើរគាត់យកទៅកាន់ទេវលោក ។ ពួកទេវតា ក៏បានអញ្ជើញគាត់ ឲ្យទៅកើត ក្នុងឋានទេវលោក ។ ធម្មិកឧបាសក បាននិយាយអង្វរករនឹងពួកទេវតា ថា "ឈប់ចាំសិនៗ" ព្រោះគាត់ប្រាថ្នា*

ចង់ស្តាប់ធម៌ ដែលព្រះសង្ឃកំពុងតែសូត្រ ឲ្យបានចប់ហើយ ចាំទៅជាមួយពួកទេវតា ។

ពួកភិក្ខុទាំងឡាយ បានឮធម្មិកឧបាសក និយាយថា "ឈប់ចាំសិនៗ" ដូច្នេះ ក៏ឈប់សូត្រធម៌ ហើយចំរើនពរ លាត្រឡប់ទៅវត្តវិញទៅ ។

នៅពេលដែលភិក្ខុទាំងឡាយ បាននិមន្តត្រឡប់ ទៅកាន់វត្តវិញអស់ហើយ ធម្មិកឧបាសកមានស្មារតីដឹងខ្លួនឡើងវិញ មិនឃើញព្រះភិក្ខុសង្ឃ ក៏សួរកូនប្រុសស្រីថា "តើព្រះសង្ឃ និមន្តទៅទីណាបាត់អស់ហើយ?" ។

កូនប្រុសស្រី បានប្រាប់ថា "ព្រះសង្ឃ បាននិមន្តទៅវត្តវិញហើយ ព្រោះលោកឪពុកបាននិយាយថាៈ ឲ្យលោកឈប់ (សូត្រធម៌) សិន" ។

ធម្មិកឧបាសក ក៏បានភ្ញាក់ខ្លួនព្រើត និយាយទៅកាន់កូនៗ ថា "ពុទ្ធោអើយ! ឪពុកមិនបាននិយាយ ឲ្យលោកឈប់សូត្រធម៌ ពីកាលណា! ឪពុកនិយាយជាមួយនឹងពួកទេវតាដែលចុះមក ដើម្បីនាំយកឪពុកឲ្យទៅកើត នៅឯឋានទេវលោកនោះទេតើ" ។ ទោះជាឧបាសកខំពន្យល់ប្រាប់នូវរឿងពិតនេះ ឲ្យកូនប្រុសស្រីបានយល់ យ៉ាងណាក៏ដោយ ក៏កូនៗ មិនជឿគាត់ដែរ ។ ធម្មិកឧបាសក បានប្រាប់កូនឲ្យយកកម្រងផ្កា បោះឡើងទៅលើអាកាសវេហាស៍ ហើយបានអធិដ្ឋានឲ្យកម្រងផ្កានោះ អណ្តែតជាប់នឹងចន្ទោលទេវរថ ដែលពួកទេវតា

*នាំមកអំពីឋានតុសិតទេវលោក ។*

*ពួកមនុស្សឯទៀតៗ មើលឃើញតែកម្រងផ្កា មិនឃើញនូវទេវរថទេ ។ ភិក្ខុទាំងឡាយ លុះនិមន្តមកដល់វត្តវិញហើយ បានចូលទៅក្រាបទូលព្រះសាស្តា ថា "បពិត្រព្រះអង្គដ៏ចំរើន ធម្មិកឧបាសកពេលដែលខ្ញុំព្រះករុណាទាំងឡាយ កំពុងសូត្រធម្មិសតិបដ្ឋានសូត្រនោះ គាត់បាននិយាយប្រាប់ ឲ្យខ្ញុំព្រះករុណាទាំងឡាយ ឈប់សូត្រធម្មិសតិបដ្ឋានសូត្រ" ។*

*ព្រះសាស្តា ទ្រង់ត្រាស់ពន្យល់ នូវរឿងធម្មិកឧបាសកនោះ ឲ្យភិក្ខុទាំងនោះ បានយល់ច្បាស់ ហើយទ្រង់ត្រាស់ព្រះគាថានេះថា៖*

**ឥធ មោទតិ បេច្ច មោទតិ**
**កតបុញ្ញោ ឧភយត្ថ មោទតិ**
**សោ មោទតិ សោ បមោទតិ**
**ទិស្វា កម្មវិសុទ្ធិមត្តនោ ។**

*បុគ្គលអ្នកបានធ្វើបុណ្យទុកហើយ រមែងរីករាយ ក្នុងលោកទាំងពីរ គឺ រីករាយក្នុងលោកនេះផង ក្នុងលោកខាងមុខផង, បុគ្គលនោះ រមែងរីករាយ ស្រស់ស្រាយ ព្រោះបានឃើញនូវអំពើបរិសុទ្ធរបស់ខ្លួន ។*

## ១២- រឿងភិក្ខុទេវទត្ត

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធភិក្ខុទេវទត្ត ចាប់តាំងអំពីពេល*

## រឿងភិក្ខុទេវទត្ត

ដែលភិក្ខុទេវទត្ត ចូលមកបួសហើយ បានប្រព្រឹត្តធ្វើនូវអំពើអាក្រក់លាមក មានប្រការផ្សេងៗ ដូចមានតទៅនេះគឺ ៖

(១) បានបបួលព្រះរាជកុមារអជាតសត្រូវ ឲ្យទៅសម្លាប់ព្រះបាទពិម្ពិសារ ដែលត្រូវជាព្រះរាជបិតា របស់ទ្រង់ ។

(២) បានបញ្ជូនមនុស្ស ឲ្យទៅសម្លាប់ព្រះបរមសាស្តា តែពួកមនុស្សទាំងនោះ បានស្តាប់ព្រះធម៌ទេសនា របស់ព្រះអង្គហើយ ក៏បានសម្រេចនូវព្រះសោតាបត្តិផល គ្រប់ៗ គ្នា,

(៣) បានឡើងទៅ លើកំពូលភ្នំគិជ្ឈកូដ ហើយទម្លាក់ដុំថ្មចុះមក បានធ្វើលោហិតុប្បាទ ដល់ព្រះសាស្តា,

(៤) បានលែងដំរីនាឡាគិរី ដែលចុះប្រេង ឲ្យទៅធ្វើអន្តរាយដល់ព្រះសាស្តា តែមិនបានសម្រេចដូចគោលបំណងឡើយ,

(៥) បានប្រមូលពួកភិក្ខុ ៥០០ រូប ធ្វើសង្ឃភេទ គឺបំបែកសង្ឃ ។

ចំណេរកាលក្រោយមក ភិក្ខុទេវទត្ត មានជម្ងឺយ៉ាងធ្ងន់ អស់រយៈពេល ៩ ខែ, ទីបំផុត ភិក្ខុទេវទត្ត បានដឹងទោសកំហុសរបស់ខ្លួនហើយ មានសេចក្តីប្រាថ្នាចង់ទៅក្រាបថ្វាយបង្គំ សុំខមាទោសចំពោះព្រះភក្ត្រ នៃព្រះមានព្រះភាគ បានឲ្យកូនសិស្សសែងទៅ គាល់ព្រះអង្គ, ពេលដែលកូនសិស្សសែងទៅដល់មាត់ស្រះ ក្បែរវត្តជេតពន បានប្រាប់ឲ្យកូនសិស្សដាក់ចុះសិន ។ នៅពេលដែលភិក្ខុទេវទត្តដាក់ជើងចុះដល់ផែនដីភ្លាមនោះ ព្រះធរណី ក៏បានស្រូបយកភិក្ខុទេវទត្ត

លិចចូលបាត់ទៅ ក្នុងថ្ងៃនោះឯង ។

ភិក្ខុទាំងឡាយ បានក្រាបទូលសួរព្រះសាស្ដា ថា "បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុទេវទត្ត បានធ្វើបាបកម្ម ដ៏ធន់យ៉ាងនេះ តើនឹងទៅកើតនៅក្នុងទីណាដែរ?" ។

ព្រះសាស្ដា ទ្រង់ត្រាស់ ថា "ម្នាលភិក្ខុទាំងឡាយ ភិក្ខុទេវទត្តនឹងទៅកើត នៅក្នុងអវិចីនរក" ហើយទ្រង់ត្រាស់ព្រះគាថានេះ ថា ៖

ឥធ តប្បតិ បេច្ច តប្បតិ
បាបការី ឧភយត្ថ តប្បតិ
បាបំ មេ កតន្តិ តប្បតិ
ភិយ្យោ តប្បតិ ទុគ្គតឹ គតោ ។

បុគ្គលអ្នកធ្វើអំពើបាប រមែងក្ដៅក្រហាយ ក្នុងលោកទាំងពីរ គឺ ក្ដៅក្រហាយ ក្នុងលោកនេះផង ក្នុងលោកខាងមុខផង, បុគ្គលអ្នកធ្វើអំពើបាបនោះ រមែងក្ដៅក្រហាយ ដោយនឹកឃើញថា បាបអញបានធ្វើហើយ លុះធ្វើមរណកាលទៅកាន់ទុគ្គតិ រឹងរឹតតែក្ដៅក្រហាយក្រៃលែង ។

❋ ❋ ❋

## ១៣- រឿង នាងសុមនាទេវី

ព្រះបរមសាស្ដា ទ្រង់ប្រារព្ធនូវនាងសុមនាទេវី ជាធីតារបស់សេដ្ឋីឈ្មោះអនាថបិណ្ឌិក ។ នាងសុមនាទេវី បានសម្រេចសកទាគាមិផល តាំងតែអំពីនាងនៅជាកុមារីមកម្ល៉េះ, នាង មានជម្ងឺជាទម្ងន់

ហើយបានហៅអនាថបិណ្ឌិកសេដ្ឋី ថា ប្អូនប្រុស ។

អនាថបិណ្ឌិកសេដ្ឋី គិតថា "នាងសុមនាទេវីកូនស្រីពៅ ភ្លេចភ្លាំងសតិស្មារតី" ។ កាលបើនាងសុមនាទេវី បានធ្វើមរណកាលទៅហើយនោះ, លោកសេដ្ឋី មានទុក្ខទោមនស្ស សោកស្តាយ អាឡោះអាល័យកូនស្រីពៅខ្លាំងណាស់ ហើយបានចូលទៅ ក្រាបទូលរឿងនេះ ថ្វាយព្រះសាស្តា ទ្រង់ជ្រាប តាំងតែអំពីដើម រហូតដល់ចប់ ។

ព្រះសាស្តា ទ្រង់ត្រាស់រឿងពិត ថា "នែសេដ្ឋី នាងសុមនាទេវី មិនបានភ្លេចភ្លាំងសតិស្មារតីអ្វីទេ គឺ នាងហៅ ទៅតាមមគ្គផលទេតើ ព្រោះនាងជាសកទាគាមី, ឯលោកសេដ្ឋី ជាសោតាបន្ន" ។

អនាថបិណ្ឌិកសេដ្ឋីបានក្រាបទូលសួរព្រះសាស្តាថា "បពិត្រព្រះអង្គដ៏ចំរើន តើនាងសុមនាទេវី កូនស្រីពៅ របស់ទូលព្រះបង្គំបានទៅកើត នៅក្នុងទីណាដែរ?" ។

ព្រះសាស្តា ទ្រង់ត្រាស់ថា "នាងសុមនាទេវី បានទៅកើតនៅឯឋានតុសិតទេវលោកឯណោះហើយ" ស្រេចហើយ ទ្រង់ត្រាស់នូវព្រះគាថានេះថា ៖

ឥធ នន្ទតិ បេច្ច នន្ទតិ
កតបុញ្ញោ ឧភយត្ថ នន្ទតិ
បុញ្ញំ មេ កតន្តិ នន្ទតិ
ភិយ្យោ នន្ទតិ សុគតឹ គតោ ។

បុគ្គលអ្នកបានធ្វើបុណ្យទុកហើយ រមែងត្រេកអរ ក្នុងលោក

គាថាធម្មបទប្រែ

ទាំងពីរ គឺត្រេកអរក្នុងលោកនេះផង ត្រេកអរក្នុងលោកខាងមុខផង, បុគ្គលនោះ រមែងត្រេកអរ ដោយគិតឃើញថា បុណ្យអាត្មាអញបាន ធ្វើហើយ លុះធ្វើមរណកាលទៅកាន់សុគតិ ក៏រឹងរឹតតែត្រេកអរយ៉ាង ក្រៃលែង ។

♣ ❇ ♣

១៤- រឿងទេ្វសហាយកភិក្ខុ

ព្រះបរមសាស្តា ទ្រង់ប្រារព្ធភិក្ខុពីររូប ជាមិត្រសំឡាញ់នឹង គ្នា ។ ភិក្ខុមួយរូបបានរៀនខាងផ្នែកវិបស្សនាធុរៈ ខំបំពេញព្យាយាម យ៉ាងខ្លាំងក្លាបំផុត រហូតដល់បានសម្រេចអរហត្តផល, ចំណែកភិក្ខុ មួយរូបផ្សេងទៀត បានរៀនខាងគន្ថធុរៈ ជាអ្នកឈ្លាសវាងវៃ ក្នុង ព្រះត្រៃបិដក មានកូនសិស្សជាច្រើន ហើយបែរជាមើលងាយ ដល់ ភិក្ខុដែលរៀនខាងផ្នែកវិបស្សនាធុរៈ ថា "ជាអ្នកគ្មានចេះដឹងអ្វីបន្តិច បន្តួចសោះ" ហើយចង់ទៅសាកសួរបញ្ហា ជាមួយនឹងភិក្ខុដែលរៀន វិបស្សនាធុរៈនោះ ។

លុះដល់ថ្ងៃឆ្លើយបញ្ហា ព្រះសាស្តាទ្រង់ស្តេចយាងទៅ ក្នុងទី ប្រជុំនោះដែរ ហើយទ្រង់ត្រាស់សួរនូវបញ្ហា ដោយព្រះអង្គឯងផ្ទាល់ ជាមួយនឹងភិក្ខុដែលរៀនគន្ថធុរៈ ។ គន្ថធុរភិក្ខុនោះ ឆ្លើយបញ្ហា របស់ ព្រះសាស្តា ពុំបានឡើយ, ចំណែកវិបស្សនាធុរភិក្ខុ ឆ្លើយបញ្ហា របស់ ព្រះសាស្តាបានទាំងអស់ គ្មានទើសទាក់ឡើយ ។ ព្រះអង្គទ្រង់ប្រទាន សាធុការថា សាធុៗ ។

# រឿងទេ្វសហាយកភិក្ខុ

*ពួកភិក្ខុជាសិស្ស របស់ភិក្ខុអ្នករៀនគន្ថធុរៈ បានឮព្រះបរម-សាស្ដា ប្រទានសាធុការ ដល់ភិក្ខុអ្នករៀនវិបស្សនាធុរៈ យ៉ាងនេះហើយ ក៏នាំគ្នារិះគន់ព្រះអង្គ ថា "ចុះហេតុអ្វី? បានជាព្រះសាស្ដាទ្រង់ប្រទានសាធុការ ដល់ភិក្ខុដែលរៀនវិបស្សនាធុរៈ ជាអ្នកមិនចេះដឹងអ្វីបន្តិចសោះ យ៉ាងនេះទៅវិញហ្នំ ម្ដេចក៏មិនទ្រង់ប្រទាន ដល់ភិក្ខុដែលចេះព្រះត្រៃបិដក? ព្រះអង្គទ្រង់ធ្វើដូច្នេះ មិនត្រឹមត្រូវទាល់តែសោះឡើយ" ។*

*ព្រះសាស្ដា ទ្រង់បានត្រាស់ នូវព្រះគាថានេះ ថា ៖*

ពហុម្បិ ចេ សហិតំ ភាសមានោ
ន តក្ករោ ហោតិ នរោ បមត្តោ
គោបោវ គាវោ គណយំ បរេសំ
ន ភាគវា សាមញ្ញស្ស ហោតិ ។
អប្បម្បិ ចេ សហិតំ ភាសមានោ
ធម្មស្ស ហោតិ អនុធម្មចារី
រាគញ្ច ទោសញ្ច បហាយ មោហំ
សម្មប្បជានោ សុវិមុត្តចិត្តោ
អនុបាទិយានោ ឥធ វា ហុរំ វា
ស ភាគវា សាមញ្ញស្ស ហោតិ ។

*បើនរជន ពោលពាក្យប្រកបដោយប្រយោជន៍ សូម្បីច្រើនយ៉ាងណាក៏ដោយ តែជាអ្នកប្រមាទ មិនធ្វើតាមពាក្យនោះ រមែងជា*

-២៩-

គាថាធម្មបទ ប្រែ

*អ្នកមិនមានចំណែកសាមញ្ញផលឡើយ ដូចជាអ្នករក្សាគោ កាលរាប់គោ ប្រគល់ឲ្យអ្នកដទៃហើយ ( ជាអ្នកមិនបានបរិភោគ នូវបញ្ចគោរស ) ដូច្នោះឯង ។*

*ផ្ទុយទៅវិញ បើនរជន ពោលពាក្យប្រកបដោយប្រយោជន៍ សូម្បីតែបន្តិចបន្តួច តែជាអ្នកប្រព្រឹត្តធម៌សមគួរដល់ធម៌ បានលះបង់ចោល នូវរាគៈ ទោសៈ និង មោហៈ ជាអ្នកដឹងនូវធម៌ ដែលគួរកំណត់តាមហេតុ មានចិត្តដកផុតអំពីសេចក្តីសៅហ្មង មិនមានសេចក្តីប្រកាន់មាំ ក្នុងលោកនេះ និង លោកខាងមុខ នរជននោះរមែងជាអ្នកបានចំណែកសាមញ្ញផលមែនពិត ។*

ចប់ យមកវគ្គ ទី ១

**ចប់ គាថាធម្មបទ ប្រែ**
**ភាគ ទី ១**

សូមសិក្សា ភាគ ទី២ បន្តទៅទៀត

# គាថាធម្មបទប្រែ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ភាគ ទី ២

អប្បមាទវគ្គ ទី ២

១៥- រឿង ព្រះនាងសាមាវតី

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធសេចក្តីស្លាប់របស់ស្រ្តីពីរពួក គឺ ពួកនាងសាមាវតី ១ ពួកនាងមាគន្ទិយា ១ ។ នាងសាមាវតី និង នាងមាគន្ទិយា ទាំងពីរនាក់នេះ គឺជាមហេសី របស់ព្រះរាជា ទ្រង់ព្រះនាមឧទេន នៅក្នុងក្រុងកោសម្ពី ។*

*សម័យនោះ ព្រះសាស្តា ទ្រង់គង់ចាំព្រះវស្សានៅ ក្នុងក្រុងកោសម្ពីនោះដែរ ។ ពួកនាងសាមាវតី បានសម្រេចសោតាបត្តិផល, ចំណែកឯ ពួកនាងមាគន្ទិយា មិនបានសម្រេចផលអ្វីទេ ថែមទាំងមិនមានចិត្តជ្រះថ្លា ចំពោះព្រះសាស្តាទៀតផង គិតតែពីរករឿងហេតុប្រទូសរ៉ាយ ចំពោះព្រះសាស្តា និង ព្រះនាងសាមាវតី ដោយប្រការផ្សេងៗ ដូចជាជួលមនុស្ស ឲ្យទៅស្រែកជេរព្រះអង្គ ប្រើមនុស្សឲ្យទៅលួចដុតប្រាសាទ របស់នាងសាមាវតីជាដើម ។*

*ពេលនោះ ព្រះនាងសាមាវតី ព្រមទាំងស្រីស្នំ ត្រូវភ្លើងឆេះស្លាប់ទាំងអស់គ្នា គ្មានសល់ម្នាក់ឡើយ ។*

*ព្រះបាទឧទេន ទ្រង់បានជ្រាបហើយ ទើបទ្រង់ស្វះស្វែងរកឧបាយកល ដើម្បីនឹងរកហេតុផល ចាប់អ្នកដែលបានដុតប្រាសាទ*

នោះ ឲ្យទាល់តែបាន លុះទ្រង់ជ្រាបច្បាស់ហើយ ទើបទ្រង់ត្រាស់បញ្ជា ប្រើឲ្យពួកអាមាត្យ ជីកនូវអន្លង់ កប់ក្រុមបក្សពួក របស់នាងមាគន្ទិយា ត្រឹមផ្ចិត ហើយឲ្យយកក្រឹងជុតទាំងរស់ រួចហើយឲ្យយកនង្គ័លរនាស់ដែក ភ្ជួររាស់ថែមពីលើទៀត ។ សម្រាប់នាងមាគន្ទិយាវិញ ព្រះរាជាទ្រង់ត្រាស់បញ្ជា ឲ្យរាជអាមាត្យ អារសាច់នាងម្តងមួយដុំៗ យកទៅចៀនខ្លាញ់ ឲ្យឆ្អិនហើយ ត្រាស់ឲ្យយកសាច់ចៀននោះទៅឲ្យនាងមាគន្ទិយាស៊ី រហូតដល់នាងស្លាប់តែម្តង ។

ភិក្ខុទាំងឡាយ បានប្រជុំ សន្ទនាគ្នាអំពីរឿងនាងមាគន្ទិយា និង នាងសាមាវតី ដោយប្រការផ្សេងៗ ។

ព្រះសាស្តា ទ្រង់ជ្រាបហើយទ្រង់ត្រាស់នូវព្រះគាថានេះថា៖

អប្បមាទោ អមតំ បទំ　　បមាទោ មច្ចុនោ បទំ
អប្បមត្តា ន មីយន្តិ　　យេ បមត្តា យថា មតា
ឯតំ វិសេសតោ ញត្វា　　អប្បមាទម្ហិ បណ្ឌិតា
អប្បមាទេ បមោទន្តិ　　អរិយានំ គោចរេ រតា
តេ ឈាយិនោ សាតតិកា　　និច្ចំ ទឡ្ហបរក្កមា
ផុស្សន្តិ ធីរា និព្វានំ　　យោគក្ខេមំ អនុត្តរំ ។

សេចក្តីមិនប្រមាទ ជាផ្លូវនៃសេចក្តីមិនស្លាប់ សេចក្តីប្រមាទជាផ្លូវនៃសេចក្តីស្លាប់, ជនទាំងឡាយ ដែលមិនប្រមាទហើយ ឈ្មោះថា មិនស្លាប់, ជនទាំងឡាយ ដែលប្រមាទហើយ ទុកដូចជាមនុស្សដែលស្លាប់ទៅហើយ ។ ពួកបណ្ឌិត បានជ្រាបនូវដំណើរនេះ ដោយ

ប្លែកគ្នា (ទើបឋិតនៅ) ក្នុងសេចក្ដីមិនប្រមាទ រីករាយ ក្នុងសេចក្ដីមិនប្រមាទ, បណ្ឌិតទាំងនោះ ជាអ្នកត្រេកអរហើយ ក្នុងធម៌ជាគោចរ នៃព្រះអរិយបុគ្គលទាំងឡាយ មានការពិនិត្យជាប្រក្រតី មានព្យាយាមជាប់តគ្នា មានសេចក្ដីប្រឹងប្រែងមាំមួនជានិច្ច ជាអ្នកមានប្រាជ្ញា តែងប៉ះពាល់នូវព្រះនិព្វាន ជាទីក្សេមក្សាន្តចាកយោគៈ ជាគុណជាត ដ៏ប្រសើរបំផុត ។

## ១៦- រឿង កុម្ភឃោសកសេដ្ឋី

ព្រះបរមសាស្ដា ទ្រង់ប្រារព្ធកុម្ភឃោសកសេដ្ឋី ជាកូនរបស់សេដ្ឋី ក្រុងរាជគ្រឹះ ។ កាលអហិវាតករោគកើតឡើងហើយ ដល់សេដ្ឋីជាបិតា, សេដ្ឋីបុត្រនោះ ក៏បានរត់គេចខ្លួនគេចចេញពីអហិ-វាតករោគនោះ ទៅរស់នៅ ក្នុងស្រុកមួយ លុះរស់នៅ ក្នុងស្រុកនោះបាន ១២ ឆ្នាំហើយ ក៏បានត្រឡប់មករកស្រុកកំណើតរបស់ខ្លួនវិញ ។ ក្នុងគ្រានោះ គ្មានបុគ្គលណាមួយ ចាំមុខសេដ្ឋីបុត្រនោះ បានឡើយ ព្រោះសេដ្ឋីបុត្រនោះ ទៅរស់នៅស្រុកគេ អស់ពេលជាច្រើនឆ្នាំមកហើយ ។

សម័យថ្ងៃមួយ កុម្ភឃោសកៈ គិតនឹងជីកយកកំណប់ទ្រព្យដែលខ្លួនបានកប់ទុកអំពីពេលមុន យកមកប្រើប្រាស់ តែខ្លាចក្រែងមានសេចក្ដីអន្តរាយកើតឡើងដល់ខ្លួន ទើបបានបន្ទំខ្លួនធ្វើជាអ្នកស៊ីឈ្នួលគេ ដើម្បីយកប្រាក់មកចិញ្ចឹមជីវិត ធ្វើហាក់ដូចជាមនុស្សអ្នក

កំសត់ទុគ៌ិត ។

គ្រានោះ ព្រះរាជា ទ្រង់ព្រះនាមពិម្ពិសារ ទ្រង់ព្រះសណ្ដាប់សម្ដេងរបស់កុម្ភឃោសកៈនោះហើយ ទ្រង់ជ្រាបថា “បុរសនេះ ពិតជាអ្នកមានទ្រព្យសម្បត្តិច្រើន” ហើយទ្រង់ស្រាវជ្រាវរកការពិត លុះទ្រង់ជ្រាបច្បាស់ហើយ ទ្រង់បានព្រះរាជទាន នូវតំណែងជាសេដ្ឋី និងព្រះរាជធីតា របស់ព្រះអង្គ ឲ្យដល់កុម្ភឃោសកៈជាមហេសី ។

ក្រោយមក ព្រះបាទពិម្ពិសារ ទ្រង់បាននាំកុម្ភឃោសកសេដ្ឋីទៅ ក្រាបថ្វាយបង្គំគាល់ព្រះសាស្ដា ស្រេចហើយក្រាបទូលនូវគុណសម្បត្តិ របស់កុម្ភឃោសកសេដ្ឋី ថ្វាយដល់ព្រះអង្គទ្រង់ជ្រាប ។

ព្រះសាស្ដា ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

**ឧដ្ឋានវតោ សតីមតោ សុចិកម្មស្ស និសម្មការិនោ**
**សញ្ញតស្ស ច ធម្មជីវិនោ អប្បមត្តស្ស យសោ ភិវឌ្ឍតិ ។**

យស តែងចំរើនរុងរឿង ដល់បុគ្គលអ្នកដែលមានសេចក្ដីប្រឹងប្រែង មានស្មារតី មានការងារបរិសុទ្ធល្អ ជាអ្នកពិចារណារួចហើយទើបធ្វើ ជាអ្នកសង្រួម រស់នៅដោយធម៌ ជាអ្នកមិនប្រមាទ ។

❊ ❊

១៧- រឿងព្រះចូឡបន្ថកត្ថេរ

ព្រះបរមសាស្ដា ទ្រង់ប្រារព្ធ នូវព្រះចូឡបន្ថកត្ថេរ ។ ក្នុងសាសនាព្រះពុទ្ធទ្រង់ព្រះនាមកស្សបៈ ព្រះថេរៈអង្គនេះ ជាអ្នកមានប្រាជ្ញាច្រើន ពេលថ្ងៃមួយ លោកបានឃើញ នូវភិក្ខុមួយរូបដែលមាន

## រឿងព្រះចូឡបន្ថកត្ថេរ

ប្រាជ្ញាតិច ហើយក៏បានសើចចំអកឲ្យ រហូតដល់ភិក្ខុរូបនោះ មានសេចក្តីអៀនខ្មាស ឈប់រវល់នឹងការរៀនធម៌ បន្តទៅទៀត... ព្រោះទោសនៃការសើចចំអកនេះឯង ទើបមកដល់ជាតិនេះ បានមកកើតជាព្រះចូឡបន្ថកៈ ទន្ទេញធម៌មិនចេះចាំ ទាល់តែសោះ សូម្បីតែព្រះគាថាមួយបទ ដែលព្រះមហាបន្ថកៈជាបងប្រុសដាក់ឲ្យទន្ទេញ អស់រយៈពេល ៤ ខែ ក៏ទន្ទេញមិនចាំដែរ ។

ព្រះមហាបន្ថកត្ថេរ ជាបង បានជេរស្តីបន្ទោស នូវព្រះចូឡ-បន្ថកត្ថេរ ដោយប្រការផ្សេងៗ ធ្វើឲ្យព្រះចូឡបន្ថកត្ថេរ មានសេចក្តីអាក់អន់ស្រពន់ចិត្ត យ៉ាងខ្លាំង ចំពោះវាសនារបស់ខ្លួនឯង ហើយគិតនឹងលាចាកសិក្ខាបទ ។

ព្រះសាស្តា ទ្រង់ជ្រាបហើយ ទ្រង់ប្រទានព្រះកម្មដ្ឋាន និងប្រទានឱវាទដល់លោក រហូតដល់បានសម្រេចព្រះអរហត្តផល ។

សម័យថ្ងៃមួយ ពួកភិក្ខុទាំងឡាយ បានប្រជុំព្រមគ្នា សន្ទនាពោលសរសើរអំពីសេចក្តីព្យាយាម របស់ព្រះចូឡបន្ថកត្ថេរ ។

ព្រះសាស្តា ទ្រង់ជ្រាបហើយ ទ្រង់ត្រាស់ព្រះគាថានេះថា ៖

**ឧដ្ឋានេនប្បមាទេន សញ្ញមេន ទមេន ច**
**ទីបំ កយិរាថ មេធាវី យំ ឱឃោ នាភិកីរតិ ។**

ទឹកជំនន់គឺកិលេស ជន់ពន្លិចកោះ គឺអរហត្តផល ណាពុំបាន, អ្នកប្រាជ្ញ គប្បីសាងកោះ គឺអរហត្តផលនោះ ដោយសេចក្តីប្រឹងប្រែងផង ដោយសេចក្តីមិនប្រមាទផង ដោយការសង្រួម ក្នុង

ចតុប្បារិសុទ្ធិសីលផង ដោយការទូន្មានឥន្ទ្រីយ៍ផង ។

♣ ❇ ♣

## ១៨- រឿងពាលនក្ខត្រ

ព្រះបរមសាស្ដា ទ្រង់ប្រារព្ធនក្ខត្តឫក្ស របស់ពួកជនពាល ។ ថ្ងៃមួយ ពួកជនពាលទាំងឡាយ បាននាំគ្នាលេងនក្ខត្តឫក្សផ្សេងៗ ដែលជាល្បែងមិនសមរម្យ មិនគួរគេប្បីនឹងទស្សនា មិនគួរស្ដាប់ និងមិនជាទីត្រេកអរពេញចិត្ត ដល់ព្រះអរិយសាវកទាំងឡាយ ។

ពួកអរិយសាវកទាំងឡាយ បានធ្វើជាព័ត៌មានមួយ ផ្ញើទៅថ្វាយ ដល់ព្រះសាស្ដា មានសេចក្ដីថា “បពិត្រព្រះអង្គដ៏ចំរើន សូមព្រះអង្គ ព្រមទាំងភិក្ខុសង្ឃ ប្រថាប់គង់នៅក្នុងព្រះវិហារសិនចុះ សូមកុំទាន់អាលនិមន្តចេញទៅខាងក្រៅឲ្យសោះ” ហើយក៏បាននាំគ្នាចាត់ចែងរៀបចំនូវភត្តាហារ ទៅថ្វាយដល់ព្រះអង្គ ព្រមទាំងភិក្ខុសង្ឃនៅឯវត្ត ។

លុះកន្លងទៅបាន ៧ ថ្ងៃ ការលេងនក្ខត្តឫក្ស របស់ពួកជនពាលទាំងនោះ ក៏បានចប់ឈប់លេងដែរ ។

អរិយសាវកទាំងឡាយ បានក្រាបទូលអំពីការលេងនក្ខត្ត-ឫក្សនោះ ថ្វាយដល់ព្រះសាស្ដា ទ្រង់ជ្រាប ។

ព្រះសាស្ដា ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

**បមាទមនុយុញ្ជន្តិ ពាលា ទុម្មេធិនោ ជនា**
**អប្បមាទញ្ច មេធាវី ធនំ សេដ្ឋំវ រក្ខតិ ។**

រឿង ព្រះមហាកស្សបត្ថេរ

មា បមាទមនុយុញ្ជេថ មា កាមរតិសន្ថវំ
អប្បមត្តោ ហិ ឈាយន្តោ បប្បោតិ វិបុលំ សុខំ ។

*ពួកជនពាល អប្បឥតប្រាជ្ញា តែងប្រកបរឿយៗ នូវសេចក្តីប្រមាទ ចំណែកអ្នកប្រាជ្ញ រមែងរក្សាទុក នូវសេចក្តីមិនប្រមាទ ដូចបុគ្គលរក្សាទ្រព្យដ៏ប្រសើរ យ៉ាងនោះឯង ។ អ្នកទាំងឡាយ ចូរកុំប្រកបរឿយៗ នូវសេចក្តីប្រមាទ ចូរកុំប្រកបរឿយៗ នូវសេចក្តីរីករាយត្រេកអរ ក្នុងកាមឡើយ ដ្បិតបុគ្គលមិនប្រមាទ ខំសង្កេតពិនិត្យ តែងបានសុខដ៏ទូលាយ ។*

១៩- រឿង ព្រះមហាកស្សបត្ថេរ

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធព្រះមហាកស្សបត្ថេរ ។ ថ្ងៃមួយព្រះថេរៈ បានគង់ប្រមើលមើល នូវពួកសត្វទាំងឡាយដែលកំពុងតែច្យុត និង បដិសន្ធិ ដោយទិព្វចក្ខុ ។*

*ព្រះសាស្តា ទ្រង់ជ្រាបនូវហេតុនោះហើយ ទើបទ្រង់បានត្រាស់ហាម ថា “ម្នាលកស្សបៈ នេះមិនមែនជាវិស័យ របស់អ្នកទេ, វិស័យរបស់អ្នក គឺជាអ្នកដែលមិនប្រមាទទេតើ, ការដឹង និង ការឃើញពួកសត្វដែលច្យុត និង បដិសន្ធិ នេះ ជាវិស័យរបស់ព្រះពុទ្ធគ្រប់ព្រះអង្គ” ដូច្នេះហើយ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

បមាទំ អប្បមាទេន យទា នុទតិ បណ្ឌិតោ
បញ្ញាបាសាទមារុយ្ហ អសោកោ សោកិនឹ បជំ

## គាថាធម្មបទប្រែ

**បមាទំ អប្បមាទេន យទា នុទតិ បណ្ឌិតោ ។**

**បញ្ញាបាសាទមារុយ្ហ អសោកោ សោកិនឹ បជំ ។**

**បព្វតដ្ឋោវ ភុម្មដ្ឋេ ធីរោ ពាលេ អវេក្ខតិ ។**

*ពេលណា បណ្ឌិត បន្ទោបង់នូវសេចក្តីប្រមាទ ដោយសេចក្តីមិនប្រមាទ ពេលនោះ លោកនឹងឡើងកាន់ប្រាសាទគឺបញ្ញា ជាបុគ្គលមិនសោក រមែងឃើញពួកសត្វដែលមានសេចក្តីសោក, ធីរជន តែងឃើញ នូវពួកជនពាល ដូចបុគ្គលដែលឈរ លើកំពូលភ្នំហើយក្រឡេកឃើញពួកជន ដែលឋិតនៅលើផែនដី ដូច្នោះឯង ។*

♣ ♣ ♣

## ២០- រឿងសហាយកភិក្ខុ

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធភិក្ខុពីររូប ដែលជាមិត្តសំឡាញ់នឹងគ្នា ។ ភិក្ខុទាំងពីររូបនេះ បានរៀនកម្មដ្ឋាន ក្នុងសំណាក់ នៃព្រះសាស្តា ហើយក្រាបថ្វាយបង្គំលាព្រះអង្គទៅបំពេញសមណធម៌ នៅក្នុងវត្តមួយ ដែលនៅក្នុងព្រៃ ។*

*បណ្តាភិក្ខុទាំងពីររូបនោះ ភិក្ខុមួយរូប មានសេចក្តីព្យាយាមមិនប្រមាទ ខិតខំបំពេញសមណធម៌ជាប់ជានិច្ច មិនយូរប៉ុន្មាន ក៏បានសំរេចព្រះអរហត្តផល ព្រមទាំងបដិសម្ភិទាទាំងឡាយ ។*

*ចំណែកភិក្ខុមួយរូបទៀត លោកមិនបានធ្វើអ្វីបន្តិចសោះ គិតតែពីនិយាយគ្នាលេងសប្បាយ ជាមួយនឹងពួកភិក្ខុសាមណេរផងគ្នាផ្សេងៗ ទៀត បានត្មះតិះដៀលភិក្ខុដែលបានខិតខំចំរើនសមណធម៌នោះ ថា “ភិក្ខុ អង្គនេះ ជាអ្នកខ្ជិលច្រអូសណាស់ មិនចេះគិតធ្វើអ្វីនឹងគេសោះឡើយ” ។*

## រឿងសក្កទេវរាជ

លុះបវារណាចេញវស្សាហើយ ពួកភិក្ខុទាំងអស់នោះ បាន នាំគ្នាទៅក្រាបថ្វាយបង្គំព្រះសាស្ដា ។ ភិក្ខុ ដែលខ្ជិលច្រអូស បាន ក្រាបទូលអំពីរឿងភិក្ខុដែលបានសម្រេច នូវព្រះអរហត្តផល ដល់ ព្រះសាស្ដា ថា "ជាអ្នកខ្ជិលច្រអូសណាស់" ហើយបាននិយាយអួត លើកខ្លួនឯង ថា "ជាអ្នកមិនប្រមាទ មិនខ្ជិលច្រអូស ខិតខំរកឧស មកដុត ទាំងព្រឹកល្ងាច គ្មានបានឈប់សម្រាកឡើយ" ។ ព្រះសាស្ដា ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

**អប្បមត្តោ បមត្តេសុ សុត្តេសុ ពហុជាគរោ**
**អពលស្សំវ សីឃស្សោ ហិត្វា យាតិ សុមេធសោ ។**

បណ្ឌិត មានប្រាជ្ញាមុះមុត កាលពួកបុគ្គលកំពុងតែប្រមាទ លោកមិនប្រមាទ កាលពួកបុគ្គលកំពុងតែដេកលក់ លោកភ្ញាក់រឭក ច្រើន លោកលះបង់ចោលនូវបុគ្គលបែបនោះ ដូចជាសេះដែលមាន ល្បឿនលឿន បោលឈ្នះនូវសេះដែលមានកម្លាំងទន់ខ្សោយ យ៉ាង ដូច្នោះឯង ។

♣ ❇ ♣

## ២១- រឿងសក្កទេវរាជ

ព្រះបរមសាស្ដា ទ្រង់ប្រារព្ធនូវស្ដេចសក្កទេវរាជ ។ សម័យ ថ្ងៃមួយ ក្សត្រលិច្ឆវី ព្រះនាមមហាលី ទ្រង់ព្រះសណ្ដាប់ នូវសក្ក- បញ្ហាសូត្រ ក៏កើតមានសេចក្ដីសង្ស័យ ហើយទ្រង់យាងចូលទៅគាល់ ព្រះពុទ្ធជាម្ចាស់ ស្រេចហើយ ក៏បានក្រាបទូលសួរថា "បពិត្រព្រះ

អន្តជីចំរើន តើព្រះអង្គទ្រង់បានទតព្រះនេត្រឃើញ ទ្រង់បានស្គាល់ច្បាស់នូវសក្កទេវរាជ ដែរឬទេ?" ។

ព្រះសាស្តា ទ្រង់ត្រាស់ឆ្លើយថា "តថាគត ពិតជាបានឃើញ បានស្គាល់សក្កទេវរាជ ច្បាស់ណាស់ ហើយថែមទាំងដឹង នូវធម៌ដែលធ្វើឲ្យកើតទៅជាសក្កទេវរាជទៀតផង, សក្កទេវរាជ មានឈ្មោះថា "**មឃវា**" ព្រោះកាលនៅជាមនុស្ស មានឈ្មោះថា មឃមាណព, មានឈ្មោះថា "**បុរិន្ទ:**" ព្រោះកាលនៅជាមនុស្ស បានផ្តើមធ្វើបុណ្យមុនជន ៣០ នាក់, មានឈ្មោះថា "**វាសវ:**" ព្រោះកាលនៅជាមនុស្ស បានឲ្យនូវទីនៅ ទីសំណាក់អាស្រ័យ, មានឈ្មោះថា "**សហស្សក្ខ:**" ព្រោះទ្រង់ព្រះតម្រិះ ក្នុងមួយប្រប្រិចភ្នែក បានមួយពាន់រឿង, មានឈ្មោះថា "**សុជម្បតី**" ព្រោះបាននាងសុជាតាដែលជាធីតា របស់អសុរ ជាព្រជះយា ។ វត្តបទ គឺ ធម៌ដែលធ្វើឲ្យកើតជាសក្កទេវរាជ មាន ៧ ប្រការ គឺ ៖

១- ចិញ្ចឹមមាតាបិតា,

២- គោរពចាស់ទុំ ក្នុងត្រកូល,

៣- មានវាចាដ៏ពីរោះ,

៤- មិននិយាយចាក់ដោត,

៥- មិនកំណាញ់,

៦- ជាអ្នក មានសច្ច:,

៧- ជាអ្នកមិនចេះក្រោធខឹង ។

## រឿងអញ្ញាត្រភិក្ខុ

*សក្កទេវរាជ មិនប្រមាទ ញ៉ាំងវត្តបទទាំង ៧ ប្រការនេះ ឲ្យពេញបរិបូណ៌ហើយ ទើបបានសម្រេចជាសក្កទេវរាជ" ដូច្នេះហើយ នៅទីបញ្ចប់ ព្រះអង្គទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

**អប្បមាទេន មឃវា ទេវានំ សេដ្ឋតំ គតោ**
**អប្បមាទំ បសំសន្តិ បមាទោ គរហិតោ សទា ។**

*មឃមាណព បានដល់នូវភាពជាអ្នកប្រសើរបំផុត ជាងទេវតាទាំងឡាយ ព្រោះសេចក្តីមិនប្រមាទ, អ្នកប្រាជ្ញទាំងឡាយតែងសរសើរនូវសេចក្តីមិនប្រមាទ, សេចក្តីប្រមាទ បណ្ឌិតលោកតិះដៀលគ្រប់ពេល ។*

❋ ❋ ❋

## ២២- រឿងអញ្ញាត្រភិក្ខុ

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវភិក្ខុមួយរូប ដែលបានរៀននូវកម្មដ្ឋាន នៅក្នុងសំណាក់ នៃព្រះពុទ្ធជាម្ចាស់ ហើយបានក្រាបថ្វាយបង្គំលាព្រះអង្គ ទៅបំពេញសមណធម៌ នៅក្នុងព្រៃដែលស្ងាត់មួយកន្លែង ។*

*ភិក្ខុរូបនោះ ទោះបីជាខិតខំបំពេញកម្មដ្ឋាន ដ៏ខ្លាំងក្លា យ៉ាងណាក៏ដោយ ក៏នៅតែមិនបានសម្រេចព្រះអរហត្តផល ដូចក្តីប្រាថ្នាដែរ ក្រោយមក លោកគិតត្រឡប់មកគាល់ព្រះសាស្តាវិញ ដើម្បីនឹងទូលសុំផ្លាស់កម្មដ្ឋានសាជាថ្មី លុះមកដល់ពាក់កណ្តាលផ្លូវ ក៏ស្រាប់តែឃើញនូវភ្លើងព្រៃកំពុងឆេះ ក៏បានកំណាត់យកភ្លើងនោះ មកធ្វើជា*

អារម្មណ៍ ថា "ភ្លើងនេះ ឆេះកំទេចព្រៃបាន យ៉ាងណា, ភ្លើង គឺអរិយ-មគ្គញ្ញាណ ក៏ដុតបំផ្លាញ នូវសំយោជនៈ តូចធំបាន យ៉ាងនោះដែរ" ។

ព្រះសាស្តា ទ្រង់ជ្រាបហើយ ទ្រង់បានបញ្ចេញព្រះរស្មីទៅរកភិក្ខុនោះ បីដូចជាទ្រង់ប្រថាប់គង់ នៅត្រង់ទីចំពោះមុខ នៃភិក្ខុរូបនោះ ហើយទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

**អប្បមាទរតោ ភិក្ខុ បមាទេ ភយទស្សិ វា**
**សញ្ញោជនំ អណុំ ថូលំ ឌហំ អគ្គីវ គច្ឆតិ ។**

ភិក្ខុអ្នកត្រេកអរ ក្នុងសេចក្តីមិនប្រមាទ ឬ ឃើញភ័យ ក្នុងសេចក្តីប្រមាទ រមែងដុតចោលនូវសំយោជនៈ ទាំងតូចទាំងធំបាន ដូចភ្លើងឆេះ (រាលនូវកំទេចទាំងតូចទាំងធំ) យ៉ាងដូច្នោះឯង ។

## ២៣- រឿង ព្រះនិគមតិស្សត្ថេរ

ព្រះបរមសាស្តា ទ្រង់ប្រារព្ធព្រះនិគមតិស្សត្ថេរ ។ ព្រះថេរៈជាអ្នកមានសេចក្តីប្រាថ្នាតិច និង សន្តោស នៅពេលដែលអនាថ-បិណ្ឌិកសេដ្ឋី ថ្វាយមហាទានក្តី និង ព្រះបាទបសេនទិកោសល ទ្រង់ថ្វាយអសទិសទានក្តី ក៏លោកមិនព្រមនិមន្តទៅទទួលដែរ បែរជានិមន្តទៅបិណ្ឌបាត្រ តាមផ្ទះទៅវិញ បានយ៉ាងណា ឆាន់យ៉ាងនោះ ។ ពួកភិក្ខុទាំងឡាយ បានចោទដល់ព្រះថេរៈថា "ជាអ្នកជាប់ជំពាក់ ក្នុងពួកញាតិញោម" ។

ព្រះសាស្តា ទ្រង់ត្រាស់បញ្ជាឲ្យភិក្ខុទៅនិមន្តលោកមក ដើម្បី

រឿង ព្រះមេឃិយត្ថេរ

ត្រាស់សួររឿងពិត ។ ព្រះថេរៈ បានក្រាបទូល នូវភាពនៃខ្លួនជាអ្នកប្រាថ្នាតិច និង សន្ដោស ថ្វាយព្រះអង្គទ្រង់បានជ្រាប ។

ព្រះពុទ្ធអង្គ ទ្រង់ត្រាស់អនុមោទនា ហើយទ្រង់បានត្រាស់សរសើរថា "នេះគឺជាប្រពៃណី របស់ព្រះអង្គ ដែលទ្រង់ធ្លាប់បានប្រព្រឹត្តមក" រួចហើយទ្រង់ត្រាស់សំដែងនូវអតីតនិទាន របស់ព្រះអង្គដែលបានយោនយកកំណើតកើតជាសត្វសេក ឈ្មោះសុវរាជ ក៏មានសេចក្ដីប្រាថ្នាតិច និង សន្ដោស ដូចជាព្រះថេរៈនេះដែរ នៅទីបញ្ចប់នៃអតីតនិទាន ព្រះអង្គទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

**អប្បមាទរតោ ភិក្ខុ  បមាទេ ភយទស្សិ វា**
**អភព្វោ បរិហានាយ  និព្វានស្សេវ សន្តិកេ ។**

ភិក្ខុអ្នកត្រេកអរ ក្នុងសេចក្ដីមិនប្រមាទ ឬ ឃើញភ័យ ក្នុងសេចក្ដីប្រមាទ ជាអ្នកមិនគួរនឹងសាបសូន្យចាកគុណធម៌ ឈ្មោះថាស្ថិតនៅ ក្នុងទីជិតបង្កើយនៃព្រះនិព្វាន ។

**ចប់ អប្បមាទវគ្គ ទី ២**

បិត្តវគ្គ ទី៣

២៤- រឿង ព្រះមេឃិយត្ថេរ

ព្រះបរមសាស្ដា ទ្រង់ប្រារព្ធនូវព្រះមេឃិយត្ថេរ នៅពេលដែលព្រះថេរៈកំពុងធ្វើជាព្រះឧបដ្ឋាកនៅឡើយ ។ សម័យថ្ងៃមួយព្រះថេរៈ បាននិមន្តទៅឃើញនូវអម្ពវន្តស្ថាន ជាកន្លែងដែលគួរជាទី

វីកវាយពេញចិត្ត ហើយបានក្រាបថ្វាយបង្គំសុំលាព្រះអង្គ ដើម្បីទៅបំពេញសមណធម៌ នៅក្នុងទីនោះ ។

ព្រះសាស្តា ទ្រង់ត្រាស់ហាមថា "កុំទាន់អាលនិមន្តទៅធ្វើអ្វី បង្អង់រង់ចាំ នៅពេលណាដែលរកភិក្ខុ ដែលជាអ្នកឧបដ្ឋាកថ្មី បានជាមុនសិន ហើយសឹមនិមន្តទៅបំពេញសមណធម៌ចុះ" ។

ព្រះមេឃិយៈ មិនព្រមស្តាប់ព្រះតម្រាស់របស់ព្រះអង្គឡើយ ថែមទាំងបានពោលពាក្យទ្រគោះបោះបោក ទៅរកព្រះអង្គថា "តើធ្វើដូចម្តេចទៅបាន បើព្រះអង្គទ្រង់បានសម្រេចកិច្ចអស់ហើយនោះ តែទូលព្រះបង្គំវិញនោះ មិនទាន់បានសម្រេចគុណធម៌អ្វីទេ កំពុងតែប្រតិបត្តិនៅឡើយ នឹងធ្វើឲ្យដូចជាព្រះអង្គ យ៉ាងណាបាន" ហើយក៏និមន្តទៅទីនោះតែម្តង មិនយូរប៉ុន្មាន ក៏ត្រូវអកុសលវិត្តកៈ គ្របសង្កត់ យ៉ាងខ្លាំង ទ្រាំពុំបាន ទើបបានត្រឡប់មក ក្រាបទូលរឿងនោះថ្វាយដល់ព្រះអង្គទ្រង់ជ្រាប ។

ព្រះសាស្តាទ្រង់ត្រាស់ថា "នែមេឃិយៈ ធម្មតាចិត្តនេះ ជាធម្មជាត ដែលត្រាច់រង្គាត់ទៅបានឆ្ងាយណាស់, ការអប់រំទូន្មានចិត្តឲ្យស្ថិតនៅ ក្នុងអំណាចរបស់ខ្លួនបាន គឺជាការប្រសើរពេកណាស់" ដូច្នេះហើយ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

ផន្ទនំ ចបលំ ចិត្តំ ទុរក្ខំ ទុន្និវារយំ
ឧជុំ ករោតិ មេធាវី ឧសុការោវ តេជនំ ។
វារិជោវ ថលេ ខិត្តោ ឱកមោកតឧព្ភតោ
បរិផន្ទតិទំ ចិត្តំ មារធេយ្យំ បហាតវេ ។

## រឿងអញ្ញត្រភិក្ខុ

អ្នកប្រាជ្ញ តែងធ្វើចិត្តដែលញាប់ញ័រ ឃ្លេងឃ្លោង រក្សាបានដោយកម្រ ហាមឃាត់បានដោយលំបាក ឲ្យជាចិត្តត្រង់បាន ដូចជាអ្នកធ្វើព្រួញ ពត់ព្រួញឲ្យត្រង់ ។ ចិត្តនេះ ដែលបុគ្គលលើកឡើងចាកអាល័យ គឺកាមគុណ ៥ ហើយបោះទៅក្នុងវិបស្សនាកម្មដ្ឋាន ដើម្បីលះបង់នូវវដ្តៈ ជាទីនៅនៃមារ រមែងញាប់ញ័រ ដូចជាវារិជាត (សត្វដែលកើតក្នុងទឹកមានត្រីជាដើម) ដែលអ្នកនេសាទ ចាប់លើកឡើងផុតអំពីទឹក ហើយបោះទៅលើគោក (តែងបម្រះនទៀល) យ៉ាងនោះឯង ។

♣ ♣ ♣

## ២៥- រឿងអញ្ញត្រភិក្ខុ

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវភិក្ខុមួយរូប ។ ភិក្ខុអង្គនេះបានឮព័ត៌មាន ពីពួកភិក្ខុដែលបានពោលសរសើរអំពីឧបាសិកាម្នាក់ឈ្មោះថា មាតិកមាតា ក្នុងសំណាក់ព្រះសាស្តាថា “មហាឧបាសិកានេះ ជាអ្នកដឹងចិត្តរបស់អ្នកដទៃ គាត់បានប្រគេនចង្ហាន់បិណ្ឌបាត្រតាមសមគួរ បម្រើតាមសេចក្តីត្រូវការ ចង់បានអ្វី គាត់ធ្វើតាមទាំងអស់” លុះឮដូច្នេះហើយ ក៏មានចិត្តចង់ទៅនៅ ក្នុងទីនោះតែម្តង ។

ពេលដែលពួកភិក្ខុទាំងនោះ បាននិមន្តទៅនៅទីនោះហើយ, មហាឧបាសិកា ក៏បានឧបត្ថម្ភទំនុកបំរុងលោក ដោយបច្ច័យ ៤ តាមសេចក្តីត្រូវការរបស់លោក មិនឲ្យមានការខ្វះខាតអ្វីឡើយ ។ ហេតុនេះហើយ បានជាធ្វើឲ្យភិក្ខុមួយរូបនេះ លោកមានការខ្មាសអៀន

យ៉ាងខ្លាំង ចំពោះមហាឧបាសិកានោះ ដោយនឹកគិតថា "អាត្មាអញនេះ ជាបុថុជ្ជននៅឡើយទេ កម្រណាស់ នឹងហាមចិត្តឲ្យបានល្អ បើអាត្មាអញ គិតនូវរឿងអ្វីមួយដែលមិនល្អហើយ, មហាឧបាសិកានេះ នឹងមើលងាយមើលថោក ដល់អាត្មាអញ មិនខានឡើយ" ហើយ និមន្តចេញអំពីទីនោះ ទៅគាល់ព្រះសាស្តា បានក្រាបទូលការនឹកគិតរបស់ខ្លួន ថ្វាយព្រះអង្គទ្រង់ជ្រាប ។

ព្រះសាស្តា ទ្រង់ត្រាស់បញ្ជា ឲ្យភិក្ខុរូបនោះ ត្រឡប់ទៅនៅក្នុងទីនោះវិញ ទ្រង់បានត្រាស់ទូន្មាន ប្រៀនប្រដៅ ឲ្យលោកខិតខំព្យាយាមរក្សាចិត្ត របស់ខ្លួនឲ្យបានល្អ ហើយទ្រង់ត្រាសនូវព្រះគាថានេះ ថា ៖

**ទុន្និគ្គហស្ស លហុនោ យត្ថ កាមនិបាតិនោ**
**ចិត្តស្ស ទមថោ សាធុ ចិត្តំ ទន្តំ សុខាវហំ ។**

ការទូន្មានចិត្ត ដែលសង្កត់សង្កិនបាន ដោយលំបាក ជាធម្មជាតរហ័ស មានប្រក្រតីធ្លាក់ចុះទៅ តាមសេចក្តីប្រាថ្នា ក្នុងអារម្មណ៍ណាមួយ រមែងជាគុណញ៉ាំងប្រយោជន៍ឲ្យសម្រេច (ព្រោះថា) ចិត្តដែលគេហ្វឹកហ្វឺនបានហើយ រមែងនាំមកនូវសេចក្តីសុខ ។

♣ ❇ ♣

## ២៦- រឿងឧក្កណ្ឋិតភិក្ខុ

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវភិក្ខុមួយរូប ដែលប្រាថ្នាចង់លាចាកសិក្ខាបទ ។ កាលពីដើមឡើយ លោកបានចូលមកបួស ក៏

## រឿងឧក្កណ្ឋិតភិក្ខុ

*ដើម្បីចង់ឲ្យរួចផុតអំពីសេចក្តីទុក្ខ ។ សម័យថ្ងៃមួយ លោកបានស្តាប់ព្រះឧបជ្ឈាយ៍ និង គ្រូអាចារ្យដែលបានអប់រំថា "របស់នេះ ភិក្ខុគប្បីធ្វើ របស់នេះ ភិក្ខុមិនគួរគប្បីធ្វើ, ធ្វើយ៉ាងនេះត្រឹមត្រូវ ធ្វើយ៉ាងនេះមិនត្រឹមត្រូវទេ" ប៉ុណ្ណោះជាដើម ហើយមានសេចក្តីធុញទ្រាន់ យ៉ាងខ្លាំង ធ្វើតាមមិនបានទើបគិតថា "ព្រះធម៌វិន័យនេះ មានច្រើនណាស់ ហើយពិបាកនឹងប្រតិបត្តិតាមថែមទៀតផង" ដូច្នេះហើយ ក៏គិតថា នឹងលាចាកសិក្ខាបទ ។*

*គ្រានោះ ព្រះឧបជ្ឈាយ៍ និង អាចារ្យ បាននាំភិក្ខុរូបនោះ ទៅគាល់ព្រះសាស្តា ហើយបានក្រាបទូលរឿងនោះថ្វាយ ដល់ព្រះអង្គទ្រង់ជ្រាប ។*

*ព្រះសាស្តា ទ្រង់ត្រាស់សួរភិក្ខុនោះ ថា "ម្នាលភិក្ខុ បើអ្នកមិនអាចធ្វើតាមព្រះធម៌វិន័យទាំងអស់នោះបានទេ ចូរអ្នករក្សាតែធម្មជាតមួយប៉ុណ្ណោះក៏បានដែរ តើអ្នកអាចរក្សាធម្មជាតមួយនោះ បានដែរឬទេ?" ។*

*ភិក្ខុអង្គនោះ ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះករុណា អាចរក្សាធម្មជាតម្យ៉ាងនោះបាន" ។ ព្រះអង្គទ្រង់ត្រាស់ថា "បើដូច្នេះ ចូរអ្នករក្សាចិត្ត របស់អ្នកឲ្យបានល្អ អ្នកនឹងរួចផុតចាកអំពីសេចក្តីទុក្ខទាំងពួងបាន" ដូច្នេះហើយ ទ្រង់ត្រាស់ព្រះគាថានេះថា ៖*

សុទុទ្ទសំ សុនិបុណំ  យត្ថ កាមនិបាតិនំ
ចិត្តំ រក្ខេថ មេធាវី  ចិត្តំ គុត្តំ សុខាវហំ ។

## គាថាធម្មបទប្រែ

អ្នកមានប្រាជ្ញា គួររក្សាចិត្ត ដែលឃើញដោយកម្រក្រៃពេក ដែលល្អិតពន់ពេកណាស់ មានប្រក្រតីធ្លាក់ចុះទៅតាមសេចក្តីប្រាថ្នាក្នុងអារម្មណ៍ណាមួយ (ព្រោះថា) ចិត្ត ដែលបុគ្គលរក្សាបានហើយ រមែងនាំមកនូវសេចក្តីសុខ ។

♣ ❇ ♣

## ២៧- រឿង ព្រះភាគិនេយ្យសង្ឃរក្ខិតត្ថេរ

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវព្រះសង្ឃរក្ខិតត្ថេរ ។ សម័យថ្ងៃមួយ លោកបានសំពត់វស្សិកសាដកពីរកំណាត់ មួយកំណាត់ទុកសំរាប់ប្រើប្រាស់ខ្លួនឯង មួយកំណាតទៀតយកទៅប្រគេនដល់ព្រះឧបជ្ឈាយ៍, តែព្រះឧបជ្ឈាយ៍ មិនព្រមទទួលយក ព្រោះលោកមានចីពរប្រើប្រាស់ គ្រប់គ្រាន់ហើយ ។

ព្រះសង្ឃរក្ខិតត្ថេរ មានសេចក្តីខូចចិត្ត យ៉ាងខ្លាំង ហើយគិតថា "ព្រះថេរៈ លោកត្រូវជាអ៊ុំ របស់អាត្មាអញផង ជាព្រះឧបជ្ឈាយ៍ផង បើលោកមិនព្រមទទួល នូវសំពត់នេះទេ គឺលោកពិតជាមិនស្រឡាញ់អាត្មាអញឡើយ ដូច្នេះ អាត្មាអញនៅបួសធ្វើអ្វីទៀត មានតែលាចាកសិក្ខាបទ ទៅធ្វើការរកស៊ី ទើបជាការប្រសើរជាង... បើអញសឹកហើយ អញនឹងយកសំពត់នេះទៅលក់ លុះលក់បានលុយហើយ អញនឹងទៅទិញមេពពែមួយមកចិញ្ចឹម កាលបើមេពពែ កើតកូនមកហើយ អញ នឹងយកកូនវាទៅលក់ លុះលក់បានលុយច្រើន អញ នឹងយកលុយទៅជណ្តើងប្រពន្ធ លុះដល់បានកូនមួយ អញ នឹង

ដាក់ឈ្មោះវា ឲ្យដូចជាឈ្មោះរបស់ព្រះឧបជ្ឈាយ៍ ហើយអញនឹងនាំយកកូននោះ ទៅលេងជាមួយនឹងព្រះឧបជ្ឈាយ៍ ពេលដែលអញធ្វើដំណើរទៅដល់ពាក់កណ្ដាលផ្លូវ អញនឹងពកូននោះ ផ្លាស់វេនគ្នាម្ដងម្ដង ជាមួយនឹងភរិយាអញ បើប្រពន្ធអញ មិនបេះព និង មិនបេះល្អងលោមកូន ធ្វើបាបកូន ហើយបោះវាចោល នៅតាមផ្លូវរទេះ ពេលនោះ កង់រទេះ នឹងកិនសង្កត់ លើកូនអញស្លាប់ អញ នឹងយករំពាត់ខ្សែតី វាយប្រពន្ធអញ...” ក្នុងពេលដែលព្រះសង្ឃរក្ខិតត្ថេរ គិតបណ្ដើរ បក់ផ្លិតប្រគេនព្រះឧបជ្ឈាយ៍បណ្ដើរ យ៉ាងដូច្នេះហើយ ចិត្តដែលទឹកគិត វវើរវាយនោះ ក៏បណ្ដាលឲ្យយកផ្លិតទៅវាយសិរសា (ក្បាល) របស់ព្រះឧបជ្ឈាយ៍របស់ខ្លួន ឮសូរសម្លេងប៉ុងៗ តែម្ដង ។

ព្រះឧបជ្ឈាយ៍ បានភ្ញាក់ព្រើត គិតថា “នេះគឺជារឿងអ្វីហ្ន៎?” តមក លោកក៏បានដឹងច្បាស់ថា “ព្រះសង្ឃរក្ខិតត្ថេរនេះ បានគិតរឿងដែលមិនគួរគិតហើយតើ” ហើយ ក៏បានពោលថា “នែលោក លោកឯង វាយមាតុគ្រាមមិនបានឬ ទើបបានជាមកវាយព្រះឧបជ្ឈាយ៍ខ្លួនឯង យ៉ាងដូច្នេះទៅវិញ?” ។

ព្រះសង្ឃរក្ខិតៈ បានឮដូច្នេះហើយ ក៏មានចិត្តតក់ស្លុត ភ័យខ្លាច យ៉ាងខ្លាំង ព្រោះដឹងថា ព្រះឧបជ្ឈាយ៍បានដឹងចិត្តរបស់ខ្លួនដែលបានគិតមកហើយ ក៏បានបោះផ្លិតនោះចោល ប្រាថ្នាដើម្បីនឹងរត់គេចចេញអំពីវត្ត ។

ភិក្ខុទាំងឡាយ បាននាំគ្នាដេញចាប់ព្រះសង្ឃរក្ខិតៈនោះ យក

ទៅ ថ្វាយដល់ព្រះសាស្តា ។

ព្រះសាស្តា ទ្រង់បានត្រាស់ថា “ចូលមកចុះភិក្ខុ ចូរអ្នកកុំគិតអ្វីឡើយ ធម្មតាចិត្តនេះ តែងទទួលអារម្មណ៍ក្នុងទីឆ្ងាយ, ភិក្ខុ ត្រូវតែខិតខំព្យាយាម ដើម្បីរំដោះខ្លួន ឲ្យរួចផុតពីរាគៈ ទោសៈ និង មោហៈ ទើបជាការប្រសើរ” ដូច្នេះហើយ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

**ទូរង្គមំ ឯកចរំ អសរីរំ គុហាសយំ**
**យេ ចិត្តំ សញ្ញមេស្សន្តិ មោក្ខន្តិ មារពន្ធនា ។**

ជនទាំងឡាយណា នឹងសង្រួមចិត្តដែលទៅឆ្ងាយ ជាចិត្តត្រាច់ទៅតែឯង មិនមានសរីរៈ មានគុហា គឺមហាភូតរូប ៤ ជាទីនៅអាស្រ័យ, ជនទាំងឡាយនោះឯង រមែងរួចផុតអំពីចំណងនៃមារ ។

## ២៨- រឿង ព្រះចិត្តហត្ថត្ថេរ

ព្រះបរមសាស្តា ទ្រង់ប្រារព្ធភិក្ខុមួយរូប ឈ្មោះចិត្តហត្ថៈ ។ ភិក្ខុ រូបនេះ លោកឃើញព្រះពុទ្ធសាសនានេះ មានលាភសក្ការៈ ជាច្រើនកើតឡើង ទើបបានមកបួស ក្នុងព្រះពុទ្ធសាសនា លុះបួសបានមិនយូរប៉ុន្មាន ក៏មានរាងកាយធាត់ធំ មានកម្លាំងច្រើនហើយបានលាចាកសិក្ខាបទ មកជាគ្រហស្ថវិញ លោកបានបួសសឹក សឹកបួស ធ្វើយ៉ាងនេះ អស់រយៈពេលដល់ទៅ ៦ លើក រហូតដល់ប្រពន្ធមានផ្ទៃពោះ... នៅលើកទី ៧ លោកបានឃើញប្រពន្ធ របស់ខ្លួនកំពុងតែដេកលក់ មានអាការគួរខ្ពើម បីដូចជាអសុភៈហើមប៉ោង ក៏កើតមានចិត្ត

-៥០-

## រឿង ព្រះចិត្តហត្ថត្ថេរ

នឿយណាយធុញទ្រាន់ យ៉ាងខ្លាំង ហើយបានចុះពីលើផ្ទះ ដើរយ៉ាងលឿន សំដៅឆ្ពោះទៅវត្ត មកដល់ពាក់កណ្តាលផ្លូវ ក៏បានសម្រេចសោតាបត្តិផល លុះបានមកដល់វត្តហើយ បានចូលទៅរកព្រះសង្ឃ ដើម្បីសុំបួសជាថ្មីម្តងទៀត ។ ព្រះសង្ឃ មិនព្រមបំបួសឲ្យ តែនាយចិត្តហត្ថៈ ចេះតែសុំអង្វរករព្រះសង្ឃ ជាច្រើនលើក ច្រើនគ្រា ។ ព្រះសង្ឃ ទន់ចិត្តអាណិតអាសូរ ក៏បានបំបួសឲ្យជាថ្មីម្តងទៀត ។ លុះបួសស្រេចហើយ ក៏បានសម្រេចព្រះអរហត្តផល ក្នុងពេលនោះ ។

ពួកភិក្ខុទាំងឡាយ មិនឃើញលោកសឹក ដូចជាលើកមុនៗទៀត ក៏កើតមានសេចក្តីសង្ស័យ ហើយក៏បានសួរព្រះថេរៈ ថា "ចុះហេតុអ្វី បានជាលោកម្ចាស់ មិនចង់សឹក ដូចជាលើកមុនៗ ទៀត?" ។

ព្រះថេរៈ ឆ្លើយថា "ខ្ញុំ មិនមានការជាប់ជំពាក់អ្វីទៀតហើយ ឈប់មានធម៌ជាគ្រឿងទៅទៀតហើយ" ។

ពួកភិក្ខុទាំងឡាយ បានចោទព្រះថេរៈ ថា "លោកពោលអួតព្រះអរហត្តផលដែលមិនមានក្នុងខ្លួន" ហើយបាននាំយករឿងនេះទៅក្រាបទូលថ្វាយ ដល់ព្រះសាស្តាទ្រង់ជ្រាប ។

ព្រះសាស្តា ទ្រង់ជានារ៉ាប់រង ថា "ព្រះថេរៈ បានពោលត្រឹមត្រូវហើយ" ក្នុងទីបញ្ចប់ ព្រះអង្គទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

អនវដ្ឋិតចិត្តស្ស　　សទ្ធម្មំ អវិជានតោ
បរិប្លវប្បសាទស្ស　　បញ្ញា ន បរិបូរតិ ។
អនវស្សុតចិត្តស្ស　　អនន្វាហតចេតសោ

គាថាធម្មបទប្រែ

**បុញ្ញបាបប្បហីនស្ស នត្ថិ ជាគរតោ ភយំ ។**

*ប្រាជ្ញា រមែងមិនបរិបូណ៌ ដល់បុគ្គលដែលមានចិត្តមិនខ្ជាប់ខ្ជួន មិនដឹងច្បាស់នូវព្រះសទ្ធម្ម មានសេចក្តីជ្រះថ្លាអណ្តែតទៅ ។ ភ័យ រមែងមិនមាន ដល់បុគ្គលអ្នកមានចិត្តមិនទទឹកដោយរាគៈ មានចិត្តដែលទោសខ្ទាំងខ្ទប់មិនបាន មានបុណ្យនិងបាបលះចោលហើយ ភ្ញាក់រឭកជានិច្ច ។*

♣ ♣ ♣

២៩- រឿង អារទ្ធវិបស្សកភិក្ខុ

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវភិក្ខុ ៥០០ រូប ដែលជាអ្នកចំរើនវិបស្សនាកម្មដ្ឋាន ។ ពួកភិក្ខុទាំងនេះ បានរៀនកម្មដ្ឋាន ក្នុងសំណាក់នៃព្រះសាស្តា ក្រោយមក ក៏បានក្រាបថ្វាយបង្គំលាព្រះអង្គ ទៅបំពេញសមណធម៌ ក្នុងព្រៃដ៏ស្ងាត់មួយ ដែលជាទីនៅអាស្រ័យរបស់ពពួកទេវតាទាំងឡាយ ។*

*រុក្ខទេវតាទាំងឡាយ បានឃើញនូវពួកភិក្ខុទាំងនោះ ដែលជាអ្នកមានសីលបរិសុទ្ធ នៅពីខាងក្រោមខ្លួន យ៉ាងដូច្នេះហើយ ក៏នាំគ្នាយកកូនចៅ ចុះពីលើដើមឈើ មកនៅ លើផែនដី ជាការបណ្តោះអាសន្នសិន ដោយនឹកគិតថា "ពួកភិក្ខុទាំងអស់នេះ នឹងនៅសំណាក់ក្នុងទីនេះ ប្រហែលជាពីរ ឬ បី ថ្ងៃប៉ុណ្ណោះឯង ហើយនឹងនិមន្តចេញទៅវិញ" ។*

*ពួកភិក្ខុទាំងនោះ បានកន្លែងសមគួរហើយ មិនចង់និមន្តទៅទី*

រឿងអារញ្ញវិបស្សកភិក្ខុ

ដទៃទៀតឡើយ ហើយគិតគ្នាថា "ពួកយើង នៅក្នុងទីនេះហើយ" ។ អាស្រ័យហេតុនេះ ពួករុក្ខទេវតា មានការលំបាក យ៉ាងខ្លាំង ក្នុងការរកទីកន្លែងនៅអាស្រ័យ ហើយបានសម្តែងអាការផ្សេងៗ ដែលគួរឲ្យភ័យខ្លាច ដល់ភិក្ខុទាំងនោះ ដើម្បីកុំឲ្យលោកនៅក្នុងទីកន្លែងរបស់ខ្លួនបានតទៅទៀត ។

ពួកភិក្ខុទាំងឡាយ បានឃើញអាការផ្សេងៗ ដែលគួរឲ្យភ័យខ្លាច ដូច្នេះហើយ ក៏មិនហ៊ាននៅអាស្រ័យ ក្នុងទីនោះ តទៅទៀតទេ ហើយបាននាំគ្នាទៅគាល់ព្រះសាស្តា ក្រាបទូលរឿងនោះ ថ្វាយព្រះអង្គទ្រង់ជ្រាប ។

ព្រះបរមសាស្តា ទ្រង់ត្រាស់បញ្ជា ឲ្យពួកភិក្ខុទាំងនោះ និមន្តត្រឡប់ទៅបំពេញសមណធម៌ ក្នុងទីនោះ ជាថ្មីម្តងទៀត ហើយទ្រង់បានប្រទាននូវអាវុធ គឺករណីយមេត្តសូត្រ ដល់ភិក្ខុទាំងនោះ ដើម្បីទុកការពារខ្លួន ។

ភិក្ខុទាំងនោះ ក៏បាននិមន្តត្រឡប់ទៅ បំពេញនូវសមណធម៌ក្នុងទីនោះជាថ្មីម្តងទៀត តាមព្រះបញ្ជារបស់ព្រះសាស្តា ហើយបានស្វាធ្យាយ នូវករណីយមេត្តសូត្រ ដែលព្រះអង្គទ្រង់ប្រទានឲ្យ ។

ពួករុក្ខទេវតា បានស្តាប់ករណីយមេត្តសូត្រហើយ មានចិត្តប្រកបដោយមេត្តា ជួយនាំគ្នាថែរក្សាការពារពួកភិក្ខុទាំងនោះ មិនឲ្យមានសត្វអ្វី មកបៀតបៀនបានឡើយ ។ កាលបើភិក្ខុទាំងនោះ មានសេនាសនៈ សម្រាប់នៅអាស្រ័យ ដែលជាទីសប្បាយហើយ ចិត្តក៏

-៥៣-

គាថាធម្មបទប្រែ

មានអារម្មណ៍មូលតែមួយ ពិចារណាឃើញនូវរូបរាងកាយ បីដូចជាកាជនៈដី ដែលកើតហើយបែកទៅវិញ ។

ព្រះសាស្តា ទ្រង់បានបញ្ចេញព្រះរស្មីទៅ ដូចជាទ្រង់ប្រថាប់គង់នៅ ក្នុងទីចំពោះមុខ នៃភិក្ខុទាំងនោះ ហើយទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

កុម្ភូបមំ កាយមិមំ វិទិត្វា
នគរូបមំ ចិត្តមិទំ ថកេត្វា
យោធេថ មារំ បញ្ញាវុធេន
ជិតញ្ច រក្ខេ អនិវេសនោ សិយា ។

បុគ្គលគប្បីដឹងច្បាស់នូវកាយនេះថា ដូចជាឆ្នាំងដី គប្បីរក្សាចិត្តនេះ ឲ្យដូចជាគេរក្សាទ្វារនគរ គប្បីច្បាំងនូវមារ ដោយអាវុធ គឺបញ្ញា គប្បីរក្សាទុកនូវធម៌ ដែលខ្លួនបានឈ្នះហើយ មិនគប្បីជាអ្នកជំអក់នៅ ក្នុងធម៌នោះឡើយ ។

❋ ❋ ❋

៣០- រឿងព្រះបូតិគត្តតិស្សត្ថេរ

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវព្រះតិស្សត្ថេរ ដែលមានរាងកាយស្អុយរលួយ ។ ក្នុងសាសនាព្រះពុទ្ធព្រះនាមកស្សបៈ ព្រះថេរៈអង្គនេះលោកបានកើតជាព្រានព្រៃ ដើរបរបាញ់សត្វស្លាបគ្រប់ជំពូកធ្វើបាបកម្មនេះ អស់រយៈពេលជាច្រើនឆ្នាំ ។ សត្វស្លាបទាំងឡាយដែលគាត់ចាប់បានមកនោះ គាត់ទុកសម្រាប់បរិភោគ ក្នុងគ្រួសារខ្លះ

-៥៤-
# រឿង ព្រះបូតិកត្តតិស្សត្ថេរ

ទុកសម្រាប់លក់ដូរខ្លះ ។ សត្វស្លាបដែលនៅសល់ពីបរិភោគ និង លក់ដូរ គាត់បានធ្វើឲ្យវេទនាទុក្ខហួសប្រមាណ គឺគាត់កាច់ស្លាបខ្លះ កាច់ជើងខ្លះ កុំឲ្យវាហើរ ឬ ដើរទៅណាបាន ។

ថ្ងៃមួយ នៅពេលព្រឹក ព្រានព្រៃនោះ បានឃើញនូវភិក្ខុមួយរូប ជាព្រះខីណាស្រព និមន្តបិណ្ឌបាត្រ ឈរនៅត្រង់មុខផ្ទះរបស់ខ្លួន ក៏មានចិត្តជ្រះថ្លា ចង់ធ្វើបុណ្យដាក់បាត្រ ព្រោះនឹកឃើញថា "ខ្លួនបានធ្វើអំពើបាបនេះ ជាយូរឆ្នាំមកហើយ ពុំដែលបានធ្វើបុណ្យកុសលអ្វីដែលជាទីពឹងដល់ខ្លួន បន្តិចសោះឡើយ" លុះបានគិតស្រេចហើយ ក៏បានយកភត្តាហារមក ប្រគេនព្រះខីណាស្រពអង្គនោះ ដោយចិត្តជ្រះថ្លា រីករាយសប្បាយជាទីបំផុត ។ នៅក្នុងសាសនាព្រះសមណ-គោតម នៃយើងនេះ បានមកបួសក្នុងសំណាក់នៃព្រះសាស្តា ដោយបសាទសទ្ធា ពេលដែលបួសហើយ លោកកើតមានដំបៅ ពងបែកពាសពេញទាំងរាងកាយ មានក្លិនស្អុយ គួរឲ្យខ្ពើមជាទីបំផុត រហូតដល់ពួកភិក្ខុសាមណេរទាំងឡាយ នៅជាមួយមិនបាន ក៏រត់ចោលអស់ទៅ បណ្តោយទុកឲ្យលោកនៅលំបាក គ្មានទីពឹងតែម្នាក់ឯង ។

សម័យនោះឯង ព្រះសាស្តាទ្រង់ជ្រាបហើយ ទ្រង់ស្តេចយាងទៅ ជួយព្យាបាលជម្ងឺ ដោយព្រះអង្គឯងផ្ទាល់ គឺព្រះអង្គឲ្យលោកស្រង់ទឹក ជម្រះលាងរាងកាយ ផ្លាស់ស្បង់ចីពរថ្មី ។ ខណៈនោះឯង ព្រះតិស្សត្ថេរ មានរាងកាយគ្រាន់បានធូរស្រាលបន្តិច ។ ព្រះសាស្តាទ្រង់បានប្រទានព្រះឱវាទ តាមសមគួរហើយ ទើបទ្រង់ត្រាស់នូវព្រះ

## គាថាធម្មបទប្រែ

គាថានេះ ថា ៖

**អចិរំ វតយំ កាយោ  បឋវឹ អធិសេស្សតិ**
**ឆុទ្ធោ អបេតវិញ្ញាណោ  និរត្ថំវ កលិង្គរំ ។**

ឱហ្ន៎ កាយនេះ មិននៅយូរប៉ុន្មានឡើយ តែមានវិញ្ញាណទៅប្រាសហើយ ជាកាយគឺគេបោះបង់ចោល មុខជានឹងដេកស្តូកស្តឹងលើផែនដី ដូចជាអង្កត់ឧស រកប្រយោជន៍គ្មានឡើយ ។

♣ ♣ ♣

## ៣៧- រឿង នាយនន្ទគោបាល

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវនាយនន្ទគោបាល ។ នាយនន្ទគោបាលនេះ ជាអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ តែជាអ្នកបានគៀសខ្លួនចេញពីរាជភ័យ ដោយភាពជាអ្នកចិញ្ចឹមគោរបស់អនាថ-បិណ្ឌិកសេដ្ឋី គាត់ជាអ្នកមានសទ្ធាមុតមាំ ក្នុងព្រះពុទ្ធសាសនា បានអារាធនានិមន្តព្រះពុទ្ធជាម្ចាស់ ដើម្បីស្តេចយាងទៅផ្ទះរបស់ខ្លួន ។

ព្រះសាស្តាទ្រង់រង់ចាំឲ្យញាណ របស់នាយនន្ទគោបាលនោះចាស់ក្លាបន្តិចសិន លុះដល់ញាណចាស់ក្លាហើយ ទើបព្រះអង្គស្តេចយាងទៅផ្ទះរបស់គាត់ ព្រមជាមួយនឹងភិក្ខុសង្ឃជាច្រើនអង្គ ។

នាយនន្ទគោបាល បានអង្គាសព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន អស់រយៈពេល ៧ ថ្ងៃ ។ ព្រះសាស្តា ទ្រង់ត្រាស់សម្តែងអនុបុព្វីកថា ប្រោសនាយនន្ទគោបាល ឲ្យបានសម្រេចសោតាបត្តិ-ផល ហើយស្តេចយាងត្រឡប់មកអារាមវិញ ។

-៥៦-

រឿង ព្រះសោរេយ្យត្ថេរ

នាយនន្ទគោបាល បានជូនព្រះដំណើរព្រះសាស្ដា និង ភិក្ខុសង្ឃ មកបានតែបន្តិច ក៏ត្រឡប់មកផ្ទះរបស់ខ្លួនវិញ ។ នៅពេលជាមួយគ្នានោះឯង មានព្រានម្នាក់ បានមកបាញ់នាយនន្ទគោបាលនោះស្លាប់ភ្លាមទៅ ។

ភិក្ខុទាំងឡាយ បានឃើញនាយនន្ទគោបាល ត្រូវព្រានបាញ់ស្លាប់ហើយ ទើបក្រាបទូលព្រះសាស្ដាថា "បពិត្រព្រះអង្គ ដ៏ចំរើន ព្រោះតែព្រះអង្គស្ដេចយាងមក បានជានាយនន្ទគោបាល ត្រូវបានព្រានបាញ់សម្លាប់" ។

ព្រះសាស្ដា ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ព្រោះតែតថាគត មកក្ដី មិនបានមកក្ដី ឧបាយដែលនឹងធ្វើឲ្យរួចផុតពីសេចក្ដីស្លាប់នោះ ប្រាកដជាមិនមានសោះឡើយ" ហើយទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

**ទិសោ ទិសំ យន្តំ កយិរា   វេរី វា បន វេរិនំ**
**មិច្ឆាបណិហិតំ ចិត្តំ   បាបិយោ នំ តតោ ករេ ។**

ចោរ ក្រឡេកឃើញចោរផងគ្នា ឬក៏ បុគ្គលអ្នកមានពៀរក្រឡេកឃើញបុគ្គលមានពៀរផងគ្នា គប្បីធ្វើនូវសេចក្ដីវិនាស ណាមួយ ដល់គ្នានឹងគ្នា, ចិត្ត ដែលបុគ្គលតាំងទុកខុសហើយ រមែងធ្វើបុគ្គលនោះ ឲ្យអាក្រក់ក្រៃលែង ជាងសេចក្ដីវិនាសនោះទៅទៀត ។

៣២- រឿង ព្រះសោរេយ្យត្ថេរ

## គាថាធម្មបទប្រែ

ព្រះបរមសាស្តា ទ្រង់ប្រារព្ធ នូវព្រះសោរេយ្យត្ថេរ ជាបុត្តសេដ្ឋីក្រុងសោរេយ្យៈ ។ ពេលដែលព្រះថេរៈ នៅជាគ្រហស្ថ លោកបានឃើញនូវព្រះមហាកច្ចាយនត្ថេរ ក៏កើតសេចក្តីស្រឡាញ់លោកភ្លាម បាននឹកគិត ក្នុងចិត្តថា "ព្រះថេរៈអង្គនេះ មានរូបស្អាតអ្វីម៉្លេះហ្ន៎ បើបានជាភរិយា របស់អញ ឬក៏ ភរិយារបស់អញ មានរូបរាងស្អាតដូចជាព្រះថេរៈអង្គនេះ ពិតជាប្រសើរណាស់ហ្ន៎" ។ ក្នុងមួយខណៈចិត្តដែលគិតនោះ, បុរសភេទ របស់សោរេយ្យសេដ្ឋីនោះ ក៏បានប្រែក្លាយទៅជាស្ត្រីភេទភ្លាម មួយរំពេចនោះឯង ។ ពេលដែលសោរេយ្យសេដ្ឋីនោះ បានក្លាយខ្លួនជាស្ត្រីហើយ គាត់មានការខ្មាសអៀនយ៉ាងខ្លាំង មិនហ៊ានត្រឡប់ទៅនៅផ្ទះ របស់ខ្លួនវិញឡើយ ក៏បានភៀសខ្លួនទៅ រស់នៅឯទីក្រុងតក្កសិលា ហើយបានជាភរិយា របស់សេដ្ឋីបុត្រ នៅទីក្រុងនោះឯង ។

ពេលដែលសោរេយ្យសេដ្ឋី នៅជាបុរស ក្នុងក្រុងសោរេយ្យៈនោះ គាត់មានបុត្រ ២ នាក់, ពេលដែលក្លាយខ្លួនជាស្ត្រី បានស្វាមីនៅឯទីក្រុងតក្កសិលានោះ ក៏មានបុត្រ ២ នាក់ដែរ ។

សម័យថ្ងៃមួយ សំឡាញ់ របស់សោរេយ្យសេដ្ឋី ដែលជាអ្នកស្និទ្ធស្នាលនឹងគ្នា នៅឯទីក្រុងសោរេយ្យៈ បានទៅលេងទីក្រុងតក្កសិលា ដឹងដំណឹងថា "សោរេយ្យសេដ្ឋី ដែលជាសំឡាញ់ របស់ខ្លួនបានក្លាយខ្លួនជាស្រី ហើយបានស្វាមី នៅទីក្រុងតក្កសិលា" ក៏កើតសេចក្តីតក់ស្លុតរន្ធត់ចិត្ត យ៉ាងខ្លាំង បានចូលទៅជួបហើយ ណែនាំ

-៥៨-

## រឿង ព្រះសោរេយ្យត្ថេរ

សោរេយ្យសេដ្ឋីនោះ ឲ្យទៅសុំខមាទោស ចំពោះព្រះមហាកច្ចាយនត្ថេរ ។ ព្រះមហាកច្ចាយនត្ថេរ ក៏បានលើកលែងទោសឲ្យ ក្នុងគ្រានោះឯង ។

ក្នុងពេលនោះ ស្ត្រីភេទ ក៏បានវិនាសបាត់ទៅ ឯបុរសភេទ ក៏បានមកជំនួស ដូចរូបដើមវិញភ្លាម ។ ក្រោយមក សោរេយ្យសេដ្ឋី មានសទ្ធាជ្រះថ្លា បានសាងផ្នួស ក្នុងសំណាក់ព្រះមហាកច្ចាយនត្ថេរ មិនយូរប៉ុន្មាន ក៏បានសម្រេចព្រះអរហត្តផល ។

សម័យថ្ងៃមួយ ពួកពុទ្ធបរិស័ទ ក៏បានមក សួរព្រះថេរៈ ថា "បពិត្រព្រះគុណម្ចាស់ បុត្រដែលកើតចេញពីផ្ទៃនៃភរិយា និង បុត្រដែលកើតចេញពីផ្ទៃនៃព្រះគុណម្ចាស់ តើព្រះគុណម្ចាស់ ស្រឡាញ់បុត្រខាងណា ច្រើនជាងគេបំផុត?" ។

ព្រះថេរៈ បានឆ្លើយថា "ឥឡូវនេះ ខ្ញុំព្រះករុណា អាត្មាភាព មិនស្រឡាញ់បុត្រខាងណា ខ្លាំងជាងខាងណាទៀតឡើយ គឺឈប់ស្រឡាញ់ទាំងអស់ហើយ" ។

ពួកពុទ្ធបរិស័ទ បានចោទព្រះថេរៈថា "លោកពោលអួតព្រះអរហត្តផល" ដូច្នេះហើយ នាំគ្នាយករឿងនេះ ទៅក្រាបទូលថ្វាយដល់ព្រះសាស្ដាទ្រង់ជ្រាប ។

ព្រះសាស្ដា ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ បុត្រ របស់តថាគត មិនបានពោលអួតព្រះអរហត្តផលទេ សេចក្ដីស្នេហា ក្នុងបុត្រទាំងឡាយ ក៏មិនកើតមាន ដល់បុត្ររបស់តថាគតដែរ" ដូច្នេះ

-៥៩-

គាថាធម្មបទប្រែ

*ហើយ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

ន តំ មាតា បិតា កយិរា អញ្ញេ វាបិ ច ញាតកា
សម្មាបណិហិតំ ចិត្តំ សេយ្យសោ នំ តតោ ករេ ។

*មាតាបិតា មិនគប្បីធ្វើនូវហេតុនោះបាន ឬ ជនទាំងឡាយដទៃ ជាញាតិ ក៏មិនគប្បីធ្វើនូវហេតុនោះបានឡើយ, ចំណែកខាងចិត្ត ដែលបុគ្គលតាំងទុកត្រូវហើយ រមែងធ្វើបុគ្គលនោះ ឲ្យប្រសើរជាងហេតុនោះបាន ។*

បប់អប្បមាទវគ្គ ទី ២

**ចប់ ធម្មបទគាថា ប្រែ**
**ភាគ ទី ២**

សូមសិក្សាបន្តទៅភាគទី ៣ ទៀត

# គាថាធម្មបទប្រែ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ភាគ ទី ៣

បុប្ផវគ្គ ទី ៤

៣៣- រឿង បឋវីបសុតបញ្ចសតភិក្ខុ

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធភិក្ខុ ៥០០ រូប ។ ភិក្ខុ ទាំងនេះបានប្រជុំគ្នាសន្ទនាអំពីរឿងផែនដី ថា "ទីនោះមានដីស្មើ ទីនោះមានដីមិនស្មើ ទីនោះ មានភក់ច្រើន ទីនោះ មានក្រួសច្រើន ទីនោះ មានដីខ្មៅច្រើន ទីនោះ មានដីក្រហមច្រើន" ។*

*ព្រះសាស្តា ស្តេចយាងមក ក្នុងទីប្រជុំនោះហើយ ត្រាស់សំដែងថា "ម្នាលភិក្ខុទាំងឡាយ នេះគឺជាផែនដី ដែលមាននៅខាងក្រៅទេ អ្នកទាំងឡាយ គប្បីធ្វើបរិកម្មនូវផែនដីដែលមាននៅខាងក្នុងវិញ ទើបជាការប្រសើរជាង" ស្រេចហើយ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

កោ ឥមំ បឋវឹ វិជេស្សតិ
យមលោកញ្ច ឥមំ សទេវកំ
កោ ធម្មបទំ សុទេសិតំ
កុសលោ បុប្ផមិវ បចេស្សតិ ។
សេខោ បឋវឹ វិជេស្សតិ
យមលោកញ្ច ឥមំ សទេវកំ

គាថាធម្មបទប្រែ

**សេខោ ធម្មបទំ សុទេសិតំ**
**កុសលោ បុប្ផមិវ បចេស្សតិ ។**

*អ្នកណា នឹងដឹងច្បាស់នូវផែនដី គឺអត្តភាពនេះ នឹងយមលោក គឺ អបាយភូមិ ៤ នឹងមនុស្សលោកនេះ ព្រមទាំងទេវលោកបាន, អ្នកណានឹងជ្រើសរើសនូវចំណែកនៃធម៌ ដែលតថាគតសម្តែងប្រពៃហើយ ដូចមាលាការ ដែលឈ្លាសវៃ ជ្រើសរើសនូវផ្កា ដូច្នោះឯង ។ ព្រះសេក្ខបុគ្គល នឹងដឹងច្បាស់នូវផែនដី គឺអត្តភាពនេះ និងយមលោក គឺអបាយភូមិ ៤ និង មនុស្សលោកនេះ ព្រមទាំងទេវលោកបាន, ព្រះសេក្ខបុគ្គល នឹងជ្រើសរើសនូវចំណែកនៃធម៌ ដែលតថាគតសម្តែងប្រពៃហើយ ដូចជាមាលាការ ដែលឈ្លាសវៃ ជ្រើសរើសនូវផ្កា ដូច្នោះឯង ។*

♣ ❇ ♣

## ៣៤- រឿង មរីចិកម្មដ្ឋានិកត្ថេរ

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធ នូវភិក្ខុអ្នកចំរើនមរីចិកម្មដ្ឋាន ។ ភិក្ខុ អង្គនេះ បានរៀនកម្មដ្ឋាន ក្នុងសំណាក់ព្រះសាស្តា ហើយក្រាបបង្គំលាព្រះអង្គ ទៅបំពេញសមណធម៌ ក្នុងព្រៃដែលស្ងាត់មួយ ។ ការបំពេញសមណធម៌ មិនបានលទ្ធផល ដល់ភិក្ខុអង្គនោះឡើយ ។ ដូច្នេះហើយ ភិក្ខុរូបនោះ ក៏បានវិលត្រឡប់មកគាល់ព្រះសាស្តាវិញ ដើម្បីសុំផ្លាស់ព្រះកម្មដ្ឋានថ្មីមួយទៀត លុះមកដល់ពាក់កណ្តាលផ្លូវ ក៏បានឃើញនូវថ្ងៃបណ្តើរកូនប្រិចៗ ក្នុងគិម្ហរដូវ និង ពពុះទឹកដែល*

*ប៉ោងឡើងហើយ បែកទៅវិញ ដោយអំណាចនៃខ្យល់ទឹកហូរ ទើបកំណត់យកធ្វើជាអារម្មណ៍ថា "ថ្ងៃបណ្ដើរកូននេះ កើតមាន ក្នុងគិម្ហរដូវ រមែងឃើញច្បាស់ ដល់បុគ្គលដែលឈរ នៅក្នុងទីឆ្ងាយ ដូចជាមានរូបរាង តែមិនឃើញច្បាស់ ដល់បុគ្គលដែលបានចូលមកជិតយ៉ាងណាមិញ, អត្តភាពនេះ ក៏មានរូបរាង យ៉ាងនោះដែរ ព្រោះកើតឡើងហើយ ក៏វិនាសទៅវិញ ក្នុងទីបំផុត" ។*

*ព្រះសាស្ដា ទ្រង់ជ្រាបហើយ ទ្រង់បញ្ចេញព្រះរស្មីទៅ ដូចជាទ្រង់ប្រថាប់នៅ ក្នុងទីចំពោះមុខ ហើយទ្រង់ត្រាស់ព្រះគាថានេះថា ៖*

**ផេណូបមំ កាយមិមំ វិទិត្វា**
**មរីចិធម្មំ អភិសម្ពុធានោ**
**ឆេត្វាន មារស្ស បបុប្ផកានិ**
**អទស្សនំ មច្ចុរាជស្ស គច្ឆេ ។**

*ភិក្ខុ កាលដឹងច្បាស់ នូវកាយនេះថា ដូចជាដុំពពុះទឹក ដឹងច្បាស់នូវកាយនេះថា មានសភាពដូចជាព្រេញថ្ងៃ គប្បីកាត់នូវផ្កា ជាប្រធាននៃមារ គឺ វដ្តៈ ៣ ទៅកាន់ស្ថានជាទីមិនឃើញនៃមច្ចុរាជ ។*

៣៥- រឿង ព្រះចានវិឌូឌភៈ

*ព្រះបរមសាស្ដា ទ្រង់ប្រារព្ធនូវព្រះបាទវិឌូឌភៈ ដែលត្រូវទឹកជំនន់ជន់លិច ទ្រង់ទិវង្គត ព្រមទាំងពួកបរិវារទាំងអស់គ្នា ។ ព្រះបាទវិឌូឌភៈ ជាព្រះរាជឱរសរបស់ព្រះបាទបសេនទិកោសល, ព្រះមាតា*

គាថាធម្មបទ ប្រែ

ទ្រង់ព្រះនាម វាសភខត្តិយា ជាធីតារបស់មហានាមសក្យរាជ កើតពី នាងទាសី ។ នៅពេលដែលព្រះបាទវិឌូឌភៈ មានវ័យជាកុមារនោះ ទ្រង់បានយាងទៅសួរសុខទុក្ខ របស់ព្រះញាតិវង្សានុវង្ស ខាងព្រះមាតា នៅក្រុងកបិលភស្តុ ។

ក្រោយពេលដែលព្រះវិឌូឌភរាជកុមារ យាងត្រឡប់មកវិញ ហើយនោះ ពួកសាក្យរាជទាំងឡាយ ទ្រង់ត្រាស់បញ្ជាប្រើឲ្យមនុស្ស លាងនូវទីអាសនៈ ដែលវិឌូឌភរាជកុមារប្រថាប់ឲ្យស្អាត ។ មនុស្ស ដែលមកលាងទីអាសនៈនោះ បានជេរប្រទេចនូវព្រះវិឌូឌភកុមារ ថា "ព្រោះតែកូននាងទាសី វាមកអង្គុយនៅ ត្រង់ទីនេះហើយ បានជា អញត្រូវពិបាក មកដុសលាងសម្អាតអាសនៈនេះ" ។

ព្រះបាទវិឌូឌភៈ ទ្រង់ព្រះពិរោធ យ៉ាងខ្លាំង បានចងគំនុំគុំកួន នឹងពួកសាក្យរាជ តាំងតែពីពេលនោះតរៀងមក ។ លុះព្រះអង្គបាន ឡើងគ្រងរាជ្យហើយ ទ្រង់បានលើកកងទ័ពជាច្រើន ដើម្បីទៅសង សឹក យកឈាមរបស់ពួកសាក្យរាជ មកលាងទីអាសនៈនោះវិញ ។ ពេលដែលព្រះអង្គលើកកងទ័ព មកដល់ពាក់កណ្តាលផ្លូវ ទ្រង់បាន ចួបនឹងព្រះបរមសាស្តា ទ្រង់ជ្រាបថា "ព្រះពុទ្ធជាម្ចាស់ ច្បាស់ជា ស្តេចយាងមក ក្នុងទីនេះ ដើម្បីទ្រង់ហាមឃាត់ព្រះអង្គ កុំឲ្យលើក កងទ័ព ទៅសម្លាប់ពួកសាក្យរាជពុំខាន" ហើយទ្រង់បានលើកកង ទ័ព វិលត្រឡប់ទៅព្រះនគរវិញ ។

ក្រោយមក ព្រះបាទវិឌូឌភៈ ក៏បានលើកកងទ័ពទៅជាថ្មីម្តង

ទៀត ហើយបានចួបនឹងព្រះសាស្តា ដូចលើកមុនទៀត ទើបទ្រង់បាន លើកកងទ័ព វិលត្រឡប់មក កាន់ព្រះបរមរាជវាំងវិញ យ៉ាងនេះអស់ រយៈពេល ៣ ដង ។

នៅលើកទី ៤ ព្រះសាស្តា ទ្រង់ជ្រាបបុព្វកម្ម របស់ពួកសាក្យ រាជទាំងនោះ ដែលបានយកថ្នាំពិសទៅដាក់បំពុលត្រី កាលពីអតីត- ជាតិ ទើបទ្រង់បណ្ដោយទៅតាមយថាកម្ម ទ្រង់ពុំបានហាមឃាត់ ដូច លើកមុនៗ ។

គ្រានោះឯង ព្រះបាទវិឌូឌភកុមារ ទ្រង់បានលើកកងទ័ព ទៅ សម្លាប់ពួកសក្យរាជទាំងនោះហើយ យកឈាមមកលាងទីអាសនៈ នោះ ដូចសេចក្ដីគុំកួនរបស់ព្រះអង្គ ដែលបានចងទុកមកពីកាលមុន ស្រេចហើយ ទ្រង់លើកកងទ័ពត្រឡប់មកព្រះបរមរាជវាំងវិញ ដល់ ពាក់កណ្ដាលផ្លូវ ទ្រង់ឈប់សម្រាកព្រះកាយ លើវាលខ្សាច់ ក្បែរ មាត់ស្ទឹងអចេរវតី ។

ពេលជាមួយគ្នានោះ ស្រាប់តែមានភ្លៀងយ៉ាងធំ បង្អុរធ្លាក់ចុះ មក លិចកួចយកព្រះបាទវិឌូឌភកុមារលង់ទិវង្គត ព្រមទាំងពួកបរិវារ ទាំងអស់គ្នា គ្មានសេសសល់ឡើយ ។

ពួកភិក្ខុទាំងឡាយ បានប្រជុំសន្ទនាគ្នាពីរឿងព្រះបាទវិឌូឌភ- កុមារ ព្រមទាំងពួកបរិវារ ដោយប្រការផ្សេងៗ ។

ព្រះសាស្តា ទ្រង់ស្ដេចយាងមក ក្នុងទីប្រជុំនោះហើយ ទ្រង់ ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ កាលបើមនោរថ របស់ពួកសត្វទាំង

*អស់នោះ មិនទាន់បានដល់ទីបំផុតនោះទេ, មច្ចុរាជ បានកាត់ផ្តាច់នូវជីវិតិន្ទ្រិយ៍ ឲ្យធ្លាក់ចុះទៅ ក្នុងសមុទ្រ គឺអបាយទាំង ៤ ដូចជាមហាសាគរ ជន់លិច ក្ងួចយកអ្នកស្រុកដែលកំពុងដេកលក់ទៅ យ៉ាងនោះឯង" ដូច្នេះហើយ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

**បុប្ផានិ ហេវ បចិនន្តំ ព្យាសត្តមនសំ នរំ**
**សុត្តំ គាមំ មហោឃោវ មច្ចុ អាទាយ គច្ឆតិ ។**

*មច្ចុ គឺសេចក្តីស្លាប់ តែងកៀរយកទៅនូវនរជន អ្នកមានចិត្តជាប់ជំពាក់ ក្នុងអារម្មណ៍ផ្សេងៗ កំពុងជ្រើសរើសនូវផ្កា គឺកាមគុណ ៥ នុ៎ះឯង ដូចទឹកជំនន់ធំ ដែលក្ងួចយកអ្នកស្រុកកំពុងដេកលក់ ទៅដូច្នោះឯង ។*

## ៣៦- រឿង នាងបតិបូជិកា

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនាងបតិបូជិកា ។ កាលពីអតីតជាតិ នាងបានកើតជាទេពធីតា របស់មាលាភារីទេវបុត្រ នៅឋានតាវត្តិង្ស ។ សម័យថ្ងៃមួយ នាងបានមកកើត ក្នុងមនុស្សលោក ក្នុងក្រុងសាវត្ថី ជាស្រីដែលចាំជាតិបាន ជាអ្នកមានសទ្ធាខ្លាំងក្លា ក្នុងព្រះពុទ្ធសាសនា បានបំពេញបុណ្យកុសលជាច្រើន នាងបានប្រាថ្នា ថា "ដោយបុណ្យកុសលដែលខ្ញុំបានធ្វើហើយនេះ សូមឲ្យនាងខ្ញុំបានទៅកើត ក្នុងឋានទេវលោក ដូចកាលពីអតីតជាតិវិញ" ។ នៅក្នុងឋានមនុស្សលោកនេះ នាងមានស្វាមី ហើយមានកូន ៤ នាក់ ក្រោយមក*

*នាង ក៏បានធ្វើមរណកាល (ស្លាប់) ពីមនុស្សលោកនេះ បានទៅកើតក្នុងឋានទេវលោក ដូចសេចក្ដីប្រាថ្នា ។*

*បានឮមកថា មួយថ្ងៃនៃឋានតាវត្តិង្សទេវលោក ត្រូវជា ១០០ ឆ្នាំ នៃឋានមនុស្សលោកយើងនេះ ។ ព្រោះហេតុនោះ មាលាភារីទេវបុត្រ មិនទាន់បានវិលត្រឡប់ មកអំពីកំសាន្តសួនច្បារផង លុះឃើញនូវនាងទេពធីតា ត្រឡប់មករកខ្លួនវិញ ទើបសួរថា "កាលពីពេលមុនបន្តិចនេះ តើនាងទៅលេងកំសាន្តនៅទីណា បានជាទើបនឹងមកទីនេះ?" ។ នាង បាននិយាយរៀបរាប់ប្រាប់រឿងរ៉ាវសព្វគ្រប់ ឲ្យមាលាភារីទេវបុត្របានដឹង ។*

*មាលាភារីទេវបុត្រ បានស្ដាប់នូវរឿងនេះហើយ កើតសេចក្ដីសង្វេគតក់ស្លុត យ៉ាងខ្លាំង ហើយគិត ថា "ឱហ្ន៎ អាយុជីវិត របស់មនុស្សលោកនេះ តិចអ្វីម៉្លេះហ្ន៎! ប្រៀបដូចជាដេកលក់ហើយ ក្រោកឡើងវិញអញ្ចឹងឯង" ។*

*គ្រានោះ ពួកភិក្ខុទាំងឡាយ បានដឹងថា "នាងបតិបូជិកា បានធ្វើមរណកាលហើយ" ទើបនាំយករឿងនេះ ទៅក្រាបទូលថ្វាយ ដល់ព្រះសាស្ដាទ្រង់ជ្រាប ។ ព្រះពុទ្ធ ត្រាស់សម្ដែងរឿងនាងបតិបូជិកា ឲ្យពួកភិក្ខុបានស្ដាប់ហើយ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

**បុប្ផានិ ហេវ បចិនន្តំ　ព្យាសត្តមនសំ នរំ**
**អតិត្តំយេវ កាមេសុ　អន្តកោ កុរុតេ វសំ ។**

*អ្នកធ្វើទីបំផុត គឺមរណៈ តែងធ្វើនូវនរជន ដែលមានចិត្តជាប់*

## គាថាធម្មបទប្រែ

ជំពាក់ក្នុងអារម្មណ៍ផ្សេងៗ កំពុងជ្រើសរើសផ្កា គឺកាមគុណ ៥ មិនបេះផ្អែតផ្អូន ក្នុងកាមទាំងឡាយទុំះឯង ឲ្យនៅក្នុងអំណាចរបស់ខ្លួន ។

❉ ❉ ❉

## ៣៧- រឿងមច្ឆរិយកោសិយសេដ្ឋី

ព្រះបរមសាស្តា ទ្រង់ប្រារព្ធ នូវមច្ឆរិយកោសិយសេដ្ឋី ជាមនុស្សកំណាញ់ស្វិតស្វាញ ហួសប្រមាណ ។ សម័យថ្ងៃមួយ លោកសេដ្ឋី ចង់បរិភោគនំអំបែង ព្រោះតែគាត់កំណាញ់ខ្លាំងពេក ខ្លាចក្រែងមានពួកអ្នកស្រុកមកសុំគាត់ស៊ី ទើបមិនហ៊ានឲ្យប្រពន្ធគាត់ ធ្វើនំ នៅកន្លែងដែលមានពួកអ្នកស្រុកទៅមកច្រើន គាត់បានប្រើប្រពន្ធឲ្យយករបស់របរធ្វើនំ ឡើងទៅជាន់ខាងលើគេបង្អស់ ដើម្បីកុំឲ្យពួកមនុស្សម្នាមើលឃើញ ។ ចំណែកឯ របស់សម្រាប់ធ្វើនំនោះសោត ក៏គាត់មិនឲ្យយករបស់ដែលមានតម្លៃច្រើនៗ ទៅធ្វើនំទេ គឺគាត់បានឲ្យយកតែចុងអង្ករខ្ទេចៗ ប៉ុណ្ណោះ ព្រោះគាត់ខ្លាចអស់អង្ករ ។ និយាយអំពីនំដែលគាត់ឲ្យធ្វើនោះ សូម្បីតែប្រពន្ធសំឡាញ់ចិត្ត ដែលជាអ្នកធ្វើនំ ឲ្យគាត់បរិភោគនោះ ក៏គាត់មិនឲ្យបរិភោគដែរ គឺ ឲ្យធ្វើសម្រាប់តែមាត់គាត់ម្នាក់ឯងប៉ុណ្ណោះ ។

ព្រះសាស្តា ទ្រង់ទតព្រះនេត្រឃើញឧបនិស្ស័យ នៃសោតាបត្តិផល របស់លោកសេដ្ឋី និង ភរិយា ទើបទ្រង់ត្រាស់ហៅ នូវព្រះមហាមោគ្គល្លានត្ថេរ ឲ្យនិមន្តទៅ ទូន្មានអប់រំ ដើម្បីឲ្យលោកសេដ្ឋីលះបង់ចិត្តកំណាញ់ស្វិត ចោលឲ្យអស់ កុំឲ្យមានសេសសល់ ។

-៦៨-

រឿង ចាដិកាជីវក

ព្រះមហាមោគ្គល្លាន បាននិមន្តទៅ អប់រំទូន្មានលោកសេដ្ឋី និង ភរិយា ឲ្យមានសេចក្តីជ្រះថ្លា ក្នុងព្រះពុទ្ធសាសនា ហើយនាំគាត់ទាំងពីរនាក់ប្តីប្រពន្ធ ទៅក្រាបថ្វាយបង្គំព្រះសាស្តា ។

ព្រះបរមសាស្តា ទ្រង់ត្រាស់សម្តែងព្រះធម៌ទេសនា ប្រោសលោកសេដ្ឋី និង ភរិយា ឲ្យបានសម្រេចសោតាបត្តិផល ក្នុងពេលនោះឯង ។

ពួកភិក្ខុទាំងឡាយ បានប្រជុំគ្នា ពោលសរសើរគុណ របស់ព្រះមហាមោគ្គល្លានត្ថេរ ដោយប្រការផ្សេងៗ ។

ព្រះសាស្តា ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

**យថាបិ ភមរោ បុប្ផំ វណ្ណគន្ធំ អហេឋយំ**
**បលេតិ រសមាទាយ ឯវំ គាមេ មុនី ចរេ ។**

អ្នកប្រាជ្ញ គប្បីត្រាច់ទៅ ក្នុងស្រុក ឲ្យដូចជាភមរជាតិ មិនធ្វើផ្កាឈើដែលមានពណ៌ និង ក្លិន ឲ្យវិនាសទេ ក្រេបយកតែរស ហើរទៅ ក៏យ៉ាងនោះឯង ។

♣ ❇ ♣

៣៨- រឿង ចាដិកាជីវក

ព្រះបរមសាស្តា ទ្រង់ប្រារព្ធបាជិកាជីវក ។ បាជិកាជីវកនេះ បានហាមមិនឲ្យនាងគហបតានី ដែលជាឧបដ្ឋាយិកា របស់ខ្លួន ចូលទៅរកព្រះសាស្តា ព្រោះគាត់ខ្លាចនាងរត់ចោលខ្លួន ។

ព្រះសាស្តា ទ្រង់ធ្វើភត្តកិច្ចស្រេចហើយ ទ្រង់ធ្វើអនុមោទនា

*ដោយធម្មីកថា យ៉ាងពីរោះចាប់ចិត្ត ។ នាងគហបតានី បានស្តាប់នូវអនុមោទនា របស់ព្រះអង្គហើយ មានសេចក្តីជ្រះថ្លារីករាយសប្បាយចិត្ត យ៉ាងក្រៃលែង ហើយទទួលអនុមោទនា ថា "សាធុៗ" ។*

*ក្នុងពេលនោះ បាជិកាជីវក កំពុងតែឈរ នៅខាងក្រោយផ្ទះ បានស្តាប់ឮដូច្នោះហើយ ក៏ក្រោធខឹង យ៉ាងខ្លាំង បានជេរប្រទេចព្រះសាស្តា ដោយប្រការផ្សេងៗ រហូតនាងគហបតានី ទ្រាំលែងបាន ។*

*ព្រះសាស្តា ទ្រង់ត្រាស់លួងលោមនាងគហបតានី ដោយព្រះធម៌ទេសនា ហើយទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

**ន បរេសំ វិលោមានិ ន បរេសំ កតាកតំ**
**អត្តនោវ អវេក្ខេយ្យ កតានិ អកតានិ ច ។**

*ពាក្យចាក់ដោតទាំងឡាយ របស់ជនដទៃ បុគ្គលមិនគួរធ្វើទុកក្នុងចិត្តឡើយ, កិច្ចការដែលគេធ្វើហើយ និង មិនទាន់ធ្វើហើយ របស់ជនដទៃ បុគ្គល មិនគួរពិនិត្យមើលឡើយ, បុគ្គល គួរតែពិនិត្យពិចារណាកិច្ចការទាំងឡាយ ដែលធ្វើហើយ និង មិនទាន់ធ្វើហើយ របស់ខ្លួនតែម្យ៉ាង ។*

## ៣៩- រឿងឆត្តបាណិឧបាសក

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវឆត្តបាណិឧបាសក ជាអ្នកប្រាជ្ញ ជាអនាគាមិបុគ្គល ។ ថ្ងៃមួយ ព្រះរាជា ទ្រង់ព្រះនាមបសេនទិកោសល ទ្រង់ត្រាស់បញ្ជា ឲ្យរាជអាមាត្យ ទៅអញ្ជើញឧបាសក*

## រឿងឆត្តបាណិឧបាសក

ឆត្តបាណិនោះមក ដើម្បីឱ្យគាត់សម្តែងធម៌ទេសនា ក្នុងព្រះបរម-រាជវាំង របស់ព្រះអង្គ ។

ឆត្តបាណិឧបាសក ជ្រាបហើយ មិនបានទទួល តាមព្រះរាជ-បញ្ជារបស់ព្រះរាជាទេ ហើយបានក្រាបទូលថា “នេះជាភារកិច្ចរបស់ព្រះសង្ឃ” ។ ព្រះរាជា ទ្រង់ស្តេចយាងទៅអារាធនានិមន្តព្រះសាស្តាដោយព្រះអង្គឯង ។

ព្រះសាស្តា ទ្រង់ប្រគល់ភារកិច្ចនេះ ទៅឲ្យព្រះអានន្ទ ។ ថ្ងៃក្រោយមក ព្រះសាស្តា ទ្រង់ត្រាស់សួរព្រះអានន្ទ ថា “ម្នាលអានន្ទអ្នកណាខ្លះ រៀនធម៌ដោយគោរព?” ។ ព្រះអានន្ទត្ថេរ បានក្រាបទូលថា “បពិត្រព្រះអង្គដ៏ចំរើន នាងមល្លិកា បានរៀនធម៌ ដោយគោរព, តែនាង វាសភខត្តិយា មិនបានរៀនធម៌ ដោយគោរពទេ” ។

ព្រះសាស្តា ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

យថាបិ រុចិរំ បុប្ផំ វណ្ណវន្តំ អគន្ធកំ
ឯវំ សុភាសិតា វាចា អផលា ហោតិ អកុព្វតោ
យថាបិ រុចិរំ បុប្ផំ វណ្ណវន្តំ សគន្ធកំ
ឯវំ សុភាសិតា វាចា សផលា ហោតិ សុកុព្វតោ ។

ផ្កាឈើ មានទ្រង់ទ្រាយស្រស់ល្អ មានពណ៌ល្អ ប៉ុន្តែមិនមានក្លិនក្រអូប (រមែងមិនក្រអូបដល់អ្នកដែលទ្រទ្រង់) យ៉ាងណាមិញ, វាចាជាសុភាសិត រមែងមិនមានផល ដល់អ្នកដែលមិនធ្វើតាម យ៉ាងដូច្នោះដែរ, ផ្កាឈើដែលមានទ្រង់ទ្រាយស្រស់ល្អ មានពណ៌ល្អ មាន

គាថាធម្មបទ ប្រែ

ក្លិនក្រអូប (រមែងក្រអូបដល់អ្នកដែលទ្រទ្រង់) ដូចម្ដេចមិញ, វាចាជាសុភាសិត រមែងមានផល ដល់អ្នកដែលធ្វើតាម ដោយគោរពយ៉ាងដូច្នោះឯង ។

❃❃❃

## ៤០- រឿង នាងវិសាខា

ព្រះបរមសាស្ដា ទ្រង់ប្រារព្ធមហាឧបាសិកា ឈ្មោះវិសាខា ជាអ្នកមានបុណ្យច្រើន កើតក្នុងត្រកូលនៃធនញ្ជ័យសេដ្ឋី មានរូបរាងស្រស់ស្អាត ជាបញ្ចកល្យាណី មានកម្លាំងស្មើនឹងដំរីសារ ៥ ជាអ្នកមានប្រាជ្ញាច្រើន បានសម្រេចសោតាបត្តិផល តាំងតែពីនាងនៅមានអាយុ ៧ ឆ្នាំ ។

ពេលនាងមានអាយុ ១៦ ឆ្នាំហើយ នាងត្រូវបានឪពុកម្ដាយរៀបមង្គលការ ជាមួយនឹងបុត្ររបស់មិគារសេដ្ឋី ឈ្មោះបុណ្ណវឌ្ឍនកុមារ ។ នាងវិសាខា បានធ្វើឲ្យត្រកូលរបស់ស្វាមី មានមិគារសេដ្ឋីជាដើម ដែលជាឪពុកក្មេក ជាអ្នកដែលមានមិច្ឆាទិដ្ឋិ ឲ្យក្លាយទៅជាអ្នកមានសម្មាទិដ្ឋិ វិញ ។ នាងវិសាខា មានកូនចៅច្រើន គឺ កូនប្រុស ១០ កូនស្រី ១០, បណ្ដាកូនទាំងអស់នោះ កូនម្នាក់ៗ មានកូនប្រុស ១០ កូនស្រី ១០, ក្នុងចំណោមចៅប្រុសស្រីទាំងនោះ ចៅម្នាក់ៗ មានកូនប្រុស ១០ កូនស្រី ១០, បូករួមមនុស្សទាំងអស់ មានដល់ទៅ ៨,៤២០ នាក់ ។

នាងវិសាខា មានអាយុ ១២០ ឆ្នាំ ហាក់បីដូចជាស្ត្រី ដែល

-៧២-

រឿង នាងវិសាខា

មានអាយុត្រឹមតែ ១៦ ឆ្នាំ ប៉ុណ្ណោះ នាងជាពុទ្ធុប្បដ្ឋាយិកា បានជួយឧបត្ថម្ភ ទំនុកបំរុងព្រះភិក្ខុសង្ឃ ហើយបានបរិច្ចាគគ្រឿងសម្លៀកបំពាក់ របស់នាង ឈ្មោះមហាលតា ដើម្បីសាងវត្តបុព្វារាម ថ្វាយព្រះពុទ្ធសាសនា ។ ពេលដែលនាងបានសាងវត្តបុព្វារាម រួចស្រេចហើយ នាងមានបីតិ រីករាយ ឥតឧបមា បានឧទានគាថា ដើរជុំវិញព្រះវិហាររបស់នាង ។

ភិក្ខុទាំងឡាយ បានឃើញនាងវិសាខា ដើរជុំវិញព្រះវិហារហើយ ឧទានគាថា យ៉ាងដូច្នេះហើយ ទើបនាំគ្នាទៅក្រាបទូល ដល់ព្រះសាស្តា ថា "នាងវិសាខា ដើរច្រៀងលេងសប្បាយ" ។

ព្រះសាស្តា ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ នាងវិសាខាបានឧទាន ជុំវិញព្រះវិហារយ៉ាងនេះ ព្រោះនាងបានឃើញនូវសេចក្តីប្រាថ្នា របស់ខ្លួនបានសម្រេចជាស្ថាពរហើយ" ស្រេចហើយ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

យថាបិ បុប្ផរាសិម្ហា  កយិរា មាលាគុឡេ ពហូ
ឯវំ ជាតេន មច្ចេន  កត្តព្វំ កុសលំ ពហុំ ។

នាយមាលាការ បេះធ្វើសំណុំ នៃកម្រងផ្កា អំពីគំនរនៃផ្កាផ្សេងៗ គ្នា ឲ្យបានច្រើន យ៉ាងណាមិញ, បុគ្គល ដែលមានសេចក្តីស្លាប់ជាធម្មតា គួរធ្វើកុសល ឲ្យបានច្រើន ក៏យ៉ាងដូច្នោះដែរ ។

## គាថាធម្មបទប្រែ

### ៥១-រឿងអានន្ទត្ថេរបញ្ហា

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវបញ្ហា របស់ព្រះអានន្ទត្ថេរ ។ សម័យថ្ងៃមួយ ព្រះអានន្ទ បានគិតថា "បណ្តាក្លិនទាំងឡាយ ក្លិនដែលកើតអំពីឫស ខ្លឹម និង កើតអំពីផ្កា រមែងក្រអូបទៅ តាមខ្យល់តែម៉្យាងប៉ុណ្ណោះ ក្រអូបច្រាសខ្យល់ពុំបានឡើយ, តើក្លិនអ្វីទៅហ្ន៎ ដែលក្រអូបច្រាសខ្យល់បាន?" ហើយ បានចូលទៅ ក្រាបទូលសួរព្រះសាស្តាៗ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

ន បុប្ផគន្ធោ បដិវាតមេតិ
ន ចន្ទនំ តគរមល្លិកា វា
សតញ្ច គន្ធោ បដិវាតមេតិ
សព្វា ទិសា សប្បុរិសោ បវាយតិ ។

ចន្ទនំ តគរំ វាបិ ឧប្បលំ អថ វស្សិកី
ឯតេសំ គន្ធជាតានំ សីលគន្ធោ អនុត្តរោ ។

ក្លិនផ្កាឈើ ផ្សាយទៅច្រាសខ្យល់មិនបាន, ក្លិនខ្លឹមចន្ទន៍ក្តី ក្លិនខ្លឹមក្រស្នាក្តី ក្លិនផ្កាម្លិះរួតក្តី ក៏ផ្សាយទៅច្រាសខ្យល់មិនបានដែរ, ចំណែក ក្លិន របស់សប្បុរសទាំងឡាយ រមែងផ្សាយទៅច្រាសខ្យល់បាន ព្រោះសប្បុរស រមែងផ្សាយទៅបានគ្រប់ទិស ។ ក្លិន នៃសីលជាគុណជាត ប្រសើរបំផុត ជាងគន្ធជាតទាំងនេះ គឺ ខ្លឹមចន្ទន៍ ខ្លឹមក្រស្នា ផ្កាឧប្បល ផ្កាម្លិះលា ។

♣ ♣ ♣

## ៤២- រឿង មហាកស្សបបិណ្ឌបាតទាន

ព្រះបរមសាស្តា ទ្រង់ប្រារព្ធការថ្វាយបិណ្ឌបាត្រ ដល់ព្រះមហាកស្សបត្ថេរ ។ សម័យថ្ងៃមួយ ព្រះថេរៈ បានចេញពីនិរោធ-សមាបត្តិ មានប្រាថ្នាចង់ជួយអនុគ្រោះ ដល់មនុស្សកំសត់ទុគ៌តទាំងឡាយ ។

គ្រានោះ ព្រះឥន្ទ្រាធិរាជ និង នាងសុជាតាទេវធីតា បានចុះមកបន្លំខ្លួន ធ្វើជាតាចាស់ យាយចាស់ កំសត់ទុគ៌ត អង្គុយត្បាញសំពត់ នៅក្នុងទីកន្លែងមួយ ក្បែរទីក្រុងរាជគ្រឹះ ។

ព្រះថេរៈ បាននិមន្តចូលទៅបិណ្ឌបាត្រនៅទីនោះ ។ ព្រះឥន្ទ្រាធិរាជ និង នាងសុជាតា ក្រឡេកឃើញព្រះថេរៈហើយ ធ្វើបីដូចជាមិនដឹងខ្លួនសោះ បានយកបិណ្ឌបាត មកប្រគេនដល់ព្រះថេរៈ ធ្វើជារំភើយ ។

នៅពេលដែលព្រះឥន្ទ្រាធិរាជ និង នាងសុជាតា បានប្រគេនបិណ្ឌបាត រួចស្រេចហើយ, ព្រះថេរៈ បានដឹងច្បាស់ថា “តាចាស់យាយចាស់ ពីរនាក់នេះ ប្រាកដជាមិនមែនមនុស្សធម្មតាទេ គឺពិតជាព្រះឥន្ទ្រាធិរាជ និង នាងសុជាតា បានបន្លំខ្លួន មកប្រគេនបិណ្ឌបាត” ដូច្នេះហើយ ក៏បានហាមប្រាមឲ្យព្រះឥន្ទ្រាធិរាជ និង នាងសុជាតា កុះឱ្យធ្វើយ៉ាងដូច្នេះ បន្តទៅទៀត ។

ព្រះឥន្ទ្រាធិរាជ បានសួរព្រះថេរៈ ថា “បពិត្រព្រះគុណម្ចាស់ ទាន ដែលខ្ញុំម្ចាស់បានធ្វើហើយនោះ តើមានផលានិសង្សឬទេ?” ។ ព្រះថេរៈ ឆ្លើយតបថា “ទានរបស់មហារាជ មានផលានិសង្សដ៏ល្អ” ។

## គាថាធម្មបទប្រែ

ព្រះឥន្ទ្រាធិរាជ ឮយ៉ាងដូច្នោះហើយ មានព្រះទ័យត្រេកអររីករាយ ក្រៃលែង បានឧទានសុភាសិតហើយ ទើបបានហោះទៅ កាន់ឋាន ទេវលោកវិញ ។

ព្រះសាស្តា ទ្រង់ព្រះសណ្តាប់សុភាសិតនោះហើយ ទ្រង់ ត្រាស់ហៅភិក្ខុទាំងឡាយមកហើយ ត្រាស់សំដែងរឿងនោះ ដល់ ភិក្ខុទាំងនោះបានស្តាប់ស្រេចហើយ ទ្រង់ត្រាស់ព្រះគាថានេះ ថា ៖

**អប្បមត្តោ អយំ គន្ធោ យ្វាយំ តគរចន្ទនី**
**យោ ច សីលវតំ គន្ធោ វាតិ ទេវេសុ ឧត្តមោ ។**

ក្លិនក្រស្នា និង ក្លិនចន្ទន៍ ណា, ក្លិននេះ មានប្រមាណតិចទេ, ចំណែក ក្លិននៃបុគ្គលអ្នកមានសីលទាំងឡាយណា ក្លិននោះ ទើប ក្រអូបលើសលប់ផ្សាយទៅ ក្នុងទេវលោក និង មនុស្សលោកបាន ។

❇ ❇ ❇

## ៤៣- រឿងគោធិកត្ថេរបរិនិព្វាន

ព្រះបរមសាស្តា ទ្រង់ប្រារព្ធការបរិនិព្វាន របស់ព្រះគោធិក-ត្ថេរ ។ ព្រះថេរៈ បានចំរើនឈានឲ្យកើតឡើងហើយ ក៏វិនាសបាត់ ទៅវិញ អស់រយៈពេល ៦ ដង ដោយអំណាចរោគ ដែលកើតមាន នៅក្នុងរាងកាយ, ព្រះថេរៈ បានត្រិះរិះថា "គតិ របស់អ្នកដែលមាន ឈានវិនាសទៅហើយ ជាគតិមិនទៀងទាត់ទេ" ក្នុងលើកទី ៧ លោក បានញុំាងឈាន ឲ្យកើតឡើងហើយ ទើបយកកាំបិតកោរ មកអារ-ក របស់ខ្លួនឯងហើយ ខិតខំបំពេញវិបស្សនាកម្មដ្ឋាន រហូតដល់បាន

សម្រេចព្រះអរហត្តផល ហើយបានបរិនិព្វាន ក្នុងទីបំផុតនោះឯង ។

ក្នុងពេលព្រះថេរៈ ប្រារព្ធនឹងអារ-ក ខ្ទនឯងនោះ, មារាធិរាជ ចូលទៅហាមឃាត់ ដោយប្រការផ្សេងៗ លុះដឹងថា មិនបានផល ក៏ចូលទៅក្រាបថ្វាយបង្គំ ទូលថ្វាយដល់ព្រះសាស្តាទ្រង់ជ្រាប ។ ព្រះសាស្តា ទ្រង់ជ្រាបហើយ ក៏មិនបានហាមឃាត់ព្រះថេរៈដែរ ។

ក្នុងពេលដែលព្រះថេរៈបរិនិព្វានហើយ, មារាធិរាជ បានដើរស្វែងរក នូវបដិសន្ធិវិញ្ញាណ របស់ព្រះថេរៈ សព្វទិសទី តែពុំបានចួបប្រទះឡើយ ទើបចូលទៅក្រាបទូលសួរព្រះសាស្តា ។

ព្រះបរមសាស្តាចារ្យ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

**តេសំ សម្បន្នសីលានំ អប្បមាទវិហារិនំ**
**សម្មទញ្ញា វិមុត្តានំ មារោ មគ្គំ ន វិន្ទតិ ។**

មារាធិរាជ ទុកជាខំស្វែងរក ក៏មិនចួបនូវផ្លូវរបស់លោកអ្នកមានសីលបរិបូណ៌ អ្នកនៅដោយសេចក្តីមិនប្រមាទ អ្នករួចស្រឡះចាកធម៌ ជាគ្រឿងសៅហ្មង ព្រោះដឹងច្បាស់តាមហេតុ ទាំងនោះបានឡើយ ។

♣ ❇ ♣

## ៤៤- រឿង នាយគរហទិន្ន

ព្រះបរមសាស្តា ទ្រង់បានប្រារព្ធ នូវនាយគរហទិន្ន ជាសាវ័ករបស់ពួកនិគ្រន្ថ ត្រូវជាសំឡាញ់ នឹងគ្នាជាមួយនាយសិរិគុត ដែលជាសាវ័ក របស់ព្រះសាស្តា ។ ថ្ងៃមួយ នាយគរហទិន្ន ចូលទៅល្បួង

លោមនាយសិរិគុត ឲ្យជ្រះថ្លា ក្នុងពួកនិគ្រន្ថ ពោលសរសើរអួតអាង ពួកនិគ្រន្ថ ថា "ជាអ្នកដឹង នូវហេតុការណ៍ទាំងពួង គឺ ទាំងអតីត អនាគត ទាំងបច្ចុប្បន្ន" ។

នាយសិរិគុត បានស្ដាប់នូវរឿងដូច្នោះហើយ ក៏ប្រើឲ្យនាយគរហទិន្ន ទៅអញ្ជើញពួកនិគ្រន្ថ មកជប់លៀង នៅឯផ្ទះ របស់ខ្លួន ហើយ ប្រញាប់ប្រញាល់មកផ្ទះ បានប្រើឲ្យពួកបរិវារ របស់ខ្លួន ជីកអន្លង់ យ៉ាងជ្រៅ ឲ្យយកលាមករាវ មកចាក់ឲ្យពេញ ក្នុងអន្លង់ទាំងអស់ហើយ ឲ្យបិទមាត់អន្លង់ឲ្យជិត កុំឲ្យមើលឃើញទាល់តែសោះ ។ លុះដល់ថ្ងៃកំណត់ហើយ នាយគរហទិន្ន បានអញ្ជើញពួកនិគ្រន្ថ មកផ្ទះ របស់សិរិគុតឧបាសក ។ ព្រោះដឹងមិនដល់ នាយគរហទិន្ន និង ពួកនិគ្រន្ថ បានធ្លាក់ចុះទៅ ក្នុងអន្លង់លាមកទាំងអស់គ្នា គ្មានសល់អ្នកណាមួយឡើយ ។

គ្រានោះ សិរិគុតឧបាសក បាននិយាយចំអកឲ្យ ថា "ពួកអ្នកឯង ទាំងអស់គ្នា ជាអ្នកដឹងហេតុការណ៍អ្វីៗ បានគ្រប់យ៉ាងទាំងអស់ ចុះហេតុអ្វីទៅ បានជានាំគ្នាមកហែលលេងកំសាន្តសប្បាយ នៅក្នុងអន្លង់លាមក ដែលស្អុយ យ៉ាងនេះទៅវិញ?" ហើយបានស្រែកជេរប្រទេចសព្វគ្រប់ ថែមទាំងនាំគ្នា យកដំបងវាយសំពងពួកនិគ្រន្ថ និង នាយគរហទិន្ន ទាល់តែអស់ចិត្តអស់ចង់ហើយ ក៏បណ្ដេញឲ្យរត់ទៅផ្ទះរៀងៗ ខ្លួនវិញ ។

ពួកនិគ្រន្ថ និង នាយគរហទិន្ន បានទទួលនូវការឈឺចាប់ និង

រឿង នាយគរហទិន្ន

ការខ្មាសអៀនយ៉ាងខ្លាំង តែពុំដឹងជាធ្វើយ៉ាងណាបាន ។ ក្រោយមក ពួកនិគ្រន្ថ និង នាយគរហទិន្ន បានគិតរិះរកវិធីសងសឹកនឹងសិរិគុត ឧបាសក វិញ លុះដល់បាននូវឱកាសល្អហើយ ទើបប្រើឧបាសក សិរិគុត ឲ្យទៅអារាធនានិមន្តព្រះសាស្តា ព្រមទាំងព្រះភិក្ខុសង្ឃ ដើម្បីមកឆាន់នៅផ្ទះ របស់ខ្លួនហើយ ជីកអន្លង់យ៉ាងជ្រៅ ដាក់សុទ្ធតែរងើកភ្លើងដ៏ក្តៅ ពេញអន្លង់ទាំងអស់ហើយ បិទមាត់អន្លង់ យ៉ាងជិតល្អ មិនឲ្យមើលឃើញ ។

លុះដល់ថ្ងៃកំណត់ហើយ, ព្រះសាស្តា ទ្រង់យាងទៅកាន់ផ្ទះ នាយគរហទិន្ន ព្រមជាមួយនឹងព្រះភិក្ខុសង្ឃ ។ ដោយអំណាចនៃពុទ្ធានុភាព រងើកភ្លើង ដែលនៅពេញអន្លង់ទាំងអស់នោះ ក៏បានប្រែក្លាយទៅជាផ្កាឈូក ចាំទទួលទ្រព្រះបាទ របស់ព្រះអង្គ ។

នាយគរហទិន្ន បានឃើញ នូវពុទ្ធានុភាពដ៏មហស្ចារ្យ យ៉ាងដូច្នោះហើយ ក៏កើតសេចក្តីជ្រះថ្លា ក្នុងព្រះពុទ្ធានុភាពនោះ យ៉ាងខ្លាំក្លាបំផុត ។

ព្រះសាស្តា ទ្រង់ត្រាស់ ថា “សត្វទាំងអស់នេះ មិនដឹងគុណពួកសាវ័កនៃតថាគត និង គុណព្រះពុទ្ធសាសនា ព្រោះតែមិនមានបញ្ញាចក្ខុ នេះឯង, សត្វដែលប្រាសចាកពីបញ្ញាចក្ខុ ឈ្មោះថា ជាអ្នកងងឹតងងល់, ឯអ្នកដែលមានបញ្ញា ឈ្មោះថា មានបញ្ញាចក្ខុ” ដូច្នេះហើយ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

**យថា សង្ការធានស្មឹ ឧជ្ឈិតស្មឹ មហាបថេ**

គាថាធម្មបទប្រែ

បទុមំ តត្ថ ជាយេថ សុចិគន្ធំ មនោរមំ
ឯវំ សង្ការភូតេសុ អន្ធភូតេ បុថុជ្ជនេ
អតិរោចតិ បញ្ញា សម្មាសម្ពុទ្ធសាវកោ ។

*ផ្កាឈូក ទុកជាកើត ក្នុងគំនរសម្រាម ដែលគេចាក់ចោល ក្បែរផ្លូវធំនោះ ក៏គង់មានក្លិនក្រអូប ជាទីរីករាយនៃចិត្តបាន ដូចម្តេចមិញ, បណ្តាជនដែលដូចជាគំនរសម្រាម សាវ័ក របស់ព្រះសម្មា-សម្ពុទ្ធ រមែងរុងរឿង កន្លងផុតបុថុជ្ជនទាំងឡាយ ដែលល្ងិតល្ងង់ដោយប្រាជ្ញា យ៉ាងនោះឯង ។*

**ចប់ បុប្ផវគ្គ ទី ៤**

ពាលវគ្គ ទី ៥

៤៥- រឿង អញ្ញាត្របុរស

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធព្រះបាទបសេនទិកោសល និងបុរសម្នាក់ ។ ព្រះបាទបសេនទិកោសល ទ្រង់មានព្រះទ័យស្នេហាលើភរិយារបស់បុរសម្នាក់ យ៉ាងខ្លាំង ហើយទ្រង់បានបង្កើតឧបាយ-កលមួយ ដើម្បីនឹងទ្រង់យកកំហុស ប្រហារជីវិតបុរសជាស្វាមីនាងនោះចោល ហើយយកភរិយាមក ដើម្បីអភិរម្យរួមរស់ស្នេហា ។*

*បុរសជាស្វាមី បានដឹងហើយ មានការភ័យខ្លាច យ៉ាងខ្លាំងចំពោះមរណភ័យ មិនដឹងជានឹងធ្វើយ៉ាងណាបាន នឹងរកបុគ្គលណាម្នាក់ មកធ្វើជាទីពឹងពាក់អាស្រ័យដល់ខ្លួន ក៏រកមិនបានដែរ, គិតទៅ*

## រឿង អញ្ញាត្របុរស

គិតមក ឃើញមានតែព្រះសង្ឃទេ ដែលអាចពឹងពាក់អាស្រ័យ ជួយអនុគ្រោះខ្លួនបាន ព្រោះដឹងច្បាស់ថា "ព្រះសង្ឃ ជាអ្នកមានព្រះទ័យមេត្តា ករុណា ច្រើន" ។

ពិតណាស់ មនុស្សយើង កាលដែលមិនទាន់មានសេចក្តីទុក្ខដ៏ធំ កើតមានមកដល់ខ្លួនទេ ពុំដឹងថា "ព្រះសង្ឃជាអ្នកមានចិត្តមេត្តាករុណា" លុះត្រាតែមានសេចក្តីទុក្ខដ៏ធំកើតឡើងហើយ ទើបបានដឹងថា ព្រះសង្ឃ ជាអ្នកមានចិត្តល្អ ។

បុរសស្វាមីនោះ បានដឹងយ៉ាងនេះហើយ ទើបចូលទៅរកវត្តថ្វាយបង្គំព្រះសង្ឃ ទាំងទឹកភ្នែកដែលហូររហាម សុំព្រះសង្ឃស្នាក់នៅអាស្រ័យ ជាការបណ្តោះអាសន្នសិន ។

ព្រះសង្ឃ បានឃើញហើយ ក៏មានចិត្តអាណិតអាសូរ បានឲ្យទីនៅអាស្រ័យ ឲ្យបាយទឹក ម្ហូបអាហារ ដល់បុរសនោះ សមតាមសេចក្តីត្រូវការ ។

ក្នុងរាត្រីនោះឯង ព្រះបាទបសេនទិកោសល ទ្រង់មានព្រះទ័យក្រហល់ក្រហាយ ដោយកាមរាគៈ ទ្រង់ព្រះបន្ទំ ពុំបានលក់សោះ ព្រោះទ្រង់ព្រះចិន្តា នឹកឃើញតែសេចក្តីស្នេហាប៉ុណ្ណោះ ឥតស្រាកស្រាន្តឡើយ, លុះដល់ពាក់កណ្តាលអាធ្រាត្រយប់ស្ងាត់, ព្រះអង្គទ្រង់ព្រះសណ្តាប់សំឡេងប្រេតស្រែក ថា "**ទុ... ស... ន... សោ...**" ទ្រង់មានព្រះហឫទ័យ ភ័យខ្លាច ចំពោះមរណភ័យ យ៉ាងក្រៃលែង ។

ព្រះនាងមល្លិកា ទ្រង់ជ្រាបថាៈ ព្រះស្វាមី មិនសប្បាយព្រះ

ទ័យ ទើបនាំព្រះអង្គទៅគាល់ព្រះសាស្តា ហើយបានក្រាបទូលរឿងរ៉ាវនោះ ថ្វាយដល់ព្រះសាស្តាទ្រង់ជ្រាប ។

ព្រះសាស្តា ទ្រង់ត្រាស់ព្រះធម៌ទេសនា ពន្យល់ឲ្យព្រះរាជាទ្រង់អស់សេចក្តីសង្ស័យហើយ ឲ្យកើតមានព្រះទ័យ ក័យខ្លាចតក់ស្លុតរន្ធត់ ចំពោះទោសនៃការប្រព្រឹត្តិខុស ក្នុងកាមទាំងឡាយ ហើយទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

**ទីឃា ជាគរតោ រត្តិ ទីឃំ សន្តស្ស យោជនំ**
**ទីឃោ ពាលានំ សំសារោ សទ្ធម្មំ អវិជានតំ ។**

រាត្រី វែង ចំពោះតែអ្នកភ្ញាក់រឭក(អ្នកដេកមិនលក់), យោជន៍វែង ចំពោះតែអ្នកនឿយហត់, សង្សារវដ្ត វែង ចំពោះតែបុគ្គលពាលទាំងឡាយ ដែលមិនដឹងច្បាស់នូវព្រះសទ្ធម្ម ។

## ៤៦- រឿងមហាកស្សបសទ្ធិវិហារិក

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវសទ្ធិវិហារិក របស់ព្រះមហាកស្សបត្ថេរ, សទ្ធិវិហារិកអង្គនោះ បានយកកិច្ចវត្ត របស់សទ្ធិវិហារិកមួយរូបទៀត ដែលលោកបានធ្វើប្រគេន ដល់ព្រះមហាកស្សបៈ ហាក់ដូចជាខ្លួនបានធ្វើ យ៉ាងដូច្នោះឯង ។

ព្រះមហាកស្សបៈ បានដឹងរឿងនោះហើយ បានអប់រំទូន្មានប្រៀនប្រដៅ ដើម្បីកុំឲ្យលោកធ្វើអំពើ ដែលមិនត្រឹមត្រូវ យ៉ាងនេះតទៅទៀត ។ តែលោកអង្គនោះ មិនព្រមស្តាប់ មិនព្រមធ្វើតាមឱវាទ

## រឿង មហាកស្សបសទ្ធិវិហារិក

របស់ព្រះថេរៈសោះ នៅតែចចេស ក្បាលរឹងហើយ ទឹងទឹងព្រះថេរៈថែមទៀតផង ។

សម័យថ្ងៃមួយ ព្រះមហាកស្សបត្ថេរ បាននិមន្តទៅ កាន់ទីដទៃ ។ សទ្ធិវិហារិកនោះ បានទៅវាយបំបែកនូវគ្រឿងសមណបរិក្ខារ របស់ព្រះថេរៈ បាក់បែក ខូចខាតទាំងអស់ គ្មានសល់ឡើយ ហើយបានយកភ្លើង មកដុតនូវបណ្ណសាលា ឲ្យឆេះខ្ទេចខ្ទីអស់ទៀត ស្រេចហើយ ក៏រត់ចេញពីទីនោះ ទៅកាន់ទីដទៃទៀត ។ សទ្ធិវិហារិក ដែលជាអ្នកប្រព្រឹត្តត្រឹមត្រូវមួយរូបទៀត ដឹងរឿងនោះហើយ ទើបទៅក្រាបទូល ដល់ព្រះមានព្រះភាគទ្រង់ជ្រាប ។

ព្រះសាស្តា ទ្រង់ជ្រាបហើយ ទ្រង់ត្រាស់នូវអតីតនិទាន ថា "កាលដែលសទ្ធិវិហារិករូបនេះកើតជាសត្វពានរ, ព្រះមហាកស្សបៈកើតជាសត្វគ្រលេងគ្រលោង ពណ៌ល្មៀងខ្ចី ។ នៅពេលដែលមានភ្លៀងធំ បង្អុរធ្លាក់ចុះមក, សត្វពានរនោះ មានរាងកាយរងាញ័រញាក់យ៉ាងខ្លាំង រកទីកន្លែងជ្រកមិនបាន បោលទៅ-មក ស្រាប់តែឃើញសំបុកសត្វគ្រលេងគ្រលោងហើយ បានទៅជ្រកសម្រាក នៅក្រោមសំបុកនោះ ដើម្បីការពារខ្លួនកុំឲ្យរងា ។ សត្វគ្រលេងគ្រលោង បានឃើញសត្វពានរ មកជ្រក នៅក្រោមសំបុក របស់ខ្លួនដូច្នោះហើយ ក៏និយាយ ថា "បងពានរឯង មានដៃ ជើង ក្បាល មុខ និង មាត់ ដូចជាមនុស្សដែរ ចុះហេតុដូចម្តេច បានជាបងពានរឯង មិនព្រមធ្វើសំបុកសម្រាប់ជ្រកទឹកភ្លៀងនឹងគេ?" ។

គាថាធម្មបទប្រែ

*សត្វពានរ បានឮពាក្យតិះដៀល យ៉ាងដូច្នេះហើយ ក៏ក្រោធខឹង យ៉ាងខ្លាំង នឹងសត្វគ្រលេងគ្រលោងហើយ ក៏ស្ទុះទៅទាញ បោចកន្ទ្រាក់ ទំលាយសំបុកគ្រលេងគ្រលោង ចោលខ្ទេចខ្ទីទាំងអស់" នៅក្នុងទីបញ្ចប់ នៃអតីតនិទាន ព្រះអង្គទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

**ចរញ្ចេ នាធិគច្ឆេយ្យ សេយ្យំ សទិសមត្តនោ**
**ឯកចរិយំ ទឡ្ហំ កយិរា នត្ថិ ពាលេ សហាយតា ។**

*បុគ្គលកាលស្វះស្វែងរកកល្យាណមិត្រ បើមិនបានមិត្រ ដ៏ប្រសើរជាងខ្លួន ឬ មិត្រដែលស្មើនឹងខ្លួនទេ គប្បីប្រព្រឹត្តនៅតែម្នាក់ឯង ឲ្យបានខ្ជាប់ខ្ជួនវិញ ព្រោះថា សហាយតាគុណ (ភាពជាមិត្រសំឡាញ់) មិនមាន ក្នុងបុគ្គលពាលឡើយ ។*

❋ ❋ ❋

## ៤៧- រឿង អានន្ទសេដ្ឋី

*ព្រះបរមសាស្ដា ទ្រង់បានប្រារព្ធអានន្ទសេដ្ឋី ដែលជាមនុស្សកំណាញ់ ស្វិតស្វាញ ។ អានន្ទសេដ្ឋីនេះ មានកូនប្រុសមួយ ឈ្មោះមូលសិរិ, គាត់បានកប់កំណប់ទ្រព្យទុក មានប្រាំកន្លែង មិនឲ្យអ្នកណាម្នាក់បានដឹងឡើយ ។ ថ្ងៃក្រោយមក អានន្ទសេដ្ឋីនេះ បានធ្វើមរណកាលហើយ ទៅកើត ក្នុងត្រកូលចណ្ឌាល មានរូបរាងវិកលវិការ មិនសមប្រកបជាមនុស្សនឹងគេ មិនជាទីពេញចិត្ត ដល់អ្នកផងទាំងឡាយឡើយ ។*

*ចាប់តាំងតែអំពីពេលដែលទារកនោះ បានចាប់បដិសន្ធិ មក*

## រឿង អានន្ទសេដ្ឋី

*រហូតដល់ពេលសម្រាលចេញមក, ត្រកូលចណ្ឌាលនោះ ក៏ធ្លាក់ខ្លួនក្រីក្រលំបាក រកស៊ីធ្វើកិច្ចការងារ មិនបានរីកចំរើន រកព្រឹកខ្វះល្ងាច រកល្ងាចខ្វះព្រឹក, ម្តាយ មិនអាចចិញ្ចឹមកូននោះបាន ក៏បណ្តោយ ឲ្យកូនដើរទៅរកសុំទានគេ យកមកចិញ្ចឹមជីវិត ។ សម័យថ្ងៃមួយ ក្មេងនោះ បានដើរចូលទៅ ដល់ផ្ទះមូលសិរិសេដ្ឋី ដែលជាផ្ទះរបស់ខ្លួនកាលពីជាតិមុន ។*

*ក្នុងថ្ងៃជាមួយគ្នានោះផងដែរ ព្រះសាស្តា មានព្រះអានន្ទ ជាបច្ឆាសមណៈ ស្តេចយាងទៅទីនោះ ទ្រង់ទតព្រះនេត្រឃើញក្មេងនោះហើយ ទ្រង់ត្រាស់ប្រាប់ដល់មូលសិរិសេដ្ឋី ថា “ក្មេងនេះ គឺជាអានន្ទសេដ្ឋី បិតារបស់អ្នក” ។*

*មូលសិរិសេដ្ឋី មិនជឿឡើយ ។ ព្រះសាស្តា ទ្រង់ត្រាស់ ឲ្យក្មេងនោះ ប្រាប់កំណប់ទ្រព្យ ដែលខ្លួនបានកប់ទុក កាលពីជាតិមុន ដើម្បីនឹងបញ្ជាក់ឲ្យមូលសិរិសេដ្ឋីជឿ... ហើយទ្រង់បានត្រាស់នូវព្រះគាថានេះ ថា ៖*

**បុត្តា មត្ថិ ធនមត្ថិ ឥតិ ពាលោ វិហញ្ញតិ**
**អត្តា ហិ អត្តនោ នត្ថិ កុតោ បុត្តា កុតោ ធនំ ។**

*ជនពាល តែងព្រួយលំបាក ដោយសេចក្តីសម្គាល់ ថាៈ កូនទាំងឡាយ របស់អញមាន, ទ្រព្យ របស់អញមាន, តាមដែលពិតសូម្បីខ្លួនរបស់ខ្លួន ក៏មិនមាន ចំណង់បើកូនទាំងឡាយ នឹងរាប់ថាមានមកអំពីណាបាន ទ្រព្យនឹងរាប់ថា មានមកអំពីណាបាន ។*

# គាថាធម្មបទ ប្រែ

## ៤៨- រឿង គណ្ឋិភេទកចោរ

*ព្រះបរមសាស្ដាទ្រង់ប្រារព្ធនូវគណ្ឋិភេទកចោរ ជាចោរដែលលួចប្លន់ ក្នុងចំណោមនៃចោរដូចគ្នា ។ មានចោរពីរនាក់ បានទៅវត្តជេតពន ជាមួយនឹងប្រជាជនដែលនាំគ្នាទៅវត្ត ដើម្បីស្ដាប់ព្រះធម៌ទេសនា ។*

*បណ្ដាចោរទាំងពីរនាក់នោះ ចោរម្នាក់ បានអង្គុយ តាំងចិត្តស្ដាប់នូវព្រះធម៌ទេសនា ដោយសេចក្ដីគោរពហើយ បានសម្រេចសោតាបត្តិផល, ចំណែកឯ ចោរម្នាក់ទៀត អង្គុយសម្លឹងចាំតែលួចទ្រព្យសម្បត្តិ របស់អ្នកដទៃតែប៉ុណ្ណោះ, បើម្ចាស់គេភ្លេចខ្លួន នៅពេលណា, ក៏នឹងលួចយក នៅពេលនោះភ្លាម ។ បន្តិចក្រោយមក ចោរនោះ ក៏បានលួចទ្រព្យ របស់ឧបាសកម្នាក់ ដែលគាត់វេចជាប់នឹងជាយស្បៃ ចំនួន ៥ មាសក ហើយយកប្រាក់នោះ ទៅទិញម្ហូបអាហារ ស្រា ចំណី មកស៊ីផឹកសប្បាយ នៅឯផ្ទះរបស់ខ្លួន និយាយដៀមដាម ចាក់ដោតទៅកាន់សំឡាញ់ម្នាក់នោះ ដោយប្រការផ្សេងៗ និយាយលើកតម្កើងតែខ្លួនឯង ថា “ជាអ្នកមានបញ្ញា ជាបណ្ឌិត” ។ ចំណែកឯ ចោរម្នាក់ទៀត ដែលសម្រេចសោតាបត្តិផល នោះ បានចូលទៅក្រាបទូលរឿងនោះ ថ្វាយព្រះសាស្ដាទ្រង់ជ្រាប ។*

*ព្រះសាស្ដា ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

យោ ពាលោ មញ្ញតិ ពាល្យំ បណ្ឌិតោ វាបិ តេន សោ
ពាលោ ច បណ្ឌិតមានី ស វេ ពាលោតិ វុច្ចតិ ។

រឿង ព្រះឧទាយិត្ថេរ

បុគ្គលណា ជាមនុស្សពាល ហើយដឹងនូវភាពនៃខ្លួន ថា ជាពាល អ្នកនោះ នឹងទៅជាបណ្ឌិតបានខ្លះ ដោយហេតុដែលដឹងខ្លួន ថា ជាពាលនោះ, ម្យ៉ាងទៀត បុគ្គលណា ជាមនុស្សពាល មានសេចក្តីប្រកាន់ ថា ជាបណ្ឌិត បុគ្គលនោះ ឈ្មោះថា ជាមនុស្សពាល ដោយពិតប្រាកដ ។

❈ ❈ ❈

៤៩- រឿង ព្រះឧទាយិត្ថេរ

ព្រះបរមសាស្តា ទ្រង់ប្រារព្ធព្រះឧទាយិត្ថេរ ។ ព្រះឧទាយិត្ថេរលោកបានទៅគង់នៅ ក្នុងធម្មសភា ធ្វើដូចជាព្រះមហាថេរ ។ ពួកភិក្ខុអាគន្តុកៈទាំងឡាយ បានឃើញលោកហើយ នឹកសំគាល់ថា ជាព្រះមហាថេរៈ អ្នកចេះដឹងច្រើន ហើយបានសាកសួរបញ្ហាធម៌ផ្សេងៗ ។

ព្រះឧទាយិត្ថេរ រកឆ្លើយនូវបញ្ហាធម៌មិនបានទាល់តែសោះ ។

ភិក្ខុអាគន្តុកៈទាំងនោះ បានតិះដៀល ថា “ភិក្ខុរូបនេះ គង់នៅក្នុងវត្ត ជាមួយនឹងព្រះសាស្តាដែរ តែមិនដឹងធម៌អាថ៌អ្វីបន្តិចសោះ” ដូច្នេះហើយ ក៏នាំយករឿងនោះ ទៅក្រាបទូលថ្វាយព្រះសាស្តាទ្រង់ជ្រាប ។

ព្រះសាស្តា ទ្រង់ជ្រាបហើយ ទ្រង់ត្រាស់ព្រះគាថានេះ ថា ៖

យាវជីវម្បិ ចេ ពាលោ   បណ្ឌិតំ បយិរុបាសតិ
ន សោ ធម្មំ វិជានាតិ   ទព្វី សូបរសំ យថា ។

ជនពាល ទោះបីចូលទៅអង្គុយជិតអ្នកប្រាជ្ញ សូម្បីអស់មួយ

*ជីវិត ក៏គេឥតបានដឹងរសធម៌អ្វី ឲ្យច្បាស់លាស់ឡើយ ប្រៀបដូចជា វែក ដែលមិនដឹងរសជាតិសម្ល យ៉ាងនោះឯង ។*

♣ ❇ ♣

៥០- រឿង ចាវេយ្យកភិក្ខុ

*ព្រះបរមសាស្ដា ទ្រង់ប្រារព្ធនូវពួកភិក្ខុបាវេយ្យកៈ ចំនួន ៣០ រូប គឺពួកភិក្ខុភទ្ទវគ្គិយៈ ដែលបានទទួលឯហិភិក្ខុឧបសម្បទា នៅក្នុងបឋមពោធិកាល ។ ក្រោយមក ពួកភិក្ខុទាំងអស់នោះ នាំគ្នាទៅគាល់ព្រះសាស្ដា ស្ដាប់ព្រះធម៌ទេសនាហើយ បានសម្រេចព្រះអរហត្ត-ផល អស់កិលេសពីខន្ធសន្ដាន គ្រប់ៗ រូប ។*

*ពួកភិក្ខុដទៃទៀត បានពោលសរសើរ ថា “ពួកភិក្ខុទាំង ៣០ រូបនេះ បានសម្រេចព្រះអរហត្តផលយ៉ាងឆាប់រហ័សពេកណាស់” ។*

*ព្រះសាស្ដា ទ្រង់ត្រាស់ នូវព្រះគាថានេះ ថា ៖*

**មុហុត្តម្បិ ចេ វិញ្ញូ　　បណ្ឌិតំ បយិរុបាសតិ**
**ខិប្បំ ធម្មំ វិជានាតិ　　ជីវ្ហា សូបរសំ យថា ។**

*វិញ្ញូជន បើចូលទៅអង្គុយជិតអ្នកប្រាជ្ញ សូម្បីតែមួយរំពេច រមែងយល់រសធម៌បាន យ៉ាងឆាប់រហ័ស ដូចជាអណ្ដាត ដឹងនូវរសសម្ល យ៉ាងនោះឯង ។*

♣ ♣ ♣

៥១- រឿង សុប្បពុទ្ធកុដ្ឋិ

*ព្រះបរមសាស្ដា ទ្រង់ប្រារព្ធនូវសុប្បពុទ្ធកុដ្ឋិ ។ សុប្បពុទ្ធកុដ្ឋិ*

## រឿង សុប្បពុទ្ធកុដ្ឋិ

នោះ ស្ដាប់ព្រះធម៌ទេសនាហើយ បានសម្រេចជាព្រះសោតាបន្ន ជាអ្នកជឿច្បាស់ ក្នុងព្រះពុទ្ធ ព្រះធម៌ និង ព្រះសង្ឃ យ៉ាងពិតប្រាកដ ។

សម័យថ្ងៃមួយ ព្រះឥន្ទ្រាធិរាជ ចង់សាកល្បងគាត់មើល ថា "តើគាត់ជឿពិត ឬក៏ មិនពិត" ហើយចូលទៅរកសុប្បពុទ្ធកុដ្ឋិ ត្រាស់ពន្យល់ថា "បើអ្នកនិយាយថា: ព្រះពុទ្ធ មិនមែនជាព្រះពុទ្ធ, ព្រះធម៌មិនមែនជាព្រះធម៌, ព្រះសង្ឃមិនមែនជាព្រះសង្ឃដូច្នេះហើយ យើងនឹងឲ្យទ្រព្យសម្បត្តិជាច្រើន ដល់អ្នក" ។ សុប្បពុទ្ធកុដ្ឋិ ឆ្លើយតបថា "ខ្ញុំនេះ មិនមែនជាអ្នកទីទ័លក្រទេ គឺជាអ្នកមានអរិយទ្រព្យ" ។ ព្រះឥន្ទ្រាធិរាជ ទ្រង់ជ្រាបហើយ ទើបស្ដេចយាងទៅ ក្រាបទូលព្រះមានព្រះភាគទ្រង់ជ្រាប ។

គ្រានោះ សុប្បពុទ្ធកុដ្ឋិ ក៏បានទៅគាល់ព្រះសាស្ដាផងដែរ ។ នៅពេលដែលសុប្បពុទ្ធកុដ្ឋិ ត្រឡប់មកពីគាល់ព្រះសាស្ដាវិញនោះ, ស្រាប់តែមានមេគោកូនខ្ចីមួយ ដែលធ្លាប់មានពៀរនឹងគ្នាអំពីជាតិមុនបានបោលមក ជល់គាត់ស្លាប់ ក្នុងមួយរំពេចនោះឯង ។

ពួកភិក្ខុទាំងឡាយ បានឃើញហេតុនោះហើយ ទើបនាំគ្នាទៅក្រាបទូលថ្វាយដល់ព្រះសាស្ដា ។

ព្រះសាស្ដា ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

**ចរន្តិ ពាលា ទុម្មេធា    អមិត្តេនេវ  អត្តនោ**
**ករោន្តា បាបកំ កម្មំ     យំ ហោតិ កដុកប្ផលំ ។**

ជនពាលទាំងឡាយ មិនមានប្រាជ្ញា មានខ្លួនដូចជាសត្រូវ ដើរ

គាថាធម្មបទ ប្រែ

ធ្វើតែកម្មដ៏លាមក ដែលជាអំពើមានផលក្តៅក្រហាយ ។

## ៥២- រឿង នាយកសកៈ

ព្រះបរមសាស្តា ទ្រង់បានប្រារព្ធនូវអ្នកស្រែម្នាក់ ដែលមានឧបនិស្ស័យ នឹងបានសម្រេចសោតាបត្តិផល ។ ព្រះអង្គ ទ្រង់យាងទៅ តាមភ្លឺស្រែ របស់នាយកសកៈនោះ ដែលកំពុងតែភ្ជួរស្រែ ទ្រង់ទតព្រះនេត្រឃើញបង្វេចទ្រព្យ ដែលពួកចោរបានធ្វើធ្លាក់ ក្នុងស្រែរបស់គាត់ហើយ ទ្រង់ត្រាស់ទៅកាន់ព្រះអានន្ទ ថា: ម្នាលអានន្ទ អ្នកចូរមក មើលអាសិរពិស ។

គ្រានោះឯង ពួកម្ចាស់ទ្រព្យ បានតាមមកប្រកិតៗ មកដល់ទីស្រែនោះ ហើយបានឃើញបង្វេចទ្រព្យ របស់ពួកគេ នៅក្នុងស្រែរបស់នាយកសកៈនោះហើយ ក៏នាំគ្នាចាប់ចង វាយដំ ធ្វើបាប យ៉ាងខ្លាំងឃោរឃៅ ដោយនឹកគិតថា "គាត់ជាចោរ បានលួចប្លន់ទ្រព្យនេះមកលាក់ទុក ក្នុងស្រែនេះ" ។

អ្នកស្រែនោះ បាននិយាយប្រាប់ម្ចាស់ទ្រព្យ ថា "ខ្ញុំ មិនមែនជាចោរ លួចទ្រព្យសម្បត្តិ របស់ពួកអ្នកមកទេ" ហើយបាននិយាយអះអាង ដល់ព្រះពុទ្ធ និង ព្រះអានន្ទ ដើម្បីធ្វើជាសាក្សី ។ ពួកម្ចាស់ទ្រព្យ បានឮដូច្នេះហើយ ក៏នាំនាយកសកៈនោះ ទៅទូលដល់ព្រះរាជា ។ ព្រះរាជា ទ្រង់បាននាំយកទៅ គាល់ព្រះសាស្តាហើយ ទ្រង់ក្រាបទូលសួរពីការនិយាយអះអាង របស់អ្នកស្រែនោះនឹងព្រះអង្គ។

-៩០-

រឿង នាយសុមនមាលាការ

ព្រះសាស្តា ទ្រង់ត្រាស់ ថា "តថាគត បានឃើញបង្វេចទ្រព្យក្នុងស្រែនោះមែន" ដូច្នេះហើយ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

**ន តំ កម្មំ កតំ សាធុ យំ កត្វា អនុតប្បតិ**
**យស្ស អស្សុមុខោ រោទំ វិបាកំ បដិសេវតិ ។**

បុគ្គល ធ្វើកម្មណាហើយ រមែងក្តៅក្រហាយ ជាខាងក្រោយ មានមុខប្រឡាក់ដោយទឹកភ្នែក ស្រែកទួញយំ ទទួលនូវផលនៃកម្មណា, កម្មដែលគេធ្វើហើយនោះ ឈ្មោះថាជាកម្មមិនល្អសោះឡើយ។

❋ ❋ ❋

៥៣- រឿង នាយសុមនមាលាការ

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវនាយសុមនមាលាការ ជាអ្នកបេះផ្កាម្លិះ យកទៅថ្វាយព្រះបាទពិម្ពិសារ ជារៀងរាល់ថ្ងៃ ។ ថ្ងៃមួយគាត់ ឃើញនូវព្រះសាស្តាហើយ មានចិត្តរីករាយជ្រះថ្លា យ៉ាងក្រៃលែង បានយកផ្កាម្លិះ មកថ្វាយជាពុទ្ធបូជា ។ ការបូជាផ្កាម្លិះ របស់នាយសុមនមាលាការនេះ មានអានុភាពខ្លាំងក្លាណាស់ ។

ព្រះបាទពិម្ពិសារ ទ្រង់ជ្រាបហើយ មានព្រះទ័យសោមនស្សយ៉ាងក្រៃលែង ទ្រង់ព្រះរាជទានព្រះរាជទ្រព្យជាច្រើន ដល់នាយមាលាការ ។

ភិក្ខុទាំងឡាយ បានប្រជុំគ្នា និយាយសរសើរ នូវព្រះពុទ្ធានុភាព និង ការបូជានូវផ្កាម្លិះ ដែលនាយសុមនមាលាការ បូជាថ្វាយចំពោះព្រះសាស្តា ដោយចិត្តជ្រះថ្លា ។

-៩១-

គាថាធម្មបទប្រែ

*ព្រះសាស្តា ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

តញ្ច កម្មំ កតំ សាធុ    យំ កត្វា នានុតប្បតិ
យស្ស បតីតោ សុមនោ    វិបាកំ បដិសេវតិ ។

*បុគ្គល ធ្វើកម្មណាហើយ រមែងមិនក្តៅក្រហាយ ជាខាងក្រោយ ដល់នូវសេចក្តីពេញចិត្ត មានចិត្តល្អ ទទួលនូវផលនៃកម្មណា, កម្ម ដែលគេធ្វើហើយនោះឯង ឈ្មោះថា ជាកម្មល្អ ។*

♣ ❇ ♣

៥៤- រឿង នាងឧប្បលវណ្ណាថេរី

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវនាងឧប្បលវណ្ណាថេរី ជាធីតារបស់សេដ្ឋីក្រុងសាវត្ថី ។ ពេលដែលនាងនៅជាគ្រហស្ថ, មានព្រះរាជា និង មហាសេដ្ឋីជាច្រើន ចង់បាននាងមកធ្វើជាមហេសី ។ សេដ្ឋីជាបិតា មានការបង្អៀតចង្អល់ចិត្ត យ៉ាងខ្លាំង មិនដឹងជានឹងលើកកូនក្រមុំ ទៅឲ្យដល់អ្នកណាមួយទេ ទើបបានបង្ហាញផ្លូវ ឲ្យនាងចេញទៅបួសជាភិក្ខុនី ។ នាងឧប្បលវណ្ណា ឮបិតាអនុញ្ញាត ឲ្យទៅបួសដូច្នេះហើយ មានចិត្តត្រេកអរ យ៉ាងក្រៃលែង ហើយបានចូលទៅបួសជានាងភិក្ខុនី ក្នុងសំណាក់នៃនាងភិក្ខុនីទាំងឡាយ មិនយូរប៉ុន្មានក៏បានសម្រេចព្រះអរហត្តផល ។*

*គ្រានោះ នន្ទមាណព ដែលជាកូនឪពុកធំ របស់នាង មានសេចក្តីស្នេហា មកលើរូបនាងឧប្បលវណ្ណាថេរី តាំងតែអំពីពេលដែលនាងនៅជាគ្រហស្ថមកម្ល៉េះ លុះដល់បានឱកាសល្អហើយនោះ*

នន្ទមាណព ក៏បានចូលទៅ ប្រទូសរ៉ាយ រំលោភលើនាងឧប្បលវណ្ណាថេរី ហើយបានសម្រេច ដូចសេចក្តីបំណងរបស់ខ្លួន ។ នៅពេលជាមួយគ្នានោះ ព្រះធរណី មិនអាចនឹងទ្រ នូវជនពាលនោះបានឡើយ ក៏បានប្រេះបែក ញែកចេញជា ២ បំណែក ស្រូបយកនាយនន្ទមាណព ចូលទៅដល់មហាអវិចីនរកភ្លាមនោះឯង ។

ពួកភិក្ខុទាំងឡាយ បានសន្ទនាគ្នាថា “ព្រះខីណាស្រព ទាំងឡាយ នៅតែមានសេចក្តីត្រេកអរនឹងការសេពកាម” ។

ព្រះសាស្តាទ្រង់ត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ ព្រះខីណាស្រព ទាំងឡាយ មិនត្រេកអរ ក្នុងកាមសុខ មិនមានចិត្តជាប់ជំពាក់ក្នុងកាមឡើយ ដូចតំណក់ទឹកមិនជាប់នៅលើស្លឹកឈូក យ៉ាងដូច្នោះឯង” ដូច្នេះហើយ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

**មធុវា មញ្ញតី ពាលោ  យាវ បាបំ ន បច្ចតិ**
**យទា ច បច្ចតី បាបំ  អថ ទុក្ខំ និគច្ឆតិ ។**

ដរាបណា បាបមិនទាន់ហុចផលឲ្យ ដរាបនោះ ជនពាលតែងសំគាល់នូវបាបនោះ ថា មានរសជាតិ ដូចទឹកឃ្មុំ, លុះតែកាលណា បាបហុចផលឲ្យ ជនពាល ទើបប្រទះនូវសេចក្តីទុក្ខ ក្នុងកាលណោះ ។

## ៥៥- រឿងជម្ពុកាជីវក

ព្រះបរមសាស្តា ទ្រង់បានប្រារព្ធ នូវជម្ពុកាជីវកម្នាក់ ។ ក្នុង

-៩៣-

# គាថាធម្មបទប្រែ

*សាសនា នៃព្រះពុទ្ធព្រះនាមកស្សបៈ ជម្ពុកាជីវកនេះ ធ្លាប់បានបួសជាភិក្ខុ ប្រព្រឹត្តមិនល្អ បានជេរប្រទេចព្រះខីណាស្រពមួយរូប ដោយផលវិបាកនៃកម្មនោះឯង លុះស្លាប់ទៅ ក៏បានទៅសោយទុក្ខ យ៉ាងធ្ងន់ ក្នុងមហាអវិចីនរក អស់មួយពុទ្ធន្តរ... លុះដល់សាសនា នៃព្រះសមណគោតមយើងនេះ បានមកកើតជាមនុស្សនៅក្រុងរាជគ្រឹះ ដើរស្រាត មិនស្លៀកពាក់ខោអាវ មិនស៊ីបាយ ស៊ីតែលាមក ប៉ុណ្ណោះ ចូលចិត្តដេក លើកផែនដី នៅពេលដែលមានសក់វែង យកជន្ទាប់មកចាប់ដក ។*

*មហាជនភាគច្រើន និយមរាប់អានជ្រះថ្លា នឹងជម្ពុកាជីវកនេះខ្លាំងណាស់ បាននាំយកម្ហូបអាហារជាច្រើន ដើម្បីល្បួងលោមឲ្យគាត់បរិភោគ ។ តែជម្ពុកាជីវក មិនព្រមបរិភោគសោះ គ្រាន់តែយកចុងស្បូវភ្លាំង មកជ្រលក់ផ្តិតនឹងម្ហូបអាហារហើយ ដាក់លើចុងអណ្តាត តែប៉ុណ្ណោះឯង គាត់បានប្រព្រឹត្តយ៉ាងនេះ អស់រយៈពេល ៥៥ ឆ្នាំ ។*

*ក្នុងសម័យនោះ ព្រះសាស្តា ទ្រង់ទតព្រះនេត្រឃើញ នូវឧបនិស្ស័យរបស់ជម្ពុកាជីវកហើយ ទ្រង់យាងចូលទៅជិតៗ គាត់ ។*

*នៅក្នុងបឋមយាម មហារាជទាំង ៤ បានចូលទៅគាល់ព្រះសាស្តា, ក្នុងមជ្ឈិមយាម សក្កទេវរាជ ក៏បានចូលមកគាល់, ក្នុងបច្ឆិមយាម មហាព្រហ្ម បានចូលមកគាល់ មានពន្លឺភ្លឺស្វាង យ៉ាងត្រចះត្រចង់ រហូតរាត្រី ។*

*ជម្ពុកាជីវក បានឃើញហើយ នឹកអស្ចារ្យចំឡែក យ៉ាងខ្លាំង*

-៩៤-
## រឿងអហិប្រេត

ព្រឹកឡើង ក៏បានចូលទៅ ក្រាបទូលសួរនឹងព្រះសាស្ដា ។ ព្រះអង្គទ្រង់បានទេសនាពន្យល់ ឲ្យជម្ពុកាជីវកនោះ បានសម្រេចដល់ព្រះអរហត្តផល ។

គ្រានោះឯង ពួកមហាជន ជាច្រើន បានមក ក្នុងទីនោះដែរ កើតមានសេចក្ដីសង្ស័យ ថា "ព្រះសមណគោតម នឹង ជម្ពុកាជីវក តើអ្នកណា ធំជាងអ្នកណា?" ។

ព្រះសាស្ដា ទ្រង់ជ្រាបហើយ ទើបទ្រង់ត្រាស់ព្រះបញ្ជា ឲ្យព្រះថេរៈ គឺជម្ពុកាជីវក ដោះស្រាយនូវសេចក្ដីសង្ស័យ របស់មហាជន កុំឲ្យមានការសង្ស័យ តទៅទៀត ហើយទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

មាសេ មាសេ កុសគ្គេន  ពាលោ ភុញ្ជេថ ភោជនំ
ន សោ សង្ខាតធម្មានំ  កលំ អគ្ឃតិ សោឡសឹ ។

ជនពាល ទុកជាបរិភោគ នូវភោជន ដោយចុងស្បូវភ្លាំងរាល់ៗ ខែ ជនពាលនោះ ក៏មិនដល់មួយចំណិតនៃចំណែក ទី ១៦ ៗ លើក របស់បុគ្គលទាំងឡាយដែលមានធម៌បានដឹង ឬ បានពិចារណាហើយឡើយ ។

✣ ❈ ✣

## ៥៦- រឿងអហិប្រេត

ព្រះបរមសាស្ដា ទ្រង់បានប្រារព្ធនូវប្រេតមួយ ដែលមានរាងកាយដូចជាសត្វពស់ វែងប្រវែង ២០ យោជន៍ មានក្បាលដូចមនុស្ស

## -៩៥-
## គាថាធម្មបទប្រែ

អាស្រ័យនៅ លើកំពូលភ្នំគិជ្ឈកូដ ។

ព្រះមហាមោគ្គល្លានត្ថេរ បានឃើញ នូវប្រេតនោះហើយ ក៏និយាយ ជាមួយនឹងព្រះលក្ខណត្ថេរ នៅទីចំពោះព្រះភក្ត្រ នៃព្រះសាស្តា, ព្រះអង្គ ទ្រង់ធ្វើជាសក្សី របស់ព្រះមហាមោគ្គល្លាន ។

ពួកភិក្ខុទាំងឡាយ បានក្រាបទូលសួរនូវបុព្វកម្ម របស់ប្រេតនោះ នឹងព្រះសាស្តា ។ ព្រះអង្គ ទ្រង់ត្រាស់នូវអតីតនិទានថា "កាលពីអតីតកាល ប្រេតនេះបានកើតជាអ្នកស្រែម្នាក់ ឃើញពួកប្រជាជនដើរជាន់ស្រូវស្រែរបស់គាត់ ដើម្បីទៅធ្វើបុណ្យនឹងព្រះបច្ចេកពុទ្ធ ជារៀងរាល់ថ្ងៃ ពុំដែលដាច់ ក៏កើតសេចក្តីក្រោធខឹងយ៉ាងខ្លាំង នឹងពួកប្រជាជនព្រមទាំងព្រះបច្ចេកពុទ្ធ ។ ថ្ងៃមួយ ជួនជាព្រះបច្ចេកពុទ្ធ មិននៅ ក្នុងបណ្ណសាលា, គាត់បានចូលទៅវាយបំបែកគ្រឿងបរិក្ខារប្រើប្រាស់ របស់ព្រះបច្ចេកពុទ្ធ បែកខូចខាតទាំងអស់ ស្រេចហើយបានយកភ្លើងមកដុតបណ្ណសាលា ឲ្យឆេះខ្ទេចអស់ថែមទៀត, ដោយផលនៃកម្មនោះ លុះគាត់ស្លាប់ទៅ ក៏បានទៅកើត ក្នុងនរក សោយទុក្ខវេទនាយ៉ាងខ្លាំង រហូតដល់ផែនដីដុះឡើងបានមួយយោជន៍ ទើបបានមកកើតជាប្រេត មានអត្តភាពដូចជាពស់ មានក្បាលដូចមនុស្ស រស់នៅ លើភ្នំគិជ្ឈកូដនេះ" ក្នុងទីបញ្ចប់អតីតនិទាន ទ្រង់ត្រាស់ នូវព្រះគាថានេះ ថា ៖

ន ហិ បាបំ កតំ កម្មំ សជ្ជុខីរំវ មុច្ចតិ
ឌហន្តំ ពាលមន្វេតិ ភស្មាច្ឆន្នោវ បាវកោ ។

-៩៦-
រឿងសដ្ឋីក្ូដប្រេត

*បាបកម្ម ដែលជនពាលធ្វើហើយ មិនទាន់ឲ្យផលនោះក៏មាន ដូចទឹកដោះស្រស់ដែលមិនទាន់ប្រែក្លាយ (ក្នុងមួយរំពេច) ដូច្នោះ, បាបកម្មនោះ រមែងតាមដុតនូវបុគ្គលពាល ដូចរងើកភ្លើងដែលបិទបាំងទុក ដោយផេះ យ៉ាងដូច្នោះឯង ។*

## ៥៧- រឿងសដ្ឋីកូដប្រេត

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវសដ្ឋីកូដប្រេត ដែលរស់នៅលើភ្នំគិជ្ឈកូដ មានអត្តភាពប្រវែងបីគាវុត មានដែកក្រហមឆ្អិនឆ្អៅ ៦ ហ្មឺនដុំ ធ្លាក់ចុះមកសំពងក្បាល ម្តងហើយម្តងទៀត ឥតមានឈប់ឈរឡើយ ។*

*ព្រះមហាមោគ្គល្លានត្ថេរ បានឃើញ នូវប្រេតនោះហើយ ក៏និយាយ ជាមួយនឹងព្រះលក្ខណត្ថេរ នៅទីចំពោះព្រះភក្ត្រ នៃព្រះសាស្តា, ព្រះអង្គ ទ្រង់ធ្វើជាសក្សី របស់ព្រះមហាមោគ្គល្លាន ។ ពួកភិក្ខុទាំងឡាយ បានក្រាបទូលសួរ នូវបុព្វកម្មនោះនឹងព្រះសាស្តា ។*

*គ្រានោះ ព្រះសាស្តា ទ្រង់ត្រាស់អតីតនិទាននេះ ថា “សម័យថ្ងៃមួយ មានបុរសខ្ញើម្នាក់ ជាអ្នកពូកែខាងផ្ទាត់គ្រាប់ក្រួស ។ ថ្ងៃមួយ ព្រះរាជា ទ្រង់បានត្រាស់បញ្ជា ឲ្យពួកអាមាត្យទៅតាមបុរសនោះមកគាល់ ហើយទ្រង់ត្រាស់ទៅកាន់បុរសខ្ញើនោះ ថា “ខ្ញុំ មានបុរោហិតម្នាក់ ជាអ្នកចូលចិត្តនិយាយច្រើនណាស់, នៅពេលណាដែលបុរោហិតនោះ ចូលមកគាល់ខ្ញុំ ហើយហាមាត់និយាយ, ចូរអ្នក*

*ផ្ទាត់អាចម៍ពពែទាំងអស់នេះ តម្រង់ចូលទៅ ក្នុងមាត់ របស់គេ នៅពេលនោះភ្លាម, តើអ្នកអាចធ្វើ យ៉ាងនេះ បានដែរឬទេ? ” ។ បុរសគឿនោះ ក្រាបទូលថា “ទូលព្រះបង្គំ អាចធ្វើបាន” ហើយក៏បានធ្វើតាមព្រះរាជបញ្ជា ។*

*ចាប់តាំងតែពីពេលនោះមក បុរោហិត ក៏ស្ងប់ស្ងាត់ លែងនិយាយច្រើន ដូចមុនទៀត ។ ព្រះរាជាទ្រង់ព្រះរាជទានរង្វាន់ជាច្រើនដល់បុរសគឿនោះ ។ ក្រោយមក មានបុរសម្នាក់ ចង់រៀនវិជ្ជាផ្ទាត់ដុំក្រួស អំពីបុរសគឿនោះ ហើយបានចូលទៅផ្ញើខ្លួនប្រាណ ធ្វើជាកូនសិស្ស ដើម្បីរៀនយកនូវវិជ្ជានោះ ។ លុះរៀនចប់សព្វគ្រប់ហើយ ក៏ចង់សាកល្បងវិជ្ជានោះលមើល, ថ្ងៃមួយ បុរសម្នាក់នេះ ក៏បានមកជួបប្រទះ នឹងព្រះបច្ចេកពុទ្ធមួយព្រះអង្គ ក៏គិត ថា “បុគ្គលម្នាក់នេះប្រាកដជាគ្មានឪពុកម្តាយ មែនពិត” ហើយបានផ្ទាត់ដុំក្រួស សំដៅទៅ ត្រង់ចំរន្ធត្រចៀកខាងស្តាំ របស់ព្រះបច្ចេកពុទ្ធ ធ្លុះចេញទៅ រន្ធត្រចៀកខាងឆ្វេង ធ្វើឲ្យព្រះបច្ចេកពុទ្ធអង្គនោះ បរិនិព្វាន ក្នុងមួយរំពេចនោះឯង ។ ព្រោះបាបកម្មនេះឯង បុរសនោះ លុះស្លាប់ទៅ ក៏បានទៅសោយទុក្ខយ៉ាងធ្ងន់ នៅក្នុងមហាអវិចីនរក រហូតដល់ផែនដីដុះបានមួយយោជន៍ ទើបបានមកកើតជាសដ្ឋីកូដប្រេត លើកំពូលភ្នំគិជ្ឈកូដនេះ” នៅទីបញ្ចប់នៃអតីតនិទាន ព្រះអង្គទ្រង់ត្រាស់ នូវព្រះគាថានេះ ថា ៖*

យាវទេវ អនត្ថាយ ញត្តំ ពាលស្ស ជាយតិ

-៩៨-

រឿង ព្រះសុធម្មត្ថេរ

**ហន្តិ ពាលស្ស សុក្កំសំ មុទ្ធស្ស វិបាតយំ ។**

*ចំណេះវិជ្ជា តែងកើតឡើង ដល់បុគ្គលពាល គ្រាន់តែដើម្បីសេចក្ដីវិនាសតែប៉ុណ្ណោះ, ចំណេះវិជ្ជានោះ រមែងញ៉ាំងបញ្ញា របស់គេ ឲ្យធ្លាក់ចុះ (ថែមទាំង) បំផ្លេចបំផ្លាញចំណែកធម៌ស របស់បុគ្គលពាលនោះ ។*

♣ ❇ ♣

៥៨- រឿង ព្រះសុធម្មត្ថេរ

*ព្រះបរមសាស្ដា ទ្រង់ប្រារព្ធនូវព្រះសុធម្មត្ថេរ ជាចៅអធិការវត្តអម្ពាតកវន ក្នុងមច្ឆិកាសណ្ឌនគរ ។ ព្រះសុធម្មត្ថេរ ឃើញចិត្តគហបតី អ្នកបានសម្រេចអនាគាមី ដែលជាឧបដ្ឋាក របស់ខ្លួន មានចិត្តជ្រះថ្លា ជាមួយនឹងព្រះអគ្គសាវ័ក ច្រើនជាងមករកខ្លួន ដែលធ្វើជាចៅអធិការវត្ត ហើយបាននិមន្តព្រះអគ្គសាវ័កជាមុន ទើបនិមន្តខ្លួនជាខាងក្រោយ បានក្រោធខឹងអន់ចិត្តយ៉ាងខ្លាំង ចំពោះចិត្តគហបតីនោះ ហើយបាននិយាយចាក់ដោត ដៀមដាម ជាច្រើនប្រការ ក្រោយមកបានរត់ចោលវត្ត ទៅក្រាបទូលដល់ព្រះសាស្ដា ។*

*ព្រះសាស្ដា ទ្រង់បានត្រាស់បញ្ជា ឲ្យភិក្ខុទាំងឡាយ នាំព្រះសុធម្មត្ថេរ មកដើម្បីទៅសុំខមាទោស ចំពោះចិត្តគហបតី ហើយទ្រង់ត្រាស់ថា "ពិតណាស់ សមណៈ មិនត្រូវប្រកាន់ខ្លួន ឬក៏ មានចិត្តប្រណែន យ៉ាងនេះថា វត្តរបស់អញ, ទីលំនៅ របស់អញ, ឧបាសកឧបាសិកា របស់អញ, ព្រោះថា បើសមណៈ ធ្វើយ៉ាងដូច្នេះ, កិលេស*

*ទាំងឡាយ មានឫស្យា និង មានះ ជាដើម រមែងកើតឡើង" ដូច្នេះ ហើយ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

អសន្តំ ភាវមិច្ឆេយ្យ     បុរេក្ខារញ្ច ភិក្ខុសុ
អាវាសេសុ ច ឥស្សរិយំ     បូជា បរកុលេសុ ច
មមេវ កត មញ្ញន្តុ     គិហិបព្វជិតា ឧភោ
មមេវ អតិវសា អស្សុ     កិច្ចាកិច្ចេសុ កិស្មិញ្ចិ
ឥតិ ពាលស្ស សង្កប្បោ     ឥស្សា មានោ ច វឌ្ឍតិ ។

*ភិក្ខុពាល រមែងប្រាថ្នានូវសេចក្តីសរសើរ ដែលមិនមាន (ក្នុងខ្លួន) ផង នូវការធ្វើជាប្រមុខ (ធ្វើជាធំ) លើពួកភិក្ខុផង នូវភាពជាឥស្សរៈ ក្នុងអាវាសទាំងឡាយផង នូវការបូជាទាំងឡាយ ក្នុងត្រកូលនៃជនទាំងឡាយដទៃផង, សេចក្តីត្រិះរិះ រមែងកើតមាន ដល់ភិក្ខុពាល យ៉ាងនេះ គឺ គ្រហស្ថ និង បព្វជិត ទាំងពីរពួក ចូរសំគាល់ នូវកិច្ចដែលមនុស្សដទៃធ្វើហើយ ថា ជាកិច្ច របស់អញវិញ, អំណាចដ៏ក្រៃលែង របស់អញ ចូរមាន ក្នុងកិច្ចតូច ធំ ណាៗ មួយ, (កាលបើយ៉ាងនេះ) ឫស្យា និង មានះ រមែងចំរើនឡើង ។*

♣ ❊ ♣

## ៥៩- រឿង ព្រះវនវាសីតិស្សត្ថេរ

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវព្រះវនវាសីតិស្សត្ថេរ ជាបុត្ររបស់ញោមឧបដ្ឋាក របស់ព្រះធម្មសេនាបតីសារីបុត្រ ។ ព្រះវន-វាសីតិស្សៈ លោកមានសេចក្តីជ្រះថ្លា ចំពោះព្រះសារីបុត្រ តាំងតែពី*

## រឿង ព្រះវនវាសីតិស្សត្ថេរ

លោកនៅជាកុមារមកម៉្លេះ លុះអាយុបាន ៧ ឆ្នាំ ក៏បានចូលទៅបួសជាសាមណេរ នៅក្នុងសំណាក់ព្រះសារីបុត្រ លោកជាអ្នកបរិបូណ៌ដោយលាភសក្ការៈជាច្រើន តែលោកមិនមានចិត្តត្រេកអរ ក្នុងលាភសក្ការៈនោះឡើយ បានរៀនកម្មដ្ឋាន ក្នុងសំណាក់ព្រះសាស្តា ហើយក្រាបថ្វាយបង្គំសុំលាព្រះអង្គ ទៅបំពេញសមណធម៌ ក្នុងព្រៃស្ងាត់មួយកន្លែង រហូតដល់បានសម្រេចអរហត្តផល ក្នុងទីនោះ ។

ពួកភិក្ខុទាំងឡាយ បានពោលសរសើរគុណ របស់ព្រះថេរៈថា "លោកបានធ្វើកម្មដែលគេធ្វើបានដោយកម្រ ហើយបានលះបង់ចោលនូវលាភសក្ការៈ ចូលទៅនៅ ក្នុងព្រៃដ៏ស្ងាត់ តែម្នាក់ឯង រហូតបានសម្រេចព្រះអរហត្តផល ក្នុងទីបំផុត" ។

ព្រះសាស្តា ស្តេចយាងមក ក្នុងទីប្រជុំនោះ ហើយត្រាស់ ថា "ម្នាលភិក្ខុទាំងឡាយ ការប្រតិបត្តិ ដែលអាស្រ័យលាភសក្ការៈនោះផ្សេង ការប្រតិបត្តិ ដែលញ៉ាំងសត្វឲ្យដល់ព្រះនិព្វាននោះផ្សេង, ក៏អបាយទាំង ៤ មានទ្វារបើកចំហ ចាំទទួលភិក្ខុដែលរក្សាការប្រតិបត្តិដែលអាស្រ័យលាភសក្ការៈ ដោយអំណាចការសមាទានធុតង្គ មានការនៅក្នុងព្រៃ ជាដើម ដោយសង្ឃឹមថា "អាត្មាអញ នឹងបានលាភព្រោះការប្រតិបត្តនេះ" ចំណែក ភិក្ខុ អ្នកលះបង់លាភសក្ការៈ ដែលកើតឡើង ដោយការប្រតិបត្តិ ដែលញ៉ាំងសត្វ ឲ្យដល់ព្រះនិព្វាន ហើយចូលទៅក្នុងព្រៃ ខិតខំព្យាយាម បំពេញសមណធម៌ រមែងបានសម្រេចព្រះអរហត្តផល" ដូច្នេះហើយ ទ្រង់ត្រាស់ព្រះគាថានេះថា ៖

-១០១-

គាថាធម្មបទ ប្រែ

អញ្ញា ហិ លាភូបនិសា អញ្ញា និព្វានគាមិនី
ឯវមេតំ អភិញ្ញាយ ភិក្ខុ ពុទ្ធស្ស សាវកោ
សក្ការំ នាភិនន្ទេយ្យ វិវេកមនុព្រូហយេ ។

*បដិបទា អាស្រ័យនូវលាភផ្សេង បដិបទា ជាដំណើរទៅកាន់ព្រះនិព្វានផ្សេង, ភិក្ខុ ជាសាវ័ករបស់ព្រះពុទ្ធ ដឹងច្បាស់នូវហេតុនោះយ៉ាងនេះហើយ មិនគួរត្រេកអរចំពោះលាភសក្ការៈឡើយ គប្បីញ៉ាំងវិវេក ឲ្យចំរើន ដោយលំដាប់ ។*

ចប់ពាលវគ្គ ទី ៣

**ចប់ គាថាធម្មបទ ប្រែ**
**ភាគ ទី ៣**

# គាថាធម្មបទប្រែ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ភាគ ទី ៤

បណ្ឌិតវគ្គ ទី ៦

៦០- រឿង ព្រះរាធត្ថេរ

*ព្រះបរមសាស្តា ទ្រង់បានប្រារព្ធនូវព្រះរាធត្ថេរដ៏មានអាយុ ។ កាលដែលលោកនៅជាគ្រហស្ថ ជាមនុស្សក្រខ្សត់ខ្លាំងណាស់ នៅអាស្រ័យជាមួយនឹងភិក្ខុទាំងឡាយ ដើម្បីចិញ្ចឹមជីវិត ជារៀងរាល់ថ្ងៃ រាធព្រាហ្មណ៍ បានបោសសំអាតវត្តអារាម ពុំដែលខានឡើយ ។*

*ព្រះសាស្តា ទ្រង់ទតព្រះនេត្រឃើញឧបនិស្ស័យ នៃអរហត្ត-ផល របស់រាធព្រាហ្មណ៍ហើយ ទើបទ្រង់យាងទៅប្រាស្រ័យសន្ទនាជាមួយ ។ រាធព្រាហ្មណ៍ បានក្រាបបង្គំទូលសុំបព្វជ្ជា ឧបសម្បទ ព្រោះគាត់មានបំណងចង់បួសខ្លាំងណាស់ អស់ជាច្រើនឆ្នាំហើយ ។ ព្រះសាស្តា ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយ មកប្រជុំគ្នា ហើយត្រាស់សួរបញ្ជាក់ថា “តើភិក្ខុ អង្គណា នឹករឭកឃើញ នូវឧបការគុណរបស់ព្រាហ្មណ៍នេះបានដែរ?” ។*

*ក្នុងគ្រានោះ ព្រះសារីបុត្រ បានក្រាបទូលថា “បពិត្រព្រះអង្គដ៏ចំរើន ទូលព្រះបង្គំ នឹករឭកឃើញនូវឧបការគុណ របស់ព្រាហ្មណ៍នេះបាន គឺកាលអំពីពេលមុន គាត់បានប្រគេនបាយមួយវែក ដល់ទូលព្រះបង្គំ” ។ ព្រះសាស្តាទ្រង់ជ្រាបហើយ ត្រាស់ឲ្យព្រះសារីបុត្រ*

*បំបួសរាធព្រាហ្មណ៍ ជាភិក្ខុ ក្នុងព្រះពុទ្ធសាសនា ក្នុងគ្រានោះឯង ។*

*លុះបួសហើយ លោកជាអ្នកដែលគេប្រដៅបានងាយ មិនចចេស ស្តាប់បង្គាប់តាមឱវាទ របស់ព្រះសារីបុត្រ មិនយូរប៉ុន្មាន ក៏បានសម្រេចព្រះអរហត្តផល ។ ភិក្ខុទាំងឡាយ ពោលសរសើរគុណរបស់ព្រះសារីបុត្រ ថា "ជាអ្នកមានកតញ្ញូកតវេទិតាធម៌... " ហើយពោលសរសើរព្រះរាធៈ ថា "ជាអ្នកដែលគេប្រដៅបានដោយងាយទទួលឱវាទ ដោយគោរព" ។*

*ព្រះសាស្តា ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

**និធីនំវ បវត្តារំ  យំ បស្សេ វជ្ជទស្សិនំ**
**និគ្គយ្ហវាទឹ មេធាវឹ  តាទិសំ បណ្ឌិតំ ភជេ**
**តាទិសំ ភជមានស្ស  សេយ្យោ ហោតិ ន បាបិយោ ។**

*បុគ្គល គួរឃើញនូវអ្នកប្រាជ្ញណា ដែលជាអ្នកនិយាយសង្កត់សង្កិន ចង្អុលប្រាប់ទោស ថា ដូចជាបុគ្គលអ្នកប្រាប់កំណប់ទ្រព្យឲ្យដូច្នោះ គួរគប់រកអ្នកប្រាជ្ញបែបនោះ (ព្រោះថា) កាលបុគ្គលគប់រកអ្នកប្រាជ្ញបែបនោះ រមែងមានសេចក្តីគាប់ប្រសើរ មិនមានសេចក្តីអាក្រក់ឡើយ ។*

❋❋❋

## ៦១- រឿងអស្សជិបុនព្វសុកភិក្ខុ

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវភិក្ខុអស្សជិបុនព្វសុកៈ ។ ភិក្ខុទាំងពីររូបនេះ ជាភិក្ខុ ក្នុងចំណោមនៃពួកភិក្ខុឆព្វគ្គីយ៍ ជាសទ្ធិវិហារិក*

*របស់ព្រះអគ្គសាវ័ក តែជាភិក្ខុអលជ្ជី ប្រព្រឹត្តអនាចារ ដើរធ្វើកុល-ទូសកកម្ម ចិញ្ចឹមជីវិត ដោយបច្ច័យដែលបានមកនោះ... ចាំវស្សា នៅទីនគ្នុំគីជាគិរី ជាមួយភិក្ខុ ៥០០ រូប ដែលជាបរិវារ របស់ខ្លួន ។*

*ព្រះសាស្តា ទ្រង់ជ្រាបហេតុនោះហើយ ទ្រង់ត្រាស់បញ្ជា ឲ្យព្រះអគ្គសាវ័កទាំងពីរ និមន្តទៅអប់រំទូន្មានដល់ភិក្ខុទាំងនោះ...ហើយ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

**ឱវទេយ្យានុសាសេយ្យ អសព្ភា ច និវារយេ**
**សតំ ហិ សោ បិយោ ហោតិ អសតំ ហោតិ អប្បិយោ ។**

*បណ្ឌិត គួរទូន្មានប្រៀនប្រដៅ គួរហាមឃាត់ នូវជនទាំងឡាយ ចាកអំពើអសប្បុរស, អ្នកប្រាជ្ញនោះ រមែងជាទីស្រឡាញ់ របស់សប្បុរស តែម៉្យាង មិនជាទីស្រឡាញ់ នៃអសប្បុរសឡើយ ។*

❇ ❇ ❇

## ៦២- រឿង ព្រះឆន្នត្ថេរ

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវព្រះឆន្នត្ថេរ ។ ឆន្នភិក្ខុ រូបនេះ ជាអ្នកដែលគេប្រដៅបានដោយលំបាក ប្រកាន់មានះយ៉ាងខ្លាំង បាន ជេរប្រទេចព្រះអគ្គសាវ័កទាំងពីររូប ថា "អញ កាលតាមស្តេចចេញ មហាអភិនេស្រ្កមណ៍ ជាមួយព្រះរាជបុត្រ នៅពេលនោះ មិនឃើញ មានអ្នកណាម្នាក់សោះ តែឥឡូវនេះ អ្នកទាំងពីរនាក់នេះ ដើរប្រកាស ឃោសនា ប្រាប់គេឯងឱ្យដឹងថា: អាត្មាអញ ឈ្មោះសារីបុត្រ ឈ្មោះ មោគ្គល្លាន យើងទាំងពីរនាក់ជាព្រះអគ្គសាវ័ក..." ។*

## គាថាធម្មបទប្រែ

*ព្រះសាស្តា ទ្រង់ជ្រាបហើយ ទ្រង់បានត្រាស់បញ្ជា ឲ្យហៅភិក្ខុឆន្នៈ មកហើយ ទ្រង់ត្រាស់ទូន្មានប្រៀនប្រដៅ... ។ ភិក្ខុឆន្នៈ នៅស្ងៀម បានតែមួយភ្លេចប៉ុណ្ណោះ លុះដល់ត្រឡប់មកវិញ ក៏បានចាប់ផ្តើមជេរប្រទេចព្រះអគ្គសាវ័ក ដូចពីដើមវិញ ។ ព្រះសាស្តា ទ្រង់ត្រាស់ឲ្យហៅឆន្នភិក្ខុ ដែលកំពុងតែជេរប្រទេចនោះមកហើយ ទ្រង់ត្រាស់អប់រំទូន្មានម្តងទៀត ថា នែឆន្នៈ ព្រះអគ្គសាវ័កទាំងពីរនេះ ជាកល្យាណមិត្រ ជាបុគ្គលប្រសើរបំផុតសម្រាប់អ្នក [១] ចូរអ្នកសេពគប់ជាមួយនឹងកល្យាណមិត្រទាំងពីរនេះចុះ" ហើយ ទ្រង់ត្រាស់ នូវព្រះគាថានេះ ថា ៖*

**ន ភជេ បាបកេ មិត្តេ ន ភជេ បុរិសាធមេ**
**ភជេថ មិត្តេ កល្យាណេ ភជេថ បុរិសុត្តមេ ។**

*បុគ្គល មិនគួគប់នឹងបាបមិត្រ មិនគួរគប់នឹងបុរសថោកទាប គួរគប់រកតែនឹងកល្យាណមិត្រ គួរគប់រកតែនឹងបុរសខ្ពង់ខ្ពស់ ។*

♣ ❇ ♣

## ៦៣- រឿង ព្រះមហាកប្បិនត្ថេរ

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវព្រះមហាកប្បិនត្ថេរ ។ កាល*

---

១- ទោះបីជាព្រះសាស្តា ទ្រង់ត្រាស់ទូន្មាន ដល់ទៅ ៣ លើក ក៏ឆន្នភិក្ខុ មិនព្រមធ្វើតាមព្រះឱវាទ របស់ព្រះអង្គដែរ ពេលដែលព្រះអង្គទ្រង់បរិនិព្វានទៅហើយ ព្រះអានន្ទបានធ្វើព្រហ្មទណ្ឌ ដល់ឆន្នភិក្ខុៗ កើតសេចក្តីសង្វេគតក់ស្លុត លះបង់ទិដ្ឋិមានះ រឹងត្អឹងខិតខំចំរើនវិបស្សនា រហូតដល់បានសម្រេចព្រះអរហត្តផល ។

-១០៦-

## រឿង ព្រះមហាកប្បិនត្ថេរ

ពីព្រះថេរៈនៅជាគ្រហស្ថនោះ លោកជាព្រះមហាក្សត្រ សោយរាជ្យសម្បត្តិ នៅនគរកុក្កុដវតី ទ្រង់មានព្រះអគ្គមហេសី ទ្រង់ព្រះនាមអនោជាទេវី ។

សម័យថ្ងៃមួយ ព្រះរាជា ទ្រង់បានព្រះសណ្ដាប់ព័ត៌មាន អំពីពួកពាណិជ ថា "ឥឡូវនេះ ព្រះពុទ្ធរតនៈ ព្រះធម្មរតនៈ និង ព្រះសង្ឃរតនៈ បានកើតឡើងហើយ ក្នុងក្រុងសាវត្ថី" ដូច្នេះហើយ ទ្រង់មានព្រះទ័យសោមនស្ស យ៉ាងក្រៃលែង ហើយទ្រង់បានព្រះរាជទានព្រះរាជទ្រព្យ ឲ្យដល់ពួកពាណិជទាំងអស់នោះ តាមសមគួរ ក្រោយមក ព្រះអង្គទ្រង់លះបង់រាជសម្បត្តិ ចេញទៅសាងផ្នួស មួយអន្លើដោយពួកបរិវារ មាន ចំនួន ១,០០០ នាក់ ទ្រង់យាងឆ្ពោះទៅកាន់ទីក្រុងសាវត្ថី ហើយទ្រង់ចួបប្រទះនឹងព្រះសាស្ដា នៅពាក់កណ្ដាលផ្លូវ ទ្រង់បានព្រះសណ្ដាប់ នូវព្រះធម្មទេសនា គឺអនុបុព្វីកថា អំពីព្រះសាស្ដា ហើយទ្រង់បានសម្រេចព្រះអរហត្តផល ជាឯហិភិក្ខុ ក្នុងគ្រានោះឯង ។

សម័យក្រោយមក ព្រះនាងអនោជាទេវី ព្រមទាំងស្រីស្នំដែលជាពួកបរិវារ បានឮនូវដំណឹងនោះហើយ ទើបយាងទៅកាន់សំណាក់ នៃព្រះសាស្ដា បានស្ដាប់ព្រះធម្មទេសនា របស់ព្រះអង្គហើយ ក៏បានសម្រេចជាព្រះសោតាបន្ន បន្ទាប់មក ព្រះនាងបានសាងផ្នួសជានាងភិក្ខុនី ក្នុងសំណាក់ នៃនាងភិក្ខុនី ឈ្មោះ ឧប្បលវណ្ណាថេរី មួយអន្លើដោយពួកបរិវារ ហើយបានសម្រេចព្រះអរហត្ត

ផល ទាំងអស់គ្នា ក្នុងគ្រានោះឯងហោង ។

សម័យថ្ងៃមួយ ពួកភិក្ខុទាំងឡាយ បានឮសំឡេងដែលព្រះមហាកប្បិនត្ថេរ បានឧទាន ថា "សុខហ្ន៎! ៗ" ទើបនាំគ្នាទៅក្រាបទូលថ្វាយ ដល់ព្រះសាស្តា ថា "ព្រះមហាកប្បិនត្ថេរ បានឧទានប្រារព្ធនូវសេចក្តីសុខ ក្នុងរាជ្យសម្បត្តិ" ។

ព្រះសាស្តា ទ្រង់ត្រាស់ជានារ៉ាប់រង ថា "ព្រះថេរៈ មិនបានឧទានប្រារព្ធសេចក្តីសុខ ក្នុងរាជ្យសម្បត្តិទេ គឺ ឧទានប្រារព្ធសេចក្តីសុខ ក្នុងព្រះនិព្វានទេតើ" ដូច្នេះហើយ ទ្រង់ត្រាស់ព្រះគាថានេះថា៖

**ធម្មប្បីតិ សុខំ សេតិ វិប្បសន្នេន ចេតសា**
**អរិយប្បវេទិតេ ធម្មេ សទា រមតិ បណ្ឌិតោ ។**

បណ្ឌិត ដែលមានសេចក្តីឆ្អែត ក្នុងព្រះធម៌ មានចិត្តជ្រះថ្លាហើយ រមែងដេកជាសុខ រមែងត្រេកអរ ក្នុងធម៌ ដែលព្រះអរិយៈប្រកាសទុកហើយ សព្វៗ កាល ។

♣ ❉ ♣

## ៦៤- រឿង បណ្ឌិតសាមណេរ

ព្រះបរមសាស្តា ទ្រង់ប្រារព្ធបណ្ឌិតសាមណេរ ជាបុត្ររបស់ញោមឧបដ្ឋាកព្រះសារីបុត្រ ក្នុងក្រុងសាវត្ថី ។ បណ្ឌិតសាមណេរ បានបំពេញបុណ្យកុសលទុកមកពីជាតិមុន ពេលមានអាយុបាន ៧ ឆ្នាំ បានចូលទៅបួសជាសាមណេរ ក្នុងសំណាក់ព្រះសារីបុត្រ ។

សម័យថ្ងៃមួយ លោកបាននិមន្តទៅបិណ្ឌបាត ជាមួយព្រះ

# រឿងបណ្ឌិតសាមណេរ

សារីបុត្រ បានឃើញអ្នកស្រែ កំពុងតែបាចទឹកបញ្ចូលទៅ ក្នុងស្រែ ឃើញជាងធ្វើព្រួញ កំពុងតែពត់ព្រួញឲ្យត្រង់ ឃើញជាងឈើកំពុងតែចាំងឈើ ធ្វើបានតាមសេចក្ដីត្រូវការរបស់ខ្លួន ហើយបានកំណត់យកមកធ្វើជាអារម្មណ៍ គិតអប់រំទូន្មានខ្លួន ឲ្យបានបែបបទល្អ ទើបថ្វាយបង្គំសុំលាព្រះសារីបុត្រ វិលត្រឡប់មកកាន់វត្តវិញ រួចបានផ្ដែផ្ដាំនឹងព្រះថេរៈ ឲ្យយកបិណ្ឌបាតមកជូនផង បន្តិចក្រោយមក សាមណេរ ក៏បាននិមន្តមកដល់វត្ត ហើយបានចូលទៅ ក្នុងបន្ទប់ បិទទ្វារកុដិ យ៉ាងជិត គង់ធ្វើសមាធិ ពិចារណាពងកាយ របស់ខ្លួន ឲ្យធ្លាក់ចូលទៅ ក្នុងត្រៃលក្ខណ៍ទាំង ៣ ។

ក្នុងគ្រានោះ បណ្ឌុកម្ពលសិលាអាសន៍ របស់សក្កទេវរាជ បានសំដែងអាការក្ដៅ ខុសប្លែកពីប្រក្រតី ដោយអំណាចនៃតេជានុភាព របស់សាមណេរនោះ ។ សក្កទេវរាជ ទ្រង់ព្រះចិន្ដាពិចារណាហើយ ទើបទ្រង់ទតព្រះនេត្រឃើញបណ្ឌិតសាមណេរ កំពុងតែគង់ធ្វើសមាធិ អប់រំទូន្មានចិត្តរបស់ខ្លួន ទើបទ្រង់ត្រាស់បញ្ជា ឲ្យមហារាជទាំង ៤ ទៅចាំយាមការពារជុំវិញវត្ត ដើម្បីកុំឲ្យមានសំឡេងសត្វយំ នាំឲ្យមានការរំខាន ដល់សាមណេរ ទ្រង់បញ្ជាចន្ទិមទេវបុត្រ និងសុរិយទេវបុត្រ ឲ្យបញ្ឈប់មណ្ឌលរស្មីរបស់ខ្លួនសិន ចំណែកព្រះអង្គ ទ្រង់យាម នៅត្រង់ខ្លោងទ្វារវត្ត ។

ក្នុងខណៈនោះឯង មានសភាពស្ងប់ស្ងាត់ល្អណាស់ ធ្វើឲ្យសាមណេរ មានចិត្តមូល មានអារម្មណ៍តែមួយ ធ្វើឲ្យបានសម្រេច

ផល ៣ ខាងដើម ដោយលំដាប់ នៅសល់តែព្រះអរហត្តផលមួយប៉ុណ្ណោះឯង ។

ព្រះសាស្តា ទ្រង់ជ្រាប ថា "បើព្រះសារីបុត្រ យកភត្តាហារទៅឲ្យសាមណេរ ក្នុងពេលជាមួយគ្នានោះ នឹងធ្វើមិនឲ្យសាមណេរបានសម្រេចព្រះអរហត្តផល" ហើយ ទ្រង់យាងមក ប្រថាប់គង់នៅត្រង់មាត់ទ្វារព្រះវិហារ ។ កាលព្រះសារីបុត្រ និមន្តមកដល់ហើយ, ព្រះសាស្តា ទ្រង់ត្រាស់សួរប្រស្នាធម៌ ជាមួយនឹងព្រះថេរៈ ។ លុះចប់ប្រស្នាធម៌ហើយ សាមណេរ ក៏បានសម្រេចព្រះអរហត្តផល ។ ព្រះសាស្តា ទ្រង់ត្រាស់ឲ្យព្រះសារីបុត្រ យកភត្តាហារ ទៅប្រគេន ដល់សាមណេរ ។

ពេលបណ្ឌិតសាមណេរ ឆាន់នូវភត្តាហារហើយ, សុរិយទេវបុត្រ ក៏បានបញ្ចេញ នូវពន្លឺភ្លឺស្វាងរុងរឿងឡើង ។ ព្រះអាទិត្យ ក៏បានប្រាកដ នៅក្នុងវេលាថ្ងៃរសៀល ។

ភិក្ខុទាំងឡាយ បានឃើញហេតុអស្ចារ្យដូច្នេះហើយ ក៏កើតសេចក្តីសង្ស័យភ្ញាម បានសន្ទនាគ្នា ថា "ថ្ងៃ ដូចជាបែររសៀល អ្វីក៏លឿនម្ល៉េះ? សាមណេរ ទើបតែនឹងឆាន់ចង្ហាន់រួចហើយថ្មីៗ តើមានហេតុអ្វីហ្ន៎?" ។

ព្រះសាស្តា ស្តេចយាងមក ក្នុងទីប្រជុំនោះហើយ ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ពេលដែលអ្នកមានបុណ្យ ធ្វើសមណធម៌ សុរិយទេវបុត្រ បានចាប់មណ្ឌលព្រះអាទិត្យទុក..." ដូច្នេះហើយ

ទ្រង់ត្រាស់ នូវព្រះគាថានេះ ថា ៖

**ឧទកញ្ហិ នយន្តិ នេត្តិកា**
**ឧសុការា នមយន្តិ តេជនំ**
**ទារុំ នមយន្តិ តច្ឆកា**
**អត្តានំ ទមយន្តិ បណ្ឌិតា ។**

ជម្មតា អ្នកបង្ហូរទឹក តែងបង្ហូរទឹកទៅ, អ្នកធ្វើព្រួញ តែងពត់ព្រួញ (ឲ្យត្រង់) អ្នកចាំងឈើ តែងចាំងឈើ, រីឯ បណ្ឌិតទាំងឡាយ តែងទូន្មានអប់រំខ្លួន (ឲ្យបានល្អ ដូច្នោះដែរ) ។

❀ ❀ ❀

## ៦៥- រឿង ព្រះលកុណ្ដកភទ្ទិយ:

ព្រះបរមសាស្តា ទ្រង់ប្រារព្ធ នូវព្រះលកុណ្ដកភទ្ទិយត្ថេរ ។ ពួកភិក្ខុ និង សាមណេរទាំងឡាយ ដែលជាបុថុជ្ជន បានឃើញព្រះថេរៈ ហើយនាំគ្នាចាប់សិរសាលេងខ្លះ ចាប់ត្រចៀកលេងខ្លះ ចាប់ច្រមុះលេងខ្លះ ហើយនិយាយសើចលេង ដោយប្រការផ្សេងៗ ។ ព្រះលកុណ្ដកភទ្ទិយៈ កាលបើពួកភិក្ខុ និង សាមណេរ ប្រឡែងលេងយ៉ាងនេះហើយ ក៏លោកមិនមានសេចក្តីក្រោធខឹង ចំពោះភិក្ខុ និង សាមណេរទាំងនោះដែរ ។

ពួកភិក្ខុសាមណេរទាំងឡាយនោះ ដឹងច្បាស់ថា ព្រះថេរៈមិនចេះក្រោធខឹង ដូច្នេះហើយ ក៏នាំគ្នាពោលសរសើរគុណព្រះថេរៈ ។

ព្រះសាស្តា ស្តេចយាងមក ក្នុងទីប្រជុំនោះហើយ ទ្រង់ត្រាស់

ថា "ម្នាលភិក្ខុទាំងឡាយ ព្រះខីណាស្រព មិនក្រោធខឹង មិនញាប់ញ័រ ដូចជាភ្នំថ្មតាន់" ដូច្នេះហើយ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

**សេលោ យថា ឯកឃនោ   វាតេន ន សមីរតិ**
**ឯវំ  និន្ទាបសំសាសុ   ន សម្មិញ្ជន្តិ បណ្ឌិតា ។**

ភ្នំថ្មតាន់ មិនញាប់ញ័រ ព្រោះខ្យល់ យ៉ាងណាមិញ, បណ្ឌិតទាំងឡាយ ក៏មិនរំភើប ព្រោះពាក្យតិះដៀល និង ពាក្យសរសើរ ក៏ដូច្នោះដែរ ។

♣ ❈ ♣

## ៦៦- រឿង មាតានាងកាណា

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវមាតារបស់នាងកាណា ដែលបានរៀបចំធ្វើនំ ដើម្បីជូនកូនស្រី របស់ខ្លួនទៅត្រកូលស្វាមី ។ គ្រានោះ មានភិក្ខុ ៤ រូប បានផ្លាស់ប្តូរគ្នា ចូលទៅបិណ្ឌបាត, ភិក្ខុ មួយរូបៗ ចូលទៅបិណ្ឌបាត ដល់ទៅ ៤ លើក រហូតដល់មាតា របស់នាងកាណា ធ្វើនំមិនទាន់ ដែលជាហេតុធ្វើឲ្យយឺតយូរដំណើរ ក្នុងការជូនកូនស្រីរបស់ខ្លួន ទៅត្រកូលនៃស្វាមី ។ ព្រោះតែការយឺតយូរនេះឯងបានជាស្វាមី របស់នាងកាណា រៀបការជាមួយស្រីថ្មីទៀត ។ នាងកាណា បានដឹងរឿងនេះហើយ ក៏មានចិត្តក្រោធខឹង នឹងពួកភិក្ខុទាំងនោះ យ៉ាងខ្លាំង ឃើញពួកភិក្ខុ ពេលណា ក៏ជេរប្រទេច តិះដៀលគ្រប់បែបយ៉ាង មិនរើសមុខថា អង្គណាជាអង្គណាឡើយ ។

ព្រះសាស្តា ទ្រង់យាងទៅ ទេសនាប្រោសនាងកាណា ឲ្យ

-១១២-

# រឿង មាតានាងកាណា

នាងបានសម្រេចព្រះសោតាបត្តិផលហើយ ស្តេចយាង តាមផ្លូវព្រះបរមរាជវាំង ។ ព្រះបាទបសេនទិកោសល ទ្រង់ទតព្រះនេត្រឃើញព្រះសាស្តា ហើយទើបស្តេចយាងមកគាល់ ។

ព្រះសាស្តា ទ្រង់ត្រាស់រឿងនាងកាណា តាំងពីដើមមករហូតដល់នាងបានសម្រេចសោតាបត្តិផល ឲ្យព្រះរាជាទ្រង់ជ្រាប ។ ព្រះរាជា ទ្រង់មានព្រះទ័យ សោមនស្សជាទីបំផុត ហើយទ្រង់បានយកនាងកាណានោះ ទៅចិញ្ចឹម ដូចជាធីតា របស់ព្រះអង្គ ។ នាងកាណាបានជាភរិយារបស់មហាអាមាត្យ ។ ចាប់តាំងពីពេលនោះមក នាងមានចិត្តជ្រះថ្លា ចេះធ្វើបុណ្យកុសល ក្នុងព្រះពុទ្ធសាសនា តែនាងមិនបានទទួលភិក្ខុដែលខ្លួនត្រូវឧបដ្ឋាក ព្រោះភិក្ខុទាំងនោះ បានរាងចាលចាប់តាំងតែអំពីពេលដែលត្រូវនាងជេរប្រទេជមកម្ល៉េះ ។ នាង បានដាក់វេន ឲ្យបុរសឈរចាំត្រង់ មាត់ទ្វារនគរ ដើម្បីនិមន្តលោកឲ្យមកផ្ទះរបស់ខ្លួន ហើយបានបំពេញនូវបុណ្យកុសល បរិច្ចាគទានផ្សេង ៗ ពុំដែលដាច់ឡើយ ។

ពួកភិក្ខុទាំងឡាយ ប្រជុំគ្នា និយាយពីរឿងនាងកាណា ហើយពោលសរសើរគុណ របស់ព្រះសាស្តា ។

ព្រះសាស្តា ទ្រង់បានត្រាស់ នូវព្រះគាថានេះ ថា ៖

**យថាបិ រហទោ គម្ភីរោ  វិប្បសន្នោ អនាវិលោ**
**ឯវំ ធម្មានិ សុត្វាន  វិប្បសីទន្តិ បណ្ឌិតា ។**

អន្លង់ទឹកដែលជ្រៅ រមែងថ្លាមិនល្អក់ យ៉ាងណា, បណ្ឌិតទាំង

គាថាធម្មបទប្រែ

*ឡាយបើបានស្តាប់ធម៌ទេសនាហើយ រមែងជ្រះថ្លាស៊ប់ យ៉ាងនោះ ។*

♣ ❇ ♣

## ៦៧- រឿង បញ្ចសតភិក្ខុ

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវភិក្ខុ ៥០០ រូប នៅពេលដែលព្រះអង្គគង់ចាំវស្សា ក្នុងទីក្រុងវេរញ្ជា រហូតដល់បានចួបប្រទះនឹងពេលដែលមានភិក្ខា រកបានដោយលំបាក ។ ពួកភិក្ខុទាំងនោះ មានសេចក្តីលំបាក យ៉ាងខ្លាំង ក្នុងចង្ហាន់បិណ្ឌបាត ទោះជាយ៉ាងនោះក៏ដោយ ភិក្ខុទាំងនោះ ក៏នៅតែមានអាការស្ងប់ស្ងៀម តាមសមណវិស័យ លុះចេញព្រះវស្សាហើយ ក៏បាននិមន្តទៅវត្តជេតពន នាក្រុងសាវត្ថី ជាមួយនឹងព្រះសាស្តា ។*

*ពួកមហាជន បានប្រគេនអាគន្តុកភត្ត ជាច្រើន ដល់ភិក្ខុទាំងនោះ ក្នុងពេលនោះ មានវិឃាសាទជន គឺ ក្មេងវត្តចំនួន ៥០០ នាក់ អាស្រ័យពួកភិក្ខុ នៅក្នុងព្រះវិហារ ពេលដែលពួកគេទទួលភោជនរួចហើយ ក៏នាំគ្នាលេងប្រដាល់ប្រតប់ លោតប្រឡែងគ្នាលេង តាមទំនើងចិត្ត ឥតមានការខ្មាសអៀនបន្តិចសោះ ។ ពួកភិក្ខុ បានឃើញយ៉ាងនេះហើយ ក៏បានរិះគន់ នូវកិរិយាមិនសមរម្យ របស់ពួកក្មេងវត្តទាំងនោះ ។*

*ព្រះសាស្តា ស្តេចយាងមក ក្នុងទីប្រជុំ ហើយទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

សព្វត្ថ វេ សប្បុរិសា វជន្តិ

-១១៤-

រឿង ព្រះធម្មិកត្ថេរ

**ន កាមកាមា លបយន្តិ សន្តោ**
**សុខេន ផុដ្ឋា អថ វា ទុក្ខេន**
**ន ឧច្ចាវចំ បណ្ឌិតា ទស្សយន្តិ ។**

*សប្បុរសទាំងឡាយ តែងលះ (ឆន្ទរាគ) ក្នុងធម៌ទាំងពួង, ពួកលោកដែលស្ងប់រម្ងាប់ មិនអន្ទះអន្ទែង ព្រោះសេចក្តីប្រាថ្នា ក្នុងកាម, ពួកបណ្ឌិត បើសេចក្តីសុខ ឬ ទុក្ខ ពាល់ត្រូវហើយ រមែងមិនសំដែងនូវអាការឡើងចុះឡើយ ។*

❃ ❃ ❃

៦៨- រឿង ព្រះធម្មិកត្ថេរ

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវព្រះធម្មិកត្ថេរ ។ កាលដែលលោកនៅជាគ្រហស្ថ, ជាឧបាសកម្នាក់ដែលមានសទ្ធាជ្រះថ្លា យ៉ាងខ្លាំង ក្នុងព្រះពុទ្ធសាសនា ប្រាថ្នាចង់បួសជាភិក្ខុ ហើយក៏បានប្រឹក្សាជាមួយនឹងភរិយា របស់ខ្លួន ។ ភរិយា មិនចង់ឲ្យទៅបួសទេ បាននិយាយប្រាប់ ថា “សូមបងកុំអាលទៅបួសអី ចាំឲ្យកូនយើង ក្នុងផ្ទៃប្រសូតមកសិន” ។ លុះដល់ទារក ប្រសូតមកហើយ, ភរិយា បានប្រាប់ស្វាមីទៀត ថា “សូមបងរង់ចាំឲ្យកូនតូចនេះ ចេះដើរបន្តិចសិនចាំទៅបួសចុះ” ។ ឧបាសក ឃើញដូចជាគ្មានបានការសោះ ទើបលួចរត់ទៅបួសជាភិក្ខុ ខំព្យាយាម បំពេញសមណធម៌ រហូតដល់បានសម្រេចព្រះអរហត្តផល ។*

*ចំណែកភរិយានៅម្នាក់ឯងពុំបាន ក៏ចូលទៅបួសជាភិក្ខុនី ក្នុង*

ព្រះពុទ្ធសាសនា ហើយបានសម្រេចព្រះអរហត្តផលដូចគ្នាដែរ ។

ភិក្ខុទាំងឡាយ ប្រជុំគ្នានិយាយរឿងព្រះធម្មិកត្ថេរ ។

ព្រះបរមសាស្ដាចារ្យ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

ន អត្តហេតុ ន បរស្ស ហេតុ
ន បុត្តមិច្ឆេ ន ធនំ ន រដ្ឋំ
ន ឥច្ឆេយ្យ អធម្មេន សមិទ្ធិមត្តនោ
ស សីលវា បញ្ញវា ធម្មិកោ សិយា ។

បណ្ឌិតមិនគួរធ្វើអាក្រក់ ព្រោះហេតុនៃខ្លួន មិនគួរធ្វើអាក្រក់ ព្រោះហេតុនៃអ្នកដទៃ មិនគួរប្រាថ្នាកូន មិនគួរប្រាថ្នាទ្រព្យ មិនគួរប្រាថ្នារដ្ឋ មិនគួរប្រាថ្នាសិទ្ធិ ដើម្បីខ្លួន ដោយហេតុមិនមែនជាធម៌ឡើយ លោកគួរជាអ្នកមានសីល មានប្រាជ្ញា ប្រកបដោយធម៌ ។

♣ ❇ ♣

## ៦៩- រឿង ធម្មស្សវនៈ

ព្រះបរមសាស្ដា ទ្រង់ប្រារព្ធនូវការស្ដាប់ធម៌ របស់មហាជន ក្នុងទីក្រុងសាវត្ថី ។ សម័យថ្ងៃមួយ មហាជន បានប្រជុំគ្នា ធ្វើបុណ្យឲ្យទាន មានធម្មស្សវនៈ គឺស្ដាប់ព្រះធម៌ទេសនា រហូតដល់ព្រឹកឡើង ពួកខ្លះ មានសេចក្ដីត្រេកត្រអាល ក្នុងកាម បានត្រឡប់ទៅផ្ទះវិញក៏មាន ពួកខ្លះ ដេកលក់ ក្នុងព្រះវិហារ ដល់ព្រឹកឡើងត្រឡប់ទៅផ្ទះវិញក៏មាន ។ ភិក្ខុទាំងឡាយ បានឃើញយ៉ាងដូច្នេះហើយ ក៏ជួបជុំគ្នានិយាយអំពីរឿងនោះ ។

រឿង អាគន្តុកភិក្ខុ

ព្រះសាស្តា ស្តេចយាងមក ក្នុងទីប្រជុំ សំដែងធម្មីកថា ហើយ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

អប្បកា តេ មនុស្សេសុ　　យេ ជនា បារគាមិនោ
អថាយំ ឥតរា បជា　　តីរមេវានុធាវតិ ។
យេ ច ខោ សម្មទក្ខាតេ　　ធម្មេ ធម្មានុវត្តិនោ
តេ ជនា បារមេស្សន្តិ　　មច្ចុធេយ្យំ សុទុត្តរំ ។

បណ្តាមនុស្សទាំងឡាយ ពួកជនណា ដែលឆ្លងដល់ត្រើយ គឺ ព្រះនិព្វាន ពួកជននោះ មានប្រមាណតិចពេកណាស់, ចំណែកឯពួកសត្វ ក្រៅពីនេះ រមែងស្ទុះទៅកាន់ត្រើយ (សក្កាយទិដ្ឋិ) ។

ជនទាំងឡាយណា ប្រព្រឹត្តតាមធម៌ក្នុងធម៌ដែលព្រះតថាគត ទ្រង់សំដែងទុកហើយ ដោយប្រពៃ ជនទាំងឡាយនោះ នឹងឆ្លងនូវលំនៅនៃមច្ចុ ដែលមិនងាយនឹងឆ្លងបាន ហើយដល់នូវព្រះនិព្វាន ។

❁ ❁ ❁

៧០- រឿង អាគន្តុកភិក្ខុ

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវភិក្ខុអាគន្តុកៈ ៥០០ រូប ដែលចាំវស្សា ក្នុងទីក្រុងកោសល ។ លុះពេលចេញវស្សាហើយ ភិក្ខុទាំងនោះ ក៏បាននាំគ្នាទៅក្រាបថ្វាយបង្គំព្រះសាស្តា នៅវត្តជេតពន ក្រុងសាវត្ថី ។

ព្រះសាស្តា កាលទ្រង់សំដែងធម្មីកថា ដើម្បីរម្ងាប់ នូវសឹកសត្រូវ នៃភិក្ខុទាំងនោះ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

-១១៧-

គាថាធម្មបទប្រែ

កណ្ហំ ធម្មំ វិប្បហាយ សុក្កំ ភាវេថ បណ្ឌិតោ
ឱកា អនោកមាគម្ម វិវេកេ យត្ថ ទូរមំ
តត្រាភិរតិមិច្ឆេយ្យ ហិត្វា កាមេ អកិញ្ចនោ
បរិយោទបេយ្យ អត្តានំ ចិត្តក្លេសេហិ បណ្ឌិតោ ។
យេសំ សម្ពោធិយង្គេសុ សម្មា ចិត្តំ សុភាវិតំ
អាទានប្បដិនិស្សគ្គេ អនុបាទាយ យេ រតា
ខីណាសវា ជុតិមន្តោ តេ លោកេ បរិនិព្វុតា ។

*បណ្ឌិតគួរលះបង់ធម៌ខ្មៅចេញ ញុំាងធម៌-ស ឲ្យចំរើនឡើង ចេញចាកអាល័យគឺកាមគុណ ហើយឈមទៅរកព្រះនិព្វាន ជាធម្ម-ជាត មិនមានអាល័យ គប្បីលះបង់កាមទាំងឡាយចេញ ជាអ្នកមិនមានកង្វល់ ប្រាថ្នានូវសេចក្តីត្រេកអរ ក្នុងវិវេក ដែលពួកសត្វត្រេកអរបាន ដោយកម្រនោះ, បណ្ឌិត គួរញុំាងខ្លួន ឲ្យស្អាតផូរផង់ ចាកគ្រឿងសៅហ្មងចិត្ត ។ ចិត្ត ដែលបណ្ឌិតទាំងឡាយណា បានអប់រំល្អហើយ ក្នុងអង្គនៃធម៌ជាគ្រឿងត្រាស់ដឹងទាំងឡាយ ឬ បណ្ឌិតទាំងឡាយណា មិនប្រកាន់មាំ ត្រេកអរ ក្នុងការលះនូវសេចក្តីប្រកាន់មាំ បណ្ឌិតទាំងឡាយនោះៗ រមែងជាអ្នកអស់អាសវៈ មានសេចក្តីរុងរឿង បរិនិព្វាន ក្នុងលោក ។*

**ចប់ បណ្ឌិតវគ្គ ទី ៦**

# អរហន្តវគ្គ ទី ៧

## ៧១- រឿង ហ្មជីវក

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវបញ្ហាដែលហ្មជីវក បានក្រាបទូលសួរ នៅវេលាដែលភិក្ខុទេវទត្ត គិតនឹងធ្វើគុតព្រះអង្គ គឺទម្លាក់ដុំថ្មមក ពីលើភ្នំគិជ្ឈកូដ ។ ដុំថ្មនោះ បានធ្លាក់មកប៉ះទង្គិចគ្នា បែកជាពីរបំណែក, បំណែកមួយ បានរមៀលធ្លាក់មក ត្រូវព្រះបាទា របស់ព្រះមានព្រះភាគធ្វើឲ្យព្រះលោហិតជាំ ។ ភិក្ខុទាំងឡាយ បាននិមន្តព្រះអង្គ យាងទៅកាន់ជីវកម្ពវ័ន ។ ហ្មជីវក បានយកថ្នាំ មកបិទថ្វាយហើយយកកំណាត់សំពត់ មករុំទុកមួយរយៈសិន រួចក្រាបថ្វាយបង្គំលាព្រះអង្គ ដើម្បីទៅជួយព្យាបាលបុរសម្នាក់ទៀត ស្រេចហើយនឹងវិលត្រឡប់មក ស្រាយសំពត់ដែលបានរុំទុកនោះចេញ។ កាលដែលហ្មជីវក ចេញទៅព្យាបាលអ្នកជម្ងឺនោះ, វេលា ក៏ព្រលប់ល្ងាច ។ អ្នកយាមទ្វារ ក៏បានបិទនូវទ្វារក្រុងទាំងអស់, ហ្មជីវក ចូលទៅរកព្រះសាស្តាមិនបាន ហើយមានសេចក្តីព្រួយបារម្ភ យ៉ាងខ្លាំង ។

ព្រះសាស្តា ទ្រង់ជ្រាបនូវសេចក្តីវិតក្កៈ របស់ហ្មជីវក ហើយទ្រង់ត្រាស់ឲ្យព្រះអានន្ទ ស្រាយថ្នាំនោះចេញ ។ លុះព្រឹកឡើង ទើបគេបើកទ្វារក្រុង, ហ្មជីវក ប្រញាប់ប្រញាល់ ចូលមកគាល់ព្រះអង្គ ហើយបានក្រាបទូល នូវសេចក្តីវិតក្កៈ របស់ខ្លួន ថ្វាយព្រះសាស្តាទ្រង់ជ្រាប ។

ព្រះបរមសាស្តា ទ្រង់ត្រាស់ថា “តថាគត មិនមានសេចក្តីក្តៅក្រហាយឡើយ” ដូច្នេះហើយ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

គាថាធម្មបទប្រែ

**គតទ្ធិនោ វិសោកស្ស វិប្បមុត្តស្ស សព្វធិ**
**សព្វគន្ថប្បហីនស្ស បរិឡាហោ ន វិជ្ជតិ ។**

*សេចក្ដីក្ដៅក្រហល់ក្រហាយ រមែងមិនមាន ដល់លោកអ្នកមានផ្លូវឆ្ងាយដើរដល់ហើយ មិនមានសេចក្ដីសោក រួចស្រឡះចាកធម៌ទាំងពួង មានកិលេសជាគ្រឿងចាក់ស្រេះទាំងពួង លះបង់ចោលអស់ហើយ ។*

♣ ❇ ♣

## ៧២- រឿង ព្រះមហាកស្សបត្ថេរ

*ព្រះបរមសាស្ដា ទ្រង់ប្រារព្ធនូវព្រះមហាកស្សបត្ថេរ ។ ព្រះមហាកស្សប: មានញាតិញោមស្គាល់ជាច្រើន នៅក្នុងក្រុងរាជគ្រឹះ ។ ភិក្ខុទាំងឡាយ បានរិះគន់ព្រះថេរ: ថា "ជាអ្នកជាប់ជំពាក់ ក្នុងត្រកូលញាតិញោម និង ក្នុងបច្ច័យទាំងឡាយ" ។*

*ព្រះសាស្ដា ជ្រាបហើយ ទ្រង់ធានារ៉ាប់រង ថា "ព្រះមហាកស្សប: មិនបានជាប់ជំពាក់ ក្នុងអ្វីៗ ទាំងអស់" ហើយទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

**ឧយ្យុញ្ជន្តិ សតិមន្តោ ន និកេតេ រមន្តិ តេ**
**ហំសាវ បល្លលំ ហិត្វា ឱកមោកំ ជហន្តិ តេ ។**

*ព្រះខីណាស្រពទាំងឡាយ មានស្មារតី រមែងខ្វល់ខ្វាយ មិនត្រេកអរ ក្នុងទីនៅអាស្រ័យ លោកលះបង់ចោលស្រឡះនូវអាល័យ ដូចជាសត្វហង្ស លះបង់កក់ហើរទៅ យ៉ាងដូច្នោះឯង ។*

## ៧៣- រឿង ព្រះពេលដ្ឋសីសត្ថេរ

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវព្រះពេលដ្ឋសីសត្ថេរ ដ៏មានអាយុ ។ ព្រះថេរៈរូបនេះ និមន្តទៅបិណ្ឌបាត បានបាយច្រើន, បាយដែលសល់ពីឆាន់ លោកយកទៅហាល ធ្វើជាបាយក្រៀម ពេលណាលោកត្រូវការឆាន់ ក៏បានយកបាយក្រៀមនោះ មកត្រាំទឹក ហើយឆាន់ យូរៗ ទើបទៅបិណ្ឌបាតម្តង ។ មិនយូរប៉ុន្មាន រឿងនេះ ក៏បានឮទៅដល់ពួកភិក្ខុទាំងឡាយៗ បាននាំរឿងនេះ ទៅក្រាបទូលថ្វាយព្រះសាស្តាទ្រង់ជ្រាប ។

ព្រះសាស្តា ទ្រង់ត្រាស់ហៅភិក្ខុសង្ឃមកប្រជុំគ្នាហើយ ទ្រង់បានបញ្ញត្តសិក្ខាបទ ហាមធ្វើការសន្សំទុក ទ្រង់បានប្រកាសថា "ព្រះថេរៈ ជាអ្នកមិនមានទោស ក្នុងរឿងនេះទេ ព្រោះព្រះអង្គមិនទាន់បានបញ្ញត្តសិក្ខាបទនេះទុកមកពីមុន និង ព្រះថេរៈ ធ្វើយ៉ាងនេះ ព្រោះភាពជាអ្នកមានសេចក្តីប្រាថ្នាតិច" យ៉ាងដូច្នេះហើយ ទ្រង់ត្រាស់ នូវព្រះគាថានេះ ថា ៖

យេសំ សន្និច្ចយោ នត្ថិ   យេ បរិញ្ញាតភោជនា
សុញ្ញតោ អនិមិត្តោ ច   វិមោក្ខោ យេស គោចរោ
អាកាសេវ សកុន្តានំ   គតិ តេសំ ទុរន្នយា ។

ជនទាំងឡាយណា មិនមានសេចក្តីសន្សំទុក ជនទាំងឡាយណា កំណត់ដឹងភោជនហើយ ជនទាំងឡាយណា មានសុញ្ញតវិមោក្ខ អនិមិត្តវិមោក្ខ នឹងអប្បណិហិតវិមោក្ខ ជាគោចរ, គតិ គឺដំណើររបស់ជនទាំងឡាយនោះៗ បុគ្គលកម្រដឹងបាន ដូចដំណើរនៃពួកសត្វស្លាប

ព្ធដ៏អាកាស យ៉ាងដូច្នោះឯង ។

❋ ❋ ❋

## ៧៤- រឿង ព្រះអនុរុទ្ធត្ថេរ

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវព្រះអនុរុទ្ធត្ថេរ ។ ថ្ងៃមួយ ព្រះថេរៈ និមន្តទៅស្វែងរកសំពត់បង្សុកូល ព្រោះលោកមានចីវរចាស់ដាច់ដាចទាំងអស់ ក៏ឃើញសំពត់ទិព្វដែលនាងទេពធីតា បានយកមកដាក់ លើគំនរសម្រាម ទើបលោកទាញយកសំពត់នោះមកដោយបង្សុកូលសញ្ញា ហើយយកសំពត់នោះ ធ្វើជាចីវរប្រើប្រាស់ ។

គ្រានោះឯង ព្រះសាស្តា ព្រមជាមួយព្រះអសីតិមហាសាវក ទ្រង់យាងទៅជួយធ្វើចីវរព្រះអនុរុទ្ធត្ថេរផងដែរ ។

ពួកមហាជន បាននាំគ្នាមកធ្វើចង្ហាន់បិណ្ឌបាត ដើម្បីថ្វាយព្រះពុទ្ធជាម្ចាស់ ព្រមទាំងព្រះភិក្ខុសង្ឃ ដែលបាននិមន្តមក ជួយធ្វើចីវរ រហូតដល់មានភោជនាហារនៅសល់ជាច្រើន ។ ពួកភិក្ខុទាំងឡាយ ឃើញយ៉ាងដូច្នេះហើយ ក៏បានតិះដៀល ថា "ព្រះអនុរុទ្ធត្ថេរមានបំណងចង់អួតអាង ឲ្យអ្នកផងគេដឹង ថា ខ្លួន មានញាតិញោមច្រើន ហើយបានឲ្យប្រជាជន យកចង្ហាន់បិណ្ឌបាត មកច្រើនលើសលប់ទៀតផង" ។

ព្រះសាស្តា មុននឹងទ្រង់ដោះស្រាយនូវពាក្យចោទ របស់ភិក្ខុទាំងអស់នោះ ទ្រង់ត្រាស់ថា "ព្រះខីណាស្រពទាំងឡាយ មិនដែលនិយាយពាក្យដែលទាក់ទង ដោយបច្ច័យឡើយ" ដូច្នេះហើយ ទ្រង់

-១២២-

រឿង ព្រះមហាកច្ចាយនត្ថេរ

ត្រាស់នូវព្រះគាថានេះ ថា ៖

យស្សាសវា បរិក្ខីណា អាហារេ ច អនិស្សិតោ
សុញ្ញតោ អនិមិត្តោ ច វិមោក្ខោ យស្ស គោចរោ
អាកាសេវ សកុន្តានំ បទន្តស្ស ទុរន្នយំ ។

ជនណា អស់អាសវៈហើយទាំងមិនអាស្រ័យ(តណ្ហានិងទិដ្ឋិ) ក្នុងអាហារ, ជនណា មានសុញ្ញតវិមោក្ខ អនិមិត្តវិមោក្ខ និង អប្បណិហិតវិមោក្ខ ជាគោចរ, គតិ គឺដំណើររបស់ជននោះៗ បុគ្គលកម្រដឹងបាន ដូចដំណើរ នៃពួកសត្វស្លាប ក្នុងអាកាស យ៉ាងដូច្នោះឯង ។

♣ ❈ ♣

៧៥- រឿង ព្រះមហាកច្ចាយនត្ថេរ

ព្រះបរមសាស្ដា ទ្រង់ប្រារព្ធនូវព្រះមហាកច្ចាយនត្ថេរ ។ ព្រះថេរៈ គង់ចាំវស្សា នៅក្នុងអវន្តីជនបទ ។ លុះបវារណា ចេញវស្សាហើយ ព្រះសាស្ដា ព្រមជាមួយនឹងព្រះមហាសាវ័ក បានប្រជុំគ្នា ក្នុងបុព្វារាម ទុកអាសនៈតែមួយ សម្រាប់ព្រះមហាកច្ចាយនៈ ។ ពេលនោះ សក្កទេវរាជ ទ្រង់យាងចុះមកធ្វើសក្ការបូជាហើយ ទ្រង់ទតព្រះនេត្រឃើញព្រះមហាកច្ចាយនៈនិមន្តមកហើយ ទ្រង់សោមនស្ស រីករាយ ក្រាបថ្វាយបង្គំ បូជាដោយផ្កាកម្រងគ្រឿងក្រអូបដែលជាទិព្វ ។ ពួកភិក្ខុទាំងឡាយ បានរិះគន់ តិះដៀល ដល់សក្កទេវរាជ ថា "ធ្វើនូវសក្ការបូជា ដោយរើសមុខ" ។

ព្រះសាស្ដា ទ្រង់ត្រាស់ថា "ភិក្ខុ ដែលសង្រួមឥន្ទ្រិយ៍ ដូចជា

ព្រះមហាកច្ចាយនៈនេះ នឹងជាទីស្រឡាញ់ របស់ទេវតាទាំងឡាយ" ដូច្នេះហើយ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

**យស្សិន្ទ្រិយានិ សមថង្គតានិ**
**អស្សា យថា សារថិនា សុទន្តា**
**បហីនមានស្ស អនាសវស្ស**
**ទេវាបិ តស្ស បិហយន្តិ តាទិនោ ។**

ឥន្ទ្រីយ៍ទាំងឡាយ របស់បុគ្គលណា ដល់នូវការស្ងប់រម្ងាប់ ដូចជាសេះ ដែលនាយសារថីហ្វឹកហាត់ល្អហើយ, សូម្បីទេវតា នឹងមនុស្សទាំងឡាយ ក៏ស្រឡាញ់បុគ្គលនោះឯង ដែលមានមានះលះបង់ហើយ មិនមានអាសវៈ ជាបុគ្គលមានចិត្តនឹងធឹង មិនញាប់ញ័រ ។

## ៧៦- រឿង ព្រះសារីបុត្តត្ថេរ

ព្រះបរមសាស្តា ទ្រង់បានប្រារព្ធ នូវព្រះសារីបុត្រ ។ ពេលបវារណាចេញវស្សាហើយ, ព្រះថេរៈ មានបំណងចង់និមន្តទៅកាន់ទីចារិកផ្សេងៗ មានភិក្ខុជាច្រើនរូប ជូនដំណើរទៅផង លោកបានប្រាស្រ័យទាក់ទង ជាមួយនឹងភិក្ខុទាំងឡាយនោះ យ៉ាងស្និទ្ធស្នាល, តែមិនបានប្រាស្រ័យទំនាក់ទំនង ជាមួយនឹងភិក្ខុមួយរូបប៉ុណ្ណោះ ។ ជួនជាពេលនោះ ជាយសង្ឃាដី របស់ព្រះសារីបុត្រ បានប៉ះខ្លួនភិក្ខុរូបនោះៗ ក្រោធខឹងយ៉ាងខ្លាំងនឹងព្រះសារីបុត្រ ហើយបានទៅក្រាបទូល ដល់ព្រះសាស្តាថា "ព្រះសារីបុត្រ បានធ្វើខុសហើយ មិនព្រម

សុំទោសឡើយ” ។

ព្រះសាស្តា ទ្រង់បានត្រាស់ឲ្យភិក្ខុ ទៅនិមន្តព្រះសារីបុត្រមក ហើយ ទ្រង់ត្រាស់សួររឿងនោះ នឹងព្រះថេរៈ ៗ បានក្រាបទូល នូវការៈនៃខ្លួនលោក ជាអ្នកមានចិត្តស្មើដោយផែនដី ដោយទឹក ដោយភ្លើង និងស្មើដោយខ្យល់ជាដើម ។ ភ្លាមនោះ ក៏ស្រាប់តែមានសេចក្តីក្តៅក្រហាយ កើតឡើង ពេញរូបរាងកាយ របស់ភិក្ខុរូបនោះ ។

ព្រះសាស្តា ទ្រង់បានត្រាស់បញ្ជា ឲ្យព្រះសារីបុត្រ សុំខមាទោស នឹងភិក្ខុនោះ ។ ព្រះសារីបុត្រ បានអង្គុយប្រហោង ប្រណម្យអញ្ជលី សុំខមាទោសភិក្ខុនោះភ្លាម ។ ពួកភិក្ខុទាំងឡាយ បានពោលសរសើរគុណ របស់ព្រះថេរៈ ។

ព្រះសាស្តា ទ្រង់បានត្រាស់នូវព្រះគាថានេះ ថា ៖

> បឋវីសមោ នោ វិរុជ្ឈតិ
> ឥន្ទខីលូបមោ តាទិ សុព្វតោ
> រហទោវ អបេតកទ្ទមោ
> សំសារា ន ភវន្តិ តាទិនោ ។

ភិក្ខុណា មានចិត្តដូចជាផែនដី មិនក្រោធខឹង មានវត្តល្អ មានចិត្តនឹងធឹង ដូចជាសសរគោល មានចិត្តថ្លាស្អាត ដូចជាអន្លង់ប្រាសចាកភក់, សង្សារទាំងឡាយ របស់ភិក្ខុបែបនោះ មិនមានឡើយ ។

## គាថាធម្មបទប្រែ

### ៧៧- រឿង ព្រះកោសម្ពីវាសីតិស្សត្ថេរ

*ព្រះបរមសាស្ដា ទ្រង់ប្រារព្ធសាមណេរ របស់ព្រះតិស្សត្ថេរ ដែលនៅក្នុងក្រុងកោសម្ពី លោកបានសម្រេចព្រះអរហត្តផល និង បដិសម្ភិទា តាំងតែពីអាយុបាន ៧ ឆ្នាំ ក្នុងខណៈដែលដាក់កាំបិតកោរ ដល់សិរសា, តែព្រះតិស្សត្ថេរ ដែលជាព្រះឧបជ្ឈាយ៍ លោកនៅជា បុថុជ្ជននៅឡើយ ។*

*ក្នុងថ្ងៃមួយ ព្រះតិស្សត្ថេរ បាននាំសាមណេរ ទៅគាល់ព្រះ សាស្ដា នៅក្រុងសាវត្ថី លុះនិមន្តមកដល់ពាក់កណ្ដាលផ្លូវ ក៏ឈប់ សម្រាក នៅក្នុងព្រះវិហារមួយ ក្នុងរាត្រីយប់នោះ បានសិងរួមនៅ ជាមួយនឹងសាមណេរ ដល់យប់ជ្រៅ ព្រះឧបជ្ឈាយ៍ បានសិងលង់ លក់ឈឹងតែម្ដង ចំណែកឯ សាមណេរ បានគង់ធ្វើសមាធិ នៅក្បែរ គ្រែព្រះឧបជ្ឈាយ៍ ។ លុះដល់វេលាជិតភ្លឺ ព្រះឧបជ្ឈាយ៍ នឹកគិតថា "សាមណេរ បានសិងលក់" ទើបយកផ្ចិត មកគោះសាមណេរ ឲ្យ ក្រោកទៅខាងក្រៅ ដើម្បីកុំឲ្យមានទោស ព្រោះកិរិយាសិងរួមគ្នា ។ ពេលនោះ ចុងផ្ចិតបានត្រូវភ្នែកសាមណេរខ្វាក់ម្ខាង ។ សាមណេរ ធ្វើដូចជាមិនដឹងខ្លួន ថែមទាំងមិនបានប្រាប់ ឲ្យឧបជ្ឈាយ៍ដឹងផង ។*

*លុះវេលាព្រឹកឡើង សាមណេរ បានធ្វើវត្តប្រតិបត្តិ ដូចជា ប្រក្រតី ។ ព្រះឧបជ្ឈាយ៍ បានឃើញភ្នែកសាមណេរខ្វាក់ម្ខាង ក៏សួរ ថា "តើភ្នែក កើតអី សាមណេរ? " ។ សាមណេរ បានរៀបរាប់រឿង នោះ ឲ្យព្រះឧបជ្ឈាយ៍បានជ្រាប ។ ព្រះឧបជ្ឈាយ៍ បានដឹងរឿងនេះ*

ហើយ ក៏មានចិត្តតក់ស្លុតរន្ធត់ យ៉ាងខ្លាំង ហើយបានសុំខមាទោស នឹងសាមណេរ ៗ ក៏បាននិយាយលួងលោម មិនឲ្យព្រះឧបជ្ឈាយ៍កិតក័យថា "ទោសរបស់ព្រះគុណម្ចាស់មិនមានទេ នេះ គឺជាទោសរបស់វដ្តៈ ទេតើ" ។

ព្រះឧបជ្ឈាយ៍ ពេលនិមន្តទៅដល់ក្រុងសាវត្ថីហើយ ក៏បានក្រាបទូលរឿងរ៉ាវនេះ ថ្វាយព្រះសាស្តាទ្រង់ជ្រាប ។

ព្រះសាស្តា ទ្រង់បានត្រាស់នូវព្រះគាថានេះ ថា ៖

**សន្តំ តស្ស មនំ ហោតិ សន្តា វាចា ច កម្ម ច**
**សម្មទញ្ញា វិមុត្តស្ស ឧបសន្តស្ស តាទិនោ ។**

ចិត្តស្ងប់ វាចាស្ងប់ នឹងកាយកម្មក៏ស្ងប់ រមែងមានដល់លោកអ្នកដែលដឹង ដោយប្រពៃ រួចផុតស្រឡះ (ចាកពាគាទិក្កិលេស) ជាអ្នកស្ងប់រម្ងាប់ យ៉ាងដូច្នោះ ។

♣ ❇ ♣

## ៧៨- រឿង ព្រះសារីបុត្តត្ថេរ

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវព្រះសារីបុត្រ ។ ថ្ងៃមួយ ព្រះអង្គ ទ្រង់ទតព្រះនេត្រឃើញឧបនិស្ស័យរបស់ភិក្ខុ ៣០ រូប ដែលចាំវស្សា នៅក្នុងព្រៃ បាននិមន្តមកថ្វាយបង្គំព្រះអង្គៗ ទ្រង់ត្រាស់ហៅព្រះសារីបុត្រ មកសួរ ថា "សារីបុត្រ ជឿទេ ថា ឥន្ទ្រីយ៍ទាំង ៥ ដែលបុគ្គលបានធ្វើឲ្យច្រើន ធ្លាក់ចុះទៅកាន់អមតធម៌ មានអមតធម៌ជាទីបំផុត" ។

គាថាធម្មបទប្រែ

ព្រះថេរៈ បានក្រាបទូលថា "បពិត្រព្រះអង្គដ៏ចំរើន ក្នុងរឿងនេះ ខ្ញុំព្រះករុណា មិនត្រូវជឿព្រះដ៏មានព្រះភាគ អ្នកណា បានដឹងហើយ បានពាល់ត្រូវហើយ ដោយបញ្ញា អ្នកនោះ មិនត្រូវជឿអ្នកដទៃទេ" ។

គ្រានោះ ភិក្ខុទាំងឡាយ មិនយល់នូវសេចក្ដីនោះ ក៏និយាយគ្នាថា "ព្រះសារីបុត្រ ជាអ្នកមានមិច្ឆាទិដ្ឋិ មិនជឿព្រះសាស្ដា" ។

ព្រះសាស្ដា ទ្រង់ត្រាស់អធិប្បាយ ថា "តថាគត សួរថា អ្នកដែលមិនចំរើនឥន្ទ្រីយ៍ហើយ អាចធ្វើឲ្យជាក់ច្បាស់ នូវមគ្គផលបាន តើអ្នកជឿដែរឬទេ?" ។ ព្រះសារីបុត្រ បានក្រាបទូល ថា "ទូលព្រះបង្គំ មិនជឿ" ។

ព្រះសាស្ដា កាលទ្រង់ដោះស្រាយនូវសេចក្ដីនោះ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

**អស្សទ្ធោ អកតញ្ញូ ច សន្ធិច្ឆេទោ ច យោ នរោ**
**ហតាវកាសោ វន្តាសោ ស វេ ឧត្តមបោរិសោ ។**

នរជនណា មិនជឿអ្នកដទៃផង ស្គាល់ព្រះនិព្វានផង កាត់នូវគ្រឿង ត គឺ វដ្តៈ ផង មានឱកាសកំចាត់បង់ហើយផង មានសេចក្ដីប្រាថ្នាខ្ជាក់ចោលហើយផង, នរជននោះឯង ជាបុរសខ្ពង់ខ្ពស់បំផុត ។

* * *

៧៩- រឿង ព្រះខទិរវនិយរេវតត្ថេរ

ព្រះបរមសាស្ដា ទ្រង់ប្រារព្ធ នូវព្រះរេវតត្ថេរ ជាប្អូនប្រុស

របស់ព្រះសារីបុត្រ ។ កាលព្រះរេវតៈ មានអាយុបាន ៧ ឆ្នាំ, លោកបានរត់ទៅបួស នៅអាស្រ័យជាមួយនឹងព្រះភិក្ខុសង្ឃ ក្នុងស្រុកមួយ ហើយបានចូលទៅនៅក្នុងព្រៃសង្កែ ដើម្បីធ្វើសមណធម៌ រហូតដល់បានសម្រេចព្រះអរហត្តផល ក្នុងពាក់កណ្តាលវស្សានោះឯង ។

លុះដល់ចេញវស្សាហើយ, ព្រះសាស្តា ព្រមជាមួយនឹងភិក្ខុសង្ឃ ចំនួន ៥០០ ស្តេចយាងទៅកាន់ទីលំនៅ នៃរេវតសាមណេរ ។ សាមណេរ ដឹងថា ព្រះសាស្តា ស្តេចយាងមកហើយ ទើបបាននិមិត្តនូវព្រះគន្ធកុដី ទទួលព្រះអង្គ ហើយបាននិមិត្តនូវទីចង្ក្រមន៍ និង ទីនៅអាស្រ័យ ៥០០ សំរាប់ភិក្ខុ ៥០០ រូប ។ ក្នុងចំណោមភិក្ខុ ៥០០ នោះ មានភិក្ខុចាស់ ២ រូប បានឃើញនូវទីនៅអាស្រ័យ របស់សាមណេរ ហើយ ក៏គិតក្នុងចិត្ត ថា រេវតសាមណេរ ធ្វើសេនាសនៈ យ៉ាងនេះ ប្រាកដជាមិនអាចនឹងធ្វើ នូវសមណធម៌បានឡើយ" ។

ព្រះសាស្តា ទ្រង់ជ្រាបវារចិត្ត របស់ភិក្ខុទាំងពីររូបនោះ ជួនជាពេលនោះ ព្រះអង្គស្តេចយាងត្រឡប់មកវត្តវិញ ទ្រង់ធ្វើឲ្យភិក្ខុទាំងពីររូបនោះ ភ្លេចបរិក្ខារ របស់ខ្លួន ក្នុងទីនោះ ។ ពេលដែលភិក្ខុពីររូបនោះ និមន្តចេញអំពីទីនោះបានបន្តិច ក៏ត្រឡប់មកយកបរិក្ខារ របស់ខ្លួនវិញ ក៏ស្រាប់តែឃើញទីនោះ សុទ្ធតែជាព្រៃសង្កែ ហើយបានយកបរិក្ខារ រៀងៗ ខ្លួន ទៅតាមព្រះសាស្តា មួងទៀត ។ នៅពេលដែលព្រះសាស្តា ព្រមទាំងភិក្ខុសង្ឃស្តេចយាង និង និមន្តមកដល់បុព្វារាមហើយ, មហាឧបាសិកា ឈ្មោះវិសាខា បានចាត់ចែង នូវអាគន្តុកភត្ត

ថ្វាយព្រះសាស្តា ព្រមទាំងព្រះសង្ឃ ហើយបានក្រាបទូលសួរទីលំនៅ របស់សាមណេររេវតៈ ។

ភិក្ខុ ចាស់ទាំងពីររូបនោះ បានឆ្លើយភ្លាម ថា "ទីលំនៅ របស់សាមណេររេវតៈនោះ សុទ្ធសឹងតែជាព្រៃសង្កើទាំងអស់" ។ នាងវិសាខា បានសួរភិក្ខុដទៃៗ ទៀត ។ ភិក្ខុទាំងនោះ បានឆ្លើយប្រាប់ ថា "ទីលំនៅ របស់រេវតសាមណេរ ជាទីកន្លែងដែលល្អ ជាទីគួររស់នៅណាស់" ។ នាងវិសាខា ដូចជាមិនអស់សេចក្តីសង្ស័យសោះ ព្រោះភិក្ខុទាំងឡាយ ឆ្លើយមិនដូចគ្នា ហើយបានចូលទៅក្រាបទូលសួរព្រះសាស្តា ។

ព្រះបរមសាស្តាចារ្យ ទ្រង់បានត្រាស់នូវព្រះគាថានេះ ថា ៖

**គាមេ វា យទិ វា រញ្ញេ និន្នេ វា យទិ វា ថលេ**
**យត្ថ អរហន្តោ វិហរន្តិ តំ ភូមិរាមណេយ្យកំ ។**

ព្រះអរហន្តទាំងឡាយ នៅក្នុងទីណា ទោះជាស្រុកក្តី ព្រៃក្តី ទីទាបក្តី ទីទួលក្តី ទីនោះឯង ជាភូមិគួរត្រេកអរ ។

## ៨០- រឿង អញ្ញាត្រិត្ថី

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវស្រីម្នាក់ ដែលបានណាត់គ្នាជាមួយនឹងបុរសម្នាក់ ដើម្បីជួបស្នេហានឹងគ្នា ក្នុងសួនច្បារមួយ លុះពេលកំណត់មកដល់ហើយ ស្រីនោះក៏បានទៅចាំបុរសគូស្នេហ៍នោះនៅឯសួនច្បារ ជាមុន ។ តែគួរឲ្យស្តាយណាស់ បុរសគូស្នេហ៍ មិន

*ឃើញមកសោះ ធ្វើឲ្យនាងអស់សេចក្ដីសង្ឃឹម ក្នុងចិត្ត ដើរទៅដើរ មក ស្រាប់តែឃើញនូវភិក្ខុមួយរូប កំពុងតែគង់ចំរើនសមាធិកម្មដ្ឋាន ហើយនាងកើតសេចក្ដីត្រេកត្រអាល ក្នុងកាមារម្មណ៍យ៉ាងខ្លាំង បាន សំដែងមារយាស្ត្រីថែចង់ភិក្ខុរូបនោះៗ បានឃើញយ៉ាងដូច្នោះហើយ កើតសេចក្ដីតក់ស្លុតចិត្ត យ៉ាងខ្លាំង ។*

*ព្រះសាស្ដា កំពុងតែប្រថាប់គង់នៅក្នុងព្រះគន្ធកុដី ទ្រង់ជ្រាប ដោយទិព្វចក្ខុហើយ ទ្រង់បញ្ចេញព្រះរស្មីទៅ បីដូចជាទ្រង់ប្រថាប់ គង់ នៅក្នុងទីចំពោះមុខហើយ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

**រម្មណីយានិ អរញ្ញានិ យត្ថ ន រមតី ជនោ**
**វីតរាគោ រមេស្សន្តិ ន តេ កាមគវេសិនោ ។**

*ព្រៃឈើទាំងឡាយ ជាទីគួររីករាយ, ជន អ្នកស្វែងរកកាម រមែងមិនត្រេកអរ ក្នុងព្រៃដែលគួររីករាយណា, ព្រះខីណាស្រពទាំង ឡាយ ដែលមានរាគៈទៅប្រាសហើយ រមែងត្រេកអរ ក្នុងព្រៃដែល គួររីករាយនោះ ព្រោះលោកជាអ្នកមិនស្វែងរកកាម ។*

**ចប់ អរហន្តវគ្គ ទី ៧**

## សហស្សវគ្គ ទី ៨

### ៨១- រឿង តម្ពទាឋិកចោរឃាតកៈ

*ព្រះបរមសាស្ដា ទ្រង់ប្រារព្ធនូវពេជ្ឈឃាតម្នាក់ ដែលមានពុក មាត់ក្រហម ជាអ្នកទទួលមុខងារ ក្នុងការសម្លាប់ចោរ ។ ក្នុងពេល*

*ដែលគាត់មានកម្លាំងអន់ថយ មិនអាចធ្វើអ្វីបាន, គាត់ក៏បានលាចេញអំពីការងារសម្លាប់ចោរនោះ ។ ថ្ងៃមួយ គាត់បានស្អិតស្អាងរាងកាយល្អត្រឹមត្រូវ ហើយរៀបចំនឹងបរិភោគអាហារឲ្យបានឆ្ងាញ់ម្ដង ។*

*ជួនជាថ្ងៃនោះឯង ព្រះសារីបុត្រ បានចេញពីនិរោធសមាបត្តិ ហើយនិមន្តត្រាច់ទៅបិណ្ឌបាត ។ នាយពេជ្ឈឃាត បានឃើញនូវព្រះថេរៈហើយ មានចិត្តត្រេកអររីករាយ យ៉ាងក្រៃលែង បានយកភោជនាហារ របស់ខ្លួន ទៅប្រគេនព្រះថេរៈ ដោយសេចក្ដីគោរព, ពេលដែលព្រះថេរៈ ឆាន់រួចហើយ បានស្ដាប់នូវអនុមោទនាថា អំពីព្រះថេរៈ ដោយសេចក្ដីសង្ខេប ហើយបានសម្រេចសោតាបត្តិផល, ពេលព្រះថេរៈ និមន្តត្រឡប់ទៅវិញ, ក៏បានជូនដំណើរព្រះថេរៈ ទៅបានបន្តិច ។ គ្រានោះឯង ស្រាប់តែមានមេគោមួយ មកជល់នាយពេជ្ឈឃាតនោះស្លាប់ នៅកណ្ដាលផ្លូវនោះឯង ។*

*ភិក្ខុទាំងឡាយ សន្ទនាគ្នា ថា "តើគតិ របស់នាយពេជ្ឈឃាតនោះ ទៅទីណាហ្ន៎?" ។ ព្រះសាស្ដាទ្រង់ត្រាស់ថា "ទៅកើតនៅឋានតុសិតទេវលោកហើយ" ។ ភិក្ខុទាំងនោះ បានក្រាបទូលសួរទៀត ថា "បពិត្រព្រះអង្គដ៏ចំរើន នាយពេជ្ឈឃាត បានស្ដាប់អនុមោទនកថា ពីព្រះសារីបុត្រ តែបន្តិចប៉ុណ្ណោះឯង តើអាចទៅកើត ក្នុងឋានតុសិតទេវលោក បានដែរឬទេ?" ។ ព្រះអង្គ ទ្រង់ត្រាស់ព្រះគាថានេះ ថា ៖*

សហស្សម្បិ ចេ វាចា អនត្ថបទសញ្ហិតា
ឯកំ អត្ថបទំ សេយ្យោ យំ សុត្វា ឧបសម្មតិ ។

បើវាចា សូម្បីមួយពាន់ម៉ាត់ក៏ដោយ ជាវាចាប្រកបដោយបទឥតមានប្រយោជន៍ វាចានោះ មិនប្រសើរឡើយ, បុគ្គលណា ស្តាប់បទ មានប្រយោជន៍ ណាហើយ រមែងស្ងប់រម្ងាប់បាន, បទមានប្រយោជន៍នោះ សូម្បីតែមួយបទ ក៏ឈ្មោះថា ជាបទប្រសើរជាង ។

❃ ❃ ❃

## ៨២- រឿង ព្រះទារុចីរិយត្ថេរ

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវព្រះទារុចីរិយត្ថេរ ។ សម័យថ្ងៃមួយ នៅពេលដែលលោកនៅជាគ្រហស្ថ, លោកបានធ្វើដំណើរទៅតាមទូក ។ ទូកបានទៅដល់កណ្តាលសមុទ្រហើយ ក៏លិចបាត់ក្នុងសមុទ្រ ។ ក្នុងពេលនោះ លោកបានស្រវាចាប់កំណាត់ឈើបានមួយកំណាត់ ខំតោងកំណាត់ឈើនោះ យ៉ាងជាប់ ដើម្បីកុំឲ្យលង់ស្លាប់ ក្នុងសមុទ្រនោះ ត្រូវរលកបក់បោករសាត់អណ្តែត រហូតមកដល់ច្រាំងសមុទ្រ គ្មានសម្លៀកបំពាក់បិទបាំងរាងកាយឡើយ ។

មហាជន បានឃើញលោកហើយ ក៏សម្គាល់ថា "ជាព្រះអរហន្ត" ហើយនាំគ្នា ធ្វើសក្ការបូជាយ៉ាងច្រើន ដោយចិត្តជ្រះថ្លា ។ លោក មានសេចក្តីសម្គាល់ខ្លួនឯង ថា "ជាព្រះអរហន្ត" ដូច្នោះដែរ តែក្រោយមក លោកបានដឹងច្បាស់ខ្លួនឯងថា មិនមែនជាព្រះអរហន្ត ព្រោះមានពួកទេវតា មកពន្យល់ប្រាប់ ក៏មានសេចក្តីតក់ស្លុត យ៉ាងខ្លាំង ហើយចូលទៅគាល់ព្រះសាស្តា ក្នុងពេលព្រះអង្គកំពុងតែទ្រង់យាងបិណ្ឌបាត ប្រោសសត្វ ហើយបានក្រាបទូលសុំ ឲ្យព្រះអង្គទ្រង់

គាថាធម្មបទប្រែ

សំដែងនូវធម៌ទេសនា ដើម្បីជាសណ្ដាប់ ក្នុងខណៈនោះ អស់រយៈពេល ៣ ដង ។

ព្រះសាស្ដា ទ្រង់ត្រាស់សំដែងព្រះធម៌ទេសនាដោយសង្ខេបដល់នាយទារុចីរិយៈ រហូតដល់បានសម្រេចអរហត្តផល ។ លោកបានទូលសុំព្រះសាស្ដាបួសជាភិក្ខុ តែមិនមានចីវរ, ព្រះអង្គត្រាស់ឲ្យទៅរកចីវរ លោកក៏បានទៅស្វែងរកចីវរ ។ នៅពេលដែលលោកស្វែងរកចីវរនោះ, ស្រាប់តែមានមេគោកូនខ្ចីមួយ បានលោតមកដល់លោកបរិនិព្វាន ក្នុងពេលនោះឯង ។

ភិក្ខុទាំងឡាយ បានសន្ទនាអំពីព្រះថេរៈ ថា "ព្រះទារុចីរិយៈបានស្ដាប់ព្រះធម៌ទេសនា តែបន្តិចប៉ុណ្ណោះ ហើយបានសម្រេចព្រះអរហត្តផល" ។ ព្រះសាស្ដា ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

**សហស្សម្បិ ចេ គាថា អនត្ថបទសញ្ហិតា**
**ឯកំ គាថាបទំ សេយ្យោ យំ សុត្វា ឧបសម្មតិ ។**

បើគាថា សូម្បីមានមួយពាន់ក៏ដោយ ជាគាថាប្រកបដោយបទឥតមានប្រយោជន៍ គាថានោះ ពុំប្រសើរឡើយ, បុគ្គលណាស្ដាប់បទនៃគាថាណាហើយ រមែងស្ងប់រម្ងាប់បាន, បទនៃគាថានោះ សូម្បីតែមួយបទ ក៏ឈ្មោះថា ជាបទប្រសើរជាង ។

## ៨៣- រឿងនាងកុណ្ឌលកេសីថេរី

ព្រះបរមសាស្ដា ទ្រង់ប្រារព្ធនូវនាងកុណ្ឌលកេសីថេរី ដែល

ជាធីតា នៃសេដ្ឋី ក្រុងរាជគ្រឹះ ។ ថ្ងៃមួយ នាងបានឃើញពួកមនុស្ស នាំយកចោរម្នាក់ទៅសម្លាប់ ហើយមានសេចក្ដីស្នេហា មកលើចោរនោះ យ៉ាងខ្លាំង បាននិយាយប្រាប់គេឯង ថា "នាងខ្ញុំ ស្រឡាញ់ចោរនោះ ខ្លាំងណាស់ បើនាងខ្ញុំ មិនបានគាត់យកមកធ្វើជាប្ដីទេ នាងខ្ញុំប្រាកដជានឹងស្លាប់ ក្នុងថ្ងៃនេះពុំខានឡើយ" ។ មាតាបិតា របស់នាងកុណ្ឌលកេសី ឮដូច្នោះហើយ នឹកស្រណោះអាណិតកូនស្រី ក៏បានយកទ្រព្យសម្បត្តិ ទៅលោះយកចោរនោះមក ដើម្បីរៀបមង្គលការជាមួយកូនស្រី របស់ខ្លួន ។

លុះបានគ្នាជាប្ដីប្រពន្ធហើយ ចោរ ដែលជាស្វាមី របស់នាងមិនបោលគំនិតអាក្រក់ ប្រាថ្នាចង់បាននូវគ្រឿងអលង្ការ មានមាសប្រាក់ជាដើម របស់ភរិយា ដើម្បីយកទៅលក់... ទិញស្រាផឹក ហើយបាននិយាយកុហកប្រពន្ធ ថា "អូនជាទីស្រឡាញ់ បងដែលមានជីវិតរស់នៅ បានមកធ្វើជាស្វាមីរបស់អូននេះ ព្រោះបងបានបន់ស្រន់បួងសួងដល់ទេវតា ឲ្យលោកជួយបង, ឥឡូវនេះ បងត្រូវតែធ្វើពលីកម្មថ្វាយទេវតាទាំងនោះ" ។

នាងកុណ្ឌលកេសី បានឮយ៉ាងដូច្នោះហើយ ក៏យល់ព្រមធ្វើតាម ហើយបាននាំគ្នាឡើងទៅ លើកំពូលភ្នំមួយ ដែលជាភ្នំសម្រាប់សម្លាប់ពួកចោរ លុះដើរទៅដល់ក្បែរជើងភ្នំ ចោរជាស្វាមី បានប្រាប់នាងថា "យើង ឡើងទៅ លើកំពូលភ្នំតែពីរនាក់បានហើយ ប្រាប់ពួកបរិវារ ឲ្យឈប់ នៅក្បែរជើងភ្នំនេះចុះ" ។ ទាំងពីរនាក់ប្ដីប្រពន្ធ នាំគ្នា

-១៣៥-

គាថាធម្មបទប្រែ

ដើរឡើងទៅលើកំពូលភ្នំ, លុះបានឡើងទៅដល់កំពូលភ្នំហើយ នាងកុណ្ឌលកេសី បាននិយាយទៅកាន់ស្វាមី ថា "ប្ដីសំឡាញ់ចិត្ត សូមបងធ្វើពលីកម្មដល់ទេវតាចុះ ពួកយើង នឹងប្រញាប់វិលត្រឡប់ទៅផ្ទះវិញ" ។

ក្នុងពេលនោះ ប្ដី ចិត្តចោរកំណាច បានប្រាប់នាង ថា "អញមិនត្រូវការធ្វើពលីកម្មដល់ទេវតាអ្វីនោះទេ គឺ អញចង់បាននូវគ្រឿងអលង្ការ មានមាសប្រាក់ ដែលនៅជាប់នឹងខ្លួននាងទេតើ ហើយអញនឹងសម្លាប់នាងឯងចោល នៅលើកំពូលភ្នំនេះទៀតផង" ។

នាងកុណ្ឌលកេសី បានឮដូច្នោះ ក៏ភ័យចំពោះសេចក្ដីស្លាប់ហើយ ស្រែកសុំអង្វរករនឹងស្វាមី ថា "បងសំឡាញ់ចិត្តអូន សូមបងមេត្តាទុកជីវិត ឲ្យអូនផងចុះ" ។ ចោរ ចិត្តសាមាន្យ មិនព្រមធ្វើតាមពាក្យអង្វរករ របស់នាងឡើយ ។ ក្នុងពេលដែលមានមរណភ័យកើតមាន យ៉ាងនេះហើយ, នាងកុណ្ឌលកេសី ក៏មានគំនិតគិតភ្លាមថា "បើសេចក្ដីស្លាប់មកដល់ហើយ, តើនឹងត្រូវធ្វើយ៉ាងណា ដើម្បីនឹងធ្វើខ្លួន ឲ្យរួចផុត ពីសេចក្ដីស្លាប់នោះ?" ដូច្នេះហើយ ក៏បានប្រើឧបាយកល លួងលោមចោរនោះ ថា "ស្វាមីបណ្ដូលចិត្តអូន! មុននឹងអូនស្លាប់, អូនសូមរាំកំដរ ជូនបងសំឡាញ់ចិត្តបន្តិចសិន ព្រោះថា ពេលនេះ គឺជាពេលចុងក្រោយបង្អស់ហើយ ដែលរូបអូននេះបានឃើញមុខបងបណ្ដូលចិត្ត របស់អូន" ។

ចោរ ឮហើយ ក៏បានប្រាប់នាង ថា "ចូរនាងឯង ធ្វើតាមចិត្ត

ចុះ" ។ នាងបានរាំបណ្ដើរ ជញ្ជីងគិតបណ្ដើរ បន្តិចក្រោយមក ក៏បាន ឃើញចោរ កំពុងតែអង្គុយភ្លេចស្មារតី ហើយនាងបានស្ទុះលោតទៅ ច្រានប្ដីចោរនោះ ដើម្បីទម្លាក់ឲ្យស្លាប់ នៅក្នុងជ្រោះភ្នំដ៏ជ្រៅ ក្នុងគ្រា នោះឯងហោង ។

ពេលដែលចោរធ្លាក់ជ្រោះស្លាប់ហើយ, នាងកុណ្ឌលកេសី បានដោះគ្រឿងអលង្ការ មានមាសប្រាក់ដែលជាប់នឹងខ្លួននាងចោល ទាំងអស់ ឥតមានសល់ នៅលើកំពូលភ្នំនោះឯង ហើយនាងបានធ្វើ ដំណើរទៅតែម្នាក់ឯង មិនឲ្យអ្នកណាមួយដឹងឡើយ រហូតទៅដល់ទី លំនៅរបស់ពួកបរិញ្វាជកហើយ នាងបានសុំបួសជាបរិញ្វាជិកា បាន សិក្សាលទ្ធិបរិញ្វាជកនោះ យ៉ាងស្ទាត់ជំនាញហើយ បានធ្វើដំណើរ ទៅសាកសួរនូវបញ្ហាប្រស្នា ជាមួយនឹងពួកប្រជាជន រហូតបានទៅ ជួបជាមួយនឹងព្រះសារីបុត្រ បានសាកសួរប្រស្នាបញ្ហា ជាមួយនឹង ព្រះថេរៈ ។

ព្រះសារីបុត្រ បានឆ្លើយដោះបញ្ហារួចទាំងអស់ ឥតទើសទាក់ ហើយបានសួរទៅនាងកុណ្ឌលកេសីនោះវិញ ប៉ុន្ដែ នាងមិនអាចនឹង ឆ្លើយបានឡើយ ។ បន្ទាប់មក នាងក៏សុំព្រះថេរៈរៀនប្រស្នានោះ ។ ព្រះសារីបុត្រ បានប្រាប់ទៅនាងថា "បើសិនជានាងបួស ដូចអាត្មាៗ នឹងឲ្យនាងរៀនបាន" ។

នាងកុណ្ឌលកេសី បានយល់ព្រមហើយ ក៏បួសក្នុងសំណាក់ ពួកនាងភិក្ខុនី មិនយូរប៉ុន្មាន ក៏បានសម្រេចអរហត្តផល ព្រមទាំង

## -១៣៧-

## គាថាធម្មបទប្រែ

បដិសម្ភិទា ។

ភិក្ខុទាំងឡាយបានសន្ទនាគ្នាថា "នាងកុណ្ឌលកេសីថេរី បាន ស្តាប់ធម៌មិនជាច្រើនប៉ុន្មានទេ តែនាងបានសម្រេចអរហត្តផល" ។

ព្រះសាស្តាទ្រង់ព្រះសណ្តាប់ហើយ ត្រាស់ព្រះគាថានេះថា ៖

យោ ច គាថា សតំ ភាសេ   អនត្ថបទសញ្ហិតា
ឯកំ ធម្មបទំ សេយ្យោ   យំ សុត្វា ឧបសម្មតិ ។
យោ សហស្សំ សហស្សេន   សង្គាមេ មានុសេ ជិនេ
ឯកញ្ច ជេយ្យមត្តានំ   ស វេ សង្គាមជុត្តមោ ។

បុគ្គលណា គប្បីពោល នូវគាថាមួយរយ ជាគាថាប្រកប ដោយបទដែលឥតប្រយោជន៍, គាថា ដែលបុគ្គលនោះពោលហើយ នោះ ពុំប្រសើរសោះឡើយ, បុគ្គលណា ស្តាប់បទនៃធម៌ហើយ រមែងស្ងប់រម្ងាប់បាន, បទនៃធម៌ របស់បុគ្គលនោះ សូម្បីតែមួយបទ ក៏ឈ្មោះថា ប្រសើរជាង ។

បុគ្គលណា គប្បីឈ្នះពួកមនុស្ស ក្នុងសង្គ្រាម អស់មួយ ពាន់ៗ ដង គឺ មួយលាន, បុគ្គលនោះ មិនឈ្មោះថា ជាអ្នកឈ្នះដ៏ ប្រសើរ ក្នុងសង្គ្រាមបានទេ, ចំណែក បុគ្គលណា ឈ្នះខ្លួនឯងម្នាក់ ឯងបាន បុគ្គលនោះ ឈ្មោះថា ជាអ្នកដែលឈ្នះដ៏ប្រសើរបំផុត ក្នុង សមរភូមិ ។

♣ ❇ ♣

## ៨៤- រឿង អនត្ថបុច្ឆកព្រាហ្មណ៍

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវអនត្ថបុច្ឆកព្រាហ្មណ៍ ជាអ្នកលេងល្បែងស៊ីសង ។ រៀងរាល់ថ្ងៃ គាត់ចិញ្ចឹមជីវិត ដោយល្បែងនេះឯង ។ សម័យថ្ងៃមួយ អនត្ថបុច្ឆកព្រាហ្មណ៍នោះ បានចូលទៅក្រាបទូលសួរព្រះសាស្តាចារ្យ ថា "បពិត្រព្រះអង្គ ដ៏ចំរើន ព្រះអង្គដូចជាទ្រង់ជ្រាបតែរឿងដែលមានប្រយោជន៍ប៉ុណ្ណោះ រឿងដែលគ្មានប្រយោជន៍ ព្រះអង្គដូចជាមិនទ្រង់ជ្រាបសោះឡើយ" ។

ព្រះសាស្តាទ្រង់ត្រាស់ថា "ម្នាលព្រាហ្មណ៍ តថាគត ដឹងរឿងដែលមានប្រយោជន៍ផង និង រឿងដែលមិនមានប្រយោជន៍ផង" ។ ក្នុងពេលនោះ ព្រាហ្មណ៍ បានទូលអារាធនាសុំឲ្យព្រះអង្គសំដែង នូវរឿងដែលមិនមានប្រយោជន៍ដល់ខ្លួន ។

ព្រះសាស្តា ទ្រង់ត្រាស់សំដែង នូវហេតុដែលព្រាហ្មណ៍នោះកំពុងតែប្រព្រឹត្ត គឺ: ដេកក្រក្រោក គឺ ដេកដល់ថ្ងៃរះឡើង ១, ខ្ជិលប្រអូស ១, កាចសាហាវ ១, ដេកច្រើន ១, ដើរផ្លូវឆ្ងាយតែម្នាក់ឯង ១, ខុសនឹងករិយា របស់អ្នកដទៃ ១, ទាំង ៦ នេះ គឺជាហេតុនៃសេចក្តីវិនាស" ។

ព្រាហ្មណ៍ បានស្តាប់យ៉ាងនេះហើយ ក៏ស៊ប់ចិត្តជឿ ឥតមានសង្ស័យឡើយ ។ ព្រះសាស្តាកាលទ្រង់សំដែងធម៌ បង្ហាញទោសនៃការលេងល្បែងភ្នាល់ ដល់ព្រាហ្មណ៍នោះ ទើបទ្រង់ត្រាស់ នូវព្រះគាថានេះ ថា ៖

អត្តា ហវេ ជិតំ សេយ្យោ យា ចាយំ ឥតរា បជា

កាថាធម្មបទប្រែ

អត្តទន្តស្ស បោសស្ស  និច្ចំ សញ្ញតចារិនោ
នេវ ទេវោ ន គន្ធព្វោ  ន មារោ សហ ព្រហ្មុនា
ជិតំ អបជិតំ កយិរា  តថារូបស្ស ជន្តុនោ ។

ខ្លួនឯងដែលឈ្នះហើយ ជាការប្រសើរជាង, ចំណែក ពួកសត្វក្រៅអំពីនេះ ដែលគេឈ្នះហើយ មិនប្រសើរឡើយ, កាលបើបុគ្គលមានខ្លួនអប់រំល្អហើយ ជាអ្នកប្រព្រឹត្តសង្រួមជានិច្ច, ទេវតា គន្ធព្វ មារ ព្រមទាំងព្រហ្ម មិនគប្បីធ្វើនូវជ័យជំនះ របស់សត្វ មានសភាពដូច្នោះ ឲ្យត្រឡប់ចាញ់វិញបានឡើយ ។

❈ ❈ ❈

៨៥- រឿងសារីបុត្តមាតុលព្រាហ្មណ៍

ព្រះបរមសាស្តា ទ្រង់ប្រារព្ធព្រាហ្មណ៍ ដែលត្រូវជាអុំ របស់ព្រះសារីបុត្រ ។ ព្រាហ្មណ៍នោះ មានចិត្តប្រាថ្នាចង់ទៅកើតនៅព្រហ្មលោក ហើយបរិច្ចាគទ្រព្យធ្វើទាន ដល់ពួកនិគ្រន្ថក្រៅសាសនា ជារៀងរាល់ខែ មិនដែលខានឡើយ ។

ព្រះសារីបុត្រ បាននាំគាត់ទៅគាល់ព្រះសាស្តាហើយ ឲ្យគាត់ក្រាបទូលសួរបញ្ហាផ្សេងៗ ចំពោះព្រះអង្គ ។ ព្រាហ្មណ៍ ក៏បានធ្វើតាមព្រះថេរៈ ។

ព្រះសាស្តា ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

មាសេ មាសេ សហស្សេន  យោ យជេថ សតំ សមំ
ឯកញ្ច ភាវិតត្តានំ  មុហុត្តមបិ បូជយេ

រឿងសារីបុត្តភាគិនេយ្យព្រាហ្មណ៍

**សាយេវ បូជនា សេយ្យោ យញ្ចេ វស្សសតំ ហុតំ ។**

*បុគ្គលណា បូជា (លោកិយមហាជន) ដោយទ្រព្យមួយពាន់រាល់ខែៗ អស់ ១០០ ឆ្នាំ គត់, ចំណែក បុគ្គលណា គប្បីបូជាចំពោះបុគ្គលដែលមានខ្លួនអប់រំហើយ តែមួយនាក់ សូម្បីតែមួយរំពេច ក៏ដោយ, ការបូជានោះឯង ជាការប្រសើរជាង ការបូជារបស់អ្នកដែលបូជាអស់ ១០០ ឆ្នាំ នោះ, ការបូជាអស់ ១០០ ឆ្នាំនោះ ពុំប្រសើរសោះឡើយ ។*

៨៦- រឿងសារីបុត្តភាគិនេយ្យព្រាហ្មណ៍

*ព្រះបរមសាស្តាទ្រង់ប្រារព្ធនូវក្មួយ របស់ព្រះសារីបុត្រដែលប្រាថ្នាចង់ទៅកើត នៅឯព្រហ្មលោក ។ ព្រាហ្មណ៍នោះ បានសម្លាប់សត្វ បូជាភ្លើងជារៀងរាល់ថ្ងៃ ។ ព្រះថេរៈ បាននាំព្រាហ្មណ៍ ទៅគាល់ព្រះសាស្តា ដើម្បីក្រាបទូលសួរបញ្ហាផ្សេងៗ ។*

*ព្រះសាស្តាចារ្យ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

**យោ ច វស្សសតំ ជន្តុ អគ្គឹ បរិចរេ វនេ**
**ឯកញ្ច ភាវិតត្តានំ មុហុត្តមបិ បូជយេ**
**សាយេវ បូជនា សេយ្យោ យញ្ចេ វស្សសតំ ហុតំ ។**

*បុគ្គលណា បម្រើភ្លើងក្នុងព្រៃអស់ ១០០ ឆ្នាំ, ចំណែកបុគ្គលណា គប្បីបូជាចំពោះបុគ្គល ដែលមានខ្លួនអប់រំហើយ តែមួយនាក់ សូម្បីតែមួយរំពេច ក៏ដោយ, ការបូជានោះឯង ជាការប្រសើរជាង*

គាថាធម្មបទប្រែ

*ការបូជា របស់អ្នកដែលបូជាអស់ ១០០ ឆ្នាំ នោះ, ការបូជា អស់ ១០០ ឆ្នាំ នោះ មិនប្រសើរឡើយ ។*

♣ ❇ ♣

## ៨៧- រឿងសារីបុត្តសហាយព្រាហ្មណ៍

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវព្រាហ្មណ៍ ដែលជាសំឡាញ់ របស់ព្រះសារីបុត្រ ដែលប្រាថ្នាចង់ទៅកើត នៅឯព្រហ្មលោក ។ ព្រាហ្មណ៍នោះ បានធ្វើការបូជាយញ្ញផ្សេងៗ ។ ព្រះថេរៈ បាននាំយក ព្រាហ្មណ៍ទៅគាល់ព្រះបរមសាស្តា ដើម្បីក្រាបទូលសួរបញ្ហាផ្សេងៗ ចំពោះព្រះអង្គ ។*

*ព្រះសាបរមស្តាចារ្យ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

យង្កិញ្ចិ យិដ្ឋញ្ច ហុតញ្ច លោកេ
សំវច្ឆរំ យជេថ បុញ្ញបេក្ខោ
សព្វម្បិ តំ ន ចតុភាគមេតិ
អភិវាទនា ឧជុគតេសុ សេយ្យោ ។

*បុគ្គលអ្នកប្រាថ្នាបុណ្យ គប្បីបូជាយញ្ញ និង គ្រឿងសក្ការៈ ធំ តូច ណាមួយ ក្នុងលោក អស់ពេលមួយឆ្នាំ, ការបូជាទាំងអស់នោះ ឯង រមែងមិនដល់នូវចំណែកទី ៤ នៃការអភិវាទន៍ឡើយ ព្រោះការ អភិវាទន៍ ចំពោះពួកលោកអ្នកដែលមានដំណើរត្រង់ ជាការប្រសើរ ជាង ។*

❇ ❇ ❇

## ៨៨- រឿង អាយុវឌ្ឍនកុមារ

ព្រះបរមសាស្តា ទ្រង់បានប្រារព្ធនូវអាយុវឌ្ឍនកុមារ ដែលព្រាហ្មណ៍ម្នាក់បានទាយ ថា "កុមារនេះ នឹងស្លាប់ ក្នុងរយៈពេល ៧ ថ្ងៃ" ។ មាតានិងបិតា របស់កុមារនោះ មានសេចក្តីតក់ស្លុតយ៉ាងខ្លាំង ហើយបានដើរសួររកគ្រឿងការពារ ដើម្បីឲ្យកូនបានរួចផុតពីសេចក្តីស្លាប់ ។ ព្រាហ្មណ៍នោះ ក៏មិនដឹងជាធ្វើយ៉ាងណាដែរ ទើបប្រាប់ឲ្យមាតាបិតា របស់កុមារនោះ ទៅក្រាបទូលសួរព្រះសាស្តា ។

មាតាបិតា ក៏បាននាំកូនទៅ ក្រាបបង្គំទូលសួរព្រះសាស្តា ។ ព្រះសម្មាសម្ពុទ្ធ ទ្រង់បានជ្រាបដូចជាព្រាហ្មណ៍នោះដែរ ហើយទ្រង់ត្រាស់ នូវហេតុដែលជាគ្រឿងការពារ ចំពោះមរណភ័យនោះ ដោយទ្រង់ត្រាស់ ឲ្យមាតាបិតា របស់កុមារនោះ និមន្តព្រះសង្ឃមកចំរើនព្រះបរិត្ត រហូត ៧ ថ្ងៃ កុំឲ្យឈប់ គឺ ៧ ថ្ងៃជាប់ៗ គ្នា ។ លុះដល់ថ្ងៃទី ៧ ទើបព្រះសាស្តា ស្តេចយាងទៅ ដោយព្រះអង្គឯងផ្ទាល់ ។

យក្ស ដែលមានគោលបំណង ចង់ផ្តាច់យកជីវិតកុមារនោះ គ្រាន់តែបានឃើញព្រះសម្មាសម្ពុទ្ធភ្លាម ក៏ភ័យខ្លាចចំពោះពុទ្ធានុភាព ហើយ ក៏បានរត់បាត់ទៅ ក្នុងពេលនោះឯង ។ លុះថ្ងៃទី ៧ បានកន្លងផុតទៅហើយ, ថ្ងៃទី ៨ ក៏បានចូលមកដល់ ជាថ្ងៃដែលហួសកំណត់នឹងផ្តាច់ នូវអាយុជីវិត និង ជាថ្ងៃដែលកុមារនោះ បានរួចផុតអំពីសេចក្តីស្លាប់ ហើយបានដល់នូវការចំរើនដោយអាយុ រហូតដល់មានអាយុ ១២០ ឆ្នាំ ។

ពួកភិក្ខុទាំងឡាយ បានសន្ទនាគ្នាអំពីរឿងអាយុវឌ្ឍកុមារនេះ

ដោយប្រការផ្សេងៗ ហើយបានចូលទៅ ក្រាបថ្វាយបង្គំទូលសួរនូវហេតុដែលអាចធ្វើឲ្យអាយុបានចំរើនដទៃទៀតក្រៅពីនេះ ចំពោះព្រះសាស្តា ។

ព្រះសាស្តាចារ្យ ទ្រង់បានត្រាស់នូវព្រះគាថានេះ ថា៖

**អភិវាទនសីលិស្ស និច្ចំ វុឌ្ឍាបចាយិនោ**
**ចត្តារោ ធម្មា វឌ្ឍន្តិ អាយុ វណ្ណោ សុខំ ពលំ ។**

ធម៌ទាំងឡាយ ៤ ប្រការ គឺ អាយុ ១, វណ្ណៈ ១, សុខៈ ១, ពលៈ ១ រមែងចំរើន ដល់អ្នកដែលមានសេចក្តីឱនកាយ ថ្វាយបង្គំជាប្រក្រតី និង អ្នកដែលមានសេចក្តីកោតក្រែង ដល់បុគ្គលដែលចំរើនជាងខ្លួន អស់កាលជានិច្ច ។

៨៩- រឿងសង្កិច្ចសាមណេរ

ព្រះបរមសាស្តា ទ្រង់បានប្រារព្ធ នូវសង្កិច្ចសាមណេរ និង អធិមុត្តកសាមណេរ ។ សង្កិច្ចសាមណេរនេះ ជាអ្នកដែលអស្ចារ្យខ្លាំងណាស់ ព្រោះមាតា របស់លោកបានធ្វើមរណកាល នៅពេលដែលលោក នៅក្នុងផ្ទៃពោះនៃមាតានៅឡើយ ។ ក្នុងពេលដែលគេយកមាតាទៅបូជានោះ, ទារក គឺសាមណេរនោះ ភ្លើងមិនឆេះទេ ។ ពួកញាតិមិត្រ បានឃើញដូច្នេះហើយ មានចិត្តត្រេកអរ ខ្លាំងណាស់ បានយកទារកនោះទៅចិញ្ចឹម បីបាច់ថែរក្សា ដោយសេចក្តីស្រឡាញ់ជាទីបំផុត ។

-១៤៤-

## រឿង សង្កិច្ចសាមណេរ

លុះដល់កុមារនោះ មានអាយុបាន ៧ ឆ្នាំ ហើយ ទើបបាន បួសជាសាមណេរ ក្នុងសំណាក់នៃព្រះសារីបុត្រ, ក្នុងខណៈដែល កោរសក់រួចនោះឯង លោកក៏បានសម្រេចអរហត្តផល ។ បន្ទាប់មក សាមណេរ បាននិមន្តទៅធ្វើសមណធម៌ ក្នុងព្រៃស្ងាត់មួយ ព្រមទាំង ភិក្ខុ ៣០ រូប នៅក្បែរទីលំនៅនៃចោរ ៥០០ ។

ពួកចោរ បានចាប់យកសាមណេរនោះទៅ ដើម្បីធ្វើពលីកម្ម ដល់ទេវតា ។ នៅពេលដែលចោរលើកដាវ ដើម្បីនឹងសម្លាប់នោះ, សាមណេរ បាននៅស្ងៀម មិនសំដែងអាការភ័យខ្លាចបន្តិចសោះ ។ ពួកចោរ បានយកដាវយ៉ាងមុត ដើម្បីកាត់-ក នៃសាមណេរ តែដាវ នោះ បានវៀចខ្ទូរមុខ កាប់មិនមុត អស់វារៈបីដង ។ ពួកចោរ បាន ឃើញដូច្នោះហើយ ក៏មានចិត្តជ្រះថ្លា ចំពោះសាមណេរ យ៉ាងក្រៃ លែង ហើយបានសុំបួសជាភិក្ខុទាំង ៥០០ នៅក្នុងពេលនោះឯង ។ សាមណេរ បាននាំចោរទាំងនោះ ទៅគាល់ព្រះសាស្តា ។ ព្រះសាស្តា ទ្រង់សំដែងធម្មីកថា ហើយទ្រង់ប្រកាសនូវគុណ របស់លោកអ្នក មានសីលទាំងឡាយ ដល់ភិក្ខុទាំងនោះ ។

លុះសង្កិច្ចសាមណេរ បួសជាភិក្ខុបាន ១០ វស្សា ហើយ ក៏ បានឲ្យអធិមុត្តកសាមណេរ ដែលត្រូវជាក្មួយ ទៅសុំអនុញ្ញាត អំពី ញោមប្រុសស្រី ដើម្បីនឹងឧបសម្បទជាភិក្ខុ ។ ពេលដែលអធិមុត្ត- កសាមណេរ និមន្តទៅដល់ពាក់កណ្តាលផ្លូវ ក៏ស្រាប់តែជួបនឹងចោរ ៥០០ ។ ពួកចោរ បានចាប់សាមណេរ យកទៅសម្លាប់ តែអធិមុត្តក-

*សាមណេរ បាននិយាយជាមួយនឹងចោរ ថា “បើពួកអ្នកទាំងអស់គ្នា លែងអាត្មាភាពហើយ អាត្មាភាពនឹងមិនប្រាប់អ្នកណាម្នាក់ ឲ្យដឹងថា ពួកអ្នក នៅក្នុងទីនេះឡើយ” ។*

*ពួកចោរទាំងនោះ បានលែងសាមណេរ ក្នុងពេលនោះឯង ។ សាមណេរ និមន្តទៅដល់ផ្ទះញោមប្រុសស្រីហើយ បានប្រាប់តែអំពីរឿងបួសតែប៉ុណ្ណោះ ស្រេចហើយ ក៏ត្រឡប់ទៅមុន ទុកឲ្យញោមប្រុសស្រីធ្វើដំណើរ មកតាមក្រោយ ។ ពួកចោរ ឃើញញោមប្រុសស្រី របស់សាមណេរ ហើយ បានចាប់គាត់ចង ។ ញោមប្រុសស្រីទាំងពីរ បានពោលថា “សាមណេរ ប្រាកដជាចូលដៃជើង ជាមួយនឹងចោរហើយ បានជាមិនប្រាប់យើងទាំងពីរនាក់ ឲ្យបានដឹងមុន” ។*

*ពួកចោរ បានស្តាប់ពួដូច្នេះហើយ ក៏មានចិត្តជ្រះថ្លា ចំពោះសាមណេរ យ៉ាងខ្លាំង ព្រោះសាមណេរជាអ្នកមានសច្ចៈ ហើយបានសុំបួស ក្នុងសំណាក់សាមណេរគ្រប់គ្នា ។ សាមណេរ បាននាំទៅគាល់ព្រះសាស្តា ។*

*ព្រះបរមសាស្តាចារ្យ ទ្រង់ត្រាស់សំដែងនូវធម្មីកថា ប្រកាសគុណរបស់លោកអ្នកមានសីលទាំងឡាយហើយ ទ្រង់បានត្រាស់ នូវព្រះគាថានេះ ថា ៖*

**យោ ច វស្សសតំ ជីវេ ទុស្សីលោ អសមាហិតោ**
**ឯកាហំ ជីវិតំ សេយ្យោ សីលវន្តស្ស ឈាយិនោ ។**

*បុគ្គលណា ជាមនុស្សទ្រុស្តសីល មានចិត្តមិនតម្កល់ខ្ជាប់*

ទោះបីរស់នៅបាន ១០០ ឆ្នាំ ក៏ដោយ, ការរស់នៅមួយថ្ងៃ របស់លោកអ្នកដែលមានសីល មានការពិនិត្យពិចារណា ជាប្រក្រតី ប្រសើរជាង (ការរស់នៅ ១០០ ឆ្នាំ របស់បុគ្គលនោះទៅទៀត) ។

❁ ❁ ❁

## ៩០- រឿង ព្រះខានុកោណ្ឌាញ្ញត្ថេរ

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវព្រះខានុកោណ្ឌញ្ញត្ថេរ ។ ថ្ងៃមួយ ព្រះថេរៈ បាននិមន្តទៅបំពេញសមណធម៌ ក្នុងព្រៃមួយ ហើយបានសម្រេចអរហត្តផល ស្រេចហើយក៏ត្រឡប់មកគាល់ព្រះសាស្តាវិញ ។ ក្នុងរាត្រីនោះ ព្រះថេរៈ បានចូលឈានសមាបត្តិ ក្នុងទីស្ងាត់មួយ ។

ក្នុងពេលជាមួយគ្នានោះ មានពួកចោរ ៥០០ បានទៅប្លន់យកទ្រព្យសម្បត្តិអ្នកស្រុក បានម្នាក់មួយថង់ៗ ដើរមកឃើញព្រះថេរៈ កំពុងតែគង់ចូលឈានសមាបត្តិ គិតស្មាន ថា "ជាគល់ឈើ" ទើបម្នីម្នាយកថង់ដែលលួចបានមកនោះ ដាក់ត្រួតលើគ្នា សង្កត់នៅពីលើព្រះថេរៈ ។

ព្រះថេរៈ ចូលឈានសមាបត្តិ តាមធម្មតា ។ ពួកចោរក៏បានដេកលក់គ្រប់ៗ គ្នា ក្នុងរាត្រីនោះ ។ លុះព្រឹកឡើង ពួកចោរ បានក្រោកពីដេក ស្រាប់តែឃើញព្រះថេរៈ ទើបដឹងថា ជាមនុស្ស ក៏ភ័យខ្លាចហើយ គិតនឹងរត់ ។ តែព្រះថេរៈ បានប្រាប់ចោរ ថា "អាត្មាភាពជាអ្នកបួសមិនចេះរករឿងបៀតបៀនអ្នកណាទេ សូមលោកអ្នកទាំង

*អស់គ្នា កុំភ័យខ្លាចឲ្យសោះ" ។ ពួកចោរ មានចិត្តជ្រះថ្លាចំពោះព្រះថេរៈ យ៉ាងខ្លាំង ហើយបានសុំទោសចំពោះព្រះថេរៈ ក្រោយមក បានបួសជាភិក្ខុទាំងអស់គ្នា ក្នុងសំណាក់ព្រះថេរៈ ។ ព្រះថេរៈ បាននាំទៅគាល់ព្រះសាស្តា ។*

*ព្រះសាស្តា ទ្រង់ត្រាស់សំដែងនូវធម្មីកថា ប្រកាសនូវគុណរបស់លោកអ្នកមានបញ្ញាទាំងឡាយ ហើយត្រាស់ព្រះគាថានេះថា ៖*

**យោ ច វស្សសតំ ជីវេ ទុប្បញ្ញោ អសមាហិតោ**
**ឯកាហំ ជីវិតំ សេយ្យោ បញ្ញវន្តស្ស ឈាយិនោ ។**

*បុគ្គលណា ជាមនុស្សមិនមានប្រាជ្ញា មានចិត្តមិនតម្កល់ខ្ជាប់ ទោះបីរស់នៅបាន ១០០ ឆ្នាំ ក៏ដោយ, ការរស់នៅមួយថ្ងៃ របស់លោកអ្នកដែលមានប្រាជ្ញា មានការពិនិត្យពិចារណា ជាប្រក្រតី ប្រសើរជាង (ការរស់នៅ ១០០ ឆ្នាំ របស់បុគ្គលនោះទៅទៀត) ។*

## ៩១- រឿង ព្រះសប្បទាសត្ថេរ

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធព្រះសប្បទាសត្ថេរ ។ ព្រះថេរៈ ជាអ្នកមានចិត្តប្រាថ្នាចង់លា ចាកសិក្ខាបទ តែបានត្រឡប់មកគិត ជាថ្មី ថា "បើអាត្មាអញ ស្លាប់ ក្នុងភេទជាព្រះសង្ឃនេះ ជាការប្រសើរជាង" ។ សម័យថ្ងៃមួយ ព្រះថេរៈ បានឃើញពួកភិក្ខុ កំពុងតែចាប់ពស់វែកដំបូក ដើម្បីយកទៅលែងចោល ទើបប្រាប់ភិក្ខុទាំងនោះ ថា "មិនថ្វីទេ ចាំខ្ញុំយកពស់នោះ ទៅលែងចោល" ហើយលូកដៃចូលទៅ*

-១៤៨-

## រឿង ព្រះសប្បទាសត្ថេរ

*ក្នុងផ្ទាំង ដើម្បីឲ្យពស់នោះចឹកខ្លួនស្លាប់ ។ តែពស់នោះ មិនចឹកព្រះថេរៈសោះ ។ ក្រោយមក ព្រះថេរៈ បានញាត់ម្រាមដៃចូលទៅ ក្នុងមាត់ពស់ តែពស់មិនខាំទៀត ។ ព្រះថេរៈ នឹកស្មានថា "ជាពស់ដែលគ្មានពិស" ហើយយកវាទៅលែងចោល ក្នុងព្រៃបាត់ទៅ ។ ក្រោយមកទៀត ព្រះថេរៈ បានយកកាំបិតកោរមក ដើម្បីអារ-ក សម្លាប់ខ្លួនឯង ហើយយក-ក ទៅពាក់នឹងដើមឈើ ដាក់មុខកាំបិតកោរលើ-ក ប្រារព្ធកម្មដ្ឋាន ព្រមជាមួយគ្នានោះផងដែរ ហើយក៏បានសម្រេចនូវអរហត្តផល ក្នុងថ្ងៃនោះឯង ។*

*ភិក្ខុទាំងឡាយ បាននាំយករឿងនោះ ទៅក្រាបទូល ដល់ព្រះសាស្តា ។ ព្រះសាស្តា ទ្រង់សំដែងនូវធម្មីកថា ប្រកាសគុណ របស់លោកអ្នកដែលមានសេចក្តីព្យាយាម ហើយត្រាស់ព្រះគាថានេះថា ៖*

**យោ ច វស្សសតំ ជីវេ កុសីតេ ហីនវីរិយោ**
**ឯកាហំ ជីវិតំ សេយ្យោ វីរិយំ អារភតោ ទឡ្ហំ ។**

*បុគ្គលណា ជាមនុស្សមានចិត្តរុលងក់ ក្នុងអកុសលវិតក្កៈ មានព្យាយាមថោកថយ ទោះបីរស់នៅបាន ១០០ ឆ្នាំ ក៏ដោយ, ការរស់នៅ សូម្បីតែមួយថ្ងៃ របស់លោកអ្នកដែលបានប្រារព្ធសេចក្តីព្យាយាមមាំមួន ប្រសើរជាង (ការរស់នៅ ១០០ ឆ្នាំ របស់បុគ្គលនោះទៅទៀត) ។*

♣ ❈ ♣

# គាថាធម្មបទប្រែ

## ៩២- រឿង នាងបដាចារាថេរី

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវនាងបដាចារាថេរី ។ នាងជាធីតារបស់សេដ្ឋី ក្នុងក្រុងសាវត្ថី នាងបានទទួលនូវសេចក្តីទុក្ខសោកវិយោគព្រាត់ប្រាស យ៉ាងក្រៃលែង គឺ ស្វាមីរបស់នាង ត្រូវពស់ចឹកស្លាប់, កូនបង ត្រូវលង់ទឹកស្លាប់, កូនពៅ ត្រូវខ្លែងឆាបយកបាត់ទៅ, មាតាបិតា បងប្រុស ក៏ត្រូវភ្លើងឆេះផ្ទះ សង្កត់លើស្លាប់ទាំងអស់គ្នាផងដែរ ។ នាង មានសេចក្តីទុក្ខ ត្រួតលើទុក្ខ ហួសប្រមាណ រហូតដល់បាត់បង់នូវសតិស្មារតី ជាស្រីវិកលចរិត ឆ្កួតលីលា ពុំដឹងខ្លួនប្រាណ សូម្បីតែសំពត់ ក៏គ្មាននៅជាប់នឹងខ្លួននាងដែរ ហើយដើរទួញយំ តែម្នាក់ឯង គ្មានទីពឹងពាក់អាស្រ័យ... ថ្ងៃមួយ នាងបានដើរចូលទៅដល់វត្តជេតពន ។

ជួនជាថ្ងៃនោះឯង ព្រះសម្មាសម្ពុទ្ធ កំពុងតែសំដែងព្រះធម៌-ទេសនា ប្រោសពុទ្ធបរិស័ទ ក្នុងវត្តជេតពននោះ ទ្រង់ទតព្រះនេត្រឃើញនាងបដាចារាហើយ ទ្រង់ត្រាស់ដាស់តឿន ឲ្យនាងត្រឡប់មកមានសតិស្មារតីឡើងវិញ ហើយទ្រង់សំដែងព្រះធម៌ទេសនា ប្រោសឲ្យនាងបានសម្រេចសោតាបត្តិផល ។ សម័យក្រោយមក នាងបដាចារា បានបួសជាភិក្ខុនី ក្នុងសំណាក់ នៃនាងភិក្ខុនីទាំងឡាយ ។ ថ្ងៃមួយនោះ នាងភិក្ខុនីបដាចារា អង្គុយពិចារណា នូវការរលត់ទៅ និងការទ្រុឌទ្រោមទៅ ។

ព្រះសាស្តា ទ្រង់ប្រថាប់គង់ ក្នុងព្រះសុគន្ធកុដី ទ្រង់ជ្រាប

*ដោយទិព្វចក្ខុហើយ ទ្រង់បានបញ្ចេញព្រះរស្មីទៅ ដូចជាទ្រង់ប្រថាប់គង់នៅ ក្នុងទីចំពោះមុខនាង ទ្រង់ត្រាស់នូវព្រះគាថានេះ (ឲ្យនាងបានសម្រេចអរហត្តផល) ថា ៖*

**យោ ច វស្សសតំ ជីវេ  អបស្សំ ឧទយព្វយំ**
**ឯកាហំ ជីវិតំ សេយ្យោ  បស្សតោ ឧទយព្វយំ ។**

*បុគ្គលណា មិនឃើញនូវការកើតឡើង និង ការវិនាសទៅ ទោះបីរស់នៅបាន ១០០ ឆ្នាំ ក៏ដោយ, ការរស់នៅ សូម្បីតែមួយថ្ងៃ របស់លោកអ្នកដែលឃើញ នូវការកើតឡើង និង ការវិនាសទៅ ប្រសើរជាង (ការរស់នៅ ១០០ ឆ្នាំ របស់បុគ្គលនោះទៅទៀត) ។*

♣ ❇ ♣

## ៩៣- រឿង នាងកិសាគោត្តមី

*ព្រះបរមសាស្ដា ទ្រង់ប្រារព្ធនូវនាងកិសាគោត្តមីថេរី ។ មានរឿងដំណាលថា: ទ្រព្យចំនួន ៤០ កោដិ របស់សេដ្ឋីក្រុងសាវត្ថី បានកើតទៅជាធ្យូងទាំងអស់ ។ លោកសេដ្ឋី មានចិត្តសោកស្ដាយ យ៉ាងខ្លាំង ។ សម័យថ្ងៃមួយ មានសំឡាញ់ របស់គាត់មកប្រាប់ថា “សូមសំឡាញ់ឯង យកទ្រព្យដែលកើតទៅជាធ្យូងទាំងអស់នេះ ទៅដាក់នៅឯទីផ្សារ បើមានអ្នកណាមួយ និយាយប្រាប់ថា “មាសប្រាក់” បើអ្នកនោះ ជាស្រី ចូរសំឡាញ់ដណ្ដឹងនាងនោះ យកមករៀបការ ជាមួយកូនប្រុសរបស់អ្នក, តែបើអ្នកនោះ ជាប្រុស ចូរសំឡាញ់លើកកូនស្រី របស់សំឡាញ់ ឲ្យទៅគេចុះ ហើយប្រគល់ទ្រព្យសម្បត្តិទាំង*

*អស់នោះ ឲ្យទៅបុរសនោះផង" ។*

*លោកសេដ្ឋី ក៏បានធ្វើតាមទាំងអស់ ។ មនុស្សដទៃៗ ទៀត បានឃើញហើយ និយាយគ្រប់ៗគ្នា ថា "ធ្យូងៗ" ។ ប៉ុន្តែនាងកិសា-គោតមី ម្នាក់ឯងប៉ុណ្ណោះ បាននិយាយប្រាប់ ថា "មាស ប្រាក់" ។ លោកសេដ្ឋី ក៏បានសុំនាង ដើម្បីយកទៅរៀបការ ជាមួយកូនប្រុស របស់ខ្លួន ហើយប្រគល់ទ្រព្យសម្បត្តិ ឲ្យទៅទាំងអស់ ។ លុះនាង កិសាគោតមី រួមរស់ជាមួយស្វាមីបាន ១០ ខែ ក៏បានកូនប្រុសមួយ ។ កូននោះ ចេះដើរបានបន្តិច ក៏បានស្លាប់ទៅ ។ នាងកិសាគោតមី មិន ដែលបានឃើញមនុស្សស្លាប់ ក៏បានពកូន ដែលស្លាប់នោះ ដើរទៅ រកថ្នាំ ដើម្បីធ្វើឲ្យកូននោះ មានជីវិតរស់ឡើងវិញ ។ ពួកអ្នកស្រុក ឃើញហើយ គិតថា "នាងជាស្រីឆ្កួត" ។*

*ក្នុងគ្រានោះ មានបុរសជាបណ្ឌិតម្នាក់ បានប្រាប់ឲ្យនាងទៅ រកព្រះសម្មាសម្ពុទ្ធ ។ នាងក៏បានទៅក្រាបទូលសុំថ្នាំនឹងព្រះអង្គ ។*

*ព្រះសាស្តា ទ្រង់ត្រាស់សំដែង នូវព្រះធម៌ទេសនា រហូតដល់ នាងបានសំរេចសោតាបត្តិផល ។ ក្រោយមក នាងកិសាគោតមី បាន សុំបួសជាភិក្ខុនី ក្នុងសំណាក់នៃនាងភិក្ខុនីទាំងឡាយ ។ ថ្ងៃមួយ នាង ពិចារណានូវភ្លើងប្រទីប ដែលឆេះហើយ រលត់ទៅវិញ ហើយយក មកប្រៀបធៀប នឹងអត្តភាពរបស់ខ្លួន ធ្វើជាអារម្មណ៍ ។*

*ព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រថាប់គង់ ក្នុងព្រះសុគន្ធកុដី ទ្រង់បាន បញ្ចេញនូវព្រះរស្មីទៅ ហាក់ដូចជាទ្រង់គង់នៅ ក្នុងទីចំពោះមុខនាង*

ទ្រង់ត្រាស់ ថា “ម្នាលគោតមី សត្វទាំងអស់នោះ តែងកើតស្លាប់ ដូចជាភ្លើងប្រទីប ប៉ុន្តែ សត្វដែលដល់ ទូវព្រះនិព្វានហើយ មិនប្រាកដដូច្នោះទេ, ការរស់នៅតែមួយខណៈ នៃលោកអ្នកឃើញព្រះនិព្វាន ប្រសើរជាងការរស់នៅ ១០០ ឆ្នាំ នៃអ្នកដែលមិនឃើញព្រះនិព្វាន” ដូច្នេះហើយ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

**យោ ច វស្សសតំ ជីវេ អបស្សំ អមតំ បទំ**
**ឯកាហំ ជីវិតំ សេយ្យោ បស្សតោ អមតំ បទំ ។**

បុគ្គលណា មិនឃើញផ្លូវព្រះនិព្វាន ទោះបីរស់នៅបាន ១០០ ឆ្នាំ ក៏ដោយ, ការរស់នៅ សូម្បីតែមួយថ្ងៃ របស់លោកអ្នកដែលឃើញព្រះនិព្វាន ប្រសើរជាង (ការរស់នៅ ១០០ ឆ្នាំ របស់បុគ្គលនោះទៅទៀត) ។

❇ ❇ ❇

## ៩៤- រឿង នាងពហុបុត្តិកាថេរី

ព្រះបរមសាស្ដា ទ្រង់ប្រារព្ធនូវនាងពហុបុត្តិកាថេរី ដែលមានកូនប្រុសស្រីច្រើន ។ ពេលស្វាមីរបស់នាងធ្វើមរណកាលទៅ, នាងបានចែកទ្រព្យសម្បត្តិទាំងអស់ ឲ្យដល់កូនប្រុសស្រី ហើយទៅនៅអាស្រ័យ ជាមួយនឹងកូនទាំងនោះ ។ ក្រោយមក នាងឃើញថា កូនប្រុសស្រី ដូចជាមិនសូវយកចិត្តទុកដាក់ទំនុកបំរុងដល់ខ្លួន ក៏បានទៅបួសជានាងភិក្ខុនី ខិតខំប្រឹងប្រែងប្រតិបត្តិធម៌ ក្រោយមក ពិចារណាឃើញព្រះធម៌ដែលព្រះពុទ្ធ ទ្រង់បានត្រាស់សំដែងទុកហើយ ។

## គាថាធម្មបទប្រែ

*ខណៈនោះ ព្រះសាស្តា ទ្រង់គង់ ក្នុងព្រះសុគន្ធកុដី ទ្រង់បាន បញ្ចេញ នូវព្រះរស្មីទៅ ដូចជាទ្រង់គង់នៅ ក្នុងទីចំពោះមុខនាង ទ្រង់ត្រាស់ថា "នៃពហុបុត្តិកា ការរស់នៅ មួយខណៈ របស់អ្នកដែលឃើញធម៌ ដែលតថាគតសំដែងទុកហើយ ប្រសើរជាងការរស់នៅ របស់អ្នកដែលមិនឃើញធម៌ ដែលតថាគតសំដែងទុកហើយ" ដូច្នេះហើយ ទ្រង់ត្រាស់នូវព្រះគាថានេះថា ៖*

យោ ច វស្សសតំ ជីវេ   អបស្សំ ធម្មមុត្តមំ
ឯកាហំ ជីវិតំ សេយ្យោ   បស្សតោ ធម្មមុត្តមំ ។

*បុគ្គលណា មិនឃើញធម៌ដ៏ខ្ពង់ខ្ពស់ ទោះបីរស់នៅបាន ១០០ ឆ្នាំ ក៏ដោយ, ការរស់នៅ សូម្បីតែមួយថ្ងៃ របស់លោកអ្នកដែលឃើញធម៌ ដ៏ខ្ពង់ខ្ពស់ ប្រសើរជាង (ការរស់នៅ ១០០ ឆ្នាំ របស់បុគ្គលនោះទៅទៀត) ។*

ចប់ សហស្សវគ្គ ទី ៨

**ចប់ គាថាធម្មបទ ប្រែ**
**ភាគ ទី ៤**

សូមសិក្សា នូវភាគ ទី ៥ បន្តទៀត

# គាថាធម្មបទប្រែ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ភាគ ទី ៥

បាបវគ្គ ទី ៩

៩៥- រឿង ចូឡេកសាដកព្រាហ្មណ៍

*ព្រះបរមសាស្ដា ទ្រង់ប្រារព្ធនូវចូឡេកសាដកព្រាហ្មណ៍ ជាអ្នកកំសត់ទុគ៌តខ្លាំងណាស់ ។ ព្រាហ្មណ៍នោះ មានតែសំពត់សាដកមួយសម្រាប់ស្លៀកដណ្ដប់ ផ្លាស់គ្នាពីរនាក់ប្ដីប្រពន្ធ តែគាត់ជាអ្នកមានសទ្ធាជ្រះថ្លា យ៉ាងមុតមាំ ក្នុងព្រះពុទ្ធសាសនា តែងតែទៅស្ដាប់ព្រះធម៌ទេសនា របស់ព្រះពុទ្ធអង្គ ជារៀងរាល់យប់ថ្ងៃ, ព្រោះគាត់មានសំពត់តែមួយ សម្រាប់ប្រើពីរនាក់ប្ដីប្រពន្ធ ទើបឲ្យប្រពន្ធ ទៅស្ដាប់ធម៌ទេសនា នៅវេលាថ្ងៃ ចំណែកខ្លួនឯង ជាប្ដី ទៅស្ដាប់ធម៌-ទេសនា នៅវេលាយប់ ។*

*រាត្រីយប់មួយនោះ ចូឡេកសាដកព្រាហ្មណ៍ ជាប្ដី បានទៅស្ដាប់ព្រះធម៌ទេសនា ជាមួយនឹងពុទ្ធបរិស័ទទាំងឡាយ មានព្រះបាទបសេនទិកោសលជាដើម ក្នុងពេលដែលកំពុងស្ដាប់ព្រះធម៌ទេសនា ក៏កើតសេចក្ដីជ្រះថ្លា យ៉ាងខ្លាំងក្លា ប្រាថ្នាចង់បូជាព្រះធម៌ទេសនា ដោយគ្រឿងសក្ការៈអ្វីមួយ តែគាត់មិនមានវត្ថុអ្វី ក្រៅតែអំពីសំពត់សាដក ដែលគាត់ដណ្ដប់នៅជាប់នឹងខ្លួន តាំងតែពីបឋមយាម គាត់ស្ដាប់ផង សញ្ជឹងគិតផង ថា "អាត្មាអញ មានសំពត់ដណ្ដប់តែមួយ*

*គត់ សម្រាប់ប្រើតែពីរនាក់ប្តីប្រពន្ធ បើអាត្មាអញ យកសំពត់សាដក នេះ ទៅបូជាព្រះធម៌ទេសនា ខ្លួនអញជាប្រុសមិនជាអ្វីទេ តែកិរិយា របស់អញគ្នាជាស្រីផង មុខជាគ្មានអ្វីដណ្តប់ឡើយ នឹងចេញទៅខាង ក្រៅផ្ទះ ក៏ពុំបានថែមទៀតផង" ។*

*តាមចិត្តសទ្ធាជ្រះថ្លាដ៏ខ្លាំងក្លានោះ គាត់ចង់បូជាសំពត់សាដក នោះ ឲ្យខានតែបាន តែចិត្តសទ្ធាជ្រះថ្លា មានតែមួយគត់ ឯចិត្តដែល កំណាញ់ មានដល់ទៅមួយពាន់ ដែលមកគ្របសង្កត់ចិត្តសទ្ធាមួយ នោះ ។ ចិត្តទាំងពីរនោះ បានប្រឆាំងច្បាំងគ្នាយ៉ាងខ្លាំង, ចិត្តសទ្ធា គិត ថាបូជា, ឯចិត្ត ដែលកំណាញ់ គិតថា កុំឲ្យបូជា ។ គាត់គិតតែក្នុងចិត្ត ឥតមានអ្នកណាម្នាក់ដឹងឡើយ ។*

*ក្នុងបច្ឆិមយាម ដោយចិត្តសទ្ធាមានតែមួយ តែជាចិត្តដែល មានកម្លាំងខ្លាំងក្លា ជាងចិត្តដែលកំណាញ់, នៅទីបំផុត ចិត្តសទ្ធា ក៏ បានយកជ័យជំនះ លើចិត្តដែលកំណាញ់ ។ កាលបើចិត្តសទ្ធា ឈ្នះ ហើយ ចូឡេកសាដកព្រាហ្មណ៍ ក៏បានស្រែកភ្ជាត់មាត់ថា "**ជិតំ មេៗ អាត្មាអញឈ្នះហើយៗ !**" យ៉ាងដូច្នេះ ។*

*ពេលនោះ ព្រះបាទបសេនទិកោសល ទ្រង់ជ្រាបហើយ ទ្រង់ មានព្រះទ័យជ្រះថ្លាយ៉ាងក្រៃលែង ទ្រង់បានព្រះរាជបញ្ជាឲ្យអាមាត្យ យកសំពត់ និង ទ្រព្យសម្បត្តិជាច្រើន មកព្រះរាជទាន ដល់ចូឡេក-សាដកព្រាហ្មណ៍នោះ ។ ព្រាហ្មណ៍ បានឡើងយសសក្តិ ជាគហបតី មានទ្រព្យសម្បត្តិជាច្រើន ដោយសារតែចិត្តសទ្ធាខ្លាំងក្លា បានច្បាំង*

ឈ្នះចិត្តកំណាញ់នេះឯង ។

ភិក្ខុទាំងឡាយ ប្រជុំសន្ទនាគ្នានិយាយពីរឿងចូឡេកសាដក-ព្រាហ្មណ៍ ។ ព្រះសាស្តា ទ្រង់ត្រាស់ថា “បើព្រាហ្មណ៍នេះ បានយកសំពត់សាដកទៅ បូជាព្រះធម៌ទេសនា តាំងតែពីបឋមយាម, គាត់នឹងបានទ្រព្យសម្បត្តិ ច្រើនជាងនេះទៅទៀត” ហើយទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

**អភិត្ថរេថ កល្យាណេ  បាបា ចិត្តំ និវារយេ**
**ទន្ធំ ហិ ករតោ បុញ្ញំ  បាបស្មឹ រមតី មនោ។**

បុគ្គល គួរប្រញាប់ប្រញាល់ធ្វើតែអំពើល្អ គួរហាមឃាត់ចិត្តចាកអំពើអាក្រក់ ព្រោះថា កាលបើបុគ្គលធ្វើបុណ្យយឺតយូរ ចិត្តរមែងត្រេកអរតែក្នុងអំពើអាក្រក់ ។

* * *

## ៩៦- រឿងសេយ្យសកភិក្ខុ

ព្រះបរមសាស្តា ទ្រង់បានប្រារព្ធនូវសេយ្យសកភិក្ខុ ដែលជាសទ្ធិវិហារិក របស់ព្រះលោឡុទាយី ។ ព្រះសេយ្យសកៈនេះ ពេលដែលរាគៈ កើតឡើងហើយ ក៏បានទៅរកព្រះលោឡុទាយីៗ បានប្រាប់ឲ្យលោករម្ងាប់រាគៈនោះ ដោយហេតុដែលមិនត្រឹមត្រូវ ។ ព្រះសេយ្យសកៈ ក៏បានធ្វើតាម ។

ព្រះបរមសាស្តាទ្រង់ជ្រាបហើយ ទ្រង់បានតិះដៀលជាច្រើន ហើយទ្រង់ត្រាស់ឲ្យប្រជុំសង្ឃ ទ្រង់បញ្ញត្តសិក្ខាបទ ហាមមិនឲ្យភិក្ខុ

ប្រព្រឹត្តយ៉ាងនេះ បន្តទៅទៀត ហើយទ្រង់ត្រាស់ព្រះគាថានេះថា ៖

**បាបញ្ចេ បុរិសោ កយិរា ន នំ កយិរា បុនប្បុនំ**
**ន តម្ហិ ឆន្ទំ កយិរាថ ទុក្ខោ បាបស្ស ឧច្ចយោ ។**

បើបុគ្គល ធ្វើអំពើអាក្រក់ កុំធ្វើអំពើអាក្រក់នោះ រឿយៗ ឡើយ កុំគប្បីធ្វើសេចក្ដីពេញចិត្ត ក្នុងអំពើអាក្រក់នោះ ព្រោះថា ការសន្សំបាប តែងនាំសេចក្ដីទុក្ខមកឲ្យ ។

## ៩៧- រឿង នាងលាជទេវធីតា

ព្រះបរមសាស្ដា ទ្រង់ប្រារព្ធនូវនាងលាជទេវធីតា ។ កាលពីនាងនៅជាមនុស្សលោក នាងជាអ្នកធ្វើស្រែ បានប្រគេនលាជ ជាច្រើន ដល់ព្រះមហាកស្សបៈ លុះដល់នាងធ្វើមរណកាលទៅ ក៏បានទៅកើត ក្នុងឋានតាវត្តិង្ស នាងដឹងថា សម្បត្តិ ដែលខ្លួនបានមកនេះ ព្រោះអាស្រ័យព្រះមហាកស្សបៈ នាងប្រាថ្នានឹងតបស្នងសងគុណដល់ព្រះថេរៈ ហើយបានមកបោសសម្អាត បរិវេណព្រះវិហារ ដងទឹកសម្រាប់ស្រង់ និង ទឹកសម្រាប់ឆាន់ អស់រយៈពេល ៣ ថ្ងៃ ។

នៅថ្ងៃទី ៣ ព្រះថេរៈ ដឹងច្បាស់ហើយ ក៏បានបណ្ដេញនាងចេញ ហាមមិនឲ្យនាងធ្វើយ៉ាងនេះ តទៅទៀត ។ នាងទេវធីតា បានអាក់អន់ចិត្ត យ៉ាងខ្លាំង ហើយបានប្រណម្យអញ្ជលី ស្រែកយំ លើអាកាស ។

ព្រះសាស្ដា ទ្រង់ជ្រាបហើយ ទ្រង់ត្រាស់ទៅកាន់នាងលាជ-

ទេវធីតា ថា "ម្នាលទេវធីតា ការធ្វើសេចក្តីសង្រួម ជានាទី របស់ព្រះមហាកស្សបៈ ការធ្វើបុណ្យ ជានាទី របស់បុគ្គលអ្នកប្រាថ្នាចង់បានបុណ្យ ព្រោះការធ្វើបុណ្យតែងបានសេចក្តីសុខ ក្នុងលោកនេះផង ក្នុងបរលោកផង" ដូច្នេះហើយ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

**បុញ្ញញ្ចេ បុរិសោ កយិរា  កយិរាថេនំ បុនប្បុនំ**
**តម្ហិ ឆន្ទំ កយិរាថ  សុខោ បុញ្ញស្ស ឧច្ចយោ ។**

បើបុគ្គលធ្វើបុណ្យ គួរធ្វើបុណ្យនោះរឿយៗ គួរធ្វើសេចក្តីពេញចិត្ត ក្នុងបុណ្យនោះផង ព្រោះថា ការសន្សំបុណ្យ តែងបានសេចក្តីសុខ ។

♣ ❇ ♣

## ៩៨- រឿង អនាថបិណ្ឌិកសេដ្ឋី

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវអនាថបិណ្ឌិកសេដ្ឋី ។ លោកសេដ្ឋី គាត់បានបរិច្ចាគទ្រព្យជាច្រើន កសាងវត្តជេតពន ហើយបានបរិច្ចាគទាន ក្នុងព្រះពុទ្ធសាសនា រៀងរាល់ថ្ងៃ មិនដែលខានឡើយ រហូតទាល់តែអស់ទ្រព្យសម្បត្តិ ចុះថយមក ជាលំដាប់ ទោះបីជាយ៉ាងនេះក៏ដោយ ក៏គាត់នៅតែបរិច្ចាគទាន មិនចេះឈប់ ។

ក្នុងពេលនោះ ទេវតា ដែលស្ថិតនៅ លើខ្លោងទ្វារផ្ទះនៃសេដ្ឋីនោះ បានហាមមិនឲ្យលោកសេដ្ឋីបរិច្ចាគទ្រព្យ តទៅទៀត តែសេដ្ឋីមិនព្រមធ្វើតាម ហើយបានបណ្តេញទេវតា មិនឲ្យនៅ លើខ្លោងទ្វាររបស់ខ្លួន ជាបន្តទៅទៀត ។

គាថាធម្មបទប្រែ

*ទេវតា ដឹងថា ខ្លួនបានធ្វើខុសហើយ ក៏បានទៅរកទេវតាទាំងឡាយ រហូតដល់សក្កទេវរាជ ដើម្បីឲ្យជួយសុំទោសសេដ្ឋី ។ សក្កទេវរាជ បានប្រាប់ឧបាយ ថា "អ្នកឯង ត្រូវតែយកទ្រព្យ ដែលគ្មានម្ចាស់ ទៅឲ្យសេដ្ឋី ហើយសុំខមាទោសលោកសេដ្ឋី" ។ ទេវតានោះបានធ្វើតាមសក្កទេវរាជ, កាលបើសេដ្ឋី លើកលែងទោសឲ្យហើយ, ក៏បាននាំគ្នាទៅគាល់ព្រះសាស្តា ។ ព្រះអង្គ ទ្រង់ប្រទានឱវាទ ដល់សេដ្ឋី និង ទេវតា ហើយទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

បាបោបិ បស្សតី ភទ្រំ យាវ បាបំ ន បច្ចតិ
យទា ច បច្ចតី បាបំ អថ (បាបោ) បាបានិ បស្សតិ ។
ភទ្រោបិ បស្សតី បាបំ យាវ ភទ្រំ ន បច្ចតិ
យទា ច បច្ចតី ភទ្រំ អថ (ភទ្រោ) ភទ្រានិ បស្សតិ ។

*អំពើអាក្រក់ មិនទាន់ហុចផលឲ្យ ត្រឹមណា មនុស្សអាក្រក់ក៏នៅឃើញតែសេចក្តីចំរើន ត្រឹមណោះ, លុះកាលណា អំពើអាក្រក់ហុចផលឲ្យ មនុស្សអាក្រក់ទើបឃើញអំពើអាក្រក់ ក្នុងកាលនោះ ។*

*អំពើល្អ មិទាន់ហុចផលឲ្យ ត្រឹមណា មនុស្សល្អ ក៏នៅឃើញតែអំពើអាក្រក់ ត្រឹមណោះ, លុះកាលណា អំពើល្អ ហុចផលឲ្យមនុស្សល្អ ទើបឃើញអំពើល្អ ក្នុងកាលនោះ ។*

♣ ❇ ♣

៩៩- រឿងអសញ្ញតបរិក្ខារភិក្ខុ

*ព្រះសាស្តា ទ្រង់ប្រារព្ធនូវភិក្ខុ ដែលមិនចេះទុកដាក់គ្រឿង*

រឿងអសញ្ញាតបរិក្ខារភិក្ខុ

បរិក្ខារ ។ ភិក្ខុរូបនេះ យកក្រែ កៅអី ទៅប្រើប្រាស់ហើយ ក៏ចោលនៅក្នុងទីនោះៗ មិនព្រមយកទៅទុកដាក់ នៅកន្លែងដើមវិញឡើយ ។ ភិក្ខុទាំងឡាយ ឃើញដូច្នេះហើយ ក៏បានដាស់តឿន ក្រើនរំលឹក ជារឿយៗ ។ តែភិក្ខុរូបនោះ មិនព្រមស្តាប់សោះ បាននិយាយទ្រគោះបោះបោកទៅវិញថា "កម្មតែបន្តិចបន្តួច តើវានឹងទៅជាអ្វី គ្រឿងបរិក្ខារនេះ វាមិនមានចិត្តគំនិតទេ" ។

ព្រះសម្មាសម្ពុទ្ធ ទ្រង់ជ្រាបហើយ ទើបទ្រង់ត្រាស់ឲ្យភិក្ខុទាំងឡាយទៅនាំយកភិក្ខុនោះមកគាល់ ហើយត្រាស់នូវព្រះគាថានេះថា៖

**មាវមញ្ញេថ បាបស្ស   ន មត្តំ អាគមិស្សតិ**
**ឧទពិន្ទុនិបាតេន   ឧទកុម្ភោបិ បូរតិ**
**បូរតិ ពាលោ បាបស្ស   ថោកំ ថោកំបិ អាចិនំ ។**

បុគ្គល មិនគួរមើលងាយបាបថា មានប្រមាណតិច នឹងមិនឲ្យផល ដូច្នេះឡើយ, សូម្បីតែក្អមទឹក (ដែលគេបើកគ្របចំហ) រមែងពេញបាន ដោយតំណក់ទឹកភ្លៀង ដែលធ្លាក់ចុះមក (ម្តងមួយតំណក់ៗ) យ៉ាងណាមិញ, បុគ្គលពាល កាលសន្សំបាប សូម្បីបន្តិចម្តងៗ គង់នឹងពេញបាន ដោយបាប ក៏យ៉ាងដូច្នោះដែរ ។

១០០- រឿងពិឡាលបទកសេដ្ឋី

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវពិឡាលបទកសេដ្ឋី ។ សេដ្ឋីម្នាក់នេះ បានឃើញបុរសអ្នកឃោសនាអំពីការធ្វើទាន ដើរមកដល់

*ផ្ទះ របស់ខ្លួន នឹកមិនពេញចិត្ត ថា "បុរសនេះ មិនធ្វើឲ្យសមល្មមនឹងកម្លាំងរបស់ខ្លួន ហើយដើរឃោសនា បបួលគេឯងថែមទៀត" ហើយបានចិបអង្ករ សណ្តែកខៀវ សណ្តែងលឿង មួយមុខបន្តិចៗ ឲ្យទៅបុរសអ្នកឃោសនានោះ ។ បុរសអ្នកផ្តើមបុណ្យ បានយករបស់សេដ្ឋីនោះ ទៅចាត់ចែងធ្វើជាចង្ហាន់ ប្រគេនដល់ព្រះសង្ឃ ។*

*លុះព្រឹកឡើង លោកសេដ្ឋី បានទៅកន្លែងធ្វើបុណ្យ ដោយតាំងចិត្តថា "បើបុរសផ្តើមបុណ្យ និយាយអាក្រក់អំពីរឿងអញៗ នឹងសម្លាប់វាចោលតែម្តង" ។ ក្នុងពេលដែលព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ឆាន់រួចស្រេចហើយ, អ្នកផ្តើមបុណ្យ បានក្រាបទូលព្រះសាស្តា ថា "បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះករុណា បានដើរឃោសនាបបួលប្រជាជន ឲ្យធ្វើទាន តាមកម្លាំងសទ្ធាជ្រះថ្លារៀងៗ ខ្លួន, អ្នកខ្លះក៏បានធ្វើច្រើន អ្នកខ្លះក៏បានធ្វើតិច, សូមកុសលផលបុណ្យ កើតមានដល់អ្នកទាំងអស់នោះឲ្យបានគ្រប់ៗ គ្នាទៅហោង" ។ សេដ្ឋី បានឮដូច្នេះហើយ ក៏ប្រែចិត្តគំនិត ជាសម្មាទិដ្ឋិ ដឹងច្បាស់ថា ខ្លួនគិតខុសហើយ ក៏ចូលទៅសុំទោស ចំពោះបុរសអ្នកផ្តើមបុណ្យនោះភ្លាម ។*

*ព្រះសាស្តាចារ្យ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

មាវមញ្ញេថ បុញ្ញស្ស  ន មត្តំ អាគមិស្សតិ
ឧទពិន្ទុនិបាតេន  ឧទកុម្ភោបិ បូរតិ
បូរតិ ធីរោ បុញ្ញស្ស  ថោកំ ថោកំបិ អាចិនំ ។

*បុគ្គល មិនគួរមើលងាយបុណ្យថា មានប្រមាណតិច នឹងមិន*

ឲ្យផល ដូច្នេះឡើយ, សូម្បីតែក្អមទឹក (ដែលគេបើកគ្របចំហ) រមែងពេញបាន ដោយតំណក់ទឹកភ្លៀង ដែលធ្លាក់ចុះមក (ម្ដងមួយតំណក់ៗ) យ៉ាងណាមិញ, អ្នកមានប្រាជ្ញា កាលសន្សំបុណ្យ សូម្បីតែបន្តិចម្ដងៗ គង់នឹងពេញបាន ដោយបុណ្យ ក៏យ៉ាងដូច្នោះដែរ ។

♣ ❇ ♣

## ១០១- រឿង មហាធនពាណិជ

ព្រះបរមសាស្ដា ទ្រង់ប្រារព្ធមហាធនពាណិជ ដែលកំពុងតែរៀបចំរបស់របរ ដាក់លើករទេះ ដើម្បីយកទៅលក់ដូរ នៅជនបទ ។ មុននឹងមហាធនពាណិជ ធ្វើដំណើរចេញទៅ គាត់បាននិមន្តភិក្ខុទាំងឡាយដែលមានបំណងនិមន្តទៅកាន់ជនបទ ឲ្យនិមន្តទៅជាមួយគាត់ ដើម្បីកុំឲ្យមានការលំបាក ដោយចង្ហាន់បិណ្ឌបាត នៅតាមផ្លូវ ។ លុះមហាធនពាណិជ បានរៀបចំរួចស្រេចហើយ ទើបបានចេញដំណើរឆ្ពោះទៅកាន់ស្រុកមួយ ដែលឋិតនៅក្បែរមាត់ព្រៃ ហើយបានឈប់សម្រាកនៅ ក្នុងទីនោះឯង ។

ពួកចោរ ទាំង ៥០០ នាក់ ដឹងថា "មហាធនពាណិជ បានឈប់សម្រាក នៅក្បែរមាត់ព្រៃនោះ" ក៏បាននាំគ្នាទៅ ចាំប្លន់ទ្រព្យសម្បត្តិគាត់ ។ ជារាសនាល្អ មហាធនពាណិជ បានដឹងខ្លួនជាមុន ហើយបានវិលត្រឡប់មកវិញ ។ ពួកចោរ បានដឹងថា គាត់ បានត្រឡប់មកវិញ ក៏បានមក ចាំស្ទាក់ប្លន់ម្ដងទៀត ។ មហាធនពាណិជ បានដឹងថា ពួកចោរបានមក ចាំស្ទាក់ប្លន់ម្ដងទៀត ក៏ឈប់សម្រាក ក្នុងទីនោះ ហើយ

បានប្រាប់រឿងដែលចោរបំរុងប្ញទ់គាត់ ដល់ភិក្ខុសង្ឃ ឲ្យបានជ្រាប ។ ភិក្ខុទាំងឡាយ ក៏ត្រឡប់មកវិញ ហើយក្រាបទូលរឿងនោះថ្វាយព្រះសាស្តាទ្រង់ជ្រាប ។

ព្រះសាស្តា ទ្រង់ជ្រាបហើយ ទ្រង់ត្រាស់នូវព្រះគាថានេះថា៖

**វាណិជោវ ភយំ មគ្គំ អប្បសត្ថោ មហទ្ធនោ**
**វិសំ ជីវិតុកាមោវ បាបានិ បរិវជ្ជយេ ។**

បុគ្គល គួរចៀសវាងអំពើអាក្រក់ទាំងឡាយឲ្យបាន ដូចជាពាណិជ ដែលមានទ្រព្យច្រើន តែមានគ្នាតិច ចៀងវាងផ្លូវគួរខ្លាច ឬដូចជាបុរស អ្នកដែលប្រាថ្នាចង់មានជីវិតរស់នៅ ចៀសវាងថ្នាំពិសដូច្នោះឯង ។

❉ ❉ ❉

## ១០២- រឿង នាយព្រានកុក្កុដមិត្រ

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវព្រានម្នាក់ ឈ្មោះកុក្កុដមិត្រ ។ ថ្ងៃមួយ នាយកុក្កុដមិត្រ បានដឹកសាច់ពេញរទេះ ដើម្បីយកទៅលក់នៅទីក្រុងរាជគ្រឹះ ។ ធីតា របស់សេដ្ឋីម្នាក់ ក្នុងទីក្រុងនោះ បានឃើញនាយកុក្កុដមិត្រហើយ ក៏មានចិត្តស្រឡាញ់គាត់ភ្លាម ដោយអំណាចនៃការធ្លាប់រួមរស់ជាមួយគ្នាពីជាតិមុន ។ ក្នុងពេលដែលនាយព្រានកុក្កុដមិត្រ បានវិលត្រឡប់ទៅស្រុកវិញ, នាងសេដ្ឋីធីតា បានរត់ទៅតាមនាយព្រាននោះ ហើយបានគ្នាជាប្តីប្រពន្ធ រហូតដល់បានកូនប្រុស ៧ កូនស្រី ៧ ។

# រឿងនាយព្រានកុក្កុដមិត្រ

ព្រះសាស្តា ទ្រង់ទតព្រះនេត្រឃើញឧបនិស្ស័យ របស់នាយព្រានកុក្កុដមិត្រ ព្រមទាំងកូនបង្កើត និង កូនប្រសា ទាំងអស់នោះ ទើបទ្រង់ស្តេចយាងទៅកន្លែងដាក់អន្ទាក់ របស់នាយព្រាននោះ ជាមុន ហើយទ្រង់សំដែងនូវស្នាមព្រះបាទ នៅក្បែរៗ អន្ទាក់នោះ ។

ក្នុងថ្ងៃនោះឯង មិនឃើញមានសត្វណាមួយ មកជាប់អន្ទាក់របស់គាត់ឡើយ ។ កាលនាយព្រានកុក្កុដមិត្រ ទៅដោះអន្ទាក់ មិនឃើញមានសត្វជាប់អន្ទាក់ ឃើញមានតែស្នាមព្រះបាទ និង ព្រះសាស្តា កំពុងគង់ នៅក្បែរអន្ទាក់របស់ខ្លួន ក៏នឹកគិត ថា "ព្រះសាស្តាទ្រង់បានដោះលែងសត្វចេញ អំពីអន្ទាក់អស់ហើយ" ក៏បានក្រោធខឹង យ៉ាងខ្លាំង ចំពោះព្រះអង្គ ហើយលើកនូវស្នា ធ្នូ ទាញដំឡើងយ៉ាងមាំ ដើម្បីនឹងបាញ់ព្រះអង្គ តែដោយពុទ្ធានុភាព ព្រានមិនអាចនឹងបាញ់ព្រះអង្គបានឡើយ ។

ចំណែក ពួកកូនប្រុសស្រី របស់នាយព្រាន មិនឃើញឪពុកវិលត្រឡប់មកផ្ទះវិញ ទើបបានចាប់ធ្នូស្នា ដើរទៅរកឪពុក ស្រាប់តែឃើញព្រះសម្មាសម្ពុទ្ធ នឹកគិតថា ជាបច្ចាមិត្រ ជាមួយនឹងឪពុករបស់ខ្លួន ក៏ទាញធ្នូស្នាឡើង ដើម្បីនឹងបាញ់ព្រះអង្គ តែមិនអាចបាញ់ព្រះអង្គបាន ។ ចំណែកឯ ភរិយានាយព្រានវិញ បានដឹងថា ប្តី និង កូនប្រុសស្រី បាត់យូរពេក មិនឃើញត្រឡប់វិលមកវិញ ក៏ម្នីម្នានាំកូនប្រសាទាំង ៧ នាក់ ទៅតាម ហើយក៏បានឃើញកូនប្រុសស្រី និង ស្វាមី កំពុងតែឈរទាញធ្នូស្នា បាញ់ព្រះសាស្តា ក៏ស្រែកប្រាប់ទៅ

*អ្នកទាំងនោះ ថា "សូមអ្នកទាំងអស់គ្នា កុំបាញ់ព្រះបិតា របស់យើងឡើយ" ។ នាយព្រាន បានឮដូច្នេះហើយ ក៏គិតថា "ព្រះសាស្តា ជាឪពុកក្មេក" ។ ឯពួកកូនៗ ក៏គិតថា "ព្រះសាស្តា ជាជីតា" ហើយបានប្រែចិត្តគំនិតជាថ្មី បានក្រាបថ្វាយបង្គំ សុំទោស ចំពោះព្រះអង្គ និងសុំយកព្រះអង្គជាទីពឹងទីរឭក ស្មើនឹងជីវិត ។*

*ព្រះសាស្តា ទ្រង់សំដែង នូវអនុបុព្វីកថា... ញ៉ាំងព្រាន ព្រមទាំងបុត្រធីតា គ្រប់គ្នា ឲ្យបានសម្រេចសោតាបត្តិផល ស្រេចហើយទើបស្តេចយាងត្រឡប់មកត្រាស់ពន្យល់រឿងនោះ ដល់ព្រះអានន្ទ ។ ភិក្ខុទាំងឡាយក្រាបទូលសួរថា "បពិត្រព្រះអង្គដ៏ចំរើន ពេលចប់ព្រះធម៌ទេសនាហើយ តើកិរិយារបស់នាយព្រានបានសម្រេចអ្វីដែរ?" ។*

*ព្រះសាស្តា ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ កិរិយារបស់នាយព្រានកុក្កុដមិត្រ បានសម្រេចសោតាបត្តិផល តាំងតែពីនាងនៅជាកុមារី មកម្ល៉េះ" ។ ភិក្ខុទាំងឡាយ មានសេចក្តីសង្ស័យថា "នាងបានសម្រេចសោតាបត្តិផល ចុះហេតុអ្វីហ្ន៎ បានជាមកសម្លាប់សត្វយ៉ាងដូច្នេះទៅវិញ?" ។*

*ព្រះសាស្តា ទ្រង់ត្រាស់ឆ្លើយតបទៅវិញ ថា "ព្រះសោតាបន្នមិនដែលសម្លាប់សត្វមានជីវិតឡើយ" ស្រេចហើយ ទើបត្រាស់ព្រះគាថានេះ ថា ៖*

បាណម្ហិ ចេ វណោ នាស្ស  ហរេយ្យ បាណិនា វិសំ
នាព្វណំ វិសមន្វេតិ  នត្ថិ បាបំ អកុព្វតោ ។

*បើដំបៅ មិនមាន ក្នុងបាតដៃទេ បុគ្គល គប្បីនាំយកថ្នាំពិស ដោយបាតដៃបាន, ថ្នាំពិស តែងមិនជ្រាបចូលទៅកាន់បាតដៃដែល គ្មានដំបៅ យ៉ាងណា, បាប រមែងមិនមានដល់បុគ្គលអ្នកមិនធ្វើ យ៉ាង នោះដែរ ។*

## ១០៣- រឿង នាយកោកសុនខលុទ្ទកៈ

*ព្រះបរមសាស្តាទ្រង់ប្រារព្ធនាយព្រានសុនខ ឈ្មោះកោកៈ ។ ថ្ងៃមួយ ព្រាននោះ បានបណ្តើរហ្វូងឆ្កែទៅដេញសត្វក្នុងព្រៃ, ថ្ងៃនោះ ឯង គាត់ រកសត្វសូម្បីតែសត្វមួយ ក៏មិនបានដែរ ដើរទៅ ដើរមក ស្រាប់តែឃើញភិក្ខុមួយរូប ទើបគិត ថា "ថ្ងៃនេះ អញ រកសត្វមិន បានសោះ ព្រោះតែអញបានជួបនឹងមនុស្ស អាក្រក់កាឡកិណី នេះ ឯង" ហើយក្រោធខឹង យ៉ាងខ្លាំង នឹងភិក្ខុរូបនោះ គាត់ ក៏បានបង្អៀ ឆ្កែ ឲ្យដេញខាំ (នូវភិក្ខុនោះ) ។*

*ភិក្ខុ រូបនោះ បានរត់ឡើងទៅលើដើមឈើ ដើម្បីកុំឲ្យឆ្កែវាខាំ បាន ។ នាយព្រានព្រៃ បានដេញតាមមកទាន់ ឃើញនូវភិក្ខុរូបនោះ ឡើងដើមឈើ ក៏យកលំពែងចាក់បាតជើងលោក ។ ភិក្ខុរូបនោះ បាន អង្វរករព្រានព្រៃ ជាច្រើនដងដដែលៗ ។ តែព្រានព្រៃចិត្តបាបចង្រៃ មិនព្រមស្តាប់ពាក្យ របស់លោកឡើយ រឹតតែពីចាក់បាតជើង ខ្លាំងជា មុនទៅទៀត ។*

*គ្រានោះឯង ចីពរ របស់ភិក្ខុ រូបនោះ បានរបូត ធ្លាក់ចុះមក*

ក្រោម គ្របលើខ្លួននាយព្រានព្រៃនោះ ។ ហ្វូងឆ្កែ បានឃើញចីពរ ធ្លាប់មកគ្រប លើម្ចាស់ហើយ វាស្មានថា "ភិក្ខុរូបនោះ បានធ្លាក់មក អំពីលើដើមឈើ" ក៏ស្ទុះបោល ចូលទៅខាំក្រញ៉ីម្ចាស់ខ្លួនឯង ស្លាប់ ក្នុងពេលនោះឯង ។

ភិក្ខុរូបនោះ បានឃើញឆ្កែខាំម្ចាស់ស្លាប់ហើយ ក៏បានបង្អើល ដេញហ្វូងឆ្កែ ឲ្យបោលរត់ចេញពីទីនោះទៅ ។ ឆ្កែ ផ្អើលរត់ចេញបាត់ ទៅហើយ ។

ភិក្ខុរូបនោះ បានចុះមកពីលើដើមឈើ មានសេចក្ដីសង្ស័យ ថា តើសីលរបស់អាត្មាអញ ដាច់ ឬក៏ មិនដាច់?" ដូច្នេះហើយ ក៏ បានចូលទៅ ក្រាបថ្វាយបង្គំ ទូលសួរចំពោះព្រះសាស្ដា ។

ព្រះសាស្ដា ទ្រង់បានត្រាស់ ថា "សីលរបស់អ្នក មិនដាច់ទេ" ដូច្នេះហើយ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

**យោ អប្បទុដ្ឋស្ស នរស្ស ទុស្សតិ**
**សុទ្ធស្ស បោសស្ស អនង្គណស្ស**
**តមេវ ពាលំ បច្ចេតិ បាបំ**
**សុខុមោ រជោ បដិវាតំវ ខិត្តោ ។**

បុគ្គលណា ប្រទូស្តចំពោះអ្នកដែលមិនប្រទូស្តតប ជាអ្នក ស្អាត បរិសុទ្ធ មិនមានកិលេសដូចជាទីទួល, បាប រមែងត្រឡប់មក រកបុគ្គលពាលនោះវិញ ដូចជាធូលីដ៏ល្អិត ដែលបុគ្គលបាចសាចទៅ កាន់ទីប្រាសខ្យល់ (រមែងរសាត់មករកខ្លួនវិញ) យ៉ាងនោះឯង ។

## ១០៤- រឿង មណីការ កុលុបគតិស្សត្ថេរ

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវព្រះតិស្សត្ថេរ ដែលចូលទៅកាន់ត្រកូលជាងកែវមណី ។ ថ្ងៃមួយ ព្រះបាទបសេនទិកោសល ទ្រង់ព្រះរាជទាននូវកែមណីឲ្យទៅជាងកែវមណីដើម្បីច្នៃ ។ ជាងកែវមណី កំពុងតែអង្គុយហាន់សាច់ មានដៃប្រឡាក់សុទ្ធតែឈាម បានទទួលកែវមណី យកមកដាក់លើជ្រញ់ ហើយក៏ក្រោកទៅលាងដៃ ។ ក្នុងខណៈនោះឯង សត្វក្រៀលដែលជាងកែវមណីចិញ្ចឹម មកឃើញកែវមណីលើជ្រញ់ ព្រមទាំងមានឈាមប្រឡាក់ នឹកស្មាន ថា "ជាដុំសាច់" ទើបចឹកលេបកែវមណីនោះ ចូលក្នុងពោះបាត់ទៅ ។

ជាងកែវមណី ចេញមកវិញ មិនឃើញកែវមណី លើជ្រញ់ នឹកគិតក្នុងចិត្ត ថា "មានតែព្រះថេរៈ មួយអង្គទេ ដែលលួចយកកែវមណី លើជ្រញ់នេះទៅ ព្រោះមិនមានអ្នកណាក្រៅអំពីព្រះថេរៈ ក្នុងទីនេះ" ហើយក៏បានចូលទៅសួរព្រះថេរៈថា "តើព្រះគុណម្ចាស់ បានយកកែវមណី លើជ្រញ់នេះមែនទេ?" ។ ព្រះថេរៈ ឆ្លើយថា "អាត្មាមិនបានយកទេ" ។ ជាងកែវមណី គិតថា "បើអាត្មាអញ សួរព្រះថេរៈស្រួលៗ ដូចជាមិនបានការសោះ អញ ត្រូវតែសម្លុត វាយធ្វើបាបទើបបានការ" ស្រេចហើយ ក៏យកខ្សែពួរមកចងព្រះថេរៈ យ៉ាងជាប់ ហើយយកដំបងមកវាយព្រះថេរៈ សួរយកចម្លើយ ធ្វើឲ្យគ្រាប់ភ្នែកព្រះថេរៈ លៀនចេញមកខាងក្រៅ លោហិត ជាច្រើន បានហូរស្រក់ចេញមក តាមត្រចៀក និង ច្រមុះ ។

សត្វក្រៀល ឃើញហើយ ក៏ចូលមកហួរចឹកឈាមព្រះថេរៈ

ស៊ី តាមចំណូលចិត្ត ។ ជាងកែវមណី កំពុងតែក្រោធខឹងយ៉ាងខ្លាំង ចំពោះព្រះថេរៈ លុះបានឃើញសត្វក្រៀល មករវីមរវាមក្បែរៗ ជើង ក៏ទាត់សត្វក្រៀលនោះ មួយជើងស្លាប់ មួយរំពេចនោះឯង ។ លុះ សត្វក្រៀលស្លាប់ហើយ, ព្រះថេរៈ បានប្រាប់ជាងកែវមណីថា "សត្វ ក្រៀលបានលេបកែវមណីនោះ ចូលទៅក្នុងពោះវាហើយ, បើញោម មិនជឿអាត្មាទេ ចូវះពោះវាមើលចុះ" ។ ជាងកែវមណី បានយក កាំបិតមក វះពោះសត្វក្រៀលដែលស្លាប់នោះ ហើយបានឃើញកែវ មណី ក្នុងពោះសត្វក្រៀលនោះ ក៏មានសេចក្ដីតក់ស្លុតរន្ធត់ចិត្ត ស្ទើរ តែបាត់បង់ស្មារតី ហើយបានក្រាបថ្វាយបង្គំ សុំខមាទោសចំពោះព្រះ ថេរៈ ។

បន្ទាប់មក ព្រះថេរៈ ក៏បានបរិនិព្វាន ដោយសារការវាយដុំ នោះ ។ សត្វក្រៀល ស្លាប់ទៅ បានទៅកើត ក្នុងផ្ទៃ នៃភរិយានាយ ព្រាននោះ ។ ចំណែកនាយព្រាន ស្លាប់ទៅ ក៏បានទៅកើត ទទួលទុក្ខ វេទនា យ៉ាងខ្លាំង ក្នុងនរក ។ ឯភរិយានាយព្រាន ស្លាប់ទៅ បានទៅ កើតនៅទេវលោក ។

ភិក្ខុទាំងឡាយ បានក្រាបទូលសួរសម្បរាយិកភព របស់ជន ទាំងនោះ នឹងព្រះសាស្ដា ។ ព្រះអង្គ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា៖

**គព្ភមេកេ ឧប្បជ្ជន្តិ  និរយំ បាបកម្មិនោ**
**សគ្គំ សុគតិនោ យន្តិ  បរិនិព្វន្តិ អនាសវា ។**

ជនពួកខ្លះ តែងកើត ក្នុងគភ៌មនុស្ស ពួកអ្នកមានអំពើអាក្រក់

តែងទៅកាន់នរក ពួកអ្នកមានគតិល្អ តែងទៅកាន់ឋានសួគ៌ ពួកអ្នកមិនមានអាសវៈ តែងបរិនិព្វាន ។

❋ ❋ ❋

១០៥- រឿង ជន ៣ នាក់

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវជន ៣ នាក់ ។ ទីមួយ មានភ្លើងឆេះផ្ទះ, ក្នុងខណៈនោះ មានរង្វេលឆ្នាំងមួយ ត្រូវភ្លើងឆេះរសាត់ទៅលើអាកាស ។ ពេលនោះ ស្រាប់តែមានក្អែកមួយ ហើរចូលទៅក្នុងរង្វេលឆ្នាំងនោះ ត្រូវភ្លើងឆេះស្លាប់ ធ្លាក់ចុះមកលើផែនដី ។ ភិក្ខុទាំងឡាយ បានឃើញហេតុនោះហើយ ក៏ចូលទៅក្រាបទូលសួរព្រះសាស្តា ។

ទីពីរ មានសំពៅមួយ បានទៅដល់កណ្តាលមហាសមុទ្រហើយ គឿងនឹងថ្កល់មិនកម្រើកខុសប្រក្រតី, ពួកមនុស្ស ក្នុងសំពៅគ្រប់ៗ គ្នា គិតថា "ក្នុងសំពៅរបស់យើងនេះ ប្រាកដជាមានមនុស្សកាឡកិណីហើយ" ទើបធ្វើជាស្លាក ចាប់គ្រប់ៗ គ្នា ។ ស្លាកនោះ បានធ្លាក់ទៅលើភរិយា របស់នាយសំពៅ ដល់ទៅ ៣ លើក ។ ពេលនោះ នាយសំពៅ ក៏បានដាច់ចិត្ត យកប្រពន្ធរបស់ខ្លួននោះ ទម្លាក់ទៅក្នុងសមុទ្រ ដើម្បីកុំឲ្យកើតមានសេចក្តីអន្តរាយ ស្លាប់បាត់បង់ជីវិតដល់មនុស្សភាគច្រើន ។ ភិក្ខុទាំងឡាយ ដែលជិះនៅ ក្នុងសំពៅនោះ ឃើញនូវហេតុនោះហើយ ទើបក្រាបទូលសួរព្រះសាស្តា ។

ទីបី មានភិក្ខុ ៧ រូប ផ្សេងពីនេះទៀត បាននៅអាស្រ័យ ក្នុង

រូងភ្នំមួយ ។ នៅវេលាពាក់កណ្តាលអាធ្រាត្រ ស្រាប់តែមានដុំថ្មធំមួយដុំ រមៀលធ្លាក់មកបិទមាត់ទ្វាររូងភ្នំនោះជិតឈឹង, ភិក្ខុទាំង ៧ រូបនោះ ខិតខំព្យាយាម ប្រមៀលនូវដុំថ្មនោះចេញ តែប្រមៀលមិនបាន ។ លុះកន្លងទៅបាន ៧ ថ្ងៃ, ដុំថ្មនោះ ក៏បានរមៀល ចេញទៅដោយខ្លួនឯង, ភិក្ខុទាំង ៧ រូបនោះ ព្រមទាំងភិក្ខុ ២ ក្រុមទៀត បាននាំគ្នា ទៅក្រាបទូលសួររឿងនោះ ចំពោះព្រះសាស្តា ។

ព្រះសាស្តា ទ្រង់ត្រាស់សំដែងនូវបុព្វកម្មរបស់សត្វទាំងនោះ ដល់ភិក្ខុទាំងអស់នោះ ដោយលំដាប់លំដោយ ថា ៖

ទីមួយ សត្វក្អែកដែលហើរចូលទៅ ក្នុងភ្លើងឆេះស្លាប់នោះ កាលពីអតីតជាតិ បានកើតជាអ្នកស្រែ ។ សម័យថ្ងៃមួយ អ្នកស្រែនោះ បានក្រោធខឹងយ៉ាងខ្លាំងនឹងគោពុតរបស់គាត់, គោពុតនោះ នៅពេលដែលម្ចាស់វា បរហ្វឹកហាត់នោះ វាដើរទៅបានបន្តិចហើយ ក៏ពុតធ្វើជាដេក ។ ម្ចាស់ខឹងខ្លាំងណាស់ ក៏បានយកចំបើង មកធ្វើជាគប់ រុំព័ទ្ធជាប់នឹង-ក របស់វា ហើយយកភ្លើងដុតគោនោះ ទាល់តែស្លាប់ នៅក្នុងទីនោះឯង ។

ទីពីរ ភរិយានាយសំពៅ ដែលត្រូវគេចាប់ចង ទម្លាក់ចោលទៅ ក្នុងសមុទ្រនោះ កាលពីអតីតជាតិ បានក្រោធខឹងនឹងឆ្កែរបស់ខ្លួន ដែលចេះតែដើរ តាមពីក្រោយនាង មិនថានាងទៅទីកន្លែងណាឡើយ ។ ពួកអ្នកស្រុក ឃើញដូច្នោះហើយ ក៏នាំគ្នានិយាយសើចចម្អកចម្អន់នាង ជាមួយនឹងឆ្កែនោះ ។ នាង មានការខ្មាសអៀន ខ្លាំង

## រឿង ជន ៣ នាក់

ពេក ទ្រាំពុំបាន ក៏យកដីខ្សាច់ប្រេក ក្នុងឆ្នាំងពេញហើយ នាំក្អែកនោះ ទៅជិតមាត់ទឹក ចងឆ្នាំងជាប់នឹងក្អែក ហើយចាប់ក្អែកបោះទម្លាក់ទៅ ក្នុងទឹក ។ ក្អែកនោះត្រូវបានសម្លាប់ ដោយសេចក្តីទុក្ខវេទនា ជាទីបំផុត ។

ទីបី ភិក្ខុ ៧ រូប ដែលអត់ចង្ហាន់ ទទួលទុក្ខលំបាក ក្នុងរូងភ្នំ អស់រយៈពេល ៧ ថ្ងៃ នោះ កាលអំពីជាតិមុន បានកើតជាក្មេងគង្វាលគោ, សម័យថ្ងៃមួយ ក្មេងគង្វាលគោទាំងនោះ បានកៀងគោទៅឃ្វាល នៅវាលស្រែដ៏ធំមួយ ហើយបានឃើញសត្វទន្សងមួយក្បាល ក៏ដេញចាប់ ។ សត្វទន្សង ភ័យយ៉ាងខ្លាំង ហើយបានបោលលូនចូលទៅ ក្នុងដំបូក ។ ពួកក្មេងឃ្វាលគោទាំងនោះ បានយកស្មៅនឹងកំណាត់ឈើ ទៅចុករន្ធដំបូកនោះ ជិតទាំងអស់ ដើម្បីទុកជីកវាក្នុងថ្ងៃស្អែក ។ លុះដល់ស្អែកឡើង, ក្មេងទាំងនោះ មិនបានជាចាប់ភ្លឹក ភ្លេចរហូតដល់ ៧ ថ្ងៃ ទើបនឹកឃើញ ហើយបាននាំគ្នា ទៅដកធ្នុករន្ធដំបូកដែលបានចុកនោះ ដើម្បីឲ្យសត្វទន្សង ចេញមកខាងក្រៅ ។ ពេលនោះ សត្វទន្សង បានវារចេញមក មានខ្លួនភ័យញ័រទទ្រើត គួរឲ្យអាណិតខ្លាំងណាស់ ស្គាំងស្គម នៅសល់តែស្បែក ព្រោះអត់អាហារស៊ី ៧ ថ្ងៃ មកហើយ ។ ក្មេងគង្វាលគោទាំងនោះ បានឃើញដូច្នោះហើយ ក៏មានចិត្តអាណិតអាសូរ ដល់សត្វទន្សងនោះ យ៉ាងខ្លាំង ហើយនិយាយប្រាប់គ្នា ថា "ពួកយើង កុំសម្លាប់វាអ្វី លែងវាឲ្យមានជីវិតទៅចុះ" ដូច្នេះ ។ នៅក្នុងទីបញ្ចប់ នៃអតីតនិទាន ព្រះអង្គទ្រង់ត្រាស់ នូវព្រះគាថានេះ ថា ៖

គាថាធម្មបទប្រែ

ន អន្តលិក្ខេ ន សមុទ្ទមជ្ឈេ
ន បព្វតានំ វិវរំ បវិស្ស
ន វិជ្ជតេ សោ ជគតិប្បទេសោ
យត្រដ្ឋិតោ មុច្ចេយ្យ បាបកម្មា ។

*បុគ្គល អ្នកធ្វើបាបកម្មហើយ ទោះបីរត់គេចទៅពួន ពួដី អាកាសក្តី នាកណ្តាលសមុទ្រក្តី កាន់ចន្លោះភ្នំទាំងឡាយក្តី ក៏នៅតែរត់គេចមិនរួច អំពីបាបកម្មនោះឡើយ ព្រោះថា ប្រទេសលើផែនដី ដែលបុគ្គលរត់គេច ទៅពួននៅហើយ គប្បីរួចផុត អំពីបាបកម្មបាននោះ មិនដែលមានឡើយ ។*

១០៦- រឿង សុប្បពុទ្ធសក្កៈ

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវសុប្បពុទ្ធសក្កៈ ដែលជាព្រះរាជបិតា របស់ព្រះនាងពិម្ពា និង ភិក្ខុទេវទត្ត ។ សុប្បពុទ្ធៈ ទ្រង់ព្រះពិរោធ យ៉ាងខ្លាំង ចំពោះព្រះសាស្តា ថា “ព្រះអង្គ ទ្រង់រត់ទៅបួស ចោលព្រះនាងពិម្ពាទេវី ឲ្យព្រះនាងនៅមេម៉ាយ, បំបួសព្រះទេវទត្ត ហើយ បានធ្វើខ្លួនឲ្យមានកម្មពៀរវេរានឹងគ្នាថែមទៀត” ។ ថ្ងៃមួយ សុប្បពុទ្ធៈ ទ្រង់ត្រាស់បញ្ជា ឲ្យពួកមនុស្សបិទនូវផ្លូវ ដើម្បីកុំឲ្យព្រះសម្មាសម្ពុទ្ធ ស្តេចយាងទៅ ទទួលនូវភត្តកិច្ចបាន ។*

*ក្នុងពេលនោះ ព្រះសាស្តា ទ្រង់ស្តេចយាងត្រឡប់មកវិញ ហើយ ទ្រង់ត្រាស់នឹងព្រះអានន្ទ ថា “ម្នាលអានន្ទ សុប្បពុទ្ធៈ ធ្វើអំពើ*

បាបកម្ម ធ្ងន់ណាស់ ព្រោះមិនបានឲ្យផ្លូវ ដល់តថាគត, ក្នុងថ្ងៃទី ៧ ផែនដី នឹងស្រូបព្រះបាទសុប្បពុទ្ធៈ នៅក្បែរជើងជណ្ដើរ នៃប្រាសាទខាងក្រោម” ។

ពួកចារបុរស បានឮដូច្នោះហើយ ក៏ទៅក្រាបទូលរឿងនោះថ្វាយព្រះបាទសុប្បពុទ្ធៈ ។ ព្រះអង្គ ទ្រង់ជ្រាបហើយ ទ្រង់មានព្រះចិន្តា ថា “ព្រះសាស្ដា ទ្រង់ត្រាស់មិនដែលខុសឡើយ តែបើទុកជាយ៉ាងនេះ ក៏ដោយ ផែនដី ក៏មិនអាចនឹងស្រូបអាត្មាអញបានដែរ” ។ ក្រោយមក ព្រះបាទសុប្បពុទ្ធៈ ទ្រង់ត្រាស់បញ្ជា ឲ្យពួកអាមាត្យ នាំយកគ្រឿងក្រយាស្ងោយ សម្រាប់សោយ ឡើងទៅលើប្រាសាទជាន់ទី ៧ ហើយ ព្រះអង្គ ក៏ឡើងទៅលើប្រាសាទ ទី ៧ នោះដែរ ទ្រង់ត្រាស់បញ្ជា ឲ្យពួកអាមាត្យ យកជណ្ដើរចេញទាំងអស់ ហើយបិទទ្វារប្រាសាទទាំងអស់ ទ្រង់ត្រាស់បញ្ជា ឲ្យពួកអ្នកចំបាប់ ជើងខ្លាំងៗនៅឈរចាំចាប់ ត្រង់មាត់ទ្វារប្រាសាទ ទ្វារមួយៗ ឲ្យមានគ្នាឈរចាំដល់ទៅ ២ នាក់ ហើយ ទ្រង់ត្រាស់ ថា “បើអញ ចង់ចុះទៅកាន់ប្រាសាទជាន់ក្រោម ដោយក្ដីធ្វេសប្រហែស ចូរអ្នកទាំងអស់គ្នា ចាប់អញទុក កុំឲ្យអញចុះទៅបាន” ។

លុះដល់ថ្ងៃទី ៧ សេះមង្គល របស់ព្រះបាទសុប្បពុទ្ធៈ បានស្រែកកញ្ជ្រោល យ៉ាងខ្លាំង ឥតមានឈប់ឡើយ ។ ព្រះបាទសុប្បពុទ្ធៈ ទ្រង់ព្រះសណ្ដាប់ ឮនូវសម្លេងសេះស្រែកញ្ជ្រោល យ៉ាងខ្លាំងដូច្នេះហើយ ទ្រង់មានព្រះទ័យចង់ទតសេះមង្គលនោះ ខ្លាំងណាស់ ។

គាថាធម្មបទប្រែ

ក្នុងគ្រានោះ ទ្វារទាំងឡាយ ក៏បានរបើកចេញមក ដោយខ្លួនឯង, ជណ្តើរ ក៏ឋិតនៅដូចដើមវិញដដែល ឥតមានអ្នកណាបើក និងដាក់វាឡើយ ។ ពួកអ្នកចំបាប់ ដែលឈរចាំ ត្រង់មាត់ទ្វារប្រាសាទ មិនបានចាប់ព្រះបាទសុប្បពុទ្ធទុកទេ ត្រឡប់ទៅជាចាប់ទម្លាក់ចុះមកក្រោម ថែមទៀត រហូតធ្លាក់មកដល់ជើងជណ្តើរនៃប្រាសាទជាន់ខាងក្រោម ។ ក្នុងខណៈនោះឯង មហាប្រឹថពី ក៏បានបើកផ្លូវជាពីរ ស្រូបយកព្រះបាទសុប្បពុទ្ធ: ទៅដាក់ដល់អវិចីមហានរកតែម្តង ។

ព្រះសាស្តា ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

ន អន្តលិក្ខេ ន សមុទ្ទមជ្ឈេ
ន បព្វតានំ វិវរំ បវិស្ស
ន វិជ្ជតេ សោ ជគតិប្បទេសោ
យត្រដ្ឋិតំ នប្បសហេយ្យ មច្ចុ ។

បុគ្គលបាប ទោះបីរត់គេចទៅលើអាកាសក្តី នៅកណ្តាលសមុទ្រក្តី ទៅកាន់ចន្លោះនៃភ្នំទាំងឡាយក្តី ក៏មិនអាចរត់គេច ឲ្យផុតអំពីមច្ចុរាជបានឡើយ ព្រោះថា ប្រទេសលើផែនដី ដែលបុគ្គលឋិតនៅហើយ មច្ចុរាជ មិនអាចសង្គ្រុបបាននោះ មិនដែលមានឡើយ ។

**ចប់ បាបវគ្គ ទី ៩**

## ទណ្ឌវគ្គ ទី ១០

### ១០៧- រឿង ឆព្វគ្គិយភិក្ខុ

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវភិក្ខុឆព្វគ្គីយ៍ ។ ពេលដែលពួកភិក្ខុសត្តរសវគ្គីយ៍ បោសសម្អាត នូវសេនាសនៈ បានស្អាតហើយ, ពួកភិក្ខុឆព្វគ្គីយ៍ និយាយថា "ពួកអ្នកឯងទាំងអស់គ្នា ចូរចេញអំពីទីនេះទៅ ពួកយើងទេ ដែលធំជាងពួកអ្នកឯង, សេនាសនៈនេះ ត្រូវបានមកលើពួកយើង" ។ ពួកភិក្ខុសត្តរសវគ្គីយ៍ បានឆ្លើយតបវិញថា "ពួកយើង មិនព្រមប្រគល់ឲ្យទេ ព្រោះពួកយើងខ្ញុំ បានបោសសម្អាតសេនាសនៈនេះ រួចមុនពួកអ្នកឯង" ។ ពួកភិក្ខុឆព្វគ្គីយ៍ ខឹងខ្លាំងពេក បានវាយពួកភិក្ខុសត្តរសវគ្គីយ៍ៗ ភិតភ័យ ខ្លាចហើយ បានស្រែកយ៉ាងខ្លាំង ។*

*ព្រះសាស្តា ទ្រង់ជ្រាបហើយ ទ្រង់បានបញ្ញត្តសិក្ខាបទ ហាមមិនឲ្យភិក្ខុ វាយប្រហារដល់គ្នានឹងគ្នា ហើយទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

សព្វេ តសន្តិ ទណ្ឌស្ស   សព្វេ ភាយន្តិ មច្ចុនោ
អត្តានំ ឧបមំ កត្វា   ន ហនេយ្យ ន ឃាតយេ ។

*សត្វទាំងឡាយគ្រប់ប្រាណ តែងតក់ស្លុតនឹងអាជ្ញា សត្វទាំងឡាយ តែងភ័យខ្លាចចំពោះសេចក្តីស្លាប់គ្រប់ៗ រូប, បុគ្គលគួរធ្វើខ្លួនឲ្យជាឧបមាហើយ មិនគួរប្រហារ ដោយខ្លួនឯង មិនគួរប្រើគេឲ្យប្រហារឡើយ ។*

♣ ❇ ♣

-១៧៧-

## គាថាធម្មបទប្រែ

### ១០៨- រឿងភិក្ខុឆព្វគ្គីយ៍

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធ នូវពួកភិក្ខុឆព្វគ្គីយ៍ ដែលបាន វាយប្រហារពួកភិក្ខុសត្តរសវគ្គីយ៍ ។ ពួកភិក្ខុសត្តរសវគ្គីយ៍ ទាំងនោះ ភ័យខ្លាចហើយ ក៏បានស្រែកយ៉ាងខ្លាំង ។*

*ព្រះសាស្តា ទ្រង់ជ្រាបហើយ ទើបទ្រង់បានបញ្ញត្តសិក្ខាបទ ហើយ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

**សព្វេ តសន្តិ ទណ្ឌស្ស សព្វេសំ ជីវិតំ បិយំ**
**អត្តានំ ឧបមំ កត្វា ន ហនេយ្យ ន ឃាតយេ ។**

*សត្វទាំងឡាយគ្រប់ប្រាណ សុទ្ធតែតក់ស្លុតនឹងអាជ្ញា ព្រោះថា ជីវិត ជាទីស្រឡាញ់ របស់សត្វគ្រប់ៗ រូប, បុគ្គលគួរធ្វើខ្លួនឲ្យជាឧបមាហើយ មិនគួរប្រហារ ដោយខ្លួនឯង មិនគួរប្រើគេឲ្យប្រហារឡើយ ។*

♣ ❇ ♣

### ១០៩- រឿងសម្ពហុលកុមារ

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធពួកកុមារ ជាច្រើន ដែលកំពុងតែនាំគ្នាវាយពស់មួយ ។ ព្រះសាស្តា ស្តេចយាងទៅ បិណ្ឌបាត ក្នុងទីក្រុងសាវត្ថី ទ្រង់ទតព្រះនេត្រឃើញហើយ ទ្រង់ត្រាស់សួរ ថា "នែកុមារទាំងឡាយ តើពួកអ្នក នាំគ្នាធ្វើអ្វី?" ។ កុមារទាំងនោះ បានក្រាបទូលថា "បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះករុណាទាំងឡាយ នាំគ្នាវាយពស់" ។ ព្រះសាស្តាទ្រង់ត្រាស់សួរទៀតថា "ព្រោះហេតុអ្វីបាន*

*ជាវាយវា? ” ។ កុមារទាំងនោះ បានក្រាបទូលថា “ព្រោះពួកខ្ញុំព្រះករុណា ខ្លាចវាខាំ” ។*

*ព្រះសាស្ដាចារ្យ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

សុខកាមានិ ភូតានិ    យោ ទណ្ឌេន វិហឹសតិ
អត្តនោ សុខមេសានោ   បេច្ច សោ ន លភតេ សុខំ ។
សុខកាមានិ ភូតានិ    យោ ទណ្ឌេន ន វិហឹសតិ
អត្តនោ សុខមេសានោ   បេច្ច សោ លភតេ សុខំ ។

*បុគ្គលណា ស្វែងរកសេចក្ដីសុខដើម្បីខ្លួន តែបៀតបៀនសត្វទាំងឡាយ ដែលប្រាថ្នាចង់បានសេចក្ដីសុខ ដោយអាជ្ញា, បុគ្គលនោះ លះលោកនេះទៅហើយ នឹងមិនបាននូវសេចក្ដីសុខឡើយ ។*

*បុគ្គលណា ស្វែងរកសេចក្ដីសុខ ដើម្បីខ្លួន តែមិនបៀតបៀនសត្វទាំងឡាយ ដែលប្រាថ្នាចង់បានសេចក្ដីសុខ ដោយអាជ្ញា, បុគ្គលនោះ លះលោកនេះទៅហើយ រមែងបាននូវសេចក្ដីសុខ ។*

❇ ❇ ❇

## ១១០- រឿង ព្រះកោណ្ឌធានត្ថេរ

*ព្រះបរមសាស្ដា ទ្រង់ប្រារព្ធ នូវព្រះកោណ្ឌធានត្ថេរ ។ តាំងតែអំពីពេលដែលព្រះថេរៈបួសមក មានរូបស្រីម្នាក់ដើរ តាមក្រោយលោក ដូចជាស្រមោលដែលអន្ទោលតាមប្រាណ ។ ព្រះថេរៈ លោកមិនឃើញស្រីនោះទេ តែពួកមហាជន បានឃើញរូបស្រីនោះ ។ ក្នុងសាសនា នៃព្រះពុទ្ធព្រះនាមកស្សបៈ, ព្រះថេរៈ កើតជាទេវតា បាន*

*ក្លែងខ្លួន ធ្វើជាស្រីម្នាក់ដើរ តាមពីក្រោយ ភិក្ខុមួយរូប ដែលជាហេតុធ្វើឲ្យភិក្ខុមួយរូបទៀត ដែលជាសំឡាញ់នឹងគ្នា បែកបាក់សាមគ្គីគ្នា ។ ព្រោះតែបាបកម្ម នេះហើយ បានជាមានរូបស្រី ដើរតាមពីក្រោយលោក ។*

*ភិក្ខុទាំងឡាយ បានចោទព្រះថេរៈ ថា "ជាភិក្ខុទ្រុស្តសីល" ។ ព្រះថេរៈ បានចោទទៅភិក្ខុទាំងនោះ ថា "ជាភិក្ខុទ្រុស្តសីល" ដូចគ្នាដែរ ។ ភិក្ខុទាំងឡាយបាននាំរឿងនេះទៅក្រាបទូលដល់ព្រះសាស្តា ។*

*ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ឲ្យហៅព្រះថេរៈមក ដើម្បីនឹងជម្រះនូវរឿងនេះ ឲ្យបានយុត្តិធម៌ ហើយត្រាស់នូវព្រះគាថានេះ ថា៖*

មាវោច ផរុសំ កញ្ចិ វុត្តា បដិវទេយ្យុ តំ
ទុក្ខា ហិ សារម្ភកថា បដិទណ្ឌា ផុសេយ្យុ តំ ។
សចេ នេរេសិ អត្តានំ កំសោ ឧបហតោ យថា
ឯស បត្តោសិ និព្វានំ សារម្ភោ តេ ន វិជ្ជតិ ។

*អ្នក កុំនិយាយពាក្យអាក្រក់នឹងអ្នកណាមួយឡើយ, ជនទាំងឡាយ ដែលត្រូវអ្នកស្តីថាឲ្យហើយ គេគប្បីស្តីថា តបមករកអ្នកវិញ ព្រោះថា ការពោលពាក្យប្រណាំងប្រជែង ជាហេតុនាំឲ្យកើតទុក្ខ, ការតស៊ូទាំងឡាយ ត្រូវប៉ះពាល់នូវខ្លួនអ្នកវិញ, បើអ្នកធ្វើខ្លួន មិនឲ្យញាប់ញ័រ ដូចជារគាំងដែលគេចៀរមាត់ហើយ រមែងមិនលាន់ឮសូរ ដូច្នោះ អ្នកនុ៎ះ ជាបុគ្គលដល់នូវព្រះនិព្វាន, ការប្រណាំងប្រជែង នឹងមិនមានដល់អ្នកទេ ។*

## ១១១-រឿង ឧបោសថកម្ម

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធឧបោសថកម្ម របស់ឧបាសិកាទាំងឡាយ មាននាងវិសាខាជាដើម ។ ក្នុងថ្ងៃឧបោសថសីល ថ្ងៃមួយ នាងវិសាខា បានសួរឧបាសិកាទាំងនោះថា "តើអ្នកទាំងអស់គ្នា រក្សាឧបោសថសីល ដើម្បីប្រាថ្នាប្រយោជន៍អ្វីខ្លះដែរ?" ។ ពួកឧបាសិកាដែលមានវ័យចាស់ៗ បានឆ្លើយថា "ដើម្បីបានទទួលទិព្វសម្បត្តិ" ។ ពួកឧបាសិកាដែលមានវ័យកណ្តាលៗ ឆ្លើយថា "ដើម្បីកុំឲ្យស្វាមី របស់ខ្លួន មានភរិយាថ្មីទៀត" ។ ពួកឧបាសិកាក្មេងៗ បានឆ្លើយថា "ដើម្បីឲ្យបានកូនប្រុស លើកដំបូង" ។ ពួកឧបាសិកា ដែលមានវ័យជំទង់ៗ បានឆ្លើយថា "ដើម្បីឲ្យមានស្វាមី តាំងតែពីអាយុនៅក្មេងៗ" ។ នាងវិសាខា ស្តាប់ឮដូច្នេះហើយ ទើបបានយករឿងនេះទៅក្រាបទូលព្រះសាស្តា ។*

*ព្រះបរមសាស្តាចារ្យ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

**យថា ទណ្ឌេន គោបាលោ គាវោ បាជេតិ គោចរំ**
**ឯវំ ជរា ច មច្ចុ ច អាយុំ បាជេតិ បាណិនំ ។**

*គង្វាលគោ រមែងកៀងគោទាំងឡាយទៅកាន់ទីគោចរ ដោយអាជ្ញា គឺ ដំបង ឬ រំពាត់ យ៉ាងណាមិញ, ជរា គឺ សេចក្តីទ្រុឌទ្រោមគ្រាំគ្រា និង មច្ចុរាជ គឺ សេចក្តីស្លាប់ តែងកៀងនូវអាយុ របស់សត្វទាំងឡាយ ក៏យ៉ាងដូច្នោះឯង ។*

❊ ❊ ❊

# គាថាធម្មបទប្រែ

## ១១២- រឿងអជគរប្រេត

ព្រះបរមសាស្ដា ទ្រង់បានប្រារព្ធនូវអជគរប្រេត ដែលមានអត្តភាព ដូចជាពស់ថ្លាន់ វែងប្រវែង ២៥ យោជន៍ ។ ព្រះមហាមោគ្គល្លានត្ថេរ និមន្តចុះអំពីកំពូលភ្នំគិជ្ឈកូដ បានឃើញនូវប្រេតនោះ ដោយទិព្វចក្ខុហើយ និយាយជាមួយនឹងព្រះលក្ខណត្ថេរ នៅទីចំពោះព្រះភក្ត្រនៃព្រះសាស្ដា ។

ព្រះបរមសាស្ដា ទ្រង់ត្រាស់សំដែងធម្មិកថា ថា "តថាគត ក៏បានឃើញប្រេតនោះដែរ" ។ ភិក្ខុទាំងឡាយ បានក្រាបទូលសួរ នូវបុព្វកម្ម របស់ប្រេតនោះ ចំពោះព្រះសាស្ដា ។

ព្រះអង្គ ទ្រង់ត្រាស់អតីតនិទានថាៈ ក្នុងសាសនា នៃព្រះពុទ្ធព្រះនាមកស្សបទសពល ប្រេតនេះ ជាចោរ បានប្រទូស្តរ៉ាយ ដល់សុមង្គលសេដ្ឋី គឺបានដុតស្រែ កាត់ជើងគោ ដុតផ្ទះរបស់លោកសេដ្ឋីដល់ទៅ ៧ ដង ប៉ុណ្ណោះហើយ ក៏នៅតែមិនឆ្អែតចិត្តទៀត បានទាំងទៅដុតនូវព្រះគន្ធកុដី ដែលលោកសេដ្ឋី សាងថ្វាយព្រះកស្សបទសពលថែមទៀត, លុះដល់ទំលាយរាងកាយស្លាប់ទៅ ក៏បានទៅកើត ក្នុងអវិចីនរក អស់កម្មអំពីឋាននរកនោះមក ក្នុងពុទ្ធកាលនេះ ក៏បានកើតជាអជគរប្រេត មានភ្លើងឆេះ នៅលើភ្នំគិជ្ឈកូដនេះ" ក្នុងទីបញ្ចប់នៃអតីតនិទាន ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

អថ បាបានិ កម្មានិ　　　　　　　ករំ ពាលោ ន ពុជ្ឈតិ
សេហិ កម្មេហិ ទុម្មេធោ　　អគ្គិទឌ្ឍោវ តប្បតិ ។

## រឿង ព្រះមហាមោគ្គល្លានត្ថេរ

បុគ្គលពាល មិនមានប្រាជ្ញា កំពុងធ្វើអំពើអាក្រក់ ក៏នៅតែមិនភ្ញាក់ខ្លួន លុះកាលជាខាងក្រោយមក ទើបក្តៅក្រហាយ ដោយសារកម្មទាំងឡាយរបស់ខ្លួន ដូចត្រូវភ្លើងឆេះ ។

♣ ❇ ♣

## ១១៣- រឿង ព្រះមហាមោគ្គល្លានត្ថេរ

ព្រះបរមសាស្តា ទ្រង់បានប្រារព្ធ នូវព្រះមហាមោគ្គល្លានត្ថេរ ដែលត្រូវពួកតិរ្ថិយ ជួលពួកចោរឲ្យទៅសម្លាប់ ។

ព្រះបាទអជាតសត្រូវ ទ្រង់ស៊ើបសួររករឿងពិត លុះទ្រង់ជ្រាបហើយ ទ្រង់ព្រះរាជបញ្ជា ឲ្យចាប់ពួកតិរ្ថិយ ដែលជាអ្នកផ្តើមហេតុ ព្រមទាំងពួកចោរ ដែលជាអ្នកសម្លាប់ព្រះថេរៈ ហើយទ្រង់ត្រាស់បញ្ជាឲ្យជីកអន្លង់កប់ត្រឹមផ្ចិត ឲ្យយកចំបើងដាក់ពីលើ ហើយឲ្យយកភ្លើងទៅដុតទាំងរស់ ធ្វើឲ្យស្លាប់គ្មានសល់ម្នាក់ឡើយ ។

ភិក្ខុទាំងឡាយ បានសន្ទនាគ្នាអំពីរឿងព្រះមហាមោគ្គល្លាន-ត្ថេរ ។ ព្រះសាស្តា ទ្រង់ត្រាស់នូវអតីតនិទាន របស់ព្រះមហាមោគ្គ-ល្លានត្ថេរ ថាៈ ក្នុងជាតិដែលព្រះមហាមោគ្គល្លាន កើតជាកុលបុត្រ មានភរិយា ត្រូវភរិយានោះ និយាយចាក់ដោត ញុះញង់ ឲ្យយកមាតាបិតា របស់ខ្លួន ទៅសម្លាប់ចោល... លុះដល់កុលបុត្រនោះ ស្លាប់ទៅបានទៅកើតរងទុក្ខ ក្នុងនរក រាប់សែនឆ្នាំ ដោយផលវិបាក ដែលខ្លួនបានសម្លាប់មាតាបិតានោះ លុះកើតក្នុងជាតិណាៗ ត្រូវគេវាយដំខ្ទេចខ្ទីង យ៉ាងដូច្នេះ រហូតមួយរយអត្តភាព... ព្រះមហាមោគ្គល្លានត្ថេរ

*បរិនិព្វាន យ៉ាងនេះ សមគួរនឹងកម្ម របស់ខ្លួនហើយ ។ ចំណែកពួក តិរ្ថិយ និង ពួកចោរ ដែលបានប្រទូស្តរ៉ាយ ចំពោះព្រះថេរៈ ជាអ្នក មិនបានប្រទូស្តរ៉ាយតបវិញនោះ បានទទួលនូវសេចក្តីទុក្ខសមគួរដូច គ្នាដែរ" ក្នុងទីបញ្ចប់នៃអតីតនិទាន ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

យោ ទណ្ឌេន អទណ្ឌេសុ អប្បទុដ្ឋេសុ ទុស្សតិ
ទសន្នមញ្ញតរំ ឋានំ ខិប្បមេវ និគច្ឆតិ
វេទនំ ផរុសំ ជានឹ សរីរស្ស វ ភេទនំ
គរុកំ វាបិ អាពាធំ ចិត្តក្ខេប វ បាបុណេ
រាជតោ វា ឧបសគ្គំ អព្ភក្ខានំ វ ទារុណំ
បរិក្ខយំ វ ញាតីនំ ភោគានំ វ បភង្គុណំ
អថ វស្ស អគារានិ អគ្គិ ឌហតិ បាវកោ
កាយស្ស ភេទា ទុប្បញ្ញោ និរយំ សោ ឧបបជ្ជតិ ។

*បុគ្គលណា ប្រទូស្ត ដោយអាជ្ញា ចំពោះបុគ្គលទាំងឡាយ ដែលមិនមានអាជ្ញា ជាអ្នកមិនប្រទូស្ត, បុគ្គលនោះ រមែងដល់នូវ ហេតុនៃសេចក្តីទុក្ខ ណាមួយ ក្នុងហេតុ ១០ យ៉ាង ដោយទាន់ហន់ គឺ គប្បីដល់នូវវេទនា ដ៏អាក្រក់ ១ សេចក្តីវិនាសទ្រព្យ ១ បែកធ្លាយ សរីរៈ ១ អាពាធជាទម្ងន់ ១ ក្រឡកចិត្ត(ឆ្កួត) ១ របៀជាន់អំពីស្តេច ១ ពោលពាក្យបង្កាច់ ដ៏អាក្រក់ ១ អស់ពួកញាតិរលីង ១ ពុកផុយ ភោគសម្បត្តិទាំងឡាយ ១ ទាំងភ្លើងនឹងឆេះបំផ្លាញនូវផ្ទះរបស់បុគ្គល នោះ ១, បុគ្គលមិនមានប្រាជ្ញានោះ លុះបែកធ្លាយរាងកាយ រមែងទៅ*

# រឿងពហុភណ្ឌិកភិក្ខុ

*កើតក្នុងនរក ។*

✻ ✻ ✻

## ១១៤- រឿងពហុភណ្ឌិកភិក្ខុ

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធ នូវភិក្ខុដែលមានគ្រឿងបរិក្ខារច្រើន ។ ភិក្ខុរូបនេះ កាលពីនៅជាគ្រហស្ថ ជាកុដុម្ពីក៍ អ្នកមានទ្រព្យសម្បត្តិច្រើន ពេលភរិយាស្លាប់ទៅ បានចូលទៅបួស ក្នុងព្រះពុទ្ធ-សាសនា តែមុននឹងបួស បានឲ្យគេសាងសាលា និង បន្ទប់សម្រាប់ដាក់នូវរបស់របរផ្សេងៗ, លុះបួសហើយ បានហៅអ្នកបម្រើមកដើម្បីឲ្យធ្វើចង្ហាន់ប្រគេន តាមសេចក្តីត្រូវការ វេលាយប់ គ្រងចីវរស្បង់មួយបន្លាស់ផ្សេង វេលាថ្ងៃ គ្រងចីវរស្បង់ មួយបន្លាស់ផ្សេងទៀត មិនឲ្យប្រឡំគ្នា ។ ពួកភិក្ខុទាំងឡាយ បានឃើញដូច្នេះហើយទើបនាំគ្នាយករឿងនេះ ទៅក្រាបទូលថ្វាយ ព្រះសាស្តាទ្រង់ជ្រាប ។ ព្រះសាស្តាទ្រង់តិះដៀលភិក្ខុរូបនោះជាច្រើន ។ ភិក្ខុរូបនោះ ក៏ក្រោធខឹងនឹងព្រះបរមសាស្តា ហើយបានដោះចីវរចេញ អំពីខ្លួនអស់ នៅសល់តែស្បង់ប៉ុណ្ណោះ ស្រេចហើយ ក៏បានទៅឈរនៅ ក្នុងទីជុំនុំនៃពួកបរិស័ទ ។*

*ព្រះសាស្តា ទ្រង់បាននាំអតីតនិទានមក សំដែងថា: ក្នុងជាតិដែលភិក្ខុរូបនេះ កើតជាអារក្សទឹក (ខ្មោចទឹក) ជាអ្នកប្រាថ្នាចង់បាននូវទេវធម៌ គឺហិរិ និង ឱត្តប្ប: តែឥឡូវនេះ បានចូលមកបួស ក្នុងព្រះពុទ្ធសាសនានេះហើយ ក៏ត្រឡប់ជាលះបង់ចោល នូវទេវធម៌នេះ ទៅ*

វិញ ហើយបានមកឈរស្លៀកស្បង់តែមួយ ក្នុងចំណោមពុទ្ធបរិស័ទ យ៉ាងនេះ តើព្រោះហេតុដូចម្តេច? ។

ភិក្ខុ រូបនោះ បានឮដូច្នេះហើយ មានការតក់ស្លុត រន្ធត់ចិត្ត យ៉ាងខ្លាំង រហូតកើតមានហិរិ និង ឱត្តប្បៈ គ្រងចីវរ ក្រាបថ្វាយបង្គំព្រះសាស្តាហើយ គង់នៅក្នុងទីដ៏សមគួរមួយ ។

ព្រះសាស្តាចារ្យ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

**ន នគ្គចរិយា ន ជដា ន បង្កា**
**នានាសកា តណ្ឌិលសាយិកា វា**
**រជោជល្លំ ឧក្កុដិកប្បធានំ**
**សោធេន្តិ មច្ចំ អវិតិណ្ណកង្ខំ ។**

កិរិយាប្រព្រឹត្តិអាក្រាតកាយ ១, ការទុកសក់ ១, ការដេកលើភក់ ១, ការមិនបរិភោគបាយ ១, ការដេកលើផែនដី ១, ការប្រឡាក់ខ្លួន ដោយធូលី ១, ការព្យាយាមអង្គុយច្រហោង ១ (ទាំងអស់នេះ) មិនជម្រះសត្វ ដែលមិនទាន់ឆ្លងផុតសេចក្តីសង្ស័យ ឲ្យបរិសុទ្ធបានសោះឡើយ ។

## ១១៥-រឿងសន្តតិមហាអមាត្យ

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវសន្តតិមហាអមាត្យ ដែលបានទៅ បង្ក្រាបនូវសត្រូវ ក្នុងបច្ចន្តជនបទ ដែលមានពួកចោរបុករុក ធ្វើឲ្យមានភាពស្ងប់ស្ងាត់ឡើងវិញហើយ ក៏បានត្រឡប់មកស្រុកវិញ ។

-១៨៦-

# រឿងសន្តតិមហាអមាត្យ

ព្រះបាទបសេនទិកោសល ទ្រង់មានព្រះរាជហឫទ័យសោមនស្ស យ៉ាងក្រៃលែង ហើយទ្រង់ព្រះរាជទានរាជ្យសម្បត្តិ ឲ្យដល់មហាអមាត្យនោះ ឡើងគ្រងរាជ្យជំនួសព្រះអង្គ អស់រយៈពេល ៧ ថ្ងៃ ។

សន្តតិមហាអមាត្យនោះ បានផឹកស្រាស្រវឹង អស់រយៈពេល ៧ ថ្ងៃ ។ នៅក្នុងថ្ងៃទី ៧ គាត់បានស្អិតស្អាងរាងកាយ ដោយគ្រឿងអលង្ការផ្សេងៗ ហើយឡើងជិះលើខ្នងដំរីមង្គលមួយ បរសំដៅឆ្ពោះទៅកាន់កំពង់ទឹក បានឃើញនូវព្រះសាស្តា ស្តេចកំពុងតែទ្រង់យាងបិណ្ឌបាត ប្រោសសត្វ ទើបបានងក់ក្បាល ដើម្បីក្រាបថ្វាយបង្គំ ។

ព្រះសាស្តា ទ្រង់បានធ្វើកិរិយាញញឹមព្រះឱស្ឋ ឲ្យប្រាកដឡើង ។ ព្រះអានន្ទ បានក្រាបទូលសួរ នូវហេតុដែលព្រះអង្គទ្រង់ញញឹមនោះ ។ ព្រះអង្គ ទ្រង់ត្រាស់ឆ្លើយថា "ម្នាលអានន្ទ សន្តតិមហាអមាត្យ នឹងមកកាន់សំណាក់តថាគត ព្រមទាំងគ្រឿងអលង្ការ ហើយនឹងបានសម្រេចព្រះអរហត្តផល បរិនិព្វាន ក្នុងថ្ងៃនេះឯង" ។

ក្នុងពេលដែលសន្តតិមហាអមាត្យ ទៅលេងទឹក តាំងតែអំពីព្រលឹម រហូតដល់ល្ងាច ហើយបានទៅកំសាន្តសួនច្បារ អង្គុយមើលតន្ត្រីដែលព្រះបាទបសេនទិកោសលទ្រង់បានព្រះរាជទានឲ្យនោះ, ក៏ស្រាប់តែមានខ្យល់សត្ថកវាត កើតឡើង យ៉ាងខ្លាំង ក្នុងផ្ទៃនៃស្រីអ្នករបាំម្នាក់ ដែលកំពុងតែរាំនោះ ហើយបានផ្តាច់យកបេះដូងនាង ធ្វើឲ្យស្លាប់ ក្នុងពេលនោះភ្លាម ។ សន្តតិមហាអមាត្យ បានឃើញស្រី

*ប្រាំនោះស្លាប់ហើយ ក៏កើតទុក្ខសោកស្តាយទាន់ យ៉ាងក្រៃលែង មិនសំឡឹងឃើញអ្នកណាម្នាក់ ដែលអាចជួយសម្រាលសេចក្តីទុក្ខ ដ៏ធំនេះបាន ទើបចូលទៅគាល់ព្រះសាស្តា ។*

*ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់សំដែងព្រះធម៌ទេសនា ប្រោសសន្តតិមហាអមាត្យនោះ រហូតដល់បានសម្រេចព្រះអរហត្តផល ក្នុងថ្ងៃនោះ ។ លុះសន្តតិមហាអមាត្យ សម្រេចព្រះអរហត្តផលហើយ ក៏បានបរិនិព្វាន ក្នុងថ្ងៃនោះផងដែរ ។*

*ភិក្ខុទាំងឡាយ បានសន្ទនាគ្នាអំពីរឿងសន្តតិមហាអមាត្យនោះថា "តើយើងត្រូវហៅសន្តតិមហាអមាត្យនេះ យ៉ាងដូចម្តេច?" ។*

*ព្រះសាស្តាចារ្យ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

អលង្កតោ ចេបិ សមំ ចរេយ្យ
សន្តោ ទន្តោ និយតោ ព្រហ្មចារី
សព្វេសុ ភូតេសុ និធាយ ទណ្ឌំ
សោ ព្រាហ្មណោ សោ សមណោ ស ភិក្ខុ ។

*បើបុគ្គលណា មានខ្លួនប្រដាប់ស្អិតស្អាងហើយ តែគប្បីប្រព្រឹត្តស្មើ ជាអ្នកស្ងប់រម្ងាប់ អប់រំខ្លួនបានល្អហើយ ជាអ្នកទៀងចំពោះមគ្គផល ជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ទម្លាក់ចោល នូវអាជ្ញាក្នុងសត្វទាំងពួងបានហើយ, បុគ្គលនោះ ហៅថា ព្រាហ្មណ៍ ក៏បាន ថា សមណៈ ក៏បាន ថា ភិក្ខុ ក៏បាន ។*

♣ ❇ ♣

## ១១៦- រឿង ព្រះបិលោតិកត្ថេរ

ព្រះបរមសាស្ដា ទ្រង់ប្រារព្ធនូវព្រះបិលោតិកត្ថេរ ។ ពេលដែលព្រះថេរៈ មិនទាន់បានបួសនោះ លោកស្លៀកសំពត់ចាស់ដាច់ដាច កាន់ត្រឡោកដូង ដើរសុំទានគេ ចិញ្ចឹមជីវិត ។ ព្រះអានន្ទ បានបបួលមកបួស ក្នុងព្រះពុទ្ធសាសនា ។ លុះលោកបួសហើយ បានយកសំពត់ ដែលខ្លួនធ្លាប់ស្លៀកពាក់ ក្នុងពេលដែលនៅជាគ្រហស្ថនោះ មកឈ្លីសាកល្បងមើល ទើបឃើញថា មិនអាចនឹងយកមកត្រងទឹកបានឡើយ ហើយ ក៏យកសំពត់នោះ ទៅពាក់លើមែកឈើមួយ ពេលណា លោកចង់សឹក ពោលនោះ ក៏បាននិមន្តទៅទីកន្លែងនោះ ដើម្បីនឹងអប់រំទូន្មានខ្លួន លុះឈប់ចង់សឹកហើយ ទើបបានវិលត្រឡប់មកវិញ ។

ភិក្ខុទាំងឡាយ បានឃើញនូវព្រះថេរៈ និមន្តទៅកាន់ទីនោះជារឿយៗ ក៏បានដណ្ដឹងសួរថា “នែលោកម្ចាស់ តើលោកម្ចាស់ និមន្តទៅវិញទៅមកកាន់ទីនោះ ព្រោះមានហេតុអ្វីដែរ?” ។ ព្រះថេរៈ បានឆ្លើយថា “ខ្ញុំព្រះករុណា ទៅរកអាចារ្យរបស់ខ្ញុំព្រះករុណា” ។ ក្រោយមក ព្រះថេរៈ បានសម្រេចនូវព្រះអរហត្តផល ។ ពួកភិក្ខុទាំងឡាយបានសួរព្រះថេរៈ ថា “ឥឡូវនេះ ម្ដេចក៏លោកម្ចាស់មិនទៅរកអាចារ្យដូចពេលមុនទៀត?” ។

ព្រះថេរៈ ឆ្លើយថា “ឥឡូវនេះ ខ្ញុំព្រះករុណា មិនបានជាប់ជំពាក់ ជាមួយនឹងលោកអាចារ្យនោះទៀតហើយ ហេតុនេះ បានជាខ្ញុំមិនទៅរកលោកអាចារ្យនោះ ដូចជាពេលមុន” ។ ភិក្ខុទាំងឡាយបាន

*ទៅក្រាបទូលរឿងនោះ ថ្វាយព្រះសាស្តាថា "ព្រះថេរៈ ពោលអួតនូវព្រះអរហត្តផល" ។*

*ព្រះសាស្តា ទ្រង់ត្រាស់នូវរឿងពិត ដល់ភិក្ខុទាំងនោះ ហើយត្រាស់នូវព្រះគាថានេះ ថា ៖*

ហិរិនិសេធោ បុរិសោ　កោចិ លោកស្មិ វិជ្ជតិ
យោ និទ្ទំ អបពោធេតិ　អស្សោ ភទ្រោ កសាមិវ ។

អស្សោ យថា ភទ្រោ កសានិវិដ្ឋោ
អាតាបិនោ សំវេគិនោ ភវាថ
សទ្ធាយ សីលេន ច វីរិយេន ច
សមាធិនា ធម្មវិនិច្ឆយេន ច
សម្បន្នវិជ្ជាចរណា បដិស្សតា
បហស្សថ ទុក្ខមិទំ អនប្បកំ ។

*បុរសអ្នកកំចាត់បង់ នូវអកុសលវិតក្កៈ ដោយសេចក្តីខ្មាសបាប មានតិចណាស់ ក្នុងលោក, បុគ្គលណា បន្ទោបង់នូវការដេកលក់ (ស្ទុះក្រោកឡើង) ដូចសេះល្អ ខ្លាចព្រោះរំពាត់ (មិនឲ្យប៉ះខ្លួនដូច្នោះ) បុគ្គលនោះ រកបានដោយកម្រ ក្នុងលោក ។*

*អ្នកទាំងឡាយ ចូរមានសេចក្តីព្យាយាម មានសេចក្តីតក់ស្លុតដូចជាសេះដែលល្អ ត្រូវនាយសារថី វាយដោយរំពាត់ តក់ស្លុតដូច្នោះឯង, បើអ្នកទាំងឡាយ ប្រកបព្រមដោយសទ្ធាផង សីលផងព្យាយាមផង សមាធិផង ធម្មវិនិច្ឆ័យផង ជាអ្នកមានវិជ្ជា និង ចរណៈ*

រឿងសុខសាមណេរ

ដ៏បរិបូណ៌ មានស្មារតីតម្កល់មាំ រមែងលះបង់នូវសេចក្ដីទុក្ខ ដែលមានប្រមាណច្រើននេះបានមិនខាន ។

❈ ❈ ❈

១១៧- រឿងសុខសាមណេរ

ព្រះបរមសាស្ដា ទ្រង់ប្រារព្ធនូវសុខសាមណេរ ដែលជាបុត្រនៃត្រកូលឧបដ្ឋាក របស់ព្រះសេនាបតីសារីបុត្រ ក្នុងក្រុងសាវត្ថី ។ សុខសាមណេរនេះ ជាអ្នកមានបុណ្យបានសន្សំទុកមកហើយ ពីជាតិមុន ក្នុងពេលដែលមានអាយុ ៧ ឆ្នាំ, បានទៅបួសជាសាមណេរ ក្នុងសំណាក់ព្រះសារីបុត្រ ។ សម័យថ្ងៃមួយ សុខសាមណេរ បាននិមន្តទៅជាមួយនឹងព្រះឧបជ្ឈាយ៍ ឃើញកសិករ កំពុងតែបាចទឹកបញ្ចូលទៅក្នុងស្រែ ឃើញជាងធ្វើព្រួញ កំពុងពត់ព្រួញឲ្យត្រង់ ឃើញជាងឈើកំពុងចាំងឈើ ហើយបានយកធ្វើជាអារម្មណ៍ អប់រំចិត្ត របស់ខ្លួនឲ្យបានល្អ ដូចជាបណ្ឌិតសាមណេរដែរ ហើយថ្វាយបង្គំលាព្រះឧបជ្ឈាយ៍ ត្រឡប់មកវិញ ខំបំពេញសមណធម៌ រហូតបានសម្រេចព្រះអរហត្តផល ក្នុងពេលនោះឯង ។ ពួកភិក្ខុទាំងឡាយ បានសន្ទនាគ្នាអំពីរឿងសុខសាមណេរនោះ ដោយប្រការផ្សេងៗ ។

ព្រះសាស្ដាចារ្យ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

ឧទកំ ហិ នយន្តិ នេត្តិកា
ឧសុការា នមយន្តិ តេជនំ
ទារុំ នមយន្តិ តច្ឆកា

គាថាធម្មបទប្រែ

**អត្តានំ ទមយន្តិ សុព្វតា ។**

*ធម្មតាអ្នកបង្ហូរទឹក តែងបង្ហូរទឹក អ្នកធ្វើព្រួញ តែងពត់ព្រួញ (ឲ្យត្រង់) អ្នកចាំងឈើតែងចាំងឈើ អ្នកមានវត្តល្អតែងទូន្មានខ្លួន ។*

**ចប់ ឧណ្ឌវគ្គ ទី ១០**

ជរាវគ្គ ទី ១១

១១៨- រឿងវិសាខាសហាយិកា

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធពួកស្ត្រីដែលជាសំឡាញ់ របស់នាងវិសាខាមហាឧបាសិកា ។ ពួកស្ត្រីទាំងនោះ ជាអ្នកចូលចិត្តផឹកស្រា ។ ពួកស្វាមី របស់ស្ត្រីទាំងនោះ បានប្រគល់ទៅឲ្យនាងវិសាខាជួយអប់រំ ទូន្មានប្រៀនប្រដៅ ។ ថ្ងៃមួយ នាងវិសាខា បាននាំពួកស្ត្រីទាំងនោះទៅ គាល់ព្រះសាស្តា ដើម្បីស្តាប់ព្រះធម៌ទេសនា ។ ពួកនាងទាំងអស់នោះ នាំយកជបស្រាទៅផឹក ក្នុងវត្តផងដែរ តែមិនឲ្យនាងវិសាខាដឹងទេ លុះផឹកស្រាហើយក៏ស្រវឹង ដើរទ្រេតទ្រោតងោកងក់ ចង់ច្រៀង រាំលេង សើចសប្បាយ ក្អាកក្អាយ នៅទីចំពោះព្រះភក្ត្រ នៃព្រះសាស្តា ។*

*ព្រះសាស្តា ទ្រង់ព្រះពិចារណា ថា "រឿងនេះ ជាអ្វីទៅហ្ន៎?" ហើយ ទ្រង់ជ្រាបនូវហេតុនោះ ទើបទ្រង់ធ្វើនូវបាដិហារិយ៍ ឲ្យងងឹតឈឹង គួរឲ្យភ័យខ្លាចខ្លាំងណាស់ ។ ពួកស្ត្រីទាំងនោះ បានឃើញនូវបាដិហារិយ៍ របស់ព្រះអង្គហើយ ក៏កិតភ័យខ្លាច ចំពោះសេចក្តីស្លាប់*

យ៉ាងក្រៃលែង រហូតដល់ស្វាងស្រាទាំងអស់គ្នា ក្នុងគ្រានោះឯង ។

ព្រះសាស្តា ទ្រង់សំដែងធម្មីកថា ប្រកាសទោស នៃសេចក្តីប្រមាទ ហើយទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

**កោ នុ ហាសោ កិមានន្ទោ   និច្ចំ បជ្ជលិតេ សតិ**
**អន្ធការេន ឱនទ្ធា   បទីបំ ន គវេសថ ។**

កាលបើលោកសន្និវាស ត្រូវភ្លើង មានរាគៈ ជាដើម ឆេះត្រលោម ជានិច្ច, ម្តេចក៏សើចទៅបាន ម្តេចក៏ត្រេកត្រអាលទៅបាន, ពួកអ្នកទាំងឡាយ ត្រូវសេចក្តីងងឹត គឺអវិជ្ជារួបរឹតហើយ (ម្តេចឡើយ) ក៏មិនស្វែងរកប្រទីប គឺប្រាជ្ញា (ដែលសម្រាប់កំចាត់បង់នូវអវិជ្ជានោះចេញ) ។

## ១១៩- រឿង នាងសិរិមា

ព្រះបរមសាស្តា ទ្រង់ប្រារព្ធ នូវនាងសិរិមា ដែលជាប្អូនស្រីរបស់គ្រូពេទ្យជីវកកោមារភច្ច ។ នាងសិរិមា ជាស្រីផ្កាមាស មានរូបសម្បត្តិស្អាតណាស់ គួរជាទីស្រឡាញ់ពេញចិត្តនៃបុរសទាំងឡាយ។ បើបុរសណាមួយ ប្រាថ្នាចង់រួមសេចក្តីសុខ ក្នុងផ្លូវកាម ជាមួយនឹងនាង ក្នុង ១ យប់ ត្រូវតែឲ្យថ្លៃទៅនាង ១ ពាន់កហាបណៈទើបបាន ។

សម័យក្រោយមក នាងសិរិមា បានស្តាប់នូវព្រះធម៌ទេសនារបស់ព្រះសាស្តាហើយ ក៏បានសម្រេចសោតាបត្តិផល ហើយមានសទ្ធាជ្រះថ្លា ក្នុងព្រះពុទ្ធសាសនា យ៉ាងក្រៃលែង បានថ្វាយសង្ឃ-

ទាន ដល់ព្រះសង្ឃ ក្នុងមួយថ្ងៃៗ ៨ រូប ស្មើៗ ។ ភិក្ខុទាំងឡាយដែល បានទទួលសង្ឃភត្ត របស់នាង បានពោលសរសើរ នូវគុណសម្បត្តិ របស់នាង ថា: នាងសិរិមា មានរូបសម្បត្តិស្អាតណាស់ ហើយថែម ទាំងធ្វើចង្ហាន់ក៏ឆ្ងាញ់ៗ ទៀតផង ។

សម័យនោះ មានភិក្ខុមួយរូប ពុំទាន់បានឃើញរូបនាងផង គ្រាន់តែបានឮឈ្មោះប៉ុណ្ណោះ ក៏កើតសេចក្ដីស្នេហា លើនាង យ៉ាង ខ្លាំង អន្ទះសាររកខ្យល់ បន់ឲ្យតែមកដល់វេនរបស់ខ្លួន លុះដល់វេន ហើយ ក៏រីករាយ សប្បាយចិត្ត ឥតឧបមា បានរៀបចំរបស់របរ តាំង តែពីព្រឹកព្រលឹម ។

ជួនជាពេលនោះ នាងសិរិមា មានជម្ងឺជាទម្ងន់ តាំងតែពីថ្ងៃ ម្សិលមិញមកម្ល៉េះ, នាង បានប្រើឲ្យគេធ្វើភត្តាហារជំនួសខ្លួន ហើយ ឲ្យគេជួយគ្រាហ៍នាងទៅ ដើម្បីថ្វាយបង្គំព្រះភិក្ខុសង្ឃ ។ កាលបើភិក្ខុ រូបនោះ បានឃើញនូវរូបឆោមដ៏ស្អាតរបស់នាងហើយ ក៏មានចិត្តរឹត តែស្រឡាញ់ខ្លាំងឡើងៗ លើសដើមទៅទៀត ហើយនឹកគិតថា “ទោះ បីជានាងមានជម្ងឺ មិនបានស្អិតស្អាងកាយក៏ដោយ ក៏នៅតែមានរូប ស្រស់ប្រិមប្រិយ គួរឲ្យស្រឡាញ់ដល់ម្ល៉ឹងទៅហើយ នៅពេលដែល នាងមិនមានជម្ងឺ ហើយបានស្អិតស្អាតរាងកាយសព្វគ្រប់ មិនដឹងជា នាងស្អាតយ៉ាងណាទេហ្ន៎?” លុះដល់ត្រឡប់មកវត្តវិញ ក៏បិទគ្រប បាត្រចោល ហើយចូលទៅ ក្នុងបន្ទប់ សិងទទូរចីពរ កើតទុក្ខវិបត្តិ ស្នេហា លើនាងសិរិមានោះ យ៉ាងខ្លាំង ។ ទោះបីជាភិក្ខុសង្ឃ ជួយ

ពន្យល់យ៉ាងណាក៏ដោយ ក៏លោកមិនព្រមធ្វើ តាមទាល់តែសោះ នៅតែសិងកើតទុក្ខ ក្នុងរឿងស្នេហានោះឯង ។

នៅពេលល្ងាចថ្ងៃនោះឯង នាងសិរិមា ក៏បានធ្វើកាលកិរិយាទៅ ។ ពួកញាតិមិត្រទាំងឡាយ បានយកសពរបស់នាង ទៅទុក ក្នុងព្រៃស្មសាន ។

លុះដល់ថ្ងៃ ទី ៤ ព្រះសាស្តា ទ្រង់បានអនុញ្ញាត ឲ្យពួកភិក្ខុទាំងឡាយ និមន្តទៅពិចារណាសាកសពនាង ។ ភិក្ខុអ្នកវិបត្តិស្នេហាលើនាងសិរិមានោះ នៅតែសិងរីងរៃកើតទុក្ខ អត់ចង្ហាន់ រហូតដល់ ៤ ថ្ងៃ ។ កត្ត ដែលនៅក្នុងបាត្រ កាលពីថ្ងៃមុននោះ ក៏ផ្អូមជូរ ដុះផ្សិតពេញទាំងបាត្រ ។ ភិក្ខុរូបនោះ កាលបើដឹងថា "ព្រះសាស្តា ទ្រង់បានអនុញ្ញាតឲ្យភិក្ខុសង្ឃ និមន្តទៅពិចារណាសពនាងសិរិមា ក៏មានចិត្តត្រេកអរីករាយ ឥតឧបមា ប្រញាប់ប្រញាល់ ក្រោកឡើងពីគ្រែសិង ហើយយកបាយ ក្នុងបាត្រ ដែលផ្អូម ទៅចោល បានលាងបាត្រ ជូតឲ្យស្អាតហើយ និមន្តទៅជាមួយនឹងព្រះសាស្តា យ៉ាងរហ័សរហួន ។

ព្រះសាស្តា ស្តេចយាងទៅដល់សពនាងសិរិមាហើយ ទ្រង់សំដែងធម្មីកថា ហើយត្រាស់នូវព្រះគាថានេះ ថា ៖

**បស្ស ចិត្តកតំ ពិម្ពំ អរុកាយំ សមុស្សិតំ**
**អាតុរំ ពហុសង្កប្បំ យស្ស នត្ថិ ធុវំ ឋិតិ ។**

អត្តភាពណា មិនទៀងទាត់ឋិតថេរ, អ្នកចូរមើលនូវអត្តភាព (នោះ) ដែលកុសលាកុសលកម្ម ធ្វើឲ្យវិចិត្រហើយ ជាកាយដែល

ពោរពេញ ទៅដោយដំបៅ ដែលឆ្អឹង ៣០០ កំណាត់ ផ្គុំគ្នាហើយ ជាអត្តភាពក្ដៅក្រហាយ កើតទុក្ខច្រើន ជាទីរំពឹងត្រិះរិះ របស់ជនច្រើនគ្នា ។

♣ ❇ ♣

## ១២០- រឿង នាងឧត្តរាថេរី

ព្រះបរមសាស្ដា ទ្រង់ប្រារព្ធនាងឧត្តរាថេរី ជាអ្នកមានអាយុ ១២០ ឆ្នាំ ។ សម័យថ្ងៃមួយ នាងបានទៅបិណ្ឌបាតតាមផ្ទះ លុះបាននូវចង្ហាន់ល្មមគ្រប់គ្រាន់ហើយ ទើបបានត្រឡប់មកវិញ ពេលមកដល់ពាក់កណ្ដាលផ្លូវ ក៏ស្រាប់តែឃើញភិក្ខុមួយរូប កំពុងតែនិមន្តបិណ្ឌបាត ហើយប្រគេនបិណ្ឌបាត របស់ខ្លួន ដល់ភិក្ខុរូបនោះទាំងអស់ទៅ នាងធ្វើយ៉ាងនេះ អស់រយៈពេលបីថ្ងៃ ក្នុងថ្ងៃទី ៤ នាងបានទៅបិណ្ឌបាត ទៀត បានចួបនឹងព្រះពុទ្ធជាម្ចាស់ ត្រង់ផ្លូវចង្អៀតមួយ ហើយបានចៀសផ្លូវ ថយក្រោយ បន្តិច បានជាន់ជាយចីវរ របស់ខ្លួនឯង ដួលនៅទីនោះភ្លាម ។

ព្រះសាស្ដា ទ្រង់សំដែងនូវធម្មីកថា ត្រាស់នូវព្រះគាថានេះ (ឲ្យនាងបានសម្រេចព្រះសោតាបត្តិផល) ថា ៖

**បរិជិណ្ណមិទំ រូបំ        រោគនិទ្ធំ  បភង្គុណំ**
**ភិជ្ជតិ  បូតិ  សន្ទេហោ  មរណន្តំ  ហិ  ជីវិតំ ។**

រូបនេះ គ្រាំគ្រាអស់ហើយ ជាទីសំណាក់នៃរោគ ជារបស់ពុកផុយ រាងកាយ ជារបស់ស្អុយគួរខ្ពើម (នេះ) តែងបែកធ្លាយទៅវិញ

ព្រោះថា ជីវិត មានសេចក្តីស្លាប់ជាទីបំផុត ។

✻ ✻ ✻

## ១២១- រឿងអធិមានិកភិក្ខុ

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវភិក្ខុ ៥០០ រូប ដែលសម្គាល់ខ្លួនថា ជាអ្នកបានសម្រេចធម៌ជាន់ខ្ពស់ ។ ភិក្ខុទាំងនោះ បានរៀននូវកម្មដ្ឋាន ក្នុងសំណាក់ព្រះសាស្តា ហើយបានក្រាបថ្វាយបង្គំលាព្រះអង្គ ទៅបំពេញសមណធម៌ ក្នុងព្រៃស្ងាត់មួយ បានសម្រេចត្រឹមតែឈានប៉ុណ្ណោះ តែសម្គាល់ថា "ខ្លួនបានសម្រេច ដល់ព្រះអរហត្តផល" ទើបបាននាំគ្នាទៅក្រាបទូល ដល់ព្រះសាស្តា អំពីគុណធម៌ដែលខ្លួនបានហើយ, ក្នុងខណៈ ដែលភិក្ខុទាំងនោះ មកដល់ខ្លោងទ្វារវត្ត ព្រះបរមសាស្តា ទ្រង់ត្រាស់ឲ្យព្រះអានន្ទ ទៅប្រាប់ភិក្ខុទាំងនោះឲ្យនិមន្តទៅព្រៃខ្មោច ជាមុនសិន ។

ភិក្ខុទាំងនោះ ក៏បានទៅកាន់ព្រៃខ្មោច លុះបានឃើញនូវសាកសព ដែលនៅស្រស់ៗ ល្អនៅឡើយនោះ ក៏កើតមានរាគៈ ក្លាមមួយរំពេច ទើបដឹងខ្លួនថា ពុំទាន់បានសម្រេចធម៌ជាន់ខ្ពស់នៅឡើយទេ ។

គ្រានោះ ព្រះសាស្តា ទ្រង់បញ្ចេញព្រះរស្មីទៅ ដូចជាទ្រង់ប្រថាប់គង់នៅ ក្នុងទីចំពោះមុខ ហើយទ្រង់ត្រាស់ នូវព្រះគាថានេះ (ឲ្យភិក្ខុទាំងនោះ បានសម្រេចព្រះអរហត្តផល) ថា ៖

យានិមានិ អបត្ថានិ   អលាពូនេវ សារទេ
កាបោតកានិ អដ្ឋីនិ   តានិ ទិស្វាន កា រតិ ។

គាថាធម្មបទប្រែ

ឆ្អឹងទាំងឡាយណា មានសម្បុរដូចសត្វព្រាប ដែលគេចោល ហើយ ដូចផ្លែឃ្លោក ក្នុងសារទកាល, សេចក្តីត្រេកអរអ្វីហ្ន៎ (របស់អ្នកទាំងឡាយ នឹងកើតមាន) ព្រោះតែឃើញឆ្អឹងទាំងឡាយនោះ ។

♣ ❊ ♣

១២២- រឿង នាងរូបនន្ទាថេរី

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវនាងរូបនន្ទាថេរី ជាធីតារបស់នាងគោតមី ។ ព្រះនាងរូបនន្ទាថេរី បានឃើញព្រះញាតិវង្ស ចេញបួសជាច្រើននាក់ ទើបបានចេញទៅបួសក្នុងសំណាក់នៃនាងភិក្ខុនី ។ ចាប់តាំងពីពេលដែលនាងបួសមក នាងមិនចង់ទៅគាល់ព្រះសាស្តាសោះ ព្រោះខ្លាចព្រះពុទ្ធ សំដែងធម៌ទេសនាអំពីរូប របស់នាង តែនាងបានឮគេពោលសរសើរ នូវព្រះធម៌ទេសនា របស់ព្រះអង្គ ជារឿយៗ ។ ថ្ងៃមួយ នាងបានទៅ លបស្តាប់ព្រះធម៌ទេសនា ជាមួយនឹងនាងភិក្ខុនី ។

ព្រះសាស្តាទ្រង់ជ្រាបហើយ ទើបទ្រង់សំដែងព្រះធម៌ទេសនាអប់រំ ពន្យល់ ឲ្យនាងរូបនន្ទាថេរី ឃើញជាក់ច្បាស់ នូវសេចក្តីប្រែប្រួលទៅនៃនាម និងរូប ដោយលំដាប់ ។ នាងរូបនន្ទាថេរី បានស្តាប់ហើយ ក៏អស់សេចក្តីស្រឡាញ់ ក្នុងនាមរូប ហើយបានសម្រេច នូវសោតាបត្តិផល ។

ថ្ងៃក្រោយមក ព្រះសាស្តា ទ្រង់ត្រាស់ នូវព្រះគាថានេះ ( ឲ្យនាងបានសម្រេចព្រះអរហត្តផល ) ថា ៖

-១៩៨-

រឿង ព្រះនាងមល្លិកាទេវី

**អដ្ឋីនំ នគរំ កតំ  មំសលោហិតលេបនំ**
**យត្ថ ជរា ច មច្ចុ ច  មានោ មក្ខោ ច ឱហិតោ។**

*សេចក្តីគ្រាំគ្រា សេចក្តីស្លាប់ សេចក្តីប្រកាន់ខ្លួន និង សេចក្តីលុបគុណគេ ប្រជុំចុះហើយ ក្នុងសរីរៈណា, (សរីរៈនោះ) ដែលកុសលាកុសលកម្ម ធ្វើហើយ ឲ្យជានគរ របស់ឆ្អឹងទាំងឡាយ ជាគ្រឿងប្រឡាក់ ដោយសាច់ និង ឈាម ។*

១២៣- រឿង ព្រះនាងមល្លិកាទេវី

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវព្រះនាងមល្លិកាទេវី ដែលជាព្រះអគ្គមហេសីនៃព្រះបាទបសេនទិកោសល ។ ព្រះនាងទ្រង់ទិវង្គតមុន ព្រះរាជស្វាមី ។ ព្រះបាទបសេនទិកោសល ទ្រង់មានព្រះទ័យសោកស្តាយព្រះអគ្គមហេសី យ៉ាងខ្លាំង ។*

*សម័យថ្ងៃមួយ ព្រះសាស្តា ស្តេចយាងទៅបិណ្ឌបាត ប្រោសសត្វ ទ្រង់បានយាងទៅកាន់ព្រះបរមរាជវាំង ។ ព្រះបាទបសេនទិ-កោសល ទ្រង់ទតព្រះនេត្រឃើញព្រះសាស្តាហើយ ទើបទ្រង់ធ្វើនូវបដិសណ្ឋារកិច្ចចាំទទួល ទ្រង់មានព្រះបំណងនឹងក្រាបទូលអារាធនាព្រះបរមសាស្តា ឲ្យស្តេចយាងទៅ លើប្រាសាទ តែព្រះសាស្តា ទ្រង់មានព្រះបំណង ចង់ប្រថាប់គង់ ក្នុងរោងព្រះរាជរថវិញ ។ ព្រះបាទបសេនទិកោសល ទ្រង់បានទូលសួរនូវគតិរបស់ព្រះនាងមល្លិកាទេវី ដោយសេចក្តីក្រៀមក្រំបំផុត ។*

## គាថាធម្មបទប្រែ

ព្រះសាស្ដា ទ្រង់ត្រាស់ ថា "ព្រះនាង បានទៅកើត ក្នុងសុគតិភពហើយ" បន្ទាប់មក ទ្រង់ត្រាស់លួងលោម នូវព្រះបាទបសេនទិ-កោសល ដោយព្រះធម្មីកថា ថា "ជាការធម្មតាទេ សង្ខារទាំងឡាយ ដែលកើតហើយ នឹងរលត់ទៅវិញ" ហើយទ្រង់បង្ហាញ នូវរាជរថ របស់ព្រះអយ្យិកា របស់ព្រះជនក និង រាជរថ របស់ព្រះអង្គ ដែលចាស់ជរាគ្រាំគ្រា ទ្រុឌទ្រោម ជាងគ្នា ជាលំដាប់លំដោយ សម្រាប់ធ្វើជាឧទាហរណ៍ ក្នុងទីបញ្ចប់ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

**ជីរន្តិ វេ រាជរថា សុចិត្តា**
**អថោ សរីរម្បិ ជរំ ឧបេតិ**
**សតញ្ច ធម្មោ ន ជរំ ឧបេតិ**
**សន្តោ ហវេ សព្ភិ បវេទយន្តិ ។**

រាជរថទាំងឡាយ ដែលវិចិត្រល្អ រមែងគ្រាំគ្រាទៅ, សូម្បីសរីរៈ ក៏ដល់នូវសេចក្ដីគ្រាំគ្រា ដូចគ្នាដែរ, ចំណែកឯ ធម៌ របស់សប្បុរសទាំងឡាយ មិនដល់នូវសេចក្ដីគ្រាំគ្រា (ដូច្នោះ) បានឡើយ, សប្បុរសទាំងឡាយ តែងនិយាយ ឲ្យពួកសប្បុរសផងគ្នាដឹងបាន ។

❈ ❈ ❈

## ១២៤- រឿង ព្រះលោឡុទាយិត្ថេរ

ព្រះបរមសាស្ដា ទ្រង់ប្រារព្ធនូវព្រះលោឡុទាយិត្ថេរ ។ កាលបើមហាជន ធ្វើនូវកិច្ចការដែលជាមង្គល, ព្រះលោឡុទាយី បាន ពោលនូវអពមង្គល មានតិរោកុឌ្ឌសូត្រ ជាដើម កាលបើមហាជន ធ្វើ

រឿង ព្រះលោឡុទាយិត្ថេរ

កិច្ចការដែលជាអពមង្គល, លោក បែរជាពោលនូវរឿងមង្គល មាន រតនសូត្រ ជាដើម ។

ភិក្ខុទាំងឡាយ បានក្រាបទូលនូវរឿងនោះ ដល់ព្រះសាស្ដា ។ ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ ថា "ព្រះលោឡុទាយីនេះ មិនតែក្នុងជាតិនេះប៉ុណ្ណោះទេ សូម្បីក្នុងអតីតជាតិ ក៏ជាអ្នកធ្វើកិរិយាបែបនេះដែរ" ហើយ ទ្រង់សំដែងនូវអតីតនិទាន ថា "ក្នុងជាតិដែលលោឡុទាយីនេះ កើតជាព្រាហ្មណ៍ឈ្មោះអគ្គិទត្ត មានគោមួយនឹមសម្រាប់ភ្ជួរស្រែ តែគោមួយក្បាល បានស្លាប់ទៅ នៅសល់តែគោមួយក្បាលប៉ុណ្ណោះ, ក្រោយមក ព្រាហ្មណ៍នោះ បានចូលទៅគាល់ព្រះរាជា ក្រុងពារាណសី ដើម្បីទូលសុំគោមួយក្បាល ឲ្យគ្រប់មួយនឹម ដូចដើមវិញ ។ នៅពេលដែលគាត់ ចូលទៅ ទូលសុំគោនោះ គាត់ត្រឡប់ជាយកគោដែលនៅសល់មួយក្បាលនោះ ទៅថ្វាយ ដល់ព្រះរាជាទៅវិញ" នៅទីបញ្ចប់នៃអតីតនិទាន ព្រះអង្គទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

អប្បស្សុតាយំ បុរិសោ ពលិពទ្ទោវ ជីរតិ
មំសានិ តស្ស វឌ្ឍន្តិ បញ្ញា តស្ស ន វឌ្ឍតិ ។

បុរសអ្នកមិនមានការចេះដឹងនេះ រមែងចាស់ទៅឥតអំពើ ដូចគោបំរើចាស់ ដែលគេឈប់ប្រើការ យ៉ាងដូច្នោះ, សាច់ទាំងឡាយរបស់វា រមែងចំរើនឡើង តែបញ្ញា របស់វា មិនបានចំរើនឡើយ ។

♣ ❊ ♣

# គាថាធម្មបទប្រែ

## ១២៥- រឿងបឋមពោធិ

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធការទូលសួរ របស់ព្រះអានន្ទត្ថេរ ។ នៅពេលដែលព្រះអង្គទ្រង់ប្រថាប់គង់ នៅក្រោមដើមមហាពោធិព្រឹក្ស ទ្រង់ផ្ចាញ់នូវពួកមារ ព្រមទាំងសេនាមារ ឲ្យបរាជ័យ ចុះចាញ់ទាំងអស់ ក្នុងពេលដែលព្រះអាទិត្យអស្តង្គត, ក្នុងបឋមយាម ទ្រង់បានកំចាត់ នូវអន្ធការ គឺសេចក្តីងងឹត ដែលបិទបាំងនូវបុព្វេនិវាសានុស្សតិញ្ញាណ, ក្នុងមជ្ឈិមយាម ទ្រង់បានជម្រះនូវទិព្វចក្ខុញ្ញាណ ឲ្យបរិសុទ្ធ, ក្នុងបច្ឆិមយាម ទ្រង់ផ្សាយព្រះមហាករុណាគុណទៅ ក្នុងពួកសត្វនិករទាំងឡាយ ឲ្យព្រះញាណធ្លាក់ចុះទៅ ក្នុងបច្ចយាការ ទ្រង់ព្រះពិចារណា នូវបច្ចយាការនោះ ដោយអំណាចនៃអនុលោម និងបដិលោម, លុះពេលជិតភ្លឺ ព្រះអង្គក៏បានត្រាស់ដឹងនូវព្រះសម្មាសម្ពោធិញ្ញាណ ព្រមទាំងហេតុដ៏អស្ចារ្យជាច្រើនប្រការ ទ្រង់ត្រាស់នូវព្រះឧទានវាចា ដែលព្រះពុទ្ធជាច្រើនសែនអង្គ មិនដែលលះបង់ចោលឡើយ ហើយទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

អនេកជាតិសំសារំ សន្ធាវិស្សំ អនិព្វិសំ
គហការំ គវេសន្តោ ទុក្ខា ជាតិ បុនប្បុនំ ។
គហការក ទិដ្ឋោសិ បុន គេហំ ន កាហសិ
សព្វា តេ ផាសុកា ភគ្គា គហកូដំ វិសង្ខតំ
វិសង្ខារគតំ ចិត្តំ តណ្ហានំ ខយមជ្ឈគា ។

*កាលតថាគត មិនទាន់បានជួបប្រទះ (ពោធិញ្ញាណ) វង់តែ*

ស្វះស្វែងរកជាងធ្វើផ្ទះ គឺតណ្ហា អ្នកធ្វើផ្ទះ គឺអត្តភាព ក៏អន្ទោលទៅកាន់សង្សារវដ្ត មានជាតិជាច្រើន សេចក្តីកើត ជាទុក្ខរឿយៗ ។

នែជាងផ្ទះ អ្នកឯងធ្វើផ្ទះគឺអត្តភាព តថាគតឃើញហើយ អ្នកនឹងធ្វើផ្ទះ (របស់តថាគត) ទៀត មិនបានឡើយ, ឆ្អឹងជំនីរ គឺកិលេសរបស់អ្នកទាំងអស់ តថាគត កាច់បំបាក់អស់ហើយ ដំបូលផ្ទះគឺអវិជ្ជា តថាគត កំចាត់ចោលអស់ហើយ, ចិត្ត របស់តថាគត ដល់ព្រះនិព្វាន ដែលមានសង្ខារទៅប្រាសហើយ តថាគត បានដល់ធម៌ជាគ្រឿងក្ស័យតណ្ហាទាំងឡាយហើយ ។

❦ ❦ ❦

## ១២៦- រឿង មហាធនសេដ្ឋីបុត្រ

ព្រះបរមសាស្តា ទ្រង់ប្រារព្ធ នូវមហាធនសេដ្ឋីបុត្រ ជាអ្នកមានទ្រព្យសម្បត្តិច្រើន ដល់ទៅ ៨០ កោដិ ។ ភរិយា ក៏ជាធីតា របស់សេដ្ឋី មានទ្រព្យ ៨០ កោដិ ដូចគ្នាដែរ ។ ទាំងពីរនាក់ ភរិយាស្វាមី បានសិក្សាតែសិល្បៈច្រៀងរាំប៉ុណ្ណោះ ព្រោះឃើញថា ទ្រព្យសម្បត្តិរបស់ខ្លួនមានច្រើនហើយ ទោះជាមិនធ្វើការងារ ដេកស៊ីតែទ្រព្យទាំងនោះ រហូតមួយជីវិត ក៏មិនចេះអស់ដែរ ។ លុះមាតាបិតា ស្លាប់ចោលទៅ សេដ្ឋីបុត្រនេះ មិនចេះថែរក្សាទ្រព្យសម្បត្តិ ឲ្យបានគង់វង្សល្អ ជាអ្នកលេងល្បែង ស៊ីផឹក មានពួកម៉ាក សុទ្ធតែជាអ្នកប្រមឹកទាំងអស់ បានចំណាយទ្រព្យជាច្រើន ក្នុងការស៊ីផឹក ជារៀងរាល់ថ្ងៃ រហូតអស់ទ្រព្យសម្បត្តិរលីង គ្មានទៅសល់ ហើយបានលក់ផ្ទះ លក់ស្រែចំការ

ច្បារដំណាំអស់ថែមទៀត ជាអ្នកគ្មានផ្ទះសម្បែង ធ្លាក់ខ្លួនក្រលំបាក នាំកិរិយាទៅ នៅអាស្រ័យនឹងសំយាបផ្ទះ របស់អ្នកដទៃ ហើយដើរសុំទានគេ មកចិញ្ចឹមជីវិត ជារៀងរាល់ថ្ងៃ ។

សម័យថ្ងៃមួយ ព្រះសាស្តា ទ្រង់ទតព្រះនេត្រឃើញសេដ្ឋីបុត្រព្រមទាំងកិរិយា កំពុងតែឈរចាំនៅ ក្បែរមាត់ទ្វារសាលាឆាន់ ដើម្បីទទួលនូវអាហារ ដែលសេសសល់អំពីព្រះភិក្ខុសង្ឃ ទើបព្រះអង្គ ត្រាស់ប្រាប់ដល់ព្រះអានន្ទ ហើយទ្រង់សំដែង ថា "ម្នាលអានន្ទ បើសេដ្ឋីបុត្រ ព្រមទាំងកិរិយា ទាំងពីរនាក់នេះ មិនបានចាយវាយទ្រព្យរបស់ខ្លួន ឲ្យអស់ទៅ ក្នុងបឋមវ័យទេ មកនាំគ្នាប្រកបការងារទាំងពួង នឹងបានកើតជាសេដ្ឋីទីមួយ ក្នុងនគរនេះ, បើនឹងចេញទៅបួសវិញ ស្វាមីនឹងបានសម្រេចអរហត្តផល ចំណែកកិរិយា នឹងបានសម្រេចអនាគាមិផល, បើសេដ្ឋីបុត្រ ព្រមទាំងកិរិយា មិនបានចាយទ្រព្យសម្បត្តិ ឲ្យអស់ទៅ ក្នុងមជ្ឈិមវ័យទេ នាំគ្នាប្រកបនូវការងារទាំងពួង នឹងបានកើតជាសេដ្ឋីទីពីរ ក្នុងនគរនេះ, បើបានចេញទៅបួស ស្វាមីនឹងបានសម្រេចជាអនាគាមី ឯកិរិយា នឹងបានតាំងនៅក្នុងសកទាគាមិផល, បើមិនបានចាយវាយទ្រព្យសម្បត្តិ ឲ្យអស់ទៅ ក្នុងបច្ឆិមវ័យទេ បានប្រកបការងារទាំងពួង នឹងបានកើតជាសេដ្ឋីទីបី នៅក្នុងនគរនេះ, បើបានចេញទៅបួស ស្វាមី នឹងបានជាសកទាគាមី កិរិយា នឹងបានសម្រេចសោតាបត្តិផល, តែក្នុងពេលឥឡូវនេះ សេដ្ឋីបុត្រនេះ បានសាបសូន្យអស់ហើយ អំពីទ្រព្យសម្បត្តិ ដែលជារបស់

## រឿង មហាធនសេដ្ឋីបុត្រ

*អ្នកគ្រប់គ្រងផ្ទះ នឹងបានវិនាសសាបសូន្យអស់ហើយ អំពីសាមញ្ញ-ផល, លុះវិនាសសាបសូន្យ យ៉ាងនេះហើយ ទើបក្រហល់ក្រហាយ ដូចជាសត្វក្រៀល ក្នុងកក់បែកក្រហែង យ៉ាងនោះឯង" ក្នុងទីបញ្ចប់ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

អចរិត្វា ព្រហ្មចរិយំ អលទ្ធា យោព្វនេ ធនំ
ជិណ្ណកោញ្ចាវ ឈាយន្តិ ខីណមច្ឆេវ បល្លលេ ។
អចរិត្វា ព្រហ្មចរិយំ អលទ្ធា យោព្វនេ ធនំ
សេន្តិ ចាបាតិខីណាវ បុរាណានិ អនុត្ថុនំ ។

*បុគ្គលពាលទាំងឡាយ មិនប្រព្រឹត្តព្រហ្មចរិយធម៌ មិនបានទ្រព្យ ក្នុងកាលដែលខ្លួននៅជាកំលោះក្រមុំ រមែងសញ្ជប់សញ្ជឹង ដូចជាសត្វក្រៀលចាស់ សំកុកនៅ ក្នុងកក់ដែលអស់ត្រីហើយ យ៉ាងនោះឯង ។*

*បុគ្គលពាលទាំងឡាយ មិនប្រព្រឹត្តព្រហ្មចរិយធម៌ មិនបានទ្រព្យ ក្នុងកាលដែលខ្លួននៅជាកំលោះក្រមុំ រមែងដេកថ្ងូរ សោកស្តាយទ្រព្យចាស់ទាំងឡាយ ដូចជាព្រួញដែលគេបាញ់ផុត ចាកខ្សែបន្ទោះ ដូច្នោះឯង ។*

ចប់ជរាវគ្គ ទី ១១

**ចប់ គាថាធម្មបទប្រែ**

**ភាគ ទី ៥**

# គាថាធម្មបទប្រែ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ភាគ ទី ៦

អត្តវគ្គ ទី ១២

១២៧- រឿង ពោធិរាជកុមារ

*ព្រះបរមសាស្ដា ទ្រង់ប្រារព្ធនូវពោធិរាជកុមារ ។ ព្រះពោធិ-រាជកុមារអង្គនេះ ទ្រង់បានឲ្យជាងកសាងនូវប្រាសាទមួយខ្នង មានឈ្មោះថា កោកនទៈ មានទ្រង់ទ្រាយល្អវិចិត្រលើសគេទាំងអស់ ហើយទ្រង់មានព្រះតម្រិះ គិតនឹងសម្លាប់ជាងដែលធ្វើប្រាសាទនោះចោល ព្រោះទ្រង់ខ្លាចក្រែងជាងកសាងប្រាសាទបែបនេះ ថ្វាយព្រះរាជាអង្គដទៃទៀត ម្ល៉ោះហើយប្រាសាទរបស់ព្រះអង្គ នឹងមិនមានការអស្ចារ្យជាងគេឡើយ ។*

*កាលបើនាយជាងបានដឹងខ្លួនទាន់ហើយ គាត់ក៏បានប្រញាប់ប្រញាល់ធ្វើសត្វគ្រុឌហើយ ដាក់គ្រឿងយន្ត ខាងក្នុង ស្រេចហើយទើបនាំយកបុត្រភរិយា រត់គេចចេញទៅដោយគ្រឿងយន្តនោះ រហូតទៅដល់ហិមវន្តប្រទេស បានកសាងនគរមួយ ឈ្មោះថា កដ្ឋវាហន-នគរ ដោយខ្លួនឯងផ្ទាល់ ហើយបានសោយរាជ្យ ក្នុងនគរនោះ ។*

*ចំណែកពោធិរាជកុមារ លុះប្រាសាទសាងរួចស្រេចហើយ ទ្រង់ប្រារព្ធនឹងធ្វើបុណ្យឆ្លង ហើយបានអារាធនានិមន្តព្រះសាស្ដា ព្រមទាំងព្រះភិក្ខុសង្ឃដើម្បីទទួលភត្តាហារ ហើយទ្រង់ព្រះរាជបញ្ជា*

ឲ្យពួកបរិវារ យកកម្រាលសំពត់មកក្រាល តាំងតែពីមាត់ទ្វារឡើង ទៅ ទ្រង់អធិដ្ឋាន ក្នុងព្រះចិន្តាថា “បើអាត្មាអញ នឹងបានទូវព្រះរាជ-បុត្រ ឬ ព្រះរាជធីតា សូមឲ្យព្រះបរមសាស្តាស្តេចយាងឡើង លើកម្រាលនេះ” ។

ពេលព្រះសាស្តាយាងមកដល់ហើយ ព្រះអង្គមិនបានយាងលើកម្រាលនោះទេ ។ ព្រះរាជកុមារ បានក្រាបអារាធនានិមន្តព្រះសាស្តា ឲ្យស្តេចយាងឡើង លើកម្រាលនោះ អស់វារៈបីដង, តែព្រះសាស្តា មិនទ្រង់យាងឡើង លើកម្រាលនោះទេ ព្រោះទ្រង់ជ្រាបថា “ព្រះរាជកុមារ ប្រាកដជាមិនបានទូវព្រះរាជបុត្រាបុត្រីឡើយ” ហើយទ្រង់ត្រាស់សំដែង នូវបុព្វកម្មអំពីអតីតកាល របស់ព្រះរាជកុមារ ថា “ក្នុងកាលនោះ ព្រះរាជកុមារ និង អគ្គមហេសី ទ្រង់ស្តេចយាងទៅកំសាន្តសមុទ្រ ដោយសំពៅ ។ លុះសំពៅ បានទៅដល់កណ្តាលសមុទ្រ ក៏បានបែកធ្លាយលិច ក្នុងសមុទ្រនោះឯង ។ ព្រះរាជកុមារ និង ព្រះអគ្គមហេសី បានស្រវាចាប់បន្ទះក្តារបានមួយ ហើយបានប្រតោងយ៉ាងជាប់ ដើម្បីកុំឲ្យលង់ទឹកស្លាប់, ទឹករលក បានបក់បោកព្រះរាជកុមារ និង ព្រះអគ្គមហេសី ឲ្យរសាត់ ទៅដល់មាត់ច្រាំង ។ ពេលនោះ ព្រះរាជកុមារ និង ព្រះអគ្គមហេសី រកព្រះក្រយាស្ងោយពុំបាន ទ្រង់បានយកពងសត្វខ្លះ មេសត្វខ្លះ មកធ្វើជាព្រះក្រយា-ស្ងោយ... ដោយផលនៃកម្មនេះឯង បានជាព្រះរាជកុមារ និង ព្រះអគ្គមហេសី មិនមានព្រះរាជបុត្រាបុត្រី” ក្នុងទីបញ្ចប់ ព្រះអង្គ ទ្រង់

ត្រាស់នូវព្រះគាថានេះ ថា ៖

អត្តានញ្ចេ បិយំ ជញ្ញា   រក្ខេយ្យ នំ សុរក្ខិតំ
តិណ្ណមញ្ញតរំ  យាមំ     បដិជគ្គេយ្យ បណ្ឌិតោ។

បើបណ្ឌិតដឹងថា ខ្លួនជាទីស្រឡាញ់ហើយ គួររក្សាខ្លួននោះឲ្យបានល្អ គួរស្ងួនគ្រងខ្លួនទុក ក្នុងវ័យទាំង ៣ វ័យណាមួយ ។

## ១២៨- រឿង ព្រះឧបនន្ទសាក្យបុត្រ

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវព្រះឧបនន្ទសាក្យបុត្រ ជាអ្នកឆ្លាត ក្នុងការសំដែងព្រះធម៌ទេសនា ប្រៀនប្រដៅដល់ភិក្ខុទាំងឡាយឲ្យជាអ្នកមានសេចក្តីប្រាថ្នាតិច តែខ្លួនលោកជាអ្នកប្រាថ្នាច្រើន ។ ថ្ងៃមួយ មានភិក្ខុ ២ រូប បានសំពត់សាដក ២ កំណាត់, សំពត់មួយកំណាត់ ជាសំពត់កម្ពល, ភិក្ខុទាំង ២ រូបនោះ ចែកគ្នា មិនចេះដាច់ស្រេចសោះ លុះឃើញនូវព្រះឧបនន្ទនិមន្តមក ក៏បានអង្វរករ សុំឲ្យលោក ជួយធ្វើជាមេចំណែក ដើម្បីចែកសំពត់នោះ ។ ព្រះឧបនន្ទ ធ្វើជាព្រងើយកន្តើយ ។ ភិក្ខុទាំង ២ រូបនោះ ខំប្រឹងអង្វរករ ជាច្រើនលើកច្រើនគ្រា ។ ព្រះឧបនន្ទ បាននិយាយថា “បើលោកទាំងពីរ ធ្វើតាមពាក្យរបស់ខ្ញុំៗ នឹងជួយចែកសំពត់នេះឲ្យបាន” ។ ភិក្ខុទាំង ២ រូបក៏បានយល់ស្របតាម ។ ព្រះឧបនន្ទ បានចែកសំពត់ទាំងពីរកំណាត់ដល់ភិក្ខុទាំងពីររូបនោះ មួយអង្គមួយកំណាត់, ចំណែកសំពត់កម្ពលគឺលោកយក ដោយខ្លួនឯង ។  ភិក្ខុទាំង ២ រូប  បានក្រោធខឹង  យ៉ាង

ខ្វាំង ចំពោះព្រះឧបនន្ទ ហើយបានទៅ ក្រាបទូលរឿងនោះ ថ្វាយព្រះសាស្តាទ្រង់ជ្រាប ។

ព្រះសាស្តាចារ្យ ទ្រង់បានត្រាស់សំដែង ថា "ព្រះឧបនន្ទ មិនមែនធ្វើឲ្យអ្នកទាំង ២ រូប ក្តៅក្រហាយ ក្នុងជាតិនេះ តែប៉ុណ្ណោះទេ សូម្បីក្នុងអតីតជាតិ ក៏ធ្លាប់បានធ្វើឲ្យអ្នកទាំងពីរ ក្តៅក្រហាយ ដូចគ្នាដែរ" ហើយ ទ្រង់ត្រាស់នូវអតីតនិទាន ថា "ក្នុងអតីតជាតិ ព្រះឧបនន្ទសាក្យបុត្រនេះ កើតជាឆ្កែចចក, អ្នកទាំងពីរ កើតជាសត្វភេ បានត្រីមួយក្បាល ចែកគ្នា មិនចេះដាច់ស្រេច ទើបឲ្យឆ្កែចចកជួយចែកឲ្យ, ឆ្កែចចក បានចែកជាបីចំណែក គឺ កន្ទុយចែកឲ្យភេ ដែលរកស៊ីក្នុងទឹករាក់, ក្បាលចែកទៅឲ្យភេ ដែលរកស៊ីក្នុងទឹកជ្រៅ, ឯសាច់ត្រង់កណ្តាល ឆ្កែចចកបានយក ដោយខ្លួនឯងទៅ" ក្នុងទីបញ្ចប់ នៃអតីតនិទាន ព្រះអង្គត្រាស់នូវព្រះគាថានេះ ថា ៖

**អត្តានមេវ បឋមំ  បដិរូបេ និវេសយេ**
**អថញ្ញមនុសាសេយ្យ  ន កិលិស្សេយ្យ បណ្ឌិតោ ។**

បណ្ឌិត គួរតម្កល់ខ្លួនទុក ក្នុងគុណដ៏សមគួរ ជាមុនសិន ហើយ សឹមប្រៀនប្រដៅអ្នកដទៃ ជាខាងក្រោយ ធ្វើយ៉ាងនេះ នឹងមិនលំបាក ។

❋ ❋ ❋

## ១២៩- រឿង ព្រះបធានិកតិស្សត្ថេរ

ព្រះបរមសាស្តា ទ្រង់បានប្រារព្ធនូវព្រះបធានិកតិស្សត្ថេរ ជា

-២០៩-

# គាថាធម្មបទប្រែ

ប្រធាននៃភិក្ខុ ៥០០ រូប បានរៀនកម្មដ្ឋាន ក្នុងសំណាក់នៃព្រះសាស្ដា ហើយ នាំគ្នាទៅបំពេញសមណធម៌ ក្នុងព្រៃស្ងាត់មួយ ។ ព្រះថេរៈ បានឲ្យឱវាទ ដល់ភិក្ខុទាំងនោះ ថា "អ្នកទាំងឡាយ ចូរកុំប្រមាទ ធ្វើសមណធម៌ចុះ" ។ នៅក្នុងពេលរាត្រី ពួកភិក្ខុទាំងឡាយ បាននាំគ្នាបំពេញសមណធម៌ ។ តែព្រះថេរៈ មិនបានធ្វើសមាធិកម្មដ្ឋានទេ បែរជាលបចូលទៅសិង, ពេលដែលភិក្ខុទាំងឡាយសិង, លោកបានក្រោក ទៅដាស់ឲ្យភិក្ខុទាំងនោះ ឲ្យក្រោកឡើង ធ្វើសមាធិកម្មដ្ឋាន ។ ព្រះថេរៈ បានធ្វើយ៉ាងនេះជារៀងរាល់ថ្ងៃ ។ ភិក្ខុទាំងឡាយ អត់ទ្រាំពុំបាន សូម្បីតែមួយរូប ក៏មិនបានសម្រេចធម៌អ្វីដែរ ទើបបានប្រឹក្សាគ្នាថា "អាចារ្យ របស់ពួកយើង ចំជាមានព្យាយាមដល់ហើយ មិនចេះសិងបន្តិចសោះ តើធ្វើយ៉ាងណាទៅហ្ន៎ ពួកយើងនឹងជួយណែនាំ ឲ្យលោកធ្វើសមាធិកម្មដ្ឋាន បានដោយស្រួល" ស្រេចហើយ ទើបនាំគ្នាទៅលបមើល លុះឃើញជាក់ច្បាស់ថា ព្រះថេរៈ បានតែពីរឿងសិងប៉ុណ្ណោះ ហើយបាននិយាយទៅកាន់ព្រះថេរៈ ថា "ស្លាប់ហើយ មើលចុះ! អាចារ្យ របស់ពួកយើង បានតែប្រដៅអ្នកដទៃសោះ ខ្លួនឯងគិតតែពីសិង" លុះចេញវស្សាហើយ ក៏បាននាំគ្នាទៅ ក្រាបទូលរឿងនេះដល់ព្រះសាស្ដា ។

ព្រះសាស្ដា ទ្រង់សំដែងនូវអតីតនិទានថា "ក្នុងជាតិដែលព្រះបធានិកតិស្សត្ថេរនេះ កើតជាមាន់ រងាវមិនដឹងពេលវេលាសោះ ធ្វើឲ្យភិក្ខុទាំងឡាយ បានយល់ខុស ដូចជាពេលឥឡូវនេះដែរ ក្នុងជាតិ

ដែលភិក្ខុទាំងឡាយ កើតជាមាណព” យ៉ាងដូច្នេះ ក្នុងទីបញ្ចប់ នៃអតីតនិទាន ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

**អត្តានញ្ចេ តថា កយិរា  យថញ្ញមនុសាសតិ**
**សុទន្តោ វត ទមេថ  អត្តា ហិ កិរ ទុទ្ទមោ។**

បុគ្គល ប្រៀនប្រដៅអ្នកដទៃ យ៉ាងណា ត្រូវធ្វើខ្លួនឲ្យបាន យ៉ាងនោះដែរ, បុគ្គលដែលទូន្មានខ្លួនបានល្អហើយ ទើបគួរទូន្មានអ្នកដទៃបាន ព្រោះថា ខ្លួនហ្នឹងហើយ ដែលគេទូន្មានបានដោយកម្រ ។

♣ ❇ ♣

១៣០- រឿង មាតារបស់កុមារកស្សបៈ

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវមាតារបស់ព្រះកុមារកស្សបៈ ដែលជាធីតារបស់សេដ្ឋី ក្រុងរាជគ្រឹះ ។ មាតា របស់កុមារកស្សបៈ នាងមាននិស្ស័យ ក្នុងបព្វជ្ជា តាំងតែពីពេលដែលនាងនៅក្មេងខ្ចីមកម្ល៉េះ នាង បានសុំមាតាទៅបួស ជារឿយៗ តែមាតានាង មិនព្រមអនុញ្ញាត ឲ្យនាងទៅសោះ លុះនាងមានវ័យពេញក្រមុំហើយ ក៏មានស្វាមី តមក នាងមានផ្ទៃពោះ តែនាងមិនបានដឹងខ្លួនសោះ ហើយក៏បានសុំលាស្វាមីទៅបួស ។ ស្វាមី ក៏បានអនុញ្ញាត ឲ្យនាងទៅបួសតាមសេចក្តីប្រាថ្នា ។ នាងបានបួស ក្នុងសំណាក់នៃនាងភិក្ខុនី ដែលត្រូវជាបក្សពួក នៃភិក្ខុទេវទត្ត ។

ចំណេរកាលក្រោយមក នាងក៏មានផ្ទៃពោះរឹតតែធំឡើងៗ ។ ភិក្ខុ ទេវទត្ត បានដឹងរឿងនេះហើយ ក៏បានប្រាប់ឲ្យនាងលាចាកសិក្ខា

បទ ។ នាង បាននិយាយប្រាប់ថា "នាងខ្ញុំ មិនបានបួសឧទ្ទិសចំពោះព្រះទេវទត្ត ទេ គឺបួសឧទ្ទិស ចំពោះព្រះសម្មាសម្ពុទ្ធទេតើ" ។ ពួកភិក្ខុនី បាននាំនាង ទៅក្រាបទូលរឿងនេះ ថ្វាយដល់ព្រះសាស្តា ។

ព្រះសាស្តាចារ្យ ទ្រង់ត្រាស់បញ្ជា ឲ្យហៅត្រកូលធំៗ មាន អនាថបិណ្ឌិកសេដ្ឋី និង នាងវិសាខាមហាឧបាសិកា ជាដើម ឲ្យជួយពិចារណា ថា "តើនាងមានផ្ទៃពោះ តាំងតែពីត្រឹមណាមក?" ។ នាងវិសាខា បានមើលថ្ងៃខែទៅ ក៏បានដឹងជាក់ច្បាស់ ថា "នាង មានផ្ទៃពោះ តាំងតែពីនាងមិនទាន់បួសមកម៉្លេះ នាង មិនមានទោសកំហុសអ្វីទេ" ។

ក្រោយមក លុះដល់នាងមានផ្ទៃពោះគ្រប់ខែហើយ ក៏បានសម្រាលកូនប្រុសមួយ ។ ព្រះបាទបសេនទិកោសល ទ្រង់យកកុមារនោះ ទៅចិញ្ចឹមហើយ ទ្រង់បានប្រទាននាមថា កុមារកស្សបៈ ។ លុះកុមារនោះ ធំដឹងក្តី ហើយបានទៅបួសជាភិក្ខុ ក្នុងព្រះពុទ្ធសាសសនាបានស្តាប់នូវបញ្ហាព្យាករណ៍ អំពីសំណាក់នៃព្រះសាស្តា ហើយបានសម្រេចព្រះអរហត្តផល ។

ចំណែកនាងភិក្ខុនីដែលជាមាតា ចាប់តាំងពីមានកូនមក មួយថ្ងៃៗ មិនដែលបានធ្វើអ្វីសោះ គិតតែពីស្រែយំ នឹកដល់កូន ឥតមានពេលភ្លេច ។ ថ្ងៃមួយ នាងភិក្ខុនីបានជួបនឹងព្រះកុមារកស្សបៈ លោកកំពុងតែនិមន្ត ទ្រង់បាត្រ ដូចគ្នាដែរ ហើយបានរត់ស្ទុះទៅ ដើម្បីនឹងចាប់ តែបានដួលជាមុន ។ ព្រះកុមារកស្សបៈ បានគិត ថា "បើញោម

ស្រី នឹងបានស្តាប់នូវពាក្យដ៏ពីរោះ អំពីសំណាក់របស់ខ្លួនហើយ ក៏នឹងវិនាសសាបសូន្យ អំពីមគ្គផល" ហើយ ក៏បាននិយាយពាក្យមិនពីរោះស្តាប់ ទៅកាន់ញោមស្រី ។ នាងភិក្ខុនីដែលជាមាតា បានស្តាប់ឮពាក្យមិនគប្បីដូច្នេះហើយ ក៏អស់សេចក្តីអាឡោះអាល័យ ចំពោះកូនហើយ បានសម្រេចព្រះអរហត្តផល ក្នុងថ្ងៃនោះឯង ។ ភិក្ខុទាំងឡាយ បានសន្ទនាគ្នាអំពីរឿងនោះ ។

ព្រះសាស្តា ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

**អត្តា ហិ អត្តនោ នាថោ   កោ ហិ នាថោ បរោ សិយា**
**អត្តនា ហិ សុទន្តេន   នាថំ លភតិ ទុល្លភំ ។**

ខ្លួនជាទីពឹងរបស់ខ្លួន បុគ្គលដទៃជាទីពឹងដូចម្តេចបាន ព្រោះថា បុគ្គលអ្នកមានខ្លួនហ្វឹកហ្វឺនល្អហើយ រមែងបាននូវទីពឹង ដែលគេបានដោយកម្រ ។

១៣១- រឿង មហាកាលឧបាសក

ព្រះបរមសាស្តា ទ្រង់បានប្រារព្ធនូវមហាកាលឧបាសក ជាសោតាបន្ន ។ ក្នុងថ្ងៃឧបោសថ មហាកាលឧបាសក បានទៅរក្សាឧបោសថសីល ក្នុងវត្ត ហើយបានស្តាប់ធម៌រហូតដល់ភ្លឺ ។ ក្នុងវេលាព្រឹកថ្ងៃនោះ មានចោរម្នាក់ លួចទ្រព្យគេ ត្រូវម្ចាស់គេដេញតាមចាប់ប្រផុតៗ បានរត់មកតាមផ្លូវក្បែរវត្ត ហើយក្រឡេកឃើញមហាកាលឧបាសក កំពុងតែដើរចេញ មកលាងមុខ នៅខាងក្រៅ ក៏បានបោះ

ទ្រព្យដែលលួចបាននោះ នៅចំពីមុខមហាកាលឧបាសកនោះស្រេច ហើយ ក៏បានរត់គេចខ្លួនបាត់ទៅ ។

ចំណែកឯម្ចាស់ទ្រព្យ បានដេញ តាមពីក្រោយមក ហើយ ឃើញទ្រព្យរបស់ខ្លួន នៅក្នុងទីចំពោះមុខនៃមហាកាលឧបាសកនោះ ទើបបានចាប់វាយដំធ្វើបាប រហូតដល់ស្លាប់ ក្នុងថ្ងៃនោះឯង ដោយ គិតថា គាត់ជាចោរ បានលួចទ្រព្យនេះមក ។

ភិក្ខុទាំងឡាយ ចេញមកខាងក្រៅ បានឃើញនូវមហាកាល-ឧបាសកស្លាប់ ក៏បាននាំយករឿងនេះ ទៅក្រាបទូល ដល់ព្រះសាស្តា ទ្រង់ជ្រាប ។

ព្រះសាស្តា ទ្រង់ត្រាស់ នូវអតីតនិទាន ថា “ក្នុងអតីតកាល មហាកាលឧបាសកនេះ កើតជាមហាអាមាត្យ របស់ព្រះរាជា ក្រុង ពារាណសី ឃើញភរិយារបស់បុរសម្នាក់ ដែលមានរូបរាងស្រស់ល្អ ស្អាត គួរជាទីពេញចិត្ត ក៏កើតមានសេចក្តីស្នេហា លើរូបនាង យ៉ាង ខ្លាំង ហើយបានយកកែវមណីទៅលាក់ទុក ក្នុងរទេះ របស់បុរសនោះ បន្តិចក្រោយមក ក៏បានស្រែកឆោឡោឡើង ថា “ចោរបានលួចយក កែវមណី របស់ខ្ញុំបាត់ទៅហើយ” ធ្វើជាដើរទៅដើរមក ក៏ឃើញកែវ មណី ដែលខ្លួនបានប្រើឲ្យគេ យកទៅលាក់ទុក ក្នុងរទេះបុរសនោះ ហើយបានចោទគាត់ ថា “ជាចោរ លួចកែវមណី” ហើយបានចាប់ ចងបុរសជាស្វាមីនោះ យកទៅសម្លាប់ចោល ហើយបានយកប្រពន្ធ គាត់មកធ្វើជាប្រពន្ធរបស់ខ្លួនឯង ។ លុះមហាអមាត្យនោះ ស្លាប់ទៅ

បានទៅកើតក្នុងអវិចីមហានរក ដោយបាបកម្មនោះ មហាអមាត្យនេះ បានមកកើតជាមហាកាលឧបាសក ត្រូវគេវាយសម្លាប់ ក្នុងអត្តភាពនេះ” ក្នុងទីបញ្ចប់នៃអតីតនិទាន ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

**អត្តនា វ កតំ បាបំ អត្រជំ អត្តសម្ភវំ**
**អភិមត្ថតិ ទុម្មេធំ វជិរំ វម្ហយំ មណឹ ។**

បាប កើតអំពីខ្លួន មានខ្លួនជាដែនកើត ដែលខ្លួនបានធ្វើហើយ តែងញាំញីមនុស្សឥតប្រាជ្ញា ដូចពេជ្រសម្រាប់កាត់កែវមណី ដែលកើតអំពីថ្ម យ៉ាងដូច្នោះឯង ។

✻ ✻ ✻

១៣២- រឿងភិក្ខុទេវទត្ត

ព្រះបរមសាស្តា ទ្រង់ប្រារព្ធ នូវភិក្ខុទេវទត្ត ។ សម័យមួយ ភិក្ខុទាំងឡាយ បានប្រជុំគ្នា និយាយតិះដៀលភិក្ខុទេវទត្ត ថា “ជាភិក្ខុទ្រុស្តសីល ជាអ្នកមានធម៌លាមក, កាលបើសេចក្តីប្រាថ្នាចង់បានកើតឡើងពេញទំហ៊ឹងហើយ, ក៏បានទៅសេពគប់ រួមគំនិតគ្នា ជាមួយនឹងព្រះបាទអជាតសត្រូវកុមារ ញុំាងលាភសក្ការៈ ឲ្យកើតឡើង ជាច្រើន ហើយបានដឹកនាំព្រះបាទអជាតសត្រូវកុមារ ឲ្យទៅសម្លាប់ព្រះបាទពិម្ពិសារដែលជាព្រះវររាជបិតា របស់ព្រះអង្គផង ព្យាយាមដើម្បីនឹងធ្វើគុតព្រះសាស្តា ដោយប្រការផ្សេងៗ” ។

ព្រះបរមសាស្តា ទ្រង់ស្តេចយាងមក ក្នុងទីប្រជុំនោះ ទ្រង់បានសំដែងធម្មីកថា ត្រាស់នូវព្រះគាថានេះ ថា ៖

គាថាធម្មបទប្រែ

**យស្ស អច្ចន្តទុស្សីល្យំ មាលុវា សាលមិវោត្ថតំ**
**ករោតិ សោ តថត្តានំ យថា នំ ឥច្ឆតី ទិសោ ។**

*ភាពជាអ្នកទ្រុស្តសីលហួសហេតុ គ្របសង្កត់ នូវអត្តភាពរបស់បុគ្គលណា ដូចវល្លិ៍ដែលរួបរឹតដើមឈើ, បុគ្គលនោះ ឈ្មោះថាធ្វើខ្លួនឯងឲ្យវិនាស ដូចជាចោរអ្នកប្រាថ្នាធ្វើបុគ្គលនោះ ឲ្យវិនាសដូច្នោះឯង ។*

---

១៣៣- រឿង ការព្យាយាមបំបែកសង្ឃ

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវការព្យាយាម ដើម្បីនឹងបំបែកសង្ឃ របស់ភិក្ខុទេវទត្ត ។ សម័យថ្ងៃមួយ ភិក្ខុទេវទត្ត បានព្យាយាមដើម្បីនឹងបំបែកបំបាក់សង្ឃឲ្យបែកគ្នា លុះឃើញព្រះអានន្ទ ដ៏មានអាយុ កំពុងតែនិមន្តបិណ្ឌបាត ក៏បានប្រាប់សេចក្តីប្រាថ្នា របស់ខ្លួនដល់ព្រះអានន្ទ ។ ព្រះអានន្ទ ក៏បានយករឿងនោះ ទៅក្រាបទូលថ្វាយព្រះសាស្តាទ្រង់ជ្រាប ។*

*ព្រះសាស្តា ទ្រង់សំដែងធម្មីកថា ត្រាស់នូវព្រះគាថានេះ ថា ៖*

**សុករានិ អសាធូនិ អត្តនោ អហិតានិ ច**
**យំ វេ ហិតញ្ច សាធុញ្ច តំ វេ បរមទុក្ករំ ។**

*កម្មទាំងឡាយណា មិនល្អផង មិនមែនជាប្រយោជន៍ដល់ខ្លួនផង, កម្មទាំងឡាយនោះ ជាកម្មដែលមនុស្សអាក្រក់ធ្វើបានដោយងាយ, កម្មឯណា ជាប្រយោជន៍ ដល់ខ្លួនផង ល្អផង, កម្ម*

ទាំងនោះឯង មនុស្សអាក្រក់ធ្វើបាន ដោយលំបាកណាស់ ។

❋ ❋ ❋

១៣៤- រឿង ព្រះកាលត្ថេរ

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវព្រះកាលត្ថេរ ។ ព្រះថេរៈ មានស្ត្រីម្នាក់ស្រឡាញ់រាប់អាន ដូចជាម្តាយបង្កើត ។ ស្ត្រីនោះ បាន មកឧបត្ថម្ភ បម្រើព្រះថេរៈ ជារៀងរាល់ថ្ងៃ, ថ្ងៃមួយ គាត់បានឮគេ ពោលសរសើរអំពីព្រះពុទ្ធ និងព្រះធម៌ទេសនា របស់ព្រះអង្គ ក៏កើត ចិត្តជ្រះថ្លា ចង់ទៅស្តាប់នូវព្រះធម៌ទេសនានោះ ហើយបានសុំព្រះ កាលត្ថេរ ដើម្បីនឹងទៅគាល់ព្រះបរមសាស្តា ។

ព្រះកាលត្ថេរ បានហាមប្រាមមិនឲ្យនាងទៅអស់វារៈបីដង ។ តែនៅទីបំផុត នាងក៏បានទៅស្តាប់ព្រះធម៌ទេសនា របស់ព្រះសាស្តា ទាល់តែបាន ថែមទាំងមិនបានសុំអនុញ្ញាត អំពីព្រះកាលត្ថេរ ទៀត ផង ។ ក្នុងថ្ងៃនោះ ព្រះកាលត្ថេរ មិនឃើញនាងមកឧបដ្ឋាកខ្លួន ដូច សព្វដង ទើបដឹងថា នាងបានទៅ ស្តាប់ព្រះធម៌ទេសនា របស់ព្រះ សម្មាសម្ពុទ្ធ ហើយ ក៏ភ័យខ្លាចក្រែងនាងមិនមកឧបដ្ឋាកខ្លួន តទៅ ទៀត បែរជាទៅគោរពរាប់អាន ចំពោះតែព្រះសម្មាសម្ពុទ្ធប៉ុណ្ណោះ ហើយបានរត់ យ៉ាងប្រញាប់ប្រញាល់ ទៅក្រាបទូលព្រះសាស្តា ថា “បពិត្រព្រះអង្គដ៏ចំរើន ស្ត្រីម្នាក់នេះ ជាមនុស្សល្ងង់ខ្លៅ សូមព្រះអង្គ កុំសំដែងធម៌ដែលជ្រៅៗ ដល់នាងឡើយ សូមទ្រង់សំដែងតែទាន និង សីល បានហើយ” ។

## គាថាធម្មបទប្រែ

ព្រះសាស្ដា ទ្រង់ជ្រាបនូវអធ្យាស្រ័យ របស់ភិក្ខុនោះហើយ ទើបទ្រង់បានត្រាស់នូវព្រះគាថានេះ ថា ៖

**យោ សាសនំ អរហតំ   អរិយានំ ធម្មជីវិនំ**
**បដិក្កោសតិ ទុម្មេធោ   ទិដ្ឋឹ និស្សាយ បាបិកំ**
**ផលានិ កណ្ដកស្សេវ   អត្តឃញ្ញាយ ផល្លតិ ។**

បុគ្គលណា អប្បឥតប្រាជ្ញា អាស្រ័យនូវទិដ្ឋិ ដ៏លាមក ហាមឃាត់នូវសាសនា របស់ព្រះអរហន្តទាំងឡាយ ដ៏ប្រសើរ រស់នៅដោយធម៌, ការហាមឃាត់ របស់បុគ្គលនោះ រមែងចេញផល ដើម្បីសម្លាប់ខ្លួនឯង ដូចជាផ្លែឫស្សី សម្លាប់ដើមឫស្សី យ៉ាងនោះឯង ។

## ១៣៥- រឿង ចុឡ្លកាលឧបាសក

ព្រះបរមសាស្ដា ទ្រង់ប្រារព្ធនូវចុឡ្លកាលឧបាសក ។ រាត្រីថ្ងៃមួយ ឧបាសក បានទៅស្ដាប់ព្រះធម៌ទេសនា ក្នុងព្រះវិហារ លុះព្រឹកឡើង គាត់បានចេញពីព្រះវិហារ ដើរសំដៅទៅកាន់ផ្ទះ របស់ខ្លួន ។ ក្នុងពេលជាមួយគ្នានោះ មានចោរមួយក្រុម បានរត់មក តាមផ្លូវនោះ ហើយបានបោះទ្រព្យដែលលួចនោះ នៅចំពោះមុខឧបាសកនោះ រួចហើយ ក៏បានរត់គេចខ្លួនបាត់ទៅ ។ ម្ចាស់ទ្រព្យ បានដេញតាមមកយ៉ាងប្រកិតៗ លុះឃើញទ្រព្យ របស់ខ្លួន នៅចំពោះមុខឧបាសកនោះហើយ ក៏សម្គាល់ ថា “ឧបាសកនេះ ជាចោរ” ហើយបានចាប់វាយធ្វើបាប យ៉ាងខ្លាំង ។

## រឿង ព្រះអត្តទត្ថត្ថេរ

ពួកនាងទាសី ទៅដងទឹក បានឃើញយ៉ាងនេះហើយ ក៏ជួយប្រាប់ដល់ម្ចាស់ទ្រព្យថា “ឧបាសកនេះ មិនមែនជាចោរទេ គឺគាត់ជាមនុស្សល្អ” ហើយបានឲ្យដោះលែង ឲ្យបានរួចផុតពីសេចក្តីស្លាប់ ។ ភិក្ខុទាំងឡាយ បានដឹងរឿងនោះហើយ ក៏នាំគ្នាទៅក្រាបទូល ដល់ព្រះសាស្តា ។

ព្រះសាស្តាចារ្យទ្រង់សំដែងធម្មិកថា ត្រាស់ព្រះគាថានេះថា៖

អត្តនា វ កតំ បាបំ អត្តនា សង្កិលិស្សតិ
អត្តនា អកតំ បាបំ អត្តនា វ វិសុជ្ឈតិ
សុទ្ធិ អសុទ្ធិ បច្ចត្តំ នាញ្ញោ អញ្ញំ វិសោធយេ ។

អ្នកធ្វើបាបខ្លួនឯង នឹងសៅហ្មងខ្លួនឯង, អ្នកមិនធ្វើបាបខ្លួនឯង តែងបរិសុទ្ធស្អាតខ្លួនឯង, សេចក្តីបរិសុទ្ធិ និង មិនបរិសុទ្ធិ មានចំពោះខ្លួន, អ្នកដទៃ នឹងធ្វើអ្នកដទៃឲ្យបរិសុទ្ធ ពុំបានឡើយ ។

♣ ❇ ♣

## ១៣៦- រឿង ព្រះអត្តទត្ថត្ថេរ

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវព្រះអត្តទត្ថត្ថេរ ។ ក្នុងពេលដែលព្រះអង្គ ទ្រង់ដាក់ព្រះជន្មាយុសង្ខារ ដើម្បីចូលកាន់បរិនិព្វានក្នុងថ្ងៃពេញបូណ៌មី ខែវិសាខនោះ, ភិក្ខុទាំងឡាយ មានការតក់ស្លុតរន្ធត់ចិត្ត យ៉ាងក្រៃលែង មិនបានទៅណាឆ្ងាយ អំពីព្រះអង្គសោះ នាំគ្នាប្រឹក្សាជាពួក ជាក្រុម ។ ចំណែកព្រះអត្តទត្ថត្ថេរ មិនបានចូលទៅប្រឹក្សា ជាមួយភិក្ខុទាំងនោះទេ តែបានតាំងចិត្ត ថា “អាត្មាអញ នឹងខំ

-២១៩-

គាថាធម្មបទប្រែ

*បំពេញសមណធម៌ ដើម្បីឲ្យបានសម្រេចដល់អរហត្តផល ក្នុងពេលដែលព្រះសម្មាសម្ពុទ្ធ ទ្រង់មានព្រះជន្មនៅឡើយ” លុះគិតយ៉ាងនេះស្រេចហើយ ក៏បានចេញទៅ តែម្នាក់ឯង ខិតខំបំពេញសមណធម៌ ក្នុងព្រៃស្ងាត់មួយ ។*

*ភិក្ខុទាំងឡាយ បានចោទនូវព្រះថេរៈ ថា “មិនមានសេចក្ដីស្រឡាញ់ ចំពោះព្រះសាស្ដា” ហើយយករឿងនេះ ទៅក្រាបទូលដល់ព្រះសាស្ដា ។ ព្រះសាស្ដា ទ្រង់បានត្រាស់ឲ្យភិក្ខុទៅនិមន្តព្រះថេរៈ នោះមក ហើយទ្រង់ត្រាស់សួររឿងពិតនឹងព្រះថេរៈ ។ ព្រះថេរៈ បានក្រាបទូលរឿងពិត ថ្វាយដល់ព្រះសាស្ដាទ្រង់ជ្រាប ។*

*ព្រះសាស្ដា ទ្រង់បានត្រាស់ប្រទាន នូវសាធុការពរ ដើម្បីឲ្យភិក្ខុទាំងឡាយ យកធ្វើជាគំរូ ហើយទ្រង់ត្រាស់សរសើរ នូវធម្មានុធម្មបដិបត្តិ គឺការប្រព្រឹត្តិដ៏សមគួរដល់ធម៌ ហើយទ្រង់ត្រាស់ នូវព្រះគាថានេះ ថា ៖*

អត្តទត្ថំ បរត្ថេន ពហុនាបិ ន ហាបយេ
អត្តទត្ថមភិញ្ញាយ សទត្ថប្បសុតោ សិយា ។

*បុគ្គល កុំគប្បីធ្វើប្រយោជន៍ខ្លួនឲ្យវិនាស ព្រោះប្រយោជន៍របស់អ្នកដទៃសូម្បីច្រើន បើដឹងច្បាស់នូវប្រយោជន៍ខ្លួនហើយ គប្បីខ្វល់ខ្វាយ ក្នុងប្រយោជន៍របស់ខ្លួន ។*

**ចប់ អត្តវគ្គ ទី ១២**

# លោកវគ្គ ទី ១៣

## ១៣៧- រឿង ទហរភិក្ខុ

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវភិក្ខុកំលោះមួយរូប ដែលបាន ឈ្លោះជាមួយចៅ របស់នាងវិសាខា បានជេរគ្នាទៅវិញទៅមក ថា "ដាច់ក្បាល" ចៅរបស់នាងវិសាខា បានទៅប្រាប់ជីដូនរបស់ខ្លួន ។ នាងវិសាខា បាននិយាយពន្យល់ ដើម្បីកុំឲ្យមានការឈ្លោះប្រកែកគ្នាតទៅទៀត ។ ភិក្ខុកំលោះ បានចោទនាងវិសខា ថា "បានចូលដៃជើងជាមួយនឹងចៅរបស់ខ្លួនឯង" ។ គ្រានោះ ព្រះឧបជ្ឈាយ៍ របស់ភិក្ខុកំលោះនោះ បាននិមន្តមក ដើម្បីសួររឿងហេតុនោះ លុះបានជ្រាបរឿងពិតច្បាស់ហើយ ទើបបានទូន្មានប្រៀនប្រដៅ ដលភិក្ខុកំលោះនោះជាច្រើន, តែភិក្ខុកំលោះនោះ មិនព្រមស្តាប់បង្គាប់ ថែមទាំងបានចោទព្រះឧបជ្ឈាយ៍ថា "ចូលដៃជើងជាមួយនាងវិសាខា ទៀតផង ។

គ្រានោះ ព្រះសាស្តា ទ្រង់ទតព្រះនេត្រឃើញនូវឧបនិស្ស័យនៃសោតាបត្តិផល របស់ភិក្ខុកំលោះនោះ ហើយទ្រង់ស្តេចយាងទៅក្នុងទីនោះ ទ្រង់ត្រាស់សួរថា "នេះជារឿងអ្វី?" ។ នាងវិសាខា បានក្រាបទូលរឿងនោះ តាំងតែអំពីដើម រហូតដល់ចប់ ។

ព្រះសាស្តា ទ្រង់បានបណ្តោយទៅតាមភិក្ខុកំលោះនោះ ទ្រង់ត្រាស់ទៅកាន់នាងវិសាខា ថា "ម្នាលនាងវិសាខា ចុះហេតុដូចម្តេចបានជាចៅរបស់នាង ជេរសាវ័ក របស់តថាគត?" ។

ខណៈនោះឯង ភិក្ខុកំលោះនោះ បានស្ទុះក្រោកឡើងភ្លាម

*ហើយ លើកអញ្ចលីបង្គំទូល ថា "បពិត្រព្រះអង្គដ៏ចំរើន ព្រះអង្គមិនទ្រង់ជ្រាបនូវព្រះឧបជ្ឈាយ៍របស់ខ្ញុំព្រះករុណា និងនាងវិសាខាទេ" ។*

*ព្រះសាស្តា ទ្រង់សំដែងធម្មីកថា ត្រាស់នូវព្រះគាថានេះ ថា ៖*

**ហីនំ ធម្មំ ន សេវេយ្យ បមាទេន ន សំវសេ**
**មិច្ឆាទិដ្ឋឹ ន សេវេយ្យ ន សិយា លោកវឌ្ឍនោ ។**

*បុគ្គល មិនគួរសេពនូវធមិដ៏ថោកទាប មិនគួររស់នៅ ដោយសេចក្តីប្រមាទ មិនគួរសេពមិច្ឆាទិដ្ឋិ មិនគួរជាមនុស្ស (នៅ) ចង្អៀតលោកឡើយ ។*

❦ ❦ ❦

## ១៣៨- រឿង ព្រះបាទសុទ្ធោទនៈ

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវព្រះបាទសុទ្ធោទនៈ ក្នុងពេលដែលព្រះអង្គស្តេចយាងទៅកាន់ក្រុងកបិលព័ស្តុ លើកដំបូងបង្អស់ព្រមជាមួយភិក្ខុសង្ឃជាច្រើនរូប ទ្រង់គង់នៅ ក្នុងវត្តនិគ្រោធារាម ទ្រង់សំដែងព្រះធមិទេសនា ដើម្បីកំចាត់នូវមានះ របស់ពួកព្រះញាតិវង្សានុវង្ស ឲ្យអស់ពីខន្ធសន្តាន ហើយទ្រង់ញុាំងភ្លៀងបោក្ខរព័សិឲ្យធ្លាក់ចុះមក ក្នុងសមាគមនៃព្រះញាតិវង្ស ទ្រង់សំដែងនូវមហា-វេស្សន្តរជាតក ទ្រង់ញុាំងសាក្យវង្ស មានព្រះបាទសុទ្ធោទនមហារាជជាដើម ឲ្យធ្វើសន្ទនាការ លុះដល់ព្រឹកឡើង ទើបស្តេចយាងទៅបិណ្ឌបាតប្រោសសត្វ ព្រមទាំងភិក្ខុសង្ឃ ។*

*ចំណែក ព្រះបាទសុទ្ធោទនមហារាជ កាលព្រះសាស្តា ស្តេច*

យាងត្រឡប់មកពីបិណ្ឌបាតវិញហើយ ទ្រង់ត្រាស់បញ្ជាឲ្យពួកបរិវារធ្វើ នូវចង្ហាន់បិណ្ឌបាត និង ឲ្យក្រាលអាសនៈទុក ដើម្បីព្រះសាស្ដាព្រមទាំងភិក្ខុសង្ឃ តែព្រះអង្គពុំបានទូលអារាធនាព្រះសាស្ដាឡើយ ព្រោះទ្រង់ត្រិះរិះ ក្នុងព្រះទ័យថា “ព្រះរាជបុត្រ របស់អាត្មាអញ បើមិនបានមកកាន់ព្រះបរមរាជវាំងទេ តើនឹងយាងទៅណា” លុះទ្រង់ជ្រាបថា ព្រះសាស្ដា ស្ដេចយាងទៅបិណ្ឌបាត យ៉ាងដូច្នេះ ទើបទ្រង់ប្រញាប់ប្រញាល់ យាងចេញមក ក្រាបថ្វាយបង្គំហើយ ទ្រង់ត្រាស់សួរថា “ចុះហេតុដូចម្ដេច បានជាព្រះរាជបុត្រ ដើរបិណ្ឌបាត ធ្វើឲ្យបិតាខ្មាសគេ យ៉ាងនេះទៅវិញ?” ។

ព្រះសាស្ដា ទ្រង់ត្រាស់ថា “បពិត្រព្រះមហារាជ តថាគត ធ្វើយ៉ាងនេះ គឺធ្វើទៅតាមព្រះរាជវង្ស” ។ ព្រះបាទសុទ្ធោទនៈ ទ្រង់មានព្រះកន្ទា ហើយទ្រង់ត្រាស់សួរថា “នេះគឺជាវង្ស របស់ពួកយើងពិតមែនឬ?” ។

ព្រះសាស្ដា ទ្រង់ត្រាស់ថា “នេះមិនមែនជាវង្ស របស់ព្រះមហាបពិត្រទេ គឺជាវង្សរបស់តថាគត ព្រោះថា ព្រះពុទ្ធទាំងឡាយទ្រង់ស្ដេចយាងបិណ្ឌបាត យ៉ាងនេះដែរ” ហើយ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

ឧត្តិដ្ឋេ នប្បមជ្ជេយ្យ  ធម្មំ សុចរិតំ ចរេ
ធម្មចារី សុខំ សេតិ  អស្មឹ លោកេ បរម្ហិ ច ។
ធម្មំ ចរេ សុចរិតំ  ន តំ ទុច្ចរិតំ ចរេ

## គាថាធម្មបទប្រែ

**ធម្មចារី សុខំ សេតិ  អស្មឹ លោកេ បរម្ហិ ច ។**

បុគ្គល មិនគួរប្រមាទ ក្នុងដុំបាយ ដែលខ្លួនគប្បីក្រោកឡើងទទួល គប្បីប្រព្រឹត្តធម៌ ឲ្យសុចរិត, បុគ្គល ប្រព្រឹត្តធម៌ជាប្រក្រតី រមែងដេកជាសុខ ក្នុងលោកនេះផង ក្នុងលោកខាងមុខផង ។

បុគ្គល គួរប្រព្រឹត្តធម៌ ឲ្យសុចរិត មិនគួរប្រព្រឹត្តធម៌នោះ ឲ្យទុច្ចរិតឡើយ, បុគ្គលប្រព្រឹត្តធម៌ជាប្រក្រតី រមែងដេកជាសុខ ក្នុងលោកនេះផង ក្នុងលោកខាងមុខផង ។

♣ ❇ ♣

## ១៣៩-រឿងវិបស្សកភិក្ខុ

ព្រះបរមសាស្តា ទ្រង់ប្រារព្ធ នូវភិក្ខុអ្នកបំពេញនូវវិបស្សនា-កម្មដ្ឋាន ចំនួន ៥០០ រូប ។ ភិក្ខុទាំងនោះ បានរៀននូវកម្មដ្ឋាន ក្នុងសំណាក់ព្រះសាស្តា ហើយបានថ្វាយបង្គំសុំលាព្រះអង្គ ទៅបំពេញសមណធម៌ ក្នុងព្រៃស្ងាត់មួយ តែមិនអាចសម្រេចមគ្គផលបានឡើយ ទើបប្រឹក្សាគ្នា ថា "យើង នឹងទៅក្រាបទូលព្រះសាស្តា ដើម្បីសុំផ្លាស់កម្មដ្ឋានថ្មីទៀត" លុះមកដល់ពាក់កណ្តាលផ្លូវ ស្រាប់តែឃើញថ្ងៃបណ្តើរកូន ហើយបានចំរើនមរីចិកម្មដ្ឋាននោះ និមន្តមកតាមផ្លូវជារឿយៗ រហូតមកដល់វត្ត ។

ក្នុងពេលនោះ មានភ្លៀងបង្អុរធ្លាក់ជោកជាំ ពពុះទឹកបានប៉ោងឡើងហើយក៏បែកទៅវិញ ដោយអំណាចកម្លាំងនៃខ្សែទឹកហូរ ។ ពួកភិក្ខុទាំងនោះ បានឈរចាំមើល ហើយក៏បានកំណត់យកមកធ្វើ ជា

អារម្មណ៍ថា អត្តភាព របស់អាត្មាអញនេះ ក៏ដូចជាពពុះទឹកនេះដែរ មានការកើតឡើង ហើយបែកធ្លាយទៅវិញជាធម្មតា" ។

ព្រះសាស្ដា ទ្រង់គង់នៅក្នុងព្រះសុគន្ធកុដី ទ្រង់ទតព្រះនេត្រ ឃើញពួកភិក្ខុទាំងនោះ ទើបទ្រង់បញ្ចេញព្រះរស្មីទៅ ហាក់បីដូចជា ទ្រង់ប្រថាប់គង់នៅ ក្នុងទីចំពោះមុខនៃភិក្ខុទាំងឡាយនោះ ហើយទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

**យថា បុព្វុឡកំ បស្សេ　យថា បស្សេ មរីចិកំ**
**ឯវំ លោកំ អវេក្ខន្តំ　មច្ចុរាជា ន បស្សតិ ។**

បុគ្គល ឃើញនូវពពុះទឹក យ៉ាងណា ឃើញព្រពញថ្ងៃ យ៉ាងណា, ស្ដេចមច្ចុរាជ មិនឃើញអ្នកពិចារណាខន្ធលោកជាដើម យ៉ាងនោះទេ ។

✻ ✻ ✻

## ១៤០- រឿង អភ័យរាជកុមារ

ព្រះបរមសាស្ដា ទ្រង់ប្រារព្ធនូវព្រះអភ័យរាជកុមារ ដែលជាព្រះរាជបុត្រ របស់ព្រះបាទពិម្ពិសារ ។ ព្រះអភ័យរាជកុមារ ទ្រង់បានយាងទៅបង្ក្រាបនូវបច្ចន្តជនបទ ឲ្យមានសន្តិសុខហើយ ស្ដេចយាងត្រឡប់មកកាន់ព្រះបរមរាជវាំងវិញ ។ ព្រះវររាជបិតា ទ្រង់មានព្រះទ័យសោមនស្ស យ៉ាងក្រៃលែង ទ្រង់ព្រះរាជទានស្រីរបាំម្នាក់ ជាអ្នកពូកែខាងរាំ ហើយឲ្យឡើងគ្រងរាជ្យជំនួសព្រះអង្គ អស់រយៈពេល ៧ ថ្ងៃ ។ លុះដល់ថ្ងៃ ទី ៨ ព្រះអភ័យរាជកុមារ ទ្រង់យាងទៅកំពង់ទឹក

គាថាធម្មបទប្រែ

ទ្រង់ស្រង់ព្រះវារី ជម្រះនូវព្រះកាយពលហើយ ទើបទ្រង់យាងទៅកំសាន្ត ក្នុងព្រះឧទ្យាន ទ្រង់ទតព្រះនេត្រស្រីរបាំនោះ ។

គ្រានោះ ស្រីអ្នករបាំនោះ ក៏បានធ្វើមរណកាល ដោយខ្យល់ដែលកើតឡើង ក្នុងផ្ទៃមកផ្តាច់ជីវិត ។ ព្រះអភ័យរាជកុមារ ទ្រង់ព្រះវិយោគសោកសៅពន់ប្រមាណ ទ្រង់ពុំឃើញមានអ្នកណាម្នាក់ ដែលអាចជួយសម្រាលសេចក្តីទុក្ខសោកវិយោគ របស់ព្រះអង្គនេះបានឡើយ ទ្រង់ទតព្រះនេត្រឃើញតែព្រះសម្មាសម្ពុទ្ធ ប៉ុណ្ណោះ ដែលអាចជួយសម្រាលសេចក្តីទុក្ខនេះបាន ទើបស្តេចយាងទៅគាល់ព្រះសាស្តា ។ ព្រះសាស្តា ទ្រង់សំដែងធម្មិកថា ដើម្បីជួយរំលត់សេចក្តីទុក្ខសោកវិយោគ របស់ព្រះអភ័យរាជកុមារ ហើយទ្រង់បានត្រាស់នូវព្រះគាថានេះ ថា ៖

**ឯថ បស្សថិមំ លោកំ ចិត្តំ រាជរថូបមំ**
**យត្ថ ពាលា វិសីទន្តិ នត្ថិ សង្គោ វិជានតំ ។**

អ្នកទាំងឡាយ ចូរមកមើលនូវលោកនេះ ដែលត្រកាល ដូចជារាជរថ, បុគ្គលពាលទាំងឡាយ រមែងលិចលង់ ក្នុងលោកណា, សេចក្តីជាប់ជំពាក់ ក្នុងលោកនោះ រមែងមិនមាន ដល់ជនជាបណ្ឌិតទាំងឡាយ ដែលដឹងច្បាស់ទេ ។

♣ ❇ ♣

១៤១- រឿង ព្រះសម្មជ្ជនត្ថេរ

ព្រះបរមសាស្តា ទ្រង់បានប្រារព្ធ នូវព្រះសម្មជ្ជនត្ថេរ ជាអ្នក

## រឿង ព្រះសម្មជ្ជនត្ថេរ

ឧស្សាហ៍ខាងបោសសំអាតវត្តអារាម ជារៀងរាល់ថ្ងៃ មិនបានគិតថា វេលាព្រឹក ឬ ល្ងាចឡើយ ។

សម័យថ្ងៃមួយ ព្រះថេរៈ កំពុងតែបោសសំអាតវត្ត បាន ឃើញព្រះរេវតៈ គង់ក្នុងទីសម្រាកពេលថ្ងៃត្រង់ ក៏បានតិះដៀលព្រះ រេវតៈ ថា “ភិក្ខុរូបនេះ ខ្ជិលច្រអូសខ្លាំងណាស់ មិនគិតធ្វើនូវការងារ អ្វីសោះ ឆាន់ចង្ហាន់ដែលទាយកទាយិកាប្រគេន ដោយសទ្ធាហើយ មកគង់ធ្វើព្រងើយ មិនគិតជួយបោសសំអាតវត្តអារាមសោះ” ។

វេលាថ្ងៃមួយ ព្រះរេវតៈ បានឲ្យឱវាទថា “ការបោសសំអាត វត្តអារាមនេះ ជាការល្អប្រពៃមែនហើយ តែត្រូវចេះចែកពេលវេលា ខ្លះផង ដើម្បីពិចារណានូវអាការ ៣២ ប្រការ ហើយកំណត់ការរលត់ អស់ទៅ និង ការវិនាសទ្រុឌទ្រោមទៅ នៃអត្តភាពរាងកាយផង ទើប សមគួរ” ។

ព្រះសម្មជ្ជនត្ថេរ បានតាំងចិត្តស្តាប់នូវឱវាទ របស់ព្រះរេវតៈ ដោយសេចក្តីគោរព មិនយូរប៉ុន្មាន ក៏បានសម្រេចព្រះអរហត្តផល។

ទីវត្តអារាម កាលបើព្រះថេរៈ មិនបានបោសសំអាត រៀង រាល់ថ្ងៃ ដូចជាពេលមុនៗ ក៏មានតែសម្រាមស្លឹកឈើ ជ្រុះពាស ពេញ មិនជាទីរីករាយសប្បាយចិត្តអ្នកផងទាំងឡាយ ។

ភិក្ខុទាំងឡាយ ឃើញដូច្នោះហើយ ក៏បានសួរព្រះសម្មជ្ជន-ត្ថេរ ថា “ឥឡូវនេះ ហេតុដូចម្តេចបានជាព្រះគុណម្ចាស់មិនគិតបោស សំអាតវត្ត ដូចជាពេលមុនៗ ទៀត?” ។ ព្រះថេរៈ បានឆ្លើយតប ថា

## គាថាធម្មបទប្រែ

*“កាលពីពេលមុនៗ នោះ ខ្ញុំព្រះករុណា ជាអ្នកប្រមាទហើយ តែឥឡូវនេះ ខ្ញុំព្រះករុណា ឈប់ប្រមាទទៀតហើយ” ។*

*ភិក្ខុទាំងឡាយ បានចោទព្រះថេរៈ ថា “លោកពោលអួត នូវព្រះអរហត្តផល” ហើយក្រាបទូលរឿងនោះ ដល់ព្រះសាស្តា ។*

*ព្រះសាស្តា ទ្រង់ធានារ៉ាប់រង ថា “ព្រះថេរៈ បានពោលត្រឹមត្រូវហើយ” ហើយទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

**យោ ច បុព្វេ បមជ្ជិត្វា  បច្ឆា សោ នប្បមជ្ជតិ**
**សោមំ លោកំ បភាសេតិ  អព្ភា មុត្តោវ ចន្ទិមា ។**

*បុគ្គលណាមួយ កាលពីមុនប្រមាទហើយ លុះកាលជាខាងក្រោយ គេមិនប្រមាទវិញ, បុគ្គលនោះ ឈ្មោះថា ញុំាងឧទ្ទាទិលោកនេះ ឲ្យភ្លឺច្បាស់ ដូចជាព្រះចន្ទ រះផុតចាកពពក បំភ្លឺលោក ឲ្យត្រចះត្រចង់ ដូច្នោះ ។*

## ១៤២- រឿង ព្រះអង្គុលិមាលត្ថេរ

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវព្រះអង្គុលិមាលត្ថេរ ។ ក្នុងពេលដែលលោកនៅជាគ្រហស្ថ ជាចោរមានឈ្មោះសំឡេង អាក្រក់ល្បីខ្ចរខ្ចាយគ្រប់ទិសទីកន្លែងទាំងអស់ មនុស្ស ៤០ នាក់ មិនអាចតស៊ូជាមួយបាន ដើរកាប់សម្លាប់មនុស្ស អស់ជាច្រើន ហើយកាត់យកម្រាមដៃ ដោតធ្វើជាកម្រងផ្កា ។*

*ព្រះសាស្តា ស្តេចយាងទៅបង្ក្រាប នូវចោរអង្គុលិមាលនោះ*

## រឿង ព្រះអង្គុលិមាលត្ថេរ

ដោយព្រះបារមី ។ អង្គុលិមាល បានលះបង់នូវបាបកម្មនោះចោល ហើយសុំព្រះសាស្តាបួសជាភិក្ខុ ក្នុងព្រះពុទ្ធសាសនា ជាអ្នកមិនប្រមាទហើយ សម្រេចព្រះអរហត្តផល លុះមានវ័យចាស់ជរាហើយ ក៏បរិនិព្វាន ។

ភិក្ខុទាំងឡាយ មិនដឹងរឿងច្បាស់ ក៏ប្រឹក្សាគ្នាថា "តើអង្គុលិមាល ទៅកើត ក្នុងទីណាហ្ន៎?" ។ ព្រះសាស្តា ស្តេចយាងមក ក្នុងទីប្រជុំនោះ ហើយទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ភិក្ខុអង្គុលិមាល បរិនិព្វានហើយ" ។

ភិក្ខុទាំងនោះ មានសេចក្តីសង្ស័យ ហើយក្រាបទូលសួរព្រះអង្គ បន្តទៀត ថា "បពិត្រព្រះអង្គដ៏ចំរើន ពេលដែលភិក្ខុអង្គុលិមាល មិនទាន់បួសនោះ លោកបានសម្លាប់មនុស្ស អស់ជាច្រើនណាស់ តើបរិនិព្វាន យ៉ាងដូចម្តេចកើត" ។

ព្រះសាស្តាទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ កាលពីពេលមុននោះ ភិក្ខុអង្គុលិមាល មិនបានសេពគប់ជាមួយនឹងកល្យាណមិត្រ បានជាធ្វើបាបកម្ម ខ្លាំងក្លា កាចសាហាវជាទីបំផុត តែដល់ក្រោយមក អង្គុលិមាល បានសេពគប់ជាមួយកល្យាណមិត្រ ឈប់ប្រព្រឹត្តធ្វើនូវបាបកម្មទៀតហើយៗ ជាអ្នកមិនប្រមាទ លះបង់អំពើអាក្រក់ចោលទាំងអស់ ដោយការធ្វើតែអំពើល្អ" ដូច្នេះហើយ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

យស្ស បាបំ កតំ កម្មំ  កុសលេន បហីយតិ

គាថាធម្មបទប្រែ

**សោមំ លោកំ បភាសេតិ អព្ភា មុត្តោវ ចន្ទិមា ។**

*បុគ្គលណាមួយ ធ្វើអំពើបាបហើយ បិទខ្ទប់អំពើបាបនោះដោយកុសល ពោលគឺអរហត្តមគ្គបាន, បុគ្គលនោះ ឈ្មោះថាញ៉ាំងខន្ធាទិលោកនេះ ឲ្យភ្លឺច្បាស់ ដូចជាព្រះចន្ទ រះផុតចាកពពក បំភ្លឺលោក ឲ្យត្រចះត្រចង់ ដូច្នោះ ។*

♣ ♣ ♣

១៤៣- រឿង ធីតាជាងតម្បាញ

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវធីតា របស់ជាងតម្បាញ ជាអ្នកស្រុកអាឡវី ។ នាងបានស្តាប់នូវមរណសតិ អំពីសំណាក់ព្រះសាស្តា ហើយព្យាយាមចំរើនមរណសតិនោះ អស់រយៈពេល ៣ ឆ្នាំ ។*

*ព្រះសាស្តា ទ្រង់ទតព្រះនេត្រឃើញឧបនិស្ស័យ របស់នាងហើយ ស្តេចយាងទៅ ក្នុងស្រុកនោះ មួយអន្លើដោយព្រះភិក្ខុសង្ឃ ៥០០ អង្គ ។ ពួកទាយក ទាយិកា បាននាំគ្នា ធ្វើនូវបដិសណ្ឋារកិច្ចថ្វាយព្រះអង្គហើយ ប្រជុំគ្នា ស្តាប់ព្រះធម៌ទេសនា ។*

*គ្រានោះ ព្រះសាស្តា ត្រាស់សួរប្រស្នាធម៌ ជាមួយនឹងនាងដូចតទៅនេះ ៖*

*១- នែនាងកុមារិកា តើនាងមកពីទីណា? ។ នាង ក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំម្ចាស់មិនដឹងទេ ។*

*២- នែនាងកុមារិកា តើនាងទៅទីណា? ។ នាង ក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំម្ចាស់មិនដឹងទេ ។*

រឿង ធីតាជាងតម្បាញ

៣- នៃនាងកុមារិកា តើនាងមិនដឹងទេឬ? ។ នាង ក្រាបទូល ថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំម្ចាស់ដឹង ។

៤- នៃនាងកុមារិកា តើនាងដឹងមែនឬ? ។ នាង ក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំម្ចាស់មិនដឹងទេ ។

ក្នុងគ្រានោះ ពួកមហាជន ដែលមិនបានដឹងជាក់ច្បាស់ នូវបញ្ហាធម៌នោះ ក៏នាំគ្នាតិះដៀលនាង ថា "នាងកុមារិកានេះ បានឆ្លើយសំណួរនឹងព្រះសាស្តា ដោយពាក្យឆ្លើយតបធ្វើដូចជាលេង១" ។

ព្រះសាស្តា ទ្រង់ជ្រាបដូច្នោះហើយ ទើបទ្រង់ត្រាស់ឲ្យនាងកុមារិកានោះ អធិប្បាយឲ្យបានច្បាស់លាស់ ដើម្បីកុំឲ្យមហាជនយល់ខុស ដូចតទៅនេះ គឺ ៖

១- មិនដឹងថា ខ្ញុំម្ចាស់ មកអំពីទីណា បានជាមកកើត ក្នុងមនុស្សលោកយើងនេះ,

២- មិនដឹងថា ខ្ញុំម្ចាស់ ស្លាប់អំពីមនុស្សលោកនេះហើយ មិនដឹងជានឹងទៅកើត ក្នុងទីណាទេ,

៣- ដឹងថា ខ្ញុំម្ចាស់ ប្រាកដជានឹងស្លាប់ពុំខានឡើយ,

៤- មិនដឹងថា ខ្ញុំម្ចាស់ នឹងស្លាប់ ក្នុងពេលណា ។

ក្នុងទីបញ្ចប់នៃបញ្ហាធម៌នីមួយៗ ព្រះសាស្តា ទ្រង់បានប្រទាននូវសាធុការ ថា សាធុៗ ហើយត្រាស់ នូវព្រះគាថានេះ (នាងបានសម្រេចសោតាបត្តិផល) ថា ៖

អន្ធភូតោ អយំ លោកោ តនុកេត្ថ វិបស្សតិ

គាថាធម្មបទប្រែ

**សកុណោ ជាលមុត្តោវ អប្បោ សគ្គាយ គច្ឆតិ ។**

*លោកិយមហាជននេះ ជាមនុស្សងងឹត បណ្តាជនទាំងនេះ ជន តិចគ្នាណាស់ ដែលឃើញច្បាស់ (នូវខន្ធាទិលោកនេះ ដោយ អនិច្ចលក្ខណៈជាដើម) ជន តិចគ្នាណាស់ ដែលទៅកាន់ឋានសួគ៌ ដូចជាសត្វស្ទាប ដែលជាប់សំណាញ់របស់ព្រានហើយ តិចតួច ណាស់ ដែលបានរួចផុត អំពីសំណាញ់ ដូច្នោះឯង ។*

❋ ♣ ❋

## ១៤៤- រឿងភិក្ខុ ៣០ រូប

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវភិក្ខុ ៣០ រូប ដែលបាននាំគ្នា មក ថ្វាយបង្គំព្រះអង្គ ។ ព្រះអានន្ទត្ថេរ បានឃើញភិក្ខុទាំងនោះមក ថ្វាយបង្គំ ក្នុងពេលបំរុងនឹងធ្វើកិច្ចវត្ត ចំពោះព្រះសាស្តា ហើយបាន មកឈប់នៅ ជិតមាត់ទ្វារ ដោយគិត ថា "បើព្រះសាស្តា ទ្រង់ធ្វើនូវ បដិសណ្ឋារកិច្ច ជាមួយនឹងភិក្ខុទាំងអស់នេះ តើអាត្មាអញ នឹងធ្វើវត្ត ប្រតិបត្តិ យ៉ាងណាបានទៅហ្ន៎? ណ្ហើយចុះ ចាំឲ្យព្រះអង្គធ្វើ នូវ បដិសណ្ឋារកិច្ច ជាមួយភិក្ខុទាំងឡាយនោះសិនចុះ ចាំចូលទៅធ្វើវត្ត ប្រតិបត្តិព្រះអង្គ នៅពេលជាខាងក្រោយ" ។*

*ព្រះសាស្តា លុះទ្រង់ធ្វើបដិសណ្ឋារកិច្ច ជាមួយនឹងភិក្ខុទាំង ឡាយនោះហើយ ទើបទ្រង់សំដែងនូវសារាណីយធម៌ ដល់ភិក្ខុទាំង អស់នោះ ។ ភិក្ខុទាំងឡាយនោះ លុះបានស្តាប់ នូវសារាណីយធម៌ នោះហើយ ក៏បានសម្រេចអរហត្តផល ហើយហោះទៅ តាមអាកាស*

គ្រប់ៗ រូប ។

ចំណែកព្រះអានន្ទ ឈរនៅចាំជិតមាត់ទ្វារ គិតថា យូរពេក ក៏ចូលទៅខាងក្នុង លុះចូលទៅដល់ហើយ រកមើលភិក្ខុទាំងនោះមិនឃើញ ទើបក្រាបទូលសួរព្រះសាស្តា ថា “បពិត្រព្រះអង្គដ៏ចំរើន តើភិក្ខុ ៣០ រូប ដែលចូលមក ខាងក្នុងអម្បាញ់មិញនេះ បានចេញទៅណាអស់ហើយ?” ។

ព្រះសាស្តា ទ្រង់ត្រាស់ ថា “ម្នាលអានន្ទ ភិក្ខុ ៣០ រូបនោះបានចេញទៅអស់ហើយ” ។ អានន្ទ លោកនិមន្តចេញទៅតាមផ្លូវណា? ។ ព្រះសាស្តា ទៅតាមផ្លូវអាកាស ។ អានន្ទ តើភិក្ខុទាំងនោះជាព្រះអរហន្តមែនឬ? ។ ព្រះសាស្តា មែនហើយ ភិក្ខុទាំងនោះបានស្តាប់នូវធម៌ របស់តថាគតហើយ ក៏បានសម្រេចអរហត្តផលគ្រប់ៗ រូប ។

ក្នុងពេលនោះ មានសត្វហង្សជាច្រើន បានហើរមក ពួដ៏អាកាស ។ ព្រះសាស្តាទ្រង់ត្រាស់ទៅកាន់ព្រះអានន្ទថា “ម្នាលអានន្ទ ឥទ្ធិបាទ ៤ ដែលបុគ្គលណា បានចំរើនហើយ បុគ្គលនោះ នឹងហោះទៅតាមអាកាស ដូចសត្វហង្ស យ៉ាងនោះឯង” ហើយទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

**ហំសា អាទិច្ចបថេ យន្តិ អាកាសេ យន្តិ ឥទ្ធិយា**
**នីយន្តិ ធីរា លោកម្ហា ជេត្វា មារំ សវាហនំ ។**

ពួកសត្វហង្ស តែងហើរទៅ ក្នុងគន្លងផ្លូវព្រះអាទិត្យ, ពួកអ្នក

មានឫទ្ធិ តែងហោះទៅ ក្នុងអាកាស ដោយឫទ្ធិ, ពួកអ្នកប្រាជ្ញ ផ្ចាញ់កិលេសមារ ព្រមទាំងវាហនៈ ពោលគឺតណ្ហាបានហើយ រមែងរលាស់ខ្លួនចេញ ចាករលោកបាន ។

## ១៤៥- រឿង នាងចិញ្ចមាណវិកា

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវនាងចិញ្ចមាណវិកា ។ នាងចិញ្ចមាណវិកានេះ បានចូលដៃជើង រួមគំនិតជាមួយគ្នានឹងពួកតិរ្ថិយទាំងឡាយ ដែលមានសេចក្តីប្រណែន នឹងព្រះសាស្តា នាងបានធ្វើដូចជាស្រីដែលមានផ្ទៃពោះ គឺបានយកឈើមករុំធ្វើជាកូន ចងជាប់នឹងពោះ ហើយយកសំពត់មករុំព័ទ្ធពីខាងក្រៅ យកឈើដំដៃជើងឲ្យហើមប៉ោង ធ្វើឲ្យដូចជាស្រីដែលជិតនឹងសម្រាលកូន ហើយបានចូលទៅចោទ មួលបង្កាច់ព្រះសាស្តា ដែលព្រះអង្គកំពុងតែសំដែងធម៌ទេសនា ក្នុងទីប្រជុំជនជាច្រើន ថា "នែមហាសមណៈ ព្រះអង្គទ្រង់ជ្រាបបានតែខាងអភិរម្យសប្បាយ រួមស្នេហាជាមួយនឹងនាងខ្ញុំប៉ុណ្ណោះ តែមិនជ្រាបនូវការថែរក្សាគភ៌ ដល់នាងខ្ញុំសោះ បានតែទេសនា ប្រដៅអ្នកដទៃប៉ុណ្ណោះឯង" ។

ព្រះសាស្តា ទ្រង់ត្រាស់ ថា "នែប្អូនស្រី មានតែយើងទាំងពីរនាក់ទេ ដែលអាចដឹងរឿងដែលពិត ឬ មិនពិតបាន" ។ នាងចិញ្ចមាណវិកា ឆ្លើយតបថា "នែមហាសមណៈ រឿងនោះ គឺយ៉ាងដូច្នោះឯង" ។

-២៣៤-

## រឿងនាងចិញ្ចមាណវិកា

គ្រានោះឯង សេចក្ដីក្ដៅក្រហាយ ក៏បានកើតឡើង ដល់ព្រះឥន្ទ្រាធិរាជៗ ទ្រង់ជ្រាបច្បាស់ហើយ ទ្រង់យាងចុះមក ប្រែក្រឡាខ្លួនធ្វើជាកណ្ដុរ ចូលទៅកាត់ខ្សែ ដែលនាងចងរុំព័ទ្ធពោះនោះ ឲ្យដាច់ធ្លាក់ចុះក្រោម ធ្វើខ្យល់ឲ្យបក់សំពត់ រសាត់ប៉ើងឡើងទៅលើ ។

ពួកមហាជន បានដឹងនូវរឿងពិត ដូច្នេះហើយ ក៏ក្រោធខឹងនឹងនាងចិញ្ចមាណវិកា យ៉ាងខ្លាំង ហើយចូលទៅចាប់នាង វាយធ្វើបាប ជេរស្ដី ដោយប្រការផ្សេងៗ ហើយបានបណ្ដេញ ឲ្យនាងចេញអំពីទីនោះទៅ ។

ក្នុងពេលដែលនាងចិញ្ចមាណវិកា បានចេញផុត អំពីទីប្រជុំនោះភ្លាម, ប្រឹថពី បានស្រូបយកនាងទៅដាក់ក្នុងអវិចីនរក ឥតបង្អង់ឡើយ ។ ភិក្ខុទាំងឡាយបានសន្ទនាគ្នាអំពីរឿងនាងចិញ្ចមាណវិកា។

ព្រះសាស្ដាទ្រង់យាងមកក្នុងទីប្រជុំនោះ ត្រាស់គាថានេះថា៖

**ឯកំ ធម្មំ អតីតស្ស មុសាវាទិស្ស ជន្តុនោ**
**វិតិណ្ណបរលោកស្ស នត្ថិ បាបំ អការិយំ ។**

បុគ្គល ប្រព្រឹត្តកន្លង (ពាក្យសច្ចៈ) ដែលជាធម៌ឯក និយាយតែពាក្យកុហក មានបរលោក លះចោលហើយ ឈ្មោះថា មិនធ្វើអំពើបាប មិនមែនឡើយ ។

❋ ♣ ❋

## ១៤៦- រឿងអសទិសទាន

ព្រះបរមសាស្ដា ទ្រង់ប្រារព្ធ នូវអសទិសទាន របស់ព្រះបាទ

បសេនទិកោសល ។ គ្រាដំបូង ព្រះបាទបសេនទិកោសល ទ្រង់បាន ថ្វាយទាន ប្រណាំងប្រជែងគ្នា ជាមួយប្រជាជន ហើយបានឈ្នះគ្នា ម្ដងម្នាក់ ។ ក្នុងទីបំផុត ព្រះរាជា ទ្រង់ថ្វាយទាន ដែលពួកប្រជាជន មិនអាចធ្វើ ឲ្យដូចជាព្រះអង្គបាន គឺទ្រង់បានបរិច្ចាគនូវព្រះរាជទ្រព្យ ក្នុងមួយថ្ងៃ អស់ដល់ទៅ ១៤ កោដិ និង របស់របរ ដែលមានតម្លៃ ផ្សេងៗ ទៀត ជាច្រើន ។

ក្នុងសម័យនោះ មានអាមាត្យ ២ នាក់ គឺ កាឡអាមាត្យ និង ជុណ្ហអាមាត្យ ។ កាឡអាមាត្យ មិនមានចិត្តត្រេកអរនឹងទានព្រះរាជា ទេ ។ ចំណែកជុណ្ហអាមាត្យវិញ ជាអ្នកមានចិត្តជ្រះថ្លា ចំពោះទាន នោះណាស់ ។

ព្រះសាស្ដា ទ្រង់ជ្រាបវារចិត្ត របស់អាមាត្យទាំងពីរនាក់នោះ ទ្រង់ព្រះពិចារណា ថា "បើតថាគត ធ្វើនូវការអនុមោទនា ឲ្យសមគួរ ដល់ទានរបស់ព្រះរាជាហើយ, ក្បាលរបស់កាឡអាមាត្យ នឹងបែកជា ៧ ចំណែក, ឯជុណ្ហអាមាត្យ នឹងតាំងនៅ ក្នុងសោតាបត្តិផល" ទ្រង់ មានព្រះមហាករុណាគុណ ចំពោះកាឡអាមាត្យ ទើបទ្រង់សំដែងតែ គាថា ៤ បាទ ទ្រង់អនុមោទនាស្រេចហើយ ស្ដេចយាងត្រឡប់ទៅ កាន់ព្រះវិហារវិញ ។

ព្រះបាទបសេនទិកោសល ទ្រង់ព្រះពិរោធ យ៉ាងខ្លាំង ទ្រង់ ស្ដេចយាង តាមក្រោយព្រះសាស្ដា ដើម្បីក្រាបទូលសួរព្រះអង្គអំពី ហេតុនុ៎ះ ។

រឿង ឆាយកាលៈ

ព្រះសាស្តា ទ្រង់ត្រាស់ពន្យល់អំពីរឿងរ៉ាវ របស់អាមាត្យទាំងពីរនាក់នោះ ដើម្បីឲ្យព្រះរាជាជ្រាបច្បាស់ ។ ព្រះរាជា ទ្រង់បាននិរទេសកាឡអាមាត្យ ឲ្យចេញអំពីព្រះនគរ ហើយទ្រង់ព្រះរាជទានទ្រព្យសម្បត្តិ ជាច្រើន ដល់ជុណ្ហអាមាត្យ ក្រោយមក ទ្រង់ក្រាបទូលរឿងនេះ ថ្វាយព្រះសាស្តាទ្រង់ជ្រាប ។

ព្រះសាស្តាចារ្យ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

ន វេ កទិយា ទេវលោកំ វជន្តិ
ពាលា ហវេ នប្បសំសន្តិ ទានំ
ធីរោ ច ទានំ អនុមោទមានោ
តេនេវ សោ ហោតិ សុខី បរត្ថ ។

បុគ្គល កំណាញ់ស្វិតស្វាញ មិនបានទៅកាន់ទេវលោកទេ, ជនពាលទាំងឡាយ មិនសរសើរនូវទានឡើយ, ចំណែកឯអ្នកប្រាជ្ញ តែងអនុមោទនាទាន ព្រោះហេតុនោះឯង លោកតែងបានសេចក្តីសុខ ក្នុងលោកខាងមុខ ។

❁ ❁ ❁

១៤៧- រឿង ឆាយកាលៈ

ព្រះបរមសាស្តា ទ្រង់បានប្រារព្ធ នូវបុត្រអនាថបិណ្ឌិកសេដ្ឋីឈ្មោះកាលៈ ជាអ្នកមិច្ឆាទិដ្ឋិ មិនព្រមដើរតាមគន្លងរបស់សេដ្ឋី ជាបិតា របស់ខ្លួនឡើយ ។ អនាថបិណ្ឌិកសេដ្ឋី ចង់ឲ្យកូនមានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ខ្លាំងណាស់ បានលួងលោមកូន ដោយទ្រព្យ

ថា "នែកូនសំឡាញ់ សូមកូនរក្សាសីល ស្តាប់ព្រះធម៌ទេសនា បិតានឹងឲ្យទ្រព្យមួយពាន់កហាបណៈ ដល់អ្នក" ។ នាយកាលៈ ចង់បានទ្រព្យ ខ្លាំងពេក ក៏យល់ព្រមតាមបិតា លុះដល់ពេលទៅវត្តហើយទើបបានទៅជាមួយនឹងគេដែរ តែគាត់មិនបានទៅស្តាប់ធម៌ទេសនា រក្សាឧបោសថសីល ដូចគេឯងឡើយ បានលបចូលទៅដេក ពួនសម្ងំ ក្នុងទីស្ងាត់មួយ លុះដល់ពេលព្រឹកឡើង ទើបបានវិលត្រឡប់មកផ្ទះវិញ ។

លោកសេដ្ឋី ឃើញកូនត្រឡប់មកពីវត្តវិញ មានចិត្តត្រេកអរខ្លាំងណាស់ ហើយបានឲ្យទ្រព្យមួយពាន់កហាបណៈ ដល់កូន, លុះស្អែកឡើង លោកសេដ្ឋី លួងលោមកូន ថា "បើកូនទៅវត្ត ស្តាប់ធម៌ទេសនាហើយ ចាំធម៌បានមួយបទ បិតា នឹងឲ្យទ្រព្យដល់កូន មួយពាន់កហាបណៈទៀត" ។ នាយកាលៈ យល់ព្រមហើយបានដើរទៅវត្ត គិតក្នុងចិត្ត ថា "បើអាត្មាអញ ចាំធម៌ទេសនា បានមួយបទហើយ អាត្មាអញ នឹងត្រឡប់មកផ្ទះវិញ" ។

ព្រះសាស្តា ទ្រង់ជ្រាបរឿងនោះហើយ ទ្រង់ធ្វើមិនឲ្យនាយកាលៈនោះ ចាំធម៌បាន ។ នាយកាលៈ បានយកចិត្តទុកដាក់ស្តាប់នូវព្រះធម៌ទេសានា ដោយសេចក្តីគោរព ហើយបានសម្រេចសោតាបត្តិផល ក្នុងរាត្រីនោះឯង, លុះដល់ព្រឹកឡើង ក៏បានត្រឡប់ទៅផ្ទះជាមួយភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ។

លោកសេដ្ឋី បានថ្វាយភត្តាហារ ដល់ព្រះភិក្ខុសង្ឃ មានព្រះ

*ពុទ្ធជាប្រធាន ស្រេចហើយបានយកទ្រព្យមួយពាន់កហាបណៈ មកឲ្យនាយកាលៈ ក្នុងទីចំពោះព្រះភក្ត្រព្រះសាស្ដា ។ នាយកាលៈ មានការខ្មាសអៀន មិនហ៊ានទទួលយកទ្រព្យមួយពាន់កហាបណៈ អំពីលោកសេដ្ឋីជាបិតាឡើយ ។ អនាថបិណ្ឌិកសេដ្ឋី បានក្រាបទូលរឿងនេះ ដល់ព្រះសាស្ដា តាំងតែពីដើម រហូតដល់ថ្ងៃនេះ ។*

*ព្រះសាស្ដា ទ្រង់សំដែងធម្មីកថា ត្រាស់នូវព្រះគាថានេះ ថា ៖*

បថព្យា ឯករជ្ជេន សគ្គស្ស គមនេន វា
សព្វលោកាធិបច្ចេន សោតាបត្តិផលំ វរំ ។

*សោតាបត្តិផល ជាគុណជាតដ៏ប្រសើរ ជាងភាពនៃឯករាជ្យលើផែនដីផង ជាងដំណើរទៅកាន់ឋានសួគ៌ផង ជាងភាពជាធំ ក្នុងលោកទាំងមូលផង ។*

**ចប់ លោកវគ្គ ទី ១៣**

## ពុទ្ធវគ្គ ទី ១៤

## ១៤៨- រឿង មារធីតា

*ព្រះបរមសាស្ដា ទ្រង់ប្រារព្ធនាងតណ្ហា អរតី និង នាងរាគា ដែលជាធីតា របស់ស្ដេចមារឈ្មោះវសវត្តី ។ ស្ដេចមារវសវត្តីនេះ ចាំរាវាំងបៀតបៀនដល់ព្រះសាស្ដា តាំងតែពីពេលដែលព្រះអង្គ នៅជាព្រះមហាពោធិសត្វ ទ្រង់លះបង់ចោលនូវរាជ្យសម្បត្តិ ទ្រង់ឡើងគង់នៅលើខ្នងសេះកណ្ឋកៈ មាននាយឆន្នអាមាត្យជាសំឡាញ់ ស្ដេច*

ចេញ អភិនេស្រ្កមណ៍ ពេលនោះ មានមារមកឈរចាំរាំងនៅមាត់ទ្វារព្រះនគរ ហាមឃាត់ថា "នែសិទ្ធត្ថកុមារ ចូរត្រឡប់ទៅវិញចុះ នៅតែ ៧ ថ្ងៃទៀតទេ សម្បត្តិចក្ររតនៈ នឹងកើតមាន ដល់អ្នកហើយ អ្នកនឹងបានឡើងសោយរាជ្យ ជាស្តេចចក្រពត្រាធិរាជ" ។

ព្រះអង្គ ទ្រង់ត្រាស់តបវិញ ថា "យើង ក៏ដឹងដូចគ្នាដែរ តែយើងមិនប្រាថ្នាចង់បានជាស្តេចចក្រពត្រាធិរាជនោះទេ" ។ ចាប់តាំងពីពេលនោះមក ស្តេចវសវត្តីមារ បានព្យាយាមចាំមើលកំហុសរបស់ព្រះអង្គ ដើម្បីនឹងរករឿងប្រទូស្តរ៉ាយ បៀតបៀនព្រះអង្គ អស់រយៈពេល ៧ ឆ្នាំ ។

ចំណែកព្រះពោធិសត្វ លុះស្តេចយាងចេញទៅបព្វជ្ជាហើយ ទ្រង់បំពេញនូវទុក្ករកិរិយា យ៉ាងតឹងតែងជាទីបំផុត តែពុំអាចបានសម្រេចឡើយ ទ្រង់បានលះបង់នូវទុក្ករកិរិយានោះចោល ព្រោះជាមាគ៌ាដែលធ្វើឲ្យព្រះអង្គ មានសេចក្តីលំបាកព្រះវរកាយ ដោយឥតប្រយោជន៍ ទើបទ្រង់បែរមក ធ្វើសេចក្តីព្យាយាមត្រូវ ដែលជាផ្លូវកណ្តាលហើយ ទ្រង់បានសម្រេច នូវព្រះសម្មាសម្ពោធិញ្ញាណ ក្រោមដើមមហាពោធិព្រឹក្ស ទ្រង់ប្រថាប់គង់ សោយវិមុត្តិសុខ ក្នុងទីនោះ អស់រយៈពេល ៧ ថ្ងៃ ហើយស្តេចយាងទៅ ប្រថាប់គង់នៅក្រោមដើមអជបាលនិគ្រោធ... ក្រោមដើមមុច្ចលិន្ទ នឹងទ្រង់ប្រថាប់គង់ ក្រោមដើមរាជាយតនៈ កន្លែងនីមួយៗ អស់រយៈ ពេល ៧ ថ្ងៃ ហើយស្តេចយាងមក ប្រថាប់គង់នៅ ក្រោមដើមអជបាលនិគ្រោធ

# រឿង មារធីតា

ម្តងទៀត ។

សម័យនោះ ស្តេចវសវត្តីមារ គិតថា “ឥឡូវនេះ សិទ្ធត្ថកុមារ បានកន្លងផុតនូវវិស័យ របស់យើងហើយ” ដូច្នេះហើយ ក៏កើតទុក្ខទោមនស្ស យ៉ាងខ្លាំង ។

ចំណែកធីតាមារទាំង ៣ គឺ នាងតណ្ហា អរតី និង នាងរាគា ឃើញបិតា របស់ខ្លួន កើតទុក្ខទោមនស្ស យ៉ាងនេះហើយ ទើបបាន ប្រាប់បិតា ថា “បពិត្រព្រះបិតា កូនស្រីទាំង ៣ នាក់ ជាស្រីក្រមុំ មានរូបស្រស់ស្អាតល្អ កូននឹងទៅធ្វើការលួងលោមព្រះសម្មាសម្ពុទ្ធ ឲ្យស្ថិតនៅ ក្នុងវិស័យរបស់ខ្លួនបាន សូមព្រះបិតា កុំព្រួយបារម្ភអ្វីឡើយ” ហើយបានក្រឡាខ្លួន ជាស្រីពេញជំទង់ខ្លះ ស្រីពេញក្រមុំខ្លះ ស្រីចាស់ខ្លះ មានរូបរាងស្អាត ស្រស់ធេឹតឆាយ គួរជាទីស្រឡាញ់ពន់ពេកណាស់ បាននាំគ្នាមកលួងលោម សំដែងនូវមារយាស្ត្រី មានប្រការផ្សេងៗ ហើយទូលព្រះសាស្តា ថា “បពិត្រព្រះមហាសមណៈ ខ្ញុំម្ចាស់ទាំង ៣ នាក់នេះ ជាស្រីក្រមុំ មានរូបស្រស់ប្រិមប្រិយ គួរឲ្យស្រឡាញ់ នឹងថ្វាយខ្លួន បម្រើព្រះអង្គ” ។

ព្រះសាស្តា ទ្រង់ត្រាស់បណ្តេញ នូវធីតាមារទាំង ៣ នោះ ឲ្យចេញឆ្ងាយទៅ ហើយទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

យស្ស ជិតំ នាវជីយតិ
ជិតមស្ស នោ យាតិ កោចិ លោកេ
តំ ពុទ្ធំ អនន្តគោចរំ

## គាថាធម្មបទប្រែ

**អបទំ កេន បទេន នេស្សថ ។**
**យស្ស ជាលិនី វិសត្តិកា**
**តណ្ហា នត្ថិ កុហិញ្ចិ នេតវេ**
**តំ ពុទ្ធំ អនន្តគោចរំ**
**អបទំ កេន បទេន នេស្សថ ។**

*ជ័យជំនះ របស់ព្រះពុទ្ធអង្គណា មិនត្រឡប់ចាញ់វិញ, កិលេសជាត ណាមួយ ក្នុងលោក រមែងមិនជាប់តាមជ័យជំនះ របស់ព្រះពុទ្ធអង្គនោះ, ពួកនាង នឹងប្រលោមព្រះពុទ្ធអង្គនោះ ដែលមានគោចរ រកទីបំផុតគ្មាន មិនមានកិលេសដូចស្នាមជើង ដោយកិលេសដូចស្នាមជើង ម្ដេចកើត ។*

*តណ្ហា ដែលមានបណ្ដាញ ផ្សាយចេញទៅ ក្នុងអារម្មណ៍ផ្សេងៗ មិនមាន ដល់ព្រះពុទ្ធអង្គណា ដើម្បីនឹងនាំទៅ ក្នុងភពណាមួយ, ពួកនាង នឹងប្រលោមព្រះពុទ្ធអង្គនោះ ដែលមានគោចរ រកទីបំផុតគ្មាន មិនមានកិលេសដូចស្នាមជើង ដោយកិលេសដូចស្នាមជើង ម្ដេចកើត ។*

❀ ❀ ❀

## ១៤៩- រឿងយមកបាដិហារ្យ

*ព្រះបរមសាស្ដា ទ្រង់ប្រារព្ធពួកទេវតា និង មនុស្សជាច្រើន ក្នុងពេលដែលព្រះអង្គ ទ្រង់ធ្វើនូវយមកបាដិហារ្យ ក្នុងក្រុងសាវត្ថី ហើយទ្រង់ស្ដេចយាងឡើងទៅ គង់ចាំព្រះវស្សា នៅឯឋានត្រៃត្រិង្ស*

-២៤២-

រឿងយមកបាដិហារ្យ

ទ្រង់សំដែងព្រះអភិធម្មបិដក ប្រោសព្រះពុទ្ធមាតា ឲ្យតម្កល់នៅ ក្នុងសោតាបត្តិផល ។ លុះបវារណាចេញព្រះវស្សាហើយ, ព្រះអង្គទ្រង់យាងចុះ ពីឋានត្រៃត្រិង្សទេវលោក មកកាន់សង្កស្សនគរ ។

ក្នុងពេលនោះ ពួកទេវតា មនុស្ស និង អមនុស្សទាំងឡាយ ខាងលើ រហូតដល់ព្រហ្មលោក ខាងក្រោម រហូតដល់អវិចីមហានរកទទឹង រហូតដល់សែនចក្រវាឡ មើលគ្នាឃើញទាំងអស់ គឺ ទេវតាមើលពួកមនុស្ស និង អមនុស្សឃើញ, ពួកមនុស្ស មើលពួកទេវតា និង ពួកអមនុស្សឃើញ, ពួកអមនុស្ស មើលពួកទេវតា និង ពួកមនុស្សឃើញ ។

លំដាប់នោះ ព្រះសារីបុត្តត្ថេរ បានក្រាបទូលព្រះពុទ្ធជាម្ចាស់ថា "បពិត្រព្រះអង្គដ៏ចំរើន នៅក្នុងថ្ងៃនេះ ពួកទេវតា មនុស្ស និង អមនុស្សទាំងឡាយ មានចិត្តរីករាយសប្បាយខ្លាំងណាស់ ប្រាថ្នាចង់ឃើញព្រះអង្គ" ។

ព្រះសាស្តា ទ្រង់ត្រាស់ ថា "ម្នាលសារីបុត្រ ធម្មតា ព្រះពុទ្ធទាំងឡាយ ដែលដល់ព្រម ដោយគុណធម៌ យ៉ាងនេះ នឹងជាទីស្រឡាញ់ នៃពួកទេវតា និង មនុស្សទាំងឡាយ" ដូច្នេះហើយ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

យេ ឈានបប្បសុតា ធីរា នេក្ខម្មូបសមេ រតា
ទេវាបិ តេសំ បិហយន្តិ សម្ពុទ្ធានំ សតីមតំ ។

អ្នកប្រាជ្ញទាំងឡាយណា ជាអ្នកខ្វល់ខ្វាយ ក្នុងឈាន ត្រេក

គាថាធម្មបទប្រែ

*អរ ក្នុងនេក្ខម្ម: ជាឋានស្ងប់រម្ងាប់កិលេស, សូម្បីទេវតា និង មនុស្ស ទាំងឡាយ តែងស្រឡាញ់រាប់អាន ចំពោះអ្នកប្រាជ្ញទាំងឡាយនោះ ដែលជាអ្នកត្រាស់ដឹង ដោយខ្លួនឯង ទាំងមានសតិស្មារតី ។*

♣ ❇ ♣

## ១៩០- រឿង ឯរកបត្តនាគរាជ

*ព្រះបរមសាស្តា ទ្រង់បានប្រារព្ធនូវឯរកបត្តនាគរាជ ។ ក្នុងសាសនានៃព្រះពុទ្ធទ្រង់ព្រះនាមកស្សប:, ឯរកបត្តនាគរាជនេះ បាន បួសជាភិក្ខុ ក្នុងពេលដែលលោកជិតធ្វើមរណកាល បានកើតមាន វិប្បដិសារី ក្តៅក្រហាយថា "សីល របស់អាត្មាអញ មិនបានបរិសុទ្ធ ល្អ ព្រោះបានធ្វើក្តួតគាមឲ្យដាច់ លុះលោកបានធ្វើមរណកាល អំពី អត្តភាពនេះទៅ ក៏បានទៅកើតជានាគរាជ ឈ្មោះថា ឯរកបត្ត មាន សេចក្តីប្រាថ្នាចង់ដឹង នូវការកើតឡើង នៃព្រះពុទ្ធទាំងឡាយ ហើយ បានចងក្រងជាបទចម្រៀង ឲ្យធីតារបស់ខ្លួន អង្គុយច្រៀង នៅពីលើ ខ្លួន ថា "អ្នកណាមួយ ច្រៀងឆ្លើយតបនឹងបទចម្រៀងនេះបាន យើង នឹងលើកកូនស្រី ឲ្យដល់អ្នកនោះ ធ្វើជាភរិយា" ។*

*សម័យនោះ ព្រះសម្មាសម្ពុទ្ធ ស្តេចឧបត្តិឡើងហើយ ក្នុង លោក ទ្រង់បានប្រទាន នូវចម្រៀងឆ្លើយតប ដល់ឧត្តរមាណពម្នាក់ ឲ្យទៅច្រៀង តបជាមួយនឹងធីតា របស់នាគរាជនោះ ។ ឧត្តរមាណព លុះរៀនចម្រៀងនោះបានចេះចាំហើយ ក៏បានសម្រេចសោតាបត្តិ-ផល បានយកចំរៀងនោះ ទៅច្រៀងឆ្លើយតប នឹងធីតានៃនាគរាជ ។*

-២៤៤-

រឿងអានន្ទត្ថេរប្បញ្ហា

នាគរាជ បានស្តាប់ចម្រៀងឆ្លើយតបនោះហើយ ក៏បានដឹងច្បាស់ថា "ឥឡូវនេះ ព្រះពុទ្ធជាម្ចាស់ទ្រង់ស្តេចឧបត្តិឡើងហើយ ក្នុងលោក" មានចិត្តត្រេកអររីករាយ ឥតឧបមា ហើយនាំឧត្តរមាណពចូលទៅក្រាបទូលអំពីប្រវត្តិរូបរបស់ខ្លួន ដល់ព្រះសាស្តា ។

ព្រះសាស្តាចារ្យ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

**កិច្ឆោ មនុស្សបដិលាភោ   កិច្ឆំ មច្ចាន ជីវិតំ**
**កិច្ឆំ  សទ្ធម្មស្សវនំ   កិច្ឆោ ពុទ្ធានមុប្បាទោ ។**

កិរិយាត្រឡប់បានអត្តភាពជាមនុស្សបានដោយកម្រ, កិរិយារស់នៅ របស់សត្វទាំងឡាយ បានដោយកម្រ, កិរិយាស្តាប់នូវធម៌របស់សប្បុរស បានដោយកម្រ, កិរិយាកើតឡើង នៃព្រះពុទ្ធទាំងឡាយ បានដោយកម្រ ។

❈ ❈ ❈

១៥១- រឿងអានន្ទត្ថេរប្បញ្ហា

ព្រះបរមសាស្តា ទ្រង់បានប្រារព្ធនូវបញ្ហា របស់ព្រះអានន្ទ ។ សម័យថ្ងៃមួយ ព្រះអានន្ទត្ថេរ បានចូលទៅទូលសួរ នូវឧបោសថរបស់ព្រះពុទ្ធទាំងឡាយ ។

ព្រះសាស្តា ទ្រង់បានត្រាស់សំដែង ថា "ម្នាលអានន្ទ ការធ្វើឧបោសថ របស់ព្រះពុទ្ធទាំងឡាយផ្សេងគ្នា ចំណែក ឱវាទគាថា ដូចគ្នា គ្រប់ៗ អង្គ ទាំងអស់" យ៉ាងដូច្នេះ កាលទ្រង់សំដែងឱវាទគាថានោះ ទើបទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

## គាថាធម្មបទប្រែ

សព្វបាបស្ស អករណំ  កុសលស្សូបសម្បទា
សចិត្តបរិយោទបនំ  ឯតំ ពុទ្ធាន សាសនំ ។
ខន្តី បរមំ តបោ តីតិក្ខា
និព្វានំ បរមំ វទន្តិ ពុទ្ធា
ន ហិ បព្វជិតោ បរូបឃាតី
សមណោ ហោតិ បរំ វិហេឋយន្តោ ។
អនូបវាទោ អនូបឃាតោ  បាតិមោក្ខេ ច សំវរោ
មត្តញ្ញុតា ច ភត្តស្មឹ  បន្តញ្ច សយនាសនំ
អធិចិត្តេ ច អាយោគោ  ឯតំ ពុទ្ធាន សាសនំ ។

*ការមិនធ្វើបាបទាំងពួង ការញ៉ាំងកុសលឲ្យកើតឡើង ការធ្វើចិត្តរបស់ខ្លួនឲ្យផូរផង់ នេះជាពាក្យប្រៀនប្រដៅ របស់ព្រះពុទ្ធទាំងឡាយ ។ ខន្តី គឺសេចក្តីអត់ធន់ ជាតបធម៌ដ៏ឧត្តម, ព្រះពុទ្ធទាំងឡាយតែងពោលថា ព្រះនិព្វានជាធម្មជាតដ៏ឧត្តម, បុគ្គលដែលសម្លាប់សត្វដទៃ មិនឈ្មោះថា បព្វជិតទេ បុគ្គលបៀតបៀនសត្វដទៃ មិនឈ្មោះថា សមណៈឡើយ ។*

*ការមិនតិះដៀល ១ ការមិនបៀតបៀន ១ ការសង្រួម ក្នុងបាតិមោក្ខ ១ ភាពជាអ្នកដឹងប្រមាណក្នុងភត្ត ១ ការដេក និង អង្គុយក្នុងទីស្ងាត់ ១ ការព្យាយាម ក្នុងអធិចិត្ត ១ នុ៎ះជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយ ។*

♣ ❈ ♣

## ១៥២- រឿងអនភិរតភិក្ខុ

ព្រះបរមសាស្តា ទ្រង់ប្រារព្ធភិក្ខុមួយរូប ជាអ្នកមិនត្រេកអរក្នុងបព្វជ្ជា ប្រាថ្នាចង់លាចាកសិក្ខាបទតែប៉ុណ្ណោះ ។ ភិក្ខុទាំងឡាយបានទៅក្រាបទូលរឿងនោះ ដល់ព្រះសាស្តា ។

ព្រះសាស្តា ទ្រង់ត្រាស់សួរនូវភិក្ខុនោះ ថា "ម្នាលភិក្ខុ បច្ច័យដែលទុកសម្រាប់ចិញ្ចឹមជីវិត របស់អ្នកនោះ តើមានគ្រប់គ្រាន់ ប្រើប្រាស់ដែរឬទេ?" ។

ភិក្ខុរូបនោះ ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចំរើន បច្ច័យនោះមានមួយរយកហាបណៈ, បិតា បានប្រគល់ឲ្យប្អូនប្រុស ទុកដាក់ ថែរក្សា មុនពេលដែលគាត់ធ្វើមរណកាលទៅ" ។

ព្រះសាស្តា ទ្រង់ត្រាស់ឲ្យភិក្ខុនោះ រាប់ គិត បូកកហាបណៈដែលត្រូវយកទៅចាយវាយ ប្រើប្រាស់ផ្សេងៗ មានទិញម្ហូបអាហារបរិភោគ រៀងរាល់ថ្ងៃ ទិញគោ, ក្របី, ស្រូវ, អង្ករ, ចប និង ផាលជាដើម ថា តើគ្រប់គ្រាន់ ឬ មិនគ្រប់គ្រាន់ ។

ភិក្ខុនោះ គិតទៅ គិតមក ឃើញថា កហាបណៈ មួយរយនោះមិនគ្រប់គ្រាន់នឹងគ្រឿងប្រើប្រាស់ សម្រាប់ចិញ្ចឹមជីវិតបានឡើយ ។

ព្រះសាស្តា ទ្រង់ត្រាស់ថា "ម្នាលភិក្ខុ កហាបណៈ របស់អ្នកតិចពេកណាស់ អ្នកអាស្រ័យកហាបណៈទាំងនេះហើយ នឹងញុំាងអត្តភាព ឲ្យគ្រប់គ្រាន់ យ៉ាងដូចម្តេចបាន" ដូច្នេះហើយទ្រង់ត្រាស់នូវសម័នជាតុជាតក... ក្នុងទីបញ្ចប់ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

ន កហាបណវស្សេន តិត្តិ កាមេសុ វិជ្ជតិ

-២៤៧-

គាថាធម្មបទប្រែ

អប្បស្សាទា ទុក្ខា កាមា   ឥតិ វិញ្ញាយ បណ្ឌិតោ
អបិ ទិព្វេសុ កាមេសុ   រតឹ សោ នាធិគច្ឆតិ
តណ្ហក្ខយរតោ ហោតិ   សម្មាសម្ពុទ្ធសាវកោ ។

*ការឆ្អែតស្កប់ស្កល់ ក្នុងកាមទាំងឡាយ រមែងមិនមាន ព្រោះកហាបណៈ (ដែលធ្លាក់ចុះ) ដូចទឹកភ្លៀងទេ, កាមទាំងឡាយ មានសេចក្ដីសុខតិចណាស់ (តែ) មានសេចក្ដីទុក្ខច្រើន, អ្នកប្រាជ្ញ ដឹងច្បាស់ យ៉ាងនេះហើយ លោកមិនបានត្រេកអរ ក្នុងកាមទាំងឡាយសូម្បីជាទិព្វឡើយ, សាវ័ករបស់ព្រះសម្មាសម្ពុទ្ធ រមែងជាអ្នកត្រេកអរ ក្នុងធម៌ជាគ្រឿងអស់ទៅនៃតណ្ហា ។*

❋ ❋ ❋

## ១៥៣- រឿងអគ្គិទត្តបុរោហិត

*ព្រះបរមសាស្ដា ទ្រង់ប្រារព្ធនូវបុរោហិត ឈ្មោះ អគ្គិទត្ត ជាគ្រូ របស់ព្រះបាទមហាកោសល ។ អគ្គិទត្តនេះ បានឃើញភ័យក្នុងឃរាវាស ហើយបានលះបង់ទ្រព្យសម្បត្តិ ចេញទៅបួស ជាតាបសឥសី អាស្រ័យនៅ នាចន្លោះក្រុងអង្គៈ មគធៈ និង ក្រុងកុរុ ជាប់គ្នា មានបុរសចេញបួស ជាមួយនឹងខ្លួន ចំនួនច្រើនហ្មឺននាក់ ។*

*ក្នុងសម័យនោះឯង ព្រះសាស្ដា ទ្រង់ទតព្រះនេត្រឃើញ នូវឧបនិស្ស័យ នៃព្រះអរហត្តផល របស់អគ្គិទត្តតាបស និង ពួកអន្តេវាសិកទាំងឡាយហើយ ទើបទ្រង់ត្រាស់បញ្ជាឲ្យព្រះមហាមោគ្គល្លាន និមន្តទៅ ឲ្យឪវាទ អប់រំអគ្គិទត្តតាបសនោះ ព្រមទាំងអន្តេវាសិកទាំង*

-២៤៨-

## រឿងអគ្គិទត្តបុរោហិត

នោះផង ។

ព្រះមហាមោគ្គល្លានត្ថេរ បាននិមន្តចូលទៅរកអគ្គិទត្តតាបស ហើយ សុំសំណាក់នៅអាស្រ័យជាមួយផង ។ អគ្គិទត្តតាបស បាន បង្ហាញផ្ទះខ្សាច់ ដែលជាលំនៅរបស់នាគរាជ ដល់ព្រះថេរៈ ។ ព្រះ មហាមោគ្គល្លាន បានបង្ក្រាបនូវនាគរាជនោះ ឲ្យចុះចាញ់ ឈប់កាច សាហាវ ដូចមុនទៀតហើយ ។

ពួកឥសីទាំងនោះ លុះបានឃើញឫទ្ធិ របស់ព្រះថេរៈ យ៉ាង នេះហើយ ក៏មានចិត្តជ្រះថ្លាចំពោះព្រះថេរៈ ហើយនាំគ្នាលើកអញ្ជលី ប្រណម្យ ពោលសរសើរព្រះថេរៈ ក្នុងពេលនោះឯង ។

ព្រះសាស្តា ទ្រង់ស្តេចយាងមក ក្នុងទីនោះដែរ ។ ព្រះមហា-មោគ្គល្លានត្ថេរ ឃើញនូវព្រះសាស្តាស្តេចយាងមកហើយ ទើបបាន ក្រោកឡើង ធ្វើការនមស្សការ ចំពោះព្រះអង្គ ។ គ្រានោះ ពួកឥសី ទាំងឡាយ បានសួរព្រះថេរៈ ថា "តើព្រះពុទ្ធ និង ព្រះគុណម្ចាស់ អ្នក ណាធំជាងអ្នកណាហ្ន៎?" ។ ព្រះថេរៈ ឆ្លើយតបថា "ព្រះពុទ្ធ ព្រះអង្គ ធំជាងអាត្មាភាព ព្រះអង្គជាគ្រូ របស់អាត្មាភាពៗ ជាសិស្ស របស់ ព្រះអង្គ" ។ ពួកឥសីទាំងនោះ បានឮដូច្នេះហើយ កើតមានសេចក្តី អស្ចារ្យ ក្នុងចិត្ត យ៉ាងខ្លាំង បាននាំគ្នាទៅ ក្រាបថ្វាយបង្គំព្រះសាស្តា ដោយសេចក្តីគោរព ។

ព្រះសាស្តាទ្រង់ត្រាស់សួរអគ្គិទត្ត ថា "នែអគ្គិទត្ត តើអ្នកបាន ឲ្យឱវាទ ដល់ពួកសាវ័ករបស់អ្នក យ៉ាងណាដែរ?" ។ អគ្គិទត្ត បាន

-២៤៩-

# គាថាធម្មបទប្រែ

*ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះករុណា បានឲ្យឱវាទ ដល់សាវ័ករបស់ខ្ញុំព្រះករុណា យ៉ាងដូច្នេះ ថា: អ្នកទាំងឡាយ ចូរយកនូវព្រៃភ្នំ អារាមចេតិយទាំងឡាយ មកធ្វើជាទីពឹងទីរឭកចុះ បើអ្នកទាំងឡាយ បានយកនូវវត្ថុទាំងនេះ មកធ្វើជាទីពឹងទីរឭកហើយ អ្នកទាំងឡាយ នឹងបានរួចផុត ចាកសេចក្តីទុក្ខទាំងពួង" ។*

*ព្រះសាស្តា កាលទ្រង់ប្រទាននូវឱវាទ ទ្រង់ត្រាស់នូវគាថានេះ ថា ៖*

ពហុំ វេ សរណំ យន្តិ បព្វតានិ វនានិ ច
អារាមរុក្ខចេត្យានិ មនុស្សា ភយតជ្ជិតា
នេតំ ខោ សរណំ ខេមំ នេតំ សរណមុត្តមំ
នេតំ សរណមាគម្ម សព្វទុក្ខា បមុច្ចតិ ។
យោ ច ពុទ្ធញ្ច ធម្មញ្ច សង្ឃញ្ច សរណំ គតោ
ចត្តារិ អរិយសច្ចានិ សម្មប្បញ្ញាយ បស្សតិ
ទុក្ខំ ទុក្ខសមុប្បាទំ ទុក្ខស្ស ច អតិក្កមំ
អរិយញ្ចដ្ឋង្គិកំ មគ្គំ ទុក្ខូបសមគាមិនំ
ឯតំ ខោ សរណំ ខេមំ ឯតំ សរណមុត្តមំ
ឯតំ សរណមាគម្ម សព្វទុក្ខា បមុច្ចតិ ។

*មនុស្សទាំងឡាយ ជាច្រើននាក់ ត្រូវភ័យគម្រាមហើយ តែងយកភ្នំ អារាម និង រុក្ខចេតិយ ធ្វើជាទីពឹង, ទីពឹងបែបនេះ មិនមែនជាទីពឹង ដ៏ក្សេមទេ ទីពឹងបែបនេះ មិនមែនជាទីពឹង ដ៏ឧត្តមទេ, បុគ្គល*

អាស្រ័យ នូវទីពឹងនេះហើយ រមែងមិនរួចស្រឡះ ចាកទុក្ខទាំងពួង បានឡើយ ។

លុះតែបុគ្គលណា យកព្រះពុទ្ធ ព្រះធម៌ និង ព្រះសង្ឃ ជាទីពឹង ឃើញច្បាស់នូវអរិយសច្ចទាំង ៤ គឺ ទុក្ខសច្ច ១ ទុក្ខសមុទយសច្ច ១ និរោធសច្ច កន្លងទុក្ខ ១ អរិយមគ្គ ប្រកបដោយអង្គ ៨ ជាដំណើរទៅកាន់ព្រះនិព្វានដែល ជាទីរម្ងាប់ទុក្ខ ១ ដោយប្រាជ្ញា ដ៏ប្រពៃ, នេះឯង ជាទីពឹងដ៏ក្សេម នេះឯង ជាទីពឹងដ៏ឧត្តម, បុគ្គលអាស្រ័យទីពឹងនេះហើយ រមែងរួចស្រឡះចាកទុក្ខទាំងពួងបាន ។

♣ ❈ ♣

## ១៩៤- រឿងអានន្ទត្ថេរបញ្ហា

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវបញ្ហា របស់ព្រះអានន្ទ ។ ថ្ងៃមួយ ព្រះអានន្ទ បានចូលទៅ ក្រាបទូលសួរព្រះសាស្តា ថា "បពិត្រព្រះអង្គដ៏ចំរើន តើបុរសអាជានេយ្យ កើតនៅក្នុងទីណាខ្លះ?" ។

ព្រះសាស្តា ទ្រង់ត្រាស់ ថា "ម្នាលអានន្ទ បុរសអាជានេយ្យ មិនមែនកើតនៅគ្រប់ទីកន្លែងទេ គឺ កើតនៅក្នុងត្រកូលខត្តិយមហាសាល និង ត្រកូលព្រាហ្មណ៍មហាសាល ត្រកូលណាមួយ" ហើយទ្រង់ត្រាស់នូវ ព្រះគាថានេះ ថា ៖

**ទុល្លភោ បុរិសាជញ្ញោ ន សោ សព្វត្ថ ជាយតិ**
**យត្ថ សោ ជាយតី ធីរោ តំ កុលំ សុខមេធតិ ។**

បុរសអាជានេយ្យ រកបានដោយកម្រ លោកមិនកើតក្នុងសព្វ

*ឋានទេ លោកជាអ្នកប្រាជ្ញ កើតក្នុងត្រកូលណា ត្រកូលនោះ តែង បានសេចក្តីសុខ ។*

❋ ❋ ❋

## ១៩៥- រឿងសម្ពហុលភិក្ខុ

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវការសន្ទនា របស់ភិក្ខុជាច្រើន រូប ។ ភិក្ខុទាំងនោះ បានសន្ទនាគ្នា ថា "នែអ្នកទាំងឡាយ អ្វីទៅហ្ន៎ ដែលជាសុខ ក្នុងលោកនេះ? " ។ ភិក្ខុពួកខ្លះ ឆ្លើយថា "ភាពជាព្រះ រាជានេះហើយ ជាសេចក្តីសុខ" ។ ភិក្ខុពួកខ្លះ ឆ្លើយថា "កាមនេះឯង ជាសុខ" ។ ភិក្ខុពួកខ្លះ ឆ្លើយថា "ការបរិភោគនូវភោជនាហារ ដែល មានរស់ជាតឆ្ងាញ់ៗ គឺជាសុខ" ។*

*ព្រះសាស្តា ស្តេចយាងមក ក្នុងទីប្រជុំនោះហើយ ទ្រង់ត្រាស់ នូវព្រះគាថានេះ ថា ៖*

**សុខោ ពុទ្ធានមុប្បាទោ សុខា សទ្ធម្មទេសនា**
**សុខា សង្ឃស្ស សាមគ្គី សមគ្គានំ តបោ សុខោ។**

*ការកើតឡើង នៃព្រះពុទ្ធ ជាសុខ, ការសំដែងនូវព្រះសទ្ធម្ម ជាសុខ, សេចក្តីព្រមព្រៀងគ្នានៃពួក ជាសុខ, តបធម៌ របស់បុគ្គល អ្នកព្រមព្រៀងគ្នាទាំងឡាយ ជាសុខ ។*

❋ ❋ ❋

## ១៩៦- រឿងកស្សបទសពលសុវណ្ណចេតិយ

*ព្រះបរមសាស្តា ទ្រង់ស្តេចយាងចេញ ពីទីក្រុងសាវត្ថី ឆ្ពោះ*

-២៥២-

រឿង កស្សបទសពលសុវណ្ណចេតិយ

ទៅកាន់ទីក្រុងពារាណសី ព្រមជាមួយនឹងភិក្ខុសង្ឃជាច្រើនរូប លុះយាងមកដល់សាលាមួយ នៅពាក់កណ្តាលផ្លូវ ក្បែរផ្ទះព្រាហ្មណ៍ម្នាក់ ឈ្មោះថា តោទេយ្យៈ ទ្រង់បានឈប់សម្រាក ក្នុងទីនោះ ហើយត្រាស់ឲ្យព្រះអានន្ទ និមន្តទៅតាមព្រាហ្មណ៍ ដែលកំពុងតែភ្ជួរស្រែឲ្យគាត់មកគាល់ព្រះអង្គ ។

ព្រាហ្មណ៍នោះ លុះមកដល់ហើយ ក៏មិនបានថ្វាយបង្គំព្រះសាស្តាទេ តែបានថ្វាយបង្គំចំពោះទេវស្ថានប៉ុណ្ណោះ ហើយបានឈរនៅស្ងៀម ។

ព្រះសាស្តា ទ្រង់ត្រាស់សួរ ថា "ម្នាលព្រាហ្មណ៍ អ្នកសម្គាល់នូវទេវស្ថាននេះថាទុកដូចជាអ្វី?" ។ ព្រាហ្មណ៍ ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចំរើន ទូលព្រះបង្គំ បានសម្គាល់ថា ជាចេតិយស្ថាន តាមប្រពៃណី របស់ពួកទូលព្រះបង្គំទាំងឡាយ" ។

ព្រះសាស្តា ទ្រង់ត្រាស់សរសើរ ថា "ម្នាលព្រាហ្មណ៍ អ្នកគោរពបូជានូវទេវស្ថានេះ ជាការប្រសើរហើយ" ។

ភិក្ខុទាំងឡាយបានឮហើយ ក៏កើតសេចក្តីសង្ស័យថា "ព្រោះហេតុអ្វីហ្ន៎ បានជាព្រះសាស្តាត្រាស់សរសើរ នូវការអភិវាទទេវស្ថាននេះ? " ។

ព្រះសាស្តា កាលទ្រង់ដោះស្រាយ នូវសេចក្តីសង្ស័យ របស់ភិក្ខុទាំងនោះ ទើបទ្រង់ត្រាស់ ថា "ម្នាលភិក្ខុទាំងឡាយ ទេវស្ថាននេះគឺ ជាចេតិយ របស់ព្រះពុទ្ធ" ហើយ ទ្រង់ត្រាស់សំដែង នូវពុទ្ធានុភាព

-២៥៣-

## គាថាធម្មបទប្រែ

*ដើម្បីធ្វើឲ្យចេតិយមាសនោះ មកប្រាកដ ដល់ភិក្ខុទាំងនោះ នឹងប្រជាជនទាំងអស់ ក្នុងទីនោះ ។ ពួកប្រជាជន ក៏បាននាំគ្នា ធ្វើសក្ការបូជា ចំពោះចេតិយមាសនោះ ដោយសេចក្ដីជ្រះថ្លា យ៉ាងក្រៃលែង ។*

*ព្រះសាស្ដា ទ្រង់បានសំដែងផលានិសង្ស នៃការធ្វើសក្ការបូជា ដោយព្រះគាថានេះ ថា ៖*

បូជារហេ បូជយតោ ពុទ្ធេ យទិ ច សាវកេ
បបញ្ចសមតិក្កន្តេ តិណ្ណសោកបរិទ្ទវេ
តេ តាទិសេ បូជយតោ និព្វុតេ អកុតោភយេ
ន សក្កា បុញ្ញំ សង្ខាតុំ ឥមេត្តមបិ កេនចិ ។

*បុគ្គលណាមួយ មិនអាចរាប់បុណ្យ របស់បុគ្គលដែលបូជា ដល់បូជារហបុគ្គលទាំងឡាយ គឺ ព្រះពុទ្ធ និង សាវ័ករបស់ព្រះពុទ្ធទាំងឡាយ ជាអ្នកកន្លងនូវបបញ្ចធម៌ គឺគ្រឿងយឺតយូរបានហើយ ជាអ្នកកន្លងផុតសេចក្ដីសោកនិងសេចក្ដីខ្សឹកខ្សួលអស់ហើយ ឬ របស់បុគ្គលដែលបូជា ដល់បូជារហបុគ្គលទាំងឡាយនោះ ដែលប្រកបដោយតាទិគុណ លោកមិនមានភ័យអំពីទីណា សូម្បីបរិនិព្វានទៅហើយដោយការរាប់វិធីណាមួយក៏ដោយ ថាបុណ្យនេះមានប្រមាណប៉ុណ្ណេះ បានឡើយ ។*

**ចប់ ពុទ្ធវគ្គ ទី ១៤**

# សុខវគ្គ ទី ១៥

## ១៥៧- រឿង ការហាមព្រះញាតិ

ព្រះបរមសាស្ដា ទ្រង់ប្រារព្ធនូវពួកព្រះញាតិវង្ស ដែលបានវិវាទ ឈ្លោះទាស់ទែងគ្នាអំពីរឿងទឹកធ្វើស្រែ ។ ពួកអ្នកបម្រើ របស់ពួកសាក្យៈ និង ពួកកោសិយៈ ធ្វើស្រែអាស្រ័យទឹកស្ទឹងរោហិណី ដែលនៅក្នុងចន្លោះ នៃក្រុងកបិលពស្តុ និង ក្រុងកោសិយៈ បានទប់ទំនប់ ដណ្ដើមទឹកគ្នាធ្វើស្រែ ហើយបានឈ្លោះទាស់ទែងគ្នា រហូតដល់ជម្លោះនោះ រាលដាលទៅដល់ពួកចៅហ្វាយរៀងៗ ខ្លួន ។

ក្សត្រទាំងពីរនគរនោះ ក៏បាននាំគ្នា លើកកងទ័ពទៅ ដើម្បីធ្វើសង្គ្រាមដណ្ដើមទឹកធ្វើស្រែ ។

ព្រះសាស្ដា ទ្រង់ទតព្រះនេត្រឃើញហើយ ទើបស្ដេចយាងហោះទៅ តាមអាកាស ទ្រង់គង់ធ្វើសមាធិ លើអាកាស នៅចំពាក់កណ្ដាលស្ទឹងរោហិណីនោះ ។ ពួកព្រះញាតិវង្ស បានឃើញនូវព្រះសាស្ដា គង់ធ្វើសមាធិ លើកអាកាស យ៉ាងនេះហើយ ក៏បានទម្លាក់អាវុធចោលទាំងអស់គ្នា ហើយក្រាបថ្វាយបង្គំព្រះអង្គ ។

ព្រះសាស្ដា ទ្រង់បានត្រាស់សួរថា "បពិត្រព្រះមហារាជទាំងឡាយ ទឹក និង ពួកក្សត្រ តើណាមួយ មានតម្លៃច្រើនជាងគេ? " ។

ពួកព្រះញាតិវង្ស បានក្រាបទូលថា "បពិត្រព្រះអង្គ ដ៏ចំរើន ទឹកមានតម្លៃតិចទេ ចំណែក ពួកក្សត្រ មានតម្លៃរកប្រមាណមិនបានឡើយ" ។

ព្រះសាស្ដាទ្រង់ត្រាស់ថា "អ្នកទាំងឡាយ អាស្រ័យទឹកដែល

គាថាធម្មបទប្រែ

*មានប្រមាណតិចនេះ ហើយញ៉ាំងក្សត្រដែលមានតម្លៃច្រើនប្រមាណមិនបាន ឲ្យវិនាសសាបសូន្យ តើសមគួរដែរឬ?" ស្រេចហើយ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

សុសុខំ វត ជីវាម    វេរិនេសុ អវេរិនោ
វេរិនេសុ មនុស្សេសុ    វិហរាម អវេរិនោ ។
សុសុខំ វត ជីវាម    អាតុរេសុ អនាតុរា
អាតុរេសុ មនុស្សេសុ    វិហរាម អនាតុរា ។
សុសុខំ វត ជីវាម    ឧស្សុកេសុ អនុស្សុកា
ឧស្សុកេសុ មនុស្សេសុ    វិហរាម អនុស្សុកា ។

*យើង ជាអ្នកមិនមានពៀរ រស់នៅជាសុខសប្បាយមែនពិត ក្នុងពួកមនុស្សដែលមានពៀរ, កាលពួកមនុស្សមានពៀរ យើងជាអ្នករស់នៅ មិនមានពៀរ ។ យើងជាអ្នកមិនមានសេចក្តីក្តៅក្រហាយ (ដោយសារកិលេស) រស់នៅជាសុខសប្បាយមែនពិត ក្នុងពួកមនុស្សដែលមានសេចក្តីក្តៅក្រហាយ, កាលពួកមនុស្សមានសេចក្តីក្តៅក្រហាយ យើងរស់នៅ មិនមានសេចក្តីក្តៅក្រហាយ ។ យើងជាអ្នកមិនមានសេចក្តីខ្វល់ខ្វាយ ក្នុងការស្វែងរក រស់នៅជាសុខសប្បាយមែនពិត ក្នុងពួកមនុស្សដែលមានសេចក្តីខ្វល់ខ្វាយ, កាលពួកមនុស្ស មានសេចក្តីខ្វល់ខ្វាយ យើងជាអ្នករស់នៅ មិនមានសេចក្តីខ្វល់ខ្វាយឡើយ ។*

❉ ❉ ❉

## ១៥៨- រឿង មារ

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវមារ ក្នុងពេលដែលព្រះអង្គស្តេចយាងចូលទៅកាន់ផ្ទះនៃព្រាហ្មណ៍ ដើម្បីទ្រង់បិណ្ឌបាត ប្រោសសត្វ ។

ក្នុងគ្រានោះ មារ បានចូលទៅស្ថិតនៅ ក្នុងសរីរៈរាងកាយរបស់ពួកអ្នកស្រុកទាំងអស់ ធ្វើមិនឲ្យព្រះអង្គបានចង្ហាន់បិណ្ឌបាត ហើយបាននិយាយសើចចំអកឲ្យព្រះអង្គថា "នែសមណៈ តើព្រះអង្គមិនបាននូវចង្ហាន់បិណ្ឌបាតទេឬ? បើព្រះអង្គមិនបានចង្ហាន់បិណ្ឌបាត តើព្រះអង្គមិនស្រេកឃ្លានទេឬ?" ។

ព្រះសាស្តា ទ្រង់ត្រាស់ថា "ម្នាលមារ ទោះបីជាយើងមិនបាននូវអាហារ ក៏យើងមានបីតិជាអាហារ ដូចអាភស្សរព្រហ្មដែរ" ហើយទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

**សុសុខំ វត ជីវាម យេសន្នោ នត្ថិ កិញ្ចនំ**
**បីតិភក្ខា ភវិស្សាម ទេវា អាភស្សរា យថា ។**

សេចក្តីកង្វល់ មិនមាន ដល់យើងទាំងឡាយណា យើងទាំងឡាយនោះ តែងរស់នៅជាសុខសប្បាយមែនពិត (ព្រោះថា) យើងមានបីតិជាអាហារ ដូចពួកទេវតា ជាន់អាភស្សរៈ យ៉ាងនោះឯង ។

❀ ❀ ❀

## ១៥៩- រឿង កោសលរាជបរាជ័យ

ព្រះបរមសាស្តា ទ្រង់បានប្រារព្ធការបរាជ័យ របស់ព្រះបាទកោសល ។ ជាដំបូង ព្រះរាជា ទ្រង់អាស្រ័យកាសិកគ្រាម ធ្វើសឹក

សង្គ្រាម ជាមួយនឹងព្រះបាទអជាតសត្រូវ ដែលជាព្រះភាគិនេយ្យ ។ ព្រះបាទអជាតសត្រូវទ្រង់បានធ្វើឲ្យព្រះបាទកោសលបរាជ័យ រហូតបីលើក ។ ក្នុងលើកទីបី ព្រះបាទកោសល ទ្រង់ព្រះចិន្តា ថា "យើងមិនអាចញ៉ាំងទារក ដែលមិនទាន់ដាច់ទឹកដោះ ឲ្យបរាជ័យបានឡើយ តើនឹងរស់នៅធ្វើអ្វីទៀត មានតែស្លាប់ទៅប្រសើរជាង" លុះទ្រង់ព្រះចិន្តាយ៉ាងនេះហើយ ទ្រង់មិនសោយព្រះក្រយាស្ងោយសោះ ទ្រង់មានសេចក្តីទុក្ខទោមនស្ស យ៉ាងក្រៃលែង ជាវៀងរាល់យប់ថ្ងៃ ។

ភិក្ខុទាំងឡាយ បានដឹងរឿងនេះហើយ បានក្រាបទូល ដល់ព្រះសាស្តា ។

ព្រះសាស្តាទ្រង់ជ្រាបហើយ ទើបត្រាស់នូវព្រះគាថានេះថា ៖

**ជយំ វេរំ បសវតិ ទុក្ខំ សេតិ បរាជិតោ**
**ឧបសន្តោ សុខំ សេតិ ហិត្វា ជយបរាជយំ ។**

បុគ្គលអ្នកឈ្នះ រមែងជួបប្រទះនូវពៀរ, បុគ្គលអ្នកចាញ់ រមែងដេកកើតទុក្ខ, ចំណែក បុគ្គល លះបង់ការឈ្នះ និង ការចាញ់បានហើយ ជាអ្នកស្ងប់រម្ងាប់ រមែងដេកជាសុខ ។

## ១៦០- រឿង អញ្ញាត្រកុលនារិកា

ព្រះបរមសាស្តា ទ្រង់ប្រារព្ធ នូវនាងកុមារិកាម្នាក់ ។ ម្តាយរបស់នាង បានធ្វើអាវាហមង្គលឲ្យនាង ហើយបានទៅអារាធនាព្រះសាស្តា ព្រមទាំងភិក្ខុសង្ឃ ឲ្យស្តេចយាងចូលរួម ក្នុងមង្គលការនោះ

ដើម្បីប្រោសប្រទាន នូវព្រះឱវាទដល់នាង ។

នាងកុមារិកា ជាស្រីពេញវ័យក្រមុំ បានធ្វើកិច្ចការទាំងឡាយ មានការត្រងទឹក ប្រគេនព្រះសង្ឃឆាន់ជាដើម ដើរទៅដើរមក ស្រាប់តែបានជួបប្រទះនឹងបុរសជាស្វាមីរបស់នាង ដែលកំពុងតែឈរចាំមើលនាង ។

បុរសជាស្វាមីនោះ លុះឃើញនាងហើយ ក៏កើតសេចក្តីស្រឡាញ់ យ៉ាងខ្លាំង ធ្វើកិច្ចការអ្វីលែងកើត ឈរនឹកគិតថា "អាត្មាអញ នឹងលួងលោមនាង ក្នុងពេលឥឡូវនេះ ឲ្យបានតែម្តង" ។

ព្រះសាស្តា ទ្រង់ជ្រាបនូវវារចិត្ត របស់បុរសនោះហើយ ទើបទ្រង់ ធ្វើមិនឲ្យបុរសនោះ ឃើញនាងកុមារិកាឡើយ ហើយសំដែងនូវធម្មីកថា ត្រាស់នូវព្រះគាថានេះ ថា ៖

**នត្ថិ រាគសមោ អគ្គិ  នត្ថិ ទោសសមោ កលិ**
**នត្ថិ ខន្ធសមា ទុក្ខា  នត្ថិ សន្តិបរំ សុខំ ។**

ភ្លើងស្មើដោយរាគៈមិនមានឡើយ, ទោសកំហុសស្មើដោយទោសៈ មិនមានឡើយ, ទុក្ខទាំងឡាយស្មើដោយខន្ធ មិនមានឡើយ, សុខក្រៅអំពីសេចក្តីស្ងប់ មិនមានឡើយ ។

♣ ❇ ♣

## ១៦១- រឿងអញ្ញត្រឧបាសក

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវឧបាសកម្នាក់ ក្នុងក្រុងអាឡវី ជាអ្នកកំសត់ទុគ៌ត ។ ព្រះអង្គ ទ្រង់ទតព្រះនេត្រឃើញនូវឧបនិស្ស័យ

*នៃសោតាបត្តិផលរបស់ឧបាសកនោះហើយ ស្ដេចយាងទៅកាន់ក្រុងអាឡវី មួយអន្លើដោយភិក្ខុសង្ឃ ៥០០ រូប ។ ពួកមហាជន បាននាំគ្នា ចាត់ចែងធ្វើនូវភត្តាហារ ដើម្បីថ្វាយព្រះសាស្ដា ព្រមទាំងភិក្ខុសង្ឃ តាមសទ្ធា ។*

*ក្នុងគ្រានោះ ឧបាសកកំសត់ទុគ៌តនោះ បានចេញទៅរកគោលុះឃើញគោហើយ ទើបត្រឡប់មកកាន់ទីប្រជុំវិញ ។*

*ព្រះសាស្ដា ទ្រង់បានត្រាស់ឲ្យវេយ្យាវច្ចករ ធ្វើម្ហូបអាហារឲ្យឧបាសកនោះបរិភោគ ដើម្បីបំបាត់ការស្រេកឃ្លាន ហើយទ្រង់ត្រាស់អនុបុព្វីកថា ប្រកាសនូវចតុរារិយសច្ច ។ នៅពេលបញ្ចប់ព្រះធម៌ទេសនាហើយ ឧបាសកនោះ ក៏បានសម្រេចសោតាបត្តិផល ។ ភិក្ខុទាំងឡាយ បានសន្ទនាគ្នាអំពីរឿងនោះ ។*

*ព្រះសាស្ដាចារ្យ ទ្រង់ធ្វើធម្មីកថា ត្រាស់នូវព្រះគាថានេះថា៖*

**ជិឃច្ឆា បរមា រោគា សង្ខារា បរមា ទុក្ខា**
**ឯតំ ញត្វា យថាភូតំ និព្វានំ បរមំ សុខំ ។**

*សេចក្ដីស្រេកឃ្លាន ជារោគយ៉ាងក្រៃលែង, សង្ខារទាំងឡាយ ជាទុក្ខយ៉ាងក្រៃលែង, (អ្នកប្រាជ្ញ) ដឹងច្បាស់នូវសេចក្ដីនុ៎ះតាមពិតហើយ (រមែងធ្វើឲ្យជាក់ច្បាស់) នូវព្រះនិព្វាន ជាសុខ យ៉ាងក្រៃលែង ។*

❀ ❀ ❀

១៦២- រឿង ព្រះបាទបសេនទិកោសល

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវព្រះបាទបសេនទិកោសល ។ កាលពីដើម ព្រះរាជា ទ្រង់មានព្រះកាយហាល់ នៅមិនជាសុខ ព្រោះទោសនៃការសោយព្រះស្ងោយច្រើនហួសប្រមាណ ។ លុះព្រះអង្គទ្រង់ព្រះសណ្តាប់នូវពុទ្ធភាសិត ដែលតិះដៀលនូវការបរិភោគហួសប្រមាណហើយ ពោលសរសើរការស្គាល់ប្រមាណ ក្នុងការបរិភោគតែល្មមសមគួរហើយ ទើបទ្រង់បន្ថយព្រះក្រយាស្ងោយបន្តិចម្តងៗ ។ តាំងពីពេលនោះមក ព្រះរាជា ទ្រង់មានព្រះវរកាយរីករាយសប្បាយគ្មានទុក្ខ ដូចពេលមុនឡើយ ។ ក្នុងកាលមុន ព្រះរាជា ទ្រង់បានធ្វើសង្គ្រាម ជាមួយព្រះបាទអជាតសត្រូវ តែឥឡូវនេះ ព្រះអង្គទ្រង់បានស្រុះស្រួល ឈប់ច្បាំងជាមួយនឹងព្រះបាទអជាតសត្រូវទៀតហើយ ទ្រង់មានព្រះមេត្រីភាព យ៉ាងជិតស្និទ្ធនឹងគ្នា ទ្រង់បានព្រះរាជទានព្រះរាជធីតា វជិរកុមារី ថ្វាយព្រះបាទអជាសត្រូវ ។

កែវមណីពីបុរាណ ជារបស់ព្រះបាទកុសរាជ ដែលធ្លាក់មកលើព្រះអង្គ ហើយបានបាត់ទៅ ឥឡូវនេះ ក៏បានត្រឡប់មកលើព្រះអង្គ ដូចដើមវិញ ។ ព្រះរាជា ទ្រង់មានព្រះទ័យចង់ជិតស្និទ្ធ ជាមួយព្រះបរមសាស្តា ទើបឲ្យសុំព្រះរាជធីតា អំពីសាក្យវង្ស ទ្រង់ព្រះនាមវាសភខត្តិយា ជាព្រះរាជធីតា របស់ព្រះមហានាមសាក្យរាជ មកធ្វើអភិសេក ជាព្រះអគ្គមហេសី ដើម្បីជាផ្លូវដែលធ្វើឲ្យមានសេចក្តីស្និទ្ធស្នាល ជាមួយនឹងព្រះសាវ័កទាំងឡាយ, ព្រះរាជា ទ្រង់អាស្រ័យនូវហេតុទាំងអស់នេះហើយ ទើបមានព្រះហឫទ័យសោមនស្សរីករាយ

យ៉ាងក្រៃលែង ហើយបានស្ដេចយាងចូលទៅ ក្រាបថ្វាយបង្គំ ទូលរឿងទាំងអស់នោះ ដល់ព្រះសាស្ដា ។

ព្រះសាស្ដា ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

**អារោគ្យបរមា លាភា សន្តុដ្ឋិ បរមំ ធនំ**
**វិស្សាសបរមា ញាតី និព្វានំ បរមំ សុខំ ។**

ការមិនមានរោគ ជាលាភ យ៉ាងក្រៃលែង, សេចក្ដីសន្ដោសតាមមានតាមបាន ជាទ្រព្យ យ៉ាងក្រៃលែង, សេចក្ដីស្និទ្ធស្នាលនឹងគ្នា ជាញាតិ យ៉ាងក្រៃលែង, ព្រះនិព្វាន ជាសុខ យ៉ាងក្រៃលែង ។

♣ ♣ ♣

## ១៦៣- រឿង ព្រះតិស្សត្ថេរ

ព្រះបរមសាស្ដា ទ្រង់ប្រារព្ធ នូវព្រះតិស្សត្ថេរ ក្នុងថ្ងៃដែលព្រះអង្គទ្រង់ដាក់នូវព្រះជន្មាយុសង្ខារ ដើម្បីយាងចូលនិព្វាន ក្នុងថ្ងៃពេញបូណ៌មី នាខែវិសាខ ។

ក្នុងគ្រានោះ ភិក្ខុទាំងឡាយ មានសេចក្ដីតក់ស្លុត រន្ធត់ចិត្តយ៉ាងខ្លាំង ប្រជុំគ្នាជាពួកជាក្រុម ។ ចំណែក ព្រះតិស្សត្ថេរ មិនបានចូលទៅប្រជុំ ជាមួយភិក្ខុទាំងនោះទេ តែបានគិតថា "អាត្មាអញ ត្រូវតែខំប្រឹងប្រែង ព្យាយាមបំពេញគុណធម៌ ដើម្បីឲ្យបានសម្រេចព្រះអរហត្តផល ក្នុងពេលព្រះសាស្ដា ទ្រង់មានព្រះជន្មាយុនៅឡើយ" លុះគិតស្រេចហើយ ក៏បានគេចចេញទៅតែម្នាក់ឯង ដើម្បីបំពេញសមណធម៌ ។ ភិក្ខុទាំងឡាយបានចោទព្រះថេរៈថា "មិនមានសេចក្ដី

ស្រឡាញ់ចំពោះព្រះសាស្តា" ហើយនាំយករឿងនោះ ទៅក្រាបទូលដល់ព្រះសាស្តា ។

ព្រះសាស្តា ទ្រង់បានត្រាស់បញ្ជាឲ្យភិក្ខុទៅនិមន្តព្រះថេរៈមកដើម្បីត្រាស់សួរ ។ ព្រះថេរៈ បានក្រាបទូលការនឹកគិត របស់ខ្លួនដល់ព្រះអង្គ ។

ព្រះសាស្តា ទ្រង់បានប្រទាន នូវសព្ទសាធុការ ថា "សាធុៗ" ហើយទ្រង់ត្រាស់ឲ្យភិក្ខុទាំងឡាយយកធ្វើជាគំរូ ទ្រង់ត្រាស់សរសើរនូវធម្មានុធម្មបដិបត្តិ ស្រេចហើយត្រាស់នូវព្រះគាថានេះ ថា ៖

**បវិវេករសំ បិត្វា រសំ ឧបសមស្ស ច**
**និទ្ទរោ ហោតិ និប្បាបោ ធម្មបីតិរសំ បិវំ ។**

ភិក្ខុផឹករសវិវេកផង រសព្រះនិព្វាន ជាទីរម្ងាប់កិលេសផង ផឹករសបីតិ ដែលកើតអំពីធម៌ផង ទើបជាអ្នកមិនមានសេចក្តីក្រវល់ក្រវាយ មិនមានសេចក្តីសៅហ្មងឡើយ ។

♣ ❇ ♣

## ១៦៤- រឿងសក្កទេវរាជ

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវសក្កទេវរាជ ក្នុងគ្រាដែលព្រះអង្គទ្រង់ដាក់នូវព្រះជន្មាយុសង្ខារ ហើយទ្រង់ព្រះប្រឈួន យ៉ាងធ្ងន់ ។

ក្នុងពេលនោះ សក្កទេវរាជស្តេចយាងមកធ្វើជាគិលានុបដ្ឋាកបំរើព្រះសាស្តា ពេលលើកយកនូវភាជនៈសម្រាប់ដាក់ឧច្ចារៈនៃព្រះ

## គាថាធម្មបទប្រែ

*សាស្តា ទ្រង់ទូលលើសិរសា យកទៅចោល ឥតមានការខ្ពើមរអើម បន្តិចឡើយ សូម្បីតែព្រះភក្ត្រ ក៏មិនស្រពោនក្រៀមក្រំដែរ, លុះព្រះសាស្តា ទ្រង់ជាសះស្បើយហើយ, សក្កទេវរាជ ក៏បានត្រឡប់ទៅកាន់ទេវលោកវិញ ។*

*ភិក្ខុទាំងឡាយ បានប្រជុំគ្នា ពោលសរសើរនូវសក្កទេវរាជ ។ ព្រះសាស្តា ស្តេចយាងមក ក្នុងទីប្រជុំនោះ ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ការដែលសក្កទេវរាជ បានធ្វើយ៉ាងនេះ មិនមែនជាការអស្ចារ្យទេ ព្រោះតថាគត មិនបានធ្វើឲ្យសក្កទេវរាជ សម្រេចនូវសោតាបត្តិផល ផ្លាស់អត្តភាពចាស់ កាន់យកអត្តភាពកំលោះ" ដូច្នេះហើយ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា៖*

សាធុ ទស្សនមរិយានំ សន្និវាសោ សទា សុខោ
អទស្សនេន ពាលានំ និច្ចមេវ សុខី សិយា ។
ពាលសង្គតចារី ហិ ទីឃមទ្ធាន សោចតិ
ទុក្ខោ ពាលេហិ សំវាសោ អមិត្តេនេវ សព្វទា ។
ធីរោ ច សុខសំវាសោ ញាតីនំវ សមាគមោ

តស្មា ហិ

ធីរញ្ច បញ្ញញ្ច ពហុស្សុតញ្ច
ធោរយ្ហសីលំ វតវន្តមរិយំ
តំ តាទិសំ សប្បុរិសំ សុមេធំ
ភជេថ នក្ខត្តបថំវ ចន្ទិមា ។

## រឿង តយោបព្វជិត

ការបានឃើញ នូវព្រះអរិយបុគ្គលទាំងឡាយ ជាការប្រពៃ, ការនៅរួមជាមួយព្រះអរិយបុគ្គលទាំងឡាយ ជាហេតុឲ្យកើតសេចក្តីសុខ សព្វកាល, បុគ្គលគប្បីមានសេចក្តីសុខ អស់កាលជានិច្ចបាន ព្រោះមិនបានឃើញនូវបុគ្គលពាលទាំងឡាយ ។

បុគ្គលអ្នកប្រព្រឹត្តសមគប់ ដោយបុគ្គលពាល រមែងសោកស្តាយអស់កាលជាយូរអង្វែង, ការនៅរួមជាមួយនឹងជនពាល រមែងជាទុក្ខ សព្វកាល ដូចការនៅរួមជាមួយនឹងសត្រូវ យ៉ាងដូច្នោះឯង, ចំណែក ការនៅរួមជាមួយនឹងអ្នកប្រាជ្ញ រមែងជាសុខ ដូចការជួបជុំនៃពួកញាតិទាំងឡាយ យ៉ាងនោះដែរ ព្រោះហេតុនោះហើយ បុគ្គលគួរសេពគប់នឹងសប្បុរសជាអ្នកមាំមួនផង មានបញ្ញាផង មានសេចក្តីចេះដឹងច្រើនផង មានកិរិយានាំទៅនូវធុរៈជាប្រក្រតីផង មានសីលវត្តនិង ធុតង្គវត្តផង ជាអ្នកឆ្ងាយចាកកិលេសផង មានប្រាជ្ញាល្អផង ប្រាកដដូច្នោះៗ ឲ្យដូចជាព្រះចន្ទ គប់នូវផ្លូវនៃនក្ខត្តឫក្ស យ៉ាងនោះឯង ។

**ចប់ សុខវគ្គ ទី ១៥**

## បិយវគ្គ ទី ១៦

## ១៦៥- រឿង តយោបព្វជិត

ព្រះបរមសាស្តាទ្រង់ប្រារព្ធនូវបព្វជិត ៣ រូប ។ មានរឿងមកថា: ត្រកូលមួយ មានគ្នា ៣ នាក់ គឺ ម្តាយ កូន និង ឪពុក ។ កូនជា

គាថាធម្មបទប្រែ

*អ្នកមានចិត្តជ្រះថ្លា ក្នុងព្រះពុទ្ធសាសនា បានសុំមាតាបិតាទៅបួស, តែមាតាបិតា មិនព្រមអនុញ្ញាត ឲ្យកូនទៅបួសទេ ។ លុះបានឱកាសល្អហើយ កូននោះ ក៏បានលួចរត់ចេញទៅបួស ។ បិតា បានទៅតាមរកកូន លុះឃើញកូនបួសហើយ ពុំដឹងធ្វើដូចម្ដេច ក៏បានទៅបួសជាមួយនឹងកូនព្រោះមានសេចក្ដីស្រឡាញ់កូនខ្លាំងពេក ។ ចំណែកម្ដាយបានដឹងថា កូន និង ស្វាមី បានចេញទៅបួសហើយ ក៏ចូលទៅបួសក្នុងសំណាក់នៃនាងភិក្ខុនីផងដែរ ។ លុះអ្នកទាំង ៣ នាក់នោះ បួសហើយ ពុំបានធ្វើអ្វីទេ អង្គុយនិយាយគ្នាតែម៉្យាង ថែមទាំងមិនអាចនៅបែកពីគ្នាបានឡើយ ។*

*ព្រះសាស្ដា ទ្រង់ជ្រាបដូច្នោះហើយ ទ្រង់ត្រាស់បញ្ជា ឲ្យភិក្ខុទៅហៅបព្វជិតទាំង ៣ រូបនោះ មកសួររឿងពិត ហើយទ្រង់ត្រាស់នូវព្រះគាថានេះថា ៖*

អយោគេ យុញ្ជមត្តានំ យោគស្មិញ្ចិ អយោជយំ
អត្ថំ ហិត្វា បិយគ្គាហី បិហេតត្តានុយោគិនំ ។
មា បិយេហិ សមាគញ្ឆិ អប្បិយេហិ កុទាចនំ
បិយានំ អទស្សនំ ទុក្ខំ អប្បិយានញ្ច ទស្សនំ ។
តស្មា បិយំ ន កយិរាថ បិយាបាយោ ហិ បាបកោ
គន្ថា តេសំ ន វិជ្ជន្តិ យេសំ នត្ថិ បិយាបិយំ ។

*បុគ្គល កាលប្រកបខ្លួនទុក ក្នុងអំពើដែលមិនគួរប្រកប មិនប្រកបខ្លួន ក្នុងអំពើដែលគួរប្រកប លះបង់ចោល នូវប្រយោជន៍*

*ហើយកាន់យកនូវអារម្មណ៍ ដែលជាទីស្រឡាញ់ពេញចិត្ត រមែងស្រឡាញ់បុគ្គលអ្នកប្រកបតាមខ្លួន ។ បុគ្គល កុំគប់រកសត្វនិងសង្ខារទាំងឡាយ ដែលជាទីស្រឡាញ់ និង មិនជាទីស្រឡាញ់ ក្នុងកាលណាៗឡើយ ព្រោះថា ការមិនចួបប្រសព្វសត្វ និង សង្ខារដែលជាទីស្រឡាញ់ក្តី ការចួបប្រសព្វសត្វ និង សង្ខារមិនជាទីស្រឡាញ់ក្តី ជាហេតុនាំមកនូវសេចក្តីទុក្ខ ។*

*ព្រោះហេតុនោះ បុគ្គលមិនគួរធ្វើសត្វ និង សង្ខារ ឲ្យជាទីស្រឡាញ់ឡើយ ព្រោះការព្រាត់ប្រាសចាកសត្វ និង សង្ខារ ដែលជាទីស្រឡាញ់ ជាសភាពអាក្រក់, ការស្រឡាញ់ និង ការស្អប់ មិនមានដល់បុគ្គលទាំងឡាយណា, កិលេសជាគ្រឿងចាក់ស្រែះទាំងឡាយ រមែងមិនមាន ដល់បុគ្គលទាំងឡាយនោះ ។*

♣ ♣ ♣

## ១៦៦- រឿង អញ្ញត្រកុដុម្ពី

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវកុដុម្ពីម្នាក់ ។ កុដុម្ពីនោះ កាលបើកូនស្លាប់ហើយ ក៏កើតទុក្ខទោមនស្ស យ៉ាងខ្លាំង បានទៅស្រែកយំក្នុងព្រៃស្មសាន ជារៀងរាល់ថ្ងៃ ។*

*ព្រះសាស្តា ទ្រង់ទតព្រះនេត្រឃើញឧបនិស្ស័យ នៃសោតាបត្តិផលហើយ ស្តេចយាងទៅកាន់ផ្ទះកុដុម្ពីនោះ ទ្រង់សំដែងធម្មីកថាត្រាស់នូវព្រះគាថានេះ ថា ៖*

**បិយតោ ជាយតេ សោកោ បិយតោ ជាយតេ ភយំ**

គាថាធម្មបទប្រែ

**បិយតោ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ ។**

*សេចក្តីសោកកើតពីសេចក្តីស្រឡាញ់, ភ័យ កើតអំពីសេចក្តីស្រឡាញ់, កាលបើបុគ្គលបានរួចស្រឡះ ចាកសេចក្តីស្រឡាញ់ហើយ សេចក្តីសោក ក៏លែងមាន ភ័យនឹងមានមកអំពីណា ។*

## ១៦៧- រឿង នាងវិសាខា

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវនាងវិសាខាមហាឧបាសិកា ។ នាងវិសាខា បានឲ្យនាងសុទត្តី ដែលជាធីតា របស់កូនប្រុសនាង ធ្វើជាអ្នកបម្រើព្រះសង្ឃជំនួសខ្លួន ។ ពេលដែលនាងសុទត្តី ធ្វើកាល-កិរិយាទៅហើយ មហាឧបាសិកា វិសាខា មានសេចក្តីសោកសៅអាឡោះអាល័យ យ៉ាងខ្លាំង ហើយបានចូលទៅក្រាបទូល ដល់ព្រះសាស្តា ។*

*ព្រះសាស្តា ទ្រង់សម្តែងធម្មីកថា ត្រាស់នូវព្រះគាថានេះថា ៖*

**បេមតោ ជាយតេ សោកោ បេមតោ ជាយតេ ភយំ**
**បេមតោ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ ។**

*សេចក្តីសោកកើតពីសេចក្តីស្រឡាញ់, ភ័យ កើតអំពីសេចក្តីស្រឡាញ់, កាលបើបុគ្គលបានរួចផុតស្រឡះ ចាកសេចក្តីស្រឡាញ់ហើយ សេចក្តីសោក ក៏លែងមាន ភ័យនឹងមានមកអំពីណា ។*

❇ ❇ ❇

## ១៦៨- រឿង ក្សត្រលិច្ឆវី

ព្រះបរមសាស្ដា ទ្រង់ប្រារព្ធនូវពួកក្សត្រលិច្ឆវី ដែលទ្រង់ប្រដាប់ប្រដាគ្រឿងអលង្ការគ្រប់បែបយ៉ាង ដូចជាពួកទេវតា ទាវតាំងត្រៃត្រិង្សទេវលោក ស្ដេចយាងទៅកំសាន្តព្រះឧទ្យានហើយ បានដណ្ដើមយកស្រីសោភេណីម្នាក់ រហូតដល់កាប់សម្លាប់គ្នា ឈាមដាបពោះដំរី បីដូចជាទឹកសមុទ្រ ។

ព្រះសាស្ដា ស្ដេចយាងទៅបិណ្ឌបាត ជាមួយភិក្ខុសង្ឃ ក្នុងក្រុងវេសាលី ទ្រង់ទតព្រះនេត្រឃើញនូវហេតុនេះហើយ ទើបទ្រង់ត្រាស់ ថា "ម្នាលភិក្ខុទាំងឡាយ សេចក្ដីសោកក្ដី ភ័យក្ដី កាលកើតឡើង រមែងអាស្រ័យនូវសេចក្ដីត្រេកត្រអាល ទើបកើតឡើងបាន" ដូច្នេះហើយ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

**រតិយា ជាយតេ សោកោ  រតិយា ជាយតេ ភយំ**
**រតិយា វិប្បមុត្តស្ស  នត្ថិ សោកោ កុតោ ភយំ ។**

សេចក្ដីសោក កើតមកអំពីតម្រេក ភ័យកើតមកអំពីតម្រេក កាលបុគ្គលរួចស្រឡះ ចាកតម្រេកហើយ សេចក្ដីសោក ក៏លែងមាន ភ័យនឹងមានមកអំពីណា ។

♣ ♣ ♣

## ១៦៩- រឿង អនិត្ថិគន្ធកុមារ

ព្រះបរមសាស្ដា ទ្រង់ប្រារព្ធនូវអនិត្ថិគន្ធកុមារ ដែលច្យុត ពីព្រហ្មលោក មកកើតក្នុងត្រកូលអ្នកមានទ្រព្យសម្បត្តិស្ដុកស្ដម្ភ ក្នុងទីក្រុងសាវត្ថី ។ តាំងតែពីខ្លួននៅវ័យជាកុមារ អនិត្ថិគន្ធកុមារនេះ មិន

ចង់ឲ្យពួកស្រីៗ មកប៉ះពាល់រាងកាយខ្លួនសោះ បើមានស្រីណាម្នាក់បានមកប៉ះពាល់រាងកាយហើយ ក៏ស្រែកយំ, ពេលណាដែលស្រីមេដោះ យកទឹកដោះមកឲ្យបៅ ត្រូវតែយកសំពត់មកទ្រាប់ ជាមុនសិន ទើបលើកចាប់បី-ពខ្លួនបាន... លុះដល់ពេញកំលោះហើយ ក៏មិនចូលចិត្តស្រីៗ ដែរ ។

មាតាបិតា បានអង្វរករ ច្រើនលើកច្រើនគ្រា ចង់ឲ្យកូនមានភរិយា, អនិត្ថិគន្ធកុមារ បាននិយាយទៅកាន់មាតាបិតា ថា "បើបានស្រីដែលមានរូបស្អាត ទើបខ្ញុំសុខចិត្តយកធ្វើជាភរិយា" ។ មាតាបិតាបានជួលជាងឲ្យធ្វាក់រូបស្រីមួយ យ៉ាងស្អាតអស្ចារ្យ ដែលស្អិតស្អាងខ្លួនសុទ្ធតែមាសទាំងអស់ដើម្បីឲ្យកូនមើល ។ អនិត្ថិគន្ធកុមារ គ្រាន់តែបានឃើញរូបចម្លាក់ដែលស្អាតនោះភ្លាម ក៏កើតសេចក្តីស្រឡាញ់ចង់បានភរិយា យ៉ាងខ្លាំង ហើយប្រាប់មាតាបិតា ថា "បើរកស្រីដែលមានរូបស្អាត ដូចជារូបចម្លាក់ស្រីនេះ ទើបខ្ញុំព្រមយក" ។ មាតាបិតាបានឲ្យគេដើរទៅស្វែងរកស្រីណាដែលមានរូបស្អាត គ្រប់ភូមិស្រុកនិគម ជនបទ តូចធំ រហូតដល់បានចួបប្រទះនឹងស្រីក្រមុំម្នាក់ នៅក្នុងសាគលនគរ ជាស្រីដែលមានរូបស្អាត ជាងរូបចម្លាក់មាសនោះទៅទៀត ។

គ្រានោះ អនិត្ថិគន្ធកុមារ គ្រាន់តែបានឮថា ស្រីដែលរកបាននោះ ជាស្រីមានរូបរាងស្អាត ជាងរូបចម្លាក់មាស ក៏មានចិត្តត្រេកអរយ៉ាងខ្លាំង ហើយបានឲ្យមាតាបិតាប្រញាប់ ចូលទៅស្តីដណ្តឹងនាង

នោះមកឲ្យបាន ។

មាតាបិតា ក៏បានប្រញាប់ចូលទៅស្តីដណ្តឹងនាងនោះ តាមច្បាប់ប្រពៃណី លុះស្តីដណ្តឹងបានហើយ ក៏នាំនាងនោះមក កាន់ផ្ទះរបស់ខ្លួន ពេលធ្វើដំណើរមកដល់ពាក់កណ្តាលផ្លូវ, ស្រីក្រមុំនោះ ក៏បានធ្វើកាលកិរិយា ។

អនិត្ថិគន្ធកុមារ លុះបានដឹងថា នាងបានស្លាប់ហើយ នៅតាមផ្លូវ ក៏កើតទុក្ខទោមនស្ស សោកស្តាយនាង យ៉ាងក្រៃលែង ។

ព្រះសាស្តា ទ្រង់ទតព្រះនេត្រឃើញឧបនិស្ស័យ នៃសោតាបត្តិផល របស់អនិត្ថិគន្ធកុមារនោះហើយ ទើបទ្រង់សម្តែងធម្មីកថា ដើម្បីរម្ងាប់នូវសេចក្តីសោកសៅ ឲ្យបានធូរស្រាលហើយ ទើបព្រះអង្គត្រាស់នូវព្រះគាថានេះ ថា ៖

**កាមតោ ជាយតេ សោកោ កាមតោ ជាយតេ ភយំ**
**កាមតោ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ ។**

សេចក្តីសោក កើតមកអំពីកាម ភ័យកើតមកអំពីកាម, កាលបើបុគ្គលរួចស្រឡះចាកកាមហើយ សេចក្តីសោក ក៏លែងមាន ភ័យនឹងមានមកអំពីណា ។

❋ ❋ ❋

## ១៧០- រឿង អញ្ញត្រព្រាហ្មណ៍

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវព្រាហ្មណ៍ម្នាក់ ជាអ្នកមិច្ឆាទិដ្ឋិ បានទៅធ្វើស្រែ ក្នុងឯស្រុកមួយ ។ ព្រះអង្គ ទ្រង់បានទតព្រះនេត្រ

-២៧១-

## គាថាធម្មបទប្រែ

*ឃើញនូវឧបនិស្ស័យនៃសោតាបត្តិផល របស់ព្រាហ្មណ៍នោះហើយ ទើបទ្រង់យាងទៅប្រាស្រ័យសន្ទនា ជាមួយគាត់រឿយៗ រហូតដល់ព្រាហ្មណ៍កើតមានសេចក្ដីជ្រះថ្លា ស្រឡាញ់រាប់អានព្រះអង្គ ហើយបានស្និទ្ធស្នាល ជាមួយនឹងព្រះអង្គ ដូចជាមិត្រសម្លាញ់ ។*

*ថ្ងៃមួយ ព្រាហ្មណ៍នោះ បានក្រាបទូលព្រះសាស្ដាថា "បពិត្រព្រះអង្គដ៏ចំរើន បើខ្ញុំម្ចាស់បានស្រូវល្អបរិបូណ៌ហើយ ខ្ញុំម្ចាស់ នឹងចែកឲ្យដល់សម្លាញ់ខ្លះ" ។ ក្នុងរាត្រីថ្ងៃមួយ មានភ្លៀងធ្លាក់មក ជាច្រើន បានធ្វើឲ្យស្រូវស្រែគាត់ខូចខាតអស់គ្មានសល់ ។ ព្រឹកឡើង ព្រាហ្មណ៍ បានទៅឃើញស្រូវស្រែខូចអស់ហើយ ក៏កើតទុក្ខសោកស្ដាយ យ៉ាងខ្លាំង ។*

*ព្រះសាស្ដា ស្ដេចយាងទៅកាន់ផ្ទះ របស់ព្រាហ្មណ៍ ហើយទ្រង់បានសម្ដែងធម៌ីកថា ដើម្បីរម្ងាប់នូវសេចក្ដីសោកស្ដាយ របស់ព្រាហ្មណ៍ ហើយត្រាស់នូវព្រះគាថានេះ ថា ៖*

តណ្ហាយ ជាយតេ សោកោ តណ្ហាយ ជាយតេ ភយំ
តណ្ហាយ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ ។

*សេចក្ដីសោក កើតមកអំពីតណ្ហា, ភ័យ កើតមកអំពីតណ្ហា, កាលបើបុគ្គលរួចស្រឡះ ចាកតណ្ហាហើយ សេចក្ដីសោក ក៏លែងមាន ភ័យនឹងមានមកអំពីណា ។*

♣ ♣ ♣

## ១៧១- រឿង បញ្ចសតទារក

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវកុមារ ៥០០ នាក់ ។ ក្នុងថ្ងៃលេងមហោស្រព កុមារទាំងនេះ បាននាំគ្នាទៅលេងសួនច្បារហើយ បានចួបប្រទះនឹងព្រះពុទ្ធ ព្រមទាំងព្រះភិក្ខុសង្ឃ នាកណ្តាលផ្លូវ លុះក្រឡេកឃើញព្រះមហាកស្សបៈ ក៏កើតសេចក្តីជ្រះថ្លា បានប្រគេននំដល់ព្រះថេរៈ ។ ភិក្ខុទាំងឡាយ បានតិះដៀលនូវកុមារទាំងនោះ ថា "ធ្វើបុណ្យរើសមុខ" ។

ព្រះសាស្តា ទ្រង់សម្តែងធម្មិកថា ត្រាស់នូវព្រះគាថានេះថា ៖

**សីលទស្សនសម្បន្នំ ធម្មដ្ឋំ សច្ចវាទិនំ**
**អត្តនោ កម្មកុព្វានំ តំ ជនោ កុរុតេ បិយំ ។**

ជន តែងធ្វើបុគ្គលដែលបរិបូណ៌ ដោយសីល និង ទស្សនៈ ឋិតនៅក្នុងធម៌ ពោលតែពាក្យពិតជាប្រក្រតី ធ្វើកម្មជារបស់ខ្លួននោះ ឲ្យជាទីស្រឡាញ់ពេញចិត្ត ។

## ១៧២- ព្រះអនាគាមិត្ថេរ

ព្រះបរមសាស្តា ទ្រង់ប្រារព្ធ នូវព្រះអនាគាមិថេរ មួយរូប ។ ពួកអន្តេវាសិកទាំងឡាយ របស់ព្រះថេរៈ បានសួរនូវគុណធម៌ ដែលមាននៅ ក្នុងខ្លួនលោក ។ ព្រះថេរៈ មានការខ្មាសអៀន យ៉ាងខ្លាំង ហើយគិតថា "សូម្បីតែពួកគ្រហស្ថ ក៏គេបានសម្រេចអនាគាមិផលដែរ, ចាំដល់អាត្មាអញ បានសម្រេចអរហត្តផលហើយ សឹមប្រាប់ដល់ពួកអន្តេវាសិក ជាខាងក្រោយ" ។ តែអនិច្ចា ព្រះថេរៈ មិនទាន់

បានសម្រេចអរហត្តផលផង ក៏បានធ្វើមរណកាល ហើយបានទៅកើត ក្នុងសុទ្ធាវាសទេវលោក ។

ពួកអន្តេវាសិក នាំគ្នាស្រែកយំខ្សឹកខ្សួល ហើយនាំយករឿងនេះ ទៅក្រាបទូលដល់ព្រះសាស្តា ។

ព្រះសាស្តា ទ្រង់សម្តែងធម្មីកថា ដើម្បីរម្ងាប់នូវការយំសោកខ្សឹកខ្សួល ទ្រង់សម្តែងសម្បរាយិកភព របស់ព្រះថេរៈ ស្រេចហើយ ទើបទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

ឆន្ទជាតោ អនក្ខាតេ មនសា ច ផុដ្ឋោ សិយា
កាមេសុ អប្បដិពទ្ធចិត្តោ ឧទ្ធំសោតោតិ វុច្ចតិ ។

បុគ្គល អ្នកមានសេចក្តីប្រាថ្នា ចំពោះព្រះនិព្វាន ដែលគេនិយាយប្រាប់គ្នាមិនបានផង ជាអ្នកមានមគ្គចិត្ត និង ផលចិត្ត (ខាងក្រោម) ប៉ះពាល់ហើយផង មានចិត្តមិនប្រតិព័ទ្ធ ក្នុងកាមទាំងឡាយផង តថាគត ហៅថា ជាអ្នកមានខ្សែមគ្គប្រព្រឹត្តទៅ ក្នុងខាងលើ ។

❉ ❉ ❉

## ១៧៣- រឿងនន្ទិយឧបាសក

ព្រះបរមសាស្តា ទ្រង់ប្រារព្ធ នូវនន្ទិយឧបាសក ជាកូនរបស់ជនអ្នកមានសទ្ធាជ្រះថ្លា ក្នុងព្រះពុទ្ធសាសនា គាត់ជាអនុជាតបុត្រ ។ ពេលដែលមាតាបិតាធ្វើមរណកាលទៅហើយ នន្ទិយឧបាសកក៏បានឡើងជាមហាទានបតី ថ្វាយទានដល់ភិក្ខុសង្ឃ និង ឲ្យទានដល់អ្នកកំសត់ទុគ៌តក្រីក្រ ហើយកសាងសាលា ៤ មុខ មាន ៤ បន្ទប់ ក្នុង

រឿង នន្ទិយឧបាសក

មហាវិហារ នាព្រៃឥសិបតនមិគទាយវ័នព្រមទាំងគ្រឿងសេនាសនៈ វេរប្រគេនព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ហើយច្រួចទឹក លើព្រះហស្ត របស់ព្រះសាស្តា ។

ពេលនោះ ប្រាសាទទិព្វប្រកបដោយកែវ ៧ ប្រការ មានទំហំ ១២ យោជន៍ កំពស់ ១០០ យោជន៍ ពេញដោយនាងទេពធីតា បានកើតឡើង ក្នុងទេវលោក សម្រាប់នន្ទិយឧបាសកនោះ ។

សម័យមួយ ព្រះមហាមោគ្គល្លានត្ថេរ បាននិមន្តទៅកាន់ឋានទេវលោក ហើយឃើញប្រាសាទទិព្វនោះ ទើបសួរទេវបុត្រទាំងនោះថា "ប្រាសាទទិព្វនេះ ជារបស់អ្នកណា?" ។ ពួកទេវបុត្រ ឆ្លើយថា "ជារបស់នន្ទិយឧបាសក" ។ ចំណែកនាងទេពធីតា ដែលនៅចាំរក្សាប្រាសាទនោះ បានផ្តាំផ្ញើជាមួយនឹងព្រះថេរៈថា "សូមព្រះគុណម្ចាស់មេត្តាប្រាប់ ដល់នន្ទិយឧបាសក ឲ្យគាត់ឆាប់មកកើត ក្នុងទេវលោកនេះផង" ។

ព្រះមហាមោគ្គល្លាន លុះត្រឡប់មកកាន់មនុស្សលោកវិញហើយ ក៏បានចូលទៅក្រាបទូលរឿងនេះ ថ្វាយដល់ព្រះសាស្តា ។

ព្រះបរមសាស្តាចារ្យ លុះទ្រង់ជ្រាបហើយ ទើបទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

ចិរប្បវាសឹ បុរិសំ ទូរតោ សោត្ថិមាគតំ
ញាតី មិត្តា សុហជ្ជា ច អភិនន្ទន្តិ អាគតំ
តថេវ កតបុញ្ញម្បិ អស្មា លោកា បរំ គតំ

គាថាធម្មបទប្រែ

**បុញ្ញានិ បដិគណ្ហន្តិ  បិយំ ញាតីវ អាគតំ ។**

*ពួកញាតិក្តី មិត្រក្តី សំឡាញ់ក្តី រមែងត្រេកអរនឹងបុរសដែលឃ្លាតគ្នា អស់កាលដ៏យូរអង្វែង មកអំពីចម្ងាយដោយសួស្តី មកដល់ហើយ យ៉ាងណាមិញ, បុណ្យទាំងឡាយ តែងទទួលបុគ្គលដែលបានធ្វើបុណ្យហើយ ច្យុតអំពីមនុស្សលោកនេះ ទៅកាន់លោកខាងមុខ ដូចញាតិទាំងឡាយ ចាំទទួលបុរសដែលជាទីស្រឡាញ់ ទើបមកដល់ យ៉ាងនោះដែរ ។*

**ចប់ បិយវគ្គ ទី ១៦**

កោធវគ្គ ទី ១៧

១៧៤- រឿង ព្រះនាងរោហិណី

*ព្រះបរមសាស្តា ទ្រង់បានប្រារព្ធនូវព្រះនាងរោហិណី ជាព្រះកនិដ្ឋភគិនីរបស់ព្រះអនុរុទ្ធត្ថេរ ។ ព្រះនាងរោហិណី កើតរោគស្រែងរមាស់ មានសេចក្តីអៀនខ្មាស យ៉ាងខ្លាំង លាក់ខ្លួនពួនអាត្មា មិនចង់ឲ្យអ្នកណាម្នាក់ ឃើញរូបព្រះនាងឡើយ ។*

*ព្រះអនុរុទ្ធត្ថេរ បាននិមន្តទៅ និយាយពន្យល់ ឲ្យនាងបរិច្ចាគគ្រឿងអលង្ការ របស់នាង យកទៅកសាងសាលាមួយខ្នង សម្រាប់ឈប់សំរាក ដើម្បីឲ្យរោគស្រែងរមាស់របស់នាងបានជាសះស្បើយអស់ទៅ ។*

*ព្រះនាងរោហិណី បានធ្វើតាមព្រះថេរៈ លុះកសាងសាលា*

រួចអស់ហើយ ក៏បាននិមន្តព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន មកទទួលភត្តាហារ ជាការឆ្លងសាលា ។

ព្រះសាស្តា ទ្រង់បានត្រាស់ ឲ្យគេទៅតាមនាងរោហិណី មកហើយ ត្រាស់ទេសនាអំពីបុព្វកម្មរបស់នាង ថា "ក្នុងអតីតជាតិ នាងរោហិណី បានជាអគ្គមហេសី របស់ព្រះរាជាក្រុងពារាណសី នាងមានសេចក្តីប្រណែន នឹងស្រីស្នំម្នាក់ ហើយបានយកខ្ទេរ ទៅរោយលើគ្រែដេក លើសម្លៀកបំពាក់ និង រោយលើខ្លួនស្រីស្នំនោះ ទៀតផង ។ ដោយសារខ្ទេរដែលនៅលើគ្រែ និង លើសម្លៀកបំពាក់ បានប៉ះពាល់លើខ្លួនស្រីស្នំនោះ ធ្វើឲ្យនាងកើតជារមាស់ ពាសពេញខ្លួនប្រាណ អេះឡើងកន្ទួលធំៗ មានទុក្ខវេទនា យ៉ាងខ្លាំងក្លា... ព្រោះបាបកម្មដែលនាងរោហិណី រោយខ្ទេរលើស្រីស្នំនេះ ឲ្យផល ទើបនាងកើតមានរោគស្រែង រមាស់ពាសពេញខ្លួន ក្នុងជាតិនេះ យ៉ាងដូច្នេះ" ក្នុងទីបញ្ចប់នៃអតីតនិទាន ព្រះអង្គត្រាស់នូវព្រះគាថានេះថា៖

កោធំ ជហេ វិប្បជហេយ្យ មានំ
សញ្ញោជនំ សព្វមតិក្កមេយ្យ
តំ នាមរូបស្មិមសជ្ជមានំ
អកិញ្ចនំ នានុតបន្តិ ទុក្ខា ។

បុគ្គលគួរលះបង់សេចក្តីក្រោធចេញ គួរលះបង់មានះចេញ គួរកន្លងសញ្ញោជនធម៌ ទាំងអស់ចោលចេញ, ទុក្ខទាំងឡាយ តែងមិនជាប់តាមបុគ្គលដែលមិនជំពាក់ ក្នុងនាម និងរូប មិនមានកិលេស

គ្រឿងកន្ទល់នោះ ។

♣ ♣ ♣

## ១៧៥- រឿងអញ្ញតរភិក្ខុ

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវភិក្ខុមួយរូប ក្នុងសម័យដែលព្រះអង្គមិនទាន់បានបញ្ញត្តសិក្ខាបទ ហាមមិនឲ្យភិក្ខុកាប់ដើមឈើ ។ ភិក្ខុរូបនេះ មានគម្រោងការចង់កសាងសេនាសនៈ, ថ្ងៃមួយ ភិក្ខុនោះឃើញដើមឈើ ដែលជាទីពេញចិត្ត មួយដើមយ៉ាងធំ ហើយគិតនឹងកាប់ ។

នៅលើដើមឈើនោះ មានរុក្ខទេវតា ដែលមានកូនខ្ចីមួយអង្គនៅអាស្រ័យ, រុក្ខទេវតានោះ បានសុំអង្វរករនឹងភិក្ខុរូបនោះ ដើម្បីកុំឲ្យកាប់ដើមឈើ ដែលជាទីនៅអាស្រ័យរបស់ខ្លួន ។ តែភិក្ខុរូបនោះមិនព្រមស្តាប់ នូវពាក្យសុំអង្វរករ របស់រុក្ខទេវតានោះឡើយ នៅតែចចេសកាប់ ធ្វើដូចជាមិនដឹង រហូតដល់ផ្ទៃប៉ូវថៅត្រូវដៃ របស់កូនរុក្ខទេវតា ដាច់បាត់ទៅ ។

រុក្ខទេវតា បានឃើញយ៉ាងនេះហើយ មានសេចក្តីក្រោធខឹងនឹងភិក្ខុរូបនោះ យ៉ាងខ្លាំង គិតនឹងសម្លាប់ភិក្ខុនោះចោល តែបាននឹកគិតទាន់ ថា "ភិក្ខុនេះ ជាអ្នកមានសីល បើអាត្មាអញ សម្លាប់លោកឲ្យស្លាប់ អាត្មាអញ នឹងត្រូវទទួលទុក្ខ ក្នុងអបាយភូមិ អស់ជាច្រើនឆ្នាំ ហើយពួកទេវតាទាំងឡាយ ក៏នឹងយកធ្វើជាគំរូ តាមអាត្មាអញ, មួយទៀត ភិក្ខុរូបនេះជាអ្នកមានម្ចាស់ ត្រូវតែអាត្មាអញ ទៅក្រាប

ទូលដល់ម្ចាស់ ទើបជាការប្រពៃ” គិតស្រេចហើយ ក៏ដើរស្រែយំតាមដងផ្លូវ ហើយបានទៅក្រាបទូល ដល់ព្រះសាស្តា ។

ព្រះបរមសាស្តាចារ្យ ទ្រង់ជ្រាបសេចក្តីនោះ សព្វគ្រប់អស់ហើយ ទ្រង់សម្តែងធម្មីកថា ស្រេចកាលណាហើយ ក៏ទ្រង់ត្រាស់ព្រះគាថានេះ បញ្ជាក់ថែមទៀត ថា ៖

**យោ វេ ឧប្បតិតំ កោធំ  រថំ ភន្តំវ ធារយេ**
**តមហំ សារថឹ ព្រូមិ  រស្មិគ្គាហោ ឥតរោ ជនោ ។**

បុគ្គលណា ឃាត់សេចក្តីក្រោធ ដែលកើតឡើងហើយ ដូចសារថី ទប់រថ ដែលកំពុងលឿនបាន, តថាគត ហៅបុគ្គលនោះ ថាជាសារថី, ជនក្រៅពីនេះ គ្រាន់តែជាអ្នកកាន់ខ្សែបរទេ (មិនមែនជាសារថីឡើយ) ។

## ១៧៦- រឿង នាងឧត្តរាឧបាសិកា

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវនាងឧត្តរា ឧបាសិកា ជាធីតារបស់បុណ្ណសេដ្ឋី ។ នាងឧត្តរា ឧបាសិកា នេះ ជាសោតាបន្នបុគ្គល, ឯស្វាមី របស់នាង ជាសេដ្ឋីបុត្រ ក្នុងក្រុងរាជគ្រឹះ ត្រកូលស្វាមីនាងជាអ្នកមិច្ឆាទិដ្ឋិ ។

នាងឧត្តរា មិនបានទៅធ្វើបុណ្យ តាមចិត្តនាងប្រាថ្នាទេ នាងបានជួលនាងសិរិមា ដែលជាស្រីផ្កាមាស ឲ្យមកនៅរួមជាមួយស្វាមីរបស់ខ្លួន ហើយបានលបលាក់ទៅធ្វើបុណ្យទាន មិនឲ្យស្វាមីដឹង នៅ

ឯខាងក្រៅ ។

ចំណែកឯ នាងសិរិមានោះ មានគំនិត គិតនឹងដណ្តើមស្វាមីរបស់នាងឧត្តរា ចង់ត្រួតត្រាមកលើនាង ហើយបានទៅប្រទូសរ៉ាយចំពោះនាងឧត្តរា ដោយប្រការផ្សេងៗ តែនាងឧត្តរាឧបាសិកា មិនបានក្រោធខឹងនឹងនាងសិរិមាវិញឡើយ ។ ក្រោយមក នាងសិរិមាបានដឹងទោសកំហុស របស់ខ្លួនហើយ ទើបបានទៅសុំខមាទោសនឹងនាងឧត្តរា ។ នាងឧត្តរា ក៏បាននាំនាងសិរិមា ទៅគាល់ព្រះសាស្តា ។

ព្រះសាស្តាសម្តែងធម្មីកថា ហើយត្រាស់នូវព្រះគាថានេះថា៖

**អក្កោធេន ជិនេ កោធំ អសាធុំ សាធុនា ជិនេ**
**ជិនេ កទរិយំ ទានេន សច្ចេនាលិកវាទិនំ ។**

បុគ្គល គប្បីផ្ចាញ់មនុស្សក្រោធ ដោយសេចក្តីមិនក្រោធ គប្បីផ្ចាញ់មនុស្សអសប្បុរស ដោយសប្បុរស គប្បីផ្ចាញ់មនុស្សកំណាញ់ ដោយការឲ្យ គប្បីផ្ចាញ់មនុស្សនិយាយពាក្យដែលមិនពិតដោយពាក្យពិត ។

♣ ♣

## ១៧៧- រឿងមោគ្គល្លានត្ថេរប្បញ្ហា

ព្រះបរមសាស្តា ទ្រង់បានប្រារព្ធនូវបញ្ហា របស់ព្រះមហាមោគ្គល្លាន ។ សម័យថ្ងៃមួយ ព្រះថេរៈ បាននិមន្តទៅកាន់ឋានទេវលោក បានសួរពួកនាងទេវធីតា ដែលនាំគ្នាមកថ្វាយបង្គំថា "តើនាងទាំងអស់គ្នា បានធ្វើបុណ្យអ្វីដែរ បានជាមកកើត ក្នុងទីនេះ ហើយ

បានសម្បត្តិ យ៉ាងនេះ?" ។

នាងទេវធីតាទាំងនោះ មានការខ្មាសអៀន មិនចង់ពិតទូលព្រះថេរៈ តែត្រូវព្រះថេរៈ ដេញដោលសួរខ្លាំងពេក នាងទេវធីតាខ្លះបានទូលព្រះថេរៈថា "នាងខ្ញុំមិនបានធ្វើបុណ្យអ្វីទេ គ្រាន់តែបានរក្សានូវពាក្យសច្ចៈប៉ុណ្ណោះ" ។ នាងទេវធីតាខ្លះ បានពិតទូល ថា "នាងខ្ញុំមិនបានក្រោធខឹងជាមួយនឹងអ្នកដទៃ" ។ នាងខ្លះ ក៏បានពិតទូល ថា "នាងខ្ញុំបានបរិច្ចាគសម្បត្តិនេះមួយ នោះមួយ ទើបបានសម្បត្តិយ៉ាងដូច្នេះ" ។

ព្រះមហាមោគ្គល្លាន លុះត្រឡប់មកពីទេវលោកវិញ បានចូលទៅ ក្រាបទូលរឿងនេះ ថ្វាយព្រះសាស្តាទ្រង់ជ្រាប ។

ព្រះបរមសាស្តាចារ្យ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

**សច្ចំ ភណេ ន កុជ្ឈេយ្យ ទជ្ជា អប្បំបិ យាចិតោ**
**ឯតេហិ តីហិ ឋានេហិ គច្ឆេ ទេវាន សន្តិកេ ។**

បុគ្គល គួរពោលពាក្យពិត ១ មិនគួរក្រោធ ១ កាលត្រូវគេសូមវត្ថុសូម្បីមានតិច ក៏គួរឲ្យ(តាមតិច) ១, បុគ្គលគប្បីទៅកើត ក្នុងសំណាក់ នៃទេវតាទាំងឡាយបាន ដោយហេតុ ៣ យ៉ាងនេះឯង ។

♣ ♣ ♣

## ១៧៨- រឿងភិក្ខុទូលសួរបញ្ហា

ព្រះបរមសាស្តា កាលអាស្រ័យក្រុងសាកេតុ ប្រថាប់គង់នៅក្នុងក្រុងអញ្ជនវ័ន ទ្រង់ប្រារព្ធនូវបញ្ហា ដែលភិក្ខុទាំងឡាយបានក្រាប

ទូលសួរហើយ ទ្រង់បានសម្តែងព្រះធម្មទេសនានេះ ថា “**អហឹសកា យេ**...” ប៉ុណ្ណោះជាដើម ។

កិរ បានឮថា សម័យដែលព្រះមានព្រះភាគ មានភិក្ខុសង្ឃជាបរិវារ ស្តេចយាងចូលទៅកាន់ទីក្រុងសាកេតុដើម្បីយាងបិណ្ឌបាតប្រោសសត្វនោះ, មានព្រាហ្មណ៍ចាស់ម្នាក់ កំពុងតែដើរចេញអំពីទីក្រុង ស្រាប់តែបានចួបប្រទះនឹងព្រះសាស្តា ក្បែរមាត់ទ្វារក្រុងហើយបានក្រាបរាប ក្បែរព្រះបាទា ក្រាបទូលថា “នែកូនសម្លាញ់ ធម្មតាមាតាបិតា ត្រូវបុត្រធីតាទាំងឡាយទំនុកបំរុង នៅពេលមានវ័យចាស់ជរា មិនមែនទេឬ? ទូលព្រះបង្គំបានឃើញព្រះអង្គហើយ សូមព្រះអង្គ ទ្រង់ព្រះមេត្តា និមន្តទៅសួរសុខទុក្ខនឹងមាតាផង” ដូច្នេះហើយ បានក្រាបទូលអារាធនា ឲ្យព្រះអង្គស្តេចយាងទៅកាន់ផ្ទះរបស់ខ្លួន ។

ព្រះសាស្តា ទ្រង់ស្តេចយាងទៅ កាន់ផ្ទះនោះហើយ ទ្រង់គង់នៅលើអាសនៈ ដែលព្រាហ្មណ៍បានក្រាលទុកហើយ ព្រមទាំងភិក្ខុសង្ឃ ។

ព្រាហ្មណ៍ពីរនាក់ប្តីប្រពន្ធ បានថ្វាយភត្តាហារ ដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ដោយសេចក្តីជ្រះថ្លាបំផុត ហើយបានក្រាបទូលថា “បពិត្រព្រះអង្គដ៏ចំរើន សូមព្រះអង្គទ្រង់ទទួលនូវភត្តាហារក្នុងផ្ទះ របស់ទូលព្រះបង្គំ ជារៀងរាល់ថ្ងៃចុះ” ។

ព្រះសាស្តា ត្រាស់ថា “ម្នាលព្រាហ្មណ៍ ធម្មតាព្រះពុទ្ធទាំងឡាយ នឹងមិនទទួលភត្តាហារ តែក្នុងផ្ទះនៃបុគ្គលម្នាក់ប៉ុណ្ណោះទេ” ។

-២៨២-

រឿង នាងបុណ្ណាទាសី

ភិក្ខុទាំងឡាយ មានការសង្ស័យ បានប្រជុំសន្ទនាគ្នា ថា “តើហេតុអ្វីបានជាព្រាហ្មណ៍ទាំងពីរនាក់ប្តីប្រពន្ធ ហៅព្រះសាស្តា ថា ជាកូនរបស់គាត់ យ៉ាងដូច្នេះ?” ។

ព្រះសាស្តា ស្តេចយាងមកហើយ ត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ ព្រាហ្មណ៍ទាំង ២ នាក់នេះ ធ្លាប់បានកើតជាមាតាបិតាបង្កើតរបស់តថាគត អស់កាលបីពាន់ជាតិមកហើយ ក្នុងអតីតកាល...” ។

កាលព្រាហ្មណ៍ពីរនាក់ប្តីប្រពន្ធ បានសម្រេចនូវអរហត្តផលហើយ បរិនិព្វាន, ពួកភិក្ខុ បានក្រាបទូលសួរសម្បរាយិកភព នឹងព្រះសាស្តា ។

ព្រះបរមសាស្តាចារ្យ ទ្រង់បានត្រាស់នូវព្រះគាថានេះ ថា ៖

**អហឹសកា យេ មុនយោ និច្ចំ កាយេន សំវុតា**
**តេ យន្តិ អច្ចុតំ ឋានំ យត្ថ គន្ត្វា ន សោចរេ ។**

ជនទាំងឡាយណា ជាអ្នកប្រាជ្ញ មិនបៀតបៀនសត្វដទៃ សង្រួមហើយ ដោយកាយទ្វារ (ជាដើម) ជានិច្ច, ជនទាំងឡាយនោះ រមែងទៅ កាន់ឋានដែលមិនចេះប្រែប្រួល ជាឋានដែលគេទៅដល់ហើយ តែងមិនសោកស្តាយ ។

១៧៩- រឿង នាងបុណ្ណាទាសី

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវនាងបុណ្ណទាសី ដែលជាទាសីរបស់សេដ្ឋីក្រុងរាជគ្រឹះ ។ ថ្ងៃមួយ លោកសេដ្ឋី បានប្រើឲ្យនាងបុក

អង្ករជាច្រើន ។ នាងបានបុកអង្ករ តាំងតែពីព្រឹកព្រលឹម រហូតដល់ព្រលប់ មិនចេះហើយសោះ លុះដល់យប់ នាងបានទ្រោលប្រទីបបំភ្លឺហើយ បុកអង្ករ បន្តទៀត នាងបែកញើសចេញពីរាងកាយ ហូរមកស្រស្រោក់ ហើយទៅឈប់សម្រាកកាយា ដើម្បីបំបាត់សេចក្ដីនឿយហត់ ក្នុងពេលនោះ នាងបានឃើញពន្លឺភ្លើងភ្លឺប្លុងៗ របស់ភិក្ខុទាំងឡាយ ដែលនៅអាស្រ័យ លើកំពូលភ្នំគិជ្ឈកូដ ហើយបានទឹកគិតថា "អាត្មាអញ ជាស្រីក្រីក្រលំបាក ត្រូវអត់ធន់ ចំពោះសេចក្ដីលំបាក មិនបានឈប់សម្រាក ធ្វើការមិនបានដេកពួន ក្នុងរាត្រីនេះ, ចំណែកភិក្ខុទាំងឡាយ ព្រោះហេតុអ្វីហ្ន៎ បានជាមិនសិងដែរ ឬមួយ ក៏មានសេចក្ដីមិនសប្បាយកើតឡើង ដល់ភិក្ខុទាំងនោះដែរ?" លុះដល់ព្រឹកឡើង នាងក៏បានយកកន្ទក់មកធ្វើជានំ ចំអិនស្រេចហើយ ទើបវេចដាក់នឹងថ្នក់ ដើរទៅដងទឹក ប្រាថ្នានឹងយកទៅបរិភោគ នៅតាមផ្លូវ ជួនចំជាពេលនោះ នាងបានចួបប្រទះនឹងព្រះសាស្ដា មានព្រះអានន្ទ ជាបច្ឆាសមណៈ នាងមានចិត្តជ្រះថ្លា យ៉ាងខ្លាំង ហើយបានយកនំនោះ ទៅថ្វាយដល់ព្រះសាស្ដា ។

ព្រះបរមសាស្ដា ទ្រង់ទទួលនំហើយ ទ្រង់ធ្វើអនុមោទនា ។ នាង គិតក្នុងចិត្តថា "នំរបស់អាត្មាអញនេះមិនប្រសើរទេ ព្រះសាស្ដាប្រាកដជាមិនសោយ នូវនំនេះទេមើលទៅ" ។

ព្រះសាស្ដា ទ្រង់ជ្រាបនូវវារចិត្ត របស់នាងបុណ្ណទាសីហើយ ទ្រង់បានគង់សោយនំនោះ ឲ្យនាងបានឃើញ លុះទ្រង់សោយនំនោះ

ហើយ ទ្រង់ត្រាស់ហៅនាងបុណ្ណទាសីមកហើយ ត្រាស់សួរថា "នែ នាងបុណ្ណទាសី កាលពីយប់មិញ តើនាងបានគិតដល់សាវ័ក របស់តថាគត យ៉ាងដូចម្ដេចដែរ?" ។ នាង បានក្រាបទូលរឿងនោះ ថ្វាយព្រះសាស្ដាទ្រង់ជ្រាប ។

ព្រះបរមសាស្ដាចារ្យ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

**សទា ជាគរមានានំ អហោរត្តានុសិក្ខិនំ**
**និព្វានំ អធិមុត្តានំ អត្ថំ គច្ឆន្តិ អាសវា ។**

អាសវៈទាំងឡាយ របស់បុគ្គលអ្នកភ្ញាក់រឭក សព្វកាល ជាអ្នកសិក្សាត្រៃសិក្ខា ទាំងថ្ងៃទាំងយប់ មានចិត្តចុះស៊ប់កាន់ព្រះនិព្វាន តែងដល់នូវការតាំងនៅមិនបានឡើយ ។

♣ ♣ ♣

## ១៨០- រឿងអតុលឧបាសក

ព្រះបរមសាស្ដា ទ្រង់ប្រារព្ធឧបាសកម្នាក់ ឈ្មោះអតុលៈ ។ ថ្ងៃមួយ អតុលឧបាសក និង ឧបាសក ៥០០ នាក់ទៀត បានទៅស្ដាប់ធម៌ទេសនា របស់ព្រះរេវតត្ថេរ, កាលបើព្រះរេវតៈ មិនសម្ដែងធម៌ ក៏ក្រោធខឹងហើយ បាននាំគ្នាទៅកាន់សំណាក់ព្រះសារីបុត្រ, កាលបើព្រះសារីបុត្រសម្ដែងព្រះអភិធម្ម ជ្រាលជ្រៅពេក, ក៏មិនពេញចិត្ត ហើយក៏បាននាំគ្នា ទៅរកព្រះអានន្ទ, កាលបើព្រះអានន្ទ សម្ដែងធម៌ តិចហួសពេក, ក៏បានក្រោធខឹងនឹងព្រះអានន្ទ ថា "ព្រះអានន្ទ នេះ ចំជាខ្ជិលមែនទែន សម្ដែងធម៌តែបន្តិច" ហើយ បាននាំគ្នាទៅគាល់ព្រះ

## គាថាធម្មបទប្រែ

*សាស្តា បានក្រាបទូលរឿងនោះ ថ្វាយព្រះអង្គទ្រង់ជ្រាប ។*

*ព្រះសាស្តា ទ្រង់សម្តែងធម្មីកថា ត្រាស់នូវព្រះគាថានេះថា ៖*

បោរាណមេតំ អតុល　　នេតំ អជ្ជតនាមិវ
និន្ទន្តិ តុណ្ហីមាសីនំ　　និន្ទន្តិ ពហុភាណិនំ
មិតភាណិម្បិ និន្ទន្តិ　　នត្ថិ លោកេ អនិន្ទិតោ ។
ន ចាហុ ន ច ភវិស្សតិ　　ន ចេតរហិ វិជ្ជតិ
ឯកន្តំ និន្ទិតោ បោសោ　　ឯកន្តំ វា បសំសិតោ ។
យញ្ចេ វិញ្ញូ បសំសន្តិ　　អនុវិច្ច សុវេ សុវេ
អច្ឆិទ្ទវុត្តឹ មេធាវឹ　　បញ្ញាសីលសមាហិតំ
នេក្ខំ ជម្ពោនទស្សេវ　　កោ តំ និន្ទិតុមរហតិ
ទេវាបិ នំ បសំសន្តិ　　ព្រហ្មុនាបិ បសំសិតោ ។

*ម្នាលអតុលៈ ការតិះដៀល និង ការសរសើរនេះ ជារបស់ចាស់ (មានយូរណាស់ហើយ), ការតិះដៀល និង ការសរសើរនេះ មិនមែនទើបតែនឹងកើតឡើង ក្នុងថ្ងៃនេះទេ (ព្រោះថា) ជនទាំងឡាយតែងនិន្ទានូវបុគ្គលអ្នកអង្គុយស្ងៀមក៏មាន និន្ទានូវបុគ្គលអ្នកនិយាយច្រើន ក៏មាន និន្ទានូវបុគ្គលអ្នកនិយាយតែល្មមប្រមាណ ក៏មាន (អ្នកណាៗ ក៏ដោយ) ក្នុងលោក ដែលមិនត្រូវគេនិន្ទា មិនមានឡើយ, បុគ្គលដែលត្រូវគេនិន្ទាតែម៉្យាង ឬ ត្រូវគេសរសើរតែម៉្យាង មិនមែនមានមកហើយ តែក្នុងអតីតកាលទេ នឹងមានទៅ ក្នុងអនាគត ក៏ទេ មានតែក្នុងបច្ចុប្បន្ននេះ ក៏ទេដែរ ។*

-២៨៦-

រឿងភិក្ខុឆព្វគ្គីយ៍

*បើអ្នកប្រាជ្ញទាំងឡាយ សង្កេតមើល រៀងរាល់ៗ ថ្ងៃ ហើយសរសើរបុគ្គលណា ដែលជាអ្នកប្រព្រឹត្តមិនដាច់ មានប្រាជ្ញា មានចិត្តតម្កល់ខ្ជាប់ ក្នុងបញ្ញា និង សីល, អ្នកណា គួរនឹងនិន្ទាបុគ្គលដែលដូចជាគ្រឿងនៃមាសជម្ពូនទនោះបាន សូម្បីទេវតានិងមនុស្សទាំងឡាយក៏សរសើរបុគ្គលនោះ ទាំងព្រហ្ម ក៏សរសើរបុគ្គលនោះ ដូចគ្នាដែរ ។*

❦ ❦ ❦

១៨១- រឿងភិក្ខុឆព្វគ្គីយ៍

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវភិក្ខុឆព្វគ្គីយ៍ ដែលមានពួក ៦ នាក់ គឺ បណ្ឌុកៈ ១, លោហិតកៈ ១, មេត្តិយៈ ១, ភុម្មជកៈ ១, អស្សជិ ១ បុនព្វសុកៈ ១ ។ ពួកភិក្ខុជាសម្លាញ់នឹងភិក្ខុ ៦ រូបនោះ មានឈ្មោះថា ឆព្វគ្គីយ៍ ដូចគ្នា ។ សម័យថ្ងៃមួយ ពួកភិក្ខុទាំងនោះ មានដៃកាន់ឈើច្រត់ ពាក់ស្បែកជើង ដើរចង្ក្រម ។*

*ព្រះសាស្តា ទ្រង់ព្រះសណ្តាប់ ឮសំឡេងស្បែកជើងហើយ ទ្រង់ត្រាស់សួរ នូវព្រះអានន្ទ ថា "ម្នាលអានន្ទ នុ៎ះ គឺជាសំឡេងអ្វី?" កាលព្រះអានន្ទក្រាបទូលហើយ ទើបទ្រង់បានត្រាស់បញ្ញត្តសិក្ខាបទអប់រំ ដល់ពួកភិក្ខុទាំងនោះហើយ ត្រាស់អភិសមាចារ ដើម្បីឲ្យភិក្ខុរក្សានូវចរិយាមារយាទ ឲ្យបានល្អត្រឹមត្រូវហើយ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

កាយប្បកោបំ រក្ខេយ្យ   កាយេន សំវុតោ សិយា
កាយទុច្ចរិតំ ហិត្វា   កាយេន សុចរិតំ ចរេ

គាថាធម្មបទប្រែ

វចីបកោបំ រក្ខេយ្យ　　វាចាយ សំវុតោ សិយា
វចីទុច្ចរិតំ ហិត្វា　　វាចាយ សុចរិតំ ចរេ
មនោបកោបំ រក្ខេយ្យ　មនសា សំវុតោ សិយា
មនោទុច្ចរិតំ ហិត្វា　　មនសា សុចរិតំ ចរេ
កាយេន សំវុតា ធីរា　　អថោ វាចាយ សំវុតា
មនសា សំវុតា ធីរា　　តេ វេ សុបរិសំវុតា ។

*បុគ្គល គប្បីរក្សានូវការកម្រើកកាយ គប្បីសង្រួមកាយ គប្បីលះបង់កាយទុច្ចរិត គប្បីប្រព្រឹត្តកាយសុចរិត គប្បីរក្សាការកម្រើកវាចា គប្បីសង្រួមវាចា គប្បីលះបង់វចីទុច្ចរិត គប្បីប្រព្រឹត្តវចីសុចរិត គប្បីរក្សាការកម្រើកចិត្ត គប្បីសង្រួមចិត្ត គប្បីលះបង់មនោទុច្ចរិត គប្បីប្រព្រឹត្តមនោសុចរិត, អ្នកប្រាជ្ញទាំងឡាយ បានសង្រួមកាយ សង្រួមវាចា អ្នកប្រាជ្ញទាំងឡាយ បានសង្រួមចិត្តហើយ លោកទាំងនោះឯង ឈ្មោះថា សង្រួមហើយ ដោយប្រពៃ ។*

បប់កោធវគ្គ ទី ១៧

**ចប់ គាថាធម្មបទប្រែ**
**ភាគ ទី ៦**

សូមសិក្សាភាគ ទី ៧ បន្តទៅទៀត

# គាថាធម្មបទប្រែ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ភាគ ទី ៧

មលវគ្គ ទី ១៨

១៨២- រឿង គោឃាតកបុត្រ

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវបុត្ររបស់នាយគោឃាតក៍ ។ ឪពុក ជាអ្នកសម្លាប់គោចិញ្ចឹមជីវិត បើថ្ងៃណាមួយ គាត់មិនបាន សាច់គោមកបរិភោគទេ ថ្ងៃនោះ គាត់បរិភោគអាហារមិនបានដែរ ។ ថ្ងៃមួយ គាត់រកសាច់គោមិនបាន ទើបចាប់យកកាំបិត ដើរតម្រង់ទៅ រកគោដែលឈរ នៅក្រោមផ្ទះ លុះទៅដល់ហើយ ក៏លូកដៃចូលទៅ ក្នុងមាត់គោនោះ ទាញយកនូវអណ្តាតគោមកកាត់ ហើយបានយក អណ្តាតគោនោះទៅអាំង ដើម្បីបរិភោគជាមួយនឹងបាយ ។*

*ពេលនោះ ក៏ស្រាប់តែអណ្តាត របស់នាយគោឃាតក៍ ដាច់ ចេញ អំពីក្នុងមាត់ ធ្លាក់ទៅលើចានបាយ, គាត់បានទទួលនូវបាបកម្ម ឃើញប្រាកដទាន់ភ្នែក ក្នុងបច្ចុប្បន្ន ស្រែករពេ៍ ដូចជាគោដែលគាត់ បានសម្លាប់ លុះនាយគោឃាតក៍ ស្លាប់ហើយ ក៏បានទៅកើតនៅ ក្នុង អវិចីនរក ។*

*ចំណែកឯបុត្រ របស់នាយគោឃាតក៍ បានឃើញយ៉ាងដូច្នេះ ហើយ ក៏ភ័យខ្លាចយ៉ាងខ្លាំង ហើយបានរត់ទៅរស់នៅ ឯនគរ តក្ក- សីលា បានករិយា និង បុត្រ ក្នុងនគរនោះ ។ ក្រោយមក បុត្ររបស់*

## គាថាធម្មបទប្រែ

គាត់បានទៅរស់នៅ ឯក្រុងសាវត្ថី ជាអ្នកមានសទ្ធាជ្រះថ្លា ក្នុងព្រះពុទ្ធសាសនា ហើយបាននាំយកបិតារបស់ខ្លួនទៅ រស់នៅជាមួយ ។ ថ្ងៃមួយ គាត់បាននិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន មកឆាន់នៅផ្ទះរបស់ខ្លួន ហើយក្រាបទូលសុំឲ្យព្រះសាស្តា ធ្វើអនុមោទនា ដើម្បីបិតា របស់ខ្លួន ។

ព្រះបរមសាស្តាចារ្យ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

បណ្ឌុបលាសោវ ទានិសិ
យមបុរិសាបិ ច តេ ឧបដ្ឋិតា
ឧយ្យោគមុខេ បតិដ្ឋសិ
បាថេយ្យម្បិ ច តេ ន វិជ្ជតិ ។
សោ ករោហិ ទីបមត្តនោ
ខិប្បំ វាយាម បណ្ឌិតោ ភវ
និទ្ធន្តមលោ អនង្គណោ
ទិព្វំ អរិយភូមិមេហិសិ ។
ឧបនីតវយោវ ទានិសិ
សម្បយាតោសិ យមស្ស សន្តិកំ
វាសោបិ ច តេ នត្ថិ អន្តរា
បាថេយ្យម្បិ ច តេ ន វិជ្ជតិ ។
សោ ករោហិ ទីបមត្តនោ
ខិប្បំ វាយាម បណ្ឌិតោ ភវ

-២៩០-

# រឿងគោឃាតកបុត្រ

**និទ្ធន្តមលោ អនង្គណោ**
**ន បុន ជាតិជរំ ឧបេហិសិ ។**

ឥឡូវនេះ ខ្លួនអ្នក ដូចជាស្លឹកឈើទុំហើយ ទាំងពួកបុរស របស់យមរាជ ក៏ប្រាកដ ដល់អ្នកហើយ ខ្លួនអ្នកតាំងនៅ ក្នុងមាត់នៃ សេចក្តីវិនាស សូម្បីស្បៀង គឺកុសល របស់អ្នកសោត ក៏មិនទាន់ មានឡើយ ។

អ្នកចូរធ្វើកុសល ដែលជាទីពឹងសម្រាប់ខ្លួនទៅ ចូរព្យាយាម ឲ្យបានឆាប់រហ័សទៅ ចូរជាអ្នកឆ្លាតវាងវៃទៅ (កុំជាមនុស្សល្ងង់ខ្លៅ ឡើយ) បើអ្នក (ធ្វើយ៉ាងនេះហើយ) នឹងទៅជាអ្នកកំចាត់បង់មន្ទិល បាន មិនមានទីទួល គឺកិលេស នឹងដល់នូវភូមិ របស់ព្រះអរិយៈ ដែលជាទិព្វបាន ។

ឥឡូវនេះ ខ្លួនអ្នក ត្រូវជរាចូលដល់ហើយ ជាអ្នករៀបចំ ដំណើរទៅ កាន់សំណាក់នៃយមរាជហើយ មួយទៀត ទីសំចត ក្នុង ចន្លោះ មិនមានដល់អ្នកទេ សូម្បីស្បៀង គឺកុសល របស់អ្នក ក៏មិន ទាន់មានឡើយ ។

អ្នកចូរធ្វើកុសល ដែលជាទីពឹងសម្រាប់ខ្លួនទៅ ចូរព្យាយាម ឲ្យបានឆាប់រហ័សទៅ ចូរជាអ្នកឆ្លាតវាងវៃទៅ (កុំជាមនុស្សល្ងង់ខ្លៅ ឡើយ) បើអ្នក (ធ្វើយ៉ាងនេះហើយ) នឹងទៅជាអ្នកកំចាត់បង់មន្ទិល បាន មិនមានទីទួល គឺកិលេស នឹងមិនត្រូវចូលទៅ កាន់ជាតិ ជរា ព្យាធិ និង មរណៈ ទៀតឡើយ ។

គាថាធម្មបទប្រែ

## ១៨៣- រឿង អញ្ញាតព្រាហ្មណ៍

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវព្រាហ្មណ៍ម្នាក់ ដែលជាអ្នកបានធ្វើបុណ្យកុសល ជារឿយៗ ពុំដែលខានឡើយ ។ ក្នុងគ្រាដំបូងព្រាហ្មណ៍ បានឃើញកន្លែងដែលភិក្ខុមួយរូប ឈរគ្រងចីវរមិនស្អាត មានស្មៅដុះច្រើន ក៏ទៅជម្រះទីនោះ ធ្វើឲ្យបានស្អាតល្អ យកដីខ្សាច់មកដាក់ហើយ កសាងសាលាមួយខ្នង លុះសាងរួចស្រេចហើយ ក៏បានធ្វើបុណ្យឆ្លង នូវសាលានោះទៀត បានអារាធនានិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាព្រះប្រធានហើយ ក្រាបទូលប្រវត្តិ នៃសាលានេះ តាំងតែពីដើម រហូតដល់ទីបញ្ចប់ ។*

*ព្រះសាស្តា កាលធ្វើអនុមោទនាទ្រង់ត្រាស់ព្រះគាថានេះថា៖*

**អនុបុព្វេន មេធាវី ថោកំ ថោកំ ខណេ ខណេ**
**កម្មារោ រជតស្សេវ និទ្ធមេ មលមត្តនោ ។**

*អ្នកមានប្រាជ្ញា គួរកំចាត់បង់នូវមន្ទិលរបស់ខ្លួន បន្តិចម្តងៗ រាល់ៗ ខណៈ ដោយលំដាប់ ប្រៀបដូចជាជាងមាស ជម្រះស្នឹម ឬច្រែះ របស់មាស យ៉ាងដូច្នោះឯង ។*

❇ ❇ ❇

## ១៨៤- រឿង ព្រះតិស្សត្ថេរ

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវព្រះតិស្សត្ថេរ ។ ព្រះតិស្សៈ មានចីវរសាច់ល្អម៉ដ្ឋខៃមួយ ដែលជាទីពេញចិត្តណាស់ លោកបានទុកដាក់ មិនទាន់បានប្រើប្រាស់ទេ តែអនិច្ចា! ព្រះតិស្សៈ ក៏បានធ្វើ*

## រឿងព្រះតិស្សត្ថេរ

មរណកាលទៅ ហើយបានទៅកើតជាចៃ ក្នុងចីវរនោះឯង ។

ភិក្ខុសង្ឃ ចាប់ផ្តើមប្រារព្ធនឹងចែកចីវរនោះ តែសត្វចៃ បានវារទៅ-មក ព្រោះមិនចង់ឲ្យភិក្ខុសង្ឃ យកចីវរខ្លួនទៅចែកគ្នា ។

ព្រះសាស្តា ទ្រង់ជ្រាបដោយទិព្វសោតហើយ ទើបទ្រង់បានត្រាស់ហាមឃាត់ឲ្យភិក្ខុសង្ឃ ឈប់បង្អង់ចាំសិន រហូតកន្លងទៅបាន ៧ ថ្ងៃ ហើយ ទើបត្រាស់ឲ្យភិក្ខុសង្ឃ យកចីវរនោះមកចែកគ្នា ។

ក្នុងថ្ងៃទី ៧ សត្វចៃនោះ ក៏បានស្លាប់ទៅហើយ បានទៅកើតនៅឯឋានតុសិតវិមាន ។ ភិក្ខុទាំងឡាយ មានសេចក្តីសង្ស័យ ក៏នាំគ្នាចូលទៅ ក្រាបទូលសួរ ចំពោះព្រះសាស្តា ។

ព្រះសាស្តា ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

**អយសាវ មលំ សមុដ្ឋាយ**
**តទុដ្ឋាយ តមេវ ខាទតិ**
**ឯវំ អតិធោនចារិនំ**
**សានិ កម្មានិ នយន្តិ ទុគ្គតឹ ។**

ប្រែះ កើតអំពីដែក លុះកើតអំពីដែកនោះហើយ តែងស៊ីដែកនោះវិញ យ៉ាងណាមិញ, កម្មទាំងឡាយរបស់ខ្លួន តែងនាំបុគ្គល អ្នកប្រព្រឹត្តកន្លង នូវបញ្ញាជាគ្រឿងជំរះចិត្ត ឲ្យទៅកាន់ទុគ្គតិ ក៏យ៉ាងដូច្នោះដែរ ។

♣ ♣ ♣

## គាថាធម្មបទប្រែ

### ១៨៥- រឿង ព្រះលោឡុទាយី

ព្រះបរមសាស្ដា ទ្រង់ប្រារព្ធនូវព្រះលោឡុទាយី ជាអ្នកអួតអាង ។ សម័យថ្ងៃមួយ ព្រះលោឡុទាយី បានឮពួកប្រជាជន ដែលបានទៅស្ដាប់ព្រះធម៌ទេសនាហើយ ត្រឡប់មកវិញ និយាយពោលសរសើរគុណរបស់ព្រះសារីបុត្រ និងព្រះមហាមោគ្គល្លាន ក៏និយាយទៅកាន់ប្រជាជនទាំងនោះ ថា "បើអ្នកទាំងអស់គ្នា បានស្ដាប់នូវធម៌ទេសនា របស់អាត្មាភាពវិញ មិនដឹងជាពួកអ្នកពោលសរសើរអាត្មាភាព យ៉ាងណានោះទេ" ។

ថ្ងៃមួយ ពួកប្រជាជន បាននាំគ្នាធ្វើបុណ្យឲ្យទាន ហើយបានអារាធនាព្រះលោឡុទាយី ឲ្យលោកសម្ដែងព្រះធម៌ទេសនា ។ ព្រះលោឡុទាយី ទទួលនិមន្តហើយ ក៏ឡើងលើគ្រែទេសនា ចាប់ផ្ចិតធ្វើដូចជានឹងសម្ដែងព្រះធម៌ទេសនា តែអនិច្ចា ព្រះថេរៈ រកនឹកព្រះធម៌មកសម្ដែងមិនឃើញសោះ ទើបពោលយករួចខ្លួន ថា "ក្នុងពេលថ្ងៃនេះ អាត្មាភាព មិនទាន់សម្ដែងព្រះធម៌ទេសនាទេ ចាំដល់ពេលយប់ចុះ អាត្មាភាពនឹងសម្ដែង" លុះដល់ពេលយប់ហើយ ក៏រកធម៌មកសម្ដែងមិនបាន ទើបបានពោលថា "យប់នេះ អាត្មាភាព មិនទាន់សម្ដែងទេ ចាំដល់ពេលព្រឹកចុះ" លុះព្រឹកឡើង ក៏ពោលដោះសាទៀត ថា "ចាំដល់ពេលថ្ងៃ អាត្មាភាព នឹងសម្ដែង" ។

ពួកប្រជាជន មានសេចក្ដីអស់សង្ឃឹម ឈប់មានជំនឿ តទៅទៀត ហើយបានក្រោធខឹងយ៉ាងខ្លាំង ចំពោះព្រះលោឡុទាយី បាននាំ

គ្នាជេរស្តី បន្តាប់ ចាប់ដំបងប៉ងវាយធ្វើបាប ហើយបានបណ្តេញ ឲ្យចេញអំពីទីនោះភ្លាម ។ ព្រះលោឡុទាយី ភ័យខ្លាចខ្លាំងណាស់ បានចុះរត់ទៅ ធ្លាក់ ក្នុងវច្ចកុដិ (គឺធ្លាក់ក្នុងបង្គន់អាចម៍) ។ ភិក្ខុទាំងឡាយ បានប្រជុំគ្នា និយាយអំពីរឿងព្រះលោឡុទាយីនោះ ដោយប្រការផ្សេងៗ ។

ព្រះបរមសាស្តាចារ្យ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

**អសជ្ឈាយមលា មន្តា អនុដ្ឋានមលា ឃរា**
**មលំ វណ្ណស្ស កោសជ្ជំ បមាទោ រក្ខតោ មលំ ។**

មន្តទាំងឡាយ មានការមិនស្វាធ្យាយន៍ ជាមន្ទិល ផ្ទះទាំងឡាយ មានការមិនថែទាំ ជាមន្ទិល សេចក្តីខ្ជិល ជាមន្ទិល របស់ពណ៌សម្បុរ សេចក្តីប្រមាទ ជាមន្ទិល របស់បុគ្គលអ្នករក្សា ។

❊ ❊ ❊

## ១៨៦- រឿង អញ្ញាត្រកុលបុត្រ

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវកុលបុត្រម្នាក់ ជាអ្នកមានសទ្ធាជ្រះថ្លា ក្នុងព្រះពុទ្ធសាសនា មានភរិយា គឺជាស្រីដែលមានចិត្តក្បត់ ចូលចិត្តប្រព្រឹត្តខុសសីលកាមេ ។ កុលបុត្រនោះ មិនហ៊ានចូលទៅ ក្នុងទីប្រជុំជនឡើយ ថ្ងៃមួយ បានចូលទៅគាល់ព្រះសាស្តាហើយ ក្រាបទូលរឿងនោះ ថ្វាយដល់ព្រះអង្គទ្រង់ជ្រាប ។

ព្រះសាស្តាទ្រង់ត្រាស់អតីតនិទានថា “មានភរិយារបស់សេដ្ឋីម្នាក់ ជាស្រីចូលចិត្តប្រព្រឹត្តក្បត់ស្វាមី ។ សេដ្ឋី បានដឹងហើយក៏កើត

ទុក្ខទោមនស្ស យ៉ាងខ្លាំង ។ អាចារ្យទិសាបាមោក្ខ ដែលជាគ្រូ របស់សេដ្ឋី ដឹងនូវរឿងនោះហើយ ក៏បានអប់រំទូន្មានសេដ្ឋី ថា: ស្ត្រី ក្នុងលោកនេះ ជាសាធារណៈទូទៅ សម្រាប់បុរស ដូចទឹកស្ទឹង ផ្លូវថ្នល់ តៀមស្រា សាលាធទាន សាលាក្បែរមាត់ទឹក យ៉ាងនោះឯង" ក្នុងទីបញ្ចប់នៃអតីតនិទាន ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

មលិត្ថិយា ទុច្ចរិតំ មច្ចេរំ ទទតោ មលំ
មលា វេ បាបកា ធម្មា អស្មឹ លោកេ បរម្ហិ ច
តតោ មលា មលតរំ អវិជ្ជា បរមំ មលំ
ឯតំ មលំ បហន្ត្វាន និម្មលា ហោថ ភិក្ខវោ ។

ការប្រព្រឹត្តិទុច្ចរិត ជាមន្ទិលរបស់ស្ត្រី សេចក្តីកំណាញ់ ជាមន្ទិល របស់អ្នកឲ្យ, ធម៌អាក្រក់ទាំងឡាយ ជាមន្ទិល ក្នុងលោកនេះ និង លោកខាងមុខ, ធម្មជាត ជាមន្ទិលដ៏លើសលប់ ជាងមន្ទិលទាំងនោះ គឺអវិជ្ជា ជាមន្ទិលដ៏ក្រៃលែង, ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរលះមន្ទិលទាំងនេះចោលចេញ (ឲ្យអស់) ចូរកុំជាអ្នកមានមន្ទិលឡើយ ។

❉ ❉ ❉

## ១៨៧- រឿង ចូឡសារីភិក្ខុ

ព្រះបរមសាស្តា ទ្រង់បានប្រារព្ធនូវភិក្ខុ ឈ្មោះចូឡសារី ជាសទ្ធិវិហារិក របស់ព្រះសារីបុត្រ ប្រព្រឹត្តវេជ្ជកម្ម ចិញ្ចឹមជីវិត ដោយការធ្វើជាគ្រូពេទ្យ ព្យាបាលជម្ងឺ ។ សម័យថ្ងៃមួយ ភិក្ខុចូឡសារី បាន

នូវភោជនាហារ ដ៏ប្រណីត ដោយវេជ្ជកម្មនោះហើយ ក៏បានយកទៅប្រគេនព្រះសារីបុត្រ ដែលជាព្រះឧបជ្ឈាយ៍ របស់ខ្លួន ។ ប៉ុន្តែព្រះសារីបុត្រ មិនព្រមទទួលយកមកឆាន់ឡើយ ។ ភិក្ខុទាំងឡាយ បានដឹងរឿងនោះហើយ ទើបយករឿងនោះ ទៅក្រាបទូលព្រះសាស្តាទ្រង់ជ្រាប ។

ព្រះបរមសាស្តាចារ្យ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

សុជីវំ អហិរិកេន　　កាកសូរេន ធំសិនា
បក្ខន្ទិនា បគព្ភេន　　សង្កិលិដ្ឋេន ជីវិតំ ។
ហិរីមតា ច ទុជ្ជីវំ　　និច្ចំ សុចិគវេសិនា
អលីនេនាបគព្ភេន　　សុទ្ធាជីវេន បស្សតា ។

បុគ្គលអ្នកមិនមានហិរិ ក្លៀវក្លាដូចសត្វក្អែក កំចាត់បង់គុណរបស់អ្នកដទៃ ជាអ្នកឈ្លានពាន (យកមុខមាត់) ជាអ្នកឃ្នើសឃ្នងជាមនុស្សសៅហ្មង រស់នៅដោយស្រួល ។ ចំណែកបុគ្គលអ្នកមានហិរិ ស្វែងរកអំពើស្អាតជានិច្ច មិនឡេះឡោះ មិនឃ្នើសឃ្នង រស់នៅដោយកម្មដ៏បរិសុទ្ធ ជាអ្នកឃើញត្រូវ រស់នៅដោយលំបាក ។

## ១៨៨- រឿងបញ្ចឧបាសក

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវឧបាសក ៥ នាក់ ដែលជាអ្នករក្សាសីល ៥ ម្នាក់ម៉្យាង ៗ គឺ អ្នកខ្លះ រក្សាសីល ទី១ ខ្លះរក្សាសីល ទី២ ខ្លះរក្សាសីល ទី៣ ខ្លះរក្សាសីល ទី ៤ អ្នកខ្លះ រក្សាសីល ទី៥,

-២៩៧-

## គាថាធម្មបទប្រែ

*អ្នកណា រក្សាសិក្ខាបទណាមួយ អ្នកនោះសម្គាល់ថា ត្រឹមត្រូវល្អ ហើយបានជជែកប្រកែកគ្នា ជារៀងរាល់ថ្ងៃ មិនចេះដាច់ស្រេចទាល់តែសោះ ក្រោយមក ក៏បានចូលទៅគាល់ព្រះសាស្ដា ទូលសុំឲ្យព្រះអង្គជួយកាត់សេចក្ដីឲ្យ ។*

*ព្រះសាស្ដាចារ្យ ទ្រង់ជ្រាបហើយត្រាស់នូវព្រះគាថានេះថា៖*

យោ បាណមតិមាបេតិ មុសាវាទញ្ច ភាសតិ
លោកេ អទិន្នំ អាទិយតិ បរទារញ្ច គច្ឆតិ
សុរាមេរយបានញ្ច យោ នរោ អនុយុញ្ជតិ
ឥធេវមេសោ លោកស្មឹ មូលំ ខណតិ អត្តនោ ។
ឯវំ ភោ បុរិស ជានាហិ បាបធម្មា អសញ្ញតា
មា តំ លោភោ អធម្មោ ច ចិរំ ទុក្ខាយ រន្ធយុំ ។

*ជនណា សម្លាប់សត្វផង និយាយពាក្យកុហកផង កាន់យកនូវវត្ថុដែលគេមិនបានឲ្យ ក្នុងលោកផង សេពប្រពន្ធ របស់អ្នកដទៃផង ជនណា ផឹកទឹកសុរានិងមេរ័យផង ជននោះឯង ឈ្មោះថា គាស់រំលើងនូវឫសគល់របស់ខ្លួន ក្នុងលោកនេះ ដោយពិត ។*

*ម្នាលបុរសដ៏ចំរើន អ្នកចូរដឹង យ៉ាងនេះ ថា: ជនទាំងឡាយមានធម៌ដ៏លាមក រមែងជាអ្នកមិនសង្រួម ដូច្នេះ លោភៈ និង សភាពមិនមែនជាធម៌ គឺទោសៈ ចូរកុំបៀតបៀននូវអ្នក ឲ្យបានសេចក្ដីទុក្ខអស់កាលដ៏យូរឡើយ ។*

❀ ❀ ❀

## ១៨៩- រឿងភិក្ខុកំលោះឈ្មោះតិស្សៈ

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវភិក្ខុកំលោះឈ្មោះតិស្សៈ ជាអ្នករស់នៅ ក្នុងជនបទ ។ ភិក្ខុតិស្សៈ នេះ បានបួស ក្នុងក្រុងសាវត្ថី ជាអ្នកអួតអាងតែអំពីពួកញាតិសន្តាន របស់ខ្លួន និយាយតិះដៀល បន្ទាប់ទានដែលអ្នកដទៃឲ្យហើយថា "ទាន របស់អ្នកនេះមិនបានស្មើនឹងទាន របស់ពួកញាតិអាត្មាភាពទេ" ។ ភិក្ខុទាំងឡាយ ចាប់ពាក្យមុសាវាទ របស់ភិក្ខុកំលោះ ឈ្មោះតិស្សៈ បានហើយ ទើបនាំគ្នាទៅក្រាបទូល ដល់ព្រះសាស្តា ។*

*ព្រះបរមសាស្តាចារ្យ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

ទទាតិ វេ យថាសទ្ធំ យថាបសាទនំ ជនោ
តត្ថ យោ មង្កុតោ ហោតិ បរេសំ បានភោជនេ
ន សោ ទិវា វា រត្តឹ វា សមាធឹ អធិគច្ឆតិ ។
យស្ស ចេតំ សមុច្ឆិន្នំ មូលឃច្ចំ សមូហតំ
ស វេ ទិវា វា រត្តឹ វា សមាធឹ អធិគច្ឆតិ ។

*ជន រមែងឲ្យ(ទាន) តាមសទ្ធា តាមសេចក្តីជ្រះថ្លា បុគ្គលណាជាអ្នកអៀនខ្មាស ក្នុងទឹក និង ភោជន របស់ជនទាំងឡាយដទៃនោះ បុគ្គលនោះ រមែងមិនបាននូវសមាធិចិត្ត ក្នុងវេលាថ្ងៃ ឬ ក្នុងវេលាយប់ឡើយ ។*

*លុះតែសេចក្តីអៀនខ្មាសនោះ គឺបុគ្គលណា បានផ្តាច់ផ្តិលដកឡើង ធ្វើឲ្យមានឫសគល់ដាច់ហើយ បុគ្គលនោះឯង ទើបបាននូវសមាធិចិត្ត ក្នុងវេលាថ្ងៃ ឬ ក្នុងវេលាយប់ ។*

# គាថាធម្មបទប្រែ

## ១៩០-រឿងបញ្ចឧបាសក

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវឧបាសក ៥ នាក់ ដែលបាននាំគ្នា ទៅស្តាប់ធម៌ទេសនា ក្នុងវត្តជេតពន ។ ក្នុងពេលស្តាប់ធម៌ទេសនានោះ ឧបាសកម្នាក់ អង្គុយស្តាប់ធម៌រឿយៗ ទៅ ក៏បានដេកលក់ តែម្តង ព្រោះនិស្ស័យធ្លាប់បានកើតជាសត្វពស់, ឧបាសក ម្នាក់ទៀត អង្គុយស្តាប់ធម៌ យកចង្អុលដៃគូសផែនដី ព្រោះនិស្ស័យធ្លាប់កើតជាសត្វជន្លេន, ឧបាសក ម្នាក់ទៀត អង្គុយអង្រួនដើមឈើ ព្រោះនិស្ស័យធ្លាប់បានកើតជាសត្វស្វា, ឧបាសក ម្នាក់ទៀត បានអង្គុយងើយមើលទៅលើមេឃ ព្រោះនិស្ស័យធ្លាប់បានកើតជាអ្នកហោរាសាស្ត្រ, ឯឧបាសក ម្នាក់ទៀត បានអង្គុយស្តាប់ធម៌ទេសនា ដោយសេចក្តីគោរព ព្រោះនិស្ស័យធ្លាប់បានកើតជាព្រាហ្មណ៍ ស្វាធ្យាយមន្ត ។

ព្រះអានន្ទត្ថេរ បានឃើញនូវឧបាសកទាំង ៥ នាក់នោះ មានអាការយ៉ាងដូច្នោះហើយ ក៏កើតមានសេចក្តីសង្ស័យ ហើយទៅក្រាបទូលសួរព្រះសាស្តា ថា "បពិត្រព្រះអង្គដ៏ចំរើន សត្វទាំងឡាយ មិនអាចស្តាប់ព្រះធម៌ទេសនា របស់ព្រះអង្គបាន តើព្រោះហេតុអ្វី?" ។

ព្រះសាស្តាចារ្យបរមគ្រូ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

នត្ថិ រាគសមោ អគ្គិ នត្ថិ ទោសសមោ គហោ
នត្ថិ មោហសមំ ជាលំ នត្ថិ តណ្ហាសមា នទី ។

ភ្លើងស្មើដោយរាគៈ មិនមាន ការចាប់ស្មើដោយទោសៈ មិន

# រឿង មេណ្ឌកសេដ្ឋី

មាន បណ្ដាញស្មើដោយមោហៈ មិនមាន ស្ទឹងស្មើដោយតណ្ហា មិនមាន ។

## ១៩១-រឿង មេណ្ឌកសេដ្ឋី

ព្រះបរមសាស្ដា ទ្រង់ប្រារព្ធមេណ្ឌកសេដ្ឋី ជាអ្នកមានបុណ្យច្រើន ព្រះអង្គទ្រង់ទតព្រះនេត្រឃើញ នូវឧបនិស្ស័យនៃសោតាបត្តិផល របស់ជនទាំងនេះ គឺ មេណ្ឌកសេដ្ឋី ១ ភរិយាសេដ្ឋី ១ ធនញ្ជ័យសេដ្ឋីបុត្រ ១ នាងសុមនទេវីកូនប្រសា ១ នាងវិសាខាដែលជាចៅ ១ នាយបុណ្ណៈ ១ ទើបទ្រង់ស្ដេចយាងទៅកាន់កទ្ទិយនគរ ។

មេណ្ឌកសេដ្ឋី បានឃើញព្រះសាស្ដាស្ដេចយាងមកហើយ ក៏នាំគ្នា ទៅទទួលព្រះអង្គ នាកណ្ដាលផ្លូវ ។ ពួកតិរ្ថិយ បានឃើញហើយក៏ទៅហាមឃាត់មេណ្ឌកសេដ្ឋី មិនឲ្យមកទទួលព្រះអង្គ ហើយបានតិះដៀលព្រះសាស្ដា ដោយប្រការផ្សេងៗ ។ មេណ្ឌកសេដ្ឋី មិនបានធ្វើតាមពាក្យ របស់តិរ្ថិយទាំងនោះឡើយ លុះបានស្ដាប់នូវព្រះធម៌ទេសនា របស់ព្រះសាស្ដាហើយ ក៏បានសម្រេចសោតាបត្តិផល ហើយបានក្រាបទូលរឿងនោះ ថ្វាយដល់ព្រះអង្គ ។

ព្រះបរមសាស្ដាចារ្យជាគ្រូ ទ្រង់ត្រាស់នូវព្រះគាថានេះថា ៖

សុទស្សំ វជ្ជមញ្ញេសំ អត្តនោ បន ទុទ្ទសំ
បរេសំ ហិ សោ វជ្ជានិ ឱបុនាតិ យថា ភុសំ
អត្តនោ បន ឆាទេតិ កលឹវ កិតវា សឋោ ។

## គាថាធម្មបទប្រែ

*ទោស របស់ពួកជនដទៃ ឃើញបានដោយងាយ ចំណែកឯទោស របស់ខ្លួន ឃើញបាន ដោយលំបាក ព្រោះថា បុគ្គលនោះរមែងរោយទោសទាំងឡាយ ចំពោះពួកជនដទៃ ដូចបុគ្គលរោយអង្កាម ដូច្នោះ តែថា រមែងបិទបាំងទោស របស់ខ្លួនទុក (មិនឲ្យគេឃើញ) ដូចព្រានបក្សី បិទបាំងអត្តភាព ដោយវត្ថុសម្រាប់បិទបាំង (មានមែកឈើជាដើម) ដូច្នោះឯង ៗ*

♣ ♣

## ១៩២- រឿង ព្រះឧជ្ឈានសញ្ញី

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវព្រះឧជ្ឈានសញ្ញី ៗ ព្រះថេរៈចូលចិត្តតែនិយាយអំពីរឿងរ៉ាវ របស់ពួកជនដទៃ ឃ្លាំមើលតែទោស របស់ភិក្ខុទាំងឡាយ ឃើញហើយ បានដើរទៅនិយាយប្រាប់គេប្រាប់ឯង ៗ ភិក្ខុទាំងឡាយ បានក្រាបទូលរឿងនោះ ដល់ព្រះសាស្តា ៗ*

*ព្រះសាស្តាចារ្យបរមគ្រូ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

**បរវជ្ជានុបស្សិស្ស និច្ចំ ឧជ្ឈានសញ្ញិនោ**<br>
**អាសវា តស្ស វឌ្ឍន្តិ អារា សោ អាសវក្ខយា ។**

*កាលបុគ្គលគយគន់ ឃ្លាំមើលតែទោស របស់បុគ្គលដទៃ ជាប្រក្រតី មានការសំគាល់ហេតុ ក្នុងការពោលទោស(អ្នកដទៃ) ជានិច្ចជាប្រក្រតី អាសវៈទាំងឡាយ របស់បុគ្គលនោះ តែងចំរើន បុគ្គលនោះ ឈ្មោះថា ឋិតនៅឆ្ងាយ អំពីធម៌ជាគ្រឿងអស់ទៅនៃអាសវៈ ៗ*

## ១៩៣- រឿង សុភទ្ទបរិព្វាជក

ព្រះបរមសាស្ដា ទ្រង់ប្រារព្ធនូវសុភទ្ទបរិព្វាជក ក្នុងសម័យដែលព្រះអង្គទ្រង់គង់នៅ ក្នុងព្រៃសាលវ័ននៃដែនមល្លក្សត្រ នាក្រុងកុសិនារា ទ្រង់ផ្ទំនៅ លើព្រះក្រឡាមហាបន្ទំ ជាទីកន្លែងដែលព្រះអង្គបរិនិព្វាន ។

គ្រានោះ សុភទ្ទបរិព្វាជក បានចូលទៅគាល់ព្រះអង្គ ដើម្បីក្រាបទូលសួរនូវបញ្ហា ។ ព្រះអានន្ទ បានយល់ឃើញថា ជាកាលមិនសមគួរ ទើបបានហាមឃាត់សុភទ្ទៈ មិនឲ្យចូលគាល់ព្រះអង្គ ដើម្បីនឹងសួរបញ្ហា តាមសេចក្ដីប្រាថ្នា ។ តែព្រះសាស្ដា ទ្រង់អនុញ្ញាតឲ្យសុភទ្ទៈចូលគាល់ ។ គ្រានោះ សុភទ្ទៈ បានក្រាបទូលសួរថា "បពិត្រព្រះអង្គដ៏ចំរើន ស្នាមគំនូស លើអាកាស មានដែរឬទេ? សមណៈខាងក្រៅព្រះសាសនានេះ មានដែរឬទេ? សង្ខារទាំងឡាយទាំងពួងឈ្មោះថា ទៀង មានដែរឬទេ?" ។

ព្រះសាស្ដាកាលទ្រង់ព្យាករបញ្ហានេះ ត្រាស់គាថានេះ ថា ៖

អាកាសេវ បទំ នត្ថិ សមណោ នត្ថិ ពាហិរេ
បបញ្ចាភិរតា បជា និប្បបញ្ចា តថាគតា ។
អាកាសេវ បទំ នត្ថិ សមណោ នត្ថិ ពាហិរេ
សង្ខារា សស្សតា នត្ថិ នត្ថិ ពុទ្ធានមិញ្ជិតំ ។

ស្នាមជើង ក្នុងអាកាស មិនមាន សមណៈ ខាងក្រៅ មិនមាន ពួកសត្វ ជាអ្នកត្រេកអរហើយ ក្នុងធម៌ជាគ្រឿងយឺតយូរ តថាគតទាំងឡាយ មិនមានធម៌ជាគ្រឿងយឺតយូរឡើយ ។

គាថាធម្មបទប្រែ

*ស្នាមជើង ក្នុងអាកាស មិនមាន សមណៈ ខាងក្រៅ មិនមាន សង្ខារទាំងឡាយ ឈ្មោះថា ជារបស់ទៀង មិនមាន ព្រះពុទ្ធទាំងឡាយ មិនមានកិលេសជាគ្រឿងញាប់ញ័រឡើយ ។*

**ចប់ មលវគ្គ ទី ១៨**

ធម្មដ្ឋវគ្គ ទី ១៩

១៩៤- រឿងវិនិច្ឆយមហាអមាត្យ

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវមហាអមាត្យ ដែលជាមេធាវីអ្នកកាត់ក្តីមិនបានត្រឹមត្រូវ ។ មហាអមាត្យនេះ កាលបើបានទទួលសំណូកអំពីអ្នកណាម្នាក់ហើយ ក៏កាត់សេចក្តីឲ្យអ្នកនោះឯងឈ្នះ ។ សម័យថ្ងៃមួយ ភិក្ខុទាំងឡាយ បាននិមន្តទៅតាមផ្លូវ ក្បែរសាលាវិនិច្ឆ័យនោះ ហើយបានចូលទៅជ្រកភ្លៀង លើសាលាវិនិច្ឆ័យនោះដែរ ឃើញពួកអាមាត្យ កាត់សេចក្តីមិនយុត្តិធម៌ ទើបបានយករឿងនោះ ទៅក្រាបទូលដល់ព្រះសាស្តា ។*

*ព្រះបរមសាស្តាចារ្យជាគ្រូ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

ន តេន ហោតិ ធម្មដ្ឋោ យេនត្ថំ សហសា នយេ
យោ ច អត្ថំ អនត្ថញ្ច ឧភោ និច្ឆេយ្យ បណ្ឌិតោ ។
អសាហសេន ធម្មេន សមេន នយតី បរេ
ធម្មស្ស គុត្តោ មេធាវី ធម្មដ្ឋោតិ បវុច្ចតិ ។

*បុគ្គល កាត់សេចក្តីមិនត្រឹមត្រូវ ដោយសារហេតុណា ឈ្មោះ*

*ថា ជាអ្នកតាំងនៅក្នុងធម៌ ដោយសារហេតុនោះ មិនទាន់បានទេ លុះត្រាតែ បុគ្គលណា ជាបណ្ឌិត កាត់សេចក្តីទាំងពីរ គឺសេចក្តីពិត និងសេចក្តីមិនពិត ណែនាំជនទាំងឡាយដទៃទៀត ដោយត្រឹមត្រូវល្អ ប្រកបដោយធម៌ តាមសមគួរ (ដល់ទោស) បុគ្គលនោះ ឈ្មោះថា ជាអ្នកមានប្រាជ្ញា រក្សាធម៌ ទើបឈ្មោះថា ជាអ្នកតាំងនៅក្នុងធម៌ ។*

❃ ❃ ❃

## ១៩៥- រឿង ឆព្វគ្គិយភិក្ខុ

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវភិក្ខុឆព្វគ្គិយ៍ ដែលជាអ្នកមិនមានសេចក្តីអៀនខ្មាស ពេលទៅឆាន់តាមផ្ទះក្តី ឆាន់តាមវត្តក្តី ធ្វើទីកន្លែងនោះៗ ឲ្យស្មោកគ្រោកប្រឡាក់ប្រឡូស និយាយអួតអាង ថា បក្សពួក របស់ខ្លួនជាបណ្ឌិត ហើយតិះដៀលភិក្ខុដទៃទៀតថា ជាអ្នកល្ងង់ខ្លៅ គ្មានដឹងអ្វីសោះ ។ ភិក្ខុទាំងឡាយ បានក្រាបទូលរឿងនោះដល់ព្រះសាស្តា ។*

*ព្រះសាស្តា ទ្រង់ជ្រាបហើយ ត្រាស់នូវព្រះគាថានេះ ថា ៖*

**ន តេន បណ្ឌិតោ ហោតិ  យាវតា ពហុ ភាសតិ**
**ខេមី អវេរី អភយោ  បណ្ឌិតោតិ បវុច្ចតិ ។**

*បុគ្គលនិយាយច្រើន ដោយហេតុមានប្រមាណប៉ុណ្ណា ឈ្មោះថា ជាបណ្ឌិត ដោយហេតុមានប្រមាណប៉ុណ្ណោះ មិនទាន់បានទេ លុះត្រាតែ បុគ្គលដែលមានសេចក្តីក្សេម មិនមានពៀរ មិនមានភ័យ ទើបបានឈ្មោះថា ជាបណ្ឌិត ។*

# គាថាធម្មបទប្រែ

## ១៩៦-រឿងឯកុទានត្ថេរ

*ព្រះបរមសាស្ដា ទ្រង់ប្រារព្ធ នូវព្រះឯកុទានត្ថេរ ។ ព្រះថេរៈជាព្រះអរហន្តខីណាស្រព គង់នៅក្នុងព្រៃតែមួយអង្គឯង លុះដល់ថ្ងៃឧបោសថ លោកសូត្រឧទានគាថាមួយបទ មិនដែលខាន ។ ទេវតាទាំងឡាយ ដែលនៅអាស្រ័យក្នុងព្រៃនោះ បានថ្វាយសព្ទសាធុការព្ទខ្ទរខ្ទរ ពាសពេញព្រៃ ដូចផែនដីរញ្ជួយ ។*

*សម័យថ្ងៃមួយ មានភិក្ខុពីររូប ជាអ្នករៀនចប់ព្រះត្រៃបិដក មានសិស្ស ម្នាក់ៗ ៥០០ បាននិមន្តទៅ ក្នុងព្រៃនោះដែរ ។ ព្រះឯកុទានថេរ អារាធនានិមន្ត ឲ្យភិក្ខុពីររូបនោះ សម្ដែងនូវព្រះធម៌ ។ កាលបើភិក្ខុទាំងពីររូបនោះ សម្ដែងធម៌ចប់ហើយ, ពួកទេវតាមិនបានបន្លឺសព្ទសាធុការទេ ។ តែពេលដែលព្រះឯកុទានត្ថេរ សូត្រឧទានគាថាចប់, ពួកទេវតា ក៏បានថ្វាយសព្ទសាធុការពរក្ងាម ។ ពួកកូនសិស្ស របស់ភិក្ខុទាំងពីររូបនោះ មិនពេញចិត្ត បានតិះដៀលនូវពួកទេវតាថា "បានធ្វើសព្ទសាធុការ ដោយរើសមុខ" ។ ក្រោយមក ពួកភិក្ខុទាំងនោះ បាននិមន្តចេញពីព្រៃហើយ ទៅកាន់វត្តជេតពន បានក្រាបទូលរឿងនោះ ដល់ព្រះសាស្ដា ។*

*ព្រះបរមសាស្ដា ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

ន តាវតា ធម្មធរោ　　យាវតា ពហុ ភាសតិ
យោ ច អប្បម្បិ សុត្វាន　　ធម្មំ កាយេន បស្សតិ
ស វេ ធម្មធរោ ហោតិ　　យោ ធម្មំ នប្បមជ្ជតិ ។

រឿង ព្រះលកុណ្ឌកភទ្ទិយៈ

*បុគ្គលនិយាយច្រើន ដោយហេតុមានប្រមាណប៉ុណ្ណោ ឈ្មោះថា ជាអ្នកទ្រទ្រង់ធម៌ ដោយហេតុមានប្រមាណប៉ុណ្ណោះ មិនទាន់បានទេ លុះត្រាតែបុគ្គលណា ស្តាប់ពុទ្ធវចនៈ សូម្បីមានប្រមាណតិច ហើយឃើញធម៌ ដោយនាមកាយ គឺចិត្តបាន បុគ្គលនោះឯង ទើបបានឈ្មោះថា ជាអ្នកទ្រទ្រង់ធម៌ បុគ្គលណា មិនមើលងាយធម៌ បុគ្គលនោះឯង ឈ្មោះថា ជាអ្នកទ្រទ្រង់ធម៌ ។*

❦❦❦

១៩៧- រឿង ព្រះលកុណ្ឌកភទ្ទិយៈ

*ព្រះបរមសាស្តា ទ្រង់បានប្រារព្ធនូវព្រះលកុណ្ឌកភទ្ទិយៈ ។ សម័យមួយនោះ មានភិក្ខុ ៣០ រូប បានមកគាល់ព្រះសាស្តា ហើយឃើញព្រះថេរៈ និមន្តចេញទៅខាងក្រៅ ។ កាលបើភិក្ខុទាំងនោះ គង់បានស្រួលបួលហើយ, ព្រះសាស្តាទ្រង់ត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ ក្នុងពេលដែលអ្នកទាំងអស់គ្នា ចូលមកគាល់តថាគតនេះ តើបានឃើញព្រះថេរៈ មួយរូបដែរឬទេ?" ។ ភិក្ខុទាំងនោះក្រាបទូលថា "បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះករុណាទាំងឡាយ មិនបានឃើញព្រះថេរៈទេ ឃើញតែសាមណេរ តូចមួយអង្គប៉ុណ្ណោះ" ។ ព្រះសាស្តាទ្រង់ត្រាស់ថា "នេះហើយ គឺព្រះថេរៈ" ។ ភិក្ខុទាំងនោះ ក្រាបទូលសួរថា "ចុះព្រះថេរៈអី ក៏តូចម្ល៉េះ?" ។*

*ព្រះបរមសាស្តាចារ្យ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

**ន តេន ថេរោ ហោតិ យេនស្ស បលិតំ សិរោ**

គាថាធម្មបទប្រែ

បរិបក្កោ វយោ តស្ស　　មោឃជិណ្ណោតិ វុច្ចតិ
យម្ហិ សច្ចញ្ច ធម្មោ ច　　អហឹសា សញ្ញមោ ទមោ
ស វេ វន្តមលោ ធីរោ　　សោ ថេរោតិ បវុច្ចតិ ។

*បុគ្គល មានក្បាលស្កូវហើយ ដោយហេតុណា ឈ្មោះថា ជាថេរៈ ដោយហេតុនោះ មិនទាន់បានទេ វ័យរបស់បុគ្គលនោះ ចាស់ជ្រុលហើយ តថាគត ឲ្យឈ្មោះថា ចាស់មោឃៈ(ចាស់ទទេ) ។ លុះត្រាតែសច្ចៈផង ធម៌ផង ការមិនបៀតបៀនផង ការសង្រួមផង ការទូន្មានខ្លួនផង មាន ក្នុងបុគ្គលណា បុគ្គលនោះឯង ជាអ្នកមានមន្ទិលខ្ជាក់ចោលហើយ ជាអ្នកមានប្រាជ្ញា ទើបបានឈ្មោះថា ថេរៈ ។*

♣ ♣ ♣

១៩៨- រឿងសម្ពហុលភិក្ខុ

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវភិក្ខុច្រើនរូប ជាអ្នកប្រាថ្នានូវលាភសក្ការៈ ។ ភិក្ខុទាំងនោះបានចូលទៅក្រាបទូលសុំឲ្យព្រះសាស្តាទ្រង់ត្រាស់បង្គាប់ដល់ពួកភិក្ខុដែលរៀនធម៌　ក្នុងសំណាក់ភិក្ខុដទៃៗទៀត ពេលរៀនធម៌ចប់ហើយ ត្រូវឲ្យទៅសាកប្រឡង ក្នុងសំណាក់របស់ខ្លួន ជាមុនសិនហើយ ទើបសូត្រស្វាធ្យាយបាន ។*

*ព្រះសាស្តា ទ្រង់ជ្រាបនូវសេចក្តីប្រាថ្នា របស់ភិក្ខុទាំងនោះហើយ មិនទ្រង់អនុញ្ញាតឡើយ ហើយត្រាស់នូវព្រះគាថានេះ ថា ៖*

ន វាក្ករណមត្តេន　　វណ្ណបោក្ខរតាយ វា
សាធុរូបោ នរោ ហោតិ　　ឥស្សុកី មច្ឆរី សឋោ ។

## រឿងហត្ថកភិក្ខុ

**យស្ស ចេតំ សមុច្ឆិន្នំ មូលឃច្ចំ សមូហតំ**
**ស វន្តទោសោ មេធាវី សាធុរូបោតិ វុច្ចតិ ។**

*បុគ្គល មានសេចក្តីប្រណែន មានសេចក្តីកំណាញ់ ជាអ្នកអួតអាង នឹងឈ្មោះថា ជាមនុស្សល្អ ដោយហេតុត្រឹមតែការនិយាយពាក្យពីរោះ ឬ ដោយភាពជាអ្នកមានសម្បុរជាទីគាប់ចិត្ត មិនទាន់បានទេ ។ លុះត្រាតែទោសជាតិ មានឫស្យាជាដើមនេះ បុគ្គលណាបានផ្តាច់ផ្តិលដកឡើង ធ្វើឲ្យមានឫសគល់ដាច់អស់ហើយ បុគ្គលនោះ ជាអ្នកមានទោសខ្ជាក់ចោលហើយ ជាអ្នកមានប្រាជ្ញា ទើបបានឈ្មោះថា ជាមនុស្សល្អ ។*

### ១៩៩- រឿងហត្ថកភិក្ខុ

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវហត្ថកភិក្ខុ ជាអ្នកនិយាយមិនទៀងទាត់ ត្រឡប់ត្រឡិន ។ ថ្ងៃមួយ ភិក្ខុរូបនេះបានណាត់គ្នាជាមួយនឹងពួកតិរ្ថិយ ដើម្បីបុច្ឆាវិសជ្ជនា នូវបញ្ហាគ្នាទៅវិញទៅមក លុះដល់ថ្ងៃកំណត់ហើយ ក៏បានប្រញាប់ទៅកាន់ទីប្រជុំនោះ មុនពេលដែលបានកំណត់ ។ ពួកតិរ្ថិយ កាលបើពុំទាន់ដល់ពេលកំណត់ត្រឹមត្រូវ ក៏មិនទាន់ទៅកាន់ទីប្រជុំនោះដែរ ។ ហត្ថកភិក្ខុ បានអួតអាង ថា "ពួកតិរ្ថិយ មិនហ៊ានមកប្រជុំ ព្រោះខ្លាចខ្លួន" ។*

*ព្រះសាស្តា ទ្រង់ជ្រាបហើយ ទើបទ្រង់ត្រាស់បញ្ជាឲ្យភិក្ខុទៅនិមន្តហត្ថកភិក្ខុនោះ មកគាល់ ដើម្បីជម្រះសេចក្តីនោះ ទ្រង់ត្រាស់*

*ទូន្មានប្រៀនប្រដៅ ហើយត្រាស់ព្រះនូវគាថានេះ ថា ៖*

ន មុណ្ឌកេន សមណោ អព្វតោ អលិកំ ភណំ
ឥច្ឆាលោភសមាបន្នោ សមណោ កឹ ភវិស្សតិ ។
យោ ច សមេតិ បាបានិ អណុំ ថូលានិ សព្វសោ
សមិតត្តា ហិ បាបានំ សមណោតិ បវុច្ចតិ ។

*បុគ្គល មិនបានឈ្មោះថា ជាសមណៈ ដោយភាពជាអ្នកមានក្បាលត្រងោលទេ បុគ្គលអ្នកមិនមានសីលវ័ត និង ធុតង្គវ័ត ពោលតែពាក្យឡេះឡោះ ប្រកបដោយសេចក្តីប្រាថ្នា និង លោភៈ ឈ្មោះថាជាសមណៈ ដូចម្តេចបាន ។ លុះត្រាតែ បុគ្គលណា រម្ងាប់បាបទាំងឡាយទាំងតូចទាំងធំ ដោយប្រការទាំងពួងបាន ទើបបានឈ្មោះថាជាសមណៈ ព្រោះបាបទាំងឡាយ ដែលបុគ្គលនោះរម្ងាប់បានអស់ហើយ ។*

♣ ♣

## ២០០- រឿងអញ្ញតរព្រាហ្មណ៍

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធ នូវព្រាហ្មណ៍ម្នាក់ ជាអ្នកបួសក្រៅសាសនា ដើរបិណ្ឌបាតចិញ្ចឹមជីវិត ដោយគិតថា "ព្រះសមណគោតម ត្រាស់ហៅពួកសាវ័ក របស់ព្រះអង្គថា ភិក្ខុ ការដែលព្រះអង្គត្រាស់ហៅអាត្មាអញថា ភិក្ខុ ជាការប្រពៃ" ហើយចូលទៅគាល់ព្រះសាស្តា បានក្រាបទូលរឿងនោះ ដល់ព្រះអង្គ ។*

*ព្រះសាស្តា ទ្រង់ជ្រាបហើយ ត្រាស់នូវព្រះគាថានេះ ថា ៖*

-៣១០-

រឿង តិត្ថិយ

ន តេន ភិក្ខុ សោ ហោតិ  យាវតា ភិក្ខតេ បរេ
វិសំ ធម្មំ សមាទាយ  ភិក្ខុ ហោតិ ន តាវតា ។
យោធ បុញ្ញញ្ច បាបញ្ច  វាហេត្វា ព្រហ្មចរិយវា
សង្ខាយ លោកេ ចរតិ  ស វេ ភិក្ខូតិ វុច្ចតិ ។

*បុគ្គលណា ដើរសូមជនទាំងឡាយដទៃ ដោយហេតុត្រឹមណា បុគ្គលនោះ មិនឈ្មោះថា ជាភិក្ខុ ដោយហេតុត្រឹមណោះទេ បុគ្គលសមាទានធម៌ជាពិស ឈ្មោះថា ជាភិក្ខុ ដោយហេតុត្រឹមតែការដើរសូមប៉ុណ្ណោះ មិនទាន់បានទេ ។ លុះត្រាតែបុគ្គលណា ក្នុងលោកនេះ បន្សាត់បុណ្យ និង បាបចោលចេញហើយ ជាអ្នកមានការប្រព្រឹត្តិដ៏ប្រសើរ ត្រាច់ទៅ ក្នុងលោក ដោយការចេះដឹង បុគ្គលនោះឯង ទើបបានឈ្មោះថា ជាភិក្ខុ ។*

២០១- រឿង តិត្ថិយ

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវពួកតិត្ថិយ ។ ក្នុងពេលដែលព្រះសាស្តាទ្រង់អនុញ្ញាត ឲ្យពួកភិក្ខុធ្វើអនុមោទនាវិធី, ពួកប្រជាជនបានស្តាប់ពួកភិក្ខុធ្វើការអនុមោទនាហើយ ក៏មានចិត្តជ្រះថ្លា បានធ្វើសក្ការបូជា ដល់ភិក្ខុសង្ឃជាច្រើន ។ ចំណែក ពួកតិត្ថិយ បានដើរឃោសនា ថា “ពួកសាវ័ក របស់ព្រះសាស្តា និយាយច្រើនពេក តែពួកយើងជាមុនី ជាអ្នកនៅស្ងប់ស្ងៀម” ។*

*ព្រះសាស្តាទ្រង់ជ្រាបហើយ ទើបត្រាស់នូវព្រះគាថានេះថា ៖*

គាថាធម្មបទប្រែ

ន មោនេន មុនិ ហោតិ មូឡ្ហរូបោ អវិទ្ទសុ
យោ ច តុលំវ បគ្គយ្ហ វរមាទាយ បណ្ឌិតោ ។
បាបានិ បរិវជ្ជេតិ ស មុនិ តេន សោ មុនិ
យោ មុនាតិ ឧភោ លោកេ មុនិ តេន បវុច្ចតិ ។

*បុគ្គល អ្នកមានសេចក្តីវង្វេងជាធម្មតា មិនមានការចេះដឹង មិនបានឈ្មោះថា ជាមុនី ដោយភាពជាអ្នកស្ងៀមទេ លុះត្រាតែបុគ្គលណា ជាបណ្ឌិត កាន់យកនូវធម៌ដ៏ប្រសើរ វៀរចាកបាបទាំងឡាយ ដូចជាបុគ្គលកាន់ជញ្ជីងហើយថ្លឹងដូច្នោះ បុគ្គលនោះ ទើបឈ្មោះថា ជាមុនី, បុគ្គលនោះ បានឈ្មោះថា ជាមុនី ដោយភាពជាអ្នកស្ងៀមនោះ បុគ្គលណា ដឹងប្រយោជន៍ទាំងពីរ ក្នុងលោក បុគ្គលនោះ ហៅថាមុនី ដោយហេតុនោះ ។*

♣ ❇ ♣

## ២០២- រឿង អរិយពាលិសិក:

*ព្រះសាស្តា ទ្រង់ប្រារព្ធអ្នកចងសន្ទូចម្នាក់ ឈ្មោះអរិយៈ ។ ព្រះអង្គ ទតព្រះនេត្រឃើញនូវឧបនិស្ស័យនៃសោតាបត្តិផល របស់អរិយៈនោះ ទើបយាងទៅទៅរកគាត់ ហើយទ្រង់ត្រាស់សួរ ថា "តើអ្នកឈ្មោះអ្វី?" ។ អរិយៈនោះ ក្រាបទូលថា "ខ្ញុំព្រះករុណា ឈ្មោះអរិយៈ" ។ ព្រះអង្គទ្រង់ត្រាស់ថា "បុគ្គលដែលសម្លាប់សត្វមានជីវិត មិនឈ្មោះថា អរិយៈទេ អ្នកដែលមិនសម្លាប់សត្វមានជីវិត ទើបឈ្មោះថា អរិយៈ" ដូច្នេះហើយ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

រឿងសម្ពហុលភិក្ខុ

ន តេន អរិយោ ហោតិ យេន បាណានិ ហឹសតិ
អហឹសា សព្វបាណានំ អរិយោតិ បវុច្ចតិ ។

*បុគ្គល បៀតបៀនសត្វទាំងឡាយ ដោយហេតុណា មិនបាន ឈ្មោះថា ជាអរិយៈ ដោយហេតុនោះទេ បុគ្គល ដែលតថាគត ហៅថា អរិយៈ ព្រោះមិនបៀតបៀនសត្វទាំងពួង ។*

❃ ❃ ❃

២០៣- រឿងសម្ពហុលភិក្ខុ

*ព្រះបរមសាស្ដា ទ្រង់ប្រារព្ធនូវភិក្ខុទាំងឡាយដែលដល់ព្រម ដោយសីលាទិគុណជាច្រើនរូប គឺពួកខ្លះ ដល់ព្រមដោយសីល ពួកខ្លះ ដល់ព្រមដោយធុតង្គ ពួកខ្លះ ដល់ព្រមដោយពហុស្សូត ពួកខ្លះ ដល់ព្រមដោយឈានសមាបត្តិ ពួកខ្លះ ចូលចិត្តនៅក្នុងទីសេនាសនៈស្ងាត់ ។ ភិក្ខុទាំងនោះ បានគិតគ្នាថា "ព្រះអរហត្តផល ជារឿងធម្មតា មិនមែនជាហេតុធ្វើឲ្យពិបាកនុ៎ះទេ ចង់បានថ្ងៃណា ក៏នឹងបានថ្ងៃនោះឯង" ដូច្នេះហើយ ទៅក្រាបទូលរឿងនោះ ដល់ព្រះសាស្ដា ។*

*ព្រះបរមសាស្ដាចារ្យ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

ន សីលព្វតមត្តេន ពាហុសច្ចេន វា បន
អថ វា សមាធិលាភេន វិវិត្តសយនេន វា
ផុសាមិ នេក្ខម្មសុខំ អបុថុជ្ជនសេវិតំ
ភិក្ខុ វិស្សាសមាបាទិ អប្បត្តោ អាសវក្ខយំ ។

*ម្នាលភិក្ខុ បើភិក្ខុមិនទាន់ដល់នូវការអស់អាសវៈទេ កុំអាល*

*ទុកចិត្ត ដោយគុណត្រឹមតែសីល និង វត្ត ឬ ដោយភាពជាអ្នកចេះដឹងច្រើនឡើយ មួយទៀត ដោយការបានសមាធិ ឬ ដោយការដេកក្នុងទីស្ងាត់ ឬក៏ ដោយគុណមានប្រមាណប៉ុណ្ណេះថា អាត្មាអញពាល់ត្រូវនេក្ខមសុខ ដែលបុថុជ្ជនមិនដែលចួបប្រសព្វ ដូច្នេះឡើយ ។*

**ចប់ ធម្មដ្ឋវគ្គ ទី ១៩**

## មគ្គវគ្គ ទី ២០

### ២០៤- រឿង បញ្ចសតភិក្ខុ

*ព្រះបរមសាស្តាទ្រង់ប្រារព្ធនូវភិក្ខុ ៥០០ រូប ។ ភិក្ខុទាំងអស់នោះ បានមកប្រជុំគ្នា សន្ទនាអំពីផ្លូវដែលខ្លួនបានទៅហើយថា "ផ្លូវពីស្រុកនេះ ទៅស្រុកនោះ មិនរាបស្មើ ផ្លូវពីស្រុកនេះ ទៅស្រុកនោះរាបស្មើ មានក្រួសច្រើន មិនមានក្រួស" យ៉ាងនេះជាដើម ។*

*ព្រះសាស្តា ទ្រង់ស្តេចយាងមក ក្នុងទីប្រជុំនោះ ត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងអស់គ្នា ប្រជុំគ្នាសន្ទនាអំពីរឿងអ្វី?" ។ ភិក្ខុទាំងនោះ ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះករុណាទាំងឡាយ ប្រជុំសន្ទនាគ្នាអំពីរឿងនេះ" ។*

*ព្រះសាស្តាទ្រង់សម្តែងថា "ម្នាលភិក្ខុទាំងឡាយ ផ្លូវដែលពួកអ្នកប្រារព្ធនេះ គឺជាផ្លូវដែលមាននៅខាងក្រៅទេ ភិក្ខុ ចំរើនកម្មដ្ឋានក្នុងអរិយមគ្គ ទើបប្រសើរ ព្រោះថា កាលបើភិក្ខុ ធ្វើយ៉ាងនេះ នឹងរួចផុត អំពីសេចក្តីទុក្ខទាំងពួងបាន" ហើយត្រាស់នូវព្រះគាថានេះ ថា ៖*

## រឿងបញ្ចសតភិក្ខុ

មគ្គានដ្ឋង្គិកោ សេដ្ឋោ សច្ចានំ ចតុរោ បទា
វិរាគោ សេដ្ឋោ ធម្មានំ ទិបទានញ្ច ចក្ខុមា
ឯសេវ មគ្គោ នត្ថញ្ញោ ទស្សនស្ស វិសុទ្ធិយា ។
ឯតម្ហិ តុម្ហេ បដិបជ្ជថ មារស្សេតំ បមោហនំ
ឯតម្ហិ តុម្ហេ បដិបន្នា ទុក្ខស្សន្តំ ករិស្សថ ។
អក្ខាតោ វោ មយា មគ្គោ អញ្ញាយ សល្លសត្ថនំ
តុម្ហេហិ កិច្ចំ អាតប្បំ អក្ខាតារោ តថាគតា
បដិបន្នា បមោក្ខន្តិ ឈាយិនោ មារពន្ធនា ។

*ផ្លូវមានអង្គ ៨ ប្រសើរជាងផ្លូវទាំងឡាយ បទ ៤ គឺ អរិយសច្ច ប្រសើរជាងសច្ចៈទាំងឡាយ វិរាគធម៌ ប្រសើរជាងធម៌ទាំងឡាយ មួយទៀត ព្រះតថាគត មានចក្ខុ ប្រសើរជាងសត្វទ្វេបាទទាំងឡាយ ផ្លូវនេះឯង ប្រព្រឹត្តទៅដើម្បីសេចក្ដីបរិសុទ្ធិនៃទស្សនៈ ផ្លូវដទៃមិនមានឡើយ ។ ព្រោះហេតុនោះ អ្នកទាំងឡាយ ចូរដើរទៅកាន់ផ្លូវនោះចុះ ផ្លូវនេះ ជាផ្លូវញ៉ាំងមារឲ្យវង្វេង អ្នកទាំងឡាយ ដើរទៅកាន់ផ្លូវនេះហើយ អាចនឹងធ្វើឲ្យរួចផុតទុក្ខបាន ។ ផ្លូវនេះហើយ ដែលតថាគតដឹងថា ជាផ្លូវកំចាត់បង់កូនសរ ទើបប្រាប់ដល់អ្នកទាំងឡាយ សេចក្ដីព្យាយាម ជាគ្រឿងញ៉ាំងកិលេសឲ្យក្ដៅសព្វ អ្នកទាំងឡាយគប្បីធ្វើ ព្រះតថាគតទាំងឡាយ គ្រាន់តែជាអ្នកប្រាប់ (ផ្លូវឲ្យទេ) ជនទាំងឡាយ បើបានធ្វើដំណើរទៅហើយ មានការពិនិត្យ នឹងរួចផុតចាកចំណងរបស់មារបាន ។*

## គាថាធម្មបទប្រែ

### ២០៥- រឿងអបរបញ្ចសតភិក្ខុ

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវភិក្ខុ ៥០០ រូបផ្សេងទៀត ។ ភិក្ខុទាំងនោះ រៀនកម្មដ្ឋាន ក្នុងសំណាក់នៃព្រះសាស្តាហើយ ក៏បាន ចូលទៅ ចំរើនកម្មដ្ឋាន ក្នុងព្រៃស្ងាត់មួយ, មិនយូរប៉ុន្មាន ភិក្ខុទាំង នោះ ក៏បានត្រឡប់មកគាល់ព្រះសាស្តាវិញ ដើម្បីសុំប្តូរនូវកម្មដ្ឋាន ថ្មីទៀត ព្រោះខ្លួនមិនទាន់បានសម្រេចអរហត្តផល ។*

*ព្រះសាស្តា ទ្រង់ជ្រាបហើយ ត្រាស់នូវព្រះគាថានេះ ថា ៖*

សព្វេ សង្ខារា អនិច្ចាតិ   យទា បញ្ញាយ បស្សតិ
អថ និព្វិន្ទតិ ទុក្ខេ   ឯស មគ្គោ វិសុទ្ធិយា ។
សព្វេ សង្ខារា ទុក្ខាតិ   យទា បញ្ញាយ បស្សតិ
អថ និព្វិន្ទតិ ទុក្ខេ   ឯស មគ្គោ វិសុទ្ធិយា ។
សព្វេ ធម្មា អនត្តាតិ   យទា បញ្ញាយ បស្សតិ
អថ និព្វិន្ទតិ ទុក្ខេ   ឯស មគ្គោ វិសុទ្ធិយា ។

*កាលណា បុគ្គលយល់ឃើញ ដោយប្រាជ្ញាថា សង្ខារទាំង ពួង មិនទៀង ដូច្នេះ កាលណោះ រមែងនឿយណាយ ក្នុងសេចក្តីទុក្ខ នេះជាផ្លូវនៃសេចក្តីបរិសុទ្ធិ ។*

*កាលណា បុគ្គលយល់ឃើញ ដោយប្រាជ្ញាថា សង្ខារទាំង ពួង នាំមកនូវសេចក្តីទុក្ខ ដូច្នេះ កាលណោះ រមែងនឿយណាយ ក្នុងសេចក្តីទុក្ខ នេះជាផ្លូវនៃសេចក្តីបរិសុទ្ធិ ។*

*កាលណា បុគ្គលយល់ឃើញ ដោយប្រាជ្ញាថា ធម៌ទាំងពួង*

*មិនមែនជារបស់ខ្លួន ដូច្នេះ កាលណោះ រមែងនឿយណាយ ក្នុងសេចក្ដីទុក្ខ នេះជាផ្លូវនៃសេចក្ដីបរិសុទ្ធិ ។*

❇ ❇ ❇

## ២០៦- រឿង ព្រះបធានកម្មិកតិស្សត្ថេរ

*ព្រះបរមសាស្ដា ទ្រង់ប្រារព្ធ នូវព្រះបធានកម្មិកតិស្សត្ថេរ ។ ព្រះថេរៈ បានឃើញនូវព្រះសាស្ដា ទ្រង់ធ្វើបដិសណ្ឋារកិច្ច ជាមួយភិក្ខុទាំងឡាយដែលរៀនកម្មដ្ឋាន ជាមួយខ្លួន ទៅបំពេញសមណធម៌ បានសំរេចអរហត្តផលហើយ ត្រឡប់មកគាល់ព្រះអង្គវិញ ក៏មានសេចក្ដីប្រាថ្នាចង់ឲ្យព្រះអង្គធ្វើបដិសណ្ឋារកិច្ច ជាមួយនឹងខ្លួន ទើបប្រញាប់ចេញទៅដើរចង្ក្រម ក្នុងទីស្ងាត់មួយ តែម្នាក់ឯង រហូតអស់មួយរាត្រី មានការងោកងក់ ងុយសិង យ៉ាងខ្លាំង ដើរចង្ក្រមទៅមកបានដួលភ្ជាត់បាក់ជើង ស្រែកថ្ងូរយំ ឮសូរផ្អើលគេឯងអស់ ។ ពួកភិក្ខុទាំងឡាយ មានការភ្ញាក់ផ្អើល អ៊ូអរឡើង បាននាំគ្នាជួយយកទៅព្យាបាល រហូតដល់ភ្លឺស្វាង ធ្វើឲ្យខកខាន លែងបានទៅបិណ្ឌបាតទាំងអស់គ្នា ។*

*ព្រះសាស្ដា ស្ដេចយាងមកហើយ ទ្រង់ត្រាស់សម្ដែងទោសនៃបុគ្គលអ្នកធ្វើកិច្ចការដែលត្រូវធ្វើជាមុន យកមកធ្វើជាខាងក្រោយ ហើយត្រាស់ នូវព្រះគាថានេះ ថា ៖*

ឧដ្ឋានកាលម្ហិ អនុដ្ឋហានោ
យុវា ពលី អាលសិយំ ឧបេតោ

គាថាធម្មបទប្រែ

**សំសន្នសង្កប្បមនោ កុសីតោ**
**បញ្ញាយ មគ្គំ អលសោ ន វិន្ទតិ ។**

*បុគ្គល នៅកំលោះ មានកំឡាំង ទាស់តែប្រកបដោយសេចក្តីខ្ជិលច្រអូស មិនប្រឹងប្រែង ក្នុងពេលដែលគួរប្រឹងប្រែង មានសេចក្តីត្រិះរិះ ក្នុងចិត្តលិចចុះ ក្នុងអកុសលវិតក្កៈ ជាមនុស្សខ្ជិល បុគ្គលខ្ជិលនោះ រមែងមិនបានចួបប្រទះ នូវផ្លូវនៃបញ្ញាឡើយ ។*

♣ ♣

២០៧- រឿងសូករប្រេត

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវសូករប្រេត ។ ក្នុងអតីតជាតិសូករប្រេតនេះ បានបួសជាភិក្ខុ ក្នុងសាសនានៃព្រះពុទ្ធទ្រង់ព្រះនាមកស្សបៈ បានពោលពាក្យចាក់ដោត ញុះញង់ព្រះថេរៈពីរូប ដែលមានសីលបរិសុទ្ធ ឲ្យឈ្លោះប្រកែក បែកបាក់សាមគ្គីគ្នា ព្រោះកម្មដែលបានពោលពាក្យញុះញង់នោះឯង លុះស្លាប់ទៅ ក៏បានទៅកើតក្នុងអវិចីនរក អស់មួយពុទ្ធន្តរ លុះមកដល់សាសនានេះ ក៏បានមកកើតជាប្រេត មានដងខ្លួនដូចមនុស្ស តែមានក្បាលដូចសត្វជ្រូក នៅអាស្រ័យ លើភ្នំគិជ្ឈកូដ ។*

*ព្រះមហាមោគ្គល្លាន បានឃើញប្រេតនេះហើយ ក៏និយាយទៅកាន់ព្រះលក្ខណត្ថេរ ក្នុងទីចំពោះព្រះភក្ត្រ នៃព្រះសាស្តា ។*

*ព្រះបរមសាស្តាចារ្យ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

**វាចានុរក្ខី មនសា សុសំវុតោ**

រឿង ព្រះពោឋិលត្ថេរ

**កាយេន ច អកុសលំ ន កយិរា**
**ឯតេ តយោ កម្មបថេ វិសោធយេ**
**អារាធយេ មគ្គមិសិប្បវេទិតំ ។**

*បុគ្គលគប្បីជាអ្នករក្សាវាចា សង្រួមឲ្យល្អ ដោយចិត្ត ទាំងមិនគប្បីធ្វើអកុសល ដោយកាយ បុគ្គល គប្បីជម្រះកម្មបថទាំង ៣ នេះឲ្យបានបរិសុទ្ធ និង គប្បីត្រេកអរចំពោះមគ្គ ដែលលោកអ្នកស្វែងរកគុណដ៏ល្អ សម្តែងទុកហើយ ។*

❊ ❊ ❊

២០៨- រឿង ព្រះពោឋិលត្ថេរ

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវព្រះពោឋិលៈ ជាអ្នករៀនចប់ព្រះត្រៃបិដក ជាអាចារ្យបង្រៀនធម៌ ដល់ភិក្ខុទាំងឡាយ ។ ថ្ងៃមួយព្រះពោឋិលៈ បានឮព្រះសាស្តា ត្រាស់ហៅខ្លួនថា “ភិក្ខុ មានគម្ពីរទទេ” ក៏មានសេចក្តីសង្វេគ តក់ស្លុត យ៉ាងខ្លាំង ហើយបានចូលទៅនៅអាស្រ័យជាមួយនឹងភិក្ខុដែលជាព្រះអរហន្ត ចំនួន ៣០ រូប ក្នុងព្រៃស្ងាត់មួយ ។ ជាបឋម ព្រះពោឋិលៈ បានចូលទៅរកព្រះថេរៈ ជាប្រធានមុនគេ ហើយសុំយកព្រះថេរៈ ធ្វើជាទីពឹងរបស់ខ្លួន តែព្រះថេរៈ ជាប្រធាននោះ បានបដិសេធ មិនព្រមទទួល ។ ព្រះពោឋិលៈក៏បានចូលទៅរកព្រះថេរៈ ដទៃៗ ទៀត ដើម្បីធ្វើជាទីពឹង តែព្រះថេរៈទាំងនោះ មិនព្រមទទួល ។ នៅទីបំផុត ក៏បានចូលទៅរកសាមណេរអាយុ ៧ ឆ្នាំ ។ សាមណេរ បានគង់ធ្វើព្រងើយ ដូចជាមិនចង់ទទួល,*

-៣១៩-

## គាថាធម្មបទប្រែ

ព្រះបោឋិលៈ បានទទួចសុំអន្វរករសាមណេរច្រើន លើកច្រើនគ្រា, ពេលដែលព្រះបោឋិលៈ បានលះបង់មានះហើយ សាមណេរ ក៏បានប្រាប់ ថា “នៃលោកអាចារ្យ ដំបូកមួយ មានរន្ធដល់ទៅ ៦ សត្វទន្សងចូលទៅនៅ ខាងក្នុងបាន តាមរន្ធតែមួយ បុគ្គលអ្នកមានប្រាថ្នាចង់ចាប់សត្វអន្សងនោះ ត្រូវតែញ៉ុក នូវរន្ធទាំង ៥ ហើយចាំចាប់វា នៅក្បែរមាត់រន្ធ ដែលវាលូនចូលទៅ យ៉ាងណាមិញ, លោកអាចារ្យត្រូវបិទទ្វារទាំង ៥ ហើយកំណត់យកការងារ ក្នុងមនោទ្វារ ក៏យ៉ាងនោះដែរ” ។

ព្រះបោឋិលៈ បានស្តាប់ យ៉ាងដូច្នេះហើយ ក៏កើតមានបញ្ញាយល់ជាក់ច្បាស់ ឥតមានសង្ស័យ ព្រោះលោកជាពហុស្សូត ហើយបានចាប់ផ្តើមបំពេញសមណធម៌ ។

ព្រះសាស្តា ទ្រង់បានបញ្ចេញព្រះរស្មីទៅ បីដូចជាទ្រង់គង់នៅ ក្នុងទីចំពោះមុខ ហើយត្រាស់នូវព្រះគាថានេះ ថា ៖

យោគា វេ ជាយតេ ភូរិ អយោគា ភូរិសង្ខយោ
ឯតំ ទ្វេធា បថំ ញត្វា ភវាយ វិភវាយ ច
តថត្តានំ និវេសេយ្យ យថា ភូរិ បវឌ្ឍតិ ។

ប្រាជ្ញា រមែងកើតមកពីការប្រកប ការវិនាសប្រាជ្ញា កើតមកអំពីការមិនប្រកប, អ្នកមានប្រាជ្ញា ដឹងការប្រកប និង ការមិនប្រកបទាំង ២ នេះ ថា ជាគន្លង នៃសេចក្តីចំរើន និង សេចក្តីវិនាសហើយគប្បីតម្កល់ខ្លួនទុក ដោយប្រការដែលប្រាជ្ញា នឹងចំរើនឡើងបាន ។

## ២០៩- រឿងមហាលកភិក្ខុ

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវពួកភិក្ខុចាស់ៗ ជាច្រើនរូប ។ ក្នុងពេលដែលនៅជាគ្រហស្ថ ភិក្ខុ ចាស់ទាំងនោះ ជាអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ លុះមកបួសហើយ ក៏បានកសាងសាលាមួយខ្នងយ៉ាងធំ នៅខាងក្រោយព្រះវិហារ ហើយអាស្រ័យនៅ ក្នុងសាលានោះទាំងអស់គ្នា ។ ភរិយាចាស់ របស់ភិក្ខុមួយរូប ឈ្មោះនាងមធុ-បាណិកា ជាអ្នកធ្វើចង្ហាន់ប្រគេន ជារៀងរាល់ថ្ងៃ ។ ក្រោយមក នាងមធុបាណិកា ក៏បានធ្វើកាលកិរិយាស្លាប់ចោលទៅ ។ ពួកភិក្ខុចាស់ទាំងនោះ បានទៅប្រជុំគ្នា ស្រែកយំ ព្រួកង៉រំពង ពេញសាលា ព្រោះនឹកស្រណោះអាឡោះអាល័យ ដល់នាងមធុបាណិកានោះខ្លាំងពេកៗ ភិក្ខុដទៃៗ ទៀត បានឮដូច្នេះហើយ ក៏នាំយករឿងនោះ ទៅនិយាយគ្នា ដោយប្រការផ្សេងៗ ។

ព្រះសាស្តា យាងមក ក្នុងទីប្រជុំនោះ ត្រាស់គាថានេះ ថា ៖

វនំ ឆិន្ទថ មា រុក្ខំ វនតោ ជាយតេ ភយំ
ឆេត្វា វនំ វនថញ្ច និព្វនា ហោថ ភិក្ខវោ ។

យាវញ្ហិ វនថោ ន ឆិជ្ជតិ
អណុមត្តោបិ នរស្ស នារិសុ
បដិពទ្ធមនោវ តាវ សោ
វច្ឆោ ខីរបកោវ មាតរិ ។

អ្នកទាំងឡាយ ចូរកាត់កិលេសដូចជាព្រៃចេញ ចូរកុំកាត់ដើមឈើ (ព្រោះ) ភ័យ កើតអំពីកិលេសដូចជាព្រៃ, ម្នាលភិក្ខុទាំង

ឡាយ អ្នកទាំងឡាយ ចូរកាត់កិលេសដូចជាព្រៃផង កិលេសដូចជាដើមឈើដែលដុះ ក្នុងព្រៃផង ហើយ ចូរជាអ្នកកុំមានកិលេស ដូចជាព្រៃឡើយ ព្រោះថា កិលេស ដូចជាដើមឈើដែលដុះក្នុងព្រៃ របស់នរជន សូម្បីមានប្រមាណតិចក៏ដោយ បើកាត់មិនទាន់ដាច់ ក្នុងពួកនារី ដរាបណា នរជននោះឯង តែងមានចិត្តជាប់ជំពាក់ចំពោះ ក្នុងពួកនារី ដូចកូនគោនៅកំពុងបៅដោះ ដែលមានចិត្តជាប់ជំពាក់នឹងមេដរាបនោះ ។

* * *

## ២១០- រឿងសទ្ធិវិហារិកព្រះសារីបុត្រ

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវសទ្ធិវិហារិក របស់ព្រះធម្មសេនាបតីសារីបុត្រ ដែលជាកូនជាងមាសម្នាក់ ។ ព្រះសារីបុត្រ បានបង្រៀនឲ្យចំរើនអសុភកម្មដ្ឋាន ។ ភិក្ខុរូបនោះ ខិតខំព្យាយាម ចំរើនអស់រយៈពេល ៤ ខែ តែមិនបានសម្រេចមគ្គផលអ្វីឡើយ ។ ព្រះសារីបុត្រ បាននាំទៅគាល់ព្រះសាស្តា ។ ព្រះអង្គ ទ្រង់បានប្រទានផ្កាឈូកដល់ភិក្ខុរូបនោះ ឲ្យយកទៅធ្វើបរិកម្ម ជាលោហិតកសិណ ។ ភិក្ខុនោះ បានទទួលយកផ្កាឈូកនោះ ទៅធ្វើជាបរិកម្ម លុះឃើញនូវផ្កាឈូកស្វិតស្រពោនហើយ ក៏បានកំណត់យកមកប្រៀបធៀប នឹងរាងកាយរបស់ខ្លួន ហើយពិចារណាឃើញត្រៃលក្ខណ៍ ថា “ជារបស់មិនទៀង ជាទុក្ខ ជាអនត្តា” ។

ព្រះសាស្តា ទ្រង់បានបញ្ចេញព្រះរស្មីទៅ ដូចជាទ្រង់គង់នៅ

ក្នុងទីចំពោះមុខ នៃភិក្ខុនោះ ហើយត្រាស់នូវព្រះគាថានេះ ថា ៖

ឧច្ឆិន្ទ សិនេហមត្តនោ
កុមុទំ សារទិកំវ បាណិនា
សន្តិមគ្គមេវ ព្រូហយ
និព្វានំ សុគតេន ទេសិតំ ។

អ្នកចូរដកសេចក្តីស្រឡាញ់ របស់ខ្លួនចេញ ដូចបុគ្គលដកផ្កាឈូក ដែលកើត ក្នុងសរទកាល ដោយដៃ អ្នកចូរបណ្តុះ នូវផ្លូវសន្តិភាព តែម៉្យាង ព្រោះព្រះនិព្វាន ព្រះសុគតទ្រង់ត្រាស់សំដែងទុកហើយ ។

♣ ❇ ♣

## ២១១- រឿង មហាធនពាណិជ

ព្រះបរមសាស្តា ទ្រង់បានប្រារព្ធនូវមហាធនពាណិជម្នាក់ ។ ពាណិជនេះ ជាអ្នកមានទ្រព្យសម្បត្តិច្រើន អាស្រ័យនៅ ក្នុងទីក្រុងសាវត្ថី បានធ្វើដំណើរទៅលក់ដូរ លុះធ្វើដំណើរដល់ពាក់កណ្តាលផ្លូវ ក៏មានភ្លៀងធ្លាក់មកយ៉ាងច្រើន មានទឹកដក់ពេញស្ទឹង អស់រយៈពេល ៧ ថ្ងៃ គាត់បានឈប់សម្រាកនៅពាក់កណ្តាលផ្លូវនោះឯង ។

ព្រះសាស្តា ទ្រង់ត្រាស់នឹងព្រះអានន្ទ ថា "ម្នាលអានន្ទ នៅតែ ៧ ថ្ងៃទៀតទេ មច្ចុរាជ នឹងមកផ្តាច់យកអាយុជីវិត របស់មហាធនពាណិជហើយ" ។ ព្រះអានន្ទ បានក្រាបទូលសុំព្រះសាស្តា ដើម្បីទៅឲ្យឱវាទ ដល់មហាធនពាណិជនោះ ។ មហាធនពាណិជ លុះបាន

ស្តាប់នូវឱវាទ របស់ព្រះអានន្ទហើយ ក៏មានចិត្តជ្រះថ្លា បាននិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន មកទទួលភត្តាហារ ហើយបានបរិច្ចាគមហាទាន ដើម្បីទុកជាស្បៀងទៅបរលោកនាយ ។

ព្រះសាស្តាទ្រង់ធ្វើអនុមោទនាហើយ ត្រាស់ព្រះគាថានេះ ថា

ឥធ វស្សំ វសិស្សាមិ ឥធ ហេមន្តគិម្ហិសុ
ឥតិ ពាលោ វិចិន្តេតិ អន្តរាយំ ន ពុជ្ឈតិ ។

ជនពាល រមែងគិតខុស ដូច្នេះថា អាត្មាអញ នឹងនៅក្នុងទីនេះអស់វស្សានរដូវ អាត្មាអញ នឹងនៅ ក្នុងទីនេះ ក្នុងហេមន្តរដូវ និងគិម្ហរដូវ គេមិនដឹងច្បាស់ នូវសេចក្តីអន្តរាយ (ដែលកើតមាន ដល់ខ្លួន) ឡើយ ។

❋ ❋ ❋

## ២១២- រឿងនាងកីសាគោតមី

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវនាងកីសាគោតមី ។ នាងមានកូនមួយ តែកូននោះ បានស្លាប់ទៅ នាងដើរពកូនដែលស្លាប់នោះ ទៅរកថ្នាំ ដើម្បីយកមកព្យាបាល ធ្វើឲ្យកូននាងរស់ឡើងវិញ ។

ពួកមហាជន បានឃើញនាងហើយ ក៏គិតថា “នាង ជាស្រីឆ្កួត” ។ គ្រានោះ មានបណ្ឌិតម្នាក់ បានណែនាំឲ្យនាងទៅគាល់ព្រះសាស្តា នៅឯវត្តជេតពន ។ នាងកីសាគោតមី បានចូលទៅក្រាបទូលសុំថ្នាំនឹងព្រះសាស្តា ។ ព្រះបរមសាស្តាចារ្យ ទ្រង់ត្រាស់ពន្យល់អំពីត្រៃលក្ខណ៍ ឲ្យនាងបានយល់ ហើយត្រាស់នូវព្រះគាថានេះ ថា ៖

តំ បុត្តបសុសម្មត្តំ ព្យាសត្តមនសំ នរំ
សុត្តំ គាមំ មហោឃោវ មច្ចុ អាទាយ គច្ឆតិ ។

*មច្ចុ គឺសេចក្តីស្លាប់ តែងនាំយកនរជន អ្នកស្រវឹងជប់ ក្នុងកូន និង សត្វចិញ្ចឹម មានចិត្តជាប់ជំពាក់ ក្នុងអារម្មណ៍ផ្សេងៗ នោះ ដូចទឹកជំនន់ដ៏ធំ ក្តួចយកអ្នកស្រុកដែលដេកលក់ យ៉ាងនោះឯង ។*

♣ ❇ ♣

## ២១៣- រឿង នាងបដាចារាថេរី

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធ នូវនាងបដាចារាថេរី ។ នាងបដាចារា ជាស្រីដែលមានសេចក្តីទុក្ខ ដ៏ធំក្រៃលែង ព្រោះស្វាមី កូន មាតាបិតា បងប្រុសស្រី ដែលជាទីស្រឡាញ់ របស់នាង បានស្លាប់ចោលទាំងអស់, នាង ជាស្រីវិកលចរិត ភ្លេចភ្លាំងសតិស្មារតី សូម្បីតែសម្លៀកបំពាក់ ក៏មិនជាប់នឹងខ្លួនដែរ ដើរទៅតែខ្លួនទទេ ត្រោះទៅកាន់វត្តជេតពន ក្នុងខណៈដែលព្រះសាស្តា កំពុងតែសម្តែងព្រះធម៌ទេសនា ដល់ពួកពុទ្ធបរិស័ទ ។*

*ព្រះសម្មាសម្ពុទ្ធ ទ្រង់ទតព្រះនេត្រឃើញនាងបដាចារា កំពុងតែដើរចូលមក ទើបទ្រង់ត្រាស់ដាស់តឿន គ្រើនរំឭក ឲ្យនាងត្រឡប់មានសតិស្មារតីឡើងវិញ ហើយត្រាស់នូវព្រះគាថានេះ ថា ៖*

ន សន្តិ បុត្តា តាណាយ ន បិតា នបិ ពន្ធវា
អន្តកេនាធិបន្នស្ស នត្ថិ ញាតីសុ តាណតា
ឯតមត្ថវសំ ញត្វា បណ្ឌិតោ សីលសំវុតោ

គាថាធម្មបទប្រែ

**និព្វានគមនំ មគ្គំ ខិប្បមេវ វិសោធយេ ។**

*កាលបុគ្គល ត្រូវមច្ចុគ្របសង្កត់ហើយ កូនទាំងឡាយ មិនមាន ដើម្បីជាទីពឹង បិតា ក៏មិនមាន ទាំងផៅពង្ស ក៏មិនមាន ដើម្បីជាទីពឹងឡើយ សេចក្តីទីពឹង ក្នុងញាតិទាំងឡាយ ក៏មិនមាន បណ្ឌិតដឹងអំណាចប្រយោជន៍នេះហើយ គួរជាអ្នកសង្រួមក្នុងសីល គួរប្រញាប់ប្រញាល់ជម្រះផ្លូវ ជាទីទៅកាន់ព្រះនិព្វាន ឲ្យទាល់តែបាន ។*

**ចប់ មគ្គវគ្គ ទី ២០**

បកិណ្ណកវគ្គ ទី ២១

២១៤- រឿង បុព្វកម្មរបស់ព្រះអង្គ

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវបុព្វកម្មរបស់ព្រះអង្គ ។ ក្នុងពេលដែលទីក្រុងវេសាលីកើតមានទុរ្ភិក្សអត់បាយ, ពួកមនុស្សដែលក្រីក្រទាំងឡាយ បានស្លាប់ជាច្រើន រហូតដល់សាកសពខ្មោចទាំងនោះ មានក្លិនស្អុយ ពាសពេញទាំងទីក្រុង ព្រោះក្លិនស្អុយនោះ ក៏បណ្តាលឲ្យកើតមាន អហិវាតករោគ ឡើង ។ ទាំងពួកអមនុស្ស ក៏ចូលទៅនៅច្រើន ។ ពួកប្រជាជន បានប្រជុំគ្នាប្រឹក្សា ដោះស្រាយបញ្ហានោះ ដោយវិធីផ្សេងៗ ។ តែភ័យអាសន្ននោះ ក៏មិនបានស្ងប់រម្ងាប់ឡើយ ។ ក្រោយមក ប្រជាជន ក៏បាននាំគ្នាទៅកអារាធនាព្រះសម្មាសម្ពុទ្ធ ពីទីក្រុងរាជគ្រឹះមក ហើយបាននាំគ្នា បោសសម្អាតព្រះនគរ ឲ្យអស់ក្លិនស្អុយ ដើម្បីចាំទទួលព្រះសាស្តា ។*

## រឿង បុញ្ញកម្មរបស់ព្រះអង្គ

*ពេលដែលព្រះសាស្ដា ស្ដេចយាងមកដល់ហើយ, ស្រាប់តែមេឃ បង្អុលភ្លៀងចុះមក នាំយកសាកសពខ្មោច និង កិ្ខនស្អុយនោះអស់ទៅ ។ ព្រះសាស្ដា ទ្រង់បានឲ្យព្រះអានន្ទសូត្ររតនសូត្រ ជុំវិញកំពែងបីជាន់ ។ រោគភ័យអាសន្នទាំងនោះ ក៏បានស្ងប់រម្ងាប់បាត់អស់ទៅហើយ ក្នុងគ្រានោះឯង ។*

*ក្នុងពេលដែលព្រះសាស្ដា ទ្រង់ស្ដេចយាងមកក្ដី ស្ដេចយាងត្រឡប់ទៅវិញក្ដី, ពួកមនុស្ស និង ទេវតាទាំងឡាយ រហូតដល់គ្រុឌនាគជាដើម បានធ្វើសក្ការបូជា ជាច្រើន ថ្វាយព្រះអង្គ ។ ក្នុងគ្រាដែលព្រះសាស្ដាយាងមក កាន់ទីក្រុងរាជគ្រឹះវិញ, ពួកភិក្ខុទាំងឡាយបាននាំគ្នា ពោលសរសើរព្រះពុទ្ធានុភាព របស់ព្រះអង្គ ។*

*ព្រះសាស្ដាចារ្យ ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ នេះមិនមែនជាពុទ្ធានុភាពទេ គឺជាអានុភាពនៃការបរិច្ចាគ ក្នុងអតីតជាតិដែលតថាគត បានធ្វើមកហើយ" ក្នុងទីបញ្ចប់ ទ្រង់ត្រាស់ នូវព្រះគាថានេះ ថា៖*

មត្តាសុខបរិច្ចាគា បស្សេ ចេ វិបុលំ សុខំ
ចជេ មត្តាសុខំ ធីរោ សម្បស្សំ វិបុលំ សុខំ ។

*បើបុគ្គលឃើញសេចក្ដីសុខ ដ៏ធំទូលាយ ព្រោះលះបង់សេចក្ដីសុខល្មមប្រមាណ អ្នកមានប្រាជ្ញា កាលឃើញសេចក្ដីសុខដ៏ធំទូលាយ គប្បីលះបង់សេចក្ដីសុខល្មមប្រមាណចេញ ។*

# គាថាធម្មបទប្រែ

## ២១៥- រឿង កុក្កុដណ្ឌខាទិកា

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវនាងកុមារិកាម្នាក់ជាអ្នកចូលចិត្តញ៉ាំពងមាន់ ។ មេមាន់បានឃើញនាងកុមារិកា យកពងរបស់ខ្លួនរឿយៗ ក៏ក្រោធខឹង យ៉ាងខ្លាំង ហើយបានចងកម្មពៀរជាមួយនាង ។ មេមាន់ និង នាងកុមារិកា បានចងពៀរវេរានឹងគ្នា ដូចជារឿងនាងកុលធីតា និង នាងយក្ខិនីដែរ បានស៊ីគ្នាម្តងម្នាក់ ។ ក្នុងជាតិជាទីបំផុត នាងយក្ខិនី បានស៊ីកូននាងកុលធីតា អស់ពីរលើក ក្នុងលើកទីបី នាងកុលធីតា បានពកូន រត់ចូលទៅ ក្នុងវត្តជេតពន ។*

*ពេលនោះ ព្រះសាស្តា កំពុងតែសម្តែងព្រះធម៌ទេសនា ដល់ពួកពុទ្ធបរិស័ទ ទ្រង់ទតព្រះនេត្រឃើញហើយ ត្រាស់នូវព្រះគាថានេះ ថា ៖*

**បរទុក្ខូបធានេន យោ អត្តនោ សុខមិច្ឆតិ**
**វេរសំសគ្គសំសដ្ឋោ វេរា សោ ន បរិមុច្ចតិ ។**

*បុគ្គលណា ប្រាថ្នានូវសេចក្តីសុខដើម្បីខ្លួន ដោយបន្តុទុក្ខឲ្យអ្នកដទៃ បុគ្គលនោះ ឈ្មោះថា ប្រឡូកប្រឡល់ហើយ ដោយការជាប់ជំពាក់ គឺពៀរ រមែងមិនរួចចាកពៀរឡើយ ។*

❁ ❁ ❁

## ២១៦- រឿង ភទ្ទិយភិក្ខុ

*ព្រះបរមសាស្តា ទ្រង់បានប្រារព្ធ នូវពួកភិក្ខុភទ្ទិយៈ ជាអ្នកខ្វល់ខ្វាយ ក្នុងការប្រដាប់ស្បែកជើង មិនបានសិក្សាព្រះធម៌វិន័យ*

លះបង់ចោល នូវកិច្ចវត្ត របស់ខ្លួន ។

ព្រះសាស្តាទ្រង់ជ្រាបហើយ ទើបត្រាស់នូវព្រះគាថានេះ ថា ៖

យំ ហិ កិច្ចំ តទបវិទ្ធំ អកិច្ចំ បន ករីយតិ
ឧន្នឡានំ បមត្តានំ តេសំ វឌ្ឍន្តិ អាសវា ។
យេសញ្ច សុសមារទ្ធា និច្ចំ កាយគតា សតិ
អកិច្ចន្តេ ន សេវន្តិ កិច្ចេ សាតច្ចការិនោ
សតានំ សម្បជានានំ អត្ថំ គច្ឆន្តិ អាសវា ។

ពួកភិក្ខុណា លះបង់ចោលកិច្ចដែលខ្លួនត្រូវធ្វើ តែត្រឡប់ជាទៅធ្វើកិច្ចដែលខ្លួនមិនត្រូវធ្វើទៅវិញ, អាសវៈទាំងឡាយ តែងចំរើនដល់ពួកភិក្ខុទាំងនោះ ដែលជាអ្នកមានសេចក្តីប្រមាទ ជាអ្នកមានមានះ ដូចជាដើមបបុសលើកឡើងហើយ ។

លុះតែសតិប្រព្រឹត្តទៅ ក្នុងកាយជានិច្ច ដែលពួកភិក្ខុណាប្រារព្ធល្អប្រពៃហើយ ពួកភិក្ខុទាំងនោះ រមែងជាអ្នកធ្វើការដែលគួរធ្វើរឿយៗ មិនធ្វើការដែលមិនគួរធ្វើ, អាសវៈទាំងឡាយ របស់ពួកភិក្ខុនោះ ដែលជាអ្នកមានសតិ មានសម្បជញ្ញៈ រមែងដល់នូវការអស់ទៅ ។

♣ ❈ ♣

## ២១៧- រឿងលកុណ្ឌកភទ្ទិយៈ

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវព្រះលកុណ្ឌកភទ្ទិយៈ ដែលបានមកគាល់ព្រះអង្គហើយ ក៏ក្រាបថ្វាយបង្គំលាទៅវិញ ។ ពេល

នោះ មានភិក្ខុ អាគន្តុកៈ ជាច្រើន បានមកគាល់ព្រះសាស្តា ដូចគ្នាដែរ ហើយបានឃើញព្រះលកុណ្តកភទ្ទិយៈ និមន្តចេញ ទៅខាងក្រៅ ។ ក្នុងពេលដែលពួកភិក្ខុអាគន្តុកៈទាំងនោះ ចូលទៅគាល់ហើយ, ព្រះសាស្តា ទ្រង់ត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ ពួកអ្នកបានឃើញដែរឬទេ គឺភិក្ខុដែលបាននិមន្តចេញទៅខាងក្រៅនោះ បានសម្លាប់ឪពុកម្តាយហើយ រួចផុតអំពីសេចក្តីទុក្ខ ហើយបានសម្រេចអរហត្តផល ។

ក្នុងគ្រានោះ ភិក្ខុទាំងឡាយ មានសេចក្តីសង្ស័យ បែរមើលមុខគ្នា ព្រោះមិនយល់ច្បាស់នូវព្រះពុទ្ធដីកា ទើបក្រាបទូលសួរព្រះបរមសាស្តា ។

ព្រះបរមសាស្តាចារ្យ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

មាតរំ បិតរំ ហន្ត្វា រាជានោ ទ្វេ ច ខត្តិយេ
រដ្ឋំ សានុចរំ ហន្ត្វា អនីឃោ យាតិ ព្រាហ្មណោ ។
មាតរំ បិតរំ ហន្ត្វា រាជានោ ទ្វេ ច សោត្ថិយេ
វេយ្យគ្ឃបញ្ចមំ ហន្ត្វា អនីឃោ យាតិ ព្រាហ្មណោ ។

បុគ្គល សម្លាប់តណ្ហាដូចមាតាផង សម្លាប់អស្មិមានៈ ដូចបិតាផង សម្លាប់សស្សតទិដ្ឋិ និង ឧច្ឆេទទិដ្ឋិ ដូចស្តេចជាក្សត្រពីរព្រះអង្គផង សម្លាប់អាយតនៈ ដូចជាដែនប្រព្រឹត្តទៅមួយអន្លើ ដោយបុរសអ្នកដើរតាម គឺស្មៀនផង រមែងបានទៅជាខីណាសវព្រាហ្មណ៍ ជាអ្នកមិនមានទុក្ខ ។

## រឿង នាយទារុសាកដិកៈ

*បុគ្គល សម្លាប់តណ្ហាដូចមាតាផង សម្លាប់អស្មិមានះ ដូចបិតាផង សម្លាប់សស្សតទិដ្ឋិ និង ឧច្ឆេទទិដ្ឋិ ដូចជាស្តេច ជាព្រាហ្មណ៍ទាំងពីរផង សម្លាប់វិចិកច្ឆា ដូចជាខ្លាធំជាគម្រប់ ៥ ផង (ដែលនៅស្កាត់ផ្លូវ) បានហើយ រមែងបានទៅជាខីណាសវព្រាហ្មណ៍ ជាអ្នកមិនមានទុក្ខ ។*

## ២១៨- រឿង នាយទារុសាកដិកៈ

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធ នូវកូននាយទារុសាកដិកៈ ។ ទាំងកូនទាំងឪពុក ជាអ្នកជ្រះថ្លា ក្នុងព្រះពុទ្ធសាសនា ។ សម័យថ្ងៃមួយ កូនរបស់គាត់ បានទៅលេងកូនគ្លី ជាមួយនឹងកូនរបស់ជនដទៃ ដែលជាអ្នកមិច្ឆាទិដ្ឋិ ។ ពេលលេងកូនគ្លី កូនអ្នកសម្មាទិដ្ឋិ បានរំឭកព្រះពុទ្ធគុណ មានបទថា “**ឥតិបិ សោ ភគវា**” ប៉ុណ្ណោះជាដើម ហើយ បានលេងឈ្នះកូនអ្នកមិច្ឆាទិដ្ឋិ គ្រប់ពេលវេលា ។*

*ថ្ងៃមួយនោះ ឪពុករបស់ក្មេងនោះ បាននាំគេទៅរកឧស ក្នុងព្រៃ ហើយបានដាក់រទេះ នៅក្បែរព្រៃខ្មោច ហើយលែងគោ ឲ្យដើរទៅរកស៊ី តាមចំណូលចិត្តរបស់វា ។ លុះដល់ល្ងាច គោទាំងពីរ ក៏បានដោយទៅ តាមហ្វូងចូលទៅ ក្នុងស្រុក ។ ពេលព្រលប់ ទើបនាយទារុសាកដិកៈ ទៅ តាមរកគោទាំងពីរនោះឃើញ ។ ក្នុងពេលជាមួយគ្នានោះ អ្នកនៅយាមទ្វារ បានបិទទ្វារចេញ-ចូលទាំងអស់ ។ នាយទារុសាកដិកៈ កុំនដំណើរ មិនអាចចេញទៅរកកូនបានឡើយ ។*

គាថាធម្មបទប្រែ

*ចំណែកឯ កូនរបស់គាត់ បាននៅចាំរទេះតែម្នាក់ឯង វេលាយប់ជ្រៅបន្តិចហើយ ក្មេងនោះ បានសូត្ររំឮកព្រះពុទ្ធគុណ ។ ពួកអមនុស្សក្នុងព្រៃនោះ បាននាំគ្នាមកជួយថែរក្សា ការពារ មិនឲ្យមានអន្តរាយកើតមាន ដល់ក្មេងនោះ ។*

*ក្រោយមក ព្រះរាជាក្រុងមគធៈ ទ្រង់ជ្រាបហើយ ទើបនាំយកក្មេងនោះ ទៅគាល់ព្រះសាស្តា ទ្រង់ត្រាស់សរសើរពុទ្ធានុស្សតិនិង ទ្រង់ត្រាស់សួរព្រះអង្គថា "តើមានធម៌ដទៃទៀតទេ ដែលមានអានុភាព ដូចជាពុទ្ធានុស្សតិនេះ?" ។*

*ព្រះសាស្តាចារ្យ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា
យេសំ ទិវា ច រត្តោ ច និច្ចំ ពុទ្ធគតា សតិ ។
សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា
យេសំ ទិវា ច រត្តោ ច និច្ចំ ធម្មគតា សតិ ។
សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា
យេសំ ទិវា ច រត្តោ ច និច្ចំ សង្ឃគតា សតិ ។
សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា
យេសំ ទិវា ច រត្តោ ច និច្ចំ កាយគតា សតិ ។
សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា
យេសំ ទិវា ច រត្តោ ច អហឹសាយ រតោ មនោ ។
សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា

## រឿងនាយទារុសាកដិកៈ

**យេសំ ទិវា ច រត្តោ ច ភាវនាយ រតោ មនោ ។**

សតិ របស់ជនទាំងឡាយណា ដែលឋិតនៅ ក្នុងព្រះពុទ្ធគុណ អស់កាលជានិច្ច ទាំងថ្ងៃទាំងយប់ ជនទាំងឡាយនោះ ឈ្មោះថា ជាសាវ័ក របស់ព្រះគោតម រមែងភ្ញាក់រឮកៗ ដោយប្រពៃ សព្វកាល ។

សតិ របស់ជនទាំងឡាយណា ដែលឋិតនៅក្នុងព្រះធម្មគុណ អស់កាលជានិច្ច ទាំងថ្ងៃទាំងយប់ ជនទាំងឡាយនោះ ឈ្មោះថា ជាសាវ័ក របស់ព្រះគោតម រមែងភ្ញាក់រឮកៗ ដោយប្រពៃ សព្វកាល ។

សតិ របស់ជនទាំងឡាយណា ដែលឋិតនៅ ក្នុងព្រះសង្ឃគុណ អស់កាលជានិច្ច ទាំងថ្ងៃទាំងយប់ ជនទាំងឡាយនោះ ឈ្មោះថា ជាសាវ័ក របស់ព្រះគោតម រមែងភ្ញាក់រឮកៗ ដោយប្រពៃ សព្វកាល ។

សតិ របស់ជនទាំងឡាយណា ដែលឋិតនៅ ក្នុងកាយ អស់កាលជានិច្ច ទាំងថ្ងៃទាំងយប់ ជនទាំងឡាយនោះ ឈ្មោះថា ជាសាវ័ក របស់ព្រះគោតម រមែងភ្ញាក់រឮកៗ ដោយប្រពៃ សព្វកាល ។

ចិត្ត របស់ជនទាំងឡាយណា ត្រេកអរហើយ ក្នុងកិរិយាមិនបៀតបៀនគេ ទាំងថ្ងៃទាំងយប់ ជនទាំងនោះ ឈ្មោះថា ជាសាវ័ក របស់ព្រះគោតម រមែងភ្ញាក់រឮក ៗ ដោយប្រពៃ សព្វកាល ។

ចិត្ត របស់ជនទាំងឡាយណា ត្រេកអរហើយ ក្នុងមេត្តាភាវនា ទាំងថ្ងៃទាំងយប់ ជនទាំងឡាយនោះ ឈ្មោះថា ជាសាវ័ក របស់ព្រះគោតម រមែងភ្ញាក់រឮកៗ ដោយប្រពៃ សព្វកាល ។

## គាថាធម្មបទប្រែ

### ២១៩- រឿងភិក្ខុវជ្ជីបុត្រ

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវភិក្ខុវជ្ជីបុត្រ ជាព្រះរាជឱរស របស់ក្សត្រវជ្ជី ដែលបានលះបង់រាជសម្បត្តិ ចេញទៅសាងផ្នួស នៅអាស្រ័យ ក្នុងព្រៃស្ងាត់ ក្បែរក្រុងវេសាលី ។ សម័យថ្ងៃមួយ ភិក្ខុវជ្ជីបានឮសូរសំឡេងតូរ្យតន្ត្រី យ៉ាងគគ្រឹកគគ្រេង ដែលគេបន្លឹងឡើងក្នុងទីក្រុង ក៏មានចិត្តតក់ស្លុតរន្ធត់ ពន់ប្រមាណ នឹកគិតដល់ខ្លួនឯងថា "អាត្មាអញ ជាមនុស្សអកំព្ល អនាថា មករស់នៅ ក្នុងព្រៃស្ងាត់ស្ងាត់ តែម្នាក់ឯង ឥតមានគ្នីគ្នា ប្រៀបដូចជាកំណាត់ឈើ ដែលគេបោះបង់ចោល" ហើយ មានសេចក្ដីខ្វល់ខ្វាយអន្ទះអន្ទែង ប្រាថ្នាចង់លាចាកសិក្ខាបទ ទើបបានចូលទៅគាល់ព្រះសាស្តា ក្រាបទូលរឿងនេះថ្វាយដល់ព្រះអង្គ ។*

*ព្រះសាស្តាចារ្យ ទ្រង់ជ្រាបហើយត្រាស់នូវព្រះគាថានេះថា៖*

ទុប្បព្វជ្ជំ ទុរភិរមំ ទុរាវាសា ឃរា ទុក្ខា
ទុក្ខោ សមានសំវាសោ ទុក្ខានុបតិតទ្ធគូ
តស្មា ន ចទ្ធគូ សិយា ន ច ទុក្ខានុបតិតោ សិយា ។

*ការចេញបួស បានដោយកម្រ ការត្រេកអរត្រូវបានដោយកម្រ ផ្ទះទាំងឡាយ មានការគ្រប់គ្រងមិនល្អ នាំឲ្យកើតទុក្ខ ការនៅរួមជាមួយជនស្មើគ្នា (ដែលមិនមានសេចក្ដីកោតក្រែង) នាំឲ្យកើតទុក្ខ បុគ្គលអ្នកដើរផ្លូវឆ្ងាយគឺវដ្ដៈ តែងត្រូវសេចក្ដីទុក្ខធ្លាក់ជាប់តាម ព្រោះហេតុនោះ បុគ្គល មិនគប្បីជាអ្នកដើរផ្លូវឆ្ងាយផង មិនគប្បីជា*

-៣៣៤-

រឿង ចិត្តគហបតី

*អ្នកត្រូវសេចក្ដីទុក្ខ ធ្លាក់ជាប់តាមផង ។*

❃❃❃

## ២២០- រឿង ចិត្តគហបតី

*ព្រះបរមសាស្ដា ទ្រង់ប្រារព្ធនូវចិត្តគហបតី ។ ថ្ងៃមួយ គាត់មានបំណងចង់ទៅគាល់ព្រះសាស្ដា ក្នុងក្រុងសាវត្ថី ហើយបានចេញអំពីស្រុក ព្រមជាមួយបរិវារ ជាច្រើន លុះទៅដល់ពាក់កណ្ដាលផ្លូវ មានពួកទេវតា មកជប់លៀង ដោយភោជនាហារ គ្រប់ៗ គ្នា ។*

*ពេលដែលចិត្តគហបតី ចូលទៅគាល់ព្រះសាស្ដា ក្ដី ពេលត្រឡប់ទៅវិញ ក្ដី  ពួកទេវតា បានបណ្ដាល ឲ្យមានភ្លៀងរតនៈ ៧ ប្រការ ធ្លាក់ចុះមក ពេញរទេះរបស់គាត់ទាំងអស់ ។*

*ក្នុងពេលដែលចិត្តគហបតីត្រឡប់ទៅវិញ, ព្រះអានន្ទ បានចូលទៅ ក្រាបទូលសួរព្រះសាស្ដា ថា “បពិត្រព្រះអង្គ ដ៏ចំរើន តើលាភសក្ការៈ កើតឡើង ដល់ចិត្តគហបតីនោះ ព្រោះហេតុដែលបានមកគាល់ព្រះអង្គតែប៉ុណ្ណោះទេ ឬក៏គាត់ទៅទីដទៃទៀត លាភសក្ការៈកើតឡើង ដូចគ្នាដែរ?” ។*

*ព្រះសាស្ដា ទ្រង់បានត្រាស់ថា “ម្នាលអានន្ទ ទោះបីជាចិត្តគហបតី ទៅទីណាក៏ដោយ ក៏លាភសក្ការៈ កើតឡើងបានដូចគ្នាដែរ” ដូច្នេះហើយ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

សទ្ធោ សីលេន សម្បន្នោ   យសោភោគសមប្បិតោ
យំ យំ បទេសំ ភជតិ   តត្ថ តត្ថេវ បូជិតោ ។

## គាថាធម្មបទប្រែ

បុគ្គលអ្នកមានសទ្ធា បរិបូណ៌ដោយសីល ស្គប់ស្កល់ ដោយយស និង ភោគសម្បត្តិ គប់រកប្រទេសណាៗ មានគេបូជា ក្នុងប្រទេសនោះៗ ។

✻ ✻ ✻

## ២២១-រឿង នាងចូឡសុភទ្ទា

ព្រះបរមសាស្ដា ទ្រង់ប្រារព្ធនូវនាងចូឡសុភទ្ទា ដែលជាធីតារបស់អនាថបិណ្ឌិកសេដ្ឋី ។ នាងបានទៅនៅជាមួយស្វាមីនាង ក្នុងឧគ្គនគរ ។ ក្រុមគ្រួសារស្វាមីនាង ជាមនុស្សមិច្ឆាទិដ្ឋិ ជ្រះថ្លាចំពោះពួកអចេលកៈ ។ ឪពុកក្មេក របស់នាង បានពន្យល់ឲ្យនាងគោរពបូជាពួកអចេលកៈទាំងនោះ ។ តែនាង មិនបានជ្រះថ្លា ចំពោះពួកអចេលកៈនោះទេ ថែមទាំងបានជេរប្រទេចពួកអចេលកៈ ដោយប្រការផ្សេងៗ នាងបានពោលសរសើរ នូវព្រះសម្មាសម្ពុទ្ធ តែម្យ៉ាងប៉ុណ្ណោះ ។

ឪពុកក្មេក របស់នាង បានសួរថា "តើនាងអាចបង្ហាញព្រះរបស់នាង ឲ្យពួកយើងឃើញបានដែរឬទេ?" ។ នាងបានឆ្លើយថា "នាងខ្ញុំ អាចបង្ហាញបាន" ហើយចាត់ចែងមហាទាន ដើម្បីនឹងប្រគេនដល់ព្រះសាស្ដា នាងបានរំឭកដល់ព្រះពុទ្ធគុណ ហើយទៅអារាធនានិមន្តព្រះសាស្ដា ព្រមទាំងភិក្ខុសង្ឃ មកទទួលភត្តាហារ នៅឯផ្ទះរបស់ខ្លួន ។

ក្នុងថ្ងៃជាមួយគ្នានោះ អនាថបិណ្ឌិកសេដ្ឋី ក៏បានអារាធនា

និមន្តព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន មកទទួលភត្តាហារ នៅឯផ្ទះរបស់ខ្លួនដែរ ។ តែព្រះសាស្ដា ទ្រង់មិនបានទទួលកិច្ចនិមន្ត របស់អនាថបិណ្ឌិកសេដ្ឋី ទេ ព្រោះព្រះអង្គទទួលនាងសុភទ្ទា មុនហើយ ។

អនាថបិណ្ឌិកសេដ្ឋី មានសេចក្ដីសង្ស័យ ទើបក្រាបទូលសួរព្រះអង្គ ថា "បពិត្រព្រះអង្គដ៏ចំរើន នាងចូឡសុភទ្ទា នៅឧគ្គនគរឯណោះទេ តើបានអារាធនានិមន្តព្រះអង្គ តាំងពីពេលណាមក?" ។

ព្រះសាស្ដាទ្រង់ត្រាស់ពន្យល់ហើយ ត្រាស់ព្រះគាថានេះថា៖

**ទូរេ សន្តោ បកាសេន្តិ ហិមវន្តោវ បព្វតោ**
**អសន្តេត្ថ ន ទិស្សន្តិ រត្តិំ ខិត្តា យថា សរា ។**

ពួកសប្បុរស រមែងប្រាកដ ក្នុងទីឆ្ងាយបាន ដូចភ្នំហិមពាន្តយ៉ាងដូច្នោះឯង ចំណែកពួកអសប្បុរស (បើទុកជាឋិតនៅ) ក្នុងទីជិតក៏រមែងមិនប្រាកដបានដែរ ដូចព្រួញដែលបុគ្គលបាញ់ ក្នុងពេលរាត្រីយ៉ាងដូច្នោះឯង ។

♣ ♣ ♣

## ២២២- រឿង ព្រះឯកវិហារី

ព្រះបរមសាស្ដា ទ្រង់ប្រារព្ធនូវព្រះឯកវិហារី ។ ព្រះថេរៈ ជាអ្នកចូលចិត្តនៅ តែម្នាក់ឯងប៉ុណ្ណោះ មិនចូលចិត្តនៅប្រឡូកប្រឡំជាមួយនឹងពួកគណៈឡើយ ។ ភិក្ខុទាំងឡាយ បានឃើញការប្រព្រឹត្តិរបស់ព្រះថេរៈហើយ ទើបចូលទៅក្រាបទូលដល់ព្រះសាស្ដា ។

ព្រះសាស្ដា ទ្រង់ប្រទាន នូវសព្វសាធុការពរ ត្រាស់ឲ្យភិក្ខុ

គាថាធម្មបទប្រែ

យកធ្វើជាគំរូ ហើយត្រាស់នូវព្រះគាថានេះ ថា ៖

ឯកាសនំ ឯកសេយ្យំ ឯកោ ចរមតន្ទិតោ
ឯកោ ទមយមត្តនោ វនន្តេ រមិតោ សិយា ។

បុគ្គល គួរគប់រកទីអង្គុយតែម្នាក់ឯង ទីដេកតែម្នាក់ឯង ជាអ្នកត្រាច់ទៅតែម្នាក់ឯង មិនជាអ្នកខ្ជិលច្រអូស ជាអ្នកតែម្នាក់ឯងទូន្មានខ្លួន គួរជាអ្នកត្រេកអរ ក្នុងព្រៃ ។

**ចប់ បកិណ្ណកវគ្គ ទី ២១**

និរយវគ្គ ទី ២២

២២៣- រឿង នាងសុន្ទរី

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវនាងសុន្ទរីបរិព្វាជិកា ។ នាងបានរួមគំនិតជាមួយនឹងពួកតិរ្ថិយ ដើម្បីនឹងធ្វើឧបាយកល ដូចជាខ្លួននាងបាននៅ ក្នុងកុដិ ជាមួយនឹងព្រះសាស្តា ក្នុងរាត្រីស្ងាត់ បានធ្វើឲ្យពួកប្រជាជន មានសេចក្តីសង្ស័យ ហើយពោលតិះដៀលព្រះអង្គដោយប្រការផ្សេងៗ ។

ពួកអញ្ញតិរ្ថិយ មានគោលបំណង ចង់នឹងបង្កើតរឿងរ៉ាវ ឲ្យធំជាងនេះទៅទៀត ទើបបានជួលពួកអ្នកប្រមឹក ឲ្យទៅសម្លាប់នូវនាងសុន្ទរីនោះចោលហើយ បានឲ្យគេយកសពនាងទៅកប់ទុក ជិតព្រះគន្ធកុដិ របស់ព្រះសាស្តា ស្រេចហើយ ពួកអញ្ញតិរ្ថិយទាំងនោះ បានធ្វើបន្លំ ដូចជាដើររកសពខ្មោចនាងសុន្ទរី លុះបានឃើញហើយ បាន

*ចោទព្រះសាស្តា ថា "ព្រះអង្គ បានសម្លាប់នាងសុន្ទរីចោល ដើម្បីកុំឲ្យបែកការណ៍" ។*

*ព្រះរាជា ក្រុងសាវត្ថី ទ្រង់បានស៊ើបអង្កេតរករឿងពិត លុះទ្រង់ជ្រាបច្បាស់ហើយ ទើបទ្រង់ដាក់ទោស ដល់ពួកតិរ្ថិយទាំងនោះទៅតាមទោសានុទោស របស់ខ្លួន ។ ភិក្ខុទាំងឡាយ បានយករឿងនោះទៅក្រាបទូល ដល់ព្រះសាស្តា ។*

*ព្រះសម្មាសម្ពុទ្ធ បរមគ្រូ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

អភូតវាទី និរយំ ឧបេតិ
យោ វាបិ កត្វា ន ករោមិច្ចាហ
ឧភោបិ តេ បេច្ច សមា ភវន្តិ
និហីនកម្មា មនុជា បរត្ថ ។

*បុគ្គល ពោលពាក្យមិនពិត រមែងទៅកាន់នរក ឬ បុគ្គលណា (ធ្វើអំពើអាក្រក់) ហើយនិយាយថា អញមិនធ្វើទេ (បុគ្គលនោះ) ក៏ទៅកាន់នរក ដូចគ្នាដែរ បុគ្គល ទាំងពីរនាក់ ដែលមានអំពើ ដ៏ទាបថោក (ស្មើគ្នានោះ) រមែងជាអ្នកស្មើគ្នា (ដោយគតិ) ក្នុងលោកខាងមុខទៀត ។*

❁❁❁

## ២២៤- រឿង សត្វត្រូវទុក្ខបៀតបៀន

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធពួកសត្វ ដែលត្រូវអានុភាព នៃទុច្ចរិត បៀតបៀន ។ នៅក្នុងសាសនា នៃព្រះកស្សបទសពល, ពួក*

*សត្វទាំងនោះ ជាភិក្ខុអាក្រក់លាមក, ក្នុងសាសនានេះ សត្វទាំងនោះ ត្រូវបានទទួលនូវផលកម្មនោះ នៅលើភ្នំគិជ្ឈកូដ មានរាងកាយ និង គ្រឿងបរិក្ខារ ត្រូវភ្លើងឆេះ ។ ព្រះមហាមោគ្គល្លាន បានសន្ទនារឿង នោះ ជាមួយនឹងព្រះលក្ខណត្ថេរ ក្នុងទីចំពោះព្រះភក្ត្រព្រះសាស្តា ។*

*ព្រះសម្មាសម្ពុទ្ធ ទ្រង់ជ្រាបហើយ ត្រាស់ព្រះគាថានេះ ថា ៖*

**កាសាវកណ្ឋា ពហវោ បាបធម្មា អសញ្ញតា**
**បាបា បាបេហិ កម្មេហិ និរយន្តេ ឧបបជ្ជរេ ។**

*ពួកជនច្រើននាក់ ដែលមានកព័ន្ធព័ទ្ធ ដោយសំពត់កាសាវៈ តែជាអ្នកមានធម៌ដ៏លាមក មិនបានសង្រួមហើយ ពួកជនលាមកទាំង នោះ រមែងទៅកើត ក្នុងនរក ដោយកម្មទាំងឡាយ ដ៏លាមកនោះ ។*

♣ ❇ ♣

## ២២៥- រឿងវគ្គុមុទាតីរិយភិក្ខុ

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវពួកភិក្ខុ ដែលនៅឯត្រើយ ស្ទឹងម្ខាង ឈ្មោះវគ្គុមុទា ។ ភិក្ខុទាំងនោះ បាននាំគ្នា ពោលអួតឧត្តរិ-មនុស្សធម៌ ដែលមិនមានក្នុងខ្លួន ដើម្បីជាគ្រឿងចិញ្ចឹមជីវិត ក្នុង ពេលដែលកើតទុរ្ភិក្ស ។*

*គ្រានោះ ព្រះសាស្តា ទ្រង់ជ្រាបហើយ ទើបបានតិះដៀល ដោយ ប្រការផ្សេងៗ ទ្រង់បានបញ្ញត្តសិក្ខាបទ ហាមដល់ភិក្ខុទាំងឡាយ មិន ឲ្យប្រព្រឹត្តតទៅទៀត ទ្រង់ប្រទានព្រះឱវាទ ដល់ភិក្ខុទាំងនោះហើយ ត្រាស់នូវព្រះគាថានេះ ថា ៖*

រឿងខេមកសេដ្ឋីបុត្រ

សេយ្យោ អយោគុឡោ ភុត្តោ តត្តោ អគ្គិសិខូបមោ
យញ្ចេ ភុញ្ជេយ្យ ទុស្សីលោ រដ្ឋបិណ្ឌំ អសញ្ញតោ ។

*បព្វជិត អ្នកទ្រុស្តសីល សូវបរិភោគដុំដែក ដែលកំពុងតែក្តៅ មានពណ៌ដូចអណ្តាតភ្លើង ប្រសើរជាង បព្វជិត អ្នកទ្រុស្តសីល មិនសង្រួម បរិភោគដុំបាយអ្នកដែន នឹងប្រសើរដូចម្តេចបាន ។*

♣ ♣ ♣

២២៦- រឿងខេមកសេដ្ឋីបុត្រ

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវសេដ្ឋីបុត្រម្នាក់ ឈ្មោះខេមកៈ ជាចៅរបស់អនាថបិណ្ឌិកសេដ្ឋី ។ ខេមកៈនេះ ជាអ្នកមានរូបសម្បត្តិ មុខមាត់ស្រស់ស្អាតល្អ គួរជាទីពេញចិត្តដល់អ្នកផង ។ ស្រី ណាឃើញហើយ ស្រីនោះ កើតមានសេចក្តីស្រឡាញ់ខេមកៈនោះភ្លាម ។ ខេមកៈ សេដ្ឋីបុត្រ បានប្រព្រឹត្តខុសព្រហ្មចរិយនឹងស្ត្រីៗ ជារឿយៗ ។ សេដ្ឋី ជាបិតា បាននាំខេមកៈនោះ ទៅគាល់ព្រះសាស្តា ដើម្បីឲ្យព្រះអង្គ ជួយអប់រំទូន្មានប្រៀនប្រដៅ កុំឲ្យប្រព្រឹត្តកាមេសុមិច្ឆាចារៈ ជាបន្តទៅទៀត ។*

*ព្រះបរមសាស្តាចារ្យ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

ចត្តារិ ឋានានិ នរោ បមត្តោ
អាបជ្ជតី បរទារូបសេវី ។
អបុញ្ញលាភំ ន និកាមសេយ្យំ
និន្ទំ តតិយំ និរយំ ចតុត្ថំ ។

គាថាធម្មបទប្រែ

**អបុញ្ញលាភោ ច គតី ច បាបិកា**
**ភិតស្ស ភីតាយ រតី ច ថោកិកា**
**រាជា ច ទណ្ឌំ គរុកំ បណេតិ**
**តស្មា នរោ បរទារំ ន សេវេ ។**

*នរជន អ្នកប្រមាទហើយ សេពនូវប្រពន្ធ របស់បុគ្គលដទៃ រមែងដល់នូវហេតុនៃសេចក្តីទុក្ខ ៤ យ៉ាង គឺ ទី១ បានរបស់ដែលមិនមែនជាបុណ្យ ទី២ ដេកមិនបានតាមសេចក្តីប្រាថ្នា ទី៣ ការតិះដៀល ទី៤ ការធ្លាក់នរក ។ ហេតុនៃសេចក្តីទុក្ខ ៤ យ៉ាងទៀត គឺ បានរបស់ដែលមិនមែនជាបុណ្យ ១, មានគតិអាក្រក់ ១, សេចក្តីត្រេកអររបស់បុរសអ្នកខ្លាច ជាមួយនឹងស្រ្តីដែលខ្លាចដែរ មានប្រមាណតិច ១ ព្រះរាជា នឹងដាក់អាជ្ញាយ៉ាងធ្ងន់ ១ ព្រោះហេតុនោះ បុរស មិនគួរសេពប្រពន្ធ របស់បុគ្គលដទៃឡើយ ។*

❇ ❇ ❇

## ២២៧- រឿង ទុព្វចភិក្ខុ

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវភិក្ខុមួយរូប ជាអ្នកដែលគេអប់រំទូន្មាន ប្រៀនប្រដៅ បានដោយលំបាក ។ សម័យថ្ងៃមួយ មានភិក្ខុដទៃទៀត បានចូលមកសួរអំពីរឿងបោចស្មៅថា "មានទោសដូចម្តេច?" ។ ទុព្វចភិក្ខុនោះ បានឆ្លើយថា "បើបានសម្តែងអាបត្តិហើយនោះ វានឹងមានទោសអ្វីទៅ" ហើយ ក៏បានបោចស្មៅឲ្យភិក្ខុទាំងនោះមើលថែមទៀត ។ ពួកភិក្ខុទាំងឡាយ បានឃើញ យ៉ាងនេះហើយ ក៏*

# រឿងទុព្វចភិក្ខុ

បាននាំយករឿងនោះទៅ ក្រាបទូលថ្វាយព្រះសាស្តាទ្រង់ជ្រាប ។

ព្រះបរមសាស្តា ទ្រង់ជ្រាបហើយត្រាស់នូវព្រះគាថានេះថា៖

កុសោ យថា ទុគ្គហិតោ ហត្ថមេវានុកន្តតិ
សាមញ្ញំ ទុប្បរាមដ្ឋំ និរយាយូបកឌ្ឍតិ ។
យំ កិញ្ចិ សិថិលំ កម្មំ សង្កិលិដ្ឋញ្ច យំ វតំ
សង្កស្សរំ ព្រហ្មចរិយំ ន តំ ហោតិ មហប្ផលំ ។
កយិរា ចេ កយិរាថេនំ ទឡ្ហមេនំ បរក្កមេ
សិថិលោ ហិ បរិព្វាជោ ភិយ្យោ អាកិរតេ រជំ ។

ស្បូវភ្លាំង ដែលបុគ្គលកាន់មិនចំណាប់ រមែងលះដៃឯង យ៉ាងណាមិញ, ភាពជាសមណៈ ដែលបព្វជិត កាន់មិនបានស៊ប់ សួនហើយ រមែងទាញបព្វជិតនោះទៅនរក យ៉ាងនោះឯង ។

កម្មឯណាមួយ ដែលធូរថយក្តី វតឯណាមួយ ដែលសៅហ្មង ក្តី ព្រហ្មចរិយធម៌ ដែលបុគ្គលរឮក ដោយសេចក្តីរង្កៀស ក្តី កម្ម ទាំង ៣ នោះ ជារបស់មិនមានផលច្រើនឡើយ ។

បើបុគ្គលធ្វើ គប្បីធ្វើកិច្ចនោះឲ្យមែនទែន គប្បីប្រឹងប្រែង ធ្វើ កិច្ចនោះឲ្យមាំមួន ព្រោះថា សមណធម៌ ជាគ្រឿងវៀរចាកកិលេស ដែលធូរថយ រមែងរោយធូលី គឺរាគាទិក្កិលេស ដល់បុគ្គល ដោយ ក្រៃលែង ។

♣ ❇ ♣

# គាថាធម្មបទប្រែ

## ២២៨- រឿង ស្រីអ្នកប្រណែន

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវស្រីប្រណែនម្នាក់ ។ ស្វាមីរបស់នាង បានយកនាងទាសីស្រីបម្រើ ក្នុងផ្ទះរបស់ខ្លួន មកធ្វើជាប្រពន្ធចុង ។ ថ្ងៃមួយ ស្វាមីនាងបានចេញទៅខាងក្រៅ ។ នាងប្រពន្ធដើម បានចាប់ប្រពន្ធចុងនោះចង ហើយយកកាំបិត មកកាត់ត្រចៀកច្រមុះ ស្រេចហើយ ទើបយកទៅលាក់ទុក នៅក្នុងបន្ទប់ ដើម្បីកុំឲ្យស្វាមីនាងដឹង ។ លុះដល់ស្វាមី ត្រឡប់មកវិញ នាងប្រពន្ធដើមនោះធ្វើជាបបួលស្វាមីទៅស្តាប់ធម៌ នៅឯវត្តជេតពន នាទីក្រុងសាវត្ថី ។*

*ថ្ងៃនោះឯង ពួកញាតិ របស់នាងទាសី (ប្រពន្ធចុង) បានចូលមករកនាង ក៏ស្រាប់តែឃើញនាងជាប់ចំណង ហើយបានស្រាយចំណងចេញ ។ នាងទាសីនោះ បានរួចពីចំណងហើយ ក៏ធ្វើដំណើរទៅកាន់វត្តជេតពន ដើម្បីស្តាប់ធម៌ទេសនា លុះទៅដល់ហើយ នាងបានចូលទៅ ក្រាបថ្វាយបង្គំទូលរឿងនោះ ដល់ព្រះសាស្តា ។*

*ព្រះសាស្តាទ្រង់ជ្រាបហើយ ទ្រង់ត្រាស់នូវព្រះគាថានេះថា ៖*

**អកតំ ទុក្កតំ សេយ្យោ   បច្ឆា តប្បតិ ទុក្កតំ**
**កតញ្ច សុកតំ សេយ្យោ   យំ កត្វា នានុតប្បតិ ។**

*អំពើអាក្រក់ដែលបុគ្គលមិនធ្វើ ប្រសើរជាង (ព្រោះថា) អំពើអាក្រក់ រមែងធ្វើឲ្យក្តៅក្រហាយ ក្នុងកាលជាខាងក្រោយ បុគ្គលធ្វើអំពើណាហើយ រមែងមិនក្តៅក្រហាយស្តាយក្រោយ អំពើនោះដែលបុគ្គលធ្វើហើយ ធ្វើបានល្អហើយ ឈ្មោះថា ជាអំពើដ៏ប្រសើរ ។*

## ២២៩- រឿង អាគន្តុកភិក្ខុ

ព្រះបរមសាស្ដា ទ្រង់ប្រារព្ធ នូវភិក្ខុអាគន្តុកៈ ជាច្រើនរូប ។ ពួកភិក្ខុទាំងនោះ បានទៅចាំវស្សា ក្នុងបច្ចន្តជនបទ ជាបឋម នៅចាំវស្សា មានសេចក្ដីសុខសប្បាយ ជាធម្មតាទេ តែពេលក្រោយមក មិនមានសេចក្ដីសុខសប្បាយឡើយ ព្រោះគោចរគ្រាម មានពួកចោរមកបៀតបៀន លុះដល់បវារណាចេញវស្សាហើយ ក៏បាននាំគ្នាទៅក្រាបទូលព្រះសាស្ដា ។

ព្រះសាស្ដា ទ្រង់ត្រាស់ ថា "ម្នាលភិក្ខុទាំងឡាយ ការរស់នៅជាសុខសប្បាយ អស់កាលជានិច្ចនិរន្តរ៍នោះ គឺបុគ្គលរកបានដោយកម្រពេកណាស់ ភិក្ខុ ត្រូវថែរក្សាខ្លួន ឲ្យដូចជាគេថែរក្សានគរ យ៉ាងនោះឯង" ដូច្នេះហើយ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

នគរំ យថា បច្ចន្តំ គុត្តំ សន្តរពាហិរំ
ឯវំ គោបេថ អត្តានំ ខណោ វោ មា ឧបច្ចគា
ខណាតីតា ហិ សោចន្តិ និរយម្ហិ សមប្បិតា ។

អ្នកទាំងឡាយ ចូរថែរក្សាការពារខ្លួន ឲ្យដូចជាគេថែរក្សាការពារនគរ ដែលនៅទីបំផុតដែន យ៉ាងដូច្នោះឯង ចូរកុំឲ្យខណៈកន្លងអ្នកទាំងឡាយបានឡើយ ព្រោះថា បុគ្គលទាំងឡាយ ដែលឲ្យខណៈកន្លងហួសហើយ រមែងសោកស្ដាយ ក្នុងនរក មីដេរដាស ។

♣ ♣

## ២៣០- រឿង ពួកនិគ្រន្ថ

ព្រះបរមសាស្ដា ទ្រង់ប្រារព្ធ នូវពួកនិគ្រន្ថ ក្រៅសាសនា ។

## គាថាធម្មបទប្រែ

សម័យថ្ងៃមួយ ភិក្ខុទាំងឡាយ សន្ទនាគ្នាថា "ពួកនិគ្រន្ថ មានសេចក្តីខ្មាសអៀន ជាងពួកអចេលកៈទាំងឡាយ" ។ ពួកនិគ្រន្ថ បានឮហើយ ទើបនិយាយទៅរកភិក្ខុទាំងនោះ យ៉ាងយូរ ។ ពួកភិក្ខុទាំងឡាយ បានយករឿងនោះ ទៅក្រាបទូល ដល់ព្រះសាស្តា ។

ព្រះសាស្តាចារ្យ ទ្រង់ជ្រាបហើយ ត្រាស់ព្រះគាថានេះ ថា ៖

អលជ្ជិតាយេ លជ្ជន្តិ លជ្ជិតាយេ ន លជ្ជរេ
មិច្ឆាទិដ្ឋិសមាទានា សត្តា គច្ឆន្តិ ទុគ្គតឹ ។
អភយេ ភយទស្សិនោ ភយេ ច អភយទស្សិនោ
មិច្ឆាទិដ្ឋិសមាទានា សត្តា គច្ឆន្តិ ទុគ្គតឹ ។

សត្វទាំងឡាយ ដែលប្រកាន់មិច្ឆាទិដ្ឋិ រមែងខ្មាស ក្នុងហេតុដែលគេមិនត្រូវខ្មាស រមែងមិនខ្មាស ក្នុងហេតុដែលគេត្រូវខ្មាស សត្វទាំងឡាយនោះ តែងទៅកាន់ទុគ្គតិ ។

សត្វទាំងឡាយ ដែលប្រកាន់មិច្ឆាទិដ្ឋិ រមែងយល់ឃើញ ក្នុងហេតុដែលគេមិនត្រូវខ្លាច ថា ជាហេតុដែលគេត្រូវខ្លាចផង យល់ឃើញ ក្នុងហេតុដែលគេត្រូវខ្លាច ថា ជាហេតុដែលគេមិនត្រូវខ្លាចផង សត្វទាំងឡាយនោះ តែងទៅកាន់ទុគ្គតិ ។

❈ ❈ ❈

### ២៣១- រឿង តិរ្ថិយសាវ័ក

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវពួកសាវ័ករបស់តិរ្ថិយ ។ ពួកគេទាំងអស់នោះ បានហាមប្រាមកូនៗ របស់គេ មិនឲ្យចូលទៅកាន់

# -៣៤៦-
## រឿង តិរ្ថិយសាវ័ក

សំណាក់ នៃពួកសមណសាក្យបុត្រ និង មិនឲ្យសំពះ ថ្វាយបង្គំ បូជាគ្រប់ទីកន្លែង ។

សម័យថ្ងៃមួយ កូនៗ របស់ពួកតិរ្ថិយ បានទៅជាមួយកូនៗ របស់ឧបាសកឧបាសិកា អ្នកកាន់ព្រះពុទ្ធសាសនា ក្នុងវត្តជេតពន ។ ពេលស្រេកទឹក ក្មេងៗ ទាំងនោះ បាននាំគ្នា ចូលទៅផឹកទឹក ក្នុងវត្ត ហើយបានស្តាប់ព្រះធម៌ទេសនា មានចិត្តជ្រះថ្លា ជឿច្បាស់ ក្នុងគុណព្រះរតនត្រៃនិងសីល ហើយបានត្រឡប់ទៅផ្ទះវិញ និយាយរៀបរាប់ប្រាប់ដល់ឪពុកម្តាយ របស់ខ្លួនឲ្យបានជ្រាបផង ។ ឪពុកម្តាយ បានស្តាប់ហើយ ក៏មានចិត្តជ្រះថ្លា ក្នុងព្រះពុទ្ធសាសនា ហើយនាំកូនៗ ទៅគាល់ព្រះសាស្តា រួចថ្វាយខ្លួនជាពុទ្ធមាមកជន ទាំងអស់គ្នា ។

ព្រះសាស្តា កាលទ្រង់សម្តែងព្រះធម៌ទេសនា ពន្យល់ឲ្យពួកគេ ប្រកាន់ជាសម្មាទិដ្ឋិវិញ ទើបត្រាស់នូវព្រះគាថានេះ ថា ៖

អវជ្ជេ វជ្ជមតិនោ វជ្ជេ អវជ្ជទស្សិនោ
មិច្ឆាទិដ្ឋិសមាទានា សត្តា គច្ឆន្តិ ទុគ្គតឹ ។
វជ្ជញ្ច វជ្ជតោ ញត្វា អវជ្ជញ្ច អវជ្ជតោ
សម្មាទិដ្ឋិសមាទានា សត្តា គច្ឆន្តិ សុគតឹ ។

សត្វទាំងឡាយ ដែលប្រកាន់មិច្ឆាទិដ្ឋិ រមែងយល់ឃើញ ក្នុងហេតុដែលមិនមានទោស ថា ជាហេតុដែលមានទោសផង យល់ឃើញ ក្នុងហេតុដែលមានទោស ថា ជាហេតុដែលមិនមានទោសផង សត្វទាំងឡាយនោះ តែងទៅកាន់ទុគ្គតិ ។

-៣៤៧-

គាថាធម្មបទប្រែ

*សត្វទាំងឡាយ ដែលប្រកាន់សម្មាទិដ្ឋិ ដឹងរបស់ដែលមានទោសថា ជារបស់ដែលមានទោសផង ដឹងរបស់ដែលមិនមានទោសថា ជារបស់ដែលមិនមានទោសផង សត្វទាំងនោះ តែងទៅកាន់សុគតិ ។*

**ចប់ និយវគ្គ ទី ២២**

នាគវគ្គ ទី ២៣

២៣២- រឿងរបស់ព្រះអង្គ

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវរឿងរបស់ព្រះអង្គ ។ ថ្ងៃមួយព្រះពុទ្ធអង្គ ទ្រង់ទតព្រះនេត្រឃើញឧបនិស្ស័យ នៃអនាគាមិផលរបស់ព្រាហ្មណ៍ និង នាងព្រាហ្មណី ដែលជាមាតាបិតា របស់នាងមាគន្ទិយា ក្នុងក្រុងកុរុ ទើបស្តេចយាងទៅកាន់ទីនោះ ។*

*ព្រាហ្មណ៍ ពីរនាក់ ប្តីប្រពន្ធ បានឃើញព្រះវរកាយ និង ព្រះលក្ខណៈដ៏ឆើតឆាយ របស់ព្រះសាស្តាហើយ ទើបលើកធីតា របស់ខ្លួន ថ្វាយដល់ព្រះអង្គ ។ តែព្រះសាស្តា ទ្រង់ត្រាស់បដិសេធហើយទ្រង់សម្តែងទោសនៃកាម ឲ្យព្រាហ្មណ៍ទាំងពីរនាក់ប្តីប្រពន្ធនោះបានយល់ច្បាស់ រហូតដល់បានសម្រេចអនាគាមិផល ។ ចំណែកនាងមាគន្ទិយា ជាកូនស្រី បានក្រោធខឹងនឹងព្រះសាស្តា យ៉ាងខ្លាំង ហើយបានចងអាឃាតព្យាបាទនឹងព្រះអង្គ តាំងតែពីពេលនោះមក ។ លុះក្រោយមក នាងមាគន្ទិយា ក៏បានជាអគ្គមហេសី នៃព្រះបាទឧទេន*

## រឿងរបស់ព្រះអង្គ

*ក្នុងក្រុងកោសម្ពី, សម័យថ្ងៃមួយ នាងបានឃើញព្រះសាស្តា ស្តេចយាងចូលទៅ ក្នុងនគរនោះ ទើបនាងបានប្រើឲ្យពួកមនុស្ស មកជេរប្រទេចព្រះសាស្តា ដោយអក្កោសវត្ថុ ១០ យ៉ាង ។*

*ព្រះអានន្ទ ឮដូច្នោះហើយ បានក្រាបទូលអារាធនា ឲ្យស្តេចយាងទៅទីដទៃទៀត ។ ព្រះសាស្តាទ្រង់បានត្រាស់ ថា "ម្នាលអានន្ទ អធិករណ៍ កើតឡើងហើយក្នុងទីណា ត្រូវតែឲ្យអធិករណ៍ ក្នុងទីនោះស្ងប់រម្ងាប់ ស្រួលបួល ជាមុនសិនហើយ ចាំទៅកាន់ទីដទៃទៀត ជាខាងក្រោយ ទើបសមគួរ ព្រោះការអត់ធន់អត់ទ្រាំ ចំពោះពាក្យដែលគេនិយាយ ហួសប្រមាណ ជាភារកិច្ច របស់តថាគត" ដូច្នេះហើយទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

អហំ នាគោវ សង្គាមេ ចាបាតោ បតិតំ សរំ
អតិវាក្យំ តិតិក្ខិស្សំ ទុស្សីលោ ហិ ពហុជ្ជនោ ។
ទន្តំ នយន្តិ សមិតឹ ទន្តំ រាជាភិរូហតិ
ទន្តោ សេដ្ឋោ មនុស្សេសុ យោតិវាក្យំ តិតិក្ខតិ ។
វរមស្សតរា ទន្តា អាជានីយា ច សិន្ធវា
កុញ្ជរា ច មហានាគា អត្តទន្តោ តតោ វរំ ។

*តថាគត នឹងអត់ទ្រាំពាក្យល្មើស ដូចដំរី កាលអត់ទ្រាំ ចំពោះព្រួញ ដែលរបូតចេញអំពីធ្នូ ក្នុងសង្គ្រាម ដូច្នោះ ព្រោះថា ជនទ្រុស្តសីល មានច្រើននាក់ ។ បុគ្គលទាំងឡាយ តែងនាំពាហនៈដែលទូន្មានហើយ ទៅកាន់ទីប្រជុំ, ព្រះរាជា តែងស្តេចឡើងកាន់*

គាថាធម្មបទប្រែ

ពាហនៈ ដែលគេទូន្មានហើយ បណ្តាមនុស្សទាំងឡាយ មនុស្ស ឯណា អត់សង្កត់នឹងពាក្យល្មើសបាន មនុស្សនោះ ជាអ្នកមានខ្លួន ទូន្មានហើយ ឈ្មោះថា ជាអ្នកប្រសើរបំផុត ។ ពួកសេះអស្សតរ ក្តី សេះអាជានេយ្យ ក្តី សេះសិន្ធព ក្តី ដំរីកុញ្ជរដ៏ប្រសើរ ក្តី ដែលបុគ្គល ប្រៀនប្រដៅបានបទហើយ រាប់ថា ជាសត្វប្រសើរ បុគ្គលដែលមាន ខ្លួនទូន្មានបានបទហើយ ប្រសើរជាងសត្វទាំងអស់នោះ ។

♣ ❇ ♣

២៣៣- រឿងហត្ថាចារិយបុព្វកភិក្ខុ

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវភិក្ខុមួយរូប ដែលធ្លាប់ធ្វើជា ហ្មដំរី ។ ថ្ងៃមួយ ភិក្ខុរូបនោះ បានទៅកាន់មាត់ស្ទឹងអចិរវតី ព្រម ជាមួយនឹងភិក្ខុទាំងឡាយ ស្រាប់តែក្រឡេកឃើញហ្មដំរីម្នាក់កំពុងតែ ហ្វឹកហាត់ដំរី ដែលវារចុះប្រេង ហើយនិយាយទៅកាន់ភិក្ខុទាំងឡាយ ថា "បើហ្មដំរីនោះ យកកង្វេរ មកកាប់ត្រង់កន្ទែងនោះ ដំរីវានឹងឈប់ កាចទៀតហើយ" ។ ហ្មដំរីនោះ បានឮហើយ ក៏បានធ្វើតាមពាក្យភិក្ខុ នោះភ្លាម ។ ដំរី ក៏ឈប់ចុះប្រេង លែងកាច តទៅទៀត ស្លូតបូត ដូច កាលពីដើមវិញ ។

ភិក្ខុទាំងឡាយ លុះត្រឡប់មកវត្តវិញ ក៏បានយករឿងនេះទៅ ក្រាបទូល ដល់ព្រះសាស្តា ។

ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ទូន្មាន ឲ្យពួកភិក្ខុព្យាយាមអប់រំ ខ្លួនឯង ហើយត្រាស់នូវព្រះគាថានេះ ថា ៖

រឿង បុត្រព្រាហ្មណ៍ ៤ នាក់

**ន ហិ ឯតេហិ យានេហិ គច្ឆេយ្យ អគតំ ទិសំ**
**យថាត្តនា សុទន្តេន ទន្តោ ទន្តេន គច្ឆតិ ។**

*បុគ្គល ទូន្មានខ្លួនបានបទហើយ ទូន្មានខ្លួនបានល្អហើយ ឈ្មោះថា ទូន្មានហើយ ទើបទៅកាន់ទិសដែលខ្លួនមិនធ្លាប់ទៅ គឺព្រះនិព្វានបាន ពុំមែនដូចជាបុគ្គលទៅកាន់ទិស ដែលខ្លួនមិនធ្លាប់ទៅ ដោយយានទាំងឡាយនោះឡើយ ។*

២៣៤- រឿង បុត្រព្រាហ្មណ៍ ៤ នាក់

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវកូន ៤ នាក់ របស់ព្រាហ្មណ៍ម្នាក់ ដែលមានវ័យចាស់ជរាហើយ ។ ក្នុងពេលដែលនាងព្រាហ្មណីជាប្រពន្ធ ធ្វើមរណកាលទៅហើយ, ព្រាហ្មណ៍ ជាឪពុក បានចែកទ្រព្យសម្បត្តិ ឲ្យដល់កូនទាំង ៤ នាក់នោះ អស់ទៅ ហើយបាននៅអាស្រ័យជាមួយនឹងកូនៗ ទាំងនោះ លុះដឹងជាក់ច្បាស់ថា កូនទាំង ៤ នោះ មិនសូវយកចិត្តទុកដាក់ ក្នុងការទំនុកបំរុងថែរក្សាចិញ្ចឹមខ្លួន ក៏កើតទុក្ខទោមនស្ស យ៉ាងខ្លាំង បានទៅបួសជាតាជី ដើរសុំទានគេចិញ្ចឹមជីវិត មិនសំឡឹងឃើញមានអ្នកណាម្នាក់សោះ ដែលជាទីពឹងពាក់បាន ក៏ចូលទៅគាល់ព្រះសាស្តា ហើយក្រាបទូលនូវរឿងដែលកូនទាំង ៤ នោះ មិនបានចិញ្ចឹមខ្លួន ដល់ព្រះសាស្តា ។*

*ព្រះសាស្តាចារ្យ ទ្រង់បានប្រទាន នូវព្រះគាថាភាសិត ឲ្យតាព្រាហ្មណ៍ចាស់នោះ នាំយកទៅ សូត្រប្រកាស នាកណ្តាលប្រជុំ*

-៣៥១-

## គាថាធម្មបទប្រែ

*ជន ដូចតទៅនេះ ថា ៖*

ខ្ញុំបាទ នឹងរីករាយសប្បាយ ជាមួយនឹងកូន ទាំងឡាយណា ដែលបានកើតមកហើយ នឹងប្រាថ្នានូវសេចក្តីចំរើន ដល់កូនទាំងឡាយណា, កូនទាំងឡាយនោះត្រូវបានភរិយានិយាយញុះញង់ បាក់ដោត បៀតបៀន ដល់ខ្ញុំបាទ ដូចជាសុនខបៀតបៀនជ្រូក យ៉ាងដូច្នោះឯង, បានឮមកថា កូនទាំងអស់នោះ ជាអសប្បុរស លាមកអាក្រក់ ហៅខ្ញុំបាទថា ឪពុកៗពួកគេ គឺជាខ្មោចបីសាច បានមកហើយ ដោយរូបរាង ជាកូន លះបង់នូវខ្ញុំបាទ ដែលជាមនុស្សចាស់ជរា ឪពុក របស់កូនពាល ជាមនុស្សចាស់ជរា ត្រូវដើរទៅសុំទានគេ តាមផ្ទះរបស់បុគ្គលដទៃ ដូចជាសេះ ដែលម្ចាស់គេប្រើការលែងកើត ត្រូវម្ចាស់បង្អត់ស្មៅ យ៉ាងនោះឯង, មានសេចក្តីថាឈើច្រត់ របស់ខ្ញុំបាទនេះ ដូចជាគ្រាន់បើជាង, បំណែកឯកូនទាំងឡាយ ដែលមិនបានស្តាប់បង្គាប់ (ឪពុក) នឹងប្រសើរដូចម្តេចបាន ព្រោះថា ឈើច្រត់ ការពារគោកាប ក៏បានការពារនូវឆ្កែ ក៏បាន ទុកសម្រាប់ភាវទៅ ខាងមុខ ក្នុងពេលដែលងងឹត ក៏បាន នឹងប្រើចុះទៅ ក្នុងទីដែលជ្រៅ ក៏បានដោយអានុភាពនៃឈើច្រត់ មនុស្សចាស់ជរា ដូចជាខ្ញុំបាទផ្លាតជើងដួលហើយ អាចងើបក្រោកឡើង មកវិញបាន ។

-៣៥២-

## រឿង បុត្រព្រាហ្មណ៍ ៤ នាក់

ពួកកូនព្រាហ្មណ៍ទាំង ៤ នាក់នោះ បានស្តាប់នូវពុទ្ធភាសិត ដែលឪពុកបានសូត្រប្រកាស នាកណ្តាលទីប្រជុំដូច្នោះហើយ ក៏មានការភិតភ័យ ដឹងថា ខ្លួនបានធ្វើខុស មកលើអ្នកដ៏មានគុណ ទើបបានក្រាបរាប ក្បែរបាទានៃឪពុក ហើយសុំខមាទោសដល់គាត់ ហើយយកគាត់ទៅចិញ្ចឹមបីបាច់ថែរក្សា ដោយយកចិត្តទុកដាក់ជាទីបំផុត ។

ព្រះសាស្តា ទ្រង់ត្រាស់អនុមោទនា សរសើរការទំនុកបំរុងនូវមាតាបិតា ហើយត្រាស់នូវអតីតនិទាន របស់ព្រះអង្គ ថាៈ កាលដែលតថាគត សោយជាតិជាសត្វដំរី បានចិញ្ចឹមមាតាបិតា ក្នុងព្រៃហេមពាន្ត ។ ព្រះរាជាក្រុងពារាណសី ទ្រង់ជ្រាបហើយ ទ្រង់ត្រាស់បញ្ជាឲ្យនាយហត្ថាចារ្យ ទៅចាប់ដំរីនោះមក លុះចាប់បានហើយ ទ្រង់បានចិញ្ចឹមរក្សា ដោយចំណីអាហារ យ៉ាងបរិបូណ៌ មិនឲ្យមានខ្វះឡើយ, ប៉ុន្តែ ដំរី មិនមានចិត្តត្រេកអរ នឹងចំណីអាហារនោះឡើយ ព្រោះនឹករលឹកទៅដល់ម្តាយចាស់ ដែលរស់នៅ កំសត់អត់ឃ្លាន តែម្នាក់ឯង ក្នុងព្រៃព្រឹក្សាឯណោះ ។

ព្រះរាជា ទ្រង់ត្រាស់សួរដំរី ថា "ព្រោះហេតុអ្វី បានជាអ្នកមិនស៊ីស្មៅ មិនផឹកទឹក យ៉ាងដូច្នេះសោះ?" ។ ដំរី បានទូល ថា "បានជាទូលព្រះបង្គំ មិនស៊ីស្មៅ មិនផឹកទឹកនោះ ព្រោះចិត្តរបស់ទូលព្រះបង្គំ នឹករលឹកស្រណោះអាណិត ទៅដល់ម្តាយ របស់ទូលព្រះបង្គំ ដែលចាស់ជរា នៅកំសត់ តែម្នាក់ឯង ក្នុងព្រៃ ឥតមានអ្នកណា ជួយបីបាច់ចិញ្ចឹមឯណោះទេ" ។

## គាថាធម្មបទប្រែ

*ព្រះរាជា ទ្រង់ព្រះសណ្ដាប់ យ៉ាងដូច្នោះហើយ ទ្រង់មានព្រះទ័យសោមនស្សរីករាយឥតឧបមា ហើយទ្រង់ត្រាស់បញ្ជា ឲ្យនាយហត្ថាចារ្យ នាំយកដំរីនោះទៅលែង ក្នុងព្រៃ ឲ្យរស់មានសេរីភាពជាមួយម្ដាយ របស់ខ្លួន ដូចដើមវិញ" ក្នុងទីបញ្ចប់នៃអតីតនិទាន ព្រះអង្គទ្រង់ត្រាស់ នូវព្រះគាថានេះ ថា ៖*

ធនបាលកោ នាម កុញ្ជរោ
កដុកប្បភេទនោ ទុន្និវារយោ
ពទ្ធោ កពឡំ ន ភុញ្ជតិ
សុមរតិ នាគវនស្ស កុញ្ជរោ ។

*ដំរី ឈ្មោះ ធនបាល ជាសត្វចុះប្រេង ក្លៀវក្លា ដែលនាយហត្ថាចារ្យ ហាមឃាត់បានដោយលំបាក បើនាយហត្ថាចារ្យចងភ្ជាប់ មិនស៊ីស្មៅទេ ព្រោះនឹករឮកទៅដល់ព្រៃខ្លឹង ដែលដំរីនោះ ធ្លាប់បានរស់នៅ ។*

* * *

### ២៣៥- រឿង ព្រះបាទបសេនទិកោសល

*ព្រះបរមសាស្ដា ទ្រង់ប្រារព្ធនូវព្រះបាទបសេនទិកោសល ។ នៅថ្ងៃមួយ ព្រះរាជា ទ្រង់បានសោយព្រះក្រយាស្ងោយ ច្រើនហួសប្រមាណ ទ្រង់អឹតអាត់ក្រហល់ក្រហាយ ទ្រង់មិនសប្បាយព្រះទ័យ ហើយទ្រង់យាងទៅ ក្រាបទូលរឿងនោះ ថ្វាយដល់ព្រះសាស្ដា ទ្រង់ជ្រាប ។*

-៣៥៤-

រឿងសានុសាមណេរ

ព្រះសាស្តា ទ្រង់ត្រាស់សម្តែងទោស នៃការបរិភោគអាហារច្រើនហួសប្រមាណហើយ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

មិទ្ធី យទា ហោតិ មហគ្ឃសោ ច
និទ្ទាយិតា សម្បរិវត្តសាយី
មហាវរាហោវ និវាបបុដ្ឋោ
បុនប្បុនំ គព្ភមុបេតិ មន្ទោ ។

កាលណា បុគ្គល ជាអ្នកបរិភោគភោជន មានប្រមាណច្រើនផង ជាអ្នកមានសេចក្តីងោកងុយផង ជាអ្នកដេកលក់ផង ជាអ្នកបម្រះនទៀលផង ដូចជ្រូកស្រុកដ៏ធំ ដែលគេចិញ្ចឹម ដោយសុករកត្តយ៉ាងនោះឯង, កាលនោះ បុគ្គលនោះ ជាមនុស្សខ្លៅ រមែងចូលទៅកាន់គភ៌រឿយៗ ។

♣ ❇ ♣

២៣៦- រឿងសានុសាមណេរ

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវសានុសាមណេរ ដែលជាកូនរបស់ឧបាសិកាម្នាក់ ។ សាមណេរនោះ ជាអ្នកដល់ព្រម ដោយវត្តប្រតិបត្តិ យ៉ាងត្រឹមត្រូវ ជំនាញខាងសម្តែងធម៌ទេសនា ក្រោយមកសាមណេរ ប្រាថ្នានឹងលាចាកសិក្ខាបទ ហើយនិមន្តទៅផ្ទះ ដើម្បីនឹងសុំញោមស្រី លាចាកសិក្ខាបទ ។ ញោមស្រី មិនប្រាថ្នាចង់ឲ្យសាមណេរលាចាកសិក្ខាបទទេ ហើយបានហាមឃាត់ ដោយប្រការផ្សេងៗ ។

គាថាធម្មបទប្រែ

ក្នុងខណៈនោះឯង មាននាងយក្ខិនីមួយ ដែលធ្លាប់បានកើតជាមាតា របស់សាមណេរពីជាតិមុន ដឹងហេតុនោះហើយ ក៏មិនចង់ឲ្យសាមណេរលាចាកសិក្ខាបទដែរ ទើបបានចូល ក្នុងរូបសាមណេរនោះហើយ សម្ដែងអាការផ្សេងៗ ឲ្យប្រាកដឡើង ។

ឧបាសិកា ដែលជាម្ដាយ បានឃើញយ៉ាងនោះហើយ ក៏ភ័យខ្លាចតក់ស្លុត ក្រែងសាមណេរធ្វើកាលកិរិយា ទើបស្រែកយំ យ៉ាងខ្លាំង ធ្វើឲ្យពួកអ្នកស្រុកផ្អើលអ៊ូអរ រត់ចូលមកមើលជាច្រើនកុះករ ។ កាលនាងយក្ខិនី ចេញអំពីរូបសាមណេរហើយ, សាមណេរ ក៏បានដឹងខ្លួនឡើងវិញ ឃើញញោមស្រីស្រែកយំ ព្រមទាំងអ្នកស្រុក ជាច្រើនកុះករ ទើបសួរញោមស្រី ។ ញោមស្រី ក៏បានពិត នូវរឿងនោះ ដល់សាមណេរ ហើយបានជួយពន្យល់ណែនាំ នូវសាមណេរ ដោយប្រការផ្សេងៗ ។

សាមណេរ បានយល់ច្បាស់ហើយ ក៏មានចិត្តតក់ស្លុត លែងចង់លាចាកសិក្ខាបទ ក្រោយមក ក៏បានឧបសម្បទាជាភិក្ខុ ក្នុងព្រះពុទ្ធសាសនា ។

ព្រះសាស្ដា ទ្រង់ត្រាស់ទូន្មាន ឲ្យលោកខំព្យាយាម អប់រំចិត្តរបស់ខ្លួន ឲ្យរឹងមាំហើយ ត្រាស់នូវព្រះគាថានេះ ថា ៖

ឥទំ បុរេ ចិត្តមចារិ ចារិកំ
យេនិច្ឆកំ យត្ថកាមំ យថាសុខំ
តទជ្ជហំ និគ្គហេស្សាមិ យោនិសោ

រឿង ដំរីបាវេរកៈ

**ហត្ថឹ បភិន្នំ វិយ អង្កុសគ្គាហោ ។**

ក្នុងកាលមុនអំពីកាលនេះ ចិត្តនេះ បានត្រាច់ទៅកាន់ទីចារិក តាមអាការដែលខ្លួនប្រាថ្នា តាមអារម្មណ៍ដែលខ្លួនស្រឡាញ់ តាមសេចក្តីសប្បាយ នៅក្នុងថ្ងៃនេះ អាត្មាអញ នឹងសង្កត់សង្កិនចិត្តនោះ ដោយឧបាយ ដូចជាហ្មដំរី កាន់កង្វេរ សង្កត់សង្កិនដំរី ដែលចុះប្រេង យ៉ាងនោះឯង ។

២៣៧- រឿង ដំរីបាវេរកៈ

ព្រះបរមសាស្តាចារ្យ ទ្រង់ប្រារព្ធដំរីបាវេរកៈ ជាដំរី របស់ព្រះបាទបសេនទិកោសល ។ កាលនៅវ័យក្មេង ដំរីនោះ មានកម្លាំងខ្លាំងណាស់ ធ្លាប់ចូលកាន់សមរភូមិ ជាច្រើនលើកមកហើយ លុះដល់ចាស់ទៅ ក៏មានកម្លាំងខ្សោយចុះទៅជាលំដាប់ តាមអាយុកាលផងដែរ, សម័យថ្ងៃមួយ ដំរីនោះ បានដើរទៅរកស៊ីស្មៅ នៅក្បែរមាត់បឹង ហើយបានធ្លាក់ចុះទៅ ក្នុងភក់ដ៏ជ្រៅ ឡើងមកវិញមិនរួច ។

ព្រះរាជា ទ្រង់ត្រាស់បញ្ជា ឲ្យនាយហត្ថាចារ្យ ជួយយកដំរីនោះឡើងមកវិញ ។ នាយហត្ថាចារ្យបានរៀបចំធ្វើពិធី ដូចជាកងទ័ពវាយស្គរ ពួសូរ យ៉ាងទ្រហឹងអឺងកង ។ ដំរីបាវេរកៈ បានឮសំឡេងស្គរនោះហើយ ក៏កើតសេចក្តីក្លាហាន ខំប្រឹងប្រែង រើខ្លួន ឲ្យរួចផុតអំពីភក់ ស្ទុះឡើងមក លើគោកវិញ យ៉ាងឆាប់រហ័ស ។

ភិក្ខុទាំងឡាយ បានឃើញយ៉ាងនេះហើយ ទើបយករឿងនេះ

ទៅ ក្រាបទូលដល់ព្រះសាស្តា ។ ព្រះអង្គ ទ្រង់ត្រាស់ទេសនាអប់រំ ឲ្យភិក្ខុទាំងនោះ យកធ្វើជាគំរូ ហើយត្រាស់នូវព្រះគាថានេះ ថា ៖

អប្បមាទរតា ហោថ   សចិត្តមនុរក្ខថ
ទុគ្គា ឧទ្ធរថត្តានំ   បង្កេ សន្នោវ កុញ្ជរោ ។

អ្នកទាំងឡាយ ចូរត្រេកអរ ក្នុងសេចក្តីមិនប្រមាទ ចូររក្សាចិត្តរបស់ខ្លួន ចូរស្រង់ខ្លួនចេញចាកភក់គឺកិលេស ដែលធ្លាក់បានដោយកម្រ ដូចដំរី ដែលជាប់នៅក្នុងភក់ ខំប្រឹងស្រង់ខ្លួន ឲ្យបានរួចផុតអំពីភក់យ៉ាងដូច្នោះ ។

♣ ♣

២៣៨- រឿងសម្ពហុលភិក្ខុ

ព្រះបរមសាស្តា ទ្រង់ប្រារព្ធភិក្ខុ ជាច្រើនរូប មានព្រះអានន្ទជាប្រធាន ដែលបាននាំគ្នា ទៅគាល់ព្រះអង្គ ក្នុងគ្រាដែលព្រះអង្គស្តេចយាងគេចចេញពីការវិវាទឈ្លោះប្រកែកគ្នា នៃពួកភិក្ខុកោសម្ពី ហើយស្តេចយាងទៅគង់ចាំព្រះវស្សា នៅក្នុងព្រៃរក្ខិតវ័ន ។

ព្រះអានន្ទត្ថេរ បានទៅកាន់ព្រៃរក្ខិតវ័ន ហើយបានឲ្យភិក្ខុទាំងឡាយ សម្រាករង់ចាំ នៅឯខាងក្រៅសិន ខ្លួនលោក តែមួយអង្គឯងគត់ ក៏បានចូលទៅគាល់ព្រះសាស្តា ។

គ្រានោះ ដំរីបាលិលេយ្យកៈ បានឃើញព្រះអានន្ទហើយ ក៏ចាប់កំណាត់ឈើ បោលយ៉ាងលឿន តម្រង់ឆ្ពោះទៅរកព្រះអានន្ទ ។

ព្រះសាស្តាទ្រង់ត្រាស់ហាមថា "កុំឡើយ បាលិលេយ្យកៈ" ។

# រឿងសម្ពហុលភិក្ខុ

*ដំរីនោះ បានឈប់ដេញ ហើយឈរនៅស្ងៀម ចាំមើល... ឃើញព្រះថេរៈ ចូលទៅគាល់ព្រះសាស្តាហើយ មិនយកគ្រឿងបរិក្ខាររបស់ខ្លួនដាក់លើទីប្រថាប់ របស់ព្រះសាស្តា ក៏មានចិត្តជ្រះថ្លាក្នុងគារវៈ របស់ព្រះអានន្ទ ។*

*ព្រះអានន្ទ បានក្រាបទូលព្រះពុទ្ធអង្គ ថា បពិត្រព្រះអង្គ ដ៏ចំរើន ខ្ញុំព្រះករុណា បាននាំភិក្ខុទាំងឡាយមកដែរ តែបានឲ្យនៅរង់ចាំខាងក្រៅឯណោះ ។*

*ព្រះបរមសាស្តាចារ្យ ទ្រង់បានត្រាស់បើកឱកាស ឲ្យភិក្ខុទាំងនោះ ចូលមកគាល់ហើយ ត្រាស់នូវព្រះគាថានេះ ថា ៖*

សចេ លភេថ និបកំ សហាយំ
សទ្ធឹ ចរំ សាធុវិហារិ ធីរំ
អភិភុយ្យ សព្វានិ បរិស្សយានិ
ចរេយ្យ តេនត្តមនោ សតីមា ។
នោ ចេ លភេថ និបកំ សហាយំ
សទ្ធឹ ចរំ សាធុវិហារិ ធីរំ
រាជាវ រដ្ឋំ វិជិតំ បហាយ
ឯកោ ចរេ មាតង្គរញ្ញេវ នាគោ ។
ឯកស្ស ចរិតំ សេយ្យោ នត្ថិ ពាលេ សហាយតា
ឯកោ ចរេ ន ច បាបានិ កយិរា
អប្បោស្សុកោ មាតង្គរញ្ញេវ នាគោ ។

## គាថាធម្មបទប្រែ

បើបុគ្គលបាននូវសំឡាញ់ ដែលមានប្រាជ្ញាជាគ្រឿងរក្សាខ្លួន មានបញ្ញាចងចាំ មានគុណធម៌ជាគ្រឿងនៅ ញុំាងប្រយោជន៍ឲ្យសម្រេច ជាអ្នកត្រាច់ទៅជាមួយគ្នា គួរជាអ្នកមានចិត្តត្រេកអរ មានសតិស្មារតី គ្របសង្កត់សេចក្តីអន្តរាយទាំងពួងហើយ ត្រាច់ទៅ ជាមួយនឹងសំឡាញ់នោះ ។

បើស្វែងរកមិនបាន នូវសំឡាញ់ ដែលមានប្រាជ្ញា ជាគ្រឿងរក្សាខ្លួន មានប្រាជ្ញាចងចាំ មានគុណធម៌ជាគ្រឿងនៅ ញុំាងប្រយោជន៍ឲ្យសម្រេច ជាអ្នកត្រាច់ទៅ ជាមួយគ្នាទេ គួរត្រាច់ទៅតែឯកឯងវិញ ដូចព្រះរាជាលះបង់រដ្ឋ ដែលទ្រង់ឈ្នះហើយ ស្តេចយាងទៅតែឯកអង្គ ពុំនោះសោត ដូចដំរី ឈ្មោះមាតង្គៈ ដែលលះបង់ហ្វូង ត្រាច់ទៅតែឯកឯង ក្នុងព្រៃ ដូច្នោះដែរ ។

ការត្រាច់ទៅ របស់បុគ្គលឯកឯង ជាគុណជាតប្រសើរបំផុត (ព្រោះថា) សហាយតាគុណ (ភាពជាសំឡាញ់) រមែងមិនមាន ក្នុងជនពាលឡើយ បុគ្គលនោះ គប្បីជាអ្នកមានសេចក្តីខ្វល់ខ្វាយតិច ត្រាច់ទៅតែឯកឯងផង មិនគប្បីធ្វើអំពើបាបទាំងឡាយផង ដូចជាដំរីឈ្មោះមាតង្គៈ ជាសត្វមានសេចក្តីខ្វល់ខ្វាយតិច លះបង់ហ្វូង ត្រាច់ទៅតែឯកឯង ក្នុងព្រៃ ដូច្នោះដែរ ។

❋ ❋ ❋

## ២៣៩- រឿងមារ

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវមារ ដែលចូលមកគាល់ព្រះ

*អង្គ ហើយបានក្រាបទូលឲ្យព្រះអង្គត្រឡប់យាងទៅ សោយរាជ្យ-សម្បត្តិវិញ ។ ព្រះអង្គ ទ្រង់ត្រាស់សួរសេចក្តីប្រាថ្នា របស់មារ ។*

*មារ បានក្រាបទូល ថា "ព្រះអង្គទ្រង់បរិបូណ៌ ដោយឥទ្ធិបាទ ៤ អាចអធិដ្ឋានភ្នំ ឲ្យកើតជាមាសទាំងអស់បាន បើព្រះអង្គ ទ្រង់យាងទៅសោយរាជ្យសម្បត្តិវិញហើយ ទូលព្រះបង្គំ នឹងបានមាសរបស់ព្រះអង្គ ខ្វះៗ មិនខានឡើយ" ។*

*ព្រះសាស្តា ទ្រង់ត្រាស់ថា "ភ្នំមាស មានដល់ទៅពីរ ក៏នៅតែមិនគ្រប់គ្រាន់ ដល់មនុស្សម្នាក់ដែរ, ឱវាទរបស់អ្នក និង ឱវាទរបស់តថាគត ខុសផ្សេងអំពីគ្នា" ហើយ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

អត្ថម្ហិ ជាតម្ហិ សុខា សហាយា
តុដ្ឋី សុខា យា ឥតរីតរេន
បុញ្ញំ សុខំ ជីវិតសង្ខយម្ហិ
សព្វស្ស ទុក្ខស្ស សុខំ បហានំ ។

សុខា មត្តេយ្យតា លោកេ អថោ បេត្តេយ្យតា សុខា
សុខា សាមញ្ញតា លោកេ អថោ ព្រហ្មញ្ញតា សុខា
សុខំ យាវ ជរា សីលំ សុខា សទ្ធា បតិដ្ឋិតា
សុខោ បញ្ញាបដិលាភោ បាបានំ អករណំ សុខំ ។

*កាលបើសេចក្តីត្រូវការកើតឡើងហើយ សំឡាញ់ទាំងឡាយ នាំសេចក្តីសុខមកឲ្យ សេចក្តីត្រេកអរ ដោយបច្ច័យ តាមមានតាមបាន ជាហេតុនាំសេចក្តីសុខមកឲ្យ បុណ្យ នាំសេចក្តីសុខមកឲ្យ*

គាថាធម្មបទប្រែ

*ក្នុងកាលទៀបក្ស័យជីវិត ការលះបង់សេចក្ដីទុក្ខទាំងអស់បាន នាំសេចក្ដីសុខមកឲ្យ ។*

*សេចក្ដីប្រតិបត្តិល្អ ក្នុងមាតា នាំសេចក្ដីសុខមកឲ្យ ក្នុងលោក មួយទៀត សេចក្ដីប្រតិបត្តិល្អ ក្នុងបិតា នាំសេចក្ដីសុខមកឲ្យក្នុងលោក សេចក្ដីប្រតិបត្តិល្អ ក្នុងសមណៈ ជាហេតុនាំសេចក្ដីសុខមកឲ្យ ក្នុងលោក មួយទៀត សេចក្ដីប្រតិបត្តិល្អ ក្នុងព្រាហ្មណ៍ នាំសេចក្ដីសុខមកឲ្យ សីល នាំសេចក្ដីសុខមកឲ្យ ដរាបដល់ចាស់ សទ្ធា ដែលបុគ្គលបានតម្កល់ស៊ប់ហើយ នាំសេចក្ដីសុខមកឲ្យ ការបានប្រាជ្ញា នាំសេចក្ដីសុខមកឲ្យ ការមិនធ្វើនូវបាបទាំងឡាយ នាំសេចក្ដីសុខមកឲ្យ ។*

បប់នាគវគ្គ ទី ២៣

**ចប់ គាថាធម្មបទប្រែ**

**ភាគ ទី ៧**

សូមសិក្សាភាគ ទី ៨ បន្តទៅទៀត

# គាថាធម្មបទប្រែ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ភាគ ទី ៨

តណ្ហាវគ្គ ទី ២៤

២៤០- រឿង ត្រីឈ្មោះកបិលៈ

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធត្រីផ្តិនមាសមួយ ឈ្មោះកបិលៈ មានក្លិនមាត់ស្អុយអសោច ។ ក្នុងសាសនាព្រះពុទ្ធព្រះនាមកស្សបៈ ត្រីនេះ ធ្លាប់បានបួសជាភិក្ខុ មានពួកបរិវារជាច្រើន ជាពហុស្សូត អាស្រ័យលាភសក្ការៈ បានសម្តែងព្រះធម៌វិន័យថា មិនមែនជាព្រះធម៌វិន័យ លុះធ្វើមរណកាលទៅហើយ ក៏បានទៅកើត ក្នុងអវិចីនរកអស់មួយពុទ្ធន្តរ ក្នុងព្រះពុទ្ធសាសនានេះ ក៏បានកើតជាត្រីផ្តិនមាសមួយដ៏ធំ ក្នុងស្ទឹងអចិរវតី ។*

*ថ្ងៃមួយ អ្នកនេសាទត្រី បានចាប់ត្រីផ្តិនមាសនោះបាន ឃើញដូចជាធំចំឡែកខ្លាំងណាស់ ទើបយកត្រីនោះ ទៅថ្វាយដល់ព្រះរាជាព្រះនាមព្រះបាទបសេនទិកោសល ។ ព្រះបាទបសេនទិកោសល ទ្រង់ព្រះរាជបញ្ជា ឲ្យអមាត្យ នាំយកត្រីនោះ ទៅវត្តជេតពន ហើយព្រះអង្គក្រាបទូលសួរបុព្វកម្ម របស់ត្រីនោះ ចំពោះព្រះសាស្តា ។*

*ព្រះសាស្តា ទ្រង់ត្រាស់សម្តែងបុព្វកម្ម របស់ត្រីនោះ ដូចបាន*

## -៣៦៣-

## គាថាធម្មបទប្រែ

*រៀបរាប់មកខាងលើស្រាប់ ហើយត្រាស់នូវព្រះគាថានេះ ថា ៖*

មនុជស្ស បមត្តចារិនោ
តណ្ហា វឌ្ឍតិ មាលុវា វិយ
សោ បរិប្លវតី ហុរាហុរំ
ផលមិច្ឆំវ វនស្មិ វានរោ ។

យំ ឯសា សហតេ ជម្មី    តណ្ហា លោកេ វិសត្តិកា
សោកា តស្ស បវឌ្ឍន្តិ    អភិវុដ្ឋំវ វីរណំ ។
យោ ចេតំ សហតេ ជម្មឹ    តណ្ហំ លោកេ ទុរច្ចយំ
សោកា តម្ហា បបតន្តិ    ឧទពិន្ទុវ បោក្ខរា ។
តំ វោ វទាមិ ភទ្ទំ វោ    យាវន្តេត្ថ សមាគតា
តណ្ហាយ មូលំ ខនថ    ឧសីរត្ថោវ វីរណំ ។
មា វោ នឡំវ សោតោវ    មារោ ភញ្ជិ បុនប្បុនំ ។

*តណ្ហា តែងចំរើន ដល់មនុស្សអ្នកមានការប្រព្រឹត្តិ ដោយសេចក្តីប្រមាទជាប្រក្រតី ដូចវល្លិ រួបរឹតដើមឈើហើយ ចំរើនឡើង, បុគ្គលនោះ តែងស្ទុះទៅ កាន់ភពតូចភពធំ ដូចសត្វស្វា កាលប្រាថ្នាផ្លែឈើ លោតទៅក្នុងព្រៃ យ៉ាងដូច្នោះឯង ។*

*តណ្ហានុ៎ះ ជាទោសជាតិ ដ៏លាមក ផ្សាយទៅ ក្នុងអារម្មណ៍ផ្សេងៗ ក្នុងលោក គ្របសង្កត់នូវបុគ្គលណា សេចក្តីសោកស្តាយ តែងចំរើនឡើង ដល់បុគ្គលនោះ ដូចជាស្មៅវណ្ណាស ដែលត្រូវភ្លៀងធ្លាក់ចុះជញ្ជ្រាំហើយ ពន្លកលូតលេចឡើង ដូច្នោះឯង ។*

រឿងសុករបោតិកា:

ចំណែកបុគ្គលណា គ្របសង្កត់តណ្ហា ដ៏លាមក ក្នុងលោក ដែលគេឆ្លងបានដោយកម្រនោះ សេចក្ដីសោកស្ដាយ តែងធ្លាក់ចេញ ចាកបុគ្គលនោះឯង ដូចជាតំណក់ទឹក ដែលធ្លាក់ចុះចាកស្លឹកឈូក ក៏យ៉ាងនោះដែរ ។

ព្រោះហេតុនោះ បានជាតថាគត ប្រាប់អ្នកទាំងឡាយ អ្នកទាំងឡាយមានប៉ុន្មានរូប ដែលមកប្រជុំគ្នា ក្នុងទីនេះ សេចក្ដីចំរើន ចូរមាន ដល់អ្នកទាំងឡាយទាំងប៉ុណ្ណោះចុះ អ្នកទាំងឡាយ ចូររំលើងឫសតណ្ហាចោលចេញ ដូចបុគ្គលត្រូវការ ដោយស្បូវក្លាំង គាស់ស្បូវណ្ដាស ចោលចេញដូច្នោះឯង ។

មារ ចូរកុំរុករាន ដល់អ្នកទាំងឡាយ រឿយៗ ដូចខ្សែទឹកកាច់បំបាក់ដើមបបុស យ៉ាងដូច្នោះឡើយ ។

❦❦❦

២៤១- រឿងសុករបោតិកា:

ព្រះបរមសាស្ដា ទ្រង់ប្រារព្ធនូវកូនជ្រូកមេមួយដែលស៊ីគូថ ។ ក្នុងសាសនានៃព្រះពុទ្ធព្រះនាមកក្កុសន្ធោ, កូនជ្រូកនេះ បានកើតជាមេមាន់ លុះស្លាប់ពីមេមាន់ បានទៅកើតជារាជធីតា ឈ្មោះឧព្វរី លុះស្លាប់ពីនេះទៅ ក៏បានទៅកើត ក្នុងព្រហ្មលោក ក្នុងពុទ្ធកាលនេះ បានមកកើតជាកូនជ្រូកមេ បន្ទាប់ពីនេះមក បានកើតជាស្ដ្រី នៅក្នុងក្រុងសុវណ្ណភូមិ, ក្រុងសុប្បារកបត្តនៈ ក្រុងគាវិរបត្តនៈ ក្រុងអនុរាធៈ និងក្រុងភេរបោន្តគាមៈ តាមលំដាប់លំដោយ ហើយបានជាករិយា របស់

គាថាធម្មបទប្រែ

លកុណ្ឌកអតិពរ ដែលជាអមាត្យ របស់ព្រះបាទទុដ្ឋគាមិនី នាងបាន សុំអនុញ្ញាតស្វាមីទៅបួស ជានាងភិក្ខុនី ក្នុងតិស្សមហាវិហារ នៅ លង្កាទ្វីប លុះបួសហើយ ខំព្យាយាមបំពេញសមណធម៌ រហូតដល់ បានសម្រេចអរហត្តផល ក្នុងអត្តភាពនោះ ។

ព្រះសាស្តា ស្តេចយាងទៅបិណ្ឌបាតប្រោសសត្វ ក្នុងទីក្រុង រាជគ្រឹះ ទ្រង់ទតព្រះនេត្រឃើញនូវកូនជ្រូកមេនោះហើយ ទ្រង់បាន ញញឹម ។ ព្រះអានន្ទ ក្រាបទូលសួរហេតុដែលទ្រង់ញញឹមនោះ ។

ព្រះសាស្តា ទ្រង់ត្រាស់សម្តែងរឿងកូនជ្រូកនោះ ឲ្យភិក្ខុទាំង ឡាយ កើតសេចក្តីតក់ស្លុត ហើយត្រាស់សម្តែងអំពីទោស នៃតណ្ហា ស្រេចកាលណាហើយ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

យថាបិ មូលេ អនុបទ្ទវេ ទឡ្ហេ
ឆិន្នោបិ រុក្ខោ បុនរេវ រូហតិ
ឯវម្បិ តណ្ហានុសយេ អនូហតេ
និព្វត្តតី ទុក្ខមិទំ បុនប្បុនំ ។

យស្ស ឆត្តឹសតី សោតា មនាបស្សវនា ភុសា
មហា វហន្តិ ទុទ្ទិដ្ឋឹ សង្កប្បា រាគនិស្សិតា ។
សវន្តិ សព្វធី សោតា លតា ឧព្ភិជ្ជ តិដ្ឋតិ
តញ្ច ទិស្វា លតំ ជាតំ មូលំ បញ្ញាយ ឆិន្ទថ ។

សរិតានិ សិនេហិតានិ ច
សោមនស្សានិ ភវន្តិ ជន្តុនោ

រឿងសុករចោតិកៈ

តេ សាតសិតា សុខេសិនោ
តេ វេ ជាតិជរូបគា នរា ។
តសិណាយ បុរក្ខតា បជា
បរិសប្បន្តិ សសោវ ពាធិតោ
សញ្ញោជនសង្គសត្តា
ទុក្ខមុបេន្តិ បុនប្បុនំ ចិរាយ ។
តសិណាយ បុរក្ខតា បជា
បរិសប្បន្តិ សសោវ ពាធិតោ
តស្មា តសិណំ វិនោទយេ
ភិក្ខុ អាកង្ខំ វិរាគមត្តនោ ។

កាលបើឫសឈើ មិនមានសេចក្តីអន្តរាយ នៅមាំមួនទេ ដើមឈើ ទុកជាកាប់ចោលហើយ ក៏តែងដុះឡើងទៀតបាន យ៉ាងណាមិញ, កាលបើតណ្ហានុស័យ ដែលបុគ្គលកាត់មិនទាន់បានហើយ សេចក្តីទុក្ខ (មានជាតិទុក្ខជាដើម) នេះ ក៏តែងកើតឡើងរឿយៗ ក៏យ៉ាងដូច្នោះដែរ ។

ខ្សែតណ្ហា ៣៦ ជាធម្មជាតិហូរទៅ ក្នុងអារម្មណ៍ ជាទីគាប់ចិត្ត ជាធម្មជាតិក្លៀវក្លា មានដល់បុគ្គលណា សេចក្តីត្រិះរិះទាំងឡាយដ៏ធំ ដែលអាស្រ័យនូវរាគៈ តែងនាំនូវទិដ្ឋិ ដ៏អាក្រក់ របស់បុគ្គលនោះ ។

ខ្សែតណ្ហាទាំងឡាយ តែងហូរទៅ ក្នុងអារម្មណ៍ទាំងពួង ដូចជាវល្លិដែលបែកខ្នែងឡើង តាំងនៅដូច្នោះ, បើអ្នកទាំងឡាយ ឃើញ

តណ្ហា ដូចជាវល្លិនោះ កើតឡើងហើយ ចូរកាត់ឫសចោលចេញ ដោយកាំបិត គឺបញ្ញា ។

សោមនស្សទាំងឡាយ ដែលផ្សាយទៅហើយផង ដែលប្រព្រឹត្តទៅ ដោយសេចក្តីស្រឡាញ់ផង រមែងមានដល់សត្វ ពួកសត្វទាំងនោះ ជាអ្នកអាស្រ័យនូវសេចក្តីរីករាយ ទើបស្វះស្វែងរកសេចក្តីសុខ នរជន ទាំងឡាយនោះឯង តែងឈមទៅរកជាតិ និងជរា ។

ពួកសត្វ ដែលតណ្ហា ជាទីញុំាងសត្វឲ្យតក់ស្លុត ក្រុងទុកហើយ តែងតក់ស្លុតរន្ធត់ ដូចទន្សាយ ដែលព្រានទាក់បានហើយយ៉ាងនោះឯង, ពួកសត្វដែលជាប់ ក្នុងសំយោជនធម៌ និង ធម៌ជាគ្រឿងជំពាក់ តែងដល់នូវសេចក្តីទុក្ខ ជារឿយៗ អស់កាលជាយូរអង្វែង ។

ពួកសត្វ ដែលតណ្ហា ជាទីញុំាងសត្វឲ្យតក់ស្លុត ក្រុងទុកហើយ តែងតក់ស្លុតរន្ធត់ ដូចទន្សាយ ដែលព្រានទាក់បានហើយយ៉ាងនោះឯង, ព្រោះហេតុនោះ ភិក្ខុកាលប្រាថ្នាធម៌ ជាគ្រឿងប្រាសចាករាគៈ ដើម្បីខ្លួន គប្បីបន្ទោបង់នូវតណ្ហា ដែលជាគ្រឿងតក់ស្លុតចោលឲ្យអស់ ។

✻ ✻ ✻

## ២៤២- រឿងវិព្ភន្តកភិក្ខុ

ព្រះបរមសាស្តា ទ្រង់បានប្រារព្ធ នូវភិក្ខុមួយរូប ដែលលា

## រឿងវិព្ភន្តកភិក្ខុ

ចាកសិក្ខបទ ជាសិស្សរបស់ព្រះមហាកស្សបៈ បានសម្រេចនូវ រូប-ឈាន ទី៤ ។ ថ្ងៃមួយ ភិក្ខុរូបនោះ បានឃើញស្រីរូបស្អាតម្នាក់ ក៏មានចិត្តស្រឡាញ់ យ៉ាងខ្លាំង ទៅលើស្រីនោះ អត់ទ្រាំមិនបាន ទើបបានលាចាកសិក្ខាបទ ទៅនៅរួមរស់ ជាមួយនឹងស្រីនោះ រកស៊ីចិញ្ចឹមជីវិត ធ្វើជាចោរកម្ម ។

ពួកអ្នកស្រុក ចាប់បុរសនោះបានហើយ ក៏យកទៅដាក់គុករួចហើយ ទើបយកទៅខាងក្រៅ ដើម្បីនឹងប្រហារជីវិតចោល ។ ក្នុងពេលជាមួយគ្នានោះ ព្រះមហាកស្សបៈ បានទិមន្តទៅបិណ្ឌបាតឃើញបុរសនោះហើយ ក៏បានពោលដាស់តឿន ឲ្យគាត់មានសតិស្មារតី នឹករឭកដល់ភាវនា ដែលខ្លួនគាត់ធ្លាប់បានអប់រំសន្សំទុកមកពីមុននោះ ។ បុរសជាចោរនោះ លុះបានឮដូច្នោះហើយ ក៏មានសតិស្មារតីភ្លាម ហើយបាននឹកដល់ភាវនានោះ ខំប្រឹងញ៉ាំងឈាន ទី៤ ឲ្យកើតឡើងមួយរំពេច មិនភ័យខ្លាចតក់ស្លុត ចំពោះអាជ្ញានោះ ។ ពួករាជបុរសទាំងឡាយ បានឃើញ នូវហេតុដ៏អស្ចារ្យនោះហើយ ទើបនាំគ្នាទៅក្រាបទូល ដល់ព្រះរាជា ។ ព្រះរាជា ទ្រង់យករឿងនោះទៅក្រាបទូល ដល់ព្រះសាស្តា ។

ព្រះបរមសាស្តាចារ្យ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

យោ និព្វនថោ វនាធិមុត្តោ
វនមុត្តោ វនមេវ ធាវតិ
តំ បុគ្គលមេវ បស្សថ

គាថាធម្មបទប្រែ

**មុត្តោ ពន្ធនមេវ ធាវតិ ។**

*បុគ្គលណា មិនមានអាល័យ ក្នុងគិហិភាព ដូចដើមឈើតាំងនៅ ក្នុងព្រៃ មានចិត្តចុះស៊ប់ ក្នុងព្រៃគឺតបធម៌ ជាអ្នករួចស្រឡះចាកព្រៃ គឺតណ្ហាហើយ ក៏នៅតែស្ទុះទៅរកព្រៃគឺតណ្ហាដដែលវិញ, អ្នកទាំងឡាយ ចូរមើលនូវបុគ្គលនោះឯង បុគ្គលនោះ បានរួចចាកចំណង គឺឃរាវាស ហើយ ក៏នៅតែស្ទុះទៅរកចំណង គឺឃរាវាសវិញដដែល ។*

❁ ❁ ❁

## ២៤៣- រឿង ពន្ធនាគារ

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវមន្ទីរឃុំឃាំង ក្នុងក្រុងសាវត្ថី ដែលគេធ្វើហើយ យ៉ាងរឹងប៉ឹងមាំមួនល្អ ព្រមទាំងពន្ធនាគារ សម្រាប់ដាក់អ្នកទោស ក៏មាំទាំដូចគ្នាដែរ ។ ភិក្ខុទាំងឡាយ បានឃើញហើយ ទើបចូលទៅក្រាបទូល ដល់ព្រះសាស្តា ថា "បពិត្រព្រះអង្គដ៏ចំរើន ចំណងដែលមាំមួន រឹងប៉ឹងជាងនេះ តើមានដែរឬទេ?" ។*

*ព្រះសាស្តា ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ចំណងទាំងនេះ មិនសំខាន់ទេ ចំណង ពោលគឺតណ្ហា កម្រនឹងបុគ្គលណាមួយស្រាយបានណាស់" ដូច្នេះហើយ ទ្រង់នាំអតីតនិទានមកសម្តែង ថា "សម័យថ្ងៃមួយ ព្រះពោធិសត្វ ប្រាថ្នាចង់បួស ហើយបានសុំភរិយាទៅបួស ។ ភរិយាបាន សុំអង្វរករ ថា "ចាំដល់អូន សម្រាលកូនសិនសូមបងទៅបួសចុះ" ។ លុះសម្រាលកូនរួចហើយ, ភរិយា ក៏បានសុំ*

រឿងពន្ធនាគារ

អន្ទរករស្វាមីទៀតថា "ចាំឲ្យកូនជាប់ទឹកដោះសិនណ៎ា បងសំឡាញ់ចិត្ត" ។ ពេលដែលកូនដាច់ទឹកដោះហើយ, ភរិយា ក៏មានផ្ទៃពោះមួយទៀត ។ ព្រះពោធិសត្វ បានឃើញ ភរិយាមានផ្ទៃពោះហើយ មិនសប្បាយចិត្តសោះ បានលួចរត់ទៅ បួសជាតាបសឥសី រហូតបានសម្រេចឈានសមាបត្តិ នៅជាសុខសប្បាយ ក្នុងហិមវន្តប្រទេស" ក្នុងទីបញ្ចប់នៃអតីតនិទាន ទ្រង់ត្រាស់នូវព្រះគាថានេះថា ៖

ន តំ ទឡ្ហំ ពន្ធនមាហុ ធីរា
យទាយសំ ទារុជំ បព្វជញ្ច ។
សារត្តរត្តា មណិកុណ្ឌលេសុ
បុត្តេសុ ទារេសុ ច យា អបេក្ខា
ឯតំ ទឡ្ហំ ពន្ធនមាហុ ធីរា
ឱហារិនំ សិថិលទុប្បមុញ្ចំ
ឯតំបិ ឆេត្វាន បរិព្វជន្តិ
អនបេក្ខិនោ កាមសុខំ បហាយ ។

ចំណងណា ដែលកើតអំពីដែក ក្តី កើតអំពីឈើ ក្តី កើតអំពីស្មៅបាបូង ក្តី អ្នកប្រាជ្ញ មិនហៅចំណងនោះថា ជាចំណងមាំមួនឡើយ ។

សេចក្តីត្រេកអរ ក្រៃពេក ក្នុងកែវមណី និង កុណ្ឌលទាំងឡាយ ក្តី សេចក្តីអាឡោះអាល័យ ក្នុងកូន និង ប្រពន្ធទាំងឡាយ ក្តី អ្នកប្រាជ្ញទាំងឡាយ ហៅសេចក្តីត្រេកអរ ក្រៃពេក និង សេចក្តី

អាឡោះអាល័យនោះថា ជាចំណងដ៏មាំមួន ជាចំណងទាំចុះ (ទាញសត្វទម្លាក់ទៅ ក្នុងអបាយ) ជាចំណងធូរទេ ប៉ុន្តែ សត្វ ស្រាយបានដោយលំបាក អ្នកប្រាជ្ញទាំងឡាយ កាត់ផ្តាច់ចំណងនោះចេញ ជាអ្នកមិនមានសេចក្តីអាឡោះអាល័យ លះបង់នូវកាមសុខ ហើយចេញទៅបួស ។

♣ ♣ ♣

## ២៤៤- រឿង ព្រះនាងខេមា

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវព្រះនាងខេមា ជាព្រះអគ្គមហេសី នៃព្រះបាទពិម្ពិសារ ។ ព្រះនាងជាស្រីដែលមានរូបឆោមនោះស្អាត ព្រះនាងបានដឹងថា "ព្រះសាស្តា ទ្រង់សម្តែងអំពីទោស នៃរូបរាងកាយ" នាងខ្លាចក្រែងព្រះអង្គ ទ្រង់ត្រាស់បន្ទាប់រូប របស់ខ្លួន ហើយមិនប្រាថ្នាចង់ទៅស្តាប់ព្រះធម៌ទេសនាឡើយ ។ ថ្ងៃមួយ ព្រះនាង ទ្រង់ព្រះសណ្តាប់នូវចំរៀង ដែលច្រៀងរៀបរាប់អំពីវត្តវេឡុវ័ន ដែលព្រះស្វាមីទ្រង់បាននិពន្ធ ឲ្យអ្នកចំរៀងច្រៀង ទើបបានទៅគាល់ព្រះសាស្តា ។ ក្នុងគ្រានោះ ព្រះនាងបានឃើញស្រីម្នាក់មានវ័យក្មេង មានរូបរាងស្អាត កំពុងអង្គុយ បក់ផ្លិត ថ្វាយព្រះសាស្តា ដែលជារូបសម្រេចដោយពុទ្ធនិមិត្ត ហើយទ្រង់គង់សំឡឹង ចាំមើលតែរូបស្រីមួយនោះប៉ុណ្ណោះ ។

ព្រះសាស្តា ទ្រង់ជ្រាបហើយ ទើបទ្រង់បាននិមិត្តរូបស្រី មួយនោះ ឲ្យមានការប្រែប្រួល ចាស់ជរាទៅ បន្តិចម្តងៗ ជាលំដាប់ រហូត

*ដល់រូបនោះ នៅសល់ត្រឹមតែគ្រោងឆ្អឹង ធ្វើឲ្យព្រះនាងមានសេចក្តីសង្វេគតក់ស្លុត រន្ធត់ចិត្ត យ៉ាងខ្លាំង ឃើញច្បាស់ នូវការកើតរលត់នៃនាមរូប ហើយបានសម្រេចសោតាបត្តិផល ក្នុងពេលនោះឯងក្រោយមក ព្រះអង្គទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

**យេ រាគរត្តានុបតន្តិ សោតំ**
**សយំ កតំ មក្កដកោវ ជាលំ ។**
**ឯតម្បិ ឆេត្វាន វជន្តិ ធីរា**
**អនបេក្ខិនោ សព្វទុក្ខំ បហាយ ។**

*ជនទាំងឡាយណា ជាអ្នកត្រេកអរហើយដោយរាគៈ ជនទាំងឡាយនោះ តែងធ្លាក់ចុះទៅកាន់ខ្សែនៃតណ្ហា ដូចពីងពាង ទម្លាក់ខ្លួនចុះកាន់សំណាញ់ ដែលបានធ្វើហើយ ដោយខ្លួនឯង អ្នកប្រាជ្ញទាំងឡាយ តែងកាត់ខ្សែ នៃតណ្ហានោះ ជាអ្នកមិនមានសេចក្តីអាឡោះអាល័យ លះបង់នូវសេចក្តីទុក្ខទាំងពួងចេញទៅ ។*

❃ ❃ ❃

## ២៤៥- រឿង ឧគ្គសេនសេដ្ឋីបុត្រ

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធសេដ្ឋីបុត្រ ឈ្មោះឧគ្គសេន ដែលមានភរិយាជាធីតា របស់អ្នកលេងរបាំ ។ ដោយបុព្វកម្ម ក្នុងសាសនានៃព្រះពុទ្ធព្រះនាមកស្សបទសពល, អ្នកទាំងពីរនាក់ ភរិយាស្វាមីនេះ បានធ្វើបុណ្យ ថ្វាយទាន ដល់ព្រះអរហន្តទីណាស្រេពមួយអង្គហើយបានប្រាថ្នាសុំ នូវចំណែកធម៌ ដែលព្រះអរហន្តអង្គនោះ បាន*

ឃើញហើយ ។ ព្រះអរហន្តអង្គនោះ ជ្រាបថា "សេចក្តីប្រាថ្នារបស់កិរិយាស្វាមីនេះ នឹងបានសម្រេច" ទើបបានធ្វើសេចក្តីញញឹម ឲ្យប្រាកដ ។ គូកិរិយាស្វាមីទាំង ២ នាក់នោះ បានឃើញព្រះអរហន្តអង្គនោះ ញញឹមយ៉ាងនេះហើយ ក៏បាននិយាយគ្នា ថា "លោកជាកូនរបស់អ្នកទីក្រុង បានជាធ្វើយ៉ាងនេះ" ។

ក្នុងសាសនានេះ កិរិយាបានកើតជាធីតារបស់អ្នកលេងរបាំ។ ឧគ្គសេនសេដ្ឋីបុត្រ បានទៅមើលរបាំ ឃើញនាងរបាំនោះ មានរូបស្អាត ក៏កើតសេចក្តីស្រឡាញ់ភ្លាម លុះត្រឡប់មកផ្ទះវិញ បានសុំអង្វរករឲ្យមាតាបិតា ចូលទៅស្តីដណ្តឹងនាងរបាំនោះមកធ្វើជាកិរិយា លុះរៀបការ ជាមួយនឹងនាងរបាំនោះហើយ ក៏នាំគ្នាប្រកបរបរចិញ្ចឹមជីវិត ដោយការសម្តែងរបាំនោះឯង ជារៀងរាល់ថ្ងៃ ។ នៅថ្ងៃមួយ ឧគ្គសេនសេដ្ឋីបុត្រ បានទៅសម្តែងរបាំ ក្នុងទីក្រុងរាជគ្រឹះ ។

ព្រះសាស្តា ទ្រង់បានត្រាស់ទេសនា អប់រំទូន្មាន ឲ្យឧគ្គសេន និង កិរិយា បានយល់ច្បាស់ ថា "នែឧគ្គសេន ធម្មតាបណ្ឌិត ត្រូវតែលះបង់សេចក្តីស្រឡាញ់ ក្នុងខន្ធទាំងឡាយ ទាំងអតីតៈ អនាគត ទាំងបច្ចុប្បន្ន ចោលហើយ រួចផុតអំពីសេចក្តីទុក្ខទាំងពួង មានជាតិទុក្ខ ជាដើម ទើបសមគួរ" ក្នុងទីបញ្ចប់ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

មុញ្ច បុរេ មុញ្ច បច្ឆតោ
មជ្ឈេ មុញ្ច ភវស្ស បារគូ

-៣៧៤-

រឿង ចូឡធនុគ្គហបណ្ឌិត

**សព្វត្ថ វិមុត្តមានសោ**
**ន បុន ជាតិជរំ ឧបេហិសិ ។**

*អ្នកចូរដោះ (សេចក្តីអាល័យ) ក្នុងកាលមុនចេញ ចូរដោះ (សេចក្តីអាល័យ) ក្នុងកាលជាខាងក្រោយចេញ ចូរដោះ (សេចក្តីអាល័យ) ក្នុងកាលជាកណ្តាលចេញ (កាលបើធ្វើយ៉ាងនេះ) អ្នកនឹងដល់ត្រើយនៃភព នឹងមានចិត្តរួចស្រឡះ ចាកសង្ខតធម៌ទាំងពួង នឹងមិនចូលទៅកាន់ជាតិ និង ជរា ទៀតឡើយ ។*

♣ ♣

២៤៦- រឿង ចូឡធនុគ្គហបណ្ឌិត

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធ នូវភិក្ខុកំលោះមួយរូប ដែលប្រាថ្នាចង់លាចាកសិក្ខាបទ មានរាងកាយស្គាំងស្គម ព្រោះតែសេចក្តីស្រឡាញ់ ។ ភិក្ខុទាំងឡាយ បានដឹងរឿងនោះហើយ ក៏បាននាំយកភិក្ខុរូបនោះ ទៅគាល់ព្រះសាស្តា ។*

*ព្រះសាស្តា ទ្រង់ជ្រាបហើយ ទ្រង់នាំអតីតនិទាន មកសម្តែងថា "ម្នាលភិក្ខុទាំងឡាយ ក្នុងបុព្វជាតិ ភិក្ខុរូបនេះ បានកើតជាចូឡធនុគ្គហបណ្ឌិត បានទៅសិក្សាសិល្បសាស្ត្រ ក្នុងសំណាក់អាចារ្យទិសាបាមោក្ខ ក្នុងក្រុងតក្កសីលា លុះសិក្សាចប់ហើយ ក៏សុំលាលោកគ្រូ ត្រឡប់ទៅផ្ទះរបស់ខ្លួនវិញ ។ អាចារ្យទិសាបាមោក្ខ មានចិត្តត្រេកអរខ្លាំងណាស់ ហើយបានលើកកូនក្រមុំ ឲ្យចូឡធនុគ្គហបណ្ឌិត ធ្វើជាភរិយា ។ លុះរៀបមង្គលការរួចស្រេចហើយ, នាយ*

## គាថាធម្មបទប្រែ

ចូឡធនុគ្គហបណ្ឌិត បាននាំភរិយា ជាទីស្រឡាញ់ ធ្វើដំណើរទៅក្រុងពារាណសី លុះដល់ពាក់កណ្ដាលផ្លូវ ក៏ស្រាប់តែចួបប្រទះនឹងពួកចោរ ៥០ នាក់ នៅក្បែរមាត់ព្រៃ បានបាញ់សម្លាប់ចោរ អស់ ៤៩ នាក់ ដោយកូនសរ ៤៩ ហើយបានទាញធ្នូ បាញ់ចោរម្នាក់ទៀត តែបាញ់ខុស ធ្វើឲ្យអស់កូនសរល្មម ហើយបានស្ទុះទៅ ចាប់ចោរនោះផ្ដួលចុះ ស្រែកហៅភរិយា ឲ្យយកដាវមក ដើម្បីសម្លាប់ចោរនោះ ។ ចំណែកភរិយា បានក្បត់ចិត្តស្វាមី មានចិត្តស្រឡាញ់ចោរ ទើបបានហុចដាវទៅឲ្យចោរក្លាម ។ ចោរ បានដាវហើយ ក៏សម្លាប់នូវនាយចូឡធនុគ្គហបណ្ឌិតស្លាប់ មួយរំពេចនោះឯង ស្រេចហើយ ក៏បាននាំនាងទៅមាត់ទឹក បានដោះនូវគ្រឿងអលង្ការ សំលៀកបំពាក់ ដែលមានតម្លៃ របស់នាង អស់រលីងគ្មានសល់ ទុកឲ្យនាងនៅឯការអនាថាតែម្នាក់ឯង ឥតទីពឹង ក្នុងព្រៃស្ងាត់ ហើយឆ្លងស្ទឹងទៅត្រើយម្ខាង ។ នាងនោះ បានមកកើតជាស្រី ដែលភិក្ខុកំលោះនេះស្រឡាញ់ ក្នុងពេលឥឡូវនេះឯង" ក្នុងទីបញ្ចប់នៃអតីតនិទាន ទ្រង់ត្រាស់ទូន្មាន ឲ្យភិក្ខុរូបនោះ កាត់ផ្ដាច់នូវរាគតណ្ហា ដែលកើតឡើង ព្រោះស្រីនោះហើយ ត្រាស់នូវព្រះគាថានេះ ថា ៖

វិតក្កមថិតស្ស ជន្តុនោ
តិព្វរាគស្ស សុភានុបស្សិនោ
ភិយ្យោ តណ្ហា បវឌ្ឍតិ
ឯស ខោ ទឡ្ហំ ករោតិ ពន្ធនំ ។

**វិតក្កូបសមេ ច យោ រតោ**
**អសុភំ ភាវយតី សទា សតោ**
**ឯស ខោ វ្យន្តិកាហតិ**
**ឯសច្ឆិន្ទតិ មារពន្ធនំ ។**

*តណ្ហា រមែងចំរើនក្រៃលែង ដល់បុគ្គលដែលវិតក្កៈ ញាំញី ហើយ មានតម្រេកក្លៀវក្លា យល់ឃើញអារម្មណ៍ថាល្អ បុគ្គលនោះឯង ឈ្មោះថាធ្វើចំណងឲ្យមាំមួន ។ លុះតែបុគ្គលណា ត្រេកអរ ក្នុងអសុភជ្ឈាន ដែលជាហេតុឲ្យស្ងប់រម្ងាប់វិតក្កៈ មានស្មារតី សព្វកាល តែងចំរើនអសុភជ្ឈាន បុគ្គលនោះឯង នឹងធ្វើតណ្ហា ឲ្យអស់ទៅបាន បុគ្គលនោះឯង ទើបឈ្មោះថា កាត់ចំណងមារបាន ។*

✽ ✽

## ២៤៧- រឿង មារ

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវមារ ។ ក្នុងរាត្រីយប់មួយ មារនោះ បាននិមិត្តកាយធ្វើជាដំរី មកបៀតបៀនព្រះរាហុល ដែលកំពុងតែសិង នៅពីមុខព្រះគន្ធកុដី នៃព្រះសាស្តា ។ ព្រះសាស្តា ទ្រង់ជ្រាបហើយ ទ្រង់ត្រាស់ ថា "នៃមារចិត្តបាប អ្នកមិនអាចនឹងធ្វើឲ្យបុត្ររបស់តថាគត តក់ស្លុតបានឡើយ ព្រោះបុត្ររបស់តថាគត ជាអ្នកអង់អាចក្លាហាន មានប្រាជ្ញាច្រើន ប្រាសចាកតណ្ហា" ដូច្នេះហើយ ទ្រង់ត្រាស់នូវព្រះគាថានេះថា ៖*

**និដ្ឋំ គតោ អសន្តាសី វីតតណ្ហោ អនង្គណោ**

គាថាធម្មបទប្រែ

អដ្ឋិន្និ ភវសល្លានិ អន្តិមោយំ សមុស្សយោ ។
វីតតណ្ហោ អនាទានោ និរុត្តិបទកោវិទោ
អក្ខរានំ សន្និបាតំ ជញ្ញា បុព្វបរានិ ច
ស វេ អន្តិមសារីរោ មហាបញ្ញោ មហាបុរិសោតិ វុច្ចតិ ។

*បុគ្គលណា ដល់នូវសេចក្តីសម្រេចគឺអរហត្ត ជាអ្នកមិនតក់ស្លុត មិនមានតណ្ហា មិនមានកិលេសដូចទីទួល បានកាត់នូវកូនសរគឺកិលេស ជាហេតុញ៉ាំងសត្វ ឲ្យទៅកាន់ភពបានហើយ កាយនេះដែលឆ្អឹង ៣០០ កំណាត់ ផ្គុំគ្នាហើយ របស់បុគ្គលនោះ ឈ្មោះថាតាំងនៅ ក្នុងទីបំផុត ។*

*បុគ្គលណា មិនមានតណ្ហា មិនមានសេចក្តីប្រកាន់មាំ ជាអ្នកឆ្លាត ក្នុងនិរុត្តិ (វាចាជាគ្រឿងសម្តែងចេញ) និង បទដ៏សេស ដឹងច្បាស់នូវប្រជុំ នៃអក្ខរៈទាំងឡាយផង នូវខាងដើម និង ខាងចុង នៃអក្ខរៈទាំងឡាយផង បុគ្គលនោះឯង តថាគតហៅថា អ្នកមានសរីរៈឋិតនៅ ក្នុងទីបំផុត មានបញ្ញាច្រើន ជាមហាបុរស ។*

♣ ♣ ♣

## ២៤៨- រឿង ឧបកាជីវក

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវឧបកាជីវក ក្នុងពេលដែលព្រះអង្គបានត្រាស់ដឹងអនុត្តរសម្មាសម្ពោធិញ្ញាណហើយ ស្តេចយាងចេញ ពីពោធិមណ្ឌល ដើម្បីនឹងសម្តែង នូវព្រះធម្មចក្កប្បវត្តនសូត្រប្រោសភិក្ខុបញ្ចវគ្គីយ៍ ក្នុងព្រៃឥសិបតនមិគទាយវ័ន ទ្រង់បានចួប*

រឿងសក្កទេវរាជ

ប្រទះនឹងឧបកាជីវក នាពាក់កណ្ដាលផ្លូវ ។

ឧបកាជីវក បានឃើញព្រះសាស្ដាមានព្រះវរកាយ ដ៏បរិសុទ្ធផូរផង់ នឹកអស្ចារ្យក្នុងចិត្ត ទើបក្រាបទូលសួរ ថា “លោកដ៏មានអាយុ ឥន្ទ្រិយ៍ របស់លោកល្អបរិសុទ្ធ តើលោកបួសឧទ្ទិសអ្នកណា? តើអ្នកណា ជាគ្រូរបស់លោក? លោកចូលចិត្តធម៌ របស់អ្នកណា?” ។

ព្រះសាស្ដា ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

សព្វាភិភូ សព្វវិទូហមស្មិ
សព្វេសុ ធម្មេសុ អនូបលិត្តោ
សព្វញ្ជហោ តណ្ហក្ខយេ វិមុត្តោ
សយំ អភិញ្ញាយ កមុទ្ទិសេយ្យំ ។

តថាគត ជាអ្នកគ្របសង្កត់តេភូមិកធម៌ទាំងអស់ ដឹងច្បាស់ចតុព្ភូមិកធម៌ទាំងអស់ មានចិត្តមិនបានជាប់នៅ ក្នុងតេភូមិកធម៌ទាំងអស់ លះបង់តេភូមិកធម៌ទាំងអស់ មានចិត្តរួចស្រឡះ ព្រោះអស់តណ្ហា បើតថាគតត្រាស់ដឹងធម៌ ដោយខ្លួនឯងហើយ តើចាំបាច់យកអ្នកណាជាគ្រូអាចារ្យ ទៀត ។

២៤៩- រឿងសក្កទេវរាជ

ព្រះបរមសាស្ដា ទ្រង់ប្រារព្ធនូវសក្កទេវរាជ ដែលបាននាំពួកទេវតា មកគាល់ព្រះអង្គ ដើម្បីនឹងក្រាបទូលនូវសួរបញ្ហា ៤ ប្រការ ដែលពួកទេវតា ក្នុងមួយហ្នឹងចក្រវាឡ បានជជែកប្រកែកគ្នា មិនចេះ

ដាច់ស្រេច ដូចមានតទៅនេះ គឺ ៖

ទី១- ឲ្យវត្ថុអ្វី ទើបប្រសើរ ?

ទី២- រសអ្វី ទើបប្រសើរ?

ទី៣- សេចក្ដីត្រេកអរអ្វី ទើបប្រសើរ?

ទី៤- ការអស់ទៅ នៃតណ្ហា ប្រសើរយ៉ាងណា? ។

ព្រះសាស្ដាទ្រង់ជ្រាបហើយ ទើបត្រាស់នូវព្រះគាថានេះថា ៖

សព្វទានំ ធម្មទានំ ជិនាតិ
សព្វរសំ ធម្មរសោ ជិនាតិ
សព្វរតឹ ធម្មរតិ ជិនាតិ
តណ្ហក្ខយោ សព្វទុក្ខំ ជិនាតិ ។

ធម្មទាន ឈ្នះអស់ទានទាំងពួង ធម្មរស ឈ្នះរសទាំងពួង សេចក្ដីត្រេកអរ ក្នុងធម៌ ឈ្នះសេចក្ដីត្រេកអរទាំងពួង ការអស់ទៅនៃតណ្ហា ឈ្នះសេចក្ដីទុក្ខទាំងពួង ។

✻ ✻

## ២៨០- រឿងអបុត្តកសេដ្ឋី

ព្រះបរមសាស្ដា ទ្រង់ប្រារព្ធនូវសេដ្ឋីម្នាក់ ជាអ្នកគ្មានបុត្រ ។ សេដ្ឋីនេះ ជាមនុស្សកំណាញ់ហួសប្រមាណ មានទ្រព្យសម្បត្តិដែរ តែដូចជាគ្មានប្រយោជន៍អ្វី ដល់ខ្លួនសោះ, កាលគាត់បានធ្វើកាលកិរិយាហើយ, ទ្រព្យសម្បត្តិទាំងប៉ុន្មាន ក៏បានធ្លាក់ទៅ លើព្រះរាជាទាំងអស់ ។

## រឿងអង្កុរទេវបុត្រ

ព្រះបាទបសេនទិកោសល ទ្រង់យាងទៅ គាល់ព្រះសាស្តា ហើយ ទ្រង់ក្រាបទូលរឿងសេដ្ឋីកំណាញ់នោះ ដល់ព្រះអង្គ ។

ព្រះសាស្តា ទ្រង់ត្រាស់សម្តែងបុព្វកម្ម របស់សេដ្ឋី ដោយសង្ខេប ថា "ហេតុដែលបានមកកើតជាសេដ្ឋីនេះ ព្រោះកាលពីជាតិមុន បានថ្វាយទាន ដល់ព្រះបច្ចេកពុទ្ធ ព្រះនាមតគរសិខី, ហេតុដែលមានទ្រព្យសម្បត្តិច្រើន តែមិនមានប្រយោជន៍ដល់ខ្លួននោះ ព្រោះឃើញបិណ្ឌបាត ដែលខ្លួនថ្វាយនោះប្រណីត ហើយមានចិត្តសោកស្តាយ ជាខាងក្រោយ ថា: មិនសមគួរនឹងថ្វាយសោះ បើទុកឲ្យពួកកម្មករស៊ី ដូចជាប្រសើជាង លុះសេដ្ឋីនោះ ធ្វើកាលកិរិយាទៅហើយ បានទៅទទួលទុក្ខវេទនា ក្នុងមហារោរុវនរក ព្រោះបានសម្លាប់ចៅរបស់ខ្លួន យកទ្រព្យសម្បត្តិ" ក្នុងទីបញ្ចប់នៃអតីតនិទាន ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

**ហនន្តិ ភោគា ទុម្មេធំ នោ ច បារគវេសិនោ**
**ភោគតណ្ហាយ ទុម្មេធោ ហន្តិ អញ្ញេវ អត្តនំ ។**

ភោគៈទាំងឡាយ រមែងសម្លាប់បុគ្គលអប្បប្រាជ្ញា ប៉ុន្តែមិនសម្លាប់អ្នកស្វែងរកត្រើយ គឺព្រះនិព្វានទេ ឯបុគ្គលអប្បប្រាជ្ញា រមែងសម្លាប់ខ្លួនឯង ដូចជាសម្លាប់បុគ្គលដទៃ ព្រោះប្រាថ្នាចង់បានភោគៈ។

***

## ២៥១- រឿងអង្កុរទេវបុត្រ

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវអង្កុរទេវបុត្រ ក្នុងពេលដែល

# គាថាធម្មបទប្រែ

*ព្រះអង្គស្តេចយាងទៅប្រោសព្រះពុទ្ធមាតា នៅឯឋានត្រៃត្រិង្សទេវ-លោក ទ្រង់គង់លើបណ្ឌុកម្ពលសិលា ក្រោមដើមបារិច្ឆត្តកព្រឹក្ស ។*

*គ្រានោះ មានទេវបុត្រពីរអង្គ នៅចាំគាល់ ក្នុងទេវសមាគមនោះ គឺ អង្កុរទេវបុត្រ ធ្លាប់បានឲ្យទានដល់មហាជន អស់រយៈពេលមួយឆ្នាំ, ឥន្ទកទេវបុត្រ ធ្លាប់បានប្រគេនភិក្ខាហារមួយវែក ដល់ព្រះអនុរុទ្ធត្ថេរ តែជាអ្នកមានសក្តិធំ ជាងអង្កុរទេវបុត្រ ព្រោះបានថ្វាយទាន ដល់បដិគ្គាហកៈ ដែលមានគុណសម្បត្តិច្រើនជាងគ្នា ។*

*ព្រះសាស្តាចារ្យ ទ្រង់សម្តែង នូវទក្ខិណេយ្យបុគ្គល ហើយត្រាស់នូវព្រះគាថានេះ ថា ៖*

តិណទោសានិ ខេត្តានិ　　រាគទោសា អយំ បជា
តស្មា ហិ វីតរាគេសុ　　ទិន្នំ ហោតិ មហប្ផលំ ។
តិណទោសានិ ខេត្តានិ　　ទោសទោសា អយំ បជា
តស្មា ហិ វីតទោសេសុ　　ទិន្នំ ហោតិ មហប្ផលំ ។
តិណទោសានិ ខេត្តានិ　　មោហទោសា អយំ បជា
តស្មា ហិ វីតមោហេសុ　　ទិន្នំ ហោតិ មហប្ផលំ ។
តិណទោសានិ ខេត្តានិ　　ឥច្ឆាទោសា អយំ បជា
តស្មា ហិ វីតិច្ឆេសុ　　ទិន្នំ ហោតិ មហប្ផលំ ។

*ស្រែទាំងឡាយ មានស្មៅជាទោស ពួកសត្វលោកនេះ មានរាគៈជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយ ដល់អ្នកដែលមានរាគៈអស់ហើយ រមែងជាទានមានផលច្រើន ។ ស្រែទាំង*

ឡាយ មានស្នៅជាទោស ពួកសត្វលោកនេះ មានទោសៈជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយ ដល់អ្នកដែលមានទោសៈ អស់ហើយ រមែងជាទានមានផលច្រើន ។ ស្រែទាំងឡាយមានស្មៅជាទោស ពួកសត្វលោកនេះ មានមោហៈជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយ ដល់អ្នកដែលមានមោហៈ អស់ហើយ រមែងជាទានមានផលច្រើន ។ ស្រែទាំងឡាយមានស្មៅជាទោស ពួកសត្វលោកនេះ មានសេចក្តីប្រាថ្នាជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយ ដល់អ្នកដែលមានសេចក្តីប្រាថ្នាអស់ហើយ រមែងជាទានមានផលច្រើន ។

**ចប់ តណ្ហាវគ្គ ទី ២៤**

ភិក្ខុវគ្គ ទី ២៥

២៥២- រឿងបញ្ចភិក្ខុ

ព្រះបរមសាស្តាទ្រង់ប្រារព្ធនូវភិក្ខុ ៥ រូប ។ បណ្តាភិក្ខុទាំង ៥ រូបនោះ ភិក្ខុមួយរូប សង្រួមចក្ខុទ្វារ មួយរូបទៀត សង្រួមសោតទ្វារ មួយរូបទៀត សង្រួមឃានទ្វារ មួយរូបទៀត សង្រួមជិវ្ហាទ្វារ មួយរូបទៀត សង្រួមកាយទ្វារ ។ ភិក្ខុរូបណា សង្រួមផ្លូវណា ក៏សម្គាល់ផ្លូវនោះថា មានការលំបាកជាងផ្លូវដទៃទៀត ។ ភិក្ខុទាំង ៥ រូបនោះ បាន ប្រកែកជជែកគ្នា ក្នុងទីចំពោះព្រះភក្ត្រ នៃព្រះសាស្តា ហើយក្រាបទូលអារាធនា ឲ្យព្រះអង្គជួយត្រាស់វិនិច្ឆ័យ ។

## គាថាធម្មបទប្រែ

ព្រះសាស្ដាចារ្យ ទ្រង់ត្រាស់សម្ដែងថា "ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីសង្រួម ក្នុងទ្វារទាំងពួង" ហើយត្រាស់នូវព្រះគាថានេះថា ៖

ចក្ខុនា សំវរោ សាធុ សាធុ សោតេន សំវរោ
ឃានេន សំវរោ សាធុ សាធុ ជិវ្ហាយ សំវរោ
កាយេន សំវរោ សាធុ សាធុ វាចាយ សំវរោ
មនសា សំវរោ សាធុ សាធុ សព្វត្ថ សំវរោ
សព្វត្ថ សំវុតោ ភិក្ខុ សព្វទុក្ខា បមុច្ចតិ ។

ការសង្រួមភ្នែក ជាការប្រពៃ ការសង្រួមត្រចៀក ជាការប្រពៃ ការសង្រួមច្រមុះ ជាការប្រពៃ ការសង្រួមអណ្ដាត ជាការប្រពៃ ការសង្រួមកាយ ជាការប្រពៃ ការសង្រួមវាចា ជាការប្រពៃ ការសង្រួមចិត្ត ជាការប្រពៃ ការសង្រួម ក្នុងទ្វារទាំងអស់ ជាការប្រពៃ ភិក្ខុសង្រួម ក្នុងទ្វារទាំងពួង រមែងរួចស្រឡះចាកទុក្ខទាំងពួងបាន ។

## ២៥៣- រឿងភិក្ខុសម្លាប់ហង្ស

ព្រះបរមសាស្ដា ទ្រង់ប្រារព្ធនូវភិក្ខុមួយរូប ជាអ្នកពូកែ ក្នុងរឿងផ្ទាត់ដុំក្រួស ។ ថ្ងៃមួយ ភិក្ខុនោះ កំពុងអង្គុយសន្ទនា ជាមួយនឹងភិក្ខុទាំងឡាយ បានឃើញហង្សហើរមក ទើបប្រាប់ភិក្ខុផងគ្នាថា "ខ្ញុំនឹងផ្ទាត់ដុំក្រួស ឲ្យត្រូវភ្នែកហង្សខាងនេះ ហើយឲ្យធ្លុះទៅខាងនុ៎ះ" ។ ភិក្ខុទាំងឡាយ ជាសំឡាញ់ មិនជឿ ។ ភិក្ខុរូបនោះ បានផ្ទាត់ដុំក្រួស

តម្រង់ទៅរកក្អែកហង្សហើយ ត្រូវចំក្អែកតែម្ដង ។ ហង្សបានធ្លាក់ចុះមកស្លាប់ មួយរំពេចនោះឯង ។ ភិក្ខុទាំងឡាយ បានឃើញហើយទើបយករឿងនោះ ទៅក្រាបទូល ដល់ព្រះសាស្ដា ។

ព្រះសាស្ដា ទ្រង់បានត្រាស់តិះដៀល ដោយប្រការផ្សេងៗ ហើយត្រាស់នូវព្រះគាថានេះ ថា ៖

ហត្ថសញ្ញតោ បាទសញ្ញតោ
វាចាសញ្ញតោ សញ្ញតុត្តមោ
អជ្ឈត្តរតោ សមាហិតោ
ឯកោ សន្តុសិតោ តមាហុ ភិក្ខុំ ។

បុគ្គលណាមានដៃសង្រួមហើយ មានជើងសង្រួមហើយ មានវាចាសង្រួមហើយ មានខ្លួនសង្រួមហើយ ជាអ្នកត្រេកអរហើយ ក្នុងការចំរើនកម្មដ្ឋាន ដែលមានក្នុងខ្លួន ជាអ្នកមានចិត្តតម្កល់មាំ ជាអ្នកនៅឯកឯង ជាអ្នកសន្ដោស បណ្ឌិតទាំងឡាយ ហៅបុគ្គលនោះ ថាភិក្ខុ ។

✻ ✻

២៥៤- រឿងកោកាលិកភិក្ខុ

ព្រះបរមសាស្ដា ទ្រង់បានប្រារព្ធនូវកោកាលិកភិក្ខុ ជាសាវ័ករបស់ភិក្ខុទេវទត្ត ។ កោកាលិកភិក្ខុនេះ ត្រូវផែនដីស្រូប ទៅធ្លាក់ដល់បទុមនរក ដោយបុព្វកម្ម ដែលខ្លួនបានជេរប្រទេច នូវព្រះអគ្គសាវ័កទាំងពីររូប ។

## គាថាធម្មបទប្រែ

*សម័យថ្ងៃមួយ ភិក្ខុទាំងឡាយ បានសន្ទនាគ្នា ថា "កោកា-លិកភិក្ខុត្រូវផែនដីស្រូប ព្រោះបាបកម្មដែលខ្លួនបានធ្វើមកហើយ" ។*

*ព្រះសាស្តាចារ្យ ស្តេចយាងមក ក្នុងទីប្រជុំនោះ ទ្រង់ត្រាស់កច្ឆបជាតក ថា "មានអណ្តើកមួយ ជាសំឡាញ់គ្នា ជាមួយនឹងហង្សមួយគូ ។ សត្វអណ្តើក ប្រាថ្នាចង់ទៅលេង នៅឯបឹងមួយ ក្បែរភ្នំចិត្តកូដ ទើបបានឲ្យហង្សទាំងពីរជាសំឡាញ់ ពាំកំណាត់ឈើ ខាងចុងទាំងសងខាង ខ្លួនឯងខាំចំកណ្តាល ឲ្យហង្សនាំហោះហើរទៅ តាមអាកាសវេហាស៍ ។*

*ពួកក្មេងៗ បានឃើញនូវហង្សទាំងពីរ ពាំនាំអណ្តើកហើរទៅតាមអាកាស យ៉ាងនេះហើយ ទើបស្រែកប្រាប់គ្នីគ្នា ថា "មើលនុ៎ះហ្ន៎ហង្សពាំនាំអណ្តើកហើរទៅ តាមអកាស" ។ អណ្តើក បានហាមាត់និយាយទៅកាន់ក្មេងៗ ហើយបានរបូតមាត់ ចេញពីឈើ ធ្លាក់ចុះមកលើដុំថ្ម ត្រូវស្នូកបែកស្លាប់ ក្នុងគ្រានោះឯង" ក្នុងទីបញ្ចប់នៃជាតកទ្រង់ប្រទាននូវព្រះឱវាទ ដល់ពួកភិក្ខុទាំងឡាយ ហើយត្រាស់នូវព្រះគាថានេះ ថា ៖*

យោ មុខសញ្ញតោ ភិក្ខុ   មន្តភាណី អនុទ្ធតោ
អត្ថំ ធម្មញ្ច ទីបេតិ   មធុរន្តស្ស ភាសិតំ ។

*ភិក្ខុណា មានមាត់សង្រួមហើយ ជាអ្នកពោល ដោយបញ្ញាមានចិត្តមិនរាយមាយ សម្តែងអត្ថផង ធម៌ផងបាន, ភាសិត របស់ភិក្ខុនោះ ទើបឈ្មោះថា ពីរោះ ។*

## ២៥៥- រឿង ព្រះធម្មារាមត្ថេរ

ព្រះបរមសាស្ដា ទ្រង់ប្រារព្ធព្រះធម្មារាមត្ថេរ ក្នុងពេលដែលព្រះអង្គទ្រង់ដាក់ នូវព្រះជន្មាយុសង្ខារ នឹងទ្រង់យាងចូលកាន់ព្រះបរិនិព្វាន ក្នុងថ្ងៃពេញបូរណ៌មី នាខែវិសាខ ។

គ្រានោះ ពួកភិក្ខុទាំងឡាយ កើតសេចក្ដីសង្វេគ តក់ស្លុតចិត្តយ៉ាងខ្លាំង មិនហានក្រោកចេញពីទីប្រថាប់ របស់ព្រះសាស្ដាឡើយ ប្រឹក្សាគ្នា ជាពួកជាក្រុម មិនឲ្យដាច់ ។ ចំណែកព្រះធម្មារាមត្ថេរ មិនបានទៅប្រជុំប្រឹក្សា ជាមួយនឹងភិក្ខុទាំងនោះទេ ប៉ុន្តែបានពិចារណាថា "អាត្មាអញ នឹងខំបំពេញសេចក្ដីព្យាយាម ដើម្បីឲ្យបានសម្រេចព្រះអរហត្តផល នៅពេលដែលព្រះបរមសាស្ដា ទ្រង់មានព្រះជន្មាយុនៅឡើយ" ស្រេចហើយ ទើបបានទៅបំពេញសមណធម៌ តែមួយអង្គឯងគត់ ។

ភិក្ខុទាំងឡាយ បានសន្ទនាគ្នា ថា "ព្រះធម្មារាមត្ថេរ មិនមានសេចក្ដីស្រឡាញ់ចំពោះព្រះសាស្ដា" ហើយទៅក្រាបទូល រឿងនោះដល់ព្រះសាស្ដា ។

ព្រះសាស្ដា ទ្រង់ជ្រាបហើយ ទ្រង់បានត្រាស់បញ្ជា ឲ្យភិក្ខុទៅនិមន្តព្រះធម្មារាមត្ថេរ មកត្រាស់សួរ ។ ព្រះធម្មារាមត្ថេរ បានក្រាបទូលការត្រិះរិះរបស់ខ្លួន ថ្វាយដល់ព្រះសាស្ដា ។

ព្រះសាស្ដា ទ្រង់ប្រទាននូវសាធុការ ត្រាស់ឲ្យភិក្ខុទាំងឡាយយកធ្វើជាគំរូ ទ្រង់ត្រាស់សរសើរធម្មានុធម្មបដិបត្តិ ហើយត្រាស់នូវព្រះគាថានេះ ថា ៖

គាថាធម្មបទប្រែ

ធម្មារាមោ ធម្មរតោ ធម្មំ អនុវិចិន្តយំ
ធម្មំ អនុស្សរំ ភិក្ខុ សទ្ធម្មា ន បរិហាយតិ ។

*ភិក្ខុ មានធម៌ជាទីត្រេកអរ ត្រេកអរហើយ ក្នុងធម៌ ពិចារណានូវធម៌ រលឹកនូវធម៌រឿយៗ រមែងមិនសាបសូន្យចាកព្រះសទ្ធម្ម បានឡើយ ។*

♣ ♣ ♣

## ២៩៦-រឿងអញ្ញតរវិបក្ខកភិក្ខុ

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធ នូវភិក្ខុមួយរូប ដែលបានទៅសេពគប់ជាមួយនឹងភិក្ខុ ដែលជាបក្សពួក របស់ភិក្ខុទេវទត្ត ។ ថ្ងៃមួយ ភិក្ខុដែលជាបក្សពួក របស់ភិក្ខុទេវទត្ត បានឃើញភិក្ខុរូបនោះ កំពុងតែដើរបិណ្ឌបាត ហើយបបួលឲ្យទៅនៅជាមួយ បាននិយាយពន្យល់ ថា "លាភសក្ការៈ របសខ្ញុំ មានច្រើនណាស់" ។ ភិក្ខុនោះ ក៏បានទៅនៅជាមួយ អស់រយៈពេលបួនប្រាំខែ ហើយ បានត្រឡប់មកវិញ ។ ភិក្ខុទាំងឡាយ បានដឹងរឿងនោះហើយ ទើបចូលទៅក្រាបទូល ដល់ព្រះសាស្តា ។*

*ព្រះសាស្តា ទ្រង់ត្រាស់ឲ្យភិក្ខុទៅនិមន្តភិក្ខុនោះមក ដើម្បីនឹងសាកសួរ ។ ភិក្ខុរូបនោះ បានក្រាបទូលរឿងពិត ដល់ព្រះអង្គ ។*

*ព្រះសាស្តា ទ្រង់សម្តែងធម្មីកថា ត្រាស់នូវព្រះគាថានេះថា ៖*

សលាភំ នាតិមញ្ញេយ្យ នាញ្ញេសំ បិហយំ ចរេ
អញ្ញេសំ បិហយំ ភិក្ខុ សមាធឹ នាធិគច្ឆតិ ។

-៣៨៨-

## រឿង បញ្ចគ្គទាយកព្រាហ្មណ៍

**អប្បលាភោបិ ចេ ភិក្ខុ    សលាភំ នាតិមញ្ញតិ**
**តំ វេ ទេវា បសំសន្តិ    សុទ្ធាជីវមតន្ទិតំ ។**

*ភិក្ខុ មិនត្រូវមើលងាយលាភរបស់ខ្លួន(ដែលកើតឡើងដោយធម៌) មិនគប្បីប្រព្រឹត្តចង់បានលាភរបស់ភិក្ខុដទៃ បើចង់បានលាភរបស់ភិក្ខុដទៃ រមែងមិនបាននូវសមាធិឡើយ ។ ភិក្ខុសូម្បីមានលាភតិច ក៏ដោយ (តែ) មិនមើលងាយលាភរបស់ខ្លួន ទេវតា និង មនុស្សទាំងឡាយ តែងសរសើរនូវភិក្ខុនោះឯង ដែលជាអ្នកមានព្យាយាមជាគ្រឿងអាស្រ័យ រស់នៅ ដោយបរិសុទ្ធ ជាអ្នកមិនខ្ជិលច្រអូស ។*

## ២៥៧- រឿង បញ្ចគ្គទាយកព្រាហ្មណ៍

*ព្រះបរមសាស្ដា ទ្រង់ប្រារព្ធនូវបញ្ចគ្គទាយកព្រាហ្មណ៍ ដែលជាអ្នកត្រេកអរ ក្នុងការបរិច្ចាគទាន ។ ព្រាហ្មណ៍ម្នាក់នេះ បើគាត់មិនបានបរិច្ចាគទានជាមុនហើយ គាត់ក៏មិនបរិភោគអាហារដែរ ។*

*ថ្ងៃមួយ ព្រះសាស្ដា ទ្រង់ទតព្រះនេត្រឃើញឧបនិស្ស័យ នៃអនាគាមិផល របស់ព្រាហ្មណ៍ និង នាងព្រាហ្មណី ដែលជាភរិយាហើយ ទើបស្ដេចយាងទៅបិណ្ឌបាត នៅមុខគេហដ្ឋាន របស់គាត់ ។*

*ពេលនោះ ព្រាហ្មណ៍ កំពុងតែអង្គុយបរិភោគអាហារ បែរមុខទៅ ខាងក្នុងគេហដ្ឋាន ។ ចំណែកភរិយាអង្គុយប្រតិបត្តិស្វាមី ក្នុងពេលនោះដែរ ហើយបានក្រឡេកឃើញព្រះសាស្ដា ស្ដេចទ្រង់ឈរបិណ្ឌបាត នៅមុខគេហដ្ឋានរបស់ខ្លួនយ៉ាងនេះហើយ ទើបគិតថា "បើ*

ស្វាមី របស់អាត្មាអញ ឃើញព្រះសាស្ដាហើយ ប្រាកដជានឹងយកអាហារ របស់គាត់ ទៅប្រគេនព្រះអង្គហើយ បើដូច្នេះ អាត្មាអញមិនអាចនឹងធ្វើម្ហូបអាហារ សាជាថ្មីម្ដងទៀត ឲ្យទាន់ចិត្ត របស់គាត់បានទេ" ដូច្នេះហើយ នាងក៏បានឈរបាំង ដើម្បីកុំឲ្យស្វាមីរបស់នាងឃើញព្រះសាស្ដា ។ បន្ទាប់មក នាងព្រាហ្មណី បានងាកលួចមើលព្រះសាស្ដា ដើម្បីឲ្យដឹង ថា "តើព្រះអង្គ ស្ដេចយាងត្រឡប់ទៅវត្តវិញហើយ ឬនៅ?" លុះឃើញនូវព្រះសាស្ដា កំពុងតែទ្រង់ឈរ នៅស្ងៀម ចង់ក្រាបទូលព្រះអង្គ ប៉ុន្តែ ខ្លាចក្រែងស្វាមីនាងឮ ទើបបាននិមន្ត បួញមាត់ខ្សឹបៗ ដើម្បីធ្វើជាសញ្ញា ឲ្យព្រះអង្គស្ដេចយាងទៅខាងមុខទៀត ។

ព្រះសាស្ដា ទ្រង់បានឯក់ព្រះសិរសា ឆ្លើយតប ឲ្យនាងបានដឹង ថា "តថាគត នឹងមិនទៅទេ" ។ នាងព្រាហ្មណីបានឃើញដូច្នេះហើយអត់ទ្រាំមិនបាន ក៏របូតមាត់សើចចេញមកភ្លាម ។ ព្រាហ្មណ៍ជាស្វាមី បានឮសំឡេងប្រពន្ធសើចហើយ ក៏ងាកបែរមកមើលខាងក្រោយ ហើយបានឃើញព្រះសាស្ដា កំពុងតែទ្រង់ប្រថាប់ឈរ នៅស្ងៀម ដូច្នោះហើយ ទើបលើកថាសភោជនដែលមានបាយសល់ពីខ្លួនបរិភោគនោះ ទៅក្រាបទូលព្រះអង្គ ថា "បពិត្រព្រះអង្គ ដ៏ចំរើនកត្តាហារ ដទៃទៀត ក្រៅអំពីនេះ មិនមានទេ មានតែកត្តាហារ ដែលសល់ អំពីខ្ញុំព្រះករុណាបរិភោគនេះឯង បើព្រះអង្គ មិនខ្ពើមរអើមទេ សូមទ្រង់ទទួលយក ដោយសេចក្ដីអនុគ្រោះផងចុះ" ។

## រឿងសម្ពហុលភិក្ខុ

ព្រះសាស្តា ទ្រង់ត្រាស់ ថា "ម្នាលព្រាហ្មណ៍ អាហារ ដែល បុគ្គលមិនទាន់បរិភោគក្តី បរិភោគនៅសេសសល់ក្តី អាហារដែលជា សំណល់ក្តី សមគួរ ដល់តថាគតទាំងអស់ ព្រោះថា តថាគតដូចជា បរទត្តូបជីវិប្រេត" ។

ព្រាហ្មណ៍ ឮដូច្នេះហើយ មានចិត្តជ្រះថ្លារីករាយ ជាទីបំផុត បានលាន់មាត់ភ្លាមថា "ពុទ្ធោ! ព្រះអង្គអើយ ចំជាអស្ចារ្យណាស់!" ហើយបានក្រាបទូលសួរ ថា "បពិត្រព្រះអង្គដ៏ចំរើន ព្រោះហេតុអ្វី បានជាព្រះអង្គ ហៅសាវក របស់ព្រះអង្គ ថា ភិក្ខុ" ។

ព្រះសាស្តា ទ្រង់បានត្រាស់ឆ្លើយតប ហើយត្រាស់ នូវព្រះ គាថានេះ ថា ៖

**សព្វសោ នាមរូបស្មឹ យស្ស នត្ថិ មមាយិតំ**
**អសតា ច ន សោចតិ ស វេ ភិក្ខូតិ វុច្ចតិ ។**

បុគ្គលណា មិនមានសេចក្តីប្រកាន់មាំ ក្នុងនាម និង រូបថា ជា របស់អញ ដោយប្រការទាំងពួង មួយទៀត បុគ្គលណា មិនសោក ស្តាយ ព្រោះនាម និង រូប ដែលមិនមាន បុគ្គលនោះឯង តថាគតហៅ ថា ភិក្ខុ ។

❋ ❋

## ២៥៨- រឿងសម្ពហុលភិក្ខុ

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវភិក្ខុជាច្រើនរូប ។ ពេលដែល មិនទាន់បានបួស, ភិក្ខុទាំងនោះ ជាចោរ បានទៅលួចបប្លន់ផ្ទះ របស់

## គាថាធម្មបទប្រែ

ឧបាសិកាម្នាក់ ។ មេចោរ បានលបទៅធ្វើការប្រទូសរ៉ាយឧបាសិកាម្នាក់ ដែលកំពុងតែអង្គុយស្តាប់ធម៌ទេសនា ក្នុងព្រះវិហារ ។ ក្នុងពេលជាមួយគ្នានោះដែរ ស្រាប់តែមានមនុស្ស ទៅប្រាប់ឧបាសិកានោះ ថា "ឥឡូវនេះ ពួកចោរ បានប្លន់ផ្ទះហើយ បានយកនូវទ្រព្យសម្បត្តិ នេះខ្លះ នោះខ្លះ" ។

ឧបាសិកា បាននិយាយប្រាប់ថា "បើពួកចោរចង់បានរបស់អ្វី សូមឲ្យពួកគេយករបស់ទាំងនោះ តាមសេចក្តីប្រាថ្នាចុះ ខ្ញុំ នឹងស្តាប់ព្រះធម៌ទេសនាសិន" ដូច្នេះហើយ ក៏បាននិយាយទៅកាន់អ្នកដែលមកប្រាប់នោះ អស់វារៈ ៣ ដង ។

មេចោរ បានឮឧបាសិកាពោលដូច្នោះហើយ ក៏មានចិត្តជ្រះថ្លា ហើយបានប្រញាប់ប្រញាល់ ទៅប្រាប់ដល់កូនចោរ របស់ខ្លួន ឲ្យនាំយកទ្រព្យសម្បត្តិ ដែលបានប្លន់មកនោះ ទៅទុកក្នុងផ្ទះឧបាសិកានោះ ឲ្យដូចដើមវិញ បាននាំគ្នាសុំទោសចំពោះឧបាសិកានោះ ស្រេចហើយ ក៏ចេញទៅបួសជាភិក្ខុ ក្នុងព្រះពុទ្ធសាសនាទាំងអស់គ្នា លុះបួសហើយ ក៏បានទៅបំពេញសមណធម៌ លើកំពូលភ្នំដ៏ស្ងាត់មួយ ។

ព្រះសាស្តា ទ្រង់បានបញ្ចេញនូវព្រះរស្មី ទៅរកភិក្ខុទាំងនោះ បីដូចជាទ្រង់គង់ ក្នុងទីចំពោះមុខ នៃភិក្ខុទាំងនោះ ហើយទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

មេត្តាវិហារី យោ ភិក្ខុ　　បសន្នោ ពុទ្ធសាសនេ<br>
អធិគច្ឆេ បទំ សន្តំ　　　សង្ខារូបសមំ សុខំ ។

## រឿងសម្ពហុលភិក្ខុ

សិញ្ច ភិក្ខុ ឥមំ នាវំ          សិត្តា តេ លហុមេស្សតិ
ឆេត្វា រាគញ្ច ទោសញ្ច     តតោ និព្វានមេហិសិ ។
បញ្ច ឆិន្ទេ បញ្ច ជហេ     បញ្ច ចុត្តរិ ភាវយេ
បញ្ចសង្គាតិគោ ភិក្ខុ          ឱឃតិណ្ណោតិ វុច្ចតិ ។
ឈាយ ភិក្ខុ មា ច បមាទោ
មា តេ កាមគុណេ ភមស្សុ ចិត្តំ
មា លោហគុឡំ គិលី បមត្តោ
មា កន្ទិ ទុក្ខមិទន្តិ ឌយ្ហមានោ ។
នត្ថិ ឈានំ អបញ្ញស្ស          នត្ថិ បញ្ញា អឈាយិនោ
យម្ហិ ឈានញ្ច បញ្ញា ច       ស វេ និព្វានសន្តិកេ ។
សុញ្ញាគារំ បវិដ្ឋស្ស          សន្តចិត្តស្ស ភិក្ខុនោ
អមានុសី រតិ ហោតិ          សម្មា ធម្មំ វិបស្សតោ ។
យតោ យតោ សម្មសតិ     ខន្ធានំ ឧទយព្វយំ
លភតិ បីតិបាមោជ្ជំ          អមតន្តំ វិជានតំ ។
តត្រាយមាទិ ភវតិ          ឥធ បញ្ញស្ស ភិក្ខុនោ
ឥន្ទ្រិយគុត្តិ សន្តុដ្ឋិ          បាដិមោក្ខេ ច សំវរោ
មិត្តេ ភជស្សុ កល្យាណេ     សុទ្ធាជីវេ អតន្ទិតេ ។
បដិសន្ថារវុត្យស្ស          អាចារកុសលោ សិយា
តតោ បាមោជ្ជបហុលោ     ទុក្ខស្សន្តំ ករិស្សសិ ។

*ភិក្ខុណានៅដោយអំណាចមេត្តា ជ្រះថ្លា ក្នុងព្រះពុទ្ធសាសនា*

ភិក្ខុនោះ រមែងបានបទដ៏ស្ងប់ (គឺព្រះនិព្វាន) ជាទីរម្ងាប់នូវសង្ខារ នាំមកនូវសេចក្តីសុខ ។

ម្នាលភិក្ខុ អ្នកចូរស្តារទូក គឺអត្តភាពនេះ ទូក ដែលអ្នកស្តារហើយ នឹងដល់ត្រើយយ៉ាងឆាប់ អ្នកកាត់រាគៈ និងទោសៈបានហើយ អំពីនោះ នឹងអាចដល់នូវព្រះនិព្វាន ។

ភិក្ខុ គប្បីកាត់ឱរម្ភាគិយសំយោជនៈ ៥ ផង គប្បីលះបង់ឧទ្ធម្ភាគិយសំយោជនៈ ៥ ផង គប្បីចំរើនឥន្ទ្រីយ៍ ៥ តទៅទៀត ភិក្ខុអ្នកកន្លងកិលេសជាគ្រឿងជំពាក់ ៥ (រាគៈ ទោសៈ មោហៈ មានះ និងទិដ្ឋិ) បានហើយ ទើបតថាគតហៅថា អ្នកឆ្លងអន្លង់បាន ។

ម្នាលភិក្ខុ ចូរអ្នកពិនិត្យផង ចូរកុំជាអ្នកប្រមាទផង ចិត្ត របស់អ្នក ចូរកុំវិលទៅរកកាមគុណឡើយ អ្នកចូរកុំប្រមាទ ទំពាស៊ីនូវដុំលោហៈ កុំឲ្យជាអ្នកកាលភ្លើងឆេះហើយ កន្ទក់កន្ទេញថា នេះជាទុក្ខដូច្នេះឡើយ ។

ការពិនិត្យ មិនមាន ដល់បុគ្គលអ្នកមិនមានប្រាជ្ញា ប្រាជ្ញា មិនមាន ដល់បុគ្គលអ្នកមិនពិនិត្យ ការពិនិត្យ និង ប្រាជ្ញា មានក្នុងបុគ្គលណា បុគ្គលនោះឯង ឈ្មោះថា ឋិតនៅ ក្នុងទីជិតនៃព្រះនិព្វាន ។

សេចក្តីត្រេកអរ ដែលមិនមែនជារបស់មនុស្ស រមែងមានដល់ភិក្ខុអ្នកចូលទៅកាន់ផ្ទះស្ងាត់ អ្នកមានចិត្តរម្ងាប់ ឃើញនូវធម៌ដោយប្រពៃ ។ ភិក្ខុ ពិចារណាការកើតឡើង និង ការវិនាស នៃខន្ធទាំងឡាយ ក្នុងកាលណា ក្នុងកាលនោះ ភិក្ខុនោះ រមែងបានបីតិ និង

បាមោជ្ជៈ, បីតិ និង បាមោជ្ជៈនោះ ឈ្មោះថា ជាអមតធម៌ របស់បណ្ឌិតអ្នកដឹងធម៌ទាំងឡាយ ។

គុណធម៌ ៣ យ៉ាងនេះ គឺ ការរក្សាឥន្ទ្រិយ៍ ១ សេចក្ដីសន្ដោស ១ ការសង្រួម ក្នុងបាតិមោក្ខ ១ ជាខាងដើម នៃព្រះនិព្វាននោះ តែងមានដល់ភិក្ខុអ្នកមានបញ្ញា ក្នុងសាសនានេះ (ម្នាលភិក្ខុ) អ្នកចូរសេពគប់នូវកល្យាណមិត្រ អ្នកមានព្យាយាមជាគ្រឿងរស់ ដោយបរិសុទ្ធ ជាអ្នកមិនខ្ជិលច្រអូស ។

ភិក្ខុ គប្បីជាអ្នកប្រព្រឹត្តធ្វើបដិសន្ថារៈ គប្បីជាអ្នកឈ្លៀវឆ្លាត ក្នុងអាចារៈ ព្រោះហេតុទាំងពីរនោះ អ្នកនឹងមានបាមោជ្ជៈច្រើន នឹងធ្វើនូវទីបំផុតនៃទុក្ខបាន ។

♣ ♣ ♣

## ២៥៩- រឿង ភិក្ខុ ៥០០ រូប

ព្រះបរមសាស្ដា ទ្រង់ប្រារព្ធនូវភិក្ខុ ៥០០ រូប ដែលរៀននូវកម្មដ្ឋាន ក្នុងសំណាក់ព្រះអង្គហើយ ទៅបំពេញសមណធម៌ ក្នុងព្រៃស្ងាត់មួយ ។ សម័យថ្ងៃមួយ ភិក្ខុទាំងនោះ បានឃើញផ្កាម្លិះដែលរីកស្គុសស្គាយ ក្នុងពេលព្រឹក លុះដល់ពេលល្ងាច ផ្កាម្លិះទាំងនោះ ក៏បានជ្រុះធ្លាក់ ចេញអំពីទង ទើបពិចារណា យកមកធ្វើអារម្មណ៍ ថា "ផ្កាម្លិះនេះ បានជ្រុះធ្លាក់ ចេញពីទង យ៉ាងណាមិញ, អាត្មាអញ គួរធ្វើកិលេសឲ្យធ្លាក់ជ្រុះចេញ ពីសន្ដានចិត្តឲ្យបាន ក៏យ៉ាងនោះដែរ" ។

ព្រះសាស្ដា ទ្រង់ជ្រាបហើយ ទ្រង់បញ្ចេញព្រះរស្មីទៅ ដូចជា

ទ្រង់គង់នៅ ក្នុងទីចំពោះមុខ នៃភិក្ខុទាំងនោះ ហើយត្រាស់ព្រះគាថានេះ ថា ៖

**វស្សិកា វិយ បុប្ផានិ មទ្ទវានិ បមុញ្ចតិ**
**ឯវំ រាគញ្ច ទោសញ្ច វិប្បមុញ្ចេថ ភិក្ខវោ ។**

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីជំរុះរាគៈនិងទោសៈចេញ ដូចជាម្លិះ ជំរុះផ្កាម្លិះទាំងឡាយ ដែលស្វិតស្រពោនហើយ យ៉ាងដូច្នោះ ។

## ២៦០- រឿង ព្រះសន្តកាយត្ថេរ

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវព្រះសន្តកាយត្ថេរ ។ ព្រះថេរៈជាអ្នកមានកាយស្ងប់ មានមារយាទដ៏ត្រឹមត្រូវល្អ ព្រោះនិស្ស័យធ្លាប់បានកើតជារាជសីហ៍ ។ ធម្មតារាជសីហ៍ មុននឹងដេក តែងតែកំណត់អាការនៃកាយ លុះក្រោកឡើង ដឹងអាការនោះខុសធម្មតា ក្នុងពេលដេកលក់ ទើបបានជាស់តឿនខ្លួនឯង ថា "នេះមិនសមគួរទេ" បើឃើញនូវអាការនៃកាយនៅជាប្រក្រតី ទើបក្រោកឡើង ស្រែកបន្លឺសីហនាទ ៣ ដង ហើយទៅស្វែងរកចំណី តាមសេចក្តីត្រូវការ ។

ភិក្ខុទាំងឡាយ បានឃើញនូវកាយសមាចារ របស់ព្រះថេរៈហើយ ទើបទៅក្រាបទូលដល់ព្រះសាស្តា ។

ព្រះសាស្តាទ្រង់ត្រាស់ទូន្មានដល់ពួកភិក្ខុទាំងនោះ ឲ្យយកធ្វើជាគំរូតាមព្រះសន្តកាយត្ថេរ ហើយត្រាស់នូវព្រះគាថានេះ ថា ៖

រឿង ព្រះនង្គលកូដត្ថេរ

**សន្តកាយោ សន្តវាចោ  សន្តមនោ សុសមាហិតោ**
**វន្តលោកាមិសោ ភិក្ខុ  ឧបសន្តោតិ វុច្ចតិ ។**

*ភិក្ខុ មានកាយរម្ងាប់ហើយ មានវាចារម្ងាប់ហើយ មានចិត្ត រម្ងាប់ហើយ មានចិត្តតម្កល់មាំហើយ មានអាមិស ក្នុងលោក ខ្ជាក់ចោលហើយ ទើបតថាគតហៅថា ជាអ្នកស្ងប់រម្ងាប់ ។*

❋ ❋

## ២៦១- រឿង ព្រះនង្គលកូដត្ថេរ

*ព្រះបរមសាស្ដា ទ្រង់ប្រារព្ធនូវព្រះនង្គលកូដត្ថេរ ។ ព្រះថេរៈ រូបនេះ កាលពីនៅជាគ្រហស្ថ ជាអ្នកក្រីក្រលំបាកខ្លាំងណាស់ ស្លៀកពាក់ខោអាវដាច់ដាច ដើរស៊ីឈ្នួលគេមកចិញ្ចឹមជីវិត, ថ្ងៃមួយ បានឃើញទោស ក្នុងឃរាវាស ក៏បានចូលទៅបួស ក្នុងព្រះពុទ្ធសាសនា តែបានទុកដាក់នង្គ័ល និង សំពត់អាវ ដែលចាស់ដាច់ដាចនោះ យ៉ាងល្អ ក្នុងទីកន្លែងមួយ, កាលបើសេចក្ដីអន្ទះអន្ទែងចង់សឹក កើតឡើងហើយ ក៏ទៅមើលនង្គ័ល និង សំពត់ខោអាវ ដែលខ្លួនបានទុក ក្នុងទីនោះ ហើយបានទូន្មានខ្លួន រហូតដល់បាត់សេចក្ដីអន្ទះអន្ទែងចង់សឹក ស្រេចហើយ ទើបត្រឡប់មកវិញ ។*

*ភិក្ខុទាំងឡាយ បានឃើញយ៉ាងនេះហើយ ក៏នាំគ្នាទៅសួរព្រះថេរៈ ថា "ហេតុអ្វីបានជាលោកឯង និមន្តទៅកន្លែងនោះ ញឹកញាប់ម្ល៉េះ?" ។ ព្រះថេរៈ បានឆ្លើយថា "ខ្ញុំទៅរកលោកអាចារ្យរបស់ខ្ញុំ" ។*

*ក្រោយមក ព្រះនង្គលកូដត្ថេរ បានសម្រេចនូវអរហត្តផល*

*ហើយមិនបាននិមន្តទៅកន្លែងនោះទៀតទេ ។ ភិក្ខុទាំងឡាយបានសួរព្រះថេរៈ ទៀតថា "ហេតុអ្វីបានជាលោកឯង មិននិមន្តទៅរកលោកអាចារ្យ ដូចជាកាលពីមុនទៀត?" ។ ព្រះថេរៈ បានឆ្លើយថា "ឥឡូវនេះ ខ្ញុំ ឈប់ជាប់ជំពាក់ ជាមួយនឹងលោកអាចារ្យនោះ ទៀតហើយ សេចក្តីជាប់ជំពាក់នោះ ខ្ញុំក៏បានកាត់ផ្តាច់ចោលអស់ហើយ" ។*

*ភិក្ខុទាំងឡាយ បានចោទព្រះថេរៈ ថា "ព្រះថេរៈ ពោលអួតនូវព្រះអរហត្តផល" ហើយបានចូលទៅក្រាបទូលដល់ព្រះសាស្តា ។ ព្រះសាស្តា ទ្រង់ត្រាស់ជានា ថា "ព្រះនង្គលកូដត្ថេរ បានពោលត្រឹមត្រូវហើយ" ស្រេចហើយ ទ្រង់ត្រាស់ព្រះគាថានេះ ថា ៖*

អត្តនា ចោទយត្តានំ បដិមំសេតមត្តនា
សោ អត្តគុត្តោ សតិមា សុខំ ភិក្ខុ វិហាហិសិ ។
អត្តា ហិ អត្តនោ នាថោ អត្តា ហិ អត្តនោ គតិ
តស្មា សំយម អត្តានំ អស្សំ ភទ្រំវ វាណិជោ ។

*អ្នកចូរដាស់តឿនខ្លួន ដោយខ្លួនឯង ចូរពិនិត្យខ្លួន ដោយខ្លួនឯង ម្នាលភិក្ខុ អ្នកនោះ បើមានស្មារតី រក្សាខ្លួនទុកហើយ នឹងនៅជាសុខ ។ មែនពិត ខ្លួនជាទីពឹងរបស់ខ្លួន ខ្លួនឯង ជាគតិរបស់ខ្លួន ព្រោះហេតុនោះ អ្នកចូររាំងខ្លួន ដូចជាពាណិជ រាំងសេះដ៏ល្អ យ៉ាងដូច្នោះឯង ។*

♣ ♣ ♣

## ២៦២- រឿង ព្រះវក្កលិត្ថេរ

ព្រះបរមសាស្ដា ទ្រង់ប្រារព្ធ នូវព្រះវក្កលិត្ថេរ ។ ពេលដែលព្រះថេរៈ នៅជាគ្រហស្ថ លោកបានឃើញនូវរូបសម្បត្តិ របស់ព្រះសាស្ដា ដែលស្អាត គួរជាទីស្រឡាញ់ខ្លាំងណាស់ ទើបបានចូលទៅបួស ដោយនឹកគិត ថា "អញនឹងបានឃើញរូបសម្បត្តិដ៏ល្អរបស់ព្រះពុទ្ធ ជារៀងរាល់ថ្ងៃ" ។ លុះបួសរួចហើយ ព្រះវក្កលិ មិនបានរៀនធម៌អាថ៌អ្វីសោះ ចាំមើលតែរូបសម្បត្តិ របស់ព្រះពុទ្ធ តែម៉្យាងប៉ុណ្ណោះ ។

ព្រះសាស្ដា ទ្រង់ជ្រាបហើយ ត្រាស់ទូន្មានថា "ម្នាលវក្កលិ អ្នកបានចូលមកបួស ចាំមើលតែរូបកាយដែលស្អុយរលួយ គួរខ្ពើមនេះ តើបានប្រយោជន៍អ្វី អ្នកណាឃើញធម៌ អ្នកនោះ ទើបឈ្មោះថាឃើញតថាគត អ្នកណា ឃើញនូវតថាគត អ្នកនោះ ទើបឈ្មោះថាឃើញនូវធម៌" ។

ព្រះវក្កលិ មិនព្រមស្ដាប់ព្រះពុទ្ធដីកា របស់ព្រះសម្មាសម្ពុទ្ធឡើយ ចាំមើលតែព្រះវរកាយ របស់ព្រះអង្គ រៀងរាល់ថ្ងៃ ។ ព្រះសាស្ដា ទ្រង់ត្រាស់បណ្ដេញព្រះវក្កលិចេញ ។ ព្រះវក្កលិ ខូចចិត្តយ៉ាងខ្លាំង គិតថា "ព្រះពុទ្ធ មិនស្រឡាញ់ខ្លួន" ទើបឡើងទៅ លើកំពូលភ្នំគិជ្ឈកូដ ដើម្បីលោតទម្លាក់ខ្លួនឲ្យស្លាប់ ។

ព្រះសាស្ដា ទ្រង់ជ្រាបហើយ ទើបទ្រង់បានបញ្ចេញ នូវព្រះរស្មីទៅ ទ្រង់សម្ដែងព្រះវរកាយ ឲ្យព្រះវក្កលិឃើញហើយ ត្រាស់ហៅព្រះវក្កលិ ដើម្បីឲ្យព្រះវក្កលិ កើតបីតិបាមោជ្ជៈហើយ ត្រាស់នូវព្រះគាថានេះ ថា ៖

## គាថាធម្មបទប្រែ

**បាមោជ្ជពហុលោ ភិក្ខុ បសន្នោ ពុទ្ធសាសនេ**
**អធិគច្ឆេ បទំ សន្តំ សង្ខារូបសមំ សុខំ ។**

*ភិក្ខុ អ្នកក្រាស់ដោយសេចក្ដីរីករាយ ជ្រះថ្លា ក្នុងព្រះពុទ្ធ-សាសនា រមែងបាននូវបទដ៏ស្ងប់ ជាទីរម្ងាប់នូវសង្ខារ នាំមកនូវសេចក្ដីសុខ ។*

✻ ✻

## ២៦៣-រឿងសុមនសាមណេរ

*ព្រះបរមសាស្ដា ទ្រង់ប្រារព្ធនូវសុមនសាមណេរ ដែលមានអាយុ ៧ ឆ្នាំ ជាសិស្សរបស់ព្រះអនុរុទ្ធត្ថេរ, សុមនសាមណេរ បានសម្រេចអរហត្តផល នៅក្នុងពេលកំពុងកោរសក់ ដើម្បីនឹងបព្វជ្ជា ។ កាលបើសុមនសាមណេរ បួសហើយ, ព្រះអនុរុទ្ធ បាននាំទៅគាល់ព្រះសាស្ដា នៅវត្តបុព្វារាម ពេលទៅដល់វត្តហើយ ព្រះថេរៈ មិនបានចូលទៅគាល់ព្រះសាស្ដាភ្លាមនោះទេ ។*

*ភិក្ខុទាំងឡាយ បានឃើញសាមណេរហើយ ក៏ចាប់ក្បាលលេងខ្លះ ចាប់ច្រមុះលេងខ្លះ ចាប់ដៃលេងខ្លះ ហើយនិយាយលេងជាមួយ ដោយប្រការផ្សេងៗ ។*

*ព្រះសាស្ដា ទ្រង់ទតព្រះនេត្រឃើញ នូវកិរិយារបស់ភិក្ខុទាំងនោះហើយ ទ្រង់មានព្រះទ័យសម្ដែងគុណ របស់សុមនសាមណេរឲ្យប្រាកដ ទើបត្រាស់ហៅព្រះអានន្ទ មកហើយត្រាស់ឲ្យព្រះអានន្ទប្រើសាមណេរ ដែលអាចទៅដងទឹកអំពីអនោតត្តស្រះមក ដើម្បីព្រះ*

## រឿងសុមនសាមណេរ

អង្គុលាងព្រះបាទ ។

ព្រះអានន្ទ បានហៅសាមណេរទាំងឡាយ មកប្រជុំគ្នាហើយសួរ ទៅតាមលំដាប់, តែមិនមានសាមណេរណាមួយ ដែលហ៊ានទៅដងទឹក អំពីអនោតត្តស្រះបានទេ, កាលបើព្រះអានន្ទត្រូវ សួរទៅដល់សុមនសាមណេរហើយ, សុមនសាមណេរ ក៏បានទទួល ដើម្បីទៅដងទឹក មកថ្វាយព្រះសាស្ដា ហើយយកក្អមដាក់លើស្មា ហោះសំដៅទៅ កាន់ហិមវន្តប្រទេស ដងទឹក ក្នុងអនោតត្តស្រះ មកថ្វាយព្រះសាស្ដា ក្នុងគ្រានោះឯង ។

ព្រះសាស្ដាចារ្យ ទ្រង់ត្រាស់សរសើរ នូវសុមនសាមណេរដោយប្រការផ្សេងៗ ហើយទ្រង់បានប្រទានឧបសម្បទា ថា “អ្នកចូរមកជាភិក្ខុ ចាប់តាំងតែពីថ្ងៃនេះតទៅ” ។

ភិក្ខុទាំងឡាយ បានសរសើរនូវគុណសម្បត្តិ របស់សុមនសាមណេរ ។

ព្រះសាស្ដាចារ្យបរមគ្រូ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

**យោ ហវេ ទហរោ ភិក្ខុ យុញ្ជតិ ពុទ្ធសាសនេ**
**សោមំ លោកំ បភាសេតិ អព្ភា មុត្តោវ ចន្ទិមា ។**

ភិក្ខុណា នៅកំលោះ ប្រឹងប្រែង ក្នុងព្រះពុទ្ធសាសនា ភិក្ខុនោះ រមែងញុំាងលោកនេះ ឲ្យភ្លឺស្វាងបាន ដូចព្រះចន្ទដែលរះផុតអំពីពពក យ៉ាងដូច្នោះ ។

**ចប់ ភិក្ខុវគ្គ ទី ២៥**

# គាថាធម្មបទប្រែ

## ព្រាហ្មណវគ្គ ទី ២៦

### ២៦៤- រឿងបសាទពហុលព្រាហ្មណ៍

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវព្រាហ្មណ៍ម្នាក់ ជាអ្នកមានសទ្ធាជ្រះថ្លា ក្នុងព្រះពុទ្ធសាសនាយ៉ាងខ្លាំង បានថ្វាយនូវភត្តាហារដល់ព្រះសង្ឃ ១៦ រូប នៅផ្ទះរបស់ខ្លួន ជារៀងរាល់ថ្ងៃ ជាប់ជានិច្ច ពេលថ្វាយភត្តាហារ ដល់ព្រះសង្ឃ គាត់បានហៅភិក្ខុទាំងឡាយ ថា "ព្រះអរហន្ត" ។*

*ភិក្ខុទាំងនោះ មានសេចក្តីសង្ស័យហើយ ឈប់និមន្តទៅផ្ទះរបស់ព្រាហ្មណ៍នោះ តទៅទៀត ។ ព្រាហ្មណ៍ កើតទុក្ខទោមនស្សយ៉ាងខ្លាំង ហើយបានចូលទៅក្រាបទូលដល់ព្រះសាស្តា ។*

*ព្រះសាស្តាចារ្យ ទ្រង់បានត្រាស់ហៅភិក្ខុទាំងនោះមក ហើយត្រាស់សួរ ទ្រង់ជ្រាបថា "ភិក្ខុទាំងនោះ មិនចូលចិត្តនូវពាក្យ របស់ព្រាហ្មណ៍នោះ" ទើបត្រាស់សួរ បន្តទៀតថា "តើអ្នកទាំងឡាយ បានត្រេកអរជាមួយនឹងពាក្យនោះ ដែរឬទេ?" ។*

*ភិក្ខុទាំងនោះ ក្រាបទូលថា "បពិត្រព្រះអង្គ ដ៏ចំរើន ពួកខ្ញុំព្រះករុណា មិនបានត្រេកអរនឹងពាក្យ របស់ព្រាហ្មណ៍នោះទេ" ។*

*ព្រះសាស្តា ទ្រង់ត្រាស់ថា "បើដូច្នោះមែន ក៏មិនជាការត្រូវអាបត្តិអ្វីដែរ ព្រោះព្រាហ្មណ៍ហៅ ដោយចិត្តដែលជ្រះថ្លា, អ្នកទាំងឡាយ គប្បីកាត់ផ្តាច់នូវតណ្ហា ដើម្បីបានសម្រេច នូវអរហត្តផល ដូចដែលព្រាហ្មណ៍នោះហៅ ទើបប្រសើរ" ដូច្នេះហើយ ទ្រង់ត្រាស់*

*នូវព្រះគាថានេះ ថា ៖*

ឆិន្ទ សោតំ បរក្កម្ម   កាមេ បនូទ ព្រាហ្មណ
សង្ខារានំ ខយំ ញត្វា  អកតញ្ញូសិ ព្រាហ្មណ ។

*ម្នាលព្រាហ្មណ៍ អ្នកចូរខំប្រឹងកាត់ផ្តាច់ នូវតណ្ហាដូចខ្សែទឹកចោលចេញ ចូរបន្ទោបង់នូវកាមទាំងឡាយចោលចេញ, ម្នាលព្រាហ្មណ៍ អ្នកដឹងច្បាស់នូវការអស់ទៅ នៃសង្ខារទាំងឡាយហើយឈ្មោះថា ជាអ្នកដឹងព្រះនិព្វាន ដែលបច្ច័យតាក់តែងមិនបាន ។*

♣ ♣ ♣

## ២៦៥- រឿងសម្ពហុលភិក្ខុ

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវភិក្ខុជាច្រើនរូប ដែលមានគ្នា ៣០ នាក់ ជាអ្នកចូលចិត្តនៅក្នុងទិសនោះៗ ។ ថ្ងៃមួយ ភិក្ខុទាំងនោះបាននាំគ្នា ទៅគាល់ព្រះសាស្តា ក្នុងវត្តជេតពនមហាវិហារ ។*

*ព្រះសារីបុត្រ ឃើញឧបនិស្ស័យនៃព្រះអរហន្តរបស់ភិក្ខុទាំងនោះ ក៏ចូលទៅគាល់ព្រះសាស្តាហើយ ក្រាបទូលសួរព្រះអង្គ ថា "បពិត្រព្រះអង្គដ៏ចំរើន ដែលហៅថា ធម៌ ២ យ៉ាងនោះ តើអ្វីខ្លះ?" ។*

*ព្រះសាស្តា ទ្រង់ត្រាស់ឆ្លើយ ថា "ម្នាលសារីបុត្រ ធម៌ ២ យ៉ាងនោះ គឺ សមថៈ ១ វិបស្សនា ១" ហើយ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

យទា ទ្វយេសុ ធម្មេសុ   បារគូ ហោតិ ព្រាហ្មណោ
អថស្ស សព្វេ សំយោគា   អត្ថំ គច្ឆន្តិ ជានតោ ។

-៤០៣-

គាថាធម្មបទប្រែ

*កាលណា ព្រាហ្មណ៍ជាអ្នកដល់ត្រើយ ក្នុងធម៌ពីរប្រការ គឺសមថធម៌ និង វិបស្សនាធម៌ ក្នុងកាលនោះ កិលេសជាគ្រឿងប្រកបសត្វទុកទាំងអស់ របស់ព្រាហ្មណ៍អ្នកដឹងនោះ រមែងតាំងនៅពុំបាន។*

✽ ✽

២៦៦- រឿង មារ

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវមារាធិរាជ ដែលមកក្រឡាខ្លួនធ្វើជាបុរសម្នាក់ ចូលមកគាល់ហើយ ក្រាបទូលសួរ ថា "បពិត្រព្រះអង្គ ដ៏ចំរើន ដែលហៅថា បារៈ ត្រើយនោះ គឺជាអ្វីដែរ?" ។*

*ព្រះសាស្តា ទ្រង់បានជ្រាបថា "បុរសនេះ គឺពិតជាមារាធិរាជ" ហើយ ទ្រង់ត្រាស់ថា "នែមារាធិរាជ តើអ្នកចង់បានត្រើយនោះទៅធ្វើអ្វី? បារៈ គឺត្រើយនោះ មានតែបុគ្គលដែលប្រាសចាករាគៈ ទោសៈ និង មោហៈ ទេ ដែលគប្បីបាន នេះមិនមែនជាវិស័យ របស់អ្នកឡើយ" ដូច្នេះហើយ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

**យស្ស បារំ អបារំ វា បារាបារំ ន វិជ្ជតិ**
**វីតទ្ទរំ វិសំយុត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។**

*ត្រើយក្តី ទីមិនមែនត្រើយក្តី ត្រើយនិងទីមិនមែនត្រើយក្តី មិនមានដល់បុគ្គលណា សេចក្តីប្រកាន់អាយតនៈ មិនមានដល់បុគ្គលណា តថាគត ហៅ នូវបុគ្គលនោះ ដែលជាអ្នកមានសេចក្តីក្រវល់ក្រវាយអស់ហើយ ជាអ្នកប្រាសចាកកិលេស ថា ជាព្រាហ្មណ៍ ។*

## ២៦៧- រឿង អញ្ញាត្រព្រាហ្មណ៍

ព្រះបរមសាស្ដា ទ្រង់ប្រារព្ធនូវព្រាហ្មណ៍ម្នាក់ ដែលបានគិតថា "ព្រះសាស្ដា ទ្រង់ត្រាស់ហៅសាវ័ក របស់ព្រះអង្គថា ព្រាហ្មណ៍ អាត្មាអញ ក៏ជាព្រាហ្មណ៍ ដោយជាតិ និង គោត្រដែរ បើព្រះអង្គត្រាស់ហៅអាត្មាអញ ថា ជាព្រាហ្មណ៍ ទើបជាការសមគួរដែរ" លុះគិតយ៉ាងនេះហើយ ទើបចូលទៅគាល់ព្រះសាស្ដា ហើយក្រាបទូលរឿងដែលខ្លួនបានគិតនោះ ដល់ព្រះសាស្ដា ។

ព្រះសាស្ដា ទ្រង់ត្រាស់ថា "ម្នាលព្រាហ្មណ៍ តថាគត មិនហៅនូវបុគ្គលថា ជាព្រាហ្មណ៍ ព្រោះជាតិ និង គោត្រទេ តែតថាគតហៅបុគ្គល ថា ជាព្រាហ្មណ៍ ព្រោះបុគ្គលនោះ បានសម្រេច នូវប្រយោជន៍ ដែលខ្ពស់ឡើងៗ ដោយលំដាប់" ស្រេចហើយ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

**ឈាយឹ វិរជមាសីនំ   កតកិច្ចំ អនាសវំ**
**ឧត្តមត្ថំ អនុប្បត្តំ   តមហំ ព្រូមិ ព្រាហ្មណំ ។**

តថាគត ហៅនូវបុគ្គលអ្នកចំរើនឈាន មានធូលីគឺកាមទៅប្រាសហើយ អ្នកអង្គុយនៅឯកឯង អ្នកមានសោឡសកិច្ចធ្វើស្រេចហើយ មិនមានអាសវៈ ដល់នូវប្រយោជន៍ដ៏ខ្ពង់ខ្ពស់ ដោយលំដាប់ហើយនោះថា ជាព្រាហ្មណ៍ ។

* * *

## ២៦៨- រឿង ព្រះអានន្ទ

ព្រះបរមសាស្ដា ទ្រង់ប្រារព្ធនូវព្រះអានន្ទ ។ ក្នុងថ្ងៃបវារណា

## គាថាធម្មបទប្រែ

ព្រះអានន្ទ បានឃើញនូវរស្មីព្រះអាទិត្យ រស្មីព្រះចន្ទ រស្មីនៃគ្រឿងប្រដាប់សំរាប់រាជ្យ នៃព្រះបាទបសេនទិកោសល ស្តេចយាងទៅកាន់ព្រះវិហារ រស្មីភ្លឺស្វាង របស់ព្រះកាឡុទាយី ដែលកំពុងតែចូលឈានសមាបត្តិ និង ឃើញ នូវព្រះរស្មីដ៏រុងរឿង នៃព្រះសម្ពុទ្ធ ទើបទូលសរសើរ ថា "បពិត្រព្រះអង្គដ៏ចំរើន ព្រះរស្មីរបស់ព្រះអង្គ រុងរឿងជាងរស្មីទាំងអស់" ។

ព្រះសាស្តាចារ្យ បរមគ្រូ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

ទិវា តបតិ អាទិច្ចោ    រត្តិមាភាតិ ចន្ទិមា
សន្នទ្ធោ ខត្តិយោ តបតិ    ឈាយី តបតិ ព្រាហ្មណោ
អថ សព្វមហោរត្តឹ    ពុទ្ធោ តបតិ តេជសា ។

ព្រះអាទិត្យ រុងរឿង ក្នុងវេលាថ្ងៃ ព្រះចន្ទ រុងរឿង ក្នុងវេលាយប់ ក្សត្រទ្រង់ប្រដាប់ពេញយសហើយ រមែងរុងរឿង សមណ-ព្រាហ្មណ៍ អ្នកមានឈាន រមែងរុងរឿង ចំណែកព្រះសម្ពុទ្ធ រមែងរុងរឿង ដោយតេជ រហូតថ្ងៃ និង យប់ទាំងអស់ ។

♣ ♣ ♣

## ២៦៩- រឿង អញ្ញាត្របព្វជិត

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវបព្វជិត មួយរូប ដែលបួសក្រៅព្រះពុទ្ធសាសនា បានគិតថា "ព្រះសមណគោតម ត្រាស់ហៅនូវពួកសាវ័ក របស់ព្រះអង្គថា បព្វជិត អាត្មាអញ ជាបព្វជិតដូចគ្នាដែរ ការដែលព្រះអង្គហៅអញថា ជាបព្វជិត ក៏ជាការសមគួរដែរ"

ហើយចូលទៅក្រាបទូលការនឹកគិត របស់ខ្លួន ដល់ព្រះសាស្ដា ។

ព្រះសម្មាសម្ពុទ្ធ ទ្រង់ជ្រាបយ៉ាងនេះហើយ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

ពាហិតបាបោ ហិ ព្រាហ្មណោ
សមចរិយា សមណោតិ វុច្ចតិ
បព្វាជយមត្តនោ មលំ
តស្មា បព្វជិតោតិ វុច្ចតិ ។

បុគ្គល ដែលលះបាបបានហើយ ឈ្មោះថា ព្រាហ្មណ៍ បុគ្គលដែលតថាគតហៅថា សមណៈ ព្រោះប្រព្រឹត្តត្រឹមត្រូវល្អ បុគ្គលដែលកំចាត់នូវមន្ទិលរបស់ខ្លួនចេញ ព្រោះហេតុនោះ ទើបតថាគតហៅថា បព្វជិត ។

## ២៧០- រឿង ព្រះសារីបុត្រ

ព្រះបរមសាស្ដា ទ្រង់ប្រារព្ធព្រះសារីបុត្រ ។ វេលាថ្ងៃមួយ មានព្រាហ្មណ៍ ជាមិច្ឆាទិដ្ឋិម្នាក់ បានឮគេពោលសរសើរព្រះថេរៈ ថា ជាអ្នកមិនចេះក្រោធខឹង" ទើបចង់ទៅសាកល្បងមើល ។ ក្រោយមក គាត់បានឃើញព្រះសារីបុត្រ កំពុងតែនិមន្តបិណ្ឌបាត ប្រោសសត្វ ទើបយកដៃទៅគក់ខ្នងព្រះថេរៈ លុះដឹងថា ព្រះថេរៈមិនក្រោធខឹង ក៏កើតសេចក្ដីជ្រះថ្លា សុំខមាទោសព្រះថេរៈ ហើយបាននិមន្តព្រះថេរៈ ទៅទទួលភត្តាហារ នៅឯផ្ទះរបស់ខ្លួន ។

-៤០៧-

## គាថាធម្មបទប្រែ

*ក្នុងគ្រានោះ ពួកប្រជាជនខ្លះ បានដឹងថា "ព្រាហ្មណ៍បានវាយព្រះថេរៈ ដែលលោកមិនមានចិត្តក្រោធខឹងនឹងអ្នកណា" ក៏នាំគ្នាមកដើម្បីធ្វើបាបព្រាហ្មណ៍នោះ លុះបានឃើញថា "ព្រាហ្មណ៍នោះ មានចិត្តជ្រះថ្លា ចំពោះព្រះថេរៈ" ក៏នាំគ្នាវិលត្រឡប់ទៅវិញ ។ ពួកភិក្ខុទាំងឡាយ បានសន្ទនាគ្នាអំពីរឿងនោះ ។*

*ព្រះសាស្ដា យាងទៅក្នុងទីប្រជុំនោះ ត្រាស់ព្រះគាថានេះថា ៖*

ន ព្រាហ្មណស្ស បហរេយ្យ នាស្ស មុញ្ចេថ ព្រាហ្មណោ
ធិ ព្រាហ្មណស្ស ហន្តារំ តតោ ធិ យស្ស មុញ្ចតិ ។
ន ព្រាហ្មណស្សេតទកិញ្ចិ សេយ្យោ
យទានិសេធោ មនសោ បិយេហិ
យតោ យតោ ហឹសមនោ និវត្តតិ
តតោ តតោ សម្មតិមេវ ទុក្ខំ ។

*ព្រាហ្មណ៍ មិនគួរប្រហារព្រាហ្មណ៍ទេ (ចំណែក) ព្រាហ្មណ៍ (ដែលត្រូវគេវាយប្រហារហើយ) មិនត្រូវចងពៀរ ចំពោះព្រាហ្មណ៍នោះឡើយ តថាគត តិះដៀលព្រាហ្មណ៍ដែលវាយប្រហារព្រាហ្មណ៍, ព្រាហ្មណ៍ណា ចងពៀរ ចំពោះព្រាហ្មណ៍នោះ តថាគត តិះដៀលព្រាហ្មណ៍នោះ ក្រៃលែងជាងនោះទៅទៀត ។*

*ការហាមឃាត់ចិត្ត ចាកអារម្មណ៍ ជាទីស្រឡាញ់ទាំងឡាយណា ការហាមឃាត់ចិត្ត ចាកអារម្មណ៍ ដែលជាទីស្រឡាញ់ទាំងឡាយ របស់ព្រាហ្មណ៍នោះ ជាការហាមឃាត់ដ៏ប្រសើរ មិនមែន*

*បន្តិចបន្តួចឡើយ, ចិត្ត ដែលគិតបៀតបៀនគេ រមែងងាកចេញ ចាក វត្ថុណាៗ សេចក្តីទុក្ខ រមែងរម្ងាប់ទៅបាន ព្រោះវត្ថុនោះៗ ។*

❃ ❃ ❃

## ២៧១- រឿង ព្រះនាងបជាបតិគោតមី

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធ នូវព្រះនាងបជាបតិគោតមី ដែលបានឧបសម្បទ ដោយការទទួលគរុធម៌ ៨ ប្រការ ។ ក្រោយ មក ស្រាប់តែមានការនិយាយគ្នា ថា "ព្រះនាងមហាបជាបតិគោតមី បួសមិនមានព្រះឧបជ្ឈាយ៍ អាចារ្យ គ្រងសំពត់កាសាវពស្ត្រ ដោយ ខ្លួនឯង" ។*

*គ្រានោះឯង ភិក្ខុនីទាំងឡាយ មានការវង្វៀសសង្ស័យ មិន បានធ្វើឧបោសថកម្ម និង បវារណាកម្ម ជាមួយនាងឡើយ ហើយ ចូលទៅក្រាបទូលរឿងនោះ ដល់ព្រះសាស្តា ។*

*ពេលនោះ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា "តថាគតជាអ្នកឲ្យ នូវគរុធម៌ ៨ ប្រការ ដល់ព្រះនាងបជាបតិគោតមី ជាព្រះឧបជ្ឈាយ៍ ជាគ្រូអាចារ្យ របស់ព្រះនាង អ្នកទាំងឡាយ ចូរកុំមានសេចក្តីវង្វៀស សង្ស័យ ចំពោះព្រះខីណាស្រពឡើយ" ហើយត្រាស់ នូវព្រះគាថា នេះ ថា ៖*

យស្ស កាយេន វាចាយ  មនសា នត្ថិ ទុក្កដំ
សំវុតំ តីហិ ឋានេហិ  តមហំ ព្រូមិ ព្រាហ្មណំ ។

*អំពើអាក្រក់ ដោយកាយទ្វារ វចីទ្វារ មនោទ្វារ របស់បុគ្គល*

ណា មិនមានទេ តថាគត ហៅបុគ្គលដែលបានសង្រួម ដោយឋាន ទាំងបីនោះ ថា ជាព្រាហ្មណ៍ ។

៚ ៚ ៚

## ២៧២- រឿង ព្រះសារីបុត្រ

ព្រះបរមសាស្ដាទ្រង់ប្រារព្ធនូវព្រះសារីបុត្រ ។ សម័យដែល ព្រះថេរៈ កំពុងតែស្វែងរកមោក្ខធម៌ លោកបានស្ដាប់អរិយសច្ចកថា យ៉ាងសង្ខេប អំពីព្រះអស្សជិ ហើយបានសម្រេចសោតាបត្តិផល, ក្រោយមក ព្រះថេរៈ បានជាព្រះអគ្គសាវ័ក, កាលបើព្រះថេរៈ ដឹងថា ព្រះអស្សជិ គង់នៅក្នុងទិសណា, ក៏ប្រណម្យអញ្ជលី ថ្វាយបង្គំឆ្ពោះ ទៅទិសនោះ ។ ភិក្ខុទាំងឡាយ ដែលយល់ខុស បានជៀមជាមដល់ ព្រះថេរៈ ថា "សំពះទិសដែលជាសាសនកិច្ច របស់អ្នកបួសក្រៅព្រះ ពុទ្ធសាសនា" ។

ព្រះសាស្ដាទ្រង់ត្រាស់ឲ្យនិមន្តព្រះសារីបុត្រមក ដើម្បីត្រាស់ សួរ ។ ព្រះថេរៈ បានក្រាបទូលថា "បពិត្រព្រះអង្គដ៏ចំរើន រឿងនេះ ព្រះអង្គ ទ្រង់បានជ្រាបច្បាស់ហើយ" ។

ព្រះសាស្ដា ទ្រង់ត្រាស់ពន្យល់នូវភិក្ខុទាំងនោះ ឲ្យបានយល់ ជាក់ច្បាស់ អស់សង្ស័យហើយ ទើបទ្រង់ត្រាស់ព្រះគាថានេះថា ៖

យម្ហា ធម្មំ វិជានេយ្យ   សម្មាសម្ពុទ្ធទេសិតំ
សក្កច្ចំ តំ នមស្សេយ្យ   អគ្គិហុត្តំវ ព្រាហ្មណោ ។

បុគ្គលចេះធម៌អាថ៌ ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់សម្ដែងហើយ

# រឿង ជដិលព្រាហ្មណ៍

*អំពីសំណាក់គ្រូណា គប្បីនមស្ការនូវគ្រូនោះ ដោយគោរព ដូចជាព្រាហ្មណ៍ ដែលគោរពការបូជាភ្លើង យ៉ាងដូច្នោះឯង ។*

❇ ❇ ❇

## ២៧៣- រឿង ជដិលព្រាហ្មណ៍

*ព្រះបរមសាស្តា ទ្រង់បានប្រារព្ធនូវជដិលព្រាហ្មណ៍ម្នាក់ ។ ព្រាហ្មណ៍នោះ បានគិតថា "អាត្មាអញ កើតក្នុងត្រកូលព្រាហ្មណ៍ ព្រះសមណគោតម ទ្រង់ត្រាស់ហៅពួកសាវ័ក របស់ព្រះអង្គ ថា ព្រាហ្មណ៍ ការដែលព្រះអង្គត្រាស់ហៅអញ ថា ព្រាហ្មណ៍ ក៏ជាការសមគួរដែរ" លុះគិត យ៉ាងដូច្នេះហើយ ទើបចូលទៅក្រាបទូលការនឹកគិតនោះ ដល់ព្រះសាស្តា ។*

*ព្រះសម្មាសម្ពុទ្ធ ទ្រង់ជ្រាបហើយត្រាស់នូវព្រះគាថានេះថា ៖*

**ន ជដាហិ ន គោត្តេហិ ន ជច្ចា ហោតិ ព្រាហ្មណោ**
**យម្ហិ សច្ចញ្ច ធម្មោ ច សោ សុចី សោ ច ព្រាហ្មណោ ។**

*បុគ្គល ដែលឈ្មោះថា ព្រាហ្មណ៍ ព្រោះផ្នួងសក់ ក៏មិនមែន ព្រោះគោត្រ ក៏មិនមែន ព្រោះជាតិ ក៏មិនមែន, សច្ចៈផង ធម៌ផង មាន ក្នុងបុគ្គលណា បុគ្គលនោះ ឈ្មោះថា អ្នកស្អាតផង បុគ្គលនោះ ឈ្មោះថា ព្រាហ្មណ៍ផង ។*

♣ ♣ ♣

## ២៧៤- រឿង ព្រាហ្មណ៍កុហក

*ព្រះបរមសាស្តា ទ្រង់បានប្រារព្ធ នូវព្រាហ្មណ៍កុហកម្នាក់ ។*

ព្រាហ្មណ៍នេះ បានប្រព្រឹត្តខ្លួន ដូចជាសត្វប្រចៀវ គឺ គាត់បានឡើងទៅលើដើមឈើ ហើយយកជើងទាំងពីរ ព័ន្ធនឹងមែកឈើ ហើយសំយុងក្បាលចុះមកក្រោម ស្រែកប្រាប់អ្នកស្រុកថា "អ្នកទាំងឡាយចូរយករបស់នេះ របស់នោះ មកឲ្យខ្ញុំ បើអ្នកពល់គ្នា មិនយកមកឲ្យខ្ញុំទេ ខ្ញុំនឹងលែងជើងទម្លាក់ខ្លួន ឲ្យធ្លាក់ស្លាប់ ឥឡូវនេះឯង ហើយធ្វើផ្ទះសម្តែង ស្រែចំការ របស់អ្នកពល់គ្នា ឲ្យវិនាស ខូចខាតទាំងអស់ក្នុងពេលឆាប់ៗ នេះ" ។

ពួកអ្នកស្រុក មានការភ័យខ្លាចយ៉ាងខ្លាំង ចំពោះរឿងនោះហើយ យកវត្ថុដែលព្រាហ្មណ៍នោះស្នើសុំ ទៅឲ្យតាមសេចក្តីត្រូវការរបស់គាត់ យ៉ាងប្រញាប់ ។ ភិក្ខុទាំងឡាយ បាននាំយករឿងនោះទៅក្រាបទូល ដល់ព្រះសាស្តា ។

ព្រះសម្ពុទ្ធ ទ្រង់សម្តែង ថា "ម្នាលភិក្ខុទាំងឡាយ ព្រាហ្មណ៍នេះ មិនមែនបេះកុហក តែក្នុងជាតិនេះប៉ុណ្ណោះទេ សូម្បីពីជាតិមុន ក៏បានជើរ កុហកអ្នកស្រុក ដូចគ្នាដែរ" ដូច្នេះហើយ ត្រាស់នូវអតីតនិទាននេះ ថា: កាលពីព្រាហ្មណ៍នេះ កើតជាតាបសកុហក បានធ្វើកិរិយាសង្រួម យ៉ាងត្រឹមត្រូវ ដើម្បីបញ្ឆោត ឲ្យសត្វទន្សងគោរពបូជា ព្រោះគាត់ប្រាថ្នាចង់ ចាប់សត្វទន្សងនោះមកធ្វើជាចំណី, តែសត្វទន្សងនោះ បានដឹងខ្លួនទាន់ ហើយរត់លូនចូលទៅ ក្នុងរូងដំបូកបានស្រដី តិះដៀលតាបស ដោយប្រការផ្សេងៗ ថា "លោកមិនមែនជាសមណ:ទេ ចាប់តាំងអំពីពេលដែលលោកចាប់ដំបង ដើម្បីនឹង

*វាយខ្ញុំសម្លាប់ លោកដុសសម្អាតតែខាងក្រៅប៉ុណ្ណោះ តែចិត្តគំនិតខាងក្នុងរបស់លោកអាក្រក់ណាស់...” នៅក្នុងទីបញ្ចប់ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

**កឹន្តេ ជដាហិ ទុម្មេធ កឹន្តេ អជិនសាដិយា**
**អព្ភន្តរន្តេ គហនំ ពាហិរំ បរិមជ្ជសិ ។**

*នែអ្នកអប្បប្រាជ្ញាអើយ អ្នកមានប្រយោជន៍អ្វី ដោយការទុកផ្នួងសក់ អ្នកមានប្រយោជន៍អ្វី ដោយការទ្រទ្រង់សំពត់ស្បែកខ្លា បើសន្ដានខាងក្នុងរបស់អ្នក ស្អឹងសាំញ៉ាំ ដោយរាគាទិក្កិលេស អ្នកឈ្មោះថា ដុសខាត់តែកាយខាងក្រៅទេ ។*

## ២៧៥- រឿង នាងកិសាគោតមី

*ព្រះបរមសាស្ដា ទ្រង់បានប្រារព្ធនូវនាងកិសាគោតមី ដែលលើសជាងព្រះថេរីទាំងឡាយ ផ្នែកខាងប្រព្រឹត្តកាន់យក នូវសំពត់បំសុកូលជាវត្ត ។ ថ្ងៃមួយ នាងបានហោះទៅគាល់ព្រះសាស្ដា នៅឯភ្នំគិជ្ឈកូដ បានឃើញសក្កទេវរាជ ព្រមទាំងពួកបរិវារ ចូលមកគាល់មុនហើយ ក៏បានក្រាបថ្វាយបង្គំព្រះសាស្ដា ស្រេចពេលណាហើយ ក៏ត្រឡប់ទៅវិញ ។*

*ព្រះឥន្ទ្រាធិរាជ ទតព្រះនេត្រឃើញហើយ បានក្រាបទូលសួរព្រះអង្គថា “បពិត្រព្រះអង្គដ៏ចំរើន អ្នកណាន៎ុះ មកហើយត្រឡប់ទៅវិញ?” ។*

## គាថាធម្មបទប្រែ

*ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ថា "នាងកិសាគោតមី" ហើយត្រាស់ នូវព្រះគាថានេះ ថា ៖*

**បំសុកូលធរំ ជន្តុំ  កិសំ ធមនិសន្ថតំ**
**ឯកំ វនស្មឹ ឈាយន្តំ  តមហំ ព្រូមិ ព្រាហ្មណំ ។**

*តថាគត ហៅបុគ្គលអ្នកទ្រទ្រង់សំពត់បំសុកូល មានកាយស្គាំងស្គម មានខ្លួនរវីមរវាម ដោយសរសៃ ជាបុគ្គលឯកឯង ចំរើនឈាន ក្នុងព្រៃនោះ ថា ជាព្រាហ្មណ៍ ។*

✻ ✻ ✻

## ២៧៦- រឿង អញ្ញាត្រព្រាហ្មណ៍

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធព្រាហ្មណ៍ម្នាក់ ដែលនឹកគិតថា "ព្រះសមណគោតម ទ្រង់ត្រាស់ហៅពួកសាវ័ក របស់ព្រះអង្គ ថា ព្រាហ្មណ៍ អាត្មាអញ កើតក្នុងកំណើតព្រាហ្មណ៍ ការដែលព្រះអង្គត្រាស់ហៅអាត្មាអញ ថា ព្រាហ្មណ៍ ជាការសមគួរដែរ" ហើយចូលទៅក្រាបទូលការនឹកគិត របស់ខ្លួន ដល់ព្រះសាស្តា ។*

*ព្រះសាស្តាចារ្យ បរមគ្រូ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

**ន ចាហំ ព្រាហ្មណំ ព្រូមិ  យោនិជំ មត្តិសម្ភវំ**
**ភោវាទី នាម សោ ហោតិ  ស វេ ហោតិ សកិញ្ចនោ**
**អកិញ្ចនំ អនាទានំ  តមហំ ព្រូមិ ព្រាហ្មណំ ។**

*តថាគត នឹងហៅអ្នកកើតអំពីកំណើត អ្នកកើតក្នុងផ្ទៃ នៃព្រាហ្មណ៍ ជាមាតា ថា ជាព្រាហ្មណ៍ ក៏ទេ បុគ្គលនោះ គ្រាន់តែបាន*

នាមថា ភោវាទី (អ្នកពោលថាចំរើន) ព្រោះបុគ្គលនោះឯង ជាអ្នកមានកិលេសគ្រឿងកង្វល់នៅឡើយ, តថាគត ហៅបុគ្គលអ្នកមិនមានកិលេសគ្រឿងកង្វល់ អ្នកមិនមានសេចក្ដីប្រកាន់មាំនោះឯង ថាជាព្រាហ្មណ៍ ។

♣ ♣ ♣

២៧៧- រឿង ឧគ្គសេន

ព្រះបរមសាស្ដា ទ្រង់ប្រារព្ធនូវសេដ្ឋីបុត្រ ឈ្មោះឧគ្គសេន ។ សេដ្ឋីបុត្រនេះ បានស្ដាប់នូវព្រះធម៌ទេសនា ក្នុងពេលដែលខ្លួនកំពុងតែឈរនៅ លើឈើ បានសម្រេចអរហត្តផល ព្រមទាំងបដិសម្ភិទាទាំងឡាយ ហើយចុះមក ក្រាបថ្វាយបង្គំព្រះសាស្ដា ទូលសុំបព្វជ្ជាឧបសម្បទ ។ ព្រះសុគត ទ្រង់បានប្រទានឯហិភិក្ខុឧបសម្បទា ដល់ឧគ្គសេន ក្នុងថ្ងៃនោះ ។

ក្នុងគ្រានោះ ភិក្ខុទាំងឡាយ បាននាំគ្នាសួរព្រះឧគ្គសេន ថា "ពេលដែលលោកម្ចាស់ បានចុះពីលើឈើល្បែង តើមានភ័យខ្លាចដែរឬទេ?" ។ ព្រះថេរៈ បានឆ្លើយតបថា "ខ្ញុំ លែងមានការភ័យខ្លាចហើយ" ។ ភិក្ខុទាំងនោះ បានចោទព្រះថេរៈ ថា "ពោលអួតនូវព្រះអរហត្តផល" ហើយនាំយករឿងនោះ ក្រាបទូលដល់ព្រះសាស្ដា ។

ព្រះបរមសាស្ដាចារ្យ ទ្រង់ត្រាស់ពន្យល់ ដល់ភិក្ខុទាំងនោះ ថា "ព្រះថេរៈ ពោលត្រឹមត្រូវហើយ" ហើយត្រាស់នូវព្រះគាថានេះ ថា៖

**សព្វសញ្ញោជនំ ឆេត្វា យោ វេ ន បរិតស្សតិ**

-៤១៥-

គាថាធម្មបទប្រែ

**សង្គាតិគំ វិសំយុត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។**

*បុគ្គលណា កាត់នូវសញ្ញោជនៈទាំងអស់បាន មិនរន្ធត់តក់ស្លុត តថាគត ហៅបុគ្គលនោះ ដែលមិនមានកិលេសជាគ្រឿងជំពាក់ ជាអ្នករួចស្រឡះ ចាកកិលេសហើយ ថា ជាព្រាហ្មណ៍ ។*

❇ ❇ ❇

២៧៨- រឿង ព្រាហ្មណ៍ពីរនាក់

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវព្រាហ្មណ៍ពីរនាក់ ។ បណ្តាព្រាហ្មណ៍ពីរនាក់នោះ ព្រាហ្មណ៍ម្នាក់ មានគោ ឈ្មោះចូឡរោហិត ព្រាហ្មណ៍ ម្នាក់ទៀត មានគោ ឈ្មោះមហារោហិត ។ ព្រាហ្មណ៍ទាំងពីរនាក់នោះ អួតអាងពីគោរបស់ខ្លួន ថា "សុទ្ធតែ ជើងខ្លាំងៗ" ហើយចង់សាកល្បងមើលគោទាំងពីរនោះថា "តើគោណាមួយ មានកម្លាំងខ្លាំងជាងគេ" ទើបយកដីខ្សាច់ មកផ្ទុកពេញរទេះ ហើយទឹមគោទាំងពីរនោះ បររចេញទៅ ។ តែគោទាំងពីរនោះ មិនអាចនឹងអូសទាញរទេះបានឡើយ រទេះបានដាច់ខ្សែព្ធួរ និង ខ្សែជ្រាមទាំងអស់ ។*

*ភិក្ខុទាំងឡាយ បានឃើញហើយ ទើបនាំយករឿងនោះ ទៅក្រាបទូល ដល់ព្រះសាស្តាទ្រង់ជ្រាប ។*

*ព្រះសាស្តាចារ្យ ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ខ្សែព្ធួរ និង ខ្សែជ្រាមនោះ ជារបស់ដែលមាននៅខាងក្រៅទេ អ្នកទាំងឡាយគប្បីកាត់ផ្តាច់នូវខ្សែព្ធួរ គឺសេចក្តីក្រោធខឹង និង ខ្សែជ្រាម គឺតណ្ហាដែលជារបស់មាននៅខាងក្នុងឲ្យបាន" ស្រេចហើយ ទ្រង់ត្រាស់នូវ*

## រឿងអក្កោសកភារទ្វាជព្រាហ្មណ៍

ព្រះគាថានេះ ថា ៖

ឆេត្វា នទ្ធឹ វរត្តញ្ច   សន្ទានំ សហានុក្កមំ
ឧក្ខិត្តបលិឃំ ពុទ្ធំ   តមហំ ព្រូមិ ព្រាហ្មណំ ។

តថាគត ហៅបុគ្គលដែលកាត់សេចក្ដីក្រោធ ដូចព្រួរផង កាត់តណ្ហា ដូចព្រ័ត្រផង កាត់ទិដ្ឋិ ៦២ ដូចទីត ព្រមទាំងអនុស័យ ដូចអ្នកដើរតាមផង អ្នកមានអវិជ្ជា ដូចសសរខឿន ដកចោលហើយ អ្នកត្រាស់ដឹងសច្ចៈ ៤ នោះផង ថា ជាព្រាហ្មណ៍ ។

❋ ❋

### ២៧៩- រឿងអក្កោសកភារទ្វាជព្រាហ្មណ៍

ព្រះបរមសាស្ដា ទ្រង់ប្រារព្ធនូវព្រាហ្មណ៍ ឈ្មោះអក្កោសកភារទ្វាជៈ ដែលជាអ្នកជេរប្រទេចចំពោះព្រះអង្គ ។ សម័យថ្ងៃមួយ ពួកព្រាហ្មណ៍ដែលជាមិច្ឆាទិដ្ឋិ បានប្រជុំគ្នា ជប់លៀងភោជនាហារ ។ ឯនាងព្រាហ្មណី ឈ្មោះធនញ្ជានី ដែលជាបងថ្លៃ របស់អក្កោសកភារទ្វាជព្រាហ្មណ៍នោះ ជាអ្នកសម្មាទិដ្ឋិ ជាព្រះសោតាបន្ន ពេលដែលនាងដួលក្ដី ផ្ទាតក្ដី ក្អកក្ដី ផ្ដាសាយក្ដី នាង បានឧទានវាចា ថា "**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**" ដូច្នេះ សព្វៗកាល ។ ក្នុងថ្ងៃប្រជុំគ្នានោះ នាងបានដើរដួលហើយ ឧទានឡើងដោយសំឡេង យ៉ាងខ្លាំង ថា "**នមោ តស្ស**" ប៉ុណ្ណេះជាដើម ។

ព្រាហ្មណ៍ជាស្វាមី បានឮដូច្នេះហើយ ក៏ជេរស្ដីនាង ដោយប្រការផ្សេងៗ ហើយបានទៅគាល់ព្រះសម្មាសម្ពុទ្ធ តែមិនបានក្រាប

ថ្វាយបង្គំព្រះអង្គទេ គ្រាន់តែទូលសួរនូវបញ្ហាធម៌ ចំពោះព្រះអង្គ ។

ព្រះសាស្តា ទ្រង់ត្រាស់ទេសនាពន្យល់ ឲ្យព្រាហ្មណ៍នោះ មានសេចក្តីជ្រះថ្លា ក្នុងព្រះពុទ្ធសាសនា ហើយចូលបួស បន្ទាប់មក ក៏បានសម្រេចអរហត្តផល ។

អក្កោសកភារទ្វាជព្រាហ្មណ៍ អាស្រ័យ នូវហេតុនេះហើយ បានជាក្រោធខឹង ជេរប្រទេចព្រះសាស្តា លុះបានស្តាប់នូវព្រះធម៌ ទេសនា របស់ព្រះអង្គហើយ ក៏មានចិត្តជ្រះថ្លាស៊ប់ ក្នុងព្រះរតនត្រៃ បានចូលមកបួសហើយ បានសម្រេចអរហត្តផល ម្នាក់ទៀត ។

ភិក្ខុទាំងឡាយ បានប្រជុំគ្នា ពោលសរសើរ នូវព្រះខន្តិគុណ របស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ។

ព្រះបរមសាស្តាចារ្យ ទ្រង់ត្រាស់ទេសនា អំពីអានិសង្ស នៃ សេចក្តីអត់ធន់ ហើយត្រាស់នូវព្រះគាថានេះ ថា ៖

**អក្កោសំ វធពន្ធញ្ច អទុដ្ឋោ យោ តិតិក្ខតិ**
**ខន្តិពលំ ពលានីកំ តមហំ ព្រូមិ ព្រាហ្មណំ ។**

បុគ្គលណា មិនប្រទូស្ត អត់ធន់ ចំពោះពាក្យជេរផង ការ បៀតបៀន និង ការចងផងបាន ទើបតថាគត ហៅបុគ្គលដែលមាន ខន្តិជាកម្លាំង មានខន្តិជាវេហ៍ពលនោះឯង ថា ជាព្រាហ្មណ៍ ។

❇ ❇ ❇

## ២៨០- រឿង ព្រះសារីបុត្រ

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវព្រះសារីបុត្រ ។ សម័យថ្ងៃ

-៤១៨-

## រឿង ព្រះសារីបុត្រ

មួយ ព្រះថេរៈ បាននិមន្តទៅបិណ្ឌបាត ជាមួយនឹងភិក្ខុ ៥០០ រូប ហើយបានទៅដល់មុខផ្ទះញោមស្រីរបស់លោក នៅនាលកគ្រាម ។

ញោមស្រី របស់ព្រះថេរៈ ជាអ្នកមិច្ឆាទិដ្ឋិ មិនជ្រះថ្លា ក្នុងព្រះពុទ្ធសាសនា លុះបានឃើញព្រះសារីបុត្រដែលជាកូនប្រុស នាំភិក្ខុសង្ឃជាច្រើនមកដូច្នេះហើយ ក៏ត្រូវតែធ្វើបដិសន្ថារកិច្ចទទួល ប៉ុន្តែបានជេរប្រទេចជាច្រើន ព្រោះក្រោធខឹងនឹងព្រះសារីបុត្រ ដែលបានលះបង់ទ្រព្យសម្បត្តិ រត់ចេញទៅបួស ។

ព្រះសារីបុត្រ មិនបានក្រោធខឹង នឹងញោមស្រីឡើយ ។ ពេលព្រះថេរៈ ត្រឡប់មកវិញ, ភិក្ខុទាំងឡាយ បានប្រជុំសន្ទនាគ្នាពោលសរសើរគុណរបស់ព្រះថេរៈ ដែលលោកមិនក្រោធខឹងចំពោះញោមស្រី ។

ព្រះសាស្ដា ទ្រង់ស្ដេចយាងមក ក្នុងទីប្រជុំនោះ ហើយត្រាស់នូវព្រះគាថានេះ ថា ៖

**អក្កោធនំ វត្តវន្តំ សីលវន្តំ អនុស្សទំ**  
**ទន្តំ អន្តិមសារីរំ តមហំ ព្រូមិ ព្រាហ្មណំ ។**

តថាគត ហៅបុគ្គលដែលមិនមានសេចក្ដីក្រោធខឹង មានធុតង្គវត្ត មានចតុប្បារិសុទ្ធិសីល មិនមានតណ្ហាគ្រឿងប៉ោងចិត្ត មានឥន្ទ្រិយ៍ទូន្មានហើយ មានសរីរៈ ឋិតនៅ ក្នុងទីបំផុត នោះ ថា ជាព្រាហ្មណ៍ ។

♣ ♣ ♣

## ២៨១- រឿង នាងឧប្បលវណ្ណាថេរី

*ព្រះបរមសាស្តា ទ្រង់បានប្រារព្ធនូវនាងឧប្បលវណ្ណាថេរី ។ កាលនន្ទមាណព បានប្រទូសរ៉ាយចំពោះខ្លួននាង, ពួកប្រជាជន បាននិយាយគ្នា ថា "ព្រះខីណាស្រព មានសាច់ឈាមស្រស់ មិនមែនជាឈើពុក ឬ ដំបូកទេ នៅតែត្រេកអរ ចំពោះកាមគុណនៅឡើយ" ។*

*ព្រះសាស្តា ទ្រង់យាងមក ក្នុងទីប្រជុំនោះ ហើយត្រាស់ ថា "ព្រះខីណាស្រព មិនត្រេកអរ ក្នុងកាមគុណ ដូចទឹកមិនជាប់លើស្លឹកឈូក និង ដូចគ្រាប់ស្ពៃ មិនជាប់លើចុងដែកដែលស្រួច យ៉ាងដូច្នោះឯង" ដូច្នេះហើយ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

**វារិ បោក្ខរបត្តេវ អារគ្គេរិវ សាសបោ**
**យោ ន លិប្បតិ កាមេសុ តមហំ ព្រូមិ ព្រាហ្មណំ ។**

*បុគ្គលណា មានចិត្តមិនបានជាប់នៅ ក្នុងកាមទាំងឡាយ ដូចជាទឹក មិនជាប់លើស្លឹកឈូក ឬ ដូចជាគ្រាប់ស្ពៃ មិនជាប់លើចុងដែកដែលស្រួច យ៉ាងដូច្នោះឯង តថាគត ហៅបុគ្គលនោះ ថា ជាព្រាហ្មណ៍ ។*

❋ ❋

## ២៨២- រឿង អញ្ញាត្រព្រាហ្មណ៍

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវព្រាហ្មណ៍ម្នាក់ ។ ព្រាហ្មណ៍នោះ មានកូនឈ្នួលម្នាក់ បានរត់ទៅបួស ហើយបានសម្រេចនូវព្រះអរហត្តផល ។*

-៤២០-

## រឿងអញ្ញាត្រព្រាហ្មណ៍

*សម័យនោះឯង ព្រះសម្ពុទ្ធ មិនទាន់បានបញ្ញត្តសិក្ខាបទនៅឡើយទេ ។ ព្រាហ្មណ៍ ជាចៅហ្វាយនាយ បានដើរទៅស្វែងរកកូនឈ្មួលនោះ គ្រប់ទីកន្លែង អស់កាលដ៏យូរ មិនបានចួបប្រទះសោះ វេលាថ្ងៃមួយ ស្រាប់តែមកចួបប្រទះនូវកូនឈ្មួល ដែលបួសហើយ លោកកំពុងតែនិមន្តបិណ្ឌបាត ប្រោសសត្វ ជាមួយព្រះសាស្តា ក៏ស្ទុះទៅចាប់ចីវរ របស់លោក យ៉ាងជាប់ ដើម្បីកុំឲ្យលោករត់គេច ។*

*ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់សួរព្រាហ្មណ៍ ថា "នែព្រាហ្មណ៍ នេះគឺជារឿងអ្វី?" ។ ព្រាហ្មណ៍ ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុអង្គនេះ ជាកូនឈ្មួល របស់ទូលព្រះបង្គំ" ។ ព្រះសាស្តា ទ្រង់ត្រាស់ថា "នែព្រាហ្មណ៍ ភិក្ខុអង្គនេះ លោកមានភារៈ ទម្លាក់ចោលអស់ហើយ" ។ ព្រាហ្មណ៍ បានឮដូច្នោះហើយ ក៏ដឹងច្បាស់ថា "ភិក្ខុនេះ ជាព្រះអរហន្ត" ហើយ ក៏បានលែងចីវរ របស់លោកចេញទៅ ។*

*ព្រះបរមសាស្តាចារ្យ ទ្រង់បានត្រាស់នូវព្រះគាថានេះ ថា ៖*

យោ ទុក្ខស្ស បជានាតិ ឥធេវ ខយមត្តនោ
បន្នភារំ វិសំយុត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។

*ជនណា ក្នុងសាសនានេះ ដឹងច្បាស់ការអស់ទុក្ខ របស់ខ្លួន តថាគត ហៅជននោះ អ្នកមានខន្ធភារៈដាក់ចុះ រួចស្រឡះហើយ ថា ជាព្រាហ្មណ៍ ។*

♣ ♣ ♣

## ២៨៣- រឿង នាងខេមាភិក្ខុនី

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវនាងខេមាភិក្ខុនី ។ រាត្រីយប់មួយ នាងបានទៅគាល់ព្រះសម្មាសម្ពុទ្ធ នាក្នុំគិជ្ឈកូដ លុះនាងបានឃើញព្រះឥន្ទ្រាធិរាជ ព្រមជាមួយពួកទេវតា មកចាំគាល់មុនហើយ ទើបឈរនៅ លើអាកាស ក្រាបថ្វាយបង្គំព្រះសាស្តា ហើយក៏វិលត្រឡប់ទៅវិញ ។*

*ព្រះឥន្ទ្រាធិរាជ ទតព្រះនេត្រឃើញហើយ ទ្រង់ត្រាស់សួរចំពោះព្រះសាស្តាថា "បពិត្រព្រះអង្គដ៏ចំរើន តើអ្នកណា មកថ្វាយបង្គំព្រះអង្គហើយ ត្រឡប់ទៅវិញនោះ?" ។*

*ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ថា "នោះ គឺជានាងភិក្ខុនី ឈ្មោះខេមា ជាអ្នកមានប្រាជ្ញាច្រើន" ដូច្នេះហើយ ត្រាស់ព្រះគាថានេះ ថា៖*

**គម្ភីរបញ្ញំ មេធាវឹ    មគ្គាមគ្គស្ស កោវិទំ**
**ឧត្តមត្ថំ អនុប្បត្តំ    តមហំ ព្រូមិ ព្រាហ្មណំ ។**

*តថាគត ហៅបុគ្គលដែលមានប្រាជ្ញាជ្រៅជ្រះ មានប្រាជ្ញាជាគ្រឿងទម្លាយកិលេស ជាអ្នកឈ្លាសវៃ ក្នុងផ្លូវ និង មិនមែនជាផ្លូវ បានសម្រេច នូវប្រយោជន៍ ដ៏ខ្ពង់ខ្ពស់នោះ ថា ជាព្រាហ្មណ៍ ។*

✻ ✻

## ២៨៤- រឿង ព្រះបព្ភារវាសីតិស្សត្ថេរ

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធ នូវព្រះបព្ភារវាសីតិស្សត្ថេរ ។ ព្រះថេរៈ បានរៀនកម្មដ្ឋាន ក្នុងសំណាក់ នៃព្រះសម្មាសម្ពុទ្ធ ហើយ*

-៤២២-

# រឿង ព្រះបណ្ណាវាសីតិស្សត្ថេរ

បានទៅនៅអាស្រ័យ ក្នុងចន្លោះភ្នំមួយ ជាទីកន្លែងដែលមានសេចក្តីស្ងប់សុខ ។

ទេវតាទាំងឡាយ ដែលស្ថិតនៅ នាចន្លោះភ្នំនោះ មិនចង់ឲ្យព្រះថេរៈ អាស្រ័យនៅ ក្នុងទីនោះទេ តែមិនអាចបៀតបៀន ឬ ធ្វើអន្តរាយព្រះថេរៈបានឡើយ ព្រោះព្រះថេរៈ ជាអ្នកមានសីលបរិសុទ្ធ តាំងតែអំពីលោកឧបសម្បទមក ហើយទេវតានោះ បានសម្តែងខ្លួនចូលទៅ ក្នុងរូបរាងកាយ របស់បុត្រ នៃឧបាសិកាម្នាក់ ដែលជាឧបដ្ឋាយិកា របស់ព្រះថេរៈហើយ និយាយប្រាប់ ថា "យើងមិនត្រូវការពលិកម្មអ្វីទេ បើអ្នកទៅសុំទឹកលាងជើង របស់ព្រះថេរៈ ឈ្មោះបណ្ណាវាសីតិស្សៈ មកស្រោចលើក្បាលបុត្រ របស់អ្នកហើយ យើងនឹងចេញពីរូបនេះ ឥឡូវនេះភ្លាម" ។

លុះព្រឹកឡើង ព្រះថេរៈ បាននិមន្តទៅបិណ្ឌបាត នៅឯផ្ទះឧបាសិកា ។ ឧបាសិកាដែលជាឧបដ្ឋាយិកា បានធ្វើដូចទេវតាប្រាប់ ។ ពេលព្រះថេរៈ និមន្តត្រឡប់មកពីបិណ្ឌបាតវិញហើយ, ទេវតានោះបានមកបណ្តេញព្រះថេរៈ ចេញពីទីនោះ ដោយចោទថា "ព្រះថេរៈធ្វើវេជ្ជកម្ម មានសីលមិនបរិសុទ្ធ" ។

ព្រះបណ្ណាវាសីតិស្សៈ បានគិតថា "អាត្មាអញ បានធ្វើវេជ្ជកម្មមែនឬ?" ដូច្នេះហើយ ពិចារណាសីលរបស់ខ្លួន តាំងតែពីឧបសម្បទមក មិនឃើញថា សីលរបស់ខ្លួន សៅហ្មងធ្លុះធ្លាយឡើយ ទើបមានបីតិត្រេកអរ ក្នុងសីល របស់ខ្លួនយ៉ាងខ្លាំង, កាលបើបីតិស្ងប់ហើយ,

ក៏បានសម្រេចព្រះអរហត្តផល ក្នុងពេលនោះឯង លុះចេញវស្សាហើយ ក៏បានមកគាល់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ។

ព្រះសាស្តា ទ្រង់ត្រាស់សរសើរព្រះថេរៈ ថា "ជាអ្នកមិននៅប្រឡូកប្រឡល់ ជាមួយនឹងពួកគណៈ គេចចេញទៅនៅ នាចន្លោះភ្នំតែឯកឯង" ដូច្នេះហើយ ទើបទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

**អសំសដ្ឋំ គហដ្ឋេហិ អនាគារេហិ ចូភយំ**
**អនោកសារឹ អប្បិច្ឆំ តមហំ ព្រូមិ ព្រាហ្មណំ ។**

តថាគត ហៅបុគ្គលដែលមិនប្រឡូកប្រឡល់ ដោយជនទាំងឡាយ ២ ពួក គឺ គ្រហស្ថ ១ បព្វជិត ១ ជាអ្នកត្រាច់ទៅ ដោយមិនមានសេចក្តីអាឡោះអាល័យ មានសេចក្តីប្រាថ្នាតិចនោះ ថា ជាព្រាហ្មណ៍ ។

✻ ✻

## ២៨៥- រឿងអញ្ញតរភិក្ខុ

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវភិក្ខុមួយរូប ។ ភិក្ខុរូបនេះ បានរៀនកម្មដ្ឋាន ក្នុងសំណាក់នៃព្រះសាស្តា ហើយក្រាបថ្វាយបង្គំលាព្រះអង្គ ទៅបំពេញសមណធម៌ ក្នុងព្រៃស្ងាត់ រហូតបានសម្រេចនូវព្រះអរហត្តផល ហើយប្រាថ្នានឹងមកថ្វាយបង្គំព្រះសាស្តា ទើបនិមន្តចេញពីទីនោះ ។

ពេលនោះ មានស្រីម្នាក់ឈ្លោះជាមួយស្វាមី បានចាកចេញអំពីផ្ទះ ដើម្បីទៅកាន់ត្រកូលរបស់ខ្លួន ហើយបានដើរ តាមពីក្រោយ

-៤២៤-

## រឿងអញ្ញាត្រភិក្ខុ

*ព្រះថេរៈ ។*

*គ្រានោះ ស្វាមី របស់នាង បានដើរតាមមក ក៏ជួបប្រទះនឹងករិយា នៅកណ្តាលផ្លូវ ឃើញនាងដើរ តាមពីក្រោយព្រះថេរៈ យ៉ាងនេះហើយ គិតថា "ព្រះថេរៈ បានលួចប្រពន្ធរបស់ខ្លួនរត់មក" ហើយបានស្ទុះចូលទៅវាយតប់ ដាល់ព្រះថេរៈ រហូតដល់បាត់ខឹង ស្រេចហើយ ក៏នាំករិយាវិលត្រឡប់ទៅផ្ទះរបស់ខ្លួនវិញ ។*

*កាលព្រះថេរៈ និមន្តមកដល់វត្តជេតពនវិញ, ភិក្ខុទាំងឡាយបានធ្វើអាគន្តុកវត្ត ទទួលតាមសមគួរ ហើយបានឃើញសរីរៈរបស់ព្រះថេរៈ ហើមជាំខៀវ ជាច្រើនកន្លែង ទើបសួរថា "ហេតុអ្វី បានជាសរីរៈហើម បែកជាំយ៉ាងនេះ?" ។ ព្រះថេរៈឆ្លើយថា "ត្រូវបុរសម្នាក់វាយធ្វើបាប" ។ ភិក្ខុទាំងឡាយ បានសួរទៀតថា "តើលោកម្ចាស់បានក្រោធខឹង នឹងអ្នកវាយដែរឬទេ?" ។ ព្រះថេរៈ ឆ្លើយថា "ខ្ញុំមិនបានក្រោធខឹងនឹងគេទេ" ។ ភិក្ខុទាំងឡាយ បានចោទថា "ព្រះថេរៈពោលអួតអរហត្តផល" ហើយ នាំយករឿងនោះ ទៅក្រាបទូលដល់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ជ្រាប ។*

*ព្រះសាស្តា ទ្រង់ជ្រាបហើយ ត្រាស់ទេសនាពន្យល់ភិក្ខុទាំងនោះ ថា "ម្នាលភិក្ខុទាំងឡាយ ព្រះអរហន្តខីណាស្រព ទាំងឡាយលោកមិនដែលក្រោធខឹងនឹងអ្នកណាឡើយ" ហើយ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

**និធាយ ទណ្ឌំ ភូតេសុ    តសេសុ ថាវរេសុ ច**

គាថាធម្មបទប្រែ

**យោ ន ហន្តិ ន ឃាតេតិ តមហំ ព្រូមិ ព្រាហ្មណំ ។**

*បុគ្គលណា ដាក់ចុះនូវអាជ្ញា ក្នុងសត្វទាំងឡាយ ដែលនៅតក់ស្លុត ក្តី ដែលមាំមួន គឺមិនមានតក់ស្លុត ក្តី មិនបៀតបៀនដោយខ្លួនឯង មិនប្រើគេឲ្យបៀតបៀន តថាគត ហៅបុគ្គលនោះ ថា ជាព្រាហ្មណ៍ ។*

♣ ♣ ♣

២៨៦- រឿងសាមណេរ ៤ រូប

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវសាមណេរ ៤ រូប សុទ្ធតែជាព្រះអរហន្តខីណាស្រព ដែលមានអាយុ ៧ ឆ្នាំ តែប៉ុណ្ណោះ គឺសង្កិច្ចសាមណេរ, បណ្ឌិតសាមណេរ, សោបាកសាមណេរ និងរេវតសាមណេរ ។*

*ពេលនោះ មាននាងព្រាហ្មណីម្នាក់ ប្រាថ្នាចង់ធ្វើបុណ្យ ជប់លៀង ដល់ពួកព្រាហ្មណ៍ ហើយបានឲ្យស្វាមីទៅអញ្ជើញព្រាហ្មណ៍ដែលមានវ័យចាស់ៗ ៤ រូប មកទទួលភត្តាហារ នៅផ្ទះរបស់ខ្លួន ។ ព្រាហ្មណ៍ ជាស្វាមី បានទៅរកព្រះភត្តុទេសក៍ ដើម្បីនិមន្តលោក តាមសេចក្តីប្រាថ្នា របស់ភរិយា ។ ព្រះភត្តុទេសក៍ បានចាត់ឲ្យសាមណេរ ៤ រូប ដើម្បីនិមន្តទៅទទួលភត្តាហារ នៅផ្ទះរបស់ព្រាហ្មណ៍ ។*

*នាងព្រាហ្មណី បានឃើញសាមណេរតូចៗ ទាំង ៤ រូបនោះហើយ ក៏អន់ចិត្តក្រោធខឹង យ៉ាងខ្លាំង បានស្តីបន្ទោសស្វាមី ថា “នាងខ្ញុំត្រូវការតែព្រាហ្មណ៍ចាស់ៗ ប៉ុណ្ណោះ ហេតុអ្វីហ្ន៎ បានជាបងឯង*

និមន្តព្រាហ្មណ៍ ដែលជាកូនក្មេងតូចៗ មិនដឹងខ្យល់អ្វីបន្តិចសោះ យ៉ាងដូច្នេះទៅវិញ?" ស្រេចហើយ នាងបានឲ្យសាមណេរទាំង ៤ រូបនោះ គង់ចាំនៅខាងក្រៅសិន ហើយបានប្រើឲ្យស្វាមី ទៅនិមន្តលោកសាជាថ្មីម្តងទៀត ។

ព្រាហ្មណ៍ជាស្វាមី បានទៅនិមន្តព្រះសារីបុត្រ និងព្រះមហាមោគ្គល្លានត្ថេរ ។ ព្រះថេរៈ ទាំងពីររូប លុះបានមកដល់ផ្ទះ របស់ព្រាហ្មណ៍ហើយ ក្រឡេកឃើញសាមណេរទាំង ៤ រូប គង់ចាំនៅខាងក្រៅ ដូច្នេះហើយ ក៏បាននិមន្តត្រឡប់ទៅវត្តវិញភ្លាម ។

នាងព្រាហ្មណី ឃើញព្រះថេរៈទាំងពីររូប និមន្តត្រឡប់ទៅវត្តវិញហើយ ទើបប្រើស្វាមីឲ្យទៅនិមន្តព្រាហ្មណ៍ចាស់ៗ ជាថ្មីម្តងទៀត, ប្រើទៅប្រើមក ពេលវេលាដែលត្រូវឆាន់ ក៏ជិតនឹងអស់ទៅហើយដែរ ។

ក្នុងពេលនោះឯង ព្រះឥន្ទ្រាធិរាជ បានក្រឡាខ្លួន មកធ្វើជាព្រាហ្មណ៍ចាស់ៗ ដើរសំដៅឆ្ពោះទៅផ្ទះ របស់ព្រាហ្មណ៍នោះ ។

ព្រាហ្មណ៍ជាស្វាមីបានឃើញហើយ ក៏អញ្ជើញឥន្ទព្រាហ្មណ៍ឲ្យឡើងទៅលើផ្ទះ ។ នាងព្រាហ្មណី បានឃើញព្រាហ្មណ៍ចាស់នោះហើយ មានចិត្តជ្រះថ្លា យ៉ាងក្រៃលែង ។

ឥន្ទព្រាហ្មណ៍ ឡើងទៅលើផ្ទះហើយ បានឃើញសាមណេរ ៤ រូប កំពុងគង់រង់ចាំនៅខាងក្រៅ ក៏លើកដៃសំពះថ្វាយបង្គំភ្លាម ។

នាងព្រាហ្មណី ឃើញដូច្នេះហើយ ក៏ក្រោធខឹង ស្រែកជេរ

ស្វាមី ថា "ស្អប់ហើយ ព្រះអើយ! ហេតុអ្វីបានជាបងឯង ទៅយកព្រាហ្មណ៍ដែលកញ្ចាស់ ធ្លុតលីលានេះមក តើបានប្រយោជន៍អ្វី?" ហើយ ក៏បានចាប់ក របស់ឥន្ទព្រាហ្មណ៍ វាយតប់ អូសទាញទម្លាក់ ហើយបានបណ្តេញ ឲ្យធ្លាប់ចុះចេញពីផ្ទះរបស់ខ្លួនភ្លាម ។

ក្នុងពេលនោះ ឥន្ទព្រាហ្មណ៍ បានក្រឡាខ្លួនជាព្រះឥន្ទ ដើម្បីឲ្យព្រាហ្មណ៍ទាំងពីរនាក់នោះ បានដឹងច្បាស់ថា ព្រះអង្គជាព្រះឥន្ទ ។

ព្រាហ្មណ៍ទាំងពីរនាក់ ភរិយាស្វាមី បានឃើញ យ៉ាងដូច្នេះ ហើយ ភ័យខ្លាចយ៉ាងខ្លាំង ហើយបានថ្វាយកត្តាហារ ដល់សាមណេរ ទាំង ៤ រូប និង ព្រះឥន្ទ្រាធិរាជផងដែរ ។

សាមណេរទាំង៤ រូប លុះឆាន់រួចហើយ, អង្គខ្លះ បានហោះចេញទៅ អង្គខ្លះ បានជ្រែកផែនដីចេញទៅ ។ កាលសាមណេរទាំង ៤ រូបនោះ ត្រឡប់មកដល់វត្តវិញហើយ, ភិក្ខុទាំងឡាយ បានសួរសាមណេរទាំងនោះ ថា "តើលោកម្ចាស់ គ្រប់អង្គ បានក្រោធខឹងចំពោះព្រាហ្មណ៍ ពីរនាក់ប្តីប្រពន្ធនោះដែរឬទេ?" លុះសាមណេរទាំង ៤ រូបនោះ ឆ្លើយថា "ខ្ញុំព្រះករុណា ទាំងអស់គ្នា មិនបានក្រោធខឹងទេ" យ៉ាងដូច្នេះហើយ បានចោទថា "សាមណេរទាំង ៤ រូបនេះ និយាយមិនពិត" ហើយបានយករឿងនោះ ទៅក្រាបទូល ដល់ព្រះសាស្តាទ្រង់ជ្រាប ។

ព្រះសាស្តាចារ្យ ទ្រង់ត្រាស់ថា "សាមណេរទាំង ៤ រូបនោះ បាននិយាយពិតហើយ" ស្រេចហើយ ទ្រង់ត្រាស់ព្រះគាថានេះ ថា ៖

-៤២៨-

រឿង ព្រះមហាបន្ថកត្ថេរ

**អវិរុទ្ធំ វិរុទ្ធេសុ អត្តទណ្ឌេសុ និព្វុតំ**
**សាទានេសុ អនាទានំ តមហំ ព្រូមិ ព្រាហ្មណំ ។**

*តថាគត ហៅបុគ្គលដែលមិនខឹង ចំពោះពួកជនដែលខឹង ហើយ អ្នករំលត់ ចំពោះពួកជនដែលមានអាជ្ញា ក្នុងខ្លួន អ្នកដែលមិនមានសេចក្តីប្រកាន់ ចំពោះពួកជនដែលមានសេចក្តីប្រកាន់នោះ ថា ជាព្រាហ្មណ៍ ។*

✻ ✻

២៨៧- រឿង ព្រះមហាបន្ថកត្ថេរ

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវមហាបន្ថកត្ថេរ ។ ព្រះមហា-បន្ថក ឲ្យព្រះចូឡបន្ថក ដែលជាប្អូនរបស់ខ្លួន ទន្ទេញព្រះគាថាមួយបទ អស់រយៈពេលដល់ទៅ ៤ ខែ ក៏នៅតែទន្ទេញមិនចាំ ហើយបានបណ្តេញព្រះចូឡបន្ថក ចេញពីវិហារ ។ ព្រះចូឡបន្ថក មានសេចក្តីខ្មាសអៀន តូចចិត្តយ៉ាងខ្លាំង គិតប្រាថ្នាចង់លាចាកសិក្ខាបទ ។*

*ព្រះសម្មាសម្ពុទ្ធ ទ្រង់ជ្រាបវារចិត្ត របស់ព្រះចូឡបន្ថកហើយ ទើបទ្រង់បានប្រទានព្រះឱវាទ និង កម្មដ្ឋាន ដើម្បីឲ្យព្រះចូឡបន្ថកពិចារណា ។ ព្រះចូឡបន្ថក បានពិចារណា តាមព្រះឱវាទ របស់ព្រះអង្គ ជារឿយៗ រហូតដល់បានសម្រេចព្រះអរហត្តផល ក្នុងទីបំផុត ។ ក្នុងពេលនោះ ភិក្ខុទាំងឡាយ បានប្រជុំសន្ទនាគ្នា ថា “ការដែលព្រះមហាបន្ថកត្ថេរ ធ្វើយ៉ាងនេះ ដូចជាធ្វើដោយសេចក្តីក្រោធខឹង មិនសមគួរសោះឡើយ ។*

## គាថាធម្មបទប្រែ

ព្រះសម្មាសម្ពុទ្ធ ស្តេចយាងមក ក្នុងទីប្រជុំនោះហើយ ទ្រង់ត្រាស់ពន្យល់ថា "ម្នាលភិក្ខុទាំងឡាយ ព្រះអរហន្តខីណាស្រពទាំងឡាយ មិនមានកិលេស មិនមានតណ្ហានៅក្នុងសន្តានចិត្តឡើយ ព្រះមហាបន្ថក ធ្វើយ៉ាងនេះ ព្រោះអាស្រ័យអត្ថផង ធម៌ផង" ហើយត្រាស់នូវព្រះគាថានេះ ថា ៖

**យស្ស រាគោ ច ទោសោ ច មានោ មក្ខោ ច បាតិតោ**
**សាសបោរិវ អារគ្គា តមហំ ព្រូមិ ព្រាហ្មណំ ។**

រាគៈ ទោសៈ មានះ និង ការរមិលគុណគេ ដែលបុគ្គលណាបានជម្រុះចេញហើយ ដូចជាគ្រាប់ស្ពៃ ដែលជ្រុះចុះ អំពីចុងដែកដ៏ស្រួច យ៉ាងនោះឯង តថាគត ហៅបុគ្គលនោះ ថា ជាព្រាហ្មណ៍ ។

## ២៨៨- រឿង ព្រះបិលិន្ទវច្ឆត្ថេរ

ព្រះបរមសាស្តា ទ្រង់បានប្រារព្ធនូវព្រះបិលិន្ទវច្ឆត្ថេរ ជាព្រះអរហន្ត ។ ព្រះថេរៈ ហៅគ្រហស្ថ ឬ បព្វជិតណាមួយ ច្រើនតែប្រើពាក្យថា "វសលិ មនុស្សថោកទាប អ្នកចូរមក មនុស្សថោកទាបអ្នកចូរមកចុះ" ដូច្នេះ ជារឿយៗ ព្រោះព្រះសាវកទាំងឡាយ លោកលះនូវវាសនា មិនទាន់បាន លះបានតែព្រះពុទ្ធប៉ុណ្ណោះ ។

ភិក្ខុទាំងឡាយ នាំគ្នាតិះដៀលព្រះថេរៈ ដោយប្រការផ្សេងៗ ហើយនាំយករឿងនោះ ទៅក្រាបទូល ដល់ព្រះសាស្តាទ្រង់ជ្រាប ។

ព្រះសម្មាសម្ពុទ្ធ ទ្រង់ជ្រាបហើយត្រាស់នូវព្រះគាថានេះថា ៖

រឿងអញ្ញាត្រភិក្ខុ

**អកក្កសំ វិញ្ញាបនឹ គិរំ សច្ចំ ឧទីរយេ**
**យាយ នាភិសជេ កិញ្ចិ តមហំ ព្រូមិ ព្រាហ្មណំ ។**

*បុគ្គលណា ពោលពាក្យមិនអាក្រក់ ពាក្យដែលធ្វើឲ្យយល់គ្នាបាន ជាពាក្យពិតត្រង់ ជាពាក្យដែលមិនធ្វើឲ្យអ្នកណាទាស់ចិត្តតថាគត ហៅបុគ្គលនោះ ថា ជាព្រាហ្មណ៍ ។*

❋ ❋ ❋

២៨៩- រឿងអញ្ញាត្រភិក្ខុ

*ព្រះបរមសាស្តា ទ្រង់បានប្រារព្ធ នូវភិក្ខុមួយរូប ជាព្រះខីណាស្រព ។ សម័យថ្ងៃមួយ ភិក្ខុរូបនោះ និមន្តចូលទៅកាន់ព្រះវិហារ ឃើញសំពត់ របស់ព្រាហ្មណ៍ជាអ្នកមិច្ឆាទិដ្ឋិម្នាក់ ដែលគាត់បានទុកចោល ក្នុងទីស្ងាត់មួយ ទើបបានសម្គាល់ថា "ជាសំពត់ដែលគ្មានម្ចាស់" ហើយចាប់ទាញយកមក ដោយបំសុកូលសញ្ញា ។*

*ព្រាហ្មណ៍ ឃើញយ៉ាងនេះហើយ ក៏បានតាមទៅជេរព្រះថេរៈថា "សមណៈ ក្បាលត្រងោល បានលួចសំពត់របស់អញ" ។ ព្រះថេរៈ ឮដូច្នេះហើយ ក៏បានយកសំពត់នោះ ទៅឲ្យព្រាហ្មណ៍វិញ ។*

*ភិក្ខុទាំងឡាយ បាននិយាយចំអកឲ្យព្រះថេរៈ ជារឿយៗ ថា "សំពត់នោះ វែង ខ្លី ប្រវែងណាដែរ?" ។ ព្រះថេរៈ ឆ្លើយតបថា "ខ្ញុំមិនមានចិត្តជាប់ជំពាក់ ក្នុងសំពត់នោះឡើយ" ។ ភិក្ខុទាំងឡាយ បានចោទព្រះថេរៈ ថា "ពោលអួតព្រះអរហត្តផល" ហើយនាំយករឿងនោះ ទៅក្រាបទូល ដល់ព្រះសាស្តាទ្រង់ជ្រាប ។*

-៤៣១-

គាថាធម្មបទប្រែ

*ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ដោះស្រាយ នូវពាក្យរិះគន់នោះហើយ ត្រាស់នូវព្រះគាថានេះ ថា ៖*

**យោធ ទីឃំ វា រស្សំ វា  អណុំ ថូលំ សុភាសុភំ**
**លោកេ អទិន្នំ នាទិយតិ  តមហំ ព្រូមិ ព្រាហ្មណំ ។**

*បុគ្គលណា មិនកាន់យក នូវរបស់វែង ឬខ្លី តូច ឬធំ ល្អ ឬអាក្រក់ ដែលគេមិនបានឲ្យហើយ ក្នុងលោកនេះ តថាគត ហៅបុគ្គលនោះ ថា ជាព្រាហ្មណ៍ ។*

♣ ♣ ♣

## ២៩០- រឿង ព្រះសារីបុត្រ

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធព្រះសារីបុត្រ ។ ព្រះថេរៈ បានចាំវស្សា ក្នុងវត្តដែលតាំងនៅជនបទ ព្រមជាមួយភិក្ខុ ៥០០ រូប ។*

*អ្នកស្រុកទាំងអស់ ដែលរស់នៅ ក្នុងទីនោះ បានស្រុះស្រួលបបួលគ្នា ប្រគេនសំពត់ចំណាំវស្សា ដល់ភិក្ខុទាំងអស់នោះ ។ លុះដល់ចេញវស្សាហើយ, ព្រះថេរៈ ប្រញាប់ប្រញាល់ចេញទៅ មុនគេ ហើយប្រាប់ ដល់ភិក្ខុសាមណេរ ដែលមានសេចក្តីត្រូវការសំពត់ចំណាំវស្សា ឲ្យនិមន្តទៅកាន់វត្តនោះ ។ ភិក្ខុទាំងឡាយ បានប្រជុំសន្ទនាគ្នាថា “ព្រះសារីបុត្រ ប្រហែលជានៅមានតណ្ហាទេដឹង?” ។*

*ព្រះសាស្តា ទ្រង់ស្តេចយាងមក ក្នុងទីប្រជុំនោះ ហើយទ្រង់ត្រាស់ពន្យល់ថា “ម្នាលភិក្ខុទាំងឡាយ ព្រះសារីបុត្រ មិនមានតណ្ហាលោក ប្រាប់យ៉ាងនេះ ព្រោះប្រាថ្នាជាបុណ្យកុសលដល់ពួកប្រជាជន*

*និង ប្រាថ្នានូវលោកដែលកើតឡើង ដោយធម៌ ដល់ភិក្ខុទាំងឡាយផង ដែរ" ដូច្នេះហើយ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

**អាសា យស្ស ន វិជ្ជន្តិ អស្មឹ លោកេ បរម្ហិ ច**
**និរាសាយំ វិសំយុត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។**

*បុគ្គលណា មិនមានសេចក្តីប្រាថ្នា ក្នុងលោកនេះផង ក្នុងលោកខាងមុខផង តថាគត ហៅបុគ្គលនោះ ដែលមិនមានសេចក្តីប្រាថ្នា ដែលរួចផុតស្រឡះ ចាកកិលេសហើយ ថា ជាព្រាហ្មណ៍ ។*

## ២៩១- រឿង ព្រះមហាមោគ្គល្លានត្ថេរ

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវព្រះមហាមោគ្គល្លាន ។ រឿងនេះ ដូចគ្នានឹងរឿង របស់ព្រះសារីបុត្រដែរ ។*

*ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

**យស្សាលយា ន វិជ្ជន្តិ អញ្ញាយ អកថំកថី**
**អមតោគធំ អនុប្បត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។**

*បុគ្គលណា មិនមានសេចក្តីអាល័យ គឺតណ្ហា មិនមានសេចក្តីសង្ស័យ ក្នុងអ្វីសោះ ព្រោះដឹងច្បាស់ធម៌ តថាគត ហៅបុគ្គលនោះ ដែលមានចិត្តចុះស៊ប់កាន់ព្រះនិព្វាន ដែលមានព្រះអរហត្តផល ដល់ហើយ ដោយលំដាប់ ថា ជាព្រាហ្មណ៍ ។*

❇ ❇ ❇

## ២៩២- រឿង ព្រះរេវតត្ថេរ

-៤៣៣-

គាថាធម្មបទប្រែ

*ព្រះបរមសាស្ដា ទ្រង់ប្រារព្ធនូវព្រះរេវតត្ថេរ ។ ថ្ងៃមួយ ភិក្ខុទាំងឡាយ បានពោលសរសើរ ថា "ព្រះរេវតៈ ជាអ្នកមានបុណ្យច្រើន បានធ្វើកុដិ ៥០០ ខ្នង សម្រាប់ជ្រកដល់ភិក្ខុ ៥០០ រូប" ។*

*ព្រះសម្មាសម្ពុទ្ធ ស្ដេចយាងមកហើយ ទ្រង់ត្រាស់ ថា "ម្នាលភិក្ខុទាំងឡាយ បុត្រ របស់តថាគត មិនមានបុណ្យ មិនមានបាបទេ បានលះបង់បុណ្យ និង បាបអស់ហើយ" ដូច្នេះហើយ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

យោធ បុញ្ញញ្ច បាបញ្ច ឧភោ សង្គំ ឧបច្ចគា
អសោកំ វិរជំ សុទ្ធំ តមហំ ព្រូមិ ព្រាហ្មណំ ។

*បុគ្គលណា ក្នុងលោកនេះ លះបង់បុណ្យ និង បាបទាំង ២ និង កិលេសជាគ្រឿងជាប់ជំពាក់ (មានរាគៈជាដើម)ចេញហើយ តថាគត ហៅបុគ្គលនោះ ដែលជាអ្នកមិនមានសេចក្ដីសោក មានធូលី គឺកិលេស អស់ហើយ ជាអ្នកបរិសុទ្ធ ថា ជាព្រាហ្មណ៍ ។*

♣ ♣ ♣

២៩៣- រឿង ព្រះចន្ទាភត្ថេរ

*ព្រះបរមសាស្ដា ទ្រង់ប្រារព្ធព្រះចន្ទាភត្ថេរ ។ ក្នុងសាសនានៃព្រះពុទ្ធព្រះនាមកស្សបទសពល, ព្រះថេរៈ បានបូជាព្រះចេតិយដោយចន្ទន៍ក្រហម ក្នុងសាសនានេះ លោកបានកើត ក្នុងត្រកូលព្រាហ្មណ៍មហាសាល មានរស្មីភ្លឺចេញពីផ្ចិត ដូចមណ្ឌលព្រះចន្ទ ។*

*ព្រាហ្មណ៍ទាំងឡាយ បាននាំចន្ទាភព្រាហ្មណ៍ ទៅឃោសនា*

## រឿង ព្រះចន្ទាភត្ថេរ

បោកបញ្ឆោតពួកប្រជាជនថា “បើបុគ្គលណា បានចាប់ស្ទាបអង្អែលរាងកាយ របស់ចន្ទាភព្រាហ្មណ៍ ដោយដៃខ្លួនឯងហើយ បុគ្គលនោះនឹងបានទទួលនូវសម្បត្តិយ៉ាងនេះ យ៉ាងនោះ” ដូច្នេះហើយ ក៏បានធ្វើដំណើរទៅ ដោយលំដាប់ រហូតដល់ទីក្រុងសាវត្ថី បានជួបប្រទះនឹងព្រះអរិយសាវ័កទាំងឡាយហើយ និយាយអួតអាងនូវអានុភាពរបស់ចន្ទាភព្រាហ្មណ៍ ប្រាប់ដល់ព្រះអរិយសាវ័កទាំងនោះ ។

ព្រះអរិយសាវ័កទាំងនោះ បានពោលសរសើរអំពីអានុភាពរបស់ព្រះបរមសាស្តា ។ ជនទាំងពីរក្រុមនេះ បានប្រកែក ជជែកគ្នាមិនចេះដាច់ស្រេចសោះ ហើយនាំចន្ទាភព្រាហ្មណ៍ ទៅគាល់ព្រះសម្មាសម្ពុទ្ធ ។

ពេលដែលចន្ទាភព្រាហ្មណ៍ ចូលទៅដល់សំណាក់នៃព្រះពុទ្ធជាម្ចាស់នោះ, រស្មី របស់គាត់ ក៏បានបាត់រលត់ ចេញពីផ្ចិតអស់ទៅ, ពេលដែលចន្ទាភព្រាហ្មណ៍ ចេញមកខាងក្រៅ, រស្មី ក៏ត្រឡប់មកស្ថិតនៅ ត្រង់ផ្ចិតដូចដើមវិញ, ចន្ទាភព្រាហ្មណ៍ បានធ្វើការសាកល្បងមើលអស់រយៈ ពេល ៣ ដង ហើយមានសេចក្តីអស្ចារ្យ យ៉ាងខ្លាំង គិតក្នុងចិត្ត ថា “ព្រះសមណៈរូបនេះ ពិតជាចេះមន្តអាគម ដែលធ្វើឲ្យរស្មី របស់ខ្លួនវិនាស” ទើបបានក្រាបថ្វាយបង្គំ សុំរៀននូវមន្តអាគម ជាមួយនឹងព្រះពុទ្ធជាម្ចាស់ ។

ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ ថា “បើអ្នកចូលមកបួស នៅក្នុងសំណាក់នៃតថាគត, តថាគត នឹងឲ្យអ្នករៀនមន្តអាគមនោះបាន” ។

## គាថាធម្មបទប្រែ

ចន្ទាភព្រាហ្មណ៍ បានបួសជាភិក្ខុ ក្នុងព្រះពុទ្ធសាសនា តាមព្រះពុទ្ធដីកា មិនយូរប៉ុន្មាន ក៏បានសម្រេចព្រះអរហត្តផល ។

ចំណែកពួកព្រាហ្មណ៍ដែលនាំចន្ទាភព្រាហ្មណ៍ មកគាល់ព្រះពុទ្ធជាម្ចាស់នោះ នៅរង់ចាំឲ្យចន្ទាភព្រាហ្មណ៍ រៀនមន្តអាគម យូរពេក ក៏នាំគ្នា ជួយជាស់តឿន សាកសួរអំពីការរៀនមន្តអាគម នឹងចន្ទាភព្រាហ្មណ៍ ថា "តើអ្នកបានរៀន នូវមន្តអាគមនោះ ចប់ហើយឬនៅ?" ។

ព្រះចន្ទាភត្ថេរ ឆ្លើយថា "ឥឡូវនេះ អាត្មាភាព មានធម៌ជាគ្រឿងកកក្តៅចិត្ត កើតឡើងហើយ អាត្មាភាព មិនត្រឡប់ទៅវិញបានទេ" ។

ភិក្ខុទាំងឡាយ បានចោទព្រះថេរៈថា "លោកពោលអួតព្រះអរហត្តផល" ហើយយករឿងនោះ ទៅក្រាបទូល ដល់ព្រះសាស្ដាទ្រង់ជ្រាប ។

ព្រះសាស្ដាចារ្យ ទ្រង់ត្រាស់ជានា ថា "ព្រះចន្ទាភត្ថេរ ពោលត្រឹមត្រូវហើយ" ដូច្នេះហើយ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

**ចន្ទំវ វិមលំ សុទ្ធំ វិប្បសន្នមនាវិលំ**
**នន្ទិភវបរិក្ខីណំ តមហំ ព្រូមិ ព្រាហ្មណំ ។**

តថាគត ហៅបុគ្គលដែលមិនមានសេចក្ដីសៅហ្មង ដូចជាព្រះចន្ទ ប្រាសចាកមន្ទិល ជាអ្នកបរិសុទ្ធ មានចិត្តជ្រះថ្លា មិនកករល្អក់ អស់សេចក្ដីត្រេកអរ ក្នុងភពហើយនោះ ថា ជាព្រាហ្មណ៍ ។

## ២៩៤- រឿង ព្រះសីវលី

ព្រះបរមសាស្ដា ទ្រង់ប្រារព្ធនូវព្រះសីវលីថេរៈ ជាបុត្ររបស់នាងសុប្បវាសា ។ ព្រះថេរៈ បានជាប់នៅ ក្នុងផ្ទៃមាតា អស់រយៈពេល ៧ ឆ្នាំ ៧ ខែ ៧ ថ្ងៃ ទើបបានប្រសូតចេញមក ព្រោះបុព្វកម្ម ពីអតីតជាតិ ដែលលោកធ្លាប់បានកើតជាក្សត្រ បានលើកកងទ័ព ទៅឡោមព័ទ្ធនគរមួយ អស់រយៈពេល ៧ ឆ្នាំ ៧ ខែ ៧ ថ្ងៃ ។ ក្នុងគ្រានោះឯង ព្រះនាង សុប្បវាសា បានកើតជាព្រះជននី ទ្រង់ប្រើឲ្យព្រះរាជបុត្រ របស់ព្រះនាង បិទទ្វារព្រះនគរ មិនឲ្យពួកមនុស្សចេញមកខាងក្រៅបាន ។

ពួកប្រជាជន បានសម្លាប់ព្រះរាជា របស់ខ្លួនចោល ហើយលើកព្រះនគរ ថ្វាយដល់ព្រះរាជបុត្រ របស់ព្រះនាងសុប្បវាសា ។ ព្រោះកម្មនោះឲ្យផល ទើបមកដល់ជាតិនេះ ព្រះនាងសុប្បវាសា ជាព្រះមាតា បានទទួលទុក្ខវេទនា យ៉ាងខ្លាំងក្លា ហើយទ្រង់ព្រះចិន្ដា ថា "ព្រះសាស្ដាចារ្យ ទ្រង់សម្ដែងធម៌ ដើម្បីលះបង់សេចក្ដីទុក្ខបាន ព្រះសង្ឃប្រព្រឹត្តប្រតិបត្តិធម៌ ដើម្បីលះបង់សេចក្ដីទុក្ខបាន ព្រះនិព្វានជាសុខពិត" យ៉ាងដូច្នេះហើយ ទើបឲ្យព្រះស្វាមីទៅគាល់ព្រះសាស្ដា ដើម្បីក្រាបទូលសុំព្រះពរ ។

ពេលដែលព្រះពុទ្ធជាម្ចាស់ ទ្រង់ប្រទានព្រះពរហើយ, ព្រះនាងសុប្បវាសា ទ្រង់បានប្រសូតព្រះរាជបុត្រ ដោយសុវត្ថិភាព ។ ក្នុងពេលជាមួយគ្នានោះដែរ ព្រះនាងទ្រង់បានថ្វាយមហាទាន ដល់ព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន អស់រយៈពេល ៧ ថ្ងៃ ។

-៤៣៧-

គាថាធម្មបទប្រែ

ព្រះរាជបុត្រ ដែលបានប្រសូតមក ក្នុងថ្ងៃនោះ បានជួយគ្រង ទឹក ប្រគេនព្រះសង្ឃ ក្នុងពិធីបុណ្យនោះដែរ, ក្រោយមក ក៏បាន ចេញទៅបួសជាភិក្ខុ ហើយបានសម្រេចអរហត្តផល ក្នុងទីបំផុត ។

សម័យថ្ងៃមួយ ពួកភិក្ខុទាំងឡាយ បានសន្ទនាគ្នាអំពីរឿង ព្រះសីវលី ថា "ភិក្ខុដែលដល់នូវឧបនិស្ស័យនៃព្រះអរហន្ត ក៏នៅតែ ទទួលទុក្ខវេទនា យ៉ាងដូច្នេះដែរ" ។

ព្រះសម្មាសម្ពុទ្ធ ស្តេចយាងមក ក្នុងទីប្រជុំនោះ ទ្រង់បាន ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ បុត្ររបស់តថាគត បាន រួចផុតពីសេចក្តីទុក្ខហើយ" ហើយទ្រង់ត្រាស់ នូវព្រះគាថានេះ ថា ៖

យោ ឥមំ បលិបថំ ទុគ្គំ  សំសារំ មោហមច្ចគា
តិណ្ណោ បារគតោ ឈាយី  អនេជោ អកថំកថី
អនុបាទាយ និព្វុតោ  តមហំ ព្រូមិ ព្រាហ្មណំ ។

បុគ្គលណា កន្លងផ្លូវវាង គឺរាគៈ និង ភក់ ដែលគេឆ្លងបាន ដោយកម្រ គឺកិលេស និងសង្សារវដ្ត និងមោហៈទាំងនេះបាន ជាអ្នក ឆ្លងអន្លង់ទាំងបួន បានដល់ត្រើយគឺព្រះនិព្វាន ជាអ្នកមានឈាន មិន ញាប់ញ័រ ដោយតណ្ហា មិនមានសេចក្តីសង្ស័យ មិនប្រកាន់មាំ ជា អ្នករលត់កិលេសហើយ តថាគត ហៅបុគ្គលនោះថា ជាព្រាហ្មណ៍ ។

♣ ♣ ♣

២៩៥- រឿង ព្រះសុន្ទរសមុទ្ទ

ព្រះបរមសាស្តាចារ្យ ទ្រង់ប្រារព្ធនូវព្រះសុន្ទរសមុទ្ទ ជាបុត្រ

របស់ត្រកូលស្តុកស្តម្ភ មួយ ក្នុងក្រុងសាវត្ថី ។ ថ្ងៃមួយ បុត្រនោះ បានឃើញប្រជាជនជាច្រើននាំគ្នាទៅវត្ត ដើម្បីស្តាប់ព្រះធម៌ទេសនា របស់ព្រះសម្មាសម្ពុទ្ធ ហើយបានធ្វើដំណើរទៅ ជាមួយប្រជាជនទាំង នោះ លុះបានស្តាប់ព្រះធម៌ទេសនាហើយ ក៏មានចិត្តជ្រះថ្លា សប្បាយ រីករាយ ប្រាថ្នាចង់បួស ក្នុងព្រះពុទ្ធសាសនា ពេលត្រឡប់មកផ្ទះវិញ ក៏បានសុំអនុញ្ញាត អំពីមាតាបិតា ដើម្បីលាចេញទៅបួសជាភិក្ខុ លុះ បួសរួចហើយ ក៏បានទៅគង់ចាំវស្សា ក្នុងទីក្រុងរាជគ្រឹះ ។

មាតាបិតា មានសេចក្តីទឹករពួក ស្រណោះ អាឡោះអាល័យ ដល់កូនដែលចេញទៅបួសខ្លាំងណាស់ ប្រាថ្នាចង់ឲ្យលោកកូនលា ចាកសិក្ខាបទ មកជាគ្រហស្ថ គ្រប់គ្រងផ្ទះសម្បែងវិញ ។

ក្នុងគ្រានោះឯង មានស្រីផ្កាមាសម្នាក់ បានស្ម័គ្រខ្លួនទទួលថា នឹងទៅ លួងលោមឲ្យព្រះថេរៈ លាចាកសិក្ខាបទ ឲ្យទាល់តែបាន ហើយបានទៅនៅផ្ទះដែលព្រះថេរៈ ធ្លាប់និមន្តទៅបិណ្ឌបាត ហើយ បានចាត់ចែងចង្ហាន់បិណ្ឌបាតប្រគេន ដល់ព្រះថេរៈ រហូតដល់មាន ការជិតស្និទ្ធគ្នាហើយ ទើបនិមន្តព្រះថេរៈ ឲ្យឡើងទៅលើផ្ទះជាន់ខាង លើ ហើយបានសម្តែងមាយាស្ត្រី ៤០ ប្រការ មានការញាក់ចិញ្ចើម សើយនូវសំពត់ជាដើម បង្ហាញដល់ព្រះថេរៈ ។

ព្រះថេរៈ បានឃើញនូវមាយាស្ត្រី ដែលមិនសមគួរ ដល់ សមណៈ យ៉ាងនេះហើយ ក៏មានសតិស្មារតី ដឹងខ្លួនភ្លាម ហើយមាន ការសង្វេគ តក់ស្លុតចិត្ត យ៉ាងខ្លាំង ចំពោះស្រីផ្កាមាសនោះ ។

## គាថាធម្មបទប្រែ

គ្រានោះ ព្រះសម្មាសម្ពុទ្ធ ទ្រង់ជ្រាបវារចិត្ត របស់ព្រះសុន្ទរសមុទ្ទ ហើយ ទ្រង់ត្រាស់នឹងព្រះអានន្ទ ថា "ម្នាលអានន្ទ សង្គ្រាម របស់ព្រះសុន្ទរសមុទ្ទ និង ស្រីផ្កាមាស កំពុងតែប្រព្រឹត្តទៅ" ។

ព្រះអានន្ទត្ថេរ បានក្រាបទូលសួរ ថា "បពិត្រព្រះអង្គដ៏ចំរើន បណ្ដាអ្នកទាំងពីរនាក់នោះ តើអ្នកណាឈ្នះ អ្នកណាចាញ់?" ។

ព្រះសាស្ដា ទ្រង់ត្រាស់ថា "ម្នាលអានន្ទ ព្រះសុន្ទរសមុទ្ទ ជាអ្នកទទួលជ័យជំនះ ចំណែកឯស្រីផ្កាមាស គឺជាអ្នកបរាជ័យ" ហើយ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

**យោធ កាមេ បហន្ត្វាន អនាគារោ បរិព្វជេ**
**កាមភវបរិក្ខីណំ តមហំ ព្រូមិ ព្រាហ្មណំ ។**

បុគ្គលណា ក្នុងលោកនេះ បានលះបង់កាមទាំងឡាយ ជាអ្នកមិនមានផ្ទះ គេចចេញចាកកាមបាន តថាគត ហៅបុគ្គលនោះ ដែលអស់កាមកតហើយ ថា ជាព្រាហ្មណ៍ ។

### ២៩៦- រឿង ព្រះជោតិកត្ថេរ

ព្រះបរមសាស្ដា ទ្រង់បានប្រារព្ធនូវព្រះជដិលត្ថេរ និង ព្រះជោតិកត្ថេរ ។ ក្នុងពេលដែលព្រះថេរៈទាំងពីរនោះ នៅជាគ្រហស្ថ, ជាមហាសេដ្ឋីទាំងពីរនាក់ ជាអ្នកបានបំពេញបុណ្យកុសល ជាច្រើន ក្នុងអតីតជាតិ ។

ជដិលសេដ្ឋី មានភ្នំមួយសុទ្ធតែមាស ប្រវែង ៨០ ហាត់ កើត

ឡើង ដោយខ្លួនឯង នៅឯខាងក្រោយផ្ទះ, បើពេលណា គាត់ត្រូវការ ចង់បានមាស គាត់ក៏បានចាប់យកចបជីក ទៅជីកយកមាសនោះ មក ប្រើប្រាស់ តាមសេចក្តីត្រូវការ នៅពេលនោះឯង ។ ទីកន្លែងមាស ដែលគាត់បានជីកហើយ ក៏បានត្រឡប់ពេញដូចដើមវិញ ។

ជដិលសេដ្ឋី ជាអ្នកមានសេចក្តីជ្រះថ្លា ក្នុងព្រះពុទ្ធសាសនា យ៉ាងខ្លាំង ប្រាថ្នាចង់ចេញទៅបួស ហើយបានចែកទ្រព្យសម្បត្តិ ឲ្យ ដល់កូន ៣ នាក់ បានទូន្មានអប់រំកូនទាំងបីនោះ ឲ្យតម្កល់ខ្លួន នៅក្នុង គុណធម៌ដ៏ត្រឹមត្រូវ ហើយបានចេញទៅបួស ក្នុងសំណាក់ នៃព្រះ សាស្តា មិនយូរប៉ុន្មាន ក៏បានសម្រេចព្រះអរហត្តផល ។

សម័យថ្ងៃមួយ ព្រះសម្មាសម្ពុទ្ធ ព្រមទាំងភិក្ខុសង្ឃ បាននិមន្ត ទៅទទួលភត្តាហារ នៅឯផ្ទះរបស់កូនព្រះជដិលត្ថេរនោះ ។

ភិក្ខុទាំងឡាយ បានសួរព្រះជដិលត្ថេរ ថា "សេចក្តីត្រូវការ ក្នុង ភ្នំមាស និងក្នុងបុត្រទាំងឡាយ តើមាន ក្នុងសន្តានចិត្ត របស់លោក ម្ចាស់ ដែរឬទេ?" កាលព្រះថេរៈ ឆ្លើយថា "មិនមានទេ" យ៉ាងនេះ ហើយ ទើបចោទព្រះថេរៈ ថា "ពោលអួតព្រះអរហត្តផល" ហើយ នាំយករឿងនោះ ទៅក្រាបទូល ដល់ព្រះសាស្តាទ្រង់ជ្រាប ។

ព្រះសាស្តា ទ្រង់ជ្រាបហើយ ទ្រង់ត្រាស់នូវព្រះគាថានេះថា ៖

**យោធ តណ្ហំ បហន្ត្វាន   អនាគារោ បរិព្វជេ**
**តណ្ហាភវបរិក្ខីណំ   តមហំ ព្រូមិ ព្រាហ្មណំ ។**

បុគ្គលណា ក្នុងលោកនេះ លះបង់តណ្ហាបានហើយ ជាអ្នក

មិនមានផ្ទះ គេចចេញចាកតណ្ហាបាន តថាគត ហៅបុគ្គលនោះ ដែលអស់តណ្ហា និង ភព ហើយ ថា ជាព្រាហ្មណ៍ ។

ចំណែកឯ ជោតិកសេដ្ឋី មានប្រាសាទ ៧ ជាន់ សុទ្ធតែកសាងអំពីកែវ ៧ ប្រការ ប្រកបដោយកំពែង ៧ ជាន់ មានទ្វារ ៧ មានកំណាប់ទ្រព្យ៤ កន្លែង បានផុសឡើងនៅតាមជ្រុងប្រាសាទ មានដើមកប្បព្រឹក្ស ដុះឡើង នៅជិតជ្រុងកំពែង ។ ក្នុងពេលរាត្រី មិនពិបាកដុតភ្លើងចង្កៀងប្រទីបឡើយ ព្រោះភ្លឺឯង ដោយពន្លឺនៃកែវ ៧ ប្រការនោះ ដែលសម្រេច ដោយបុញ្ញានុភាពរបស់ខ្លួន ។

ព្រះបាទអជាតសត្រូវ មានព្រះបំណង ចង់បានទ្រព្យសម្បត្តិរបស់ជោតិកសេដ្ឋី ទើបលើកកងព័ទ ទៅឡោមព័ទ្ធ នូវប្រាសាទនោះ ទ្រង់ទតព្រះនេត្រឃើញកងទ័ព របស់ព្រះអង្គ ស្ថិតនៅ ត្រង់កំពែងកែវនៃប្រាសាទហើយ បានស្លុតព្រះទ័យយ៉ាងខ្លាំង ទ្រង់មានព្រះសតិស្មារតី ជ្រាបទាន់ពេលវេលា ទើបបានប្រមូលកងទ័ពវិលត្រឡប់ទៅកាន់ព្រះបរមរាជវាំង របស់ព្រះអង្គវិញ ហើយទ្រង់ស្ដេចយាងទៅកាន់វត្តជេតពន ទ្រង់ទតព្រះនេត្រឃើញជោតិកសេដ្ឋី កំពុងតែគាល់ព្រះសាស្ដា ក្នុងវត្តជេតពននោះ ។

ជោតិកសេដ្ឋី បានដឹងព្រះរាជបំណង របស់ព្រះបាទអជាតសត្រូវ ហើយ ទើបក្រាបទូលថា “បពិត្រព្រះមហារាជ ទ្រព្យសម្បត្តិណាមួយ ដែលទូលព្រះបង្គំ មិនទាន់បានអនុញ្ញាតឲ្យហើយ បុគ្គលបែបណា ក៏ដោយ ក៏មិនអាចយកទៅបានឡើយ” ។

-៤៤២-

## រឿង ព្រះជោតិកត្ថេរ

ព្រះបាទអជាតសត្រូវ ទ្រង់មិនជឿជោតិកសេដ្ឋីឡើយ ។ សេដ្ឋីដឹងដូច្នោះហើយ បានក្រាបទូលឲ្យព្រះរាជា ដោះចិញ្ចៀន ដែលពាក់ជាប់នៅនឹងដៃរបស់ខ្លួន ។ ព្រះរាជា មិនអាចដោះចិញ្ចៀន ចេញពីដៃរបស់ជោតិកសេដ្ឋីបានឡើយ ទាន់តែសេដ្ឋីអនុញ្ញាតឲ្យហើយ ទើបអាចដោះបាន ។

ជោតិកសេដ្ឋី ឃើញព្រះបាទអជាតសត្រូវ កំពុងតែឈ្លក់វង្វេងក្នុងកិលេសតណ្ហាយ៉ាងនេះហើយ ក៏កើតសេចក្តីតក់ស្លុត យ៉ាងខ្លាំង បានក្រាបទូលសុំបព្វជ្ជាឧបសម្បទចំពោះព្រះសម្មាសម្ពុទ្ធ ក្នុងខណៈនោះឯង លុះឧបសម្បទហើយ មិនយូរប៉ុន្មានឡើយ ក៏បានសម្រេចព្រះអរហត្តផល ។

ទ្រព្យសម្បត្តិ ដែលបានកើតឡើង សម្រាប់ជោតិកសេដ្ឋីនោះ ក៏វិនាសបាត់អស់ទៅ ក្នុងពេលជាមួយគ្នានោះដែរ ។

ភិក្ខុទាំងឡាយ បានសួរព្រះជោតិកត្ថេរថា "តើលោកម្ចាស់មានសេចក្តីអាឡោះអាល័យ សោកស្តាយ ចំពោះទ្រព្យសម្បត្តិទាំងអស់នោះដែរឬទេ?" កាលព្រះថេរៈ ឆ្លើយថា "មិនមានទេ" ទើបចោទព្រះថេរៈថា "ពោលអួតព្រះអរហត្តផល" ហើយនាំយករឿងនោះទៅក្រាបទូល ដល់ព្រះសាស្តាទ្រង់ជ្រាប ។

ព្រះសាស្តា ទ្រង់ជ្រាបហើយ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

យោធ តណ្ហំ បហន្ទាន អនាគារោ បរិព្វជេ
តណ្ហាភវបរិក្ខីណំ តមហំ ព្រូមិ ព្រាហ្មណំ ។

-៤៤៣-

គាថាធម្មបទប្រែ

*បុគ្គលណា ក្នុងលោកនេះ លះបង់តណ្ហាបានហើយ ជាអ្នកមិនមានផ្ទះ គេចចេញចាកតណ្ហាបាន តថាគត ហៅបុគ្គលនោះ ដែលអស់តណ្ហា និងភព ហើយ ថា ជាព្រាហ្មណ៍ ។*

♣ ♣ ♣

២៩៧- រឿង ព្រះបឋមនដបុព្វកត្ថេរ

*ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវព្រះថេរៈមួយអង្គ ដែលធ្លាប់បានធ្វើជាតួឯកល្ខោន ។ ក្នុងពេលដែលលោកនៅជាគ្រហស្ថ ព្រះថេរៈ បានស្តាប់ព្រះធម៌ទេសនា របស់ព្រះសាស្តា ហើយ ក៏មានចិត្តជ្រះថ្លា បានបួសជាភិក្ខុ រហូតបានសម្រេចព្រះអរហត្តផល ។*

*ថ្ងៃមួយ ព្រះថេរៈ បាននិមន្តទៅបិណ្ឌបាត ជាមួយព្រះសង្ឃមានព្រះពុទ្ធជាប្រធាន បានឃើញកូន របស់អ្នកលេងរបាំម្នាក់ ។*

*គ្រានោះឯង ភិក្ខុទាំងឡាយ បានសួរព្រះថេរៈ ថា "តើលោកម្ចាស់ នៅមានចិត្តរីករាយសប្បាយ ក្នុងការលេងរបាំ ដូចជាបុរសនោះដែរឬទេ?" កាលព្រះថេរៈ ឆ្លើយថា "មិនមានទេ" ទើបចោទព្រះថេរៈ ថា "ពោលអួតព្រះអរហត្តផល" ហើយ ក៏នាំយករឿងនោះ ទៅក្រាបទូល ដល់ព្រះសាស្តាទ្រង់ជ្រាប ។*

*ព្រះសាស្តា ទ្រង់ជ្រាបហើយ ត្រាស់នូវព្រះគាថានេះ ថា ៖*

ហិត្វា មានុសកំ យោគំ ទិព្វំ យោគំ ឧបច្ចគា
សព្វយោគវិសំយុត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។

*បុគ្គលណា លះបង់កិលេស ដែលជាគ្រឿងប្រកប ដែលជា*

របស់មនុស្ស  កន្លងនូវកិលេសជាគ្រឿងប្រកប  ដែលជារបស់ទិព្វបានហើយ តថាគត ហៅបុគ្គលដែលផុតស្រឡះចាកកិលេស គ្រឿងប្រកបទាំងពួងនោះ ថា ជាព្រាហ្មណ៍ ។

✿ ✿ ✿

## ២៩៨- រឿង ព្រះឧត្តិយនជបុត្តកត្ថេរ

ព្រះបរមសាស្តា ទ្រង់ប្រារព្ធនូវព្រះថេរៈ មួយអង្គទៀត ដែលធ្លាប់លេងរបាំល្ខោន  ដូចរឿងព្រះបឋមនជបុត្តកត្ថេរនោះដែរ  ដែលមានមកហើយ ខាងលើនោះស្រាប់ ។

ព្រះសាស្តាចារ្យ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖

**ហិត្វា  រតិញ្ច  អរតិញ្ច   សីតិភូតំ  និរូបធឹ**
**សព្វលោកាភិភុំ  វីរំ       តមហំ  ព្រូមិ  ព្រាហ្មណំ ។**

តថាគត  ហៅបុគ្គលដែលលះបង់សេចក្តីត្រេកអរ  (ក្នុងកាមគុណ) និងសេចក្តីមិនត្រេកអរបានហើយ ជាអ្នកមានចិត្តត្រជាក់ មិនមានឧបធិកិលេស  គ្របសង្កត់លោកទាំងពួងបានហើយ  ជាអ្នកអង់អាចក្លាហាននោះ ថា ជាព្រាហ្មណ៍ ។

❋ ❋ ❋

## ២៩៩- រឿង ព្រះវង្គីសត្ថេរ

ព្រះបរមសាស្តា  ទ្រង់បានប្រារព្ធនូវព្រះវង្គីសត្ថេរ  ដែលជាព្រាហ្មណ៍ នៅអាស្រ័យក្នុងទីក្រុងរាជគ្រឹះ ។ ព្រះថេរៈ ជាអ្នកចេះដឹងមន្តអាគម គោះលលាដ៍ក្បាល  ហើយទាយដឹងច្បាស់ ថា  "នេះ គឺជា

លលាដ៍ក្បាល របស់បុគ្គលដែលបានទៅកើត ក្នុងនរក, នេះ គឺជាលលាដ៍ក្បាល របស់បុគ្គលដែលបានទៅកើត នៅឯក្នុងទេវលោក” ប៉ុណ្ណេះជាដើម ។

ពួកព្រាហ្មណ៍ទាំងឡាយ បាននាំវង្គីសព្រាហ្មណ៍នោះ ទៅធ្វើវិធីគោះលលាដ៍ក្បាល នៅតាមស្រុកតូចធំ និគមជនបទ ស្ទើរតែគ្រប់ច្រកល្ហកទាំងអស់ ។

មនុស្សទាំងឡាយ ដែលមានមាតាបិតា មីងមា ញាតិទាំង ៧ សន្តាន ដែលបានចែកឋានទៅហើយនោះ បានយកមាសប្រាក់ តាមកម្លាំងសទ្ធា របស់ខ្លួន ឲ្យវង្គីសព្រាហ្មណ៍នោះ គោះលលាដ៍ក្បាល របស់អ្នកទាំងនោះ ដើម្បីឲ្យដឹងថា “តើបុគ្គលទាំងនោះ បានទៅកើតក្នុងទីណាខ្លះ?” ។

វង្គីសព្រាហ្មណ៍ បានគោះនូវលលាដ៍ក្បាលទាំងនោះ មើលហើយ ដឹងច្បាស់ ថា “បុគ្គលនេះ បានទៅកើត ក្នុងទីនេះ ទីនោះ” ហើយបានចេញដំណើរទៅ តាមលំដាប់លំដោយ រហូតទៅដល់ក្រុងសាវត្ថី ក៏នៅឈប់សម្រាក ក្បែរវត្តជេតពន បានចួបប្រទះនឹងពួកអរិយសាវកទាំងឡាយ នៅក្នុងទីនោះ ។ ពួកព្រាហ្មណ៍ បានអួតសរសើរពីគុណសម្បត្តិ របស់វង្គីសព្រាហ្មណ៍ ថា “ជាអ្នកពូកែខ្លាំងណាស់” ។

ចំណែកពួកអរិយសាវក បានពោលអួតព្រះគុណ របស់ព្រះសម្មាសម្ពុទ្ធ ថា “ជាអ្នកខ្លាំងពូកែ” ដូចគ្នាដែរ ។

-៤៤៦-

រឿង ព្រះវង្គីសត្ថេរ

មនុស្សទាំងពីរក្រុមនោះ បានប្រកែកជជែកគ្នា មិនចេះដាច់ស្រេចសោះ ហើយបាននាំវង្គីសព្រាហ្មណ៍នោះ ទៅគាល់ព្រះសាស្តា ហើយបានក្រាបទូលរឿងនោះ ថ្វាយព្រះអង្គទ្រង់ជ្រាប ។

គ្រានោះឯង ព្រះសាស្តា ទ្រង់ត្រាស់ឲ្យគេយកលលាដ៍ក្បាលមនុស្សធម្មតា និង លលាដ៍នៃព្រះអរហន្ត ដើម្បីឲ្យវង្គីសព្រាហ្មណ៍ទាយ ។

វង្គីសព្រាហ្មណ៍ ក៏បានគោះនូវលលាដ៍ក្បាលមនុស្សធម្មតាហើយ ទាយត្រូវទាំងអស់ ឥតមានខុសឡើយ តែដល់គោះលលាដ៍ក្បាល របស់បុគ្គលដែលជាព្រះអរហន្ត ក៏មិនឃើញអ្វីសោះ ស្ងាត់សូន្យឈឹង មិនដឹងជាទៅកើត នៅក្នុងទីណាឡើយ ហើយបានក្រាបទូលសួរព្រះសាស្តាថា "បពិត្រព្រះអង្គដ៏ចំរើន តើព្រះអង្គទ្រង់ជ្រាបដែរឬទេ?" កាលព្រះអង្គត្រាស់ ថា "តថាគតដឹង" ទើបក្រាបទូលសុំរៀនមន្តអាគមនឹងព្រះអង្គ ។

ព្រះសម្មាសម្ពុទ្ធ ទ្រង់បានត្រាស់ ថា "បើអ្នកបួសជាភិក្ខុ ក្នុងសំណាក់តថាគត, តថាគត នឹងឲ្យអ្នករៀនមន្តអាគមនោះ" ។

វង្គីសព្រាហ្មណ៍ បានបួស តាមព្រះពុទ្ធដីកា ដើម្បីរៀនយកមន្តអាគម អំពីព្រះអង្គ ។

ព្រះសម្មាសម្ពុទ្ធ ទ្រង់បានប្រទាននូវកម្មដ្ឋាន ៣២ ប្រការ ឲ្យវង្គីសព្រាហ្មណ៍រៀនហើយត្រាស់ថា "នេះគឺជាបរិកម្មរបស់មន្តនុ៎ះ" ។

វង្គីសព្រាហ្មណ៍ បានធ្វើតាមព្រះពុទ្ធដីកា តាំងពីដើម របូត

ដល់ចប់ មិនយូរប៉ុន្មាន ក៏បានសម្រេចព្រះអរហត្តផល ។

ពួកព្រាហ្មណ៍ទាំងឡាយ ដែលនាំវង្គីសព្រាហ្មណ៍មកនោះ បានសួរ ថា "តើអ្នកបានរៀនមន្តនោះ ចប់សព្វគ្រប់ហើយឬនៅ?" ។

វង្គីសព្រាហ្មណ៍ បានឆ្លើយវិញ ថា "អាត្មាភាព មិនសមគួរនឹងត្រឡប់ទៅវិញទេ" ។

ពួកភិក្ខុទាំងឡាយ បានចោទព្រះថេរៈថា "ពោលអួតនូវព្រះអរហត្តផល" ដូច្នេះហើយ ក៏បាននាំយករឿងនោះ ទៅក្រាបទូលដល់ព្រះសាស្ដា ។

ព្រះសម្មាសម្ពុទ្ធ ទ្រង់ជ្រាបហើយ ត្រាស់នូវគាថានេះ ថា ៖

ចុតឹ យោ វេទិ សត្តានំ ឧបបត្តិញ្ច សព្វសោ
អសត្តំ សុគតំ ពុទ្ធំ តមហំ ព្រូមិ ព្រាហ្មណំ ។
យស្ស គតឹ ន ជានន្តិ ទេវា គន្ធព្វមានុសា
ខីណាសវំ អរហន្តំ តមហំ ព្រូមិ ព្រាហ្មណំ ។

បុគ្គលណា ដឹងច្បាស់នូវចុតិ និង បដិសន្ធិ របស់សត្វទាំងឡាយ ដោយអាការទាំងពួងបាន តថាគត ហៅបុគ្គលដែលជាអ្នកមិនជាប់ជំពាក់ ក្នុងកាម អ្នកមានដំណើរល្អ ដោយសេចក្ដីប្រតិបត្តិ អ្នកត្រាស់ដឹងនូវសច្ចៈ ៤ នោះ ថា ជាព្រាហ្មណ៍ ។

ទេវតា គន្ធព និង ពួកមនុស្សទាំងឡាយ មិនដឹងគតិ របស់បុគ្គលណា តថាគត ហៅបុគ្គល ដែលជាអ្នកមានអាសវៈអស់ហើយ ជាព្រះអរហន្តនោះ ថា ជាព្រាហ្មណ៍ ។

## ៣០០- រឿង នាងធម្មទិន្នាថេរី

*ព្រះបរមសាស្ដា ទ្រង់ប្រារព្ធនូវនាងធម្មទិន្នាថេរី ។ នៅពេលដែលនាងនៅជាគ្រហស្ថ, នាងជាភរិយា របស់វិសាខឧបាសក បានសុំការអនុញ្ញាតិអំពីស្វាមី ដើម្បីចេញទៅបួស លុះនាងបួសហើយ បានទៅបំពេញសមណធម៌ ក្នុងស្រុកជនបទមួយ មួយអន្លើដោយនាងភិក្ខុនីទាំងឡាយ មិនយូរប៉ុន្មាន ក៏បានសម្រេចអរហត្តផល ព្រមទាំងបដិសម្ភិទាទាំងឡាយ, ក្រោយមក នាងចង់ទៅជួយអនុគ្រោះដល់ពួកញាតិ របស់ខ្លួន ទើបបានត្រឡប់មកទីក្រុងរាជគ្រឹះវិញ ។*

*វិសាខឧបាសកជាស្វាមី ឃើញនាងត្រឡប់មកវិញ ក៏នឹកគិតថា "នាងប្រាកដជាចង់លាចាកសិក្ខាបទហើយ" ចង់សួរនាងត្រង់ៗ តែដូចជាមិនហ៊ានសួរទេ ទើបសួរជាបញ្ហាធម៌ ក្នុងសោតាបត្តិមគ្គ សកទាគាមិមគ្គ អនាគាមិមគ្គ ដែលខ្លួនបានសម្រេចហើយនោះ ។*

*នាងធម្មទិន្នាថេរី បានដោះស្រាយបញ្ហាធម៌នោះ រួចទាំងអស់ រហូតដល់ព្រះអរហត្តផល ។ វិសាខឧបាសក បានទៅក្រាបថ្វាយបង្គំព្រះសម្មាសម្ពុទ្ធជាម្ចាស់ហើយ ទូលធម្មីកថានោះ ដល់ព្រះអង្គ ។*

*ព្រះសាស្ដា ទ្រង់ត្រាស់ ថា "នាងធម្មទិន្នាថេរី បានវិសជ្ជនាត្រឹមត្រូវហើយ, បើអ្នកសួរតថាគត, ក៏តថាគត វិសជ្ជនាយ៉ាងដូច្នោះដែរ" ដូច្នេះហើយ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

**យស្ស បុរេ ច បច្ឆា ច មជ្ឈេ ច នត្ថិ កិញ្ចនំ**
**អកិញ្ចនំ អនាទានំ តមហំ ព្រូមិ ព្រាហ្មណំ ។**

*បុគ្គលណា មិនមានកង្វល់ ក្នុងកាលមុនផង ក្នុងកាលជាខាង*

ក្រោយផង ក្នុងកាលជាកណ្តាលផង តថាគត ហៅបុគ្គលដែលជាអ្នកមិនមានសេចក្តីកង្វល់ មិនប្រកាន់មាំនោះ ថា ជាព្រាហ្មណ៍ ។

♣ ♣ ♣

## ៣០៣-រឿង ព្រះអង្គុលិមាលត្ថេរ

ព្រះបរមសាស្តា ទ្រង់ប្រារព្ធព្រះអង្គុលិមាលត្ថេរ ។ ក្នុងថ្ងៃដែលព្រះបាទបសេនទិកោសល ទ្រង់ថ្វាយ នូវអសទិសទាននោះ, ព្រះអង្គ ទ្រង់បានឲ្យដំរីដែលស្លូតៗ ឈរបាំងស្វេតច្ឆត្រ ប្រគេនព្រះភិក្ខុសង្ឃ ។ ដំរីដែលស្លូតៗ នោះ នៅខ្វះតែមួយក្បាលទៀតប៉ុណ្ណោះ, ដំរីដែលនៅសល់ សុទ្ធតែជាដំរីចុះប្រេង កាចសាហាវទាំងអស់ ។

ព្រះរាជា ទ្រង់បានប្រឹក្សា ជាមួយនឹងព្រះនាងមល្លិកាទេវី ។ ព្រះនាងមល្លិកាទេវី បានក្រាបទូល ថា "បពិត្រព្រះស្វាមី បើដំរីដែលស្លូតៗ មិនមានហើយ ត្រូវតែយកដំរី ដែលកាចសាហាវមកប្រើការជំនួស ប៉ុន្តែព្រះអង្គ ត្រូវយកដំរីដែលកាចសាហាវនោះ ឲ្យឈរកាន់ស្វេតច្ឆត្រ បាំងព្រះអង្គុលិមាលត្ថេរ ទើបជាការប្រសើរ" ។ ព្រះរាជាទ្រង់បានធ្វើតាមព្រះនាងមល្លិកាទេវីទាំងអស់ ។

ដំរី ដែលកាចសាហាវនោះ គ្រាន់តែឃើញព្រះអង្គុលិមាល-ត្ថេរ ក៏ត្រឡប់ជាសត្វស្លូតបូតត្រឹមត្រូវ មិនកាចសាហាវ ដូចមុនទៀតឡើយ ។

ភិក្ខុទាំងឡាយ ឃើញដូច្នោះហើយ សួរនូវព្រះថេរៈ ថា "ព្រះគុណម្ចាស់ ឃើញដំរីដែលកាចសាហាវ ឈរបាំងស្វេតច្ឆត្រឲ្យនោះ

តើមានការភ័យខ្លាចដែរឬទេ?" កាលបើព្រះថេរៈ ឆ្លើយថា "ខ្ញុំ មិនភ័យខ្លាចទេ" ដូច្នេះហើយ ទើបចោទព្រះថេរៈថា "ពោលអួតនូវព្រះអរហត្តផល" ហើយ បាននាំយករឿងនោះ ទៅក្រាបទូល ដល់ព្រះសាស្តាទ្រង់ជ្រាប ។

ព្រះសាស្តា ទ្រង់ជ្រាបហើយ ត្រាស់ពន្យល់ដល់ភិក្ខុទាំងនោះកុំឲ្យយល់ច្រឡំ ហើយត្រាស់នូវព្រះគាថានេះ ថា ៖

**ឧសភំ បវរំ វីរំ មហេសឹ វិជិតាវិនំ**
**អនេជំ នហាតកំ ពុទ្ធំ តមហំ ព្រូមិ ព្រាហ្មណំ ។**

តថាគត ហៅវីរបុរស អ្នកអង់អាច អ្នកប្រសើរ អ្នកស្វែងរកគុណដ៏ធំ ជាអ្នកឈ្នះមារ មិនមានកិលេសគ្រឿងញាប់ញ័រ លាងកិលេសជ្រះអស់ហើយ ជាអ្នកត្រាស់ដឹងសច្ចៈនោះថាជាព្រាហ្មណ៍។

❇ ❇

៣០២- រឿងទេវហិតព្រាហ្មណ៍

ព្រះបរមសាស្តា ទ្រង់ប្រារព្ធបញ្ហារបស់ទេវហិតព្រាហ្មណ៍ ។ ព្រាហ្មណ៍នេះ បានថ្វាយនូវភេសជ្ជៈ ដល់ព្រះសាស្តា ក្នុងគ្រាដែលព្រះអង្គទ្រង់ព្រះប្រឈួន ដោយព្រះវាយោ, កាលបើព្រះអង្គ ទ្រង់បាត់ព្រះប្រឈួនហើយ, ទើបក្រាបទូល ថា "បពិត្រព្រះអង្គ ដ៏ចំរើនតើថ្វាយនូវទេយ្យធម៌ ដល់បុគ្គលបែបណា ទើបបាននូវផលានិសង្សច្រើន?" ។

ព្រះសាស្តា ទ្រង់បានត្រាស់ថា "ម្នាលព្រាហ្មណ៍ ថ្វាយដល់

*បុគ្គលជាព្រាហ្មណ៍នោះឯង ទើបបានផលានិសង្សនោះច្រើន” ដូច្នេះហើយ ទ្រង់ត្រាស់នូវព្រះគាថានេះ ថា ៖*

**បុព្វេនិវាសំ យោ វេទិ សគ្គាបាយញ្ច បស្សតិ**
**អថោ ជាតិក្ខយំ បត្តោ អភិញ្ញា វោសិតោ មុនិ**
**សព្វវោសិតវោសានំ តមហំ ព្រូមិ ព្រាហ្មណំ ។**

*បុគ្គលណាដឹងច្បាស់នូវខន្ធបញ្ចកៈ ដែលខ្លួនធ្លាប់នៅអាស្រ័យក្នុងកាលមុនផង ដឹងច្បាស់ឋានសួគ៌ និង អបាយភូមិផង មួយទៀតបានសម្រេចធម៌ជាគ្រឿងអស់ជាតិ ជាអ្នកប្រាជ្ញ ស្រេចកិច្ចហើយព្រោះដឹងច្បាស់ តថាគត ហៅបុគ្គលដែលជាអ្នកប្រព្រឹត្តព្រហ្មចរិយធម៌ ចប់សព្វគ្រប់ហើយនោះ ថា ជាព្រាហ្មណ៍ ។*

ចប់ព្រាហ្មណវគ្គ ទី ២៦

ចប់ភាគ ទី ៨

**ចប់ គាថាធម្មបទប្រែ**

ចិរំ តិដ្ឋតុ ពុទ្ធសាសនំ!

ចម្លងសាជាថ្មី ចប់សព្វគ្រប់
ថ្ងៃសុក្រ ៨ រោច ខែផល្គុន ព.ស. ២៥៤៩ ត្រូវនឹងថ្ងៃ ទី១ ខែមេសា ២០០៥
វេលាយប់ ៩:៣០ នាទី

**ភិក្ខុវិនយធរោ មហាយិន-នឿន**

# ឧទានវគ្គនៃគាថាធម្មបទ គឺ

សំដែងអំពីយមកវគ្គ ១ អប្បមាទវគ្គ ១ ចិត្តវគ្គ ១ បុប្ផវគ្គ ១ ពាលវគ្គ ១ បណ្ឌិតវគ្គ ១ អរហន្តវគ្គ ១ សហស្សវគ្គ ១ បាបវគ្គ ១ ទណ្ឌវគ្គ ១ ត្រូវជា ១០ វគ្គ ។

ជរាវគ្គ ១ អត្តវគ្គ ១ លោកវគ្គ ១ ពុទ្ធវគ្គ ១ សុខវគ្គ ១ បិយវគ្គ ១ កោធវគ្គ ១ មលវគ្គ ១ ធម្មដ្ឋវគ្គ ១ មគ្គវគ្គ ១ រួមទាំងវគ្គខាងដើម ត្រូវជា ២០ វគ្គ ។

បកិណ្ណកវគ្គ ១ និរយវគ្គ ១ នាគវគ្គ ១ តណ្ហាវគ្គ ១ ភិក្ខុវគ្គ ១ ព្រាហ្មណវគ្គ ១ បូករួមត្រូវជា ២៦ វគ្គ ដែលព្រះអាទិច្ចពន្ធុ ទ្រង់សំដែងទុកហើយ ។

ក្នុងយមកវគ្គ មាន ២០ គាថា ក្នុងអប្បមាទវគ្គ មាន ១២ គាថា ក្នុងចិត្តវគ្គ មាន ១១ គាថា ក្នុងបុប្ផវគ្គ មាន ១៦ គាថា ក្នុងពាលវគ្គ មាន ១៧ គាថា ក្នុងបណ្ឌិតវគ្គ មាន ១៤ គាថា ក្នុងអរហន្តវគ្គ មាន ១០ គាថា ក្នុងសហស្សវគ្គ មាន ១៦ គាថា ក្នុងបាបវគ្គ មាន ១៣ គាថា ក្នុងទណ្ឌវគ្គ មាន ១៧ គាថា ក្នុងជរាវគ្គ មាន ១១ គាថា ក្នុងអត្តវគ្គមាន ១២ គាថា ក្នុងលោកវគ្គ មាន ១២ គាថា ក្នុងពុទ្ធវគ្គ មាន ១៦ គាថា ក្នុងសុខវគ្គ និង បិយវគ្គ មាន ១២ គាថា ដូចគ្នា ក្នុងកោធវគ្គ មាន ១៤ គាថា ក្នុងមលវគ្គ មាន ២១ គាថា ក្នុងធម្មដ្ឋវគ្គ មាន ១៧ គាថា ក្នុងមគ្គវគ្គ មាន ១៦ គាថា ក្នុងបកិណ្ណកវគ្គ មាន ១៦

ឧទានៃនគាថាធម្មបទ

*គាថា ក្នុងនិរយវគ្គ និង នាគវគ្គ មាន ១៤ គាថា ដូចគ្នា ក្នុងតណ្ហាវគ្គ មាន ២២ គាថា ក្នុងភិក្ខុវគ្គ មាន ២៣ គាថា ក្នុងព្រាហ្មណវគ្គ ដ៏ឧត្តម មាន ៤០ គាថា ។ ៤២៣ គាថា ដទៃទៀត ព្រះអាទិច្ចពន្ធុ ទ្រង់សំដែង ទុកហើយ ក្នុងធម្មបទនិបាត ។*

♣ ♣ ♣

ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា
សោកប្បត្តា ច និស្សោកា ហោន្តុ សព្វេបិ បាណិណោ ។

*សត្វទាំងឡាយទាំងពួង ដែលដល់ហើយនូវសេចក្តីទុក្ខ សូមឲ្យជាសត្វបាត់សេចក្តីទុក្ខទៅ, ដែលដល់ហើយនូវភ័យ សូមឲ្យជាសត្វបាត់ភ័យទៅ, ដែលដល់ហើយនូវសេចក្តីសោក សូមឲ្យជាសត្វបាត់សេចក្តីសោកទៅ ។*

សៀវភៅគាថាធម្មបទប្រែ ដែលព្រះតេជគុណ អស់លោក លោកស្រី ពុទ្ធបរិស័ទ កំពុងតែអាននៅនឹងដៃនេះ គឺជាស្នាព្រះហស្ត ប្រែនិងរៀបរៀង ដោយ ព្រះភិក្ខុវិនយធរោ មហាយិន ធឿន ដែលគណៈកម្មការពុទ្ធិកវប្បធម៌អង្គការមូលនិធិវត្តបញ្ញាធំ បានទទួលយល់ព្រមយកទៅបោះពុម្ពផ្សាយជាធម្មទាន ក្រោមការឧបត្ថម្ភបោះពុម្ពរបស់មូលនិធិពុទ្ធិកសិក្សានៅតៃវ៉ាន់ (The Corporate Body of the Buddha Educational Foundation) ។

ការទទួលយកទៅបោះពុម្ពផ្សាយជាធម្មទាននេះ ដោយអាស្រ័យលើការមើលឃើញនូវកត្តាចាំបាច់មួយចំនួនដូចខាងក្រោម៖

- រក្សាស្នាដៃវប្បធម៌ព្រះពុទ្ធសាសនាឲ្យគង់វង្សស្ថិតស្ថេរ
- តម្រូវការរបស់សិក្ខាកាមអ្នកប្រាថ្នាចង់យល់ដឹងនូវខ្លឹមសារពុទ្ធសាសនា
- ផ្សាយនូវធម្មទាន ធ្វើឲ្យព្រះពុទ្ធសាសនាកាន់តែមានភាពរីកចម្រើនរុង-រឿងក្នុងលោក

MAHA PANNA VIHARA FOUNDATION ORGANIZATION

大般若寺基金會


ក្នុងករណីដែលលោកអ្នកអានបានប្រទះឃើញនូវសៀវភៅនេះមានដាក់លក់នៅកន្លែងណា ឬបានឃើញនូវកំហុសឆ្គងណាមួយ ចង់ឲ្យយើងកែតម្រូវ ឬចង់បានសៀវភៅធម៌យកទៅអាន

សូមទាក់ទងមកយើងខ្ញុំតាមអាសយដ្ឋានដូចខាងក្រោម:

វត្តបញ្ញា សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ

លេខទូរស័ព្ទ: (៨៥៥) ១២ ៩៦១ ៤២៩, (៨៥៥) ៨៨៧ ៩៦១ ៤២៩

អ៊ីមែល: maha.panna@gmail.com

គេហទំព័រ: http://www.mahapanna.org

*"Wherever the Buddha's teachings have flourished,*

*either in cities or countrysides,*

*people would gain inconceivable benefits.*

*The land and people would be enveloped in peace.*

*The sun and moon will shine clear and bright.*

*Wind and rain would appear accordingly,*

*and there will be no disasters.*

*Nations would be prosperous*

*and there would be no use for soldiers or weapons.*

*People would abide by morality and accord with laws.*

*They would be courteous and humble,*

*and everyone would be content without injustices.*

*There would be no thefts or violence.*

*The strong would not dominate the weak*

*and everyone would get their fair share."*

~THE BUDDHA SPEAKS OF
THE INFINITE LIFE SUTRA OF
ADORNMENT, PURITY, EQUALITY
AND ENLIGHTENMENT OF
THE MAHAYANA SCHOOL~

With bad advisors forever left behind,
From paths of evil he departs for eternity,
Soon to see the Buddha of Limitless Light
And perfect Samantabhadra's Supreme Vows.

The supreme and endless blessings
of Samantabhadra's deeds,
I now universally transfer.
May every living being, drowning and adrift,
Soon return to the Pure Land of Limitless Light!

**✻ The Vows of Samantabhadra ✻**

I vow that when my life approaches its end,
All obstructions will be swept away;
I will see Amitabha Buddha,
And be born in His Western Pure Land of
Ultimate Bliss and Peace.

When reborn in the Western Pure Land,
I will perfect and completely fulfill
Without exception these Great Vows,
To delight and benefit all beings.

**✻ The Vows of Samantabhadra Avatamsaka Sutra ✻**